## សម្តេច ហ៊ុន សែន
*នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា*

# សារលិខិត

ប្រជាជនកម្ពុជាបានបង្ហាញពីសមត្ថភាពតស៊ូប្តូរផ្តាច់ដ៏ធំធេងរបស់ខ្លួន និងបានធ្វើដំណើរយ៉ាងវែងឆ្ងាយ ក្នុងដំណើរការកសាងសមត្ថភាព និងស្ថាប័នឡើងវិញ បន្ទាប់ពីការរស់រានមានជីវិតជាថ្មីនៅឆ្នាំ ១៩៧៩ ចាកផុតពីផលវិបាកនៃវិនាសកម្មស្ទើរតែទាំងស្រុង ចំពោះស្ថាប័នសង្គម និងសេដ្ឋកិច្ចជាតិ ព្រមទាំងការបំផ្លាញធនធានមនុស្សក្នុងរយៈពេលជិតបួនឆ្នាំនៃរបបប្រល័យពូជសាសន៍ប៉ុលពត ។ រដ្ឋាភិបាលកម្ពុជាទាំងអស់ដែលបានគ្រប់គ្រងប្រទេសចាប់តាំងពីឆ្នាំ ១៩៧៩ មក បានចាត់ចែងដឹកនាំដំណើរការកសាងជាតិបានយ៉ាងល្អប្រសើរ ។ ក្រោយឆ្នាំ ១៩៩៨ រាជរដ្ឋាភិបាលសម្រេច និងធានាបាននូវសន្តិភាពរឹងមាំ ដោយលុបបំបាត់បាននូវជម្លោះផ្ទៃក្នុងដែលធ្លាប់មានកាលពីអតីតកាល ។ ដោយប្រកាន់ខ្ជាប់គោលការណ៍ចម្បងៗនៃអភិបាលកិច្ច និងការអភិវឌ្ឍសុខមាលភាពប្រជាជន ដែលផ្តោតជាសំខាន់លើវឌ្ឍនភាព រាជរដ្ឋាភិបាលធានាបាននូវកំណើនយ៉ាងឆៀវក្លានៅលើគ្រប់វិស័យ ។

នៅពេលប្រទេសមួយចាប់កសាងសង្គមជាតិផ្តើមចេញពីកម្រិតក្រោមសូន្យ ដូចកម្ពុជាបានជួបប្រទះកន្លងមក ដោយត្រូវដោះស្រាយការងារអាទិភាពបន្ទាន់ចំពោះមុខជាច្រើននៅលើគ្រប់ទិដ្ឋភាពនៃសកម្មភាពសង្គមនោះ ការវិនិយោគណាមួយ ឬ ចំណាយលើអ្វីមួយ សុទ្ធតែបានរួមចំណែកដល់កំណើនសេដ្ឋកិច្ច ទោះបីក្នុងរូបភាពណាមួយក៏ដោយ ។

ដោយសម្រេចបានជោគជ័យក្នុងការជម្រុញកំណើនប្រកបដោយស្ថិរភាព ក្នុងរយៈពេលជាច្រើនឆ្នាំជាប់ៗគ្នា កម្ពុជាមានការជឿជាក់លើខ្លួនឯង ហើយបានត្រៀមរៀបចំខ្លួនរួចជាស្រេចលើមាគ៌ាដ៏សំខាន់ដើម្បីធ្វើដំណើរឆ្ពោះទៅកាន់អនាគតដ៏ភ្លឺស្វាងរុងរឿង ។ ប្រជាជនកម្ពុជាបានឈានដល់ដំណាក់កាលដ៏សំខាន់មួយដើម្បីសម្លឹងមើលទៅអនាគតរបស់ខ្លួនប្រកបដោយសុទិដ្ឋិនិយម និងសេចក្តីសង្ឃឹម ។ ជម្រើសទាំងឡាយដែលយើងបានអនុវត្ត និងជំហានទាំងឡាយ ដែលយើងបានធ្វើដំណើរមកទល់ពេលនេះ នឹងបង្ហាញឱ្យឃើញនូវការឆក់យកនូវកាលានុវត្តភាព និងការរួមចំណែកជាវិជ្ជមានមួយរបស់យើងទាំងអស់គ្នា សម្រាប់ការអភិវឌ្ឍនៅក្នុងទសវត្សរ៍ខាងមុខ ។ ឥឡូវនេះ គឺជាពេលវេលាមួយដែលយើងត្រូវចាប់ផ្តើមធ្វើការជ្រើសរើស និងចាប់យកជំហានដំបូងទាំងឡាយ ដោយមានការផ្តោតការយកចិត្តទុកដាក់ច្បាស់លាស់ និងមានការជឿជាក់លើខ្លួនឯង ព្រមទាំងមានឆន្ទៈយ៉ាងមោះមុត ។

កម្រិតនៃភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ ១៩៩៣ ដែលត្រូវបានធ្វើអង្កេតជាហូរហែកន្លងមក ។ ការធ្លាក់ចុះនៃអត្រាភាពក្រីក្របានកើតឡើង ជាពិសេសដោយសារកំណើន

គឺជាពេលវេលាមួយដ៏សមស្រប ដែលធនធានទាំងឡាយនឹងត្រូវបានយកមកប្រើប្រាស់ចំទិសដៅ និង ប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ប្រយោជន៍ជាអតិបរមាចំពោះប្រជាជនទន់ខ្សោយ និង ងាយរងគ្រោះ ដើម្បីជួយលើកស្ទួយពួកគេ ឱ្យបានចូលរួមក្នុងចរន្តគោលនៃការអភិវឌ្ឍ ។

ដោយពង្រឹង និង ស្ថាបនា លើមូលដ្ឋាននៃសមិទ្ធផលទាំងឡាយ ដែលសម្រេចបានពីពេលមុនៗ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ ២០១៥ ដែលផ្តោតលើការអភិវឌ្ឍមនុស្សជាតិ តាមរយៈ ***«យុទ្ធសាស្ត្រចតុកោណ»*** បន្តពី ***«យុទ្ធសាស្ត្រត្រីកោណ»*** របស់រាជរដ្ឋាភិបាល សម្រាប់គោលដៅរួម ដែលមានការរៀបចំគិតគូរច្បាស់លាស់ ក៏ដូចជាសម្រាប់ការវិនិយោគ និង កំណើនចំពោះបណ្តាវិស័យអាទិភាព ។ កំណើនសេដ្ឋកិច្ច និង សង្គម ត្រូវមានលក្ខណៈសមធម៌ និង ជាកាលានុវត្តភាព និងជាផ្លែផ្កា ដែលទាំងអស់គ្នាអាចប្រើប្រាស់ និងទទួលបានទាំងតាមភូមិសាស្ត្រនីមួយៗ ទាំងសម្រាប់អ្នកមាន និង អ្នកក្រ ។ យើងត្រូវប្រើប្រាស់ធនធានដ៏តិចតួចស្តួចស្តើង ដើម្បីផលប្រយោជន៍ជាអតិបរមារបស់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសសម្រាប់អ្នកក្រីក្រ ហើយមិនត្រូវទុកឱ្យការវិនិយោគក្នុងវិស័យសាធារណៈជាជម្រើស ឬ ការសម្រេចចិត្តរបស់អ្នកក្រៅផ្សេងឡើយ ។

រាជរដ្ឋាភិបាលទទួលស្គាល់ថា វឌ្ឍនភាពដែលយើងសម្រេចបានយ៉ាងធំធេងចាប់តាំងពីឆ្នាំ ១៩៩៣ មក គឺដោយសារមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេសដ៏ច្រើនសន្ធឹកពីសំណាក់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសរបស់យើង ។ យើងសូមសម្តែងនូវការដឹងគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់នោះ ។ ទោះជាយ៉ាងនេះក្តី ច្បាស់ណាស់ថា ធនធានក្រៅប្រទេសយ៉ាងច្រើនកាលពីអតីតកាល ត្រូវបានប្រើប្រាស់ផ្ទាល់ដោយអ្នកផ្តល់ជំនួយទាំងនោះ ក្នុងកម្មវិធី និង សកម្មភាពទាំងឡាយ ដែលជាជម្រើសរបស់ពួកគេ ក្រៅពីរង្វង់នៃការទទួលខុសត្រូវ ឬ ការពិនិត្យពិច័យរបស់រាជរដ្ឋាភិបាល ។ ជំនួយមួយចំណែកធំត្រូវបានចាយលើផ្នែកអរូបិយនៃការអភិវឌ្ឍ ដូចជាជំនួយបច្ចេកទេសជាដើម ។ ទោះជាដូច្នេះក្តី នៅពេលអនាគត រាជរដ្ឋាភិបាលនឹងទទួលបន្ទុកពេញលេញនៅក្នុងដំណើរការទាំងមូល ហើយធានាថាធនធានទាំងអស់របស់រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស នឹងត្រូវតម្រង់ទិសច្បាស់លាស់ចំពោះអាទិភាព និង វិស័យទាំងឡាយដែលជ្រើសរើសដោយរាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តបន្ថែមទៀត ដើម្បីធានាថា សមាមាត្រដ៏ខ្ពស់បំផុតនៃមូលនិធិពីក្រៅប្រទេស នឹងត្រូវបានប្រើប្រាស់ជា ***«ហិរញ្ញប្បទាន»*** សម្រាប់ការអភិវឌ្ឍ ។

***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*** (ផយអជ) ដែលត្រូវបានរៀបចំឡើងដោយឈរលើ ***យុទ្ធសាស្ត្រចតុកោណ*** របស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយការគិតគូរគ្រប់ជ្រុងជ្រោយលើគ្រប់វិស័យ តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់ដៃគូទាំងអស់ និង ជាលទ្ធផលនៃការច្របាច់បញ្ចូលគ្នានូវឯកសារនានា មានជាអាទិ៍ ***គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គោលនយោបាយជាតិប្រជាជន*** ។ល។ គឺជាក្របខ័ណ្ឌ និង ជាត្រីវិស័យតែមួយគត់សម្រាប់ការជម្រុញ ***កំណើន*** ការបង្កើត ***ការងារ*** ការធានា ***សមធម៌*** និង

***ប្រសិទ្ធភាព*** ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងការអភិវឌ្ឍប្រកបដោយសមធម៌ ដោយមានការតម្រង់ទិសច្បាស់លាស់សម្រាប់ពេលអនាគត និងមានចរិតគាំទ្រប្រជាជនក្រីក្រ និងការ-អភិវឌ្ឍជនបទ ។ ***ផយអជ*** នេះ នឹងនាំប្រទេសជាតិឆ្ពោះទៅកាន់មាគ៌ាមួយរីកចម្រើនពិតប្រាកដ និងប្រកបដោយចីរភាព តាមរយៈការកំណត់ទស្សនវិស័យ គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាព សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ ។ ***ផយអជ*** ធ្វើការវិភាជន៍ធនធានប្រកបដោយគុណភាពប្រាកដនិយម និងអាចអនុវត្តបានសម្រាប់គ្រប់វិស័យឈរលើមូលដ្ឋានអាទិភាពកម្ម ។ ដូច្នេះការអនុវត្ត ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*** នឹងទទួលបាននូវការតាមដានត្រួតពិនិត្យ ដោយយកចិត្តទុកដាក់ និងជាប្រចាំ ដើម្បីធ្វើការកែតម្រូវប្រចាំឆ្នាំ ។

រាជរដ្ឋាភិបាលទទួលស្គាល់ពីភាពចាំបាច់ចម្បងៗ ក្នុងការបង្កើត និងពង្រឹងស្ថាប័នអភិបាលកិច្ច ដំណើរការ និងនីតិវិធីឱ្យបានប្រសើរជាងមុន តាមរយៈកំណែទម្រង់ដែលមានផែនការច្បាស់លាស់ សំដៅធានាបានការអភិវឌ្ឍប្រកបដោយចីរភាព ។ យ៉ាងណាមិញ ***«អង្គរវត្ត»*** មិនមែនកសាងតែក្នុងរយៈពេលមួយថ្ងៃហើយនោះទេ ចំណែកឯស្ថាប័នរបស់ប្រទេសកម្ពុជាទាំងមូល ដែលត្រូវបានបំផ្លិចបំផ្លាញដល់ឫសគល់ក៏មិនអាចកសាងឡើងវិញ តែក្នុងរយៈពេលមួយយប់នោះបានដែរ ក្នុងនោះរួមមាន ការកសាងស្ថាប័នសេដ្ឋកិច្ច សង្គមកិច្ច រដ្ឋាភិបាល ហិរញ្ញវត្ថុ និងស្ថាប័នផ្សេងៗទៀត ។ ប៉ុន្តែជាជំហានៗ វឌ្ឍនភាពបានកើតមានជាបន្តបន្ទាប់ ហើយបានចាប់ផ្តើមក្នុងជំហានដ៏ឆាប់រហ័ស ដែលមិនធ្លាប់មាននៅកន្លែងផ្សេងទៀតនៃពិភពលោក ។ ការអនុវត្តជាក់ស្តែងនូវកំណែទម្រង់នានា និងការអនុវត្តន៍ច្បាប់ និងនីតិវិធីទាំងឡាយ នឹងអាចបំពេញប្រព័ន្ធទាំងមូលក្នុងរយៈពេលមួយជាក់លាក់ ដោយរបៀបរបបការងារល្អប្រសើរ ហើយអាចផ្សារភ្ជាប់ និងពង្រឹងស្ថាប័ននានា ដែលមានសារសំខាន់សម្រាប់លទ្ធិប្រជាធិបតេយ្យ ដូចដែលមាននៅទី-កន្លែងផ្សេងទៀតក្នុងពិភពលោក បើទោះបីជាត្រូវការប្រើពេលវេលាយូរក៏ដោយ ។

***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*** គឺជាផែនការមួយសម្រាប់វឌ្ឍនភាពបន្តទៀត លើការកសាងកម្ពុជាថ្មីមួយ ហើយជាឯកសារគ្រប់ជ្រុងជ្រោយតែមួយគត់របស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្តរយៈពេល ៥ ឆ្នាំខាងមុខ ។

ខ្ញុំសូមអំពាវនាវដល់ក្រសួង- ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ សូមប្រកាន់ខ្ជាប់យ៉ាងហ្មត់ចត់ចំពោះអាទិភាពទាំងឡាយ ដែលបានលើកឡើងនៅក្នុង ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*** នេះ ។

*ភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៥*

**ហ៊ុន សែន**

# ផែនទីប្រទេសកម្ពុជា



# គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ



# មាតិកា


**សាររបស់សម្តេចនាយករដ្ឋមន្ត្រី** ........ i

**ផែនទីប្រទេសកម្ពុជា** ........ iv

**គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ** ........ v

**មាតិកា** ........ vi

**សេចក្តីសង្ខេប** ........ viii

**កម្ពុជា : សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ** ........ xxii

**ជំពូក ១ : សេចក្តីផ្តើម** ........ ១

ការខិតខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការងារអភិវឌ្ឍន៍ដែលមានផែនការ ........ ២

ដំណើរការរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ........ ៤

បញ្ហាអាទិភាពនិងខ្លឹមសាររបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ........ ៤

**ជំពូក ២ : វឌ្ឍនភាពដែលមានកន្លងមក និងស្ថានភាពបច្ចុប្បន្ន** ........ ៩

អភិបាលកិច្ចល្អ ........ ១៤

បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ ........ ១៩

ការលើកស្ទួយវិស័យកសិកម្ម ........ ២២

ការស្តារនិងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ....... ........ ៣០

ការអភិវឌ្ឍវិស័យឯកជននិងការបង្កើតការងារ ....... ........ ៣២

ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស .... ........ ៣៦

សេចក្តីសន្និដ្ឋាន ........ ........ ៤២

**ជំពូក ៣ : គោលដៅនិងចំណុចដៅអាទិភាព** ........ ៤៣

**ជំពូក ៤ : យុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗ** ........ ៥៣

អភិបាលកិច្ចល្អ ........ ៥៧

បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ ........ ៦៣

ការលើកស្ទួយវិស័យកសិកម្ម ........ ៧២

ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ....... ........ ៨១

ការអភិវឌ្ឍវិស័យឯកជននិងការបង្កើតការងារ ....... ........ ៨៧

ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស . ... ........ ៩៥

**ជំពូក ៥ : ចំណាយ ធនធាននិងការរៀបចំកម្មវិធី** ........ ១០៥

ធនធានដែលអាចរកបានសម្រាប់វិស័យសាធារណៈ ........ ១១១

កម្មវិធី: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ និងថវិកាប្រចាំឆ្នាំ ...................... ១១៥
**ជំពូក ៦ : ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ** ........................................ ១២០
**ជំពូក ៧ : សេចក្តីសន្និដ្ឋាន** ........................................................ ១២៥

## បញ្ជីតារាង

តារាង ២.១ : កំណើនម៉ាក្រូសេដ្ឋកិច្ច ........................................................ ២១
តារាង ២.២ : *ផសស* : កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ .......................................... ២៣
តារាង ២.៣ : *ផសស* : ឧស្សាហកម្មនិងសេវាកម្ម .................................................. ៣៣
តារាង ២.៤ : សូចនាករអប់រំ .................................................................. ៣៧
តារាង ២.៥ : សូចនាករសុខាភិបាល .......................................................... ៣៩
តារាង ២.៦ : សូចនាករប្រជាជនសំខាន់ៗ ...................................................... ៤១
តារាង ៣.១ : សមិទ្ធផលសំខាន់ៗនិងការសម្រេចមិនបានតាមចំណុចដៅរបស់ គអសក ...................... ៤៥
តារាង ៣.២ : គោលដៅជាតិនិងសូចនាករសំខាន់ៗរបស់ ផយអជ ...................................... ៥០
តារាង ៤.១ : ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ .............................................. ៧០
តារាង ៤.២ : គោលដៅក្នុងវិស័យកសិកម្មសម្រាប់ឆ្នាំ២០១០ ........................................ ៧២
តារាង ៤.៣ : ចំណុចដៅឆ្នាំ២០១០ សម្រាប់ការអភិវឌ្ឍជនបទ ...................................... ៨០
តារាង ៤.៤ : វិស័យអប់រំ: គោលដៅនិងចំណុចដៅសំខាន់ៗ ........................................ ៩៨
តារាង ៤.៥ : វិស័យសុខាភិបាល: គោលដៅនិងចំណុចដៅអាទិភាព .................................. ១០០
តារាង ៥.១ : កម្រិតវិនិយោគដែលចាំបាច់ ២០០៦-២០១០ .......................................... ១០៦
តារាង ៥.២ : វិភាជន៍ ផយអជ តាមវិស័យ ២០០៦-២០១០ .......................................... ១១៨

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១.១ : សូចនាករនិងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ...................... ១២៧
ឧបសម្ព័ន្ធ ១.២ : ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា .................................. ១៣៤
ឧបសម្ព័ន្ធ ២.១ : កម្ពុជា : សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច .................................... ១៤៥
ឧបសម្ព័ន្ធ ២.២ : ប៉ាន់ស្មានពីការវិនិយោគ ឆ្នាំ២០០៦-២០១០ ...................................... ១៤៧
ឧបសម្ព័ន្ធ ២.៣ : ចំណាយថវិកា ការបែងចែកតាមវិស័យនិងអាទិភាពក្រសួង ............................ ១៤៩
ឧបសម្ព័ន្ធ ៣ : វឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រនិងបញ្ហាប្រឈមក្នុង *ផយអជ* ...................... ១៥០
ឧបសម្ព័ន្ធ ៤ : បញ្ជីឯកសារយោង .............................................................. ១៥៨
ឧបសម្ព័ន្ធ ៥ : ពាក្យអក្សរកាត់ .............................................................. ១៦០
ឧបសម្ព័ន្ធ ៦ : ប្រកាស .................................................................... ១៦១

# សេចក្តីសង្ខេប

## ១. សេចក្តីផ្តើម

**១.១** ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ កម្ពុជាបានធ្វើដំណើរលើកំណាត់ផ្លូវដ៏វែងឆ្ងាយមួយ បន្ទាប់ពីបានឆ្លងកាត់រយៈពេលជិតបួនឆ្នាំដ៏ខ្មៅងងឹត ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ។ ការកសាងប្រទេសចាប់ផ្តើមពីក្រោមលេខសូន្យឈានទៅស្ថានភាពធម្មតា ដែលស្ថាប័ននិងសមត្ថភាពទាំងអស់ ត្រូវបានបំផ្លិចបំផ្លាញ ។ ការអភិវឌ្ឍមានដំណើរអាចកើតចាប់តាំងពីឆ្នាំ១៩៩៣ ជាមួយនឹងការចាប់ផ្តើមបន្តទទួលជំនួយពីក្រៅប្រទេស ដែលជំនួយនេះធ្លាប់ត្រូវបានបដិសេធអស់រយៈពេលជាយូរមកហើយ ។

**១.២** ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី១ (១៩៩៦-២០០០) បានកំណត់គោលដៅសម្រាប់រយៈពេលមធ្យមប្រាំឆ្នាំ[១] ហើយផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ (២០០១-២០០៥) បានកំណត់គោលដៅបន្តសម្រាប់រយៈពេលមធ្យម ៥ឆ្នាំ ទៀត ។ ជាមួយនោះដែរ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលលើកទី១ *"កវស"* (១៩៩៦-១៩៩៨) ត្រូវបានរៀបចំឡើងដោយផ្តោតជាសំខាន់លើការវិនិយោគ និងសំណើគម្រោងក្នុង វិស័យសាធារណៈ ។ ថវិកាប្រចាំឆ្នាំត្រូវមានភាពរលូនជាមួយនឹង *កវស* ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ *"យជកក"* ត្រូវបានអនុម័ត នៅឆ្នាំ២០០២ ។ ផ្អែកលើសេចក្តីប្រកាសសហស្សវត្សរ៍នៃកិច្ចប្រជុំកំពូលសហប្រជាជាតិ ឆ្នាំ២០០០ កម្ពុជាបានរៀបចំគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា *"គអសក"*[២] ដែលបានអនុម័តនៅឆ្នាំ២០០៣ តាមរយៈដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ។ ការសម្រេចចិត្តលើកដំបូងបំផុតរបស់ រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៣ ឆ្នាំ២០០៤ បានអនុម័តនូវយុទ្ធសាស្ត្រចតុកោណដ៏ទូលំទូលាយមួយ[៣] សម្រាប់ការដោះស្រាយបញ្ហាអភិបាលកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និង កិច្ចខិតខំប្រឹងប្រែងជាច្រើនទៀត ។

**១.៣** រាជរដ្ឋាភិបាលបានសម្រេចចិត្តថា ពេលនេះត្រូវផ្តោតការយកចិត្តទុកដាក់លើអាទិភាព និងគោលដៅជាយុទ្ធសាស្ត្រដែលត្រូវសម្រេចឱ្យបានក្នុងរយៈពេល៥ឆ្នាំខាងមុខ និងបន្តអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពជាគន្លឹះនានា ដើម្បីសម្រេចបានគោលដៅ លទ្ធផលជាអតិបរិមា តាមរយៈការប្រើប្រាស់ធនធានតិចតួចក្នុងលក្ខណៈប្រកបដោយវិចារណញាណ និងសមស្រប ។ ដូច្នេះ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ "ផយអជ" (២០០៦-*

---

[១] ផ្អែកលើចក្ខុវិស័យរយៈពេលវែង គម្រោងនៅក្នុងកម្មវិធីជាតិសម្រាប់ស្តារនិងអភិវឌ្ឍន៍កម្ពុជា ដែលបានរៀបចំនៅឆ្នាំ ១៩៩៤

[២] ឧបសម្ព័ន្ធ ១.១

[៣] សូមមើលគំនូសបំព្រួញនៃយុទ្ធសាស្ត្រចតុកោណនៅផ្នែកខាងដើមនៃឯកសារ

*២០១០) គឺជាឯកសារតែមួយគត់ ដែលមានដាក់បញ្ចូលនូវរាល់បណ្តាគោលដៅ និងយុទ្ធសាស្ត្រអាទិភាពនានារបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រ និងឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច សម្រាប់ផលប្រយោជន៍របស់ប្រជាជនទាំងមូល* ។ ឯកសារនេះក៏ជាការដាក់បញ្ចូលគ្នា និងកំណត់អាទិភាព នៃគោលដៅយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងជាការបន្សុីគ្នារាល់បណ្តាយុទ្ធសាស្ត្រតាមវិស័យ និងវដ្តនៃការរៀបចំផែនការសម្រាប់ចក្ខុវិស័យយូរអង្វែង ក៏ដូចជាការណែនាំដល់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់[១] ដើម្បីបន្សុី និងធ្វើសុខដុមនីយកម្ម កិច្ចខិតខំប្រឹងប្រែងនានា សំដៅធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពជំនួយ និងការផ្ទេរ "ធនធានសុទ្ធ" ខ្ពស់ជាងមុន ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាប្រតិបត្តិការនៃយុទ្ធសាស្ត្រចតុកោណ សំដៅឈានទៅសម្រេចបានគោលដៅនានាដែលបានកំណត់ ។

**១.៤** ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានរៀបចំឡើង តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើ " *លទ្ធផល* " ។ គោលដៅ ចំណុចដៅ និងសកម្មភាពជាយុទ្ធសាស្ត្រនានាដែលបានកំណត់ នឹងត្រូវលម្អិតថែមទៀតតាមរយៈផែនការតាមវិស័យដែលកំពុងដំណើរការ ឬត្រូវអនុម័តក្នុងពេលឆាប់ៗខាងមុខ និងតាមរយៈគោលដៅ និងផែនការថ្នាក់ក្រោមជាតិ ។ ការងារបែបនេះ ជាពិសេសនៅថ្នាក់ក្រោមជាតិ នឹងជួយផងដែរ ដើម្បីផ្សព្វផ្សាយ *ផយអជ* ឱ្យកាន់តែប្រសើរ ។

**១.៥** *ផយអជ* គឺជាឯកសាររស់ដែលអាចធ្វើការកែតម្រូវ និងដែលអាចកែសម្រួលប្រចាំឆ្នាំ ដោយផ្អែកតាមទិន្នន័យដែលទទួលបានពីការសិក្សាថ្មីៗ និងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃប្រចាំឆ្នាំដែលបានលើកឡើង ។

## ២. វឌ្ឍនភាពដែលមានកន្លងមក និងស្ថានភាពបច្ចុប្បន្ន[២]

**២.១** វឌ្ឍនភាពបានកើតឡើងពិតប្រាកដនៅក្នុងគ្រប់វិស័យ ហើយការផ្លាស់ប្តូរជាវិជ្ជមាន និងប្រកបដោយភាពជឿនលឿន គឺជាភស្តុតាងដ៏ច្បាស់ ដែលកើតមានជាងមួយទសវត្សរ៍កន្លងមក ។ ផែនការនេះ បង្ហាញនូវវឌ្ឍនភាពសំខាន់ៗ ដូចខាងក្រោម :

- ការស្តារឡើងវិញ និងការធ្វើឱ្យប្រសើរឡើងនូវសន្តិភាព និងសន្តិសុខផ្ទៃក្នុង ។
- លទ្ធិប្រជាធិបតេយ្យដែលបានចាក់ឫស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

[១] ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស គឺជាស្ថាប័នអភិវឌ្ឍន៍ពហុភាគី ស្ថាប័នហិរញ្ញវត្ថុ ស្ថាប័នរដ្ឋាភិបាលទ្វេភាគី ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល

[២] តារាង "កម្ពុជា : សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ" នៅទំព័រ (xxii) ដល់ (xxvi) មានគូសបញ្ជាក់នូវការសម្រេចបានកន្លងមក និងចំណុចដៅដែល ត្រូវសម្រេចបាន ជាពិសេស តារាងមួយចំនួនក្នុងជំពូកដទៃទៀតក៏មានបញ្ជាក់លម្អិត ។

- ភាពជឿនលឿនក្នុងការគោរពច្បាប់ និងការកែលម្អក្នុងការថែរក្សានូវបទបញ្ញត្តិច្បាប់ និងសណ្តាប់ធ្នាប់សង្គម ។
- ការធ្វើឱ្យប្រសើរឡើងយ៉ាងច្រើននៅក្នុងសេរីភាពសម្រាប់បុគ្គលម្នាក់ៗ និងសេរីភាពក្នុងការបញ្ចេញមតិ យោបល់ ។
- កំណើនម៉ាក្រូសេដ្ឋកិច្ចប្រកបដោយស្ថេរភាព និងគួរឱ្យកត់សំគាល់ ។
- ការធ្វើឱ្យប្រសើរឡើងជាងមុន និងជាប្រចាំ នូវការត្រួតពិនិត្យ និងគ្រប់គ្រងសារពើពន្ធ ។
- ជំរុញការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក ។
- ការកាត់បន្ថយបានគួរឱ្យកត់សម្គាល់នូវកម្រិតនៃភាពក្រីក្រ1 ។
- ការធ្វើឱ្យប្រសើរឡើងដែលអាចវាស់វែងបានជាច្រើននៅក្នុងសូចនាករវិស័យសង្គមកិច្ច ដូចជា : ការពង្រីកការអប់រំនៅបឋមសិក្សា ការកាត់បន្ថយអត្រាមរណភាពទារកនិងកុមារអាយុក្រោម៥ឆ្នាំ ការកាត់បន្ថយបានយ៉ាងច្រើននូវជម្ងឺឆ្លង ជាពិសេស ហ៊ីវ/អេដស៍ ការធ្វើឱ្យប្រសើរឡើងនូវការទទួលបានទឹកស្អាតនៅតំបន់ទីប្រជុំជន និងការទទួលបានសេវាអនាម័យនៅតំបន់ជនបទ ការកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងវិស័យជាច្រើន ។

**២.២** វិឌ្ឍនភាពដែលមានកន្លងមក ក៏បានគ្របដណ្តប់លើទិដ្ឋភាពសំខាន់ៗមួយចំនួន ដែលត្រូវដោះស្រាយតាមរយៈ *ផយអជ* ផងដែរ :

- នៃភាពក្រីក្រមានកម្រិត ៣៤,៧ភាគរយ នៃប្រជាជនទូទាំងប្រទេស ហើយនៅតំបន់ជនបទមានកម្រិតខ្ពស់ជាង ។
- កំណើនសេដ្ឋកិច្ចនិងវិឌ្ឍនភាពទាំងអស់ បានកើតមានឡើង មិនមែនចាំបាច់ដោយសារមានការប្រមូលផ្តុំការយកចិត្តទុកដាក់ខ្ពស់ (ទោះបីមួយចំណែកធំនៃវិឌ្ឍនភាពទាំងនោះ ត្រូវបានបង្កើតឡើង ដោយលក្ខខណ្ឌអំណោយផល ដែលបានបង្កឡើងដោយគោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រកបដោយលក្ខណៈវិជ្ជមាននិងជឿនលឿន ក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ចនិងសង្គមកិច្ច ក៏ដោយ) ប៉ុន្តែ ដោយសារការវិនិយោគឬចំណាយទាំងឡាយណា (ទោះបីជាក្នុងទ្រង់ទ្រាយតូចតាចឬមិនផ្តោតចំអាទិភាព) ដែលបានរួមចំណែកជំរុញឱ្យមានកំណើន នៅពេលដែលប្រទេសជាតិបានចាប់ផ្តើមពីចំណុចក្រោមសូន្យ ។ ដូច្នេះ ឥឡូវនេះ គឺជាពេលដែលត្រូវតម្រង់ទិសកំណើនឱ្យបានល្អប្រសើរជាងមុន ។

[1] សូមមើលជំពូក ២ ប្រអប់ ២.១

- កំណើនសេដ្ឋកិច្ច មិនបានកើតមានឡើងស្មើគ្នានៅតាមវិស័យនីមួយៗនោះទេ ។ ដូច្នេះ ស្ថានភាពនេះបានធ្វើឱ្យកំណើនសេដ្ឋកិច្ចងាយរងគ្រោះជាទីបំផុត ជាមួយនឹងវិបត្តិសេដ្ឋកិច្ចក្រៅប្រទេស ។ កំណើនបែបនេះ ត្រូវតែបានពង្រីកនិងពង្រឹង ដើម្បីឱ្យមានចីរភាពសម្រាប់រយៈពេលវែង ។
- កំណើនភាគច្រើនបានកើតឡើងនៅតំបន់ទីប្រជុំជន ហើយស្ថានភាពនេះចាំបាច់ត្រូវមានការប្រមូលផ្តុំការយកចិត្តទុកដាក់ឱ្យបានច្រើនទៅលើតំបន់ជនបទនាពេលអនាគត ។
- កំណែទម្រង់អភិបាលកិច្ចពុំមានវឌ្ឍនភាពទៅតាមជំហានដែលចង់បានទេ ។

**២.៣** មូលហេតុចម្បងៗដែលបច្ចុប្បន្ននេះកំពុងត្រូវបានជំនះ ហើយបានធ្វើឱ្យប្រជាជនភាគច្រើនស្ថិតនៅក្រោមកម្រិតនៃការប្រើប្រាស់ទំនិញ និងសេវាកម្មនានាដែលចាំបាច់ជាអប្បបរមាសម្រាប់ធ្វើឱ្យពួកគាត់រស់នៅពីលើខ្សែបន្ទាត់ភាពក្រីក្រ ។ ទោះបីជាយ៉ាងនេះក្តី មានការធ្លាក់យ៉ាងលឿននៃកម្រិតភាពក្រីក្រ (ធ្លាក់ចុះចំនួន១១ភាគរយ ពី៣៩ ភាគរយ មក ២៨ ភាគរយ) ក្នុង៥៦ភាគរយនៃទូទាំងប្រទេស ដែលគ្របដណ្តប់ដោយអង្កេតទាំងនៅឆ្នាំ១៩៩៣ និងឆ្នាំ២០០៤ ។ នៅឆ្នាំ២០០៤ អ្នកក្រចំនួន ៩០ ភាគរយ រស់នៅតំបន់ជនបទ ហើយក្នុងចំណោមអ្នកក្រ ភាគច្រើនរស់នៅជិតខ្សែបន្ទាត់នៃភាពក្រីក្រ ។ ការយកចិត្តទុកដាក់ឱ្យបានច្រើន និងចំគោលដៅទៅដល់តំបន់ជនបទ នឹងមានឥទ្ធិពលភ្លាមៗ និងជាក់លាក់ក្នុងការកាត់បន្ថយភាពក្រីក្រ ។

**២.៤** តាមរយៈ *ផែនការសកម្មភាពអភិបាលកិច្ចទី១* ដែលបានអនុម័តនៅឆ្នាំ២០០១ វិធានការកំណែទម្រង់សំខាន់ៗជាច្រើន ត្រូវបានចាប់ផ្តើមអនុវត្តនៅក្នុងរដ្ឋបាលសាធារណៈ ក៏ដូចជានៅក្នុងវិស័យច្បាប់និងយុត្តិធម៌ ។ *ផែនការជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈ* ដែលជាកម្មវិធីរយៈពេលយូរឆ្នាំ កំពុងតែដំណើរការ ។

**២.៥** កម្ពុជាបានបង្ហាញពីសក្ខីភាព នៃភាពរឹងមាំនិងមានកំណើន ម៉ាក្រូសេដ្ឋកិច្ចខ្ពស់នៅក្នុងរយៈពេល ១២ឆ្នាំកន្លងមក លើកលែងតែរយៈពេលពីរ-បីឆ្នាំប៉ុណ្ណោះ។ *ផសស* គិតតាមថ្លៃថេរបានកើនជាមធ្យម ៧ភាគរយក្នុងមួយឆ្នាំ ដែលនាំមុខដោយកំណើនឆាប់រហ័សនៅក្នុងឧស្សាហកម្មកាត់ដេរ ទេសចរណ៍ និងសំណង់ ។ *ផសស* សម្រាប់ប្រជាជនម្នាក់ៗដែលបានចុះបញ្ជី ក៏មានការកើនឡើងប្រហាក់ប្រហែល៤.៧ភាគរយ ទោះបីមានការកើនឡើងនៃចំនួនប្រជាជនសរុបក៏ដោយ។ អតិផរណាត្រូវបានរក្សាឱ្យនៅក្នុងកម្រិតក្រោម៥ភាគរយ ។ អត្រាប្តូរប្រាក់រវាងប្រាក់រៀលជាមួយប្រាក់ដុល្លារអាមេរិកមានស្ថេរភាព និងមានការថយចុះជាលំដាប់។ ចំណូលនិងចំណាយថវិកាជាតិ ទាំងជាក់ស្តែង និងគិតជាភាគរយនៃ *ផសស* មានភាពប្រសើរឡើងក្នុងជំហានដ៏រឹងមាំ ។ នៅក្នុងវិស័យហិរញ្ញវត្ថុ កំណែទម្រង់កំពុងតែមានការរីកចម្រើន និងវិធានការផ្សេងៗត្រូវបានដាក់ឱ្យអនុវត្តដើម្បីធ្វើនិយតកម្មនិងជំរុញវិស័យ ដើម្បីធ្វើឱ្យមានកំណើនតាមលំដាប់លំដោយ និងប្រាកដនិយម ។

**២.៦** កសិកម្ម គឺជាប្រភពបង្កើនចំណូលយ៉ាងសំខាន់ ជាពិសេសសម្រាប់ប្រជាជនក្រីក្រនៅតំបន់ជនបទ ។ ផលិតកម្មសរុបនៃកសិផល ជាពិសេសស្រូវបានកើនឡើងប្រកបដោយស្ថេរភាព ក្នុងផលលើសដែលអាចនាំចេញក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ។ ទិន្នផលស្រូវជាមធ្យមក្នុងមួយហិកតាមានការកើនឡើង ប៉ុន្តែបើប្រៀបធៀបជាមួយបណ្តាប្រទេសជិតខាងនៅមានកម្រិតទាបនៅឡើយ ហើយវិធានការមួយចំនួនដើម្បីបង្កើន និងធ្វើពិពិធកម្មផលិតកម្មកសិកម្មកំពុងដំណើរការ ។ ក្នុងវិស័យព្រៃឈើ ព្រៃសម្បទានចាស់ៗជាច្រើនត្រូវបានលុបចោលចំពោះព្រៃសម្បទានដែលមិនបានអនុវត្ត ហើយព្រៃសម្បទានថ្មីៗ ត្រូវបានផ្តល់ជាមួយនឹងលក្ខខណ្ឌតឹងរ៉ឹង និងគោរពទៅតាមផែនការ ដោយផ្អែកតាមការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ។

**២.៧** ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលបានខូចខាតជាច្រើន ជាពិសេស ផ្លូវថ្នល់ ត្រូវបាននិងកំពុងដំណើរការល្អ ។ បច្ចុប្បន្ន បរិមាណទំនិញដែលហូរចូលតាមកំពង់ផែក្រុងព្រះសីហនុ និងក្រុងភ្នំពេញកំពុងមានការកើនឡើង ។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានធ្វើការកែលម្អជាច្រើន តាមរយៈការចូលរួមពីផ្នែកឯកជនក្រោមរូបភាព *សាងសង់-ដំណើរការ-ផ្ទេរ* ។ ការផ្គត់ផ្គង់អគ្គិសនី ជាពិសេសនៅភ្នំពេញនិងបណ្តាទីប្រជុំជនមួយចំនួនបានធ្វើការកែលម្អ ដោយបង្កើនសមត្ថភាពផលិត និងបង្កើនប្រព័ន្ធបញ្ជូន និងចែកចាយអគ្គិសនី ។ ប្រភពថាមពលថ្មីៗកំពុងត្រូវបានរុករក ។ លទ្ធភាពនៃការរុករកធនធានប្រេងនិងឧស្ម័ននៅក្នុងដែនសមុទ្រមានការរីកចម្រើនច្រើនដែលជាក្តីសង្ឃឹមសម្រាប់ពេលអនាគត ។ ការប្រើប្រាស់ទូរគមនាគមន៍និងអ៊ិនធឺណែតក៏ត្រូវបានពង្រីកផងដែរ ថ្វីបើតម្លៃនៃការប្រើប្រាស់ដំបូងខ្ពស់ក៏ដោយ តម្លៃនៃការប្រើប្រាស់ត្រូវតែធ្លាក់ចុះលឿនដើម្បីលើកកម្ពស់ការប្រកួតប្រជែងក្នុងធុរៈកិច្ចនិងលទ្ធភាពទទួលយកបានរបស់ប្រជាជនភាគច្រើន ។

**២.៨** ការអភិវឌ្ឍជនបទមានការវិវត្តយ៉ាងឆាប់រហ័ស ដោយផ្លូវជាច្រើនបានធ្វើការជួសជុលនិងស្តារឡើងវិញ ទីផ្សារត្រូវបានធ្វើការកែលម្អនិងការបណ្តុះបណ្តាលមន្ត្រីរាជការបានចំនួនយ៉ាងច្រើន ។ ឥណទានជនបទត្រូវបានបង្កើន ប៉ុន្តែអត្រាការប្រាក់នៅតែមានកម្រិតខ្ពស់នៅឡើយ ហើយតម្រូវការនៅមានកម្រិតខ្ពស់ច្រើនជាងការផ្គត់ផ្គង់ ។

**២.៩** យន្តការពិសេសត្រូវបានបង្កើតឡើងដើម្បីជួយដល់វិស័យឯកជន ។ ការរួមចំណែករបស់វិស័យឧស្សាហកម្មនៅក្នុង *ផសស* បានកើនឡើងយ៉ាងឆាប់រហ័ស ដោយសារការកើនឡើងនៃវិស័យកាត់ដេរ និងសំណង់ ។ ប៉ុន្តែបញ្ហានេះចាំបាច់ត្រូវធ្វើពិពិធកម្ម ដើម្បីឱ្យមានចីរភាពសម្រាប់រយៈពេលវែង ។ វិស័យទេសចរណ៍ បានកើនឡើងយ៉ាងឆាប់រហ័ស និងមានស្ថេរភាព ។ វិធានការនានាត្រូវបានធ្វើការអនុវត្ត ដើម្បីជំរុញការអភិវឌ្ឍទៅតាមលំដាប់លំដោយនៃសហគ្រាសធុនតូច និងមធ្យម ដែលមាន ៩០ភាគរយ នៃសហគ្រាសទាំងអស់ ហើយការងារចំនួនពាក់កណ្តាលស្ថិតក្នុងវិស័យឯកជន ។

**២.១០** នៅក្នុងផ្នែកអភិវឌ្ឍន៍មនុស្ស វិស័យអប់រំ គឺជាជោគជ័យមួយ ជាមួយនឹងសន្ទស្សន៍ជាច្រើន ដែលបង្ហាញពីការធ្វើឱ្យប្រសើរឡើងគួរឱ្យកត់សម្គាល់ និងកិច្ចសហប្រតិបត្តិការកម្រិតខ្ពស់ក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ តាម *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* ។ ទោះបីជាយ៉ាងនេះក៏ដោយ ពាក់ព័ន្ធទៅនឹងការកែលម្អគុណភាពនៅគ្រប់កម្រិតត្រូវបន្តអនុវត្ត និងត្រូវធ្វើការដោះស្រាយ ។

**២.១១** វិស័យសុខាភិបាល សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ផងដែរ ។ គ្រប់សន្ទស្សន៍សុខភាពទាំងអស់បានបង្ហាញថា មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែសន្ទស្សន៍ទាំងនេះនៅតែមានកម្រិតទាបនៅឡើយ ។ អត្រាខ្ពស់នៃមរណភាពមាតា គឺជាក្តីព្រួយបារម្ភយ៉ាងខ្លាំងរបស់យើង ។ ប្រវត្តិនៃការទទួលបានជោគជ័យយ៉ាងធំធេងនៅក្នុងវិស័យនេះ គឺការថយចុះយ៉ាងឆាប់រហ័សនៃការរីករាលដាល នៃហ៊ីវ/អេដស៍ បាននាំមកនូវការសន្យាដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហានេះ និងកិច្ចសហប្រតិបត្តិការ ដ៏ល្អប្រសើររបស់រាជរដ្ឋាភិបាល ជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។

**២.១២** ភាពរីកចម្រើនជាបណ្តើរៗត្រូវបានធ្វើដើម្បីធានាសមភាពយេនឌ័រ ការរួមចំណែករបស់ស្ត្រីនៅក្នុងកម្លាំងពលកម្មសរុបមានការប្រសើរឡើង ដោយសារចំនួនស្ត្រីភាគច្រើនបានទទួលការងារធ្វើនៅក្នុងឧស្សាហកម្មកាត់ដេរដែលមានការរីកចម្រើនយ៉ាងឆាប់រហ័ស ។

**២.១៣** គោលនយោបាយជាតិប្រជាជនត្រូវបានអនុម័ត ដើម្បីឆ្ពោះទៅរកកំណើនប្រជាជនដែលមានតុល្យភាព ។ អាយុកាលមធ្យមបានកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងរយៈពេលដ៏ខ្លី ដែលឆ្លុះបញ្ចាំងឱ្យឃើញពីភាពរីកចម្រើននៅក្នុងសុខុមាលភាពជាទូទៅ ។

## ៣. គោលដៅនិងចំណុចដៅអាទិភាព[១]

**៣.១** ដើម្បីឱ្យមានវឌ្ឍនភាពទៅតាមលំដាប់លំដោយនៅក្នុងរយៈពេល៥ឆ្នាំខាងមុខ (២០០៦-២០១០) គឺទាមទារឱ្យមានការកំណត់អាទិភាពច្បាស់លាស់និងចំណុចដៅដែលអាចវាស់វែងបាន។ អាទិភាពខ្ពស់បំផុត គឺការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យមានវឌ្ឍនភាព ដើម្បីឈានទៅសម្រេចបានបណ្តាចំណុចដៅនៃ *គអសក* នៅឆ្នាំ ២០១៥ ។ *គអសក* រួមមាន ៩ ចំណុច ដោយរួមបញ្ចូលទាំងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សហប្រជាជាតិទាំង៨ចំណុចផងដែរ ។ *គអសក* នីមួយៗត្រូវបានបំបែកទៅជាគោលដៅតូចៗជាច្រើន ដែលនៅក្នុងគោលដៅតូចៗទាំងនោះមានចំណុចដៅច្បាស់លាស់ជាច្រើនទៀត[២] ។ ការសិក្សាមួយដែលបានធ្វើឡើងនៅឆ្នាំ ២០០៥ បង្ហាញថា នៅពេលដែលវឌ្ឍនភាពដ៏ល្អត្រូវបានបង្កើតឡើង ដែលធ្វើឱ្យមានលទ្ធភាពអាចសម្រេចបាន (ឬមិន

[១] សូមមើល "កម្ពុជា : សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ" និងតារាងដោយឡែកក្នុងជំពូកផ្សេងទៀត

[២] សូមមើលឧបសម្ព័ន្ធ ១:១

សម្រេចបាន) តាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាមួយចំនួននៅឆ្នាំ២០១៥ ក៏ដោយ ចាំបាច់ត្រូវតែមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាច្រើនទៀត ដើម្បីធ្វើឱ្យសម្រេចបានចំណុចដៅទាំងឡាយដែលបានគ្រោងទុក[១] ។ ដូច្នេះ *ផយអជ* ត្រូវផ្តោតទៅលើកិច្ចខិតខំរួមគ្នា ។

**៣.២** ការសម្រេចបានការកាត់បន្ថយភាពក្រីក្រ និង *គអសក* ពឹងផ្អែកយ៉ាងសំខាន់លើសមិទ្ធផលនៃវឌ្ឍនភាពជាក់លាក់ និងស្ថេរភាពនៅក្នុងវិស័យសេដ្ឋកិច្ច-សង្គមកិច្ចជាច្រើន ដូចជា កំណើនម៉ាក្រូសេដ្ឋកិច្ចឆាប់រហ័យ និងប្រកបដោយសមធម៌ ការត្រួតពិនិត្យយ៉ាងជិតដល់ទៅលើអតិផរណា ការបង្កើនជាសំខាន់នៅក្នុងផលិតភាព និងផលិតកម្មកសិកម្ម ការការពារនិងលើកកម្ពស់បរិស្ថាន ការពង្រឹងនិងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ កំណើនឆាប់រហ័យក្នុងវិស័យឧស្សាហកម្ម ការបង្កើតការងារនិងចំណូល ការកែទម្រង់រដ្ឋបាលសាធារណៈនិងប្រព័ន្ធតុលាការ កំណើនឆាប់រហ័សក្នុងការវិនិយោគផ្នែកឯកជន កំណើនក្នុងវិស័យពាណិជ្ជកម្មប្រកបដោយស្ថេរភាព និងកំណើនក្នុងវិស័យសេវាកម្ម ជាពិសេសទេសចរណ៍ ។

**៣.៣** ហេតុដូចនេះ *ផយអជ* នឹងផ្តោតការយកចិត្តទុកដាក់លើសមិទ្ធផលនៅកម្រិតជាតិ នូវអាទិភាព គោលដៅម៉ាក្រូនិងគោលដៅជាយុទ្ធសាស្ត្រមួយចំនួន និងចំណុចដៅសំខាន់ៗ (សូចនាករ) ជាមួយការកាត់បន្ថយភាពក្រីក្រជាអាទិភាពខ្ពស់បំផុត[២] ។ *ផយអជ* គឺជាក្របខ័ណ្ឌទូលំទូលាយមួយសម្រាប់ផ្តល់នូវការចង្អុលទិសនិងគោលការណ៍ណែនាំ ដើម្បីនាំប្រទេសជាតិចេញពីស្ថានភាពមួយនាចុងឆ្នាំ២០០៥ ទៅកាន់ស្ថានភាពមួយទៀតដែលត្រូវតែមាននៅឆ្នាំ២០១០[៣] ។ អនុគោលដៅ និងចំណុចដៅនិងផែនការ ដែលត្រូវយកទៅបំបែកលម្អិតបន្ថែម ដើម្បីសម្រេចបានគោលដៅម៉ាក្រូនិងគោលដៅជាយុទ្ធសាស្ត្រ និងចំណុចដៅសំខាន់ៗ នឹងត្រូវពង្រីកបន្ថែមក្នុងភាពជាក់លាក់ទៅក្នុងផែនការតាមវិស័យ និងផែនការថ្នាក់ក្រោមជាតិ ។

## ៤. យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ

**៤.១** បណ្តាគោលដៅនិងចំណុចដៅរបស់ *ផយអជ* ត្រូវតែដំណើរការនិងអនុវត្តតាមរយៈយុទ្ធសាស្ត្រចតុកោណ ។ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុឹងម៉ាត់ចំពោះគោលការណ៍ជាមូលដ្ឋានមួយចំនួន សម្រាប់ដឹកនាំប្រទេសជាតិឆ្ពោះទៅរកវិបុលភាព ដូចជា (១) ការប្រកាន់ភ្ជាប់នូវលិទ្ធិប្រជាធិបតេយ្យ ដោយមានការបើកទូលាយ និងការធានាឱ្យមានសេរីភាពក្នុងការបញ្ចេញមតិ (២) រាជរដ្ឋាភិបាលត្រូវធានាស្ថេរភាពនយោបាយ ការគោរពច្បាប់ សមធម៌ និងសណ្តាប់ធ្នាប់សង្គម (៣) រាជរដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវ មានប្រសិទ្ធភាព មានតម្លាភាព

[១] សូមមើលឧបសម្ព័ន្ធ ១.២

[២] ជំពូក៣: តារាង ៣.២

[៣] សូមមើល "កម្ពុជា : សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ" ជំពូក៣: តារាង ៣.២ និងតារាងដោយឡែកក្នុងជំពូកផ្សេងទៀត

មានគណនេយ្យភាពពេញលេញ (៤) រាជរដ្ឋាភិបាលធានាឱ្យមាន ស្ថេរភាពម៉ាក្រូ-សេដ្ឋកិច្ច បង្កើតនិងរក្សាហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបង្កើតបរិយាកាសអំណោយផលសម្រាប់វិស័យឯកជនដើម្បីការរីកចម្រើន ហើយផ្តល់សេវាកម្មសង្គមចាំបាច់សម្រាប់ការរៀបចំនិងលើកកម្ពស់មូលធនមនុស្ស ។

**៤.២** ដោយមានការប្រកាន់ខ្ជាប់នូវសន្តិភាពនិងស្ថេរភាពផ្ទៃក្នុង ការធ្វើឱ្យប្រសើរឡើងនូវសណ្តាប់ធ្នាប់សង្គម និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងរយៈពេលពីរ-បីឆ្នាំកន្លងមក កម្ពុជាកំពុងស្ថិតនៅក្នុង *ចំណុចចាប់ផ្តើមដ៏សំខាន់* សម្រាប់វឌ្ឍនភាពក្នុងពេលអនាគត ។ រយៈពេល ១០ឆ្នាំខាងមុខ គឺជា *ទសវត្សរ៍មួយនៃកាលានុវត្តភាព* ដើម្បីធ្វើឱ្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ក្លាយជាការពិតជាក់ស្តែង ហើយអ្នកក្រនិងអ្នកងាយរងគ្រោះ នឹងត្រូវបានលើកតម្កើង ។ គោលដៅនិងសកម្មភាពដែលបានកំណត់យ៉ាងជាក់លាក់នឹងគ្រប់គ្រងគ្រប់សកម្មភាពផ្សេងៗទៀត ដែលត្រូវអនុវត្តក្នុងអំឡុងឆ្នាំ២០០៦-២០១០ រួមមាន :

- ជំរុញការកាត់បន្ថយភាពក្រីក្រ និងបញ្ហាយេនឌ័រនៅក្នុងគ្រប់សកម្មភាពទាំងអស់ ។
- អនុវត្តកំណែទម្រង់ក្នុងគ្រប់វិស័យ ប៉ុន្តែកំណែទម្រង់ទាំងនោះអាចបង្កឱ្យមានការលំបាកនិងការប៉ះពាល់សម្រាប់រយៈពេលខ្លី ។
- ជំរុញ និងសម្រួលឱ្យមានកំណើនម៉ាក្រូសេដ្ឋកិច្ចឱ្យបានលឿន និងប្រកបដោយសមធម៌ ដែលបែងចែកតាមតំបន់និងតាមវិស័យមានលក្ខណៈទូលំទូលាយ ។
- បង្កើនឱ្យបានច្រើននូវ "ការវិនិយោគរូបវ័ន្ត " សម្រាប់កំណើនក្នុងវិស័យផលិតកម្មនិងក្នុងការអភិវឌ្ឍមនុស្ស ។
- តម្រង់ទិសទៅរកប្រជាជន និងតំបន់ដែលខ្វះខាតបំផុត ។
- ផ្តោតការយកចិត្តទុកដាក់លើសកម្មភាពទាំងឡាយដែលមានការសាកល្បងត្រឹមត្រូវ ត្រូវការចំណាយទាប និងអាចផ្តល់ផលឆាប់និងខ្ពស់នៅថ្នាក់មូលដ្ឋាន នឹងមានផលប៉ះពាល់ខ្លាំងនិងវិជ្ជមានលើស្ថានភាពក្រីក្រ ។
- ធ្វើឱ្យល្អប្រសើរកត្តាសម្រាប់បង្កើនផលិតភាព ។
- ប្រើប្រាស់កម្លាំងពលកម្មមនុស្សឱ្យបានច្រើនតាមដែលអាចធ្វើបាន សម្រាប់គ្រប់ការងារសាងសង់ ។ល។ ដើម្បីបង្កើនចំណូលរបស់គ្រួសារ ជាពិសេស នៅតំបន់ជនបទ ។
- យកចិត្តទុកដាក់លើការកសាងសមត្ថភាពមនុស្សក្នុងគ្រប់វិស័យទាំងអស់ ។

**៤.៣** ផ្អែកលើមូលដ្ឋានខាងលើ យុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗនឹងត្រូវបន្តអនុវត្តនៅលើទិដ្ឋភាព និងគោលគំនិតគ្រឹះផ្សេងៗគ្នានៃយុទ្ធសាស្ត្រចតុកោណ ។

**៤.៤** នៅក្នុងអភិបាលកិច្ចល្អ អាទិភាពជាច្រើនរួមមាន:

- ពង្រឹងឡើងវិញ និងពន្លឿនការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតាមគ្រប់រូបភាព ។
- អនុវត្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិជាក់លាក់ ។
- បង្កើនល្បឿន និងបន្តអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ។
- ពង្រីកនិងពង្រឹងវិធានការ ដើម្បីអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

**៤.៥** នៅក្នុងបរិស្ថានគ្របដណ្តប់សំខាន់៧ជុំវិញចតុកោណ អភិបាលកិច្ចល្អ យុទ្ធសាស្ត្រនិងសកម្មភាពនានាដែលបានលើកឡើង រួមមាន:

- ថែរក្សាដោយប្រុងប្រយ័ត្ននិងធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវសន្តិភាពរឹងមាំ ស្ថេរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គមដែលជាមូលដ្ឋានគ្រឹះសម្រាប់វឌ្ឍនភាពផ្សេងទៀត ។
- ធ្វើសមាហរណកម្មកម្ពុជាឱ្យបានទូលំទូលាយនិងស៊ីជម្រៅថែមទៀត ទៅក្នុងតំបន់និងពិភពលោក និង ទាក់ទាញការវិនិយោគ ដើម្បីសម្រេចបានការរីកចម្រើនសេដ្ឋកិច្ចសម្រាប់អ្នកក្រីក្រ ។
- បន្តពង្រឹងភាពជាដៃគូជាមួយនឹងសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។

**៤.៦** កំណើនម៉ាក្រូសេដ្ឋកិច្ចរឹងមាំនិងឆាប់រហ័ស ការត្រួតពិនិត្យសារពើពន្ធ និងវិស័យហិរញ្ញវត្ថុដែលមានសកម្មភាព គឺមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យមានវឌ្ឍនភាព ។ ហេតុដូចនេះ ត្រូវលើកឡើងនូវផែនការដូចខាងក្រោម:

- ធានាឱ្យមានស្ថេរភាពកំណើន *ផសស* ៦ភាគរយ ក្នុងមួយឆ្នាំ ។
- រក្សាវិស័យក្រៅប្រទេស និងស្ថេរភាពអត្រាប្តូរប្រាក់ ។
- រក្សាអតិផរណាឱ្យស្ថិតនៅក្រោមកម្រិត ៥ភាគរយ ។
- លើកទឹកចិត្តការវិនិយោគផ្នែកឯកជននៅក្នុងសកម្មភាពអាទិភាពនៅតំបន់ជនបទ ។
- កែលម្អការអនុវត្តថវិកា ដោយមានទាំងការបង្កើនចំណូលចរន្ត និងគម្រោងចំណាយសម្រាប់គាំទ្រអ្នកក្រដែលបានកំណត់ ។
- ធានាឱ្យមានតម្លាភាព និងគណនេយ្យភាពពេញលេញនៅគ្រប់ប្រតិបត្តិការអភិបាលកិច្ច រួមមាន ការដោះដូរ ឬការជួលទ្រព្យសម្បត្តិសាធារណៈ ។

**៤.៧** នៅក្នុងវិស័យកសិកម្ម ត្រូវបានផ្តោតទៅលើផលិតកម្មដំណាំប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផល និងចំណូលតាមជនបទ ការធ្វើពិពិធកម្មដំណាំ ការកែលម្អការគ្រប់គ្រងជលផល ការគ្រប់គ្រងព្រៃឈើប្រកបដោយ

ចីរភាព តាមរយៈកំណែទម្រង់ ការអភិរក្សបរិស្ថាន និងការអនុវត្តកំណែទម្រង់ដីធ្លី ជាពិសេស ដើម្បីធានាសិទ្ធិកាន់កាប់ដីធ្លីរបស់អ្នកក្រ ។ ក្នុងចំណោមយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗជាច្រើន រួមមាន :

- រៀបចំយុទ្ធសាស្ត្រទូលំទូលាយមួយសម្រាប់វិស័យកសិកម្ម ដើម្បីដោះស្រាយបញ្ហាសំខាន់ៗ ។
- បង្កើនការវិនិយោគសាធារណៈក្នុងវិស័យកសិកម្ម ។
- លើកកម្ពស់លទ្ធភាពទទួលបានមីក្រូហិរញ្ញវត្ថុគ្រប់គ្រាន់ ។
- លើកទឹកចិត្ត និងសម្របសម្រួលការវិនិយោគរបស់ផ្នែកឯកជនក្នុងវិស័យកសិកម្ម និងការកែច្នៃកសិផល ។
- លើកកំពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- សម្របសម្រួលការបង្កើនទិន្នផលតាមរយៈការពង្រីកសេវាផ្សព្វផ្សាយ ។
- អនុវត្តការធ្វើអន្តរាគមន៍ដោយផ្ទាល់ដោយតម្រង់ទិសទៅមូលដ្ឋាន ដែលត្រូវធ្វើការកែប្រែ ដើម្បីកាត់បន្ថយភាពក្រីក្រ ។
- ធានាលទ្ធភាពទទួលបានប្រកបដោយចីរភាពសម្រាប់អ្នកក្រនៅក្នុងវិស័យជលផល ។
- ពង្រឹងនិងពង្រីកផលិតកម្មបសុសត្វ ។
- គ្រប់គ្រងឱ្យបានប្រសើរតំបន់ដែលត្រូវការពារ ។
- អភិរក្សព្រៃឈើតាមរយៈការអនុវត្តការគ្រប់គ្រងប្រកបដោយចីរភាព ។
- រៀបចំ និងអនុវត្តគោលនយោបាយដីធ្លីទូលំទូលាយ ។
- អនុវត្តកម្មវិធីបែងចែកដីធ្លីជូនកសិករក្រីក្រ ។
- បន្តដោះមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។

**៤.៨** ដើម្បីជំរុញការអភិវឌ្ឍជនបទបន្ថែមទៀតស្របជាមួយនឹងវិមជ្ឈការនិងវិសហមជ្ឈការ ការផ្តោតការយកចិត្តទុកដាក់នឹងត្រូវធ្វើឡើងលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវ ទីផ្សារ មធ្យោបាយផ្តល់ទឹកស្អាត ប្រព័ន្ធអនាម័យ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច អាគារសាលារៀននិងសុខភាព ។ល ។) ការងារទាំងនេះត្រូវបានអនុវត្តតាមរយៈមូលនិធិវិមជ្ឈការ តាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់ ។ កិច្ចខិតខំប្រឹងប្រែងនឹងបន្តធ្វើ ដើម្បីលើកកម្ពស់លទ្ធភាពទទួលសេវាឥណទានជនបទ និងដើម្បីបញ្ចុះអត្រាការប្រាក់ ។

**៤.៩** អាទិភាពក្នុងការស្តារហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត រួមមាន ផ្លូវជាតិនិងផ្លូវខេត្ត ផ្លូវរថភ្លើង អាកាសយានដ្ឋាន កំពង់ផែ ប្រព័ន្ធធារាសាស្ត្រ ទូរគមនាគមន៍ ម៉ាស៊ីនអគ្គិសនី និងបណ្តាញចែកចាយ ។ល ។ ជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ក្នុងការទាក់ទាញផ្នែកឯកជន ដើម្បីអនុវត្តការងារ ដោយផ្អែកលើវិធីសាស្ត្រ *សាងសង់-ដំណើរការ-ផ្ទេរ* ។

**៤.១០** ការសង្ឃឹមទុកនៃការធ្វើអាជីវកម្មធនធានប្រេងនិងឧស្ម័នក្នុងសមុទ្រកំពុងមានពន្លឺកាន់តែច្បាស់ ។ រាជរដ្ឋាភិបាលនឹងអនុវត្តការសិក្សាពិសេស និងដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីធ្វើឱ្យការប្រើប្រាស់បានប្រសើរបំផុត នៃធនធានដែលមានតម្លៃទាំងនេះ និងចំណូលដែលមានលំហូរចេញពីធនធានទាំងនេះ ។

**៤.១១** ការទាក់ទាញវិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស គឺជាការសំខាន់បំផុតដើម្បីបង្កើនល្បឿនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលនឹងលុបបំបាត់ចោលឱ្យអស់និងបានឆាប់រហ័ស នូវឧបសគ្គធំៗនាពេលបច្ចុប្បន្ន រួមមាន ការពន្យារពេលក្នុងការផ្តល់សេចក្តីយល់ព្រមនិង "ការចំណាយសម្រាប់កិច្ចការធុរៈកិច្ច " ខ្ពស់ និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសទូទៅ តាមរយៈកំណែទម្រង់អភិបាលកិច្ចផ្សេងៗ ។ សហគ្រាសធុនតូចនិងមធ្យមនឹងទទួលបានការយកចិត្តទុកដាក់ខ្លាំង រួមមាន លទ្ធភាពទទួលបានហិរញ្ញវត្ថុរយៈពេលមធ្យម និងវែងកាន់តែប្រសើរ និងមានលក្ខណៈងាយស្រួលជាងមុន ។

**៤.១២** កាលានុវត្តភាពសម្រាប់ពាណិជ្ជកម្មជាមួយបណ្តាប្រទេសជិតខាង និងប្រទេសដទៃទៀត ត្រូវបានធ្វើឱ្យប្រសើរឡើង ប៉ុន្តែមិនទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្កើតតម្រូវការសម្រាប់និងដើម្បីនាំចេញ ទំនិញនិងសេវាកម្មដែលបានប្រើប្រាស់សម្រាប់ឧត្តមភាពប្រកួតប្រជែងរបស់ប្រទេស ។ ការកែទម្រង់ដើម្បីលើកកម្ពស់ការចូលរួមរបស់ផ្នែកឯកជន នឹងដោះស្រាយរាល់បណ្តាបញ្ហាដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្មផងដែរ ។

**៤.១៣** អប់រំ គឺជាវិស័យអាទិភាពមួយក្នុងការអភិវឌ្ឍមនុស្ស និងការកសាងសមត្ថភាព ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០០៦-២០១០) ត្រូវបានរៀបចំរួចហើយ ។ ក្រៅពីការផ្តល់ការអប់រំមូលដ្ឋានជាសកល គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ការយកចិត្តទុកដាក់ចាំបាច់ ត្រូវផ្តោតទៅលើកម្រិតផ្សេងៗទៀត រួមមាន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧត្តមសិក្សា ដើម្បីចាប់ផ្តើមកសាង " សំណុំដ៏សំខាន់ " នៃប្រជាជនដែលមានការអប់រំ មានជំនាញ មានទេពកោសល្យ មានសមត្ថភាព ដើម្បីបម្រើតម្រូវការអភិវឌ្ឍន៍ប្រទេសក្នុងវិស័យផ្សេងៗ ។ អាទិភាពសម្រាប់រយៈពេល៥ឆ្នាំខាងមុខ រួមមាន :

- ធានាលទ្ធភាពទទួលបានការអប់រំមូលដ្ឋានងាយស្រួលនិងប្រកបដោយសមធម៌ ជាពិសេសសម្រាប់អ្នកក្រ និងអ្នកដែលរស់នៅតំបន់ជនបទដាច់ស្រយាល រួមមាន តាមរយៈការបង្កើនចំនួនសាលាបឋមសិក្សា និងសាលាមធ្យមសិក្សាបឋមភូមិ ។
- សម្របសម្រួលការចូលរៀនរបស់ក្មេងស្រីក្នុងការចូលរៀនក្នុងសាលាមធ្យមសិក្សាបឋមភូមិ និងកម្រិតខ្ពស់ជាងនេះ រួមមាន តាមរយៈការបង្កើនចំនួនអន្តេវាសិកដ្ឋានសម្រាប់សិស្សស្រី ។
- កាត់បន្ថយបន្ទុកចំណាយចំពោះសិស្សក្រីក្រ តាមរយៈការផ្តល់អាហារូបករណ៍ ។
- បង្កើនគុណភាព និងប្រសិទ្ធភាពសេវាអប់រំ ។

- ធានាទំនាក់ទំនងល្អនៃការអប់រំនិងការបណ្តុះបណ្តាល សម្រាប់ទីផ្សារពលកម្មនិងសង្គម រយៈពេលខ្លី និងវែង ។

**៤.១៤** វិស័យសុខាភិបាល សង្កេតឃើញមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ប៉ុន្តែសន្ទស្សន៍សុខភាពខ្លះនៅមានកំរិតខ្ពស់នៅឡើយ ។ វាត្រូវបានរំពឹងទុកថា ចំណុចដៅមួយចំនួននៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា អាចត្រូវបានដោះស្រាយ[១] ចំណែកឯចំណុចដៅនៃសកម្មភាពជាក់លាក់ផ្សេងទៀត ទាមទារដើម្បីធ្វើការអនុវត្តបន្ត ។ ចំណុចដៅអាទិភាព រួមមានៈ

- ពន្លឿនការកែទម្រង់លើគ្រប់វិស័យទាំងអស់ ។
- ពង្រីកលទ្ធភាពដែលមាន នៃសម្ភារៈថែទាំសុខភាព តាមរយៈការកសាង និង/ឬការស្តារឡើងវិញនៃប្រព័ន្ធសុខាភិបាល ដូចជា មន្ទីរពេទ្យ មណ្ឌលសុខភាព ។ល។ នៅតំបន់ជនបទ ។
- ពង្រីកនិងពង្រឹងវិធីសាស្ត្រប្រកបដោយចីរភាពសម្រាប់ការផ្តល់ ការជួយចំពោះអ្នកក្រ ដើម្បីទទួលបានប្រព័ន្ធថែទាំសុខភាពសាធារណៈ ។
- ពង្រីក លើកទឹកចិត្ត និងធ្វើឱ្យមានការចូលរួមពីផ្នែកឯកជន ក្នុងការផ្តល់សេវាថែទាំសុខភាព ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ ។
- យកចិត្តទុកដាក់ជាពិសេសលើការកាត់បន្ថយការរីករាលដាល ហ៊ីវ/អេដស៍ ជាពិសេស ចំពោះគ្រួសារ ដោយការព្យាយាមអប់រំ និងការផ្តល់ព័ត៌មាន ។

**៤.១៥** បញ្ហាសមធម៌យេនឌ័រ ត្រូវបញ្ជ្រាបចូលគ្រប់សកម្មភាពទាំងអស់ ហើយត្រូវបានកំពុងដោះស្រាយក្នុងគ្រប់វិស័យ ជាពិសេសក្នុងវិស័យកសិកម្ម សុខាភិបាល និងអប់រំ ។ ក្រុមប្រឹក្សាជាតិសម្រាប់ស្ត្រី នឹងបន្តដោះស្រាយបញ្ហាជាច្រើននៃការបញ្ជ្រាបយេនឌ័រនៅគ្រប់ទិដ្ឋភាពទាំងអស់នៃអភិបាលកិច្ច និងសង្គម ។

**៤.១៦** គោលនយោបាយជាតិប្រជាជន ដែលបង្កើតឡើងដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជាទាំងមូល នឹងត្រូវអនុវត្តដើម្បីផ្តល់ព័ត៌មាន និងចំណេះដឹងចំពោះគូរស្រករទាំងអស់ និងផ្តល់លទ្ធភាពឱ្យពួកគេ ដើម្បីធ្វើការជ្រើសរើសអំពី ចំនួននិងចន្លោះកូន និងផ្តល់ឱ្យពួកគេនូវសេវានិងការផ្គត់ផ្គង់ចាំបាច់ ចំពោះគោលបំណងរបស់ពួកគេ ។

## ៥. ចំណាយ ធនធាន និងការរៀបចំកម្មវិធី

**៥.១** ការអនុវត្តប្រកបដោយជោគជ័យ និងតាមពេលវេលានៃយុទ្ធសាស្ត្រ និងសមិទ្ធផលនៃចំណុចដៅរបស់ *ផយអជ* នឹងទាមទារការវិនិយោគបន្ថែមឱ្យបានច្រើន និងចំទិសដៅ និងការប្រើប្រាស់របស់ពួកគេឱ្យចំគោលដៅ

[១] ឧបសម្ព័ន្ធ ១.២

និងប្រកបដោយប្រសិទ្ធភាព ។ ការវិនិយោគបែបនេះ ទាមទារត្រូវធ្វើទាំង ក្នុងវិស័យឯកជន និងវិស័យសាធារណៈ ប៉ុន្តែមានតែការវិនិយោគវិស័យសាធារណៈទេដែលបានលើកឡើងនៅក្នុង *ផយអជ* ។

**៥.២** ផ្អែកលើកំណើនម៉ាក្រូសេដ្ឋកិច្ចដែលបានព្យាករណ៍ទុក និងការវិនិយោគដែលចាំបាច់ក្នុងវិស័យសាធារណៈ និងធ្វើការគិតគូរពីសមត្ថភាពដែលស្រូបយកបរិក្ខារវិស័យសាធារណៈ ។ ថវិកាចំនួន ១៥.២២៥ពាន់លានរៀល ស្មើនឹង ៣.៥០០លានដុល្លារអាមេរិក ត្រូវបានប៉ាន់ប្រមាណថា នឹងត្រូវយកទៅធ្វើការចំណាយសម្រាប់វិស័យសាធារណៈ ក្នុងរយៈពេល៥ឆ្នាំខាងមុខ ២០០៦-២០១០ ដើម្បីសម្រេចបានគោលដៅនិងចំណុចដៅ ដែលបានកំណត់នៅក្នុង *ផយអជ* ។ ក្នុងកញ្ចប់ថវិកាដែលបានប៉ាន់ប្រមាណនេះ ការគិតគូរជាអាទិភាពចាំបាច់ត្រូវធ្វើការកំណត់លើវិស័យចម្បង១មួយចំនួន ។ ដើម្បីធានាការកាត់បន្ថយភាពក្រីក្រនៅជនបទ ការធ្វើវិភាជន៍ថវិកាត្រូវបង្កើនបន្ថែមសម្រាប់សកម្មភាពទាំងឡាយដែលនឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ជនបទ ។ តារាង ៥.២ ក្នុងជំពូក៥ ផ្តល់ទស្សនៈរួមនៃការធ្វើវិភាជន៍ថវិកាដែលមានអាទិភាពខ្ពស់ (ជាង៦០ភាគរយ សម្រាប់តំបន់ជនបទ) ។

**៥.៣** ធនធានដែលមានសម្រាប់ *ផយអជ* នឹងបានមកពី (ក) អតិរេកគណនេយ្យចរន្តក្នុងថវិកាជាតិប្រចាំឆ្នាំ (ខ) ជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (គ) កម្ចីសម្បទានពីស្ថាប័នហិរញ្ញវត្ថុពហុភាគី (ឃ) ធនធានពីដៃគូមិនមែនប្រពៃណី រួមមាន កម្ចីពាក់កណ្តាលសម្បទានពីស្ថាប័នហិរញ្ញវត្ថុពហុភាគី (ង) មូលនិធិដែលបានមកពីការលុបបំណុលកន្លងមក ។ អាទិភាពខ្ពស់មួយ គឺត្រូវតម្រង់ទិសធនធានក្នុងមធ្យោបាយមួយច្បាស់លាស់ ដើម្បី "ការវិនិយោគពិតប្រាកដ " រួមមាន តាមរយៈការកាត់បន្ថយឱ្យបានច្រើននូវគម្រោងជំនួយបច្ចេកទេស និងទាក់ទាញដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដើម្បីតម្រឹមជំនួយរបស់ពួកគេទៅតាម *ផយអជ* ។ រាជរដ្ឋាភិបាល មានជំនឿនិងសុទិដ្ឋិនិយមថា ការខ្វះខាតថវិកាចំនួន ៩៨០ពាន់លានរៀល ស្មើនឹង ២២៥លានដុល្លារអាមេរិក នៅក្នុងធនធាន អាចត្រូវបានរកមកបង្គ្រប់ តាមរយៈការបង្កើនចំណូលក្នុងប្រទេស និងការគាំទ្រពីក្រៅប្រទេស ។

**៥.៤** *ផយអជ* មិនបានបង្ហាញពីការស្នើឡើងក្នុងរូបភាពជាគម្រោងនិងការចំណាយជាលម្អិតទេ ។ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ដែលជាឧបករណ៍សម្រាប់ដំណើរការ ដែលបានបង្កើតឡើងសម្រាប់ជាផ្នែកដ៏សំខាន់មួយរបស់ *ផយអជ* នឹងត្រូវស្របជាមួយនឹងអាទិភាពរបស់ *ផយអជ* ហើយនឹងមានលម្អិតកម្មវិធីនិងគម្រោងតូច១ និងការចំណាយ ។ ដូចគ្នានេះដែរ ថវិកាប្រចាំឆ្នាំនឹងត្រូវស្របគ្នាជាមួយ *ផយអជ* និងកម្មវិធីវិនិយោគសាធារណៈ ដែលនឹងចាប់ផ្តើមពីឆ្នាំ២០០៧ ។

## ៦. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

**៦.១** ដោយសារ *ផយអជ* ជាឯកសាររស់ ដូច្នេះ វឌ្ឍនភាពរបស់វានឹងត្រូវពិនិត្យឡើងវិញ និងត្រូវតាមដានត្រួតពិនិត្យប្រចាំឆ្នាំ ។ ចំពោះគោលបំណងនេះ វិធីសាស្ត្រចាំបាច់សម្រាប់អង្កេតវាយតម្លៃ នឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្តក្នុងពីរ-បីខែដំបូងនៃឆ្នាំ២០០៦ ។ ការអង្កេតបែបនេះ អាចជួយដល់ការតាមដានវឌ្ឍនភាពអំពីសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗសម្រាប់សម្រេចគោលដៅទាំងឡាយ រួមទាំងគោលដៅអភិវឌ្ឍន៍សហស្ស-វត្សរ៍កម្ពុជាផង ។ ផ្អែកតាមការពិនិត្យឡើងវិញបែបនេះ របាយការណ៍វឌ្ឍនភាពមួយនឹងត្រូវរៀបចំក្នុងខែមិថុនាជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០០៦ ដើម្បីធ្វើការកែតម្រូវឡើងវិញនូវគោលដៅ និងចំណុចដៅឱ្យមានលក្ខណៈត្រឹមត្រូវ និងតាមតម្រូវការ ។

**៦.២** *ផយអជ* និងកម្មវិធីវិនិយោគសាធារណៈសម្រាប់ឆ្នាំ២០០៦-២០០៨ នឹងត្រូវបង្ហាញនៅក្នុងកិច្ចប្រជុំការកៀរគរជំនួយដែលគ្រោងធ្វើនៅខែមីនា ឆ្នាំ២០០៦ ។ ដូច្នេះ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃ *ផយអជ* និង *កវស* បីឆ្នាំរំកិល នឹងជាឯកសារដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវពិចារណាក្នុងកិច្ចប្រជុំការកៀរគរជំនួយនាពេលអនាគត ។

## ៧. សេចក្តីសន្និដ្ឋាន

**៧.១** មានកត្តា ឬហានិភ័យខ្លះ ដែលមិនអាចប៉ាន់ស្មានជាមុនបាន ដែលអាចធ្វើឱ្យវឌ្ឍនភាពនៃ *ផយអជ* មានភាពយឺតយ៉ាវ ដូចជា ធនធានដែលរំពឹងទុកមិនត្រូវបានទទួល ជាពិសេសពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស តម្លៃប្រេងនិងឧស្ម័នទីផ្សារអន្តរជាតិនៅតែបន្តកើនឡើងដែលនឹងជំរុញឱ្យមានអតិផរណាខ្ពស់ ការប្រែប្រួលស្ថានភាពខាងនយោបាយ សន្តិសុខ និងសង្គមក្នុងតំបន់ និងពិភពលោក ដោយសារសកម្មភាពនៃភេរវកម្ម ឧបសគ្គពាណិជ្ជកម្មអន្តរជាតិមិនត្រូវបានធ្លាក់ចុះតាមជំហានដែលចង់បាន ការរីករាលដាលនៃជំងឺ ដូចជា ផ្តាសាយបក្សី ឬជំងឺផ្សេងៗទៀត គ្រោះថ្នាក់ធម្មជាតិ ដូចជាទឹកជំនន់ និងភាពរាំងស្ងួតដែលកើតឡើងជាបន្តបន្ទាប់ ។ រាជរដ្ឋាភិបាលត្រូវមានជំនឿថា អាចទប់ទល់បាននូវការប្រឈមបែបនេះ និងធ្វើការកែតម្រូវ *ផយអជ* ដើម្បីសម្របសម្រួលតាមភាពជាក់ស្តែងដែលពួកគេអាចចូលរួមបាន ។ រាជរដ្ឋាភិបាលត្រូវមានសុទិដ្ឋិនិយមថា ជាមួយការប្តេជ្ញាចិត្តនិងសហ-ប្រតិបត្តិការដ៏មុឹងម៉ាត់ពីគ្រប់ដៃគូទាំងអស់ *ផយអជ* អាចអនុវត្តបានប្រកបដោយជោគជ័យ ដើម្បីសម្រេចបានគោលដៅនិងចំណុចដៅ ដែលអាចវាស់វែងបាន ដើម្បីកាត់បន្ថយនិងលើកកម្ពស់សុខុមាលភាពប្រជាជនកម្ពុជាគ្រប់រូប ។

# កម្ពុជា: សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ

**ព័ត៌មានទូទៅ**

| | |
|---|---|
| ផ្ទៃដីសរុប: គម² | ១៨១.០៣៥ |
| ចំនួនខេត្ត-ក្រុង | ២៤ |
| ចំនួនទីប្រជុំជន រួមមានភ្នំពេញ-ខេត្ត-ក្រុង | ១៦២ |
| ចំនួនស្រុក-ខ័ណ្ឌ | ១៨៥ |
| ចំនួនឃុំ-សង្កាត់ | ១.៦២១ |
| ចំនួនភូមិ | ១៣.៨៩០ |
| ឆ្នាំសារពើពន្ធ | មករា-ធ្នូ |
| រូបិយវត្ថុ | រៀល (៛) |

| | សូចនាករសំខាន់ៗ | ឯកតា | ១៩៩៣ | ២០០០ | ២០០៥ | ២០១០ |
|---|---|---|---|---|---|---|
| | | | | | ការប៉ាន់ស្មាន | ការព្យាករណ៍ |
| **១.00** | **កម្រិតនៃភាពក្រីក្រ** | | | | **២០០៤** | |
| ១.0១ | សរុបទូទាំងប្រទេស | %នៃប្រជាជន | - | ពុំមានតួលេខ | ៣៤,៦៧ | ២៥,0 |
| | ៥៦%នៃផ្ទៃប្រទេស (អង្កេតឆ្នាំ ១៩៩៣-១៩៩៤) | | ៣៩.00 | ពុំមានតួលេខ | ២៨ | |
| ១.0២ | ភ្នំពេញ | % | ១១,៤ | ពុំមានតួលេខ | ៤,៦ | |
| ១.0៣ | ទីប្រជុំជនផ្សេងទៀត | % | - | ពុំមានតួលេខ | ២៤,៦ | |
| | តំបន់ដែលបានកំណត់ (អង្កេតឆ្នាំ ១៩៩៣-១៩៩៤) | % | ៣៦,៦ | | ២0,៥ | |
| ១.0៤ | ជនបទ | % | - | ពុំមានតួលេខ | ៣៩,២ | |
| | តំបន់ដែលបានកំណត់ (អង្កេតឆ្នាំ ១៩៩៣-១៩៩៤) | % | ៤៣,១ | ពុំមានតួលេខ | ៣៣,៧ | |
| ១.0៥ | ប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រស្បៀងអាហារ | % | - | ពុំមានតួលេខ | ១៩.៧ | ១៣,0 |
| | (៥៦%នៃផ្ទៃប្រទេស (អង្កេតឆ្នាំ ១៩៩៣-១៩៩៤) | % | ២0.00 | ពុំមានតួលេខ | ១៤,២ | |
| **២.00** | **បញ្ហាយេនឌ័រ** | | | | | |
| ២.0១ | ស្ត្រីក្នុងកម្លាំងពលកម្ម (ក.ព) | | | | | |
| | ក្នុងវិស័យកសិកម្ម | %នៃ ក.ព សរុប | - | ៣៥ (១៩៩៨) | ៥២,៥ | |
| ២.0២ | ក្នុងវិស័យឧស្សាហកម្ម | %នៃ ក.ព សរុប | - | ៤៤ (១៩៩៨) | ៥៣,៥ | |
| ២.0៣ | ក្នុងវិស័យសេវាកម្ម | %នៃ ក.ព សរុប | - | ២១ (១៩៩៨) | ២៧,0 | ៣៧,00 |
| **៣.00** | **ប្រជាជន** | | | | | |
| ៣.0១ | សរុប | លាននាក់ | ១0,៦៦ | ១២,៥៧ | ១៣,៨ | ១៥,២៧ |
| ៣.0២ | ដង់ស៊ីតេប្រជាជន | ក្នុងមួយគម² | ៥៩,១ (១៩៩៦) | ៦៤(១៩៩៨) | ៧៤,0 (២០០៤) | ៨៦,00 |
| ៣.0៣ | បុរសធៀបនឹងស្ត្រី(១00) | % | ៩១,៧ (១៩៩៦) | ៩៣ (១៩៩៨) | ៩៣,៥ (២០០៤) | ៩៥ |
| ៣.0៤ | អាយុ 0-១៤ | % | ៤៣,៩ (១៩៩៦) | ៤២,៨ (១៩៩៨) | ៣៩ (២០០៤) | ៣៣,0 |
| ៣.0៥ | អាយុ ១៥-៥៩ | % | ៥0,៨ (១៩៩៦) | ៥១,៨ (១៩៩៨) | ៥៥,១ (២០០៤) | ៦១,0 |

| | សូចនាករសំខាន់ៗ | ឯកតា | ១៩៩៣ | ២០០០ | ២០០៥ | ២០១០ |
|---|---|---|---|---|---|---|
| | | | | | ការប៉ាន់ស្មាន | ការព្យាករណ៍ |
| ៣.០៦ | អាយុ ៦០ និង លើសពី៦០ | % | ៥.៣ (១៩៩៦) | ៥.៣ (១៩៩៨) | ៥.៩ (២០០៤) | ៦.០ |
| ៣.០៧ | ជនបទ | % | ៨៤.៣៩ | ពុំមានតួលេខ | ៨៥.០ | ពុំមានតួលេខ |
| ៣.០៨ | ទីប្រជុំជន | % | ១៥.៦១ | ពុំមានតួលេខ | ១៥.០ | ពុំមានតួលេខ |
| ៣.០៩ | អត្រាកំណើនប្រចាំឆ្នាំ | % | ២.៤៩ (១៩៩៨) | ១.៨១ | ១.៨១ (២០០៤) | ២.១ |
| ៣.១០ | អត្រាភាពបង្កើតកូនសរុប | % | ៥.២ (១៩៩៦) | ៤.០ | ៣.៣៤ (២០០៤) | ៣.៤ |
| ៣.១១ | អាយុកាលមធ្យមសង្ឃឹមរស់តាំងពីកំណើត-ឆ្នាំ | ប្រុស/ស្ត្រី | ៥១.៨២/៥៥.៧៩ (១៩៩៨) | ៥៤.៤/៦០.៦ | ៥៧.៨៧/៦៤.១៤ | |
| **៤.០០** | **ម៉ាក្រូសេដ្ឋកិច្ច** | | | | | |
| ៤.០១ | *ផសស* ប្រចាំឆ្នាំ (គិតតាមថ្លៃថេរ) | ពាន់លានរៀល | ៨.៤៥៦ | ១៤.០៨៩ | ១៩.២៩៤ | ២៥.៧៤៧ |
| ៤.០២ | ការរួមចំណែកក្នុង*ផសស* : | | | | | |
| | កសិកម្ម : ដំណាំ | % | ១៨.៨០ | ១៦.៥០ | ១៤.២០ | ១២.៧០ |
| ៤.០៣ | បសុសត្វ និង បសុបក្សី | % | ៨.៩០ | ៥.៤០ | ៤.៦០ | ៤.៣០ |
| ៤.០៤ | ជលផល | % | ១៣.៦០ | ១០.៨០ | ៩.៣០ | ៨.០០ |
| ៤.០៥ | ព្រៃឈើ | % | ៤.៣០ | ៣.៣០ | ២.០០ | ១.៦០ |
| ៤.០៦ | កម្មន្តសាល | % | ៨.០០ | ១៦.០០ | ២០.៩០ | ២១.៧០ |
| ៤.០៧ | សំណង់ | % | ៤.៤០ | ៥.២០ | ៦.៨០ | ៨.១០ |
| ៤.០៨ | ទេសចរណ៍(សណ្ឋាគារនិងភោជនីយដ្ឋាន) | % | ២.៤០ | ៣.៧០ | ៥.១០ | ៥.៨០ |
| ៤.០៩ | ការដឹកជញ្ជូន | % | ៦.៣០ | ៦.៦០ | ៦.៩០ | ៦.៦៣ |
| ៤.១០ | សេវាកម្មផ្សេងៗទៀត | % | ៤.៤០ | ៦.១០ | ៦.៥០ | ៧.៤០ |
| ៤.១១ | *ផសស* សម្រាប់ប្រជាជនម្នាក់ | ពាន់រៀល | ៨៩៧.០០ | ១.១១០.០០ | ១.៤០០.០០ | ២.២៤៣.៣២ |
| ៤.១២ | អត្រាកំណើន *ផសស* ប្រចាំឆ្នាំ (ថ្លៃថេរ) | % | ៣.៩០ | ៦.៥០ | ៧.០០ | ៦.០០ |
| ៤.១៣ | អតិផរណាគិតពី១ឆ្នាំទៅ១ឆ្នាំ | % | ១១៤.៣០ | (០.០៨) | ៦.២០ | ៣.០០ |
| ៤.១៤ | អត្រាប្តូរប្រាក់ | ដុល្លារអាមេរិក=រៀល | ២.៧៤៧.០០ | ៣.៩២៤.០០ | ៤.១២៨.០០ | ៤.៣៧៨.០០ |
| ៤.១៥ | ទុនបំរុងបរទេស ជាដុល្លារ | ចំនួនខែ/នាំចូល | ២.៣០ | ២.៧០ | ២.៥០ | ៣.០០ |
| ៤.១៦ | ការវិនិយោគផ្ទាល់ពីបរទេស (ប្រចាំឆ្នាំ) | លានដុល្លារ | ១២៤.០០ | ១៤២.០០ | ២១៦.០០ | ៣៣២.០០ |
| **៥.០០** | **សារពើពន្ធ** | | | | | |
| ៥.០១ | ចំណូលថវិកា | %នៃ *ផសស* | ៩.០០ (១៩៩៦) | ១០.២០ | ១១.៨០ | ១៣.៨០ |
| ៥.០២ | ពន្ធផ្ទាល់ | %នៃ *ផសស* | ៦.៤០ (១៩៩៦) | ៧.៤០ | ៨.៧០ | ៩.២០ |
| ៥.០៣ | ពន្ធមិនផ្ទាល់ និងពន្ធអន្តរជាតិ | %នៃ *ផសស* | ៦.១០ (១៩៩៦) | ៦.៤០ | ៦.១០ | ៦.៤០ |
| ៥.០៤ | ចំណូលមិនមែនពន្ធ % | %នៃ *ផសស* | ២.១០ (១៩៩៦) | ២.៩០ | ២.៩០ | ២.៧០ |
| ៥.០៥ | ចំណាយថវិកាសរុប | % នៃ *ផសស* | ១៧.៣០ (១៩៩៦) | ១៥.១០ | ១៤.៩០ | ១៦.៥០ |
| ៥.០៦ | ចំណាយចរន្ត | %នៃ *ផសស* | ៩.៨០ (១៩៩៦) | ៨.៩០ | ៩.៦០ | ១០.៨០ |
| ៥.០៧ | ចំណាយជាទុន | %នៃ *ផសស* | ៧.៦០ (១៩៩៦) | ៦.៥០ | ៥.៣០ | ៥.៨០ |

| | សូចនាករសំខាន់ៗ | ឯកតា | ១៩៩៣ | ២០០០ | ២០០៥ | ២០១០ |
|---|---|---|---|---|---|---|
| | | | | | ការប៉ាន់ស្មាន | ការព្យាករណ៍ |
| **៦.០០** | **ជំនួយអភិវឌ្ឍន៍ផ្លូវការ (រួមទាំងអង្គការក្រៅរដ្ឋាភិបាល)** | | | | | |
| ៦.០១ | សរុប | លានដុល្លារ | ៣២២,០០ | ៤៦៧,០០ | ៥៥០,០០ | ៥៥០,០០ |
| ៦.០២ | ជំនួយបច្ចេកទេស | លានដុល្លារ | ៧៨,០០ | ២០៩,០០ | ពុំមានតួលេខ | ពុំមានតួលេខ |
| ៦.០៣ | ជំនួយផ្សេងៗទៀត | លានដុល្លារ | ២៤៤,០០ | ២៥៨,០០ | ពុំមានតួលេខ | ពុំមានតួលេខ |
| **៧.០០** | **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | |
| ៧.០១ | ផ្ទៃដីដំណាំ | ពាន់ហត | ២.០៨៨ | ២.៥៥៦ | ២.៨៣៥ | ៣.៥០០ |
| ៧.០២ | ផ្ទៃដីស្រោចស្រព | ពាន់ហត | ៤០៧ (១៩៩៨) | | ៥៨៨,៦៨៧ | ៦៥០ |
| ៧.០៣ | ផ្ទៃដីដាំដុះស្រូវ | ពាន់ហត | ១.៨២៤ | ២.៣១៨ | ២.៣៧៤ | ២.៥០០ |
| ៧.០៤ | ទិន្នផលក្នុងមួយហិកតា | តោន | ១,៣១ | ២,១១ | ១,៩៧ | ២,៤០ |
| ៧.០៥ | ឡូតិ៍នេសាទ | $គម^2$ | ៩.៥៣៧ | ៤.១៧៥ | ៤.១៥២ | ៤.១៥០ |
| ៧.០៦ | - សម្រាប់សហគមន៍នេសាទ | % | - | ៥៦,២ | ៥៦,៥ | ៥៦,៥ |
| ៧.០៧ | ត្រី :នេសាទបាន (ពីគ្រប់ប្រភព) | តោន | ១០៨.៩០០ | ២៥៦,០៣០ | ៣៧៤.០០០ | ៤៥០,០០០ |
| ៧.០៨ | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | %នៃផ្ទៃដី | ៦០ | ៥៨ | ៦០ | ៦០ |
| ៧.០៩ | ព្រៃឈើដាំដុះឡើងវិញ (សរុបផ្ទៃដីដាំដុះ តាំងពីឆ្នាំ១៩៨៥) | ហត | - | ២.២៧៧ | ១៤.០៦៤ | ៣០.០០០ |
| ៧.១០ | ការប្រើប្រាស់អុសសម្រាប់ដុត | %គ្រួសារសរុប | ៩២,០ | ពុំមានតួលេខ | ៨៥.៥០ | ៦១,០ |
| ៧.១១ | កំណែទម្រង់ដីធ្លី : ប័ណ្ណកម្មសិទ្ធិដីធ្លីដែលបានផ្តល់ជូនកសិករ | %ផ្ទៃដីសរុប | | ៥ | ១២ | ២៤ |
| **៨.០០** | **ការអភិវឌ្ឍជនបទ** | | | | | |
| ៨.០១ | ផ្លូវថ្នល់ដែលបានស្តារ (នៃប្រវែងសរុប ២៨.០០០ គម) | គម | | | ២២.៧០០ | ២៥.០០០ |
| ៨.០២ | លទ្ធភាពទទួលបានទឹកស្អាត (ជនបទ) | %នៃប្រជាជន | | ២៤(១៩៩៨) | ៤១,៦ | ៤៥,០ |
| ៨.០៣ | លទ្ធភាពទទួលបានអនាម័យ (ជនបទ) | %នៃប្រជាជន | | ៨,៦(១៩៩៦) | ១៦,៤ | ២៥,០ |
| **៩.០០** | **ឧស្សាហកម្ម** | | | | | |
| ៩.០១ | ផលិតផលកម្មន្តសាល : (មិនគិតផលិតផលសំលៀកបំពាក់) | ពាន់លានរៀល | ១.៧៤៤,៧៤ | ២.៩០៤,៣៩ | ៣.៩៤៤,៩២ | ៥.៥២៩,៤៩ |
| ៩.០២ | ឧស្សាហកម្មសំលៀកបំពាក់ : | | | | | |
| | ផលិតផល | ពាន់លានរៀល | ០,០០ | ៣.៤៤៤,៣០ | ៧.៤១៦,៩០ | ១២.៨១០,៦១ |
| | កម្លាំងពលកម្ម | ចំនួន | ០,០០ | ១៦០.០០០ | ៣៣០.០០០ | ៤៨០.០០០ |
| **១០.០០** | **ថាមពល** | | | | | |
| ១០.០១ | ថាមពលដោយប្រើៈ ប្រេងសាំង & ម៉ាស៊ូត | តោន | ៦០.៥១៧ | ១១០.៦១០ | ១៧៩.១៣៦ (២០០៤) | ៣១៧.៣៥០ |
| ១០.០២ | អគ្គិសនីដែលផលិតបាន | គីកាវ៉ាត់ | ១៦៣,៣៩ | ៤៣៤,៥០ | ៧៥៩,៧០ | ១.៣៤៦,០០ |
| ១០.០៣ | ប្រវែងបណ្តាញខ្សែបញ្ជូនថាមពល (១១៥ KVA) | គម | - | ២២,៧០ | ១២៨,៧០ | ២២៨,០ |

| | សូចនាករសំខាន់ៗ | ឯកតា | ១៩៩៣ | ២០០០ | ២០០៥ | ២០១០ |
|---|---|---|---|---|---|---|
| | | | | | ការប៉ាន់ស្មាន | ការព្យាករណ៍ |
| ១០.០៤ | ចំនួនគ្រួសារប្រើប្រាស់ថាមពល | ចំនួន | ១៣.៣៦៧ | ១២៤.២៦៩ | ២០៨.៤៧៦ | ៣៧០.០០០ |
| ១០.០៥ | ការប្រើប្រាស់ថាមពលរបស់ប្រជាជនម្នាក់ក្នុង១ឆ្នាំ | គវ៉ម | ១៤.៩៦ | ៤៨.៥០ | ៥៤.០១ | ៨៩.១១ |
| **១១.០០** | **ដឹកជញ្ជូន** | | | | | |
| ១១.០១ | ផ្លូវជាតិ និងផ្លូវខេត្ត- សរុប (ផ្លូវកៅស៊ូ) | គម | | | ១១.៣១០ (២.១០០) | ១១.៣១០ (៤.១០០) |
| ១១.០២ | ចំនួននៃកំពង់ផែអន្តរជាតិ | ចំនួន | ២ | ២ | ២ | ២ |
| **១២.០០** | **ទេសចរណ៍** | | | | | |
| ១២.០១ | ចំនួនភ្ញៀវទេសចរណ៍មកដល់ | នាក់ | ១៧៧.០០០ (១៩៩៤) | ៤៦៦.៣៦៥ | ១.៣០០.០០០ | ៣.១២០.០០០ |
| ១២.០២ | ប៉ាន់ស្មានចំណូលរូបិយវត្ថុបរទេស | លានដុល្លារ | | ៣៩៥ (២០០២) | ៦០០,០០ | ១.៥០០,០០ |
| **១៣.០០** | **សុខាភិបាល** | | | | | |
| ១៣.០១ | អត្រាមរណភាពទារក | ក្នុង១.០០០កំណើត | | ៩៥ | ៦៦ | ៦០ |
| ១៣.០២ | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ | ក្នុង១.០០០កំណើត | | ១២៤ | ៨២ | ៧៥ |
| ១៣.០៣ | ទារកអាយុក្រោម១ឆ្នាំដែលទទួលវ៉ាក់សាំងប្រឆាំង DPT3 | % | | ៤៣ | ៨៣ | ៨៥ |
| ១៣.០៤ | ទារកអាយុក្រោម១ឆ្នាំដែលទទួលវ៉ាក់ស៊ាំងប្រឆាំងជម្ងឺកញ្ជ្រឹល | % | | ៤១ | ៨០ | ៨៥ |
| ១៣.០៥ | មរណភាពមាតា | ក្នុង១០០.០០០កំណើត | | ៤៣៧ | ពុំមានតួលេខ | ២៤៣ |
| ១៣.០៦ | ការបង្កើតកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ | % | | ៣២ | ពុំមានតួលេខ | ៧០ |
| ១៣.០៧ | ករណើជម្ងឺគ្រុនចាញ់ : ព្យាបាលនៅមណ្ឌលសុខភាពសាធារណ: | ក្នុង១០០០ករណើ | | ១១,៤០ | ៧,៣០ | ៦,០០ |
| ១៣.០៨ | អត្រាស្លាប់ដោយជម្ងឺគ្រុនចាញ់ | % | | ០,៤០ | ០,៣៦ | ០,២៥ |
| ១៣.០៩ | ប្រេវ៉ាឡង់ជម្ងឺរបេងក្នុងចំណោមអ្នកពិនិត្យសួត | ក្នុង១០០.០០០ | | ៤២៨ (១៩៩៧) | ពុំមានតួលេខ | ២១៤ |
| ១៣.១០ | អត្រាស្លាប់ដោយជម្ងឺរបេង | ក្នុង១០០.០០០ | | ៩០ (១៩៩៧) | ពុំមានតួលេខ | ៦០ |
| ១៣.១១ | ហ៊ីវ/អេដស៍:អត្រាប្រេវ៉ាឡង់មនុស្សពេញវ័យ | %(១៥-៤៩ឆ្នាំ) | | ៣,០ (១៩៩៧) | ១,៩ | ១,៩ |
| ១៣.១២ | មន្ទីរពេទ្យបង្អែក | ចំនួន | ៦៥ (១៩៩៧) | ៦៨ (២០០២) | ៦៩ | |
| ១៣.១៣ | មណ្ឌលសុខភាព | ចំនួន | ៥១៤ | ៩៤២ | ៩៦៥ | |
| ១៣.១៤ | លទ្ធភាពទទួលបានទឹកស្អាត (ទីប្រជុំជន) | %នៃប្រជាជន | | ៦០ (១៩៩៨) | ៧៥.៨ | ៨៥.០ |
| ១៣.១៥ | លទ្ធភាពទទួលបានអនាម័យ (ទីប្រជុំជន) | %នៃប្រជាជន | | ៤៩ (១៩៩៨) | ៥៥.០ | ៦៧.០ |
| **១៤.០០** | **អប់រំ** | | | | **២០០៤-២០០៥** | |
| ១៤.០១ | ចំនួននៃសាលាបឋមសិក្សា | ចំនួន | ៤.៦៩៣ | ៥.៤៦៨ | ៦.១៨០ | |
| ១៤.០២ | ចម្ងាយផ្លូវឆ្ងាយបំផុតទៅសាលាបឋមសិក្សា | គម | | | ២ | ១,៥ |
| ១៤.០៣ | អត្រាពិតនៃការសិក្សា : សរុប-ប្រុស-ស្រី | %នៃប្រជាជន | | ៨៧-៩០-៨៤ | ៩១,៩-៩៣,០-៩០,៧ | ១០០ សម្រាប់ទាំងអស់ |
| ១៤.០៤ | អត្រាពិតនៃការសិក្សា : ទីប្រជុំជន-ជនបទ-តំបន់ដាច់ស្រយាល | % | | | ៩១,៦ -៩២,៤-៨២,៥ | ១០០ សម្រាប់ទាំងអស់ |

| | សូចនាករសំខាន់ៗ | ឯកតា | ១៩៩៣ | ២០០០ | ២០០៥ ការប៉ាន់ស្មាន | ២០១០ ការព្យាករណ៍ |
|---|---|---|---|---|---|---|
| ១៤.០៥ | អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៦ ប្រុស/ស្រី | % | | ៥១,០ | ៥៣,១ | ១០០ សម្រាប់ទាំងអស់ |
| ១៤.០៦ | ចំនួននៃសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ៣៥៤ | ៣៦៧ | ៨០០ | |
| ១៤.០៧ | ចម្ងាយផ្លូវឆ្ងាយបំផុតទៅសាលាមធ្យមសិក្សាបឋមភូមិ | គម | | | ៨ | ៤ |
| ១៤.០៨ | អត្រាពិតនៃការសិក្សា : សរុប-ប្រុស-ស្រី | % | | ១៩-២១-១៦ | ២៦,១-២៧,៣-២៤,៨ | ៥០% សម្រាប់ទាំងអស់ |
| ១៤.០៩ | អត្រាពិតនៃការសិក្សា : ទីប្រជុំជន-តំបន់ជនបទ-តំបន់ដាច់ស្រយាល | % | - | - | ៤១,៣-២៣,៧-៣,៩ | ៧៥ ទីប្រជុំជន-៥០ តំបន់ផ្សេងទៀត |
| ១៤.១០ | អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៩ | % | - | ៣៣ | ៣០,១៨ | ៥០ |
| ១៤.១១ | ចំនួនអក្ខរជនអាយុ ១៥-២៤ឆ្នាំ | % | | ៨២ (១៩៩៩) | ៨៣,៤ | ៩៥ |
| **១៥.០០** | **កម្មវិធីសំអាតមីន** | | | | | |
| ១៥.០១ | ជនរងគ្រោះដោយសារមីនប្រចាំឆ្នាំ (ស្លាប់ និងរបួស) | នាក់ | ១.៧៤៣ (១៩៩៦) | ៨៥៨ | ៧៩៧ | ២០០ |
| ១៥.០២ | សរុបផ្ទៃដីដែលបានបោសសំអាតមីន-យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ | ហត | ១.២២៥ | ១៥.៣២៦ | ៣២.៩៧៤ | ៤៥.០០០ |

**កំណត់សម្គាល់ :** ទិន្នន័យក្នុងវិស័យសង្គមកិច្ចជាច្រើនអាចមានការប្រែប្រួលទៅតាមលទ្ធផលអង្កេតថ្មីឬកំពុងដំណើរការ

# ជំពូក ១

# សេចក្តីផ្តើម

**១.០១** ការកសាងកម្ពុជាឡើងវិញឱ្យរួចចេញយ៉ាងឆាប់រហ័ស ពីការបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងនូវសម្បត្តិធនធានដែលកម្ពុជាធ្លាប់មាន (រួមមាន ធនធានមនុស្ស ស្ថាប័នសេដ្ឋកិច្ចនិងសង្គមកិច្ច រចនាសម្ព័ន្ធរដ្ឋាភិបាល ហេដ្ឋារចនា-សម្ព័ន្ធរូបវ័ន្ត) គឺជាអាទិភាពខ្ពស់បំផុតសម្រាប់រដ្ឋាភិបាល ដែលត្រូវរ៉ាប់រងការទទួលខុសត្រូវលើការគ្រប់គ្រងប្រទេសជាតិ បន្ទាប់ពីការដួលរលំនៃរបបប្រល័យពូជសាសន៍ ក្នុងខែមករា ឆ្នាំ១៩៧៩ ។ ទោះបីជាស្ថិតក្នុងស្ថានភាពមួយដែលមានអវត្តមាននៃជំនួយមនុស្សធម៌និងជំនួយអភិវឌ្ឍន៍ពីបណ្តាប្រទេសភាគច្រើននៃពិភពលោក ដែលបង្កឡើងដោយភាពមិនអំណោយផលនៃភូមិសាស្ត្រនយោបាយ ព្រមទាំងដោយជម្លោះផ្ទៃក្នុងនិងការរំខានជាញឹកញាប់ដល់ជីវភាពរស់នៅធម្មតាតាមរយៈសកម្មភាពវិទ្ធង្សនាក៏ដោយ កម្ពុជាបានវិលបន្តិចម្តងៗមករកប្រក្រតីភាពវិញ ។ ការកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលត្រូវបានបំផ្លិចបំផ្លាញ ដែលជាការងារមួយដ៏លំបាក កំពុងតែត្រូវបានបន្តដំណើរការ ។ ការងារដែលលំបាកខ្លាំងជាងនេះទៀតនោះគឺ ការកសាងឡើងវិញនិងការពង្រឹងនូវ រចនាសម្ព័ន្ធសង្គម ស្ថាប័នសង្គម និងភាពសុខុដុមនៃក្រុមគ្រួសារ ដែលមានតម្លៃគួរជាទីគោរព ដែលត្រូវបានបាក់បែកយ៉ាងធ្ងន់ធ្ងរ ។ ការខិតខំប្រឹងប្រែងទាំងនេះ សម្រេចបានប្រកបដោយជោគជ័យ ទោះបីជាស្លាកស្នាមជាច្រើននៃអតីតកាល នៅតែបន្តមាននៅឡើយ ។ ដោយបានចាប់ផ្តើមពី ស្ថេរភាពនិងកំណើននៃផលិតកម្មកសិកម្ម ដែលជាកត្តាសំខាន់បំផុតក្នុងការផ្តល់ស្បៀងអាហារដល់ប្រជាជន វិស័យផ្សេងៗទៀតនៃខឿនសេដ្ឋកិច្ច ក៏ត្រូវបានធ្វើឱ្យមានការរីកចម្រើនផងដែរ ។ នាពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ កម្ពុជាបានចាប់ផ្តើមការជំរុញលើកទឹកចិត្តឱ្យមានអន្តរកាលទៅរកសេដ្ឋកិច្ចទីផ្សារ ។ វិស័យឯកជនផ្លូវការ ក៏បានចាប់ផ្តើមអភិវឌ្ឍឡើងផងដែរ ។ ការផ្លាស់ប្តូរដ៏សំខាន់មួយក្នុងការតម្រង់ទិសការគ្រប់គ្រងសេដ្ឋកិច្ច បានកើតឡើងនៅក្នុងឆ្នាំ១៩៨៩ ដោយបាននាំកម្ពុជាទៅដល់ផ្លូវថ្មីមួយនៃការអភិវឌ្ឍ ។

**១.០២** នៅលើមូលដ្ឋាននៃការផ្សះផ្សារជាតិនៅក្នុងចំណោមភាគីជម្លោះផ្សេងៗ នាសន្និសីទសន្តិភាពទីក្រុងប៉ារីសក្នុងខែតុលា ឆ្នាំ១៩៩១ ការបោះឆ្នោតទូទៅត្រូវបានរៀបចំឡើង នាឆ្នាំ១៩៩៣ ដែលនាំឱ្យឈានទៅដល់ការអនុម័តរដ្ឋធម្មនុញ្ញថ្មី និងការបង្កើតឡើងនៃរាជរដ្ឋាភិបាលកម្ពុជា ។ លើសពីនេះ ចាប់តាំងពីការចាប់ផ្តើមរហូតមកទល់នឹងពេលនេះ អាទិភាពខ្ពស់បំផុត ត្រូវបានផ្តោតទៅលើការធ្វើឱ្យមានវឌ្ឍនភាពយ៉ាងឆាប់រហ័សផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច សំដៅកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងជួយឱ្យកម្ពុជាស្ថិតនៅក្នុងវិថីមួយឆ្ពោះទៅរកកំណើន ដែលអាចទ្រទ្រង់ខ្លួនឯងបាន[១] ។

---

[១] តារាង *"កម្ពុជា : សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ"* ពីទំព័រ (xxii) ដល់ (xxvi) បង្ហាញពីសូចនាករ ដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពចាប់ពីឆ្នាំ១៩៩៣ និងការព្យាករណ៍រហូតដល់ ២០១០

## karxtxRbgERbgrbskmCakgkargarGPvDEnEd I manEpnkar

**១.០៣** ចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជាសម្រាប់ពេលអនាគត ត្រូវបានលើកឡើងនៅក្នុង *កម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៤ ។ ផ្អែកលើមូលដ្ឋាននេះ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទី១ (១៩៩៦-២០០០)* ត្រូវបានរៀបចំឡើង ដោយកំណត់នូវគោលដៅនិងចំណុចដៅច្បាស់លាស់ ដែលត្រូវធ្វើឱ្យសម្រេចបាននាឆ្នាំ២០០០ ។ គោលដៅសំខាន់គឺ កំណើនម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ ទន្ទឹមនឹងនេះ *កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល* ត្រូវបានរៀបចំឡើងសម្រាប់រយៈពេលឆ្នាំ១៩៩៦-១៩៩៨ ដើម្បីធ្វើឱ្យធនធានក្នុងនិងក្រៅប្រទេស អាចត្រូវបានចាត់ចែងប្រើប្រាស់សម្រាប់វិស័យអាទិភាព ដើម្បីធ្វើឱ្យសម្រេចបាននូវគោលដៅដែលបានកំណត់នៅក្នុង *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទី១* ។ ដំណើរការនៃការរៀបចំ *កម្មវិធីវិនិយោគសាធារណៈ* ជារៀងរាល់ឆ្នាំសម្រាប់រយៈពេលបីឆ្នាំ ត្រូវបានបន្តអនុវត្តចាប់តាំងពីពេលនោះមក ។ *កម្មវិធីវិនិយោគសាធារណៈ* ត្រូវបានប្រើប្រាស់ដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កៀរគរធនធានពី *ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស*[១] ។ គោលបំណងដើមនៃការងារនេះ គឺការបន្ស៊ីគ្នារវាងថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា និង *កម្មវិធីវិនិយោគសាធារណៈ* ។

**១.០៤** នាចុងដំណាក់កាលនៃផែនការប្រាំឆ្នាំលើកទី១ ផែនការប្រាំឆ្នាំលើកទី២ សម្រាប់ដំណាក់កាលឆ្នាំ២០០១-២០០៥ ត្រូវបានរៀបចំឡើង ហើយផែនការនេះបានកំណត់នូវចំណុចដៅអភិវឌ្ឍន៍ជាច្រើន ដែលត្រូវធ្វើឱ្យសម្រេចបាននាឆ្នាំ២០០៥ ។ គោលដៅចម្បងនៃផែនការនេះមានលក្ខណៈស្ទើរតែដូចគ្នានឹងគោលដៅនៃផែនការប្រាំឆ្នាំលើកទី១ ។

**១.០៥** ចាប់តាំងពីផែនការប្រាំឆ្នាំលើកទី២ ត្រូវបានចាប់ផ្តើមអនុវត្តពីឆ្នាំ២០០១មក ក្របខ័ណ្ឌនៃការងារអភិវឌ្ឍន៍ចម្បងសំខាន់ និងមានលក្ខណៈជឿនលឿន ចំនួនបីបានកើតមានឡើង ។ ការប្រជុំកំពូលសហប្រជាជាតិប្រចាំសហស្សវត្សរ៍ជាប្រវត្តិសាស្ត្រក្នុងឆ្នាំ២០០០ បានប្រកាសអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលត្រូវធ្វើឱ្យសម្រេចបានដោយប្រទេសទាំងអស់នាឆ្នាំ២០១៥ ។ ផ្អែកតាមស្មារតីខាងលើនេះ កម្ពុជាបានកំណត់នូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួន ដែលហៅថា *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក)*[២] ដោយផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយភាពក្រីក្រ ។ គោលដៅទាំងនេះ គឺជាអាទិភាពខ្ពស់បំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជា ។ ទន្ទឹមនេះ *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* ត្រូវបានរៀបចំឡើងនិងអនុម័តនៅក្នុងខែធ្នូ ឆ្នាំ២០០២ ។ ជាមួយគ្នានេះ ការងារដំបូងបង្អស់ ដែលរាជរដ្ឋាភិបាលជាប់ឆ្នោតថ្មី បានធ្វើក្នុងឆ្នាំ២០០៤ គឺត្រូវកំណត់យកនូវយុទ្ធសាស្ត្រមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងផ្តោតចំបញ្ហាសម្រាប់ការអភិវឌ្ឍនាពេលអនាគត ។ យុទ្ធសាស្ត្រនេះមានឈ្មោះថា *"យុទ្ធសាស្ត្រចតុកោណ"* សម្រាប់កំណើន ការងារ សមធម៌ និង

---

[១] *ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស :* អង្គការអន្តរជាតិ អង្គការពហុភាគី អង្គការតំបន់ អង្គការទ្វេភាគី និងអង្គការក្រៅរដ្ឋាភិបាល ដែលផ្តល់ជំនួយដល់កម្ពុជា

[២] សូមមើលឧបសម្ព័ន្ធ ១:១

ប្រសិទ្ធភាព ដែលរំលេចឡើងជាគំនូសតាងមួយ ផ្សំដោយចតុកោណស្នូលមួយពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ ដែលស្ថិតនៅចំកណ្តាលក្របខ័ណ្ឌបរិស្ថានសម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល ព្រមទាំងចតុកោណបួនផ្សេងទៀត ដែលមានលក្ខណៈជាយុទ្ធសាស្ត្រសម្រាប់ជំរុញកំណើន[១] ។

**១.០៦** ដំណាក់កាលនៃការអនុវត្តផែនការប្រាំឆ្នាំលើកទី២ បានបញ្ចប់នាខែធ្នូ ឆ្នាំ២០០៥ ហើយរាជរដ្ឋាភិបាលកម្ពុជា កំពុងតម្រង់ទិសក្នុងការធ្វើផែនការសម្រាប់កំណើនក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ។ ទន្ទឹមនេះ នៅក្នុងការរៀបចំផែនការសម្រាប់ដំណាក់កាលឆ្នាំ២០០៦-២០១០ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចប្តូរពីវិធីសាស្ត្រធ្វើផែនការមួយដែលមានលក្ខណៈសាមញ្ញនិងទូលំទូលាយ ទៅវិធីសាស្ត្រមួយទៀតដែលប្រមូលផ្តុំតែលើគោលដៅនិងសកម្មភាពជាយុទ្ធសាស្ត្រ ។ ហេតុដូចនេះ ផែនការប្រាំឆ្នាំលើកទី៣នេះមានឈ្មោះថា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ)២០០៦-២០១០* ។ ផែនការនេះ នឹងផ្តុំនូវចំណុចសំខាន់ៗរបស់ឯកសារទាំងអស់ដែលបានលើកឡើង នៅក្នុងកថាខ័ណ្ឌ១.០៥ ។ *រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកផែនការនេះថាជាឯកសារយោងនិងឯកសារណែនាំតែមួយ សម្រាប់ការអនុវត្តទៅតាមគោលដៅ ចំណុចដៅ និងសកម្មភាពជាអាទិភាព ទាំងឡាយសម្រាប់រយៈពេល ប្រាំឆ្នាំខាងមុខ (២០០៦-២០១០)* ។

**១.០៧** គោលដៅសម្រាប់រយៈពេលមធ្យមប្រាំឆ្នាំខាងមុខ មានភាពច្បាស់លាស់ ដូចជា ការសម្រេចនូវចំណុចដៅបណ្តោះអាសន្នសម្រាប់ឆ្នាំ២០១០ របស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលសំដៅដល់ការកាត់បន្ថយភាពក្រីក្រ ដោយគិតគូរដល់គោលគំនិតទាំងឡាយ ដែលបានលើកឡើងនៅក្នុង*យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* រួមជាមួយនឹងសមិទ្ធផលចាំបាច់ៗក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច វិស័យផលិតកម្ម និងវិស័យសេវាកម្ម ។ យុទ្ធសាស្ត្រ ទាំងឡាយដែលត្រូវអនុវត្ត ក៏ត្រូវបានលើកឡើងដោយ យុទ្ធសាស្ត្រចតុកោណផងដែរ ។ ឥឡូវនេះ ភាពចាំបាច់ក្នុងការរៀបចំផែនការថ្មីនេះ គឺត្រូវច្របាច់បញ្ចូលគ្នានូវទស្សនៈទាំងអស់ដែលមាន តាមរបៀបមួយដែលមានលក្ខណៈប្រទាក់ក្រឡាគ្នានិងមានតុល្យភាព និងត្រូវផ្តោតលើអនាគតនិងសកម្មភាពទាំងឡាយដែលត្រូវអនុវត្តជាលក្ខណៈសរុបរួមគ្នា ដោយផ្តើមចេញពីទស្សនៈជាតិ ជាជាងចេញពីទស្សនៈវិស័យសុទ្ធសាធ ។ ទន្ទឹមនឹងនេះ ភាពចាំបាច់ក្នុងការរៀបចំផែនការនេះ គឺត្រូវធ្វើចំណាត់អាទិភាពរបស់គោលដៅនិងចំណុចដៅ នៅក្នុងចំណោមគោលដៅនិងចំណុចដៅទាំងឡាយដែលមានការប្រជែងគ្នាដើម្បីដណ្តើមយកអាទិភាពខ្ពស់រៀងៗខ្លួន ត្រូវផ្តោតតែលើយុទ្ធសាស្ត្រនិងសកម្មភាពពិសេសៗ ត្រូវគិតគូរដល់តម្លៃដែលត្រូវចំណាយ ហើយត្រូវធ្វើការបែងចែកធនធានទាំងឡាយ ។ ឥឡូវនេះ គឺជាពេលវេលាដែលត្រូវចាប់ផ្តើមធ្វើឱ្យសម្រេចបាននូវគោលដៅរបស់ *ផយអជ* តាមរយៈ ការដាក់ឱ្យដំណើរការនូវ *យុទ្ធសាស្ត្រចតុកោណ* ។

---

[១] សូមមើលគំនូសបំព្រួញស្តីពី *"យុទ្ធសាស្ត្រចតុកោណ"*

## deNIrkarrbsEpnkaryTsa®sGPvDÆnCat

**១.០៨** ផ្តើមចេញពីការផ្តោតការយកចិត្តទុកដាក់លើលទ្ធផល ការពិគ្រោះយោបល់ដ៏ទូលំទូលាយជាច្រើន ត្រូវបានធ្វើឡើងនៅក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ (ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នផ្តល់ជំនួយ ឬ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល) ដើម្បីមានការឯកភាពគ្នាលើបណ្តាគោលដៅអាទិភាពរួម ដែលត្រូវសម្រេចឱ្យបាននៅក្នុងដំណាក់កាលរបស់ *ផយអជ* ។ សិក្ខាសាលាជាច្រើនត្រូវបានរៀបចំឡើង ដើម្បីផ្តល់ឱកាសឱ្យអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ អាចពិនិត្យមើលរួមគ្នាលើគោលដៅរបស់ *ផយអជ* និងឧបស័គ្គទាំងឡាយដែលត្រូវជំនះ ដើម្បីសម្រេចបានគោលដៅទាំងនោះ ។ ដំណើរការដែលមានការចូលរួមទូលំទូលាយ បែបនេះមិនត្រឹមតែមានសារៈប្រយោជន៍ក្នុងការទទួលបាននូវគំនិតនិងយោបល់ មកពីមជ្ឈដ្ឋានផ្សេងៗគ្នាជាច្រើនតែប៉ុណ្ណោះទេ គឺថែមទាំងមានសារៈសំខាន់ក្នុងការជួយឱ្យអ្នកចូលរួមទាំងអស់ អាចពិនិត្យមើលគោលដៅទាំងឡាយបានទូលំទូលាយជាងមុន ដើម្បីអាចមើលឃើញចំណងទាក់ទងគ្នាទៅវិញទៅមករបស់គោលដៅទាំងនោះ ជាជាងពិនិត្យមើលបញ្ហាទាំងនោះ តែពីទស្សនៈតាមវិស័យឬករណីពិសេសណាមួយ ។ តារាងម៉ាទ្រីសលទ្ធផលមួយ ដែលត្រូវបានកែលម្អនៅក្នុងការពិគ្រោះយោបល់ទាំងនោះ បានជួយសម្រិតសម្រាំងឱ្យមានទិសដៅនិងគោលដៅអាចវាស់វែងបាន ដែលត្រូវធ្វើឱ្យបានសម្រេចតាមរយៈ *ផយអជ* ព្រមទាំងសកម្មភាពអាទិភាពដែលត្រូវការជាចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាននូវគោលដៅទាំងនោះ ក៏ដូចជា ដើម្បីជំនះឧបស័គ្គធំៗ ។ សេចក្តីព្រាង *ផយអជ* ត្រូវបានយកមកពិភាក្សាយ៉ាងល្អិតល្អន់នៅក្នុងរាជរដ្ឋាភិបាល តាមរយៈយន្តការពិគ្រោះយោបល់ជាលក្ខណៈអន្តរស្ថាប័ន ។ សេចក្តីព្រាង *ផយអជ* ក៏ត្រូវបានយកទៅពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសផងដែរ ។ បន្ទាប់មក សេចក្តីព្រាងកែសម្រួល ត្រូវបានយកមកពិភាក្សាជាចំហជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់នៅក្នុងសិក្ខាសាលាជាតិ ។ សេចក្តីព្រាងចុងក្រោយ ឆ្លុះបញ្ចាំងអំពីការចូលរួមចំណែកទាំងអស់ ដែលបានមកពីដំណើរការពិគ្រោះយោបល់ទាំងនេះ ។

## bBaaGaTPaBngxmsarrbsEpnkaryTsa®sGPvDÆnCat

**១.០៩** រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុក *ផយអជ ២០០៦-២០១០* ថាជា ឧបករណ៍មួយសម្រាប់តម្រង់ទិសនិងសម្រាប់យកទៅអនុវត្ត ដើម្បីសម្រេចបានទិសដៅ គោលដៅ និងចំណុចដៅ ដូចបានពោលពីខាងលើ ។ ផែនការនេះ គឺជាឯកសារមួយ *"សម្រាប់និងដោយកម្ពុជាទាំងមូល"* ។ ផែនការនេះ មិនមែនជាឯកសារសម្រាប់ការសិក្សានៅឧត្តមសិក្សាឡើយ ហើយជាឯកសារមួយ *ដែលមានប្រយោជន៍* សម្រាប់ធ្វើឱ្យសម្រេចបាន*នាឆ្នាំ២០១០ នូវចំណុចដៅពិសេសៗរបស់ជាតិ ដែលមានអាទិភាពខ្ពស់និងមានលក្ខណៈប្រាកដនិយម* ដើម្បីឈានទៅសម្រេចបណ្តាគោលដៅសម្រាប់រយៈពេលមួយវែងជាង ដោយប្រើប្រាស់ក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ ។ ការផ្តោតការយកចិត្តទុកដាក់របស់*ផយអជ* គឺសំដៅជាសំខាន់ទៅលើលទ្ធផល (ផលប៉ះពាល់) ដែលត្រូវសម្រេចឱ្យបានហើយនឹង

មិនសង្កត់ធ្ងន់តែទៅលើធាតុចូល សកម្មភាព និងដំណើរការនោះឡើយ ។ លើសពីនេះ *ផយអជ* គឺជាឯកសារមួយខ្លី មានន័យច្បាស់លាស់ ហើយមិនមានលក្ខណៈពិពណ៌នាច្រើនហួសហេតុ ។ *ឯកសារនេះលើកឡើងនិងផ្តោតលើគោលដៅ យុទ្ធសាស្ត្រ ចំណុចដៅ និងសកម្មភាពសំខាន់ៗបំផុត ហើយទុកឱ្យការងារលម្អិតរៀបចំ និងកំណត់ឡើងនៅក្នុងផែនការតាមវិស័យ និងផែនការថ្នាក់ក្រោមជាតិ ដោយផ្អែកលើបណ្តាអាទិភាពជាតិ*[១] ។

**១.១០** *ផយអជ* កំណត់និងលើកឡើងនូវ :

- ទិសដៅចម្បងសម្រាប់រយៈពេលមធ្យម ។
- គោលដៅដែលមានអាទិភាពខ្ពស់ មានលក្ខណៈជាយុទ្ធសាស្ត្រ និងអាចវាស់វែងបាន និងចំណុចដៅដែលត្រូវសម្រេចបាននៅទូទាំងប្រទេស ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ។
- យុទ្ធសាស្ត្រជាអាទិភាពដែលត្រូវការជាចាំបាច់ និងសកម្មភាពដែលត្រូវធ្វើ ។
- ការវិនិយោគជាអាទិភាពដែលត្រូវការជាចាំបាច់ និងការបែងចែកធនធាន និងការរៀបចំកម្មវិធីប្រើប្រាស់ធនធាន តាមវិស័យ ។
- ធនធានដែលអាចមាន ។
- យន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ សម្រាប់ការវាស់វែងជាប្រចាំនូវវឌ្ឍនភាព និងសម្រាប់ជួយបង្កលក្ខណៈងាយស្រួល ដល់ការកែតម្រូវ ដែលចាំបាច់នាពាក់កណ្តាលអាណត្តិ ។

**១.១១** *ផយអជ ត្រូវបានរៀបចំឡើង ផ្អែកតាមទម្រង់ក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ ដោយចងក្រងទស្សនៈនៃការអភិវឌ្ឍទៅតាមវិស័យ មិនមែនទៅតាមក្រសួង-ស្ថាប័នទេ* ។ នៅក្នុងវិស័យមួយចំនួន គោលដៅដែលមានលក្ខណៈលម្អិតជាងនិងអនុគោលដៅទាំងឡាយសម្រាប់វិស័យនីមួយៗ ត្រូវបានរៀបចំឡើងរួចមកហើយ ហើយនៅក្នុងវិស័យមួយចំនួនទៀត ផែនការយុទ្ធសាស្ត្រតាមវិស័យ នឹងត្រូវរៀបចំឡើងក្នុងពេលឆាប់ៗនេះ[២] ។ ដូចគ្នានេះដែរ បណ្តាខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងឃុំ-សង្កាត់ នឹងយកទិសដៅនិងគោលដៅជាតិទៅលម្អិតឱ្យទៅជាទិសដៅនិងគោលដៅ ដែលពាក់ព័ន្ធនឹងស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានខ្លួន ហើយរៀបចំគោលដៅលម្អិតដែលអាចវាស់វែងបាន (រួមទាំងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅថ្នាក់ឃុំ-សង្កាត់) ព្រមទាំង ផែនការសម្រាប់ដោះស្រាយតម្រូវការអភិវឌ្ឍន៍ជាអាទិភាពក្នុងមូលដ្ឋានរៀងៗខ្លួន[៣] ដោយប្រើប្រាស់ថវិកាដែលកំពុងត្រូវបានផ្តល់ឱ្យនៅក្នុងក្របខ័ណ្ឌគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ដែលត្រូវបានពង្រីកនិងលើកកម្ពស់

---

[១] សូមយោងទៅឯកសារផែនការតាមវិស័យសម្រាប់ព័ត៌មានលម្អិតជាងនេះ ។

[២] ឯកសារទាំងនេះនឹងត្រូវរៀបចំនិងបញ្ចប់ ដោយមានការពិគ្រោះយោបល់ជាមួយនឹងមានចំណែកពាក់ព័ន្ធទាំងអស់ ត្រឹមខែមេសា ឆ្នាំ២០០៦ ។

[៣] នៅក្នុងតំណាក់កាលពីខែមករាដល់មេសា ឆ្នាំ២០០៦ ក្រសួងផែនការនឹងរៀបចំការប្រជុំពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ ដើម្បីជួយរៀបចំផែនការថ្នាក់មូលដ្ឋាន សំដៅសម្រេចឱ្យបាននូវគោលដៅរបស់ *ផយអជ* ។

ក្នុងពេលថ្មីៗនេះ ។ ការពូតផ្គុំនូវការខិតខំប្រឹងប្រែងទាំងនេះ អាចនឹងជួយឱ្យទទួលបានលទ្ធផលទាំងឡាយ ដែលបានគ្រោងទុកនៅក្នុង*ផយអជ* ។

**១.១២** *ផយអជ* គឺជា *ឧបករណ៍ដ៏មានសារៈប្រយោជន៍មួយសម្រាប់បម្រើឱ្យការអនុវត្ត ដោយផ្ដោតលើលទ្ធផល* ហើយមានទិសដៅច្បាស់លាស់ ក្នុងការ :

- លើកកម្ពស់យ៉ាងឆាប់រហ័ស នូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងអស់ ។
- ផ្ដោតការយកចិត្តទុកដាក់ខ្លាំងជាងមុន លើការកាត់បន្ថយកម្រិតភាពក្រីក្រ តាមរបៀបមួយដែលអាចវាស់វែងបាននិងដែលផ្ដល់ផលប្រយោជន៍ពិតប្រាកដដល់អ្នកក្រីក្រ ជាពិសេស នៅតំបន់ជនបទ ដែលភាពក្រីក្រនៅមានកម្រិតខ្ពស់ ។

**១.១៣** *ផយអជ* ត្រូវបានច្របាច់បញ្ចូលគ្នានូវគោលដៅទាំងឡាយរបស់ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* និង *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* ព្រមទាំងកំណត់អាទិភាពសម្រាប់គោលដៅទាំងនោះ ហើយ*ផយអជ* មាន គោលបំណងដើម្បី :

- តម្រឹមតម្រង់យុទ្ធសាស្ត្រនិងវដ្តនៃការងារផែនការតាមវិស័យ ទៅនឹងទស្សនទានរួមនៃការងារអភិវឌ្ឍន៍រយៈពេលវែង របស់រាជរដ្ឋាភិបាលកម្ពុជា ។
- ផ្ដល់នូវការតម្រង់ទិសនិងធ្វើជាមូលដ្ឋានសម្រាប់ កម្មវិធីវិនិយោគបីឆ្នាំរំកិលនិងថវិកាប្រចាំឆ្នាំ នៅពេលអនាគត ដើម្បីធ្វើឱ្យការវិភាជន៍ថវិកានិងការអនុវត្ត បានស្របទៅនឹងការធ្វើឱ្យសម្រេចបានគោលដៅទាំងឡាយរបស់ជាតិ ។
- ផ្ដល់ការតម្រង់ទិសដល់កំណែទម្រង់ស្ថាប័ន និងការរៀបចំគោលនយោបាយ ជាលក្ខណៈអន្តរវិស័យ ។
- ជួយដល់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដើម្បីធ្វើការតម្រឹមតម្រង់និងធ្វើសុខុដុមនីយកម្មការខិតខំប្រឹងប្រែងរបស់ខ្លួន សំដៅបង្កឱ្យមានភាពប្រសើរជាងមុននៃប្រសិទ្ធភាពរបស់ជំនួយ ដោយអនុវត្តតាមក្របខ័ណ្ឌគោលដៅ និងអាទិភាព ជាយុទ្ធសាស្ត្រទាំងឡាយ ដែលរៀបចំឡើងដោយជាតិទាំងមូលនិងដែលមានរាជរដ្ឋាភិបាលជាម្ចាស់ ដោយផ្ដោតលើគណនេយ្យភាពទាំងសងខាង ហើយផ្ទេរឱ្យបានកាន់តែច្រើនជាងមុន ទៅយន្តការទាំងឡាយ ដូចជា *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* សម្រាប់ការផ្ដល់ជំនួយ ដែលអាចនាំឱ្យឈានទៅដល់ការគាំទ្រថវិកា ដែលជាទម្រង់មួយដ៏សមស្រប ក្នុងការផ្ដល់ជំនួយក្រៅប្រទេស ។
- ជួយទាក់ទាញនិងតម្រង់ការវិនិយោគរបស់វិស័យឯកជន សម្រាប់ការអនុវត្តគោលនយោបាយ អាទិភាព និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ។

**១.១៤** នៅកម្ពុជា ការកាត់បន្ថយភាពក្រីក្រ នឹងអាចទទួលបានជោគជ័យដ៏ធំនិងឆាប់បំផុត តាមរយៈការធ្វើឱ្យមានការអភិវឌ្ឍនៅតំបន់ជនបទ ដែលមានអ្នកក្រីក្រភាគច្រើនបំផុតរស់នៅ ។ ដូច្នេះ *ផយអជ* នឹងបន្តកំណត់ការបែងចែកធនធានជាង៦០ភាគរយ ទៅឱ្យតំបន់ជនបទ ដោយបង្កើនការយកចិត្តទុកដាក់ទៅឱ្យផ្នែកផលិត ដូចជា វិស័យកសិកម្ម ការអភិវឌ្ឍជនបទ ហើយទៅឱ្យវិស័យសុខាភិបាលនិងអប់រំ ដើម្បីបង្កើននិងលើកកម្ពស់ធនធានមនុស្ស ព្រមទាំងការរួមចំណែកប្រសើរជាងមុន នៅក្នុងដំណើរការរួមនៃកិច្ចអភិវឌ្ឍ ។

**១.១៥** សម្មតិកម្មជាច្រើនដែលមាននៅក្នុង *ផយអជ* ចំពោះបញ្ហាចំណាយថវិកាសរុបដែលចាំបាច់នៅក្នុងដំណាក់កាលនៃផែនការនេះ (២០០៦-២០១០) និងធនធានទាំងឡាយដែលអាចមានសម្រាប់ការចំណាយខាងលើ គឺផ្អែកលើការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានការឯកភាពពីមូលនិធិរូបិយវត្ថុអន្តរជាតិ និងផ្អែកលើរបៀបមួយដ៏ល្អបំផុត ក្នុងការបែងចែកថវិកាដែលត្រូវចំណាយសម្រាប់វិស័យនានា ទាំងសម្រាប់ការធ្វើឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និងទាំងសម្រាប់ការធ្វើឱ្យសម្រេចបានការកាត់បន្ថយភាពក្រីក្រ និងចំណុចដៅទាំងឡាយរបស់ *គអសក* ។ ជាការពិត ហានិភ័យមួយចំនួនដែលមិនអាចគេចបាននិងមិនអាចដឹងមុនបាន នឹងអាចកើតមានឡើង ហើយអាចជះឥទ្ធិពលដល់សម្មតិកម្មទាំងនេះ ដូចដែលបានលើកឡើងនៅក្នុងជំពូក៤ ជំពូក៥ និងជំពូក៦ ។

**១.១៦** សម្រាប់ការអនុវត្ត *ផយអជ* ប្រកបដោយជោគជ័យ និងដើម្បីឱ្យការកែតម្រូវជាចាំបាច់អាចធ្វើឡើងបាន ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃយ៉ាងទៀងទាត់ ទាន់ពេល និងច្បាស់លាស់ ត្រូវបានទទួលស្គាល់ថាជាការងារសំខាន់ ដែលត្រូវយកចិត្តទុកដាក់ ។ អាស្រ័យហេតុនេះ ផែនការនេះត្រូវបានចាត់ទុកថាជាឯកសារមួយមានលក្ខណៈអាចកែតម្រូវបាន ដែលត្រូវតាមដានត្រួតពិនិត្យនិងវាយតម្លៃយ៉ាងទៀងទាត់ចំពោះវឌ្ឍនភាព ហើយដែលត្រូវពិនិត្យមើលឡើងវិញនិងកែតម្រូវ ដើម្បីបង្ហាញពីទិន្នន័យថ្មីៗ[១] និងដើម្បីតម្រឹមតម្រង់សកម្មភាពទាំងឡាយប្រចាំឆ្នាំ ។ របាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាព កង្វះខាត និងសកម្មភាពសម្រាប់កែតម្រូវ នឹងត្រូវរៀបចំឡើង សម្រាប់ការផ្សព្វផ្សាយនិងការពិគ្រោះយោបល់ ។

**១.១៧** ភ្ជាប់ជាមួយនឹងស្ថានភាពរួមដូចបានពោលពីខាងលើ ជំពូកទាំងឡាយដែលមានជាបន្តទៀត នឹងលើកឡើងពីខ្លឹមសារលម្អិតរបស់ *ផយអជ* :

---

[១] ទិន្នន័យទាំងអស់ដែលបានយកមកប្រើប្រាស់រហូតមកដល់ពេលបញ្ចប់ឯកសារនេះ គឺជាទិន្នន័យថ្មីៗបំផុតដែលមាន រួមទាំងទិន្នន័យដែលបានមកពីការធ្វើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៣-២០០៤ ដែលត្រូវបានយកមកបង្ហាញរួចហើយកាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៥ តែមិនទាន់បោះពុម្ពផ្សាយ ។ ទិន្នន័យថ្មីៗ អាចត្រូវបានមកពីការច្របាច់បញ្ចូលគ្នានូវលទ្ធផលនៃការសិក្សានិងការអង្កេតផ្សេងទៀត ដោយរួមទាំងការអង្កេតពីរដែលកំពុងដំណើរការ គឺអង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជាឆ្នាំ២០០៥ និងការវាយតម្លៃភាពក្រីក្រដោយមានការចូលរួម ដែលបានរៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាលនិង ស្រាវជ្រាវ ដើម្បីអភិវឌ្ឍកម្ពុជា ។

- CBk 2 : វឌ្ឍនភាពដែលមានកន្លងមក និងស្ថានភាពបច្ចុប្បន្ន (២០០៥)
- CBk 3 ³ គោលដៅនិងចំណុចដៅអាទិភាព
- CBk 4 ³ យុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗ
- CBk 5 ³ ចំណាយ ធនធាន និង ការរៀបចំកម្មវិធី
- CBk 6 ³ ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ
- CBk 7 ³ សេចក្តីសន្និដ្ឋាន

# ជំពូក ២

## វឌ្ឍនភាពដែលមានកន្លងមក និងស្ថានភាពបច្ចុប្បន្ន

**២.០១** ក្នុងការវាយតម្លៃលើស្ថានភាពនិងតម្រូវការសម្រាប់ពេលអនាគត លើសក្តានុពល និងលើលទ្ធភាពនានារបស់កម្ពុជា ដោយផ្តើមចេញពីទស្សនៈវិស័យណាមួយ ជាទូទៅប្រជាជនកម្ពុជានិងពិភពលោកទាំងមូល នឹងចងចាំជានិច្ចពីអតីតកាលរបស់ប្រទេស ។ ជាការពិត វឌ្ឍនភាពក្នុងពេលកន្លងមក គឺជាសូចនាករមួយ ដែលអាចបង្ហាញពីភាពច្បាស់លាស់នៃទស្សនៈរបស់ប្រទេស ពីជំហរឹងមាំក្នុងការប្តេជ្ញាចិត្ត ពីការខិតខំប្រឹងប្រែង ដោយខ្ជាប់ខ្ជួន និងពីស្មារតីរបស់ប្រជាជនក្នុងការរើខ្លួនចេញឱ្យផុតពីការលំបាកទាំងនេះ ។ យើងមិនត្រឹមតែក្រឡេកមើលផ្លូវដ៏វែងឆ្ងាយដែលត្រូវដើរទៅមុខ និងចំណុចខ្វះខាតជាក់ស្តែងជាច្រើនដែលបានបង្កឡើងដោយអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវឱ្យតម្លៃដល់ចម្ងាយផ្លូវដ៏វែង ដែលយើងសម្រេចបានតែក្នុងរយៈពេលដ៏ខ្លី ប្រមាណមួយភាគបួននៃទសវត្សរ៍ប៉ុណ្ណោះ បើប្រៀបធៀបនឹងប្រជាជាតិមួយផ្សេងទៀតក្នុងពិភពលោក ដែលបានជួបការខូចខាតក្នុងទំហំមួយស្រដៀងគ្នា ដែលមិនអាចនឹកស្មានដល់និងមិនធ្លាប់មានពីមុន។

**២.០២** ដំណាក់កាលបីដាច់ៗពីគ្នានៃវឌ្ឍនភាព អាចត្រូវបានមើលឃើញក្នុងអតីតកាលថ្មីៗរបស់កម្ពុជា ។ ដំណាក់កាលទី១ ដែលគិតចាប់ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩២ គឺជាដំណាក់កាលនៃការផុសចេញពីរបបប្រល័យពូជសាសន៍ដែលគ្រប់គ្រងប្រទេសរយៈពេលជិតបួនឆ្នាំ ។ រាល់អ្វីៗត្រូវចាប់ផ្តើមជាថ្មីពីលេខសូន្យ ។ ជាមួយនឹងសេចក្តីសង្ឃឹមនិងស្មារតីព្យាយាម និងក្នុងស្ថានភាពនៃការដាក់ឱ្យនៅក្នុងភាពឯកោពីអន្តរជាតិ ប្រទេសជាតិត្រូវបានស្តារឡើងវិញដោយខ្លួនឯងនិងឈានដល់ដំណាក់កាលមួយដែលមានស្ថេរភាព ប៉ុន្តែស្លាកស្នាមនិងកេរ្តិ៍ដំណែលនៃអតីតកាលនៅតែបន្តមាន ដែលស្តែងឡើងតាមរយៈ កង្វះខាតកំលាំងពលកម្មជំនាញ ។ ដំណាក់កាលទី២ ដែលគិតចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ១៩៩៧ គឺជារយៈពេលវេលាដែលប្រទេសជាតិ ត្រូវរងភ្លាមៗនូវឥទ្ធិពលនៃវិបត្តិ២ដែលមិនទាក់ទងគ្នា និងកើតឡើងស្ទើរតែក្នុងពេលដំណាលគ្នា ពោលគឺវិបត្តិសេដ្ឋកិច្ចនៅអាស៊ីបូព៌ា ដែលជាវិបត្តិក្រៅប្រទេស និងវិបត្តិក្នុងប្រទេសនាពាក់កណ្តាលឆ្នាំ១៩៩៧ ដែលបានរំខានដល់ការលូតលាស់ផ្នែកសេដ្ឋកិច្ច ។ ដំណាក់កាលទី៣ ដែលគិតចាប់ពីឆ្នាំ១៩៩៨មកដល់ពេលនេះ បានចាប់ផ្តើមជាមួយនឹងការបង្កើតរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី២ គឺជារយៈពេលមួយ ដែលមានសន្តិភាពស្ថេរភាព ព្រមទាំងកំណើននិងវឌ្ឍនភាព ដែលកើតមានឡើងជាបន្តបន្ទាប់ ។ ជាការពិត ទោះបីជាការងារភាគច្រើនបំផុត ដែលមានរហូតមកដល់ឆ្នាំ១៩៩៧ មានលក្ខណៈជា ការស្តារឡើងវិញ ឬការខំប្រឹងប្រែងដើម្បី *"ផ្សះផ្សារ"* ក៏ដោយ ការងារដែលបានចាប់ផ្តើមក្នុងឆ្នាំ១៩៩៨ នៅតែជាការងារស្តារឡើងវិញនៅឡើយ ។ ទន្ទឹមពេលដែលការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

(*ផ្នែករឹង*) បាននិងកំពុងដំណើរការ ការផ្លាស់ប្តូរប្រព័ន្ធច្បាប់និងសេដ្ឋកិច្ច ការពង្រឹងការអភិវឌ្ឍស្ថាប័ននិងទុនសង្គម (*ផ្នែកទន់*) ត្រូវការពេលវេលាយូរអង្វែង ។

**២.០៣** ការពិនិត្យមើលលើទិដ្ឋភាពរួមដែលលើកមកបង្ហាញដោយសង្ខេប ផ្តល់នូវមូលដ្ឋានមួយ ដ៏មានសារៈប្រយោជន៍ សម្រាប់ការសិក្សាវិភាគអំពីស្ថានភាពដែលមានលក្ខណៈលម្អិតជាង ។ ទោះបីជាវឌ្ឍនភាពបានកើតពិតប្រាកដនៅក្នុងគ្រប់វិស័យ ហើយការផ្លាស់ប្តូរជាវិជ្ជមាននិងប្រកបដោយភាពជឿនលឿន គឺជាភស្តុតាងដ៏ច្បាស់នៅក្នុងទសវត្សរ៍កន្លងមកក៏ដោយ ជំពូកនេះបង្ហាញតែពីវឌ្ឍនភាពសំខាន់ៗ ដូចខាងក្រោម :

- ការស្តារឡើងវិញនិងការធ្វើឱ្យប្រសើរឡើងនូវសន្តិភាពនិងសន្តិសុខផ្ទៃក្នុង ដែលមិនអាចវាស់វែងដោយងាយស្រួល ប៉ុន្តែ ជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយ សម្រាប់សកម្មភាពអភិវឌ្ឍន៍នានា ។
- លទ្ធិប្រជាធិបតេយ្យដែលបានចាក់ឫសរួចហើយ បានផ្តល់ដល់ប្រជាពលរដ្ឋគ្រប់រូប នូវកាលានុវត្តភាពនិងការបញ្ចេញសម្លេងស្មើៗគ្នា ដើម្បីបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ សម្រាប់គ្រប់គ្រងប្រទេស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈពេលកំណត់យ៉ាងទៀងទាត់ ។
- ការកែលម្អចម្បងៗក្នុងការពង្រឹងការអនុវត្តច្បាប់ និងថែរក្សានូវបទបញ្ញត្តិច្បាប់និងសណ្តាប់ធ្នាប់សង្គម ។
- ការធ្វើឱ្យប្រសើរឡើងយ៉ាងច្រើន នៅក្នុងសេរីភាពសម្រាប់បុគ្គលម្នាក់ៗ និងសេរីភាពក្នុងការបញ្ចេញមតិយោបល់ តាមរយៈប្រព័ន្ធឃោសនាទាំងអស់ ។
- កំណើនម៉ាក្រូសេដ្ឋកិច្ចប្រកបដោយស្ថេរភាពនិងគួរឱ្យកត់សម្គាល់ (ក្នុងនោះរួមមាន កំណើន *ផសស* សម្រាប់មនុស្សម្នាក់ៗ ការទប់មិនឱ្យមានការកើនឡើងនៃអតិផរណា) ដែលជំរុញដោយការវិនិយោគឯកជន និងជំនួយពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។
- ការធ្វើឱ្យប្រសើរឡើងជាងមុននិងជាប្រចាំ នូវការត្រួតពិនិត្យនិងគ្រប់គ្រងសារពើពន្ធ រួមមាន ការបង្កើនចំណូល និងការបង្វែរចំណាយទៅរកវិស័យសង្គមកិច្ច ។
- ជំរុញការធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងតំបន់និងពិភពលោក ។
- ការកាត់បន្ថយបានយ៉ាងច្រើននូវកម្រិតនៃភាពក្រីក្រ នៅក្នុងតំបន់ដែលអាចប្រៀបធៀបគ្នាបាននៅក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ១៩៩៣-១៩៩៤ និង អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ២០០៣-២០០៤ (សូមមើលប្រអប់ ២.១) ។
- ការធ្វើឱ្យប្រសើរឡើងដែលអាចវាស់វែងបានជាច្រើន នៅក្នុងសូចនាករវិស័យសង្គមកិច្ច ដូចជា : (១) ការពង្រីកការអប់រំនៅបឋមសិក្សា (២) ការកាត់បន្ថយអត្រាមរណភាពទារកនិងកុមារអាយុក្រោម ៥ឆ្នាំ (៣) ការកាត់បន្ថយបានយ៉ាងច្រើននូវជម្ងឺឆ្លង ជាពិសេស ហ៊ីវ/អេដស៍ (៤) ការធ្វើឱ្យប្រសើរឡើងនូវការទទួលបានទឹកស្អាតនៅតំបន់ទីប្រជុំជន និងការទទួលបានសេវាអនាម័យនៅតំបន់ជនបទ (៥) ការ

កាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងស្ទើរតែគ្រប់វិស័យ ជាពិសេសនៅក្នុងការអប់រំបឋមសិក្សា អក្ខរកម្ម មនុស្សពេញវ័យ និងពលកម្មដែលមានប្រាក់ឈ្នួលនៅក្នុងវិស័យកសិកម្មនិងឧស្សាហកម្ម ។

**២.០៤** ការគូសបញ្ជាក់ខាងលើអំពីការខិតខំធ្វើឱ្យប្រសើរឡើងនិងវឌ្ឍនភាពទាំងឡាយ ក៏បានគ្របដណ្តប់លើទិដ្ឋភាពមួយចំនួន ដែលត្រូវដោះស្រាយតាមរយៈ *ផយអជ* ផងដែរ :

- ការកើតមានឡើងនៃភាពក្រីក្រក្នុងកម្រិតប្រមាណ ៤៥.៦ភាគរយ នៅក្នុងតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ គឺជាបញ្ហាមួយ ហើយត្រូវការនូវការកែតម្រូវ (សូមមើលប្រអប់ ២.១) ។
- កំណើនសេដ្ឋកិច្ចនិងវឌ្ឍនភាពទាំងអស់ បានកើតមានឡើង មិនមែនចាំបាច់ដោយសារមានការប្រមូលផ្តុំការយកចិត្តទុកដាក់ខ្ពស់ (ទោះបីមួយចំណែកធំនៃវឌ្ឍនភាពទាំងនោះ ត្រូវបានបង្កើតឡើង ដោយលក្ខខណ្ឌអំណោយផល ដែលបានបង្កឡើងដោយគោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រកបដោយលក្ខណៈវិជ្ជមាននិងជឿនលឿន ក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ចនិងសង្គមកិច្ច ក៏ដោយ) ប៉ុន្តែ ដោយសារការវិនិយោគឬចំណាយទាំងឡាយណា (ទោះបីជាក្នុងទ្រង់ទ្រាយតូចតាចឬមិនផ្តោតចំអាទិភាព) ដែលបានរួមចំណែកជំរុញឱ្យមានកំណើន នៅពេលដែលប្រទេសជាតិបានចាប់ផ្តើមពីចំណុចក្រោមសូន្យ ។ ដូច្នេះ ឥឡូវនេះគឺជាពេល ដែលត្រូវតម្រង់ទិសកំណើនឱ្យបានល្អប្រសើរជាងមុន ។
- កំណើនសេដ្ឋកិច្ច មិនបានកើតមានឡើងស្មើគ្នានៅតាមវិស័យនីមួយៗនោះទេ ដោយសារកំណើននេះបានទទួលរងឥទ្ធិពលដោយផ្ទាល់ពីការរីកចម្រើនយ៉ាងខ្លាំងនៃឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ទេសចរណ៍ និងសំណង់ ។ ដូច្នេះ ស្ថានភាពនេះបានធ្វើឱ្យកំណើនសេដ្ឋកិច្ចងាយរងគ្រោះជាទីបំផុត ជាមួយនឹងវិបត្តិសេដ្ឋកិច្ចក្រៅប្រទេស ។ កំណើនបែបនេះ ត្រូវតែបានពង្រីកនិងពង្រឹង ដើម្បីឱ្យមានចីរភាព សម្រាប់រយៈពេលវែង ។
- កំណើនភាគច្រើនបានកើតឡើងនៅតំបន់ទីប្រជុំជន ដោយប្រមូលផ្តុំយ៉ាងច្រើននៅទីក្រុងភ្នំពេញ ហើយទិសដៅនានារបស់ទេសចរណ៍ មានជាអាទិ៍ សៀមរាបនិងក្រុងព្រះសីហនុ ។ ស្ថានភាពនេះ បង្ហាញឱ្យឃើញថា នៅក្នុងពេលអនាគត ចាំបាច់ត្រូវមានការប្រមូលផ្តុំការយកចិត្តទុកដាក់ឱ្យបានច្រើនជាងមុនជាបន្ទាន់ទៅលើតំបន់ជនបទ ។
- ទោះបីជាមានវឌ្ឍភាពដែលអាចវាស់វែងបាន សូចនាករសុខាភិបាលជាច្រើននៅតែមានកម្រិតទាបនៅឡើយ បើប្រៀបធៀបនឹងបណ្តាប្រទេសដទៃទៀតក្នុងតំបន់ ហើយទន្ទឹមនេះ បញ្ហាជាច្រើនទៀតដូចជាការប្រើប្រាស់គ្រឿងញៀន បាននិងកំពុងលេចឡើងគួរឱ្យកត់សម្គាល់នៅក្នុងចំណោមយុវជន ។

- កំណែទម្រង់អភិបាលកិច្ច (កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិស័យតុលាការ និងកំណែទម្រង់នៅក្នុងវិស័យដែលចាំបាច់) ពុំមានវឌ្ឍនភាពទៅតាមជំហានដែលចង់បាន ដើម្បីផ្តល់នូវបរិយាកាសចាំបាច់ ដែលអំណោយផលសម្រាប់កំណើន ប្រកបដោយលក្ខណៈល្អប្រសើរជាងមុនច្រើន និងប្រកបដោយសមធម៌ រួមទាំង ការទាក់ទាញវិនិយោគឯកជនសម្រាប់រយៈពេលវែង នៅក្នុងវិស័យផ្សេងៗគ្នាជាច្រើន និងនៅតំបន់ជនបទ ។

**២.០៥ ភាពក្រីក្រ :** មូលហេតុចម្បងៗដែលបច្ចុប្បន្ននេះកំពុងត្រូវបានជំនះ គឺស្ថិតនៅនឹងឫសគល់នៃកម្រិតដ៏ទាបនៃការអភិវឌ្ឍរបស់កម្ពុជា ហើយបានធ្វើឱ្យប្រជាជនមួយភាគធំស្ថិតនៅក្រោមកម្រិតនៃការប្រើប្រាស់ទំនិញ និងសេវាកម្មនានាដែលចាំបាច់ជាអប្បបរមា សម្រាប់ធ្វើឱ្យពួកគាត់បានរស់នៅពីលើបន្ទាត់នៃភាពក្រីក្រ ។ ភាពក្រីក្របណ្តាលមកពីមូលហេតុជាច្រើនដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដែលបង្កើតឱ្យមានវដ្តនៃភាពរងគ្រោះ ដូចជា (១) តំបន់រស់នៅដាច់ស្រយាល (២) ប្រាក់ចំណូលឬកាលានុវត្តភាពទាប ឬគ្មានប្រាក់ចំណូលឬកាលានុវត្តភាព (៣) ស្ថានភាពសុខាភិបាលនិងអប់រំទាប (៤) កង្វះនូវធនធានរូបវ័ន្តនិងសម្រាប់ផលិតកម្ម និង/ឬកង្វះនូវលទ្ធភាពទទួលធនធានទាំងនេះ (៥) ការដាក់ឱ្យនៅក្រៅសហគមន៍/សង្គម និងបញ្ហាគ្រឿងញៀន (៦) ព្រមទាំងកត្តា ផ្សេងៗទៀត ។ ដោយបានចាប់ផ្តើមក្នុងឆ្នាំ១៩៧៩ ហើយបានបន្តមកទៀតពីឆ្នាំ១៩៩៣មក ការខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា គឺបានប្រមូលផ្តុំលើការកាត់បន្ថយភាពកម្រិតភាពក្រីក្រ ។ ប្រអប់ខាងក្រោមនឹង បង្ហាញនូវព័ត៌មានលម្អិតជាងនេះ ។

### ប្រអប់ ២.១ : កម្រិតភាពក្រីក្រនៅកម្ពុជា

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាលើកទី១ឆ្នាំ១៩៩៣-១៩៩៤ អាចគ្របដណ្តប់បានតែ ៥៦ភាគរយនៃផ្ទៃប្រទេស និង ៦២ភាគរយនៃប្រជាជន និង ៦៥ភាគរយនៃគ្រួសារទាំងឡាយនៅជនបទ ដោយសារបញ្ហាអសន្តិសុខដែលមាននៅក្នុងតំបន់ខ្លះនាពេលនោះ ។ នៅក្នុងតំបន់ដែលបានគ្របដណ្តប់ ភាពក្រីក្រត្រូវបានធ្វើការវាយតម្លៃថាមានចំនួន ៣៩ភាគរយ ។ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ បានគ្របដណ្តប់ទូទាំងប្រទេស ដោយរួមបញ្ចូលទាំងតំបន់ទាំងអស់ដែលមិនបានបញ្ចូលក្នុងឆ្នាំ១៩៩៣ ។ ដោយផ្អែកលើទិន្នន័យឆ្នាំ២០០៤ កម្រិតភាពក្រីក្រនៅកម្ពុជាមានជាអាទិ៍ដូចខាងក្រោម (សូមមើលឧបសម្ព័ន្ធ ៣ សម្រាប់ព័ត៌មានលម្អិតដែលរួមបញ្ចូលទាំងតំបន់ ដែលមិនបានបញ្ចូលក្នុងការធ្វើអង្កេតឆ្នាំ១៩៩៣-១៩៩៤):

| | | |
|---|---|---|
| ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ : | ១៩៩៣-១៩៩៤ (៥៩ភាគរយនៃផ្ទៃប្រទេស) | ៣៩,០០ |
| | ២០០៤ (ទូទាំងប្រទេស) | ៣៤,៧០ |
| | ២០០៤ (តំបន់ក្នុងឆ្នាំ១៩៩៣-១៩៩៤) | ២៨,០០ |
| ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារ : | ១៩៩៣-១៩៩៤ (៥៩ភាគរយនៃផ្ទៃប្រទេស) | ២០,០០ |
| | ២០០៤ (ទូទាំងប្រទេស) | ១៩,៧០ |
| | ២០០៤ (តំបន់ក្នុងឆ្នាំ១៩៩៣-១៩៩៤) | ១៤,២០ |

នៅក្នុងតំបន់ទាំងនោះ (៥៩ភាគរយ) ដែលបានគ្របដណ្តប់ដោយការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចទាំង២លើក គឺនៅឆ្នាំ១៩៩៣-១៩៩៤ និងឆ្នាំ ២០០៣-២០០៤ សន្ទស្សន៍ភាពក្រីក្របានធ្លាក់ចុះ ១១ភាគរយ ក្នុងរយៈពេល ១១ឆ្នាំ គិតពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៤ ឬប្រហែល ១ភាគរយក្នុង១ឆ្នាំ ចំណែកឯប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារបានធ្លាក់ចុះពី ២០ភាគរយ មកត្រឹម ១៤,២០ភាគរយ ឬប្រហែល ០,៥០ភាគរយក្នុង១ឆ្នាំ ។ ការគណនាយ៉ាងសាមញ្ញមួយ ដែលផ្អែកលើតួលេខទាំងនេះ បង្ហាញថា ការប៉ាន់ស្មានសម្រាប់ឆ្នាំ២០០៤សម្រាប់តំបន់ ដែលមិនបានគ្របដណ្តប់ដោយការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ (៤១ភាគរយ) គឺប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រមាន ៤៥,៦ភាគរយ ហើយប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារមាន ២៨,៧ភាគរយ ។

ការរកឃើញសំខាន់ៗមួយចំនួនផ្សេងទៀត នៃការសិក្សាស្រាវជ្រាវ (សូមមើលឧបសម្ព័ន្ធ ៣) មានដូចខាងក្រោម :

- ៩០ភាគរយនៃអ្នកក្រីក្ររស់នៅតំបន់ជនបទ ដែលទទួលរងឥទ្ធិពលពីផលិតភាពទាបក្នុងវិស័យកសិកម្ម និងពីលទ្ធភាពទទួលបានក្នុងកម្រិតទាបនូវសេវាកម្មជាច្រើនផ្សេងទៀត ។
- ភាពក្រីក្របានធ្លាក់ចុះនៅតំបន់ជនបទក្នុងល្បឿនមួយយឺតជាងច្រើន បើធៀបនឹងតំបន់ទីប្រជុំជន ។
- សូម្បីតែនៅក្នុងចំណោមអ្នកក្រីក្រ ចំណែកមួយធំជាងមុននៃអ្នកទាំងនោះ បានស្ថិតនៅក្បែរបន្ទាត់ភាពក្រីក្រជាងមុន នាពេលបច្ចុប្បន្ននេះ ដោយបង្ហាញថា តួលេខទាំងនេះបង្ហាញថា ចំណុចដៅទាំងឡាយនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក្នុងការកាត់បន្ថយកម្រិតសរុបនៃភាពក្រីក្រ ឱ្យមកនៅត្រឹម ២៥ភាគរយ ក្នុងឆ្នាំ២០១០ និង ១៩,៥ភាគរយនៅឆ្នាំ២០១៥ ហើយនិងកម្រិតភាពក្រីក្រម្ហូបអាហារឱ្យមកនៅត្រឹម ១៣ភាគរយ ក្នុងឆ្នាំ២០១០ និង១០ភាគរយ ក្នុងឆ្នាំ២០១៥ អាចសម្រេចទៅបាន បើសិនជាសកម្មភាពសំខាន់ៗត្រូវបានចាប់ផ្តើមជាមួយ *ផយអជ* ។

គួរកត់សម្គាល់ថា ការធ្លាក់ចុះយ៉ាងខ្លាំងនៃកម្រិតភាពក្រីក្រក្នុងតំបន់ ៥៦ភាគរយនៃតំបន់ជនបទទូទាំងកម្ពុជា ដែលបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៣-១៩៩៤ បានកើតមានឡើងដោយសារការអភិវឌ្ឍជាទូទៅនៃសេដ្ឋកិច្ច-សង្គមកិច្ច ដូចជា កំណើនម៉ាក្រូសេដ្ឋកិច្ច ការកើនឡើងជាបន្តបន្ទាប់ក្នុងផលិតកម្មកសិកម្ម ការវិនិយោគក្នុងផ្នែកអប់រំនិងសុខាភិបាល ។ល។ តាមរយៈគោលនយោបាយដែលមានការតម្រង់ទិសច្បាស់លាស់ និងសកម្មភាពដែលត្រូវធ្វើដោយរាជរដ្ឋាភិបាល ប៉ុន្តែមិនមែនដោយសារយុទ្ធសាស្ត្រនិងសកម្មភាពទាំងឡាយ ដែលមានផែនការច្បាស់លាស់និងផ្តោតទៅលើតែការកាត់បន្ថយភាពក្រីក្រទេ ។ តំបន់ទាំងនេះ នឹងបន្តរីកចម្រើន និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍជាទូទៅនៃសេដ្ឋកិច្ច-សង្គមកិច្ច ដែលនឹងកើតមានឡើងក្នុងរយៈពេលនៃ *ផយអជ* ។ កម្រិតភាពក្រីក្រក្នុងតំបន់ទាំងនេះអាចបន្តធ្លាក់ចុះ ហើយអាចចុះហួសពីចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលមានកម្រិត ២៥ភាគរយ ក្នុងឆ្នាំ២០១០ និង ១៩,៥ភាគរយក្នុងឆ្នាំ២០១៥ ។ ទោះជាដូចនេះក្តី សូម្បីតែក្នុងតំបន់ទាំងនោះ ភូមិនិងឃុំដាច់ស្រយាល និងភូមិ-ឃុំដែលមានប្រជាជនក្រីក្រច្រើន ត្រូវតែទទួលបានការយកចិត្តទុកដាក់ជាពិសេស ។ វិធីសាស្ត្រមួយដែលមានលក្ខណៈស្តង់ដារ សម្រាប់ការកំណត់គ្រួសារក្រីក្រ កំពុងត្រូវបានរៀបចំកសាងឡើង ។

**២.០៦** *ជំពូកនេះ ពិនិត្យឡើងវិញជាលម្អិត អំពីវឌ្ឍនភាពចម្បងៗមួយចំនួនដែលត្រូវបានបង្កើតឡើងចាប់ពីឆ្នាំ ២០០០* រហូតមកដល់បច្ចុប្បន្ន និងសង្កេតពីស្ថានភាពទូទៅដែលកំពុងកើតមាន[១] ។ ទម្រង់នៃជំពូកនេះ ត្រូវរៀបចំឡើង ទៅតាមក្របខ័ណ្ឌនៃយុទ្ធសាស្ត្រចតុកោណ ហើយជំពូកនេះនឹងបង្ហាញពីការវិវឌ្ឍនិងស្ថានភាពនៃបញ្ហាតាមវិស័យនិងបញ្ហាអន្តរវិស័យទាំងឡាយ ដែលបានកំណត់នៅក្នុងមុំទាំងឡាយរបស់យុទ្ធសាស្ត្រចតុកោណ ។

## អភិបាលកិច្ចល្អ

**២.០៧** កត្តាទាំងឡាយដូចជា សន្តិភាព ស្ថេរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ការគ្រប់គ្រងដោយច្បាប់ ការថែរក្សាច្បាប់និងសណ្តាប់ធ្នាប់ ដែលកំពុងតែស្ថិតនៅក្នុងស្ថានភាពមួយមានតុល្យភាពជាមួយគ្នាទៅវិញទៅមក គឺជាប្រការសំខាន់និងជាបុរេលក្ខខណ្ឌ មិនត្រឹមតែសម្រាប់ការថែរក្សាសមិទ្ធផលពីអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់កំណើន ដែលមានសារៈប្រយោជន៍និងប្រកបដោយចីរភាព ។ កត្តាទាំងអស់នេះរួមគ្នាបង្កើតឱ្យមាន "*អភិបាលកិច្ចល្អ*" ដែលជាស្នូលរបស់យុទ្ធសាស្ត្រចតុកោណ ។

**២.០៨** *លទ្ធិប្រជាធិបតេយ្យ* (ដែលជាឱកាសសម្រាប់ប្រជាជនបញ្ចេញសម្លេងក្នុងការជ្រើសរើសអ្នកដឹកនាំរបស់ខ្លួនតាមកាលវេលាកំណត់ តាមរយៈការបោះឆ្នោតជ្រើសរើសស្ថាប័ននយោបាយនិងនីតិបញ្ញត្តិ) បានចាក់គ្រឹះរឹងមាំរួចហើយនៅកម្ពុជា ។ គណៈកម្មការជាតិបោះឆ្នោតឯករាជ្យមួយ រៀបចំនិងដឹកនាំការបោះឆ្នោតប្រជាធិបតេយ្យដោយផ្អែកលើសិទ្ធិបោះឆ្នោតនៃអ្នកដែលគ្រប់វ័យបោះឆ្នោតពេញលេញ ។ ការបោះឆ្នោតទូទៅលើកទី៣ ត្រូវបានប្រារព្ធធ្វើឡើងនៅឆ្នាំ២០០៣ ដើម្បីបង្កើតសភាជាតិថ្មី ។ ការបោះឆ្នោតនេះ ត្រូវបានទទួលស្គាល់ជាទូទៅពីអ្នកសង្កេតការអន្តរជាតិឯករាជ្យ ថាមានលក្ខណៈសេរីនិងយុត្តិធម៌ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដោយផ្តល់នូវលទ្ធផលសរុបមួយ គឺអសនៈសភាជាង៥០ភាគរយ ត្រូវបានផ្តល់ទៅឱ្យគណៈបក្សមួយ ប៉ុន្តែតិចជាង២/៣ ដែលចាំបាច់សម្រាប់ការបង្កើតឡើងនូវរាជរដ្ឋាភិបាលមួយ ដោយបាននាំទៅដល់ការអូសបន្លាយការចរចាក្នុងការបង្កើតរាជរដ្ឋាភិបាលចម្រុះថ្មីមួយ ។ ទោះបីជាមានការពន្យាររបៀបនេះក៏ដោយ រាជរដ្ឋាភិបាលអាណត្តិចាស់បានដំណើរការទៅមុខយ៉ាងលឿន ជាមួយនឹងការកែទម្រង់ និងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ ។

**២.០៩** នៅពេលចាប់ផ្តើមដំណើរការសម្រាប់អាណត្តិទី៣នៃរដ្ឋសភាក្នុង ខែកក្កដា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានអនុម័តយកនូវយុទ្ធសាស្ត្រដ៏ទូលំទូលាយមួយសម្រាប់អនាគត ។ យុទ្ធសាស្ត្រនេះត្រូវបានហៅថា *យុទ្ធសាស្ត្រ*

[១] ទិន្នន័យទាំងអស់ដែលបានយកមកប្រើប្រាស់រហូតមកដល់ពេលបញ្ចប់ឯកសារនេះ គឺជាទិន្នន័យថ្មីៗបំផុតដែលមានរួមទាំងទិន្នន័យដែលបានកមពីការធ្វើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៣-២០០៤ ដែលត្រូវបានយកមកបង្ហាញរួចហើយកាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៥ តែមិនទាន់បោះពុម្ពផ្សាយ ។ ទិន្នន័យថ្មីៗ អាចបានមកពីការច្របាច់បញ្ចូលគ្នានូវលទ្ធផលនៃការសិក្សានិងការអង្កេតផ្សេងទៀត ដោយរួមទាំងការអង្កេតពីរដែលកំពុងដំណើរការគឺ អង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជាឆ្នាំ២០០៥ និងការវាយតំលៃភាពក្រីក្រដោយមានការចូលរួម ដែលបានរៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។

*ចតុកោណ*[១] ដែលគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃអភិបាលកិច្ចនិងការអភិវឌ្ឍដោយមាន *អភិបាលកិច្ចល្អ* ជាស្នូលនៃក្របខ័ណ្ឌយុទ្ធសាស្ត្រទាំងមូលនេះ និងមានបរិស្ថានសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ព្រមទាំងមានមុំចតុកោណពិសេសចំនួនបួនដែលគ្របដណ្តប់បញ្ហាអភិវឌ្ឍន៍ដូចជា ការលើកស្ទួយវិស័យកសិកម្ម ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការអភិវឌ្ឍផ្នែកឯកជននិងការងារ និងការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស ។ មុំនីមួយៗនៃចតុកោណមានធាតុសំខាន់ៗបួន ដែលត្រូវដោះស្រាយជាលក្ខណៈប្រព័ន្ធ ។

**២.១០** សន្តិភាពពេញលេញបានកើតមានឡើងនៅទូទាំងកម្ពុជា ដោយសារគណបក្សទាំងអស់បានជ្រើសរើសផ្លូវនៃលទ្ធិប្រជាធិបតេយ្យដើម្បីផ្សះផ្សារភាពមិនចុះសម្រុងគ្នាតាមរយៈមធ្យោបាយសន្តិវិធី ។ រហូតមកទល់ពេលនេះពុំទាន់មានការវាស់វែងណាមួយដែលត្រូវបានយកមកប្រើសម្រាប់កំណត់ថា សន្តិភាពមានតម្លៃយ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍ ។ *សណ្តាប់ធ្នាប់សាធារណៈនិងការប្រកាន់ខ្ជាប់នូវច្បាប់ទាំងឡាយ* មានភាពប្រសើរឡើងច្រើន ហើយឧក្រិដ្ឋកម្មបានថយចុះយ៉ាងខ្លាំង ។ សហគមន៍ទាំងអស់រស់នៅជាមួយគ្នា ក្នុងភាពសុខដុមដោយគ្មានការភ័យខ្លាច និងដោយមានកិច្ចសហប្រតិបត្តិការគ្នា ។

**២.១១** ការបង្កើតឡើងឱ្យមានប្រព័ន្ធដែលមានការចូលរួមយ៉ាងទូលំទូលាយ គឺជាប្រការចាំបាច់ សម្រាប់ផ្តល់ឱកាសឱ្យថ្នាក់មូលដ្ឋានមានការពាក់ព័ន្ធនៅក្នុងការងារអភិបាលកិច្ចល្អ ។ កម្ពុជាបានរៀបចំ*ការបោះឆ្នោតថ្នាក់ឃុំ-សង្កាត់* លើកដំបូង ដើម្បីជ្រើសរើសតំណាង សម្រាប់បង្កើតឡើងនូវក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីគ្រប់គ្រងឃុំ-សង្កាត់ចំនួន ១.៦២១ នៅទូទាំងប្រទេស ដែលជាការចាប់ផ្តើមលទ្ធិប្រជាធិបតេយ្យដ៏មានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន ។ យើងគួររំឭកជាថ្មីម្តងទៀតថា ការបោះឆ្នោតនេះត្រូវបានប្រព្រឹត្តទៅដោយសេរីនិងយុត្តិធម៌ពេញលេញ ដោយមានអ្នកចូលរួមបោះឆ្នោតគ្រប់ៗរូប ។ ឃុំ-សង្កាត់ បានចាប់ផ្តើមដំណើរការងារយ៉ាងល្អប្រសើរចាប់តាំងពីពេល នោះមក ។

**២.១២** អស់រយៈពេលជិតបួនឆ្នាំកន្លងមកហើយ ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្លាស់ប្តូរស្ថានភាពដឹកនាំរដ្ឋាភិបាល ពីប្រព័ន្ធមជ្ឈការមកជាប្រព័ន្ធវិមជ្ឈការ តាមរយៈការបោះឆ្នោតសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាអាជ្ញាធរនៅថ្នាក់រដ្ឋបាលទាបជាងគេបំផុត ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមបែបប្រជាធិបតេយ្យជាលើកដំបូងបំផុតនៅឆ្នាំ២០០២ ។ កម្មវិធីសិលារបស់រាជរដ្ឋាភិបាលកម្ពុជា ជាកម្មវិធីមួយក្នុងចំណោមកម្មវិធីនានា ដែលបានរួមចំណែកក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ ។ នៅដំណាក់កាលដំបូងនៃការអនុវត្ត រាជរដ្ឋាភិបាលកម្ពុជា បានទទួលនូវសមិទ្ធិផលមួយចំនួន ដូចជា ការពង្រឹងអភិបាលកិច្ចបែបប្រជាធិបតេយ្យ ការចូលរួមកាត់បន្ថយភាពក្រីក្រ ការកសាងធនធានមនុស្សនៅមូលដ្ឋានជាដើម ។ នេះគឺជាផល

[១] សូមមើលគំនូសបំព្រួញសង្ខេប

ប៉ះពាល់យ៉ាងជ្រាលជ្រៅដល់ការពង្រីក និងពង្រឹងអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ជាមួយនិងការរីកដុះដាលនៃវប្បធម៌នៃការចូលរួមជាតំណាង ការទទួលខុសត្រូវ ការចូលរួមដោយផ្ទាល់ និងគណនេយ្យភាព ។ ហេតុដូចនេះ ដើម្បីជំរុញ និងញ៉ាំងឱ្យដំណើរការនានាក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តនៅមូលដ្ឋានដោយមានការចូលរួមសម្រាប់ការអភិវឌ្ឍ ឯកសារ *ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* បានត្រូវអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងខែ មិថុនា ឆ្នាំ២០០៥ កន្លងមកនេះ ។ ដោយមាន នីតិវិធី និងគោលការណ៍ណែនាំច្បាស់លាស់និងទូលំទូលាយ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះនឹងជួយឱ្យការផ្ទេរអំណាច ការទទួលខុសត្រូវ និងធនធានថែមទៀតសម្រាប់ការអភិវឌ្ឍនៅថ្នាក់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ ។ *ច្បាប់អង្គការ* គឺជាឧបករណ៍គតិយុត្តិដ៏ចំបងបំផុតសម្រាប់ការអនុវត្តអភិបាលកិច្ចនៅថ្នាក់រដ្ឋបាលក្រោមជាតិ ។

**២.១៣** រាជរដ្ឋាភិបាលកម្ពុជា បានអនុម័ត *ផែនការសកម្មភាពអភិបាលកិច្ចទី១ (ផសអ១)* ក្នុងខែមីនា ឆ្នាំ ២០០១ ។ ផែនការសកម្មភាពអភិបាលកិច្ចនេះ គឺជាឯកសារមួយដែលប្រមូលផ្តុំដោយសង្ខេបនូវផែនការនិងកម្មវិធីការងារចំនួនជាងមួយរយ សម្រាប់កែលម្អអភិបាលកិច្ចក្នុងវិស័យ៧ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងយុត្តិធម៌សង្គម ។ ភាគច្រើនបំផុតនៃផែនការនិងកម្មវិធីការងារទាំងនេះ បានសំដៅដោះស្រាយនូវមូលហេតុចម្បងនៃអភិបាលកិច្ចទន់ខ្សោយនិងអំពើពុករលួយ ។ តាមរយៈយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលបានអនុម័តនៅក្នុងខែធ្នូ ឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ជាថ្មីម្តងទៀតពីការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីពង្រឹងស្ថាប័ននិងដើម្បី កែលម្អអភិបាលកិច្ចក្នុងការងារអន្តរវិស័យសំខាន់ៗចំនួន ៤ : ការកែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ការកែទម្រង់រដ្ឋបាល ប្រជាធិបតេយ្យភាវូបនីយកម្ម និងអភិបាលកិច្ចមូលដ្ឋាន និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ *ផែនការសកម្មភាពអភិបាលកិច្ចទី២ (ផសអ២)* ២០០៥-២០០៨ ដែលគ្របដណ្តប់លើវិស័យកំណែទម្រង់សំខាន់ៗចំនួន ៩ ដែលមានភាពប្រទាក់ក្រឡាគ្នា និងដែលមានឥទ្ធិពលផ្ទាល់ទៅលើការកាត់បន្ថយភាពក្រីក្រ ត្រូវបានរៀបចំកសាងឡើង ហើយនឹងត្រូវបញ្ចប់ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ។

**២.១៤** រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា "*<u>អំពើពុករលួយ</u>* គឺជាបញ្ហារួមមួយដែលមានពាសពេញពិភពលោក ដែលអាចកាត់បន្ថយបាន តែតាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងប្រទេសនានា ។ សកម្មភាពពុករលួយ គឺជាលទ្ធផលនៃកាលានុវត្តភាព តរិយាបទ និងហានិភ័យ ។ វិធីសាស្ត្រសម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយអាចត្រូវតែមានលក្ខណៈប្រមូលផ្តុំគ្រប់សកម្មភាពចាំបាច់ៗ មានការចូលរួម មានលក្ខណៈសន្សឹមៗនិងប្រកបដោយចីរភាព" ។ នៅពេលដែលសេរីភាពឬអំណាចក្នុងការសម្រេចអ្វីមួយដោយគ្មានការត្រួតពិនិត្យរបស់បុគ្គលម្នាក់ ដែលត្រូវប្រគល់ភារកិច្ចឱ្យអនុវត្តការងារជាមួយអ្នកដទៃទៀតកាន់តែខ្ពស់ នោះលទ្ធភាពនៃអំពើពុករលួយក៏កាន់តែខ្ពស់ដែរ ។ ការទទួលបានផលចំណេញមិនស្របច្បាប់និងមិនត្រឹមត្រូវ ជាលក្ខណៈបុគ្គល ជារូបភាពសាច់ប្រាក់ សម្ភារៈ ឬសេវាកម្មផ្សេងៗ ដោយការបំពេញភារកិច្ចឬមួយដោយការផ្តល់ ការយោគយល់អនុគ្រោះ

ខុសឆ្គង ក្នុងតម្លៃមួយដែលត្រូវចំណាយទ្រព្យធនសាធារណៈ ជាធម្មតា តម្រូវឱ្យអំពើពុករលួយមានលក្ខណៈស្ងាត់កំបាំងលួចលាក់ ។ អំពើពុករលួយមិនអាចវាស់វែងច្បាស់លាស់បានទេ ប៉ុន្តែឥទ្ធិពលអាក្រក់របស់វាជ្រាបចូលទៅក្នុងគ្រប់សកម្មភាពរបស់រដ្ឋាភិបាល ។ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តហើយ នឹងអនុវត្តការប្រយុទ្ធប្រឆាំងតាមមធ្យោបាយចំរុះ ចំពោះបាតុភូតសេដ្ឋកិច្ចនិងសង្គមដ៏អាក្រក់នេះ ដែលរារាំងដល់កំណើនប្រកបដោយសមធម៌ ដែលមិនលើកទឹកចិត្តដល់ការវិនិយោគទុនឯកជន និងដែលមិនផ្តល់ផលប្រយោជន៍ដល់អ្នកក្រ ។ គោលដៅនៃការងារនេះ គឺត្រូវកាត់បន្ថយកាលានុវត្តភាពទាំងអស់ សម្រាប់អំពើពុករលួយ តាមរយៈច្បាប់និងនីតិវិធីច្បាស់លាស់ តម្លាភាព ការទទួលខុសត្រូវខ្ពស់ និងភាពដែលអាចដឹងមុនបានរួមផ្សំជាមួយនឹងការដាក់ពិន័យយ៉ាងតឹងរ៉ឹង ចំពោះជនទាំងឡាយណាដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើពុករលួយ ។ វឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាច្រើន ត្រូវបានធ្វើឡើងនៅក្នុងការគ្រប់គ្រងចំណូលថវិការបស់រដ្ឋាភិបាល និងក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ សេចក្តីព្រាង *ច្បាប់ប្រឆាំងអំពើពុករលួយ* ដែលសមស្របទៅនឹងការអនុវត្តយ៉ាងល្អប្រសើររបស់អន្តរជាតិ កំពុងត្រូវបានបញ្ចប់ បន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយនិងស៊ីជម្រៅ ជាមួយនឹងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ។ រាជរដ្ឋាភិបាល បានពង្រឹង *អាជ្ញាធរសវនកម្មជាតិ* ហើយបានពង្រីកលទ្ធភាពនៃការអនុវត្តអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ ចំពោះការចំណាយរបស់ក្រសួងនិងស្ថាប័នទាំងអស់ ។ ប្រព័ន្ធសវនកម្មផ្ទៃក្នុងមួយ សម្រាប់ស្ថាប័នរដ្ឋាភិបាលទាំងមូលកំពុងត្រូវបានបង្កើតឡើង ។ ជាមួយនឹងទំហំនិងរូបភាពផ្សេងៗគ្នានៃបញ្ហាពុករលួយ ចាំបាច់ត្រូវតែមានដំណោះស្រាយរយៈពេលខ្លីនិងវែង នៅក្នុងការងារមួយចំនួនដោយចាប់ផ្តើមពីការតម្លើងប្រាក់បៀវត្សមន្ត្រីរាជការ "*ការផ្លាស់ប្តូរវប្បធម៌មិនល្អនៅក្នុងការងារ*" ដល់ការរៀបចំក្របខ័ណ្ឌស្ថាប័នសម្រាប់ប្រព័ន្ធត្រួតពិនិត្យនិងតុល្យការអំណាច និងការដាក់ពិន័យដល់អ្នកដែលប្រព្រឹត្តបទល្មើស ។

**២.១៥** បញ្ហាមួយទៀតនៃអភិបាលកិច្ចល្អ គឺប្រព័ន្ធយុត្តិធម៌មួយ ដែលឯករាជ្យអព្យាក្រឹត្យ មានគុណភាព មានជំនាញវិជ្ជាជីវៈ មានសមត្ថភាព និងមានប្រសិទ្ធភាព ។ ចាប់ផ្តើមចេញពីស្ថានភាពដ៏លំបាក ខ្វះខាតសព្វបែបយ៉ាង រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងរៀបចំដាក់ចេញនូវច្បាប់សំខាន់មួយចំនួន ដើម្បីបំពេញក្របខ័ណ្ឌគតិយុត្តិ ដែលមានជាអាទិ៍ : ច្បាប់ដែលទាក់ទងនឹងសិទ្ធិមនុស្ស ច្បាប់វិនិយោគ ច្បាប់ពាណិជ្ជកម្មនិងជំនួញ និងច្បាប់ពាក់ព័ន្ធដល់ការគ្រប់គ្រងធនធានធម្មជាតិ ។ យុទ្ធសាស្ត្រសម្រាប់*កំណែទម្រង់ច្បាប់និងតុលាការ* ត្រូវបានអនុម័តនៅខែមិថុនា ឆ្នាំ២០០៣ ។ ប្រាក់បំណាច់សម្រាប់ចៅក្រមនិងអយ្យការ ត្រូវបានដំឡើងឱ្យបានខ្ពស់សមរម្យពីខែមករា ឆ្នាំ២០០៣ ។ ច្បាប់មូលដ្ឋានសំខាន់ៗសម្រាប់វិស័យតុលាការត្រូវបានរៀបចំ និងកំពុងដាក់ឱ្យធ្វើការពិភាក្សា ។ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវីកំពុងដំណើរការ ។ ការងារជា

ច្រើនផ្សេងទៀតក៏កំពុងដំណើរការផងដែរ[១] ។ កម្មវិធីសកម្មភាពដ៏ច្បាស់លាស់មួយត្រូវបានអនុម័តក្នុងពេលថ្មីៗនេះ ។ ការកែទម្រង់ក្នុងវិស័យនេះត្រូវតែអនុវត្តដោយយកចិត្តទុកដាក់និងជាបន្ទាន់ ។

**២.១៦** *កំណែទម្រង់រដ្ឋបាលសាធារណៈ* គឺជាការងារមួយក្នុងចំណោមការងារកំណែទម្រង់អភិបាលកិច្ចទាំងបួនរបស់រាជរដ្ឋាភិបាល ។ មុខងារសាធារណៈមួយដែលមានជំនាញ សមត្ថភាព ប្រសិទ្ធភាព និងតម្លាភាព ភាពស័ក្តិសិទ្ធ សម្រាប់ធ្វើឱ្យរដ្ឋបាលអាចក្លាយជាកត្តានិងដៃគូមួយដ៏មានតម្លៃនិងគួរឱ្យទុកចិត្ត នៅក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ ។ នៅចុងដំណាក់កាលនៃរបបប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៩ ស្ថាប័នរដ្ឋ រួមមានទាំងផ្នែករដ្ឋបាលផងដែរ ត្រូវបានបំផ្លាញ ។ រដ្ឋាភិបាលទាំងអស់ដែលបានគ្រប់គ្រងប្រទេសបន្ទាប់ពីពេលនោះមក បានកសាងឡើងវិញ និងពង្រឹងនូវការងាររដ្ឋបាល ក្នុងជំហានជាច្រើន ។ នៅចុងបញ្ចប់នៃនីតិកាលទី២នៃរដ្ឋសភាក្នុងឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានកសាងមូលដ្ឋានគ្រឹះទាំងឡាយសម្រាប់កំណែទម្រង់ប្រកបដោយចីរភាព ក្នុងគោលបំណងធ្វើឱ្យរដ្ឋបាលនិងមុខងារសាធារណៈ ក្លាយជាដៃគូអភិវឌ្ឍន៍ដែលអាចជឿទុកចិត្តបាន និងជា អ្នកផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ។ វឌ្ឍនភាពនៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ រួមមានៈ (១) រដ្ឋបាលត្រូវបានរៀបចំ ឱ្យមានទម្រង់ឯកភាពគ្នា (២) ក្របខ័ណ្ឌច្បាប់ត្រូវបានដាក់ឱ្យអនុវត្ត (៣) ប្រាក់បៀវត្សរ៍ជាមធ្យមបានកើន ឡើងរហូតដល់ប្រមាណ ១១៦ភាគរយ ចាប់តាំងពីខែមករា ឆ្នាំ២០០២ ដោយមិនរាប់បញ្ចូលនូវប្រាក់បំណាច់សម្រាប់គ្រួសារនិងហានិភ័យ និង (៤) ប្រព័ន្ធថ្មីៗសម្រាប់គ្រប់គ្រងកម្លាំងពលកម្ម និងសម្រាប់លើកកម្ពស់ការអនុវត្តការងារ ត្រូវបានរៀបចំឱ្យបង្កើតឡើង ។

**២.១៧** *កម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាល* មានទិសដៅជាយុទ្ធសាស្ត្របួនៈ (១) កែលម្អការផ្តល់សេវាសាធារណៈ (២) បង្កើនប្រាក់បៀវត្សរ៍ និងពង្រឹងការគ្រប់គ្រងនិយោជន៏ (៣) អភិវឌ្ឍសមត្ថភាពស្ថាប័ន (៤) ជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ ។ វិធីសាស្ត្រនេះ គឺត្រូវផ្សារភ្ជាប់កំណែទម្រង់នានាទៅនឹងស្ថានភាពជាក់ស្តែងរបស់កម្ពុជា នៅពេលដែលប្រើប្រាស់របៀបរបបដ៏ប្រសើរបំផុតក្នុងការអនុវត្តការងារ និងឧបករណ៍ថ្មីៗ ដូចជា *កន្សោមអាទិភាព* ដើម្បីបង្កើនល្បឿនការងារស្នូលរបស់ក្រសួង-ស្ថាប័ន ។ កំណែទម្រង់ទាំងឡាយ ដូចជា ការរៀបចំឡើងវិញ ត្រូវតែយកមកដោះស្រាយដោយផ្អែកលើមូលដ្ឋានដែលមាន ។ គំនិតផ្តួចផ្តើមសំខាន់ៗ នឹងត្រូវរៀបចំឡើងដោយផ្អែកលើគោលការណ៍ ៦ៈ (១) ទស្សនៈរបស់អតិថិជន (២) ភាពម្ចាស់ការ (៣) ចីរភាព (៤) ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច (៥) ភាពរលូនរវាងស្ថាប័ននានារបស់រដ្ឋ (៦) ទម្លាប់និងការសម្រេចចិត្តដែលមានកន្លងមក ។ ការងារជាច្រើនស្ថិតនៅចំពោះមុខ សម្រាប់ធ្វើឱ្យសម្រេចនូវគោលដៅរួមនៃកំណែទម្រង់រដ្ឋបាល ត្រូវយកមកដោះស្រាយដែលធ្វើឱ្យកំណែទម្រង់នេះក្លាយជាកិច្ចការមួយដែលមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដ ។

---

[១] ការងារទាំងនោះនឹងលើកឡើងនៅក្នុងជំពូកទី ៤

**២.១៨** កំណែទម្រង់កម្លាំងប្រដាប់អាវុធនិងការរំសាយកងទ័ព កំពុងបន្តដំណើរការ ហើយសមាមាត្រនៃថវិកាសម្រាប់វិស័យការពារជាតិនិងសន្តិសុខ (រួមទាំងសន្តិសុខផ្ទៃក្នុង) កំពុងមានការថយចុះពី ៦,៧ភាគរយនៃ *ផសស* នៅឆ្នាំ១៩៩៤ ដល់ ២,៥ភាគរយ ក្នុងឆ្នាំ២០០៥ ហើយនឹងស្ថិតនៅថេរជុំវិញអត្រានេះ ។ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការប្តេជ្ញាយ៉ាងខ្លាំងក្នុងការកែទម្រង់កងទ័ព នៅក្នុងគោលបំណងកសាងនូវកម្លាំងប្រដាប់អាវុធមួយដែល មានទំហំនិងគុណភាពសមស្រប ដើម្បីការពារប្រទេសក្នុងពេលសន្តិភាព ។ ការងារដែលសម្រេចបានរហូតមកទល់នឹងពេលនេះទទួលបាននូវលទ្ធផលគួរកត់សម្គាល់ ។ រចនាសម្ព័ន្ធចាត់តាំងសម្រាប់អង្គភាពនានារបស់កងទ័ព ទ័ពជើងគោក ទ័ពជើងទឹក និងអង្គភាពពិសេសដទៃទៀត ត្រូវបានធ្វើការកែសម្រួលឡើងវិញ ។ ប្រព័ន្ធនៃការតម្លើងឋានន្តរស័ក្តិក៏ត្រូវបានរៀបចំសារជាថ្មីឡើងវិញដែរ ។ ការរៀបចំឡើងវិញនូវមុខងារតួនាទីរបស់អង្គភាពក្រោម១ទៀត ត្រូវបានធ្វើឡើងដោយប្រយ័ត្នប្រយែង ។ "*សៀវភៅសការពារជាតិ*" ដ៏ទូលំទូលាយមួយស្តីពីគោលនយោបាយការពារជាតិត្រូវបានរៀបចំឡើង ។

## បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

**២.១៩** ក្រៅពីវឌ្ឍនភាពក្នុងការបង្កើតឱ្យមានសន្តិភាព ស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម (បានលើកឡើងរួចហើយ) កម្ពុជាបានធ្វើសមាហរណកម្មទៅក្នុងតំបន់ ដោយបានចូលជាសមាជិកអាស៊ាន និងដោយបានចូលរួមក្នុងសកម្មភាពនានារបស់អង្គការនេះ រួមទាំងការធ្វើជាម្ចាស់ផ្ទះសម្រាប់ការប្រជុំកំពូលមួយនៅឆ្នាំ២០០២ ។ ទោះជាយ៉ាងដូចនេះក្តី ការចូលរួមនេះត្រូវពង្រីកនិងពង្រឹងជាបន្ថែមទៀត ។ ទន្ទឹមនេះ កម្ពុជាក៏បាននិងកំពុងធ្វើសមាហរណកម្មខ្លួនឯងផងដែរទៅក្នុងពិភពលោក ដោយបានចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោកនាឆ្នាំ២០០៤ ។ ការចូលជាសមាជិកអង្គការនេះបាន បង្កើននូវការទទួលខុសត្រូវច្រើនជាងមុន ក្នុងការអនុវត្តឱ្យបានទៅតាមវិធីពិធីនិងស្តង់ដារនានា ប៉ុន្តែក៏បានបើកចំហឱ្យមានកាលានុវត្តភាពយ៉ាងច្រើនផងដែរសម្រាប់ការធ្វើពាណិជ្ជកម្មជាមួយពិភពលោក ដោយឈរលើមូលដ្ឋាននៃការប្រកួតប្រជែង ។ ប៉ុន្តែ កាលានុវត្តភាពត្រូវតែបានបង្កើតឱ្យមានច្រើនជាងមុនទៀត ដើម្បីទាញយកប្រយោជន៍ពីសេវាពាណិជ្ជកម្មទាំងអស់ ហើយដើម្បីពង្រីកចំនួនផលិតផលដែលត្រូវនាំចេញពីកម្ពុជា ដែលបច្ចុប្បន្ននេះ ប្រមូលផ្តុំយ៉ាងច្រើនតែលើផលិតផលសម្លៀកបំពាក់ ។ ការងារដែលមានសារៈសំខាន់ចម្បង គឺត្រូវកាត់បន្ថយការចំណាយខ្ពស់នៃអន្តរកម្ម ដែលធ្វើឱ្យអ្នកវិនិយោគរយៈពេលវែងដកខ្លួនថយចេញពីធុរៈកិច្ចនៅកម្ពុជា ។

**២.២០** នៅក្នុងដំណើរការនៃការរីកចម្រើនដែលកើតមានចាប់តាំងពីឆ្នាំ១៩៩៣មក កម្ពុជា បានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងប្រឹក្សាផ្តល់យោបល់ ពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ទ្វេភាគី តំបន់ ពហុភាគី អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល) ។ ការវិនិយោគរបស់វិស័យឯកជន ទាំងក្នុងស្រុកនិងក្រៅស្រុក គឺជាកម្លាំងជំរុញឱ្យមានកំណើន *ផសស* ។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ជាខ្លាំងក្នុងការពង្រឹងនិងពង្រីក

ភាពជាដៃគូក្នុងការអភិវឌ្ឍជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស វិស័យឯកជន និងសង្គមស៊ីវិល ។ នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន "*វេទិកាកម្រិតខ្ពស់រវាងរដ្ឋាភិបាល-វិស័យឯកជន*" ត្រូវបានបង្កើតឡើង ហើយការរៀបចំប្រជុំវេទិកានេះត្រូវបានធ្វើឡើងយ៉ាងទៀងទាត់ ។ ដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិ-បត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមការងារបច្ចេកទេសចំនួន ១៨ ដើម្បីបង្កើតឱ្យមានកិច្ចសម្របសម្រួលយ៉ាងជិតស្និទ្ធ នៅក្នុងចំណោមដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ជាមួយនឹងរាជរដ្ឋាភិបាល ។ *គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍* ក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីផ្តល់ការណែនាំដល់ក្រុមការងារបច្ចេកទេស និងដើម្បីពិនិត្យមើលឡើងវិញនូវវឌ្ឍនភាពលើវិស័យនានា ។

**២.២១** បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ គឺជាបុព្វបទដ៏សំខាន់មួយដើម្បីសម្រេចបាននូវអភិបាលកិច្ចល្អ និងវឌ្ឍនភាពផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច ។ ជោគជ័យដ៏គួរឱ្យកត់សម្គាល់ ដែលផ្នែកនេះទទួលបានចាប់ពីឆ្នាំ១៩៩៣ និងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ រួមមានដូចខាងក្រោម :

- *ផសស* គិតតាមថ្លៃថេរបានកើនជាមធ្យម ៧ភាគរយក្នុងមួយឆ្នាំ ទោះបីជាមានការធ្លាក់ចុះនៅក្នុងឆ្នាំ១៩៩៧ ដោយសារកត្តាលេចឡើងព្រមគ្នាពីរ ដែលបានគូសបញ្ជាក់ពីខាងដើមរួចមកហើយ[១] និងការកើនឡើងខ្លាំងនៃថ្លៃប្រេងនៅ ឆ្នាំ២០០៤ និង២០០៥ ។ ភាគច្រើននៃកំណើនសម្រេចបានដោយសារមានគោលនយោបាយដែលមានការគិតគូរច្បាស់លាស់ និងភាពហ្មត់ចត់ក្នុងការបញ្ញត្តិច្បាប់នានា ក៏ដូចជាដោយសារការរីកចម្រើនខ្លាំងដែលជំរុញដោយវិស័យឯកជននៅក្នុងផលិតកម្មឧស្សាហកម្ម និងសំណង់ ។ ការរីកលូតលាស់ក្នុងវិស័យឧស្សាហកម្ម ភាគច្រើនបានមកពីឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ។ វិស័យទេសចរណ៍ក៏មានការរីកចម្រើនយ៉ាងខ្លាំងដែរ ។
- *ផសស* សម្រាប់ប្រជាជនម្នាក់ៗ បានកើនឡើងជាមធ្យមប្រចាំឆ្នាំប្រហែល ៤,៧ភាគរយគិតតាមថ្លៃថេរ ទោះបីមានការកើនឡើងខ្លាំងនៃចំនួនប្រជាជនសរុបក៏ដោយ ។ *ផសស* សម្រាប់ប្រជាជនម្នាក់ៗ ចាប់ផ្តើមកើនឡើងពី ៨៩៧.០០០រៀល នៅឆ្នាំ១៩៩៣ ដល់ជិត ១.៤០០.០០០រៀល នាពេលបច្ចុប្បន្ន (តាមការប៉ាន់ស្មាន ឆ្នាំ ២០០៥) ។
- ការគ្រប់គ្រងអតិផរណាត្រូវបានធ្វើឡើងដោយហ្មត់ចត់និងប្រុងប្រយ័ត្ន ។ ទោះបីជាត្រូវបានរក្សាឱ្យនៅក្នុងកម្រិតទាបអស់រយៈពេលជាច្រើនឆ្នាំក៏ដោយ អត្រាអតិផរណាបានកើនពី ៥ភាគរយនៅឆ្នាំ២០០៤-២០០៥ ដោយសារថ្លៃប្រេងនៅលើពិភពលោកកើនឡើងខ្ពស់ និងដោយសារមានភាពរាំងស្ងួតនៅក្នុងប្រទេស ។ នៅក្នុងឆ្នាំ២០០៥ អត្រាអតិផរណា នឹងស្ថិតនៅក្នុងកម្រិតប្រហាក់ប្រហែលនេះដែរ ។

---

[១] សូមអានកថាខ័ណ្ឌ ២.០២

- អត្រាប្តូរប្រាក់រៀលជាមួយដុល្លារអាមេរិក ស្ថិតនៅ ២.៧៤៧រៀល/ដុល្លារអាមេរិក នៅឆ្នាំ១៩៩៣ ហើយបានកើនឡើងដល់ប្រហែល ៤.១២៨រៀល/ដុល្លារអាមេរិក នៅឆ្នាំ២០០៥ ។
- ចំណូលថវិកាជាតិបានកើនជាលំដាប់ ហើយនឹងឈានដល់ ១១,៨ភាគរយនៃ *ផសស* នៅឆ្នាំ២០០៥ ដែលអនុញ្ញាតឱ្យមានការបង្កើនការចំណាយ ជាពិសេស សម្រាប់វិស័យសង្គមកិច្ច ។

## តារាង២.១ : កំណើនម៉ាក្រូសេដ្ឋកិច្ច

| សូចនាករសំខាន់ៗ | ១៩៩៣ | ២០០០ | ២០០៥ (ប៉ាន់ស្មាន) |
|---|---|---|---|
| *គិតតាមថ្លៃថេរ (ឆ្នាំ ២០០០)* | | | |
| *ផសស* (ពាន់លានរៀល) | ៨.៤៩៦ | ១៤.០៨៩ | ១៩.២៩៤ |
| *ផសស* សម្រាប់ប្រជាជនម្នាក់ៗ (ពាន់រៀល) | ៨៩៧ | ១.១១០ | ១.៤០០ |
| កំណើន *ផសស* ប្រចាំឆ្នាំ (ភាគរយ) | ៣.៩ | ៨.៤ | ៧,០ |
| អតិផរណាគិតពី១ឆ្នាំទៅ១ឆ្នាំ (ភាគរយ) | ១១៤,៣ | -០,៨ | ៦,២ |
| អត្រាប្តូរប្រាក់ ដុល្លារអាមេរិក = រៀល | ២.៧៤៧ | ៣.៩២៤ | ៤.១២៨ |

*ប្រភព: គណនេយ្យជាតិកម្ពុជាឆ្នាំ១៩៩៣-២០០៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មូលនិធិរូបិយវត្ថុអន្តរជាតិ*

**២.២២** វិស័យហិរញ្ញវត្ថុ ដែលរួមមាន វិស័យធនាគារនិងវិស័យធានារ៉ាប់រង ព្រមទាំងសកម្មភាពពាក់ព័ន្ធទាំងឡាយ កំពុងស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើម ហើយមិនទាន់បានដើរតួនាទីមួយដ៏សំខាន់ក្នុងកំណើនសេដ្ឋកិច្ចនៅឡើយ ។ សេដ្ឋកិច្ចកម្ពុជានៅផ្អែកយ៉ាងខ្លាំងលើការប្រើប្រាស់ក្រដាសប្រាក់ផ្ទាល់ ជាមួយនឹងការរីកចម្រើនក្នុងផ្នែកឯកជនដែលកំពុងកើតមានឡើងតាមរយៈការប្រើប្រាស់ប្រភពហិរញ្ញប្បទានផ្ទាល់ខ្លួន ឬការខ្ចីពីក្រុមគ្រួសារ និងមិត្តភក្តិ[9] ។ ទោះជាដូចនេះក្តី វិស័យនេះបានឆ្លងកាត់កំណែទម្រង់សំខាន់ៗ និងសម្រេចបាននូវវឌ្ឍនភាពមួយចំនួន ។ ធនាគារជាតិកម្ពុជាជាធនាគារកណ្តាលរបស់ប្រទេស ហើយទទួលខុសត្រូវលើគោលនយោបាយរូបិយវត្ថុ (ដើម្បីរក្សាស្ថេរភាពថ្លៃ សំដៅធានាឱ្យ មានអតិផរណាទាប) លើការគ្រប់គ្រងរូបិយវត្ថុ ការគ្រប់គ្រងទុនបម្រុងបរទេសនិងធុរៈកិច្ចលើការត្រួតពិនិត្យ និងការណែនាំ ចំពោះធនាគារពាណិជ្ជកម្ម (ភាគច្រើនជាធនាគារឯកជន) ព្រមទាំងចំពោះស្ថាប័នហិរញ្ញវត្ថុ ឯកទេស និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ សមិទ្ធផលទាំងនោះ រួមមាន :

- ការដាក់ឱ្យដំណើរការ និងការអនុវត្តនូវប្រព័ន្ធអធិការកិច្ចនៅនឹងកន្លែងនិងលើឯកសារ ចំពោះស្ថាប័នហិរញ្ញវត្ថុ ។
- ការជម្រះបញ្ជីធនាគារដែលមិនអាចដំណើរការបាន ។
- ការធ្វើឯកជនភាវូបនីយកម្មធនាគារពាណិជ្ជកម្មក្រៅប្រទេស ។

[9] សូមមើល *យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកឯកជនសម្រាប់កម្ពុជា : ការវាយតម្លៃបរិយាកាសវិនិយោគ :* ធនាគារពិភពលោក មិថុនា ២០០៤

- ការពិនិត្យមើលឡើងវិញនិងការលើកកម្ពស់នូវ បទបញ្ញត្តិច្បាប់ដែលមានស្រាប់ ដើម្បីធានាការពង្រឹងការអនុវត្តច្បាប់ឱ្យបានល្អជាងមុន និងឱ្យមានប្រសិទ្ធភាព ។
- ការតាមដានត្រួតពិនិត្យការអនុវត្តដោយធនាគារនានា នូវប្លង់គណនីឯកភាព ដែលស្របទៅតាមស្តង់ដារគណនីអន្តរជាតិ ។

## ការលើកស្ទួយវិស័យកសិកម្ម

**២.២៣** ការលើកស្ទួយវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ហើយក៏រួមចំណែកយ៉ាងច្រើន នៅក្នុងកំណើន *ផសស* និងម៉ាក្រូសេដ្ឋកិច្ច ។ ភាពក្រីក្រមានកម្រិតខ្ពស់នៅជនបទ ជាពិសេសនៅតំបន់ដាច់ស្រយាល ។ ប្រជាជនកម្ពុជាជាង ៨៥ភាគរយ រស់នៅតំបន់ជនបទ ហើយជាង ៦០ភាគរយរស់នៅដោយពឹងផ្អែកលើកសិកម្ម ព្រៃឈើ និងនេសាទ ។ ៧៥ភាគរយ នៃគ្រួសារក្រីក្រ គឺជាគ្រួសារដែលមានមេគ្រួសារជាកសិករ ។ ផលិតកម្មកសិកម្ម នៅតែបន្តរណបទៅនឹងការប្រែប្រួលរបស់ធម្មជាតិ ហើយអាចមាននិន្នាការថយចុះ ដោយសារការរាំងស្ងួត ទឹកជំនន់ និងការបំផ្លាញរបស់សត្វល្អិត ។ ការលំបាកទាំងនេះនៅតែបន្តកើតមាន ហើយចាំបាច់ត្រូវតែជំនះ ។ ដោយហេតុថា ៧០ភាគរយនៃតម្រូវការបន្លែនិងផ្លែឈើរបស់កម្ពុជាត្រូវបាននាំចូល ការគិតគូរដល់ពិពិធកម្មក្នុងទ្រង់ទ្រាយធំ គឺជាការងារសំខាន់ ដើម្បីបំពេញតម្រូវការនេះ ក៏ដូចជា ដើម្បីផលិតនូវដំណាំដែលមានតម្លៃខ្ពស់ (ឧទាហរណ៍ អង្ករដែលមានគុណភាពល្អ រុក្ខជាតិឱសថ និងគ្រឿងទេស) ។ តួលេខជាក់ស្តែងនៃវិស័យកសិកម្ម បង្ហាញយ៉ាងច្បាស់នូវការធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ ។

## តារាង២.២ : *ផសស* : កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| សូចនាករសំខាន់ៗ | ១៩៩៣ | ២០០០ | ២០០៥ (ប៉ាន់ស្មាន) |
|---|---|---|---|
| ***តិតតាមថ្លៃថេរ :*** | | | |
| *កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ពាន់លានរៀល)* | ៣.៨៧៤ | ៥.០៦៥ | ៥.៧០០ |
| *% នៃ ផសស* | *៤៥.៦* | *៣៥.៩* | *៣០.១* |
| ដំណាំ (ពាន់លានរៀល) | ១.៥៩៤ | ២.៣២៨ | ២.៨០០ |
| *% នៃ ផសស* | *១៨.៨* | *១៦.៥* | *១៤.២* |
| បសុសត្វ និង បសុបក្សី (ពាន់លានរៀល) | ៧៥៩ | ៧៥៧ | ៩៤៧ |
| *% នៃ ផសស* | *៨.៩* | *៥.៤* | *៤.៦* |
| នេសាទ (ពាន់លានរៀល) | ១.១៥៨ | ១.៥១៦ | ១.៥៨៨ |
| *% នៃ ផសស* | *១៣.៦* | *១០.៨* | *៩.៣* |
| ព្រៃឈើ និង អាជីវកម្មឈើមូល (ពាន់លានរៀល) | ៣៦២ | ៤៦៤ | ៣៦៧ |
| *% នៃ ផសស* | *៤.៣* | *៣.៣* | *២.០* |
| *ផលិតកម្មស្រូវ :* | | | |
| ផ្ទៃដីសរុប (ពាន់ហិកតា) | ១.៨២៤ | ២.០៧៩ | ២.៣៧៤ |
| ផលិតកម្មស្រូវសរុប (ពាន់តោន) | ២.៣៨៣ | ៤.០៥០ | ៤.១៧០ |
| ទិន្នផលស្រូវ (តោនក្នុងមួយហិកតា) | ១,៣១ | ១,៩៤ | ១,៩៨ |

***ប្រភព :*** *គណនេយ្យជាតិកម្ពុជា ឆ្នាំ ២០០៣-២០០៤ កម្រងស្ថិតិប្រចាំឆ្នាំ២០០៣ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

**២.២៤** ទោះបីផលិតកម្មនិងការរួមចំណែករបស់វិស័យកសិកម្មនៅក្នុងសេដ្ឋកិច្ចទាំងមូល បានកើនឡើងក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះក៏ដោយ សមាមាត្ររបស់វិស័យនេះនៅក្នុង *ផសស* បានធ្លាក់ចុះគួឱ្យកត់សម្គាល់ ពី ៤៥,៦ ភាគរយ នៅឆ្នាំ១៩៩៣ មកប្រហែលត្រឹមតែ ៣០ភាគរយ នៅឆ្នាំ២០០៥ (ការប៉ាន់ស្មាន) ។ ការធ្លាក់ចុះនេះអាចបណ្តាលជាពិសេសមកពី ការកើនឡើងខ្លាំងនៅក្នុងវិស័យឧស្សាហកម្ម (ជាពិសេស ឧស្សាហកម្មកាត់ដេរ) ទេសចរណ៍ និងសំណង់ ។ ជាក់ស្តែង ពីមួយឆ្នាំទៅមួយឆ្នាំ វិស័យនេះពុំមានការកើនឡើងជាលំដាប់ៗនិងទៀងទាត់ទេ (សម្គាល់ដោយចំណុចអតិបរមានិងអប្បបរមា) ដែលឆ្លុះបញ្ចាំងឱ្យឃើញពី ការពឹងផ្អែកយ៉ាងខ្លាំងទៅលើកត្តាធម្មជាតិ និងភាពងាយទទួលរងគ្រោះដោយកត្តាអាកាសធាតុ ដូចជាភាពរាំងស្ងួត ទឹកជំនន់ ។ល។ ផ្ទៃដីដាំស្រូវសរុបបានកើនឡើងពី ១,៨លានហិកតា នៅឆ្នាំ១៩៩៣ ដល់ជាង ២,៣លានហិកតា នៅឆ្នាំ២០០៤-២០០៥ ហើយ ទិន្នផលស្រូវក្នុងមួយហិកតា ក៏បានកើនឡើងជាលំដាប់ផងដែរ (ពី ១,៣១តោន នៅឆ្នាំ១៩៩៣ ដល់ ១,៩៧តោន នៅឆ្នាំ២០០៤-២០០៥) ។ ការកើនឡើងនេះ គឺដោយសារមានការប្រើប្រាស់ប្រភេទពូជស្រូវដែលផ្តល់ទិន្នផលខ្ពស់ គួបផ្សំនឹងការងារផ្សព្វផ្សាយដើម្បីកែលម្អការអនុវត្តនិងបច្ចេកទេសកសិកម្ម ។ ការកើន

ឡើងនៅក្នុងទិន្នផលសរុប គឺបណ្តាលឱ្យមានផលិតផលស្រូវលើសពីតម្រូវការសម្រាប់ពូជនិងសម្រាប់ការចិញ្ចឹមប្រជាជនទូទាំងប្រទេសដែលកំពុងមានការកើនឡើង ។ ផលលើសនេះមានចំនួន ៤១៦.១១៨តោនអង្ករ នៅឆ្នាំ ២០០៤-២០០៥ ។ គួរកត់សម្គាល់ថា ទិន្នផលស្រូវបច្ចុប្បន្ន (ប្រហែល ២តោនក្នុងមួយហិកតា) គឺនៅតែមានកម្រិតទាបជាងច្រើនពីលទ្ធភាព (៣-៥តោនក្នុងមួយហិកតា) ដែលធ្លាប់ធ្វើបាននៅក្នុងប្រទេសជិតខាងដែលមានលក្ខខណ្ឌកសិ-អាកាសធាតុប្រហាក់ប្រហែលគ្នា ។ ទោះបីជាស្ថិតនៅមានកម្រិតតិចតួច ប៉ុន្តែត្រូវបានធ្វើឱ្យមានឡើងជាបណ្តើរៗ ការលើកកម្ពស់នៅក្នុងវិស័យនេះអាចមានផលប៉ះពាល់ខ្លាំងនិងភ្លាមៗជាវិជ្ជមានទៅលើសន្ទស្សន៍នៃភាពក្រីក្រ ។

**២.២៥** ការចិញ្ចឹមសត្វ (គោ ក្របី និងជ្រូក) ពុំមែនមានសារៈសំខាន់សម្រាប់តែកម្រិតនៃអាហារូបត្ថម្ភមួយមុខប៉ុណ្ណោះទេ ក៏ប៉ុន្តែ សម្រាប់បម្រើឱ្យការអូសទាញនិងភ្ជួររាស់ផងដែរ ។ ផលិតកម្មបសុសត្វសរុប នៅតែបន្តពុំមានស្ថេរភាព ប៉ុន្តែផលិតកម្ម បសុបក្សីបានកើនឡើងប្រកបដោយស្ថេរភាព ។

**២.២៦** ត្រីផ្តល់នូវសារៈប្រយោជន៍យ៉ាងសំខាន់ចំពោះប្រជាជនកម្ពុជារាប់លាននាក់ បើគិតអំពីស្បៀងអាហារ អាហារូបត្ថម្ភ និងប្រាក់ចំណូល ។ ការនេសាទត្រីបានកើនឡើងពី ១០៨.៩០០តោន នៅឆ្នាំ១៩៩៣ ដល់ប្រហែល ៣៧៤.០០០តោន ក្នុងឆ្នាំ២០០៥ ដោយការកើនឡើងនេះ ជាចម្បងបណ្តាលមកពីការកើនឡើងជាលំដាប់នៃវារី-វប្បកម្ម ហើយផលិតផលនេសាទទឹកសាបនិងនេសាទសមុទ្រមានការកើនឡើងនៅក្នុងល្បឿនយឺតនៅឡើយ ។ វិស័យនេសាទកំពុងធ្វើកំណែទម្រង់មួយយ៉ាងសំខាន់ តាមវិធីសាស្ត្រមួយដែលផ្តោតទៅលើផលប្រយោជន៍អ្នកក្រច្រើនជាងមុន ។ ការកែទម្រង់នេះ បាននាំឱ្យមានការបង្កើតឡើងនូវការកំណត់គោល នយោបាយសម្រាប់វិស័យនេះ និង*ផែនការសកម្មភាពអភិវឌ្ឍន៍វិស័យនេសាទ* ។ រហូតមកទល់ឆ្នាំ២០០៥ ឡូតិ៍នេសាទប្រមាណ ៥៦,៤៦ ភាគរយ ត្រូវបានរក្សាសម្រាប់ការនេសាទទ្រង់ទ្រាយតូចរបស់ប្រជាជន ។ ការធ្វើបែបនេះ បានបន្ថយទំនាស់នៅក្នុងវិស័យនេះ ។ រហូតមកទល់ពេលនេះ មានសហគមន៍នេសាទចំនួន ៤៤០ ត្រូវបានបង្កើតនិងដាក់ឱ្យដំណើរការ ។ ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ត្រូវបាន ឡាយព្រះហស្តលេខានាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ហើយអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ត្រូវបានអនុម័តនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ ។ ច្បាប់ថ្មីមួយស្តីពីការនេសាទ ត្រូវបានដាក់ជូនដល់សភាជាតិរួចហើយ ។

**២.២៧** *កំណែទម្រង់ដីធ្លី* មានសារៈសំខាន់ណាស់សម្រាប់ការបង្កើនផលិតកម្មកសិកម្ម តាមរយៈការផ្តល់ជូនដល់ប្រជាជននូវកម្មសិទ្ធិនិងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ជាពិសេស ដល់ប្រជាកសិករដែលកំពុងកាន់កាប់ដោយស្របច្បាប់លើដីធ្លីដែលពួកគាត់កំពុងធ្វើការដាំដុះ ។ ការកើនឡើងនៃប្រជាជនបានបង្កើតសម្ពាធទៅលើកម្មសិទ្ធិដីធ្លី ។ ស្ថានភាពនេះ កាន់តែមានសភាពលំបាកជាងមុន ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០ នៅពេលដែលកសិករម្នាក់ៗបានកាន់កាប់ដីមួយចំនួនរហូតមកដល់ពេលនេះ ហើយក្នុងពេលជាមួយគ្នានោះ កសិករប្រមាណ

១២ភាគរយមិនបានកាន់កាប់ដីធ្លីណាមួយទេ ។ ក្រុមប្រឹក្សាអន្តរក្រសួងសម្រាប់គោលនយោបាយដីធ្លី ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ ។ ដំណាក់កាលទី១នៃ *កម្មវិធីស្តីពី ការងាររដ្ឋបាល ការគ្រប់គ្រង ការបែងចែកដីធ្លី* សម្រាប់រយៈពេល១៥ឆ្នាំរបស់រាជរដ្ឋាភិបាល ត្រូវបានអនុម័តនៅឆ្នាំ២០០០ ។ គោលដៅទាំងឡាយរបស់កម្មវិធីនេះ គឺសំដៅធ្វើការកែលម្អ សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងជំរុញលើកទឹកចិត្តឱ្យមានការអភិវឌ្ឍទីផ្សារដីធ្លីប្រកបដោយប្រសិទ្ធភាព ។ ច្បាប់ភូមិបាលដែលជាច្បាប់ដ៏ទូលំទូលាយមួយសម្រាប់ដីធ្លី ត្រូវបានដាក់ចេញនៅឆ្នាំ២០០១ ហើយ *ក្របខ័ណ្ឌគោលនយោបាយស្តីពីដីធ្លី* ត្រូវបានអនុម័តនៅឆ្នាំ២០០២ ។ ដោយផ្អែកតាមការវាយតម្លៃនាឆ្នាំ២០០១ដែលបានបង្ហាញថា ៦ ទៅ ៧លានក្បាលដីត្រូវការប័ណ្ណកម្មសិទ្ធិនៅទូទាំងប្រទេស ការងារចេញឱ្យនូវឯកសារនេះ មានការរីកចម្រើនល្អ ដោយបានចេញឱ្យនូវប័ណ្ណកម្មសិទ្ធិជាច្រើនរយពាន់ច្បាប់ នៅក្នុងក្របខ័ណ្ឌការងារចុះបញ្ជីដីធ្លីតាមលក្ខណៈជាប្រព័ន្ធ និងក្នុងដំណើរការចុះបញ្ជីដីធ្លីទៅតាមលក្ខណៈដាច់ដោយដុំ ។ យន្តការមួយសម្រាប់ការដោះស្រាយជម្លោះដីធ្លីតាមរយៈគណៈកម្មការសុរិយោដី ត្រូវបានបង្កើតឡើង ។ គណៈកម្មការនេះបានដោះស្រាយជម្លោះចំនួន ៨៨៩ករណី នៅចន្លោះឆ្នាំ២០០៣-២០០៥ ក្នុងចំណោមជម្លោះ ចំនួន ៣.២៥៧ករណី ដែលបានទទួល ។ អនុក្រឹត្យស្តីពីការធ្វើសម្បទានដីសង្គមកិច្ច សម្រាប់យកទៅអនុវត្តការបែងចែកដីរដ្ឋប្រកបដោយសមធម៌ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច កំពុងត្រូវបានអនុវត្តក្នុងឋានៈជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ដីធ្លី ។ អនុក្រិត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រិត្យស្តីពីការធ្វើសម្បទានដីសេដ្ឋកិច្ច ត្រូវបានអនុម័ត ។ ការសាកល្បងស្តីពីការធ្វើសម្បទានដីសង្គមកិច្ចកំពុងដំណើរការ ហើយការរៀបចំនិងការអនុវត្តគម្រោងគាំទ្រសកម្មភាពនេះ ត្រូវបានរំពឹងទុកថានឹងចាប់ផ្តើមនៅឆ្នាំ២០០៦ ។ ដើម្បីអនុវត្តការងារដ៏ធំដែលពាក់ព័ន្ធនឹងកំណែទម្រង់និងការគ្រប់គ្រងដីធ្លី ឯកសារសម្រាប់ការបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ហើយមន្ត្រីជំនាញក៏ត្រូវបានទទួលការបណ្តុះបណ្តាលផងដែរ ។ បញ្ហាប្រឈមចំពោះមុខ គឺត្រូវចាប់ផ្តើមនិងជំរុញឱ្យមានការអនុវត្តបញ្ញត្តិច្បាប់ទាំងឡាយ ដើម្បីប្រឆាំងនឹងការចាប់យកដីខុសច្បាប់ ព្រមទាំងដើម្បីធានាសុវត្ថិភាពនិងសមធម៌ដីធ្លីដល់គ្រួសារក្រីក្រ ។

**២.២៨** ផ្ទៃដីដ៏ធំដែលអាចប្រកបរបរកសិកម្មបាន ត្រូវបានទទួលរងនូវផលប៉ះពាល់ដោយសារគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដ៏គ្រោះថ្នាក់ ដែលបានកប់នៅក្នុងអំឡុងពេលនៃជម្លោះផ្ទៃក្នុងកន្លងមក ។ គ្រាប់មីនទាំងនោះបានបំផ្លាញជីវិតនិងអវយវៈរបស់មនុស្សនិងសត្វជាច្រើន ។ ដូច្នេះ *ការបោសសំអាតមីន* គឺជាការងារយ៉ាងសំខាន់សម្រាប់ធ្វើឱ្យដីដែលអាចប្រកបរបរកសិកម្មបាន មានសុវត្ថិភាព សម្រាប់ការដាំដុះ និងសម្រាប់ការពារកុំឱ្យមានមនុស្សស្លាប់និងពិការ ដែលបណ្តាលមកពីការរបួសយ៉ាងធ្ងន់ធ្ងរដោយសារមីន ។ កម្មវិធីបោសសំអាតមីន បានដំណើរការអស់ជាច្រើនឆ្នាំមកហើយ ។ តាមរបាយការណ៍ប្រចាំឆ្នាំ ចំនួនជនរងគ្រោះដោយសារមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបានថយចុះពី ១.៧៤៣នាក់ នៅឆ្នាំ១៩៩៦ មកត្រឹម ៧៩៧នាក់ នៅឆ្នាំ២០០៥ (ការប៉ាន់ស្មាន) ។

ផ្ទៃដីដែលបានបោសសំអាតមីនមានទំហំ ១.២២៥ ហិកតា នៅឆ្នាំ១៩៩៣ ហើយកើនឡើងដល់ ៣២.៩៧៤ហិតា នៅឆ្នាំ២០០៥ (ការប៉ាន់ស្មាន) ។ ទោះបីយ៉ាងដូច្នេះក្តី នៅមានការងារជាច្រើនទៀតដែលត្រូវបន្តធ្វើ ។

**២.២៩** *សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ* គឺជាបញ្ហាអន្តរវិស័យ ។ អត្រាកង្វះអាហារូបត្ថម្ភគិតតាមអាហារផ្តល់ប្រូតេអ៊ីននិងថាមពល និងកង្វះមីក្រូសារជាតិ (ជាតិដែក ជាតិអ៊ីយ៉ូដ និងជីវជាតិអា) សម្រាប់កុមារអាយុក្រោម៥ឆ្នាំនិងស្ត្រី មានកម្រិតខ្ពស់ ហើយ ៥៤ភាគរយនៃការស្លាប់របស់កុមារ ត្រូវបានវាយតម្លៃថា ពាក់ព័ន្ធជាមួយបញ្ហាកង្វះអាហារូបត្ថម្ភ ។ អសន្តិសុខស្បៀងនិងកង្វះអាហារូបត្ថម្ភ ជះឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍធនធានមនុស្ស ។ កង្វះអាហារូបត្ថម្ភបង្កើនការចំណាយខ្ពស់ផ្នែកសុខភាព ដោយសារស្ថានភាពសុខភាពមិនល្អ ហើយមានផលប៉ះពាល់ អវិជ្ជមានលើគុណភាពនៃកម្លាំងពលកម្ម នៅពេលអនាគត ។ ការកែលម្អក្នុងផលិតកម្មកសិកម្ម ការចិញ្ចឹមសត្វ ការនេសាទ លទ្ធភាពប្រើប្រាស់ទីផ្សារ ផ្លូវ គមនាគមន៍ជនបទ និងវិស័យសុខាភិបាល បានជួយធ្វើឱ្យប្រសើរឡើងនូវ *សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ* នៅក្នុងអំឡុងពេល៥ឆ្នាំកន្លងមកនេះ ។ ប៉ុន្តែនៅមានភាពមិនស្មើគ្នា នៅទូទាំងប្រទេស រវាងបណ្តាតំបន់ដែលមានផលលើសនិងឱនភាពស្បៀង និងក្នុងចំណោមមជ្ឈដ្ឋានផ្សេងៗគ្នាក្នុងសង្គម ។ សមត្ថភាពផលិតកម្មអំបិលអ៊ីយ៉ូដក្នុងស្រុកបានកើនឡើងយ៉ាងខ្លាំងពី ២០ ភាគរយ នៅឆ្នាំ២០០២ ដល់ជាង ១០០ភាគរយនៃតម្រូវការនៅទូទាំងប្រទេសនៅឆ្នាំ២០០៥ ។ *ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ឆ្នាំ២០០៣-២០០៧* កំពុងត្រូវបានអនុវត្ត ។ រាជរដ្ឋាភិបាលកម្ពុជា បានជំរុញសកម្មភាពគណៈកម្មាធិការសម្របសម្រួលអាហារូបត្ថម្ភខេត្ត នៅក្នុងខេត្ត-ក្រុងមួយចំនួន និងបានតម្រូវឱ្យមានការរៀបចំនូវផែនការសកម្មភាពស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ តាមខេត្ត-ក្រុង ។

**២.៣០** *ការកែទម្រង់ព្រៃឈើ* បានដំណើរការក្នុងរយៈពេលពីរ-បីឆ្នាំកន្លងមកនេះ និងបានឈានដល់ដំណាក់កាលសំខាន់មួយ ដែលនៅក្នុងដំណាក់កាលនេះ ក្នុងចំណោមការងារទាំងអស់ ការពង្រឹងនិងការលើកកម្ពស់ស្ថាប័នក្នុងកិច្ចការសម្របសម្រួល គឺជាអាទិភាពមួយ ។ យោងតាមគោលនយោបាយសម្រាប់ *ផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ* និង *ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម* នៅតាមសហគមន៍ជិតៗ ដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយមួយ ត្រូវបានចាប់ផ្តើមឡើង ។ ចាប់ពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ននេះ ព្រៃសម្បទានដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនចំនួន ១៧ ត្រូវបានប្រកាសលុបចោល ។ ព្រៃសម្បទានទាំងនោះ ដែលមាន២៤កន្លែង គ្របដណ្តប់លើផ្ទៃដីព្រៃប្រមាណ ៣,៥លានហិកតា ។ រហូតមកដល់ពេលនេះ មានតែក្រុមហ៊ុនសម្បទានព្រៃឈើចំនួន ១២ប៉ុណ្ណោះ ដែលកំពុងស្ថិតនៅក្នុងដំណើរការរៀបចំធ្វើអាជីវកម្មព្រៃសម្បទានរបស់ពួកគេ នៅលើផ្ទៃដីព្រៃឈើប្រមាណ ៣,៤លានហិកតា ។ ការធ្វើសម្បទានថ្មីៗ ពុំត្រូវបានផ្តល់ទៀតឡើយ ប៉ុន្តែអាជីវកម្មតូចៗនិងការងារមួយចំនួនទៀត បានបន្តដោយអនុលោមទៅតាមបញ្ញត្តិច្បាប់ ។ ក្នុងការទប់ស្កាត់ការធ្វើអាជីវកម្មឈើខុសច្បាប់ រោងចក្រអារឈើខុសច្បាប់ចំនួន ១.៤៦៩កន្លែង សិប្បកម្មកែច្នៃឈើចំនួន ៦៨៩កន្លែង សិប្បកម្ម

កៃច្នៃរុក្ខជាតិខុសច្បាប់ចំនួន ៣៩កន្លែង និងកន្លែងកែច្នៃឈើមួយចំនួនទៀត ត្រូវបានលុបបំបាត់និងបំផ្លាញចោល ហើយជនល្មើសប្រមាណ ៤៤១នាក់ ត្រូវបានចាប់ឃាត់ខ្លួននិងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោស ។ នៅខែមិថុនា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា បានចេញបទបញ្ជាលេខ ០១ បប. ដើម្បីទប់ស្កាត់ និងលុបបំបាត់ការទន្ទ្រាន និងការរំលោភយកដីព្រៃ ហើយបានបង្កើតគណៈកម្មាធិការជាតិ និងអនុគណៈកម្មាធិការជាតិ ដើម្បីអនុវត្តបទបញ្ជានេះ ។ លើសពីនេះទៀត លិខិតបទដ្ឋាននិងគោលការណ៍ណែនាំមួយចំនួន ត្រូវបានចេញផ្សាយដើម្បីអនុវត្តច្បាប់ព្រៃឈើឆ្នាំ២០០២ ។ ក្រុមតាមដានត្រួតពិនិត្យថ្មីដែលឯករាជ្យ ដើម្បីរាយការណ៍ពីបទល្មើសព្រៃឈើ និងការអនុវត្តគោលនយោបាយ បាននិងកំពុងបន្តធ្វើការងារពីក្រុមមុន ។ ការផ្តួចផ្តើមឱ្យមានសហគមន៍ព្រៃឈើសាកល្បង នៅតាមតំបន់ជាច្រើននៃប្រទេស បានដាក់ឱ្យដំណើរការរួចហើយ ហើយផ្ទៃដីជិត ១១០.០០០ហិកតា ត្រូវបានធ្វើការអភិវឌ្ឍ ក្រោមការចាត់ចែងការប្រើប្រាស់ព្រៃឈើរបស់សហគមន៍ ។

**២.៣១** *បរិស្ថាននិងការអភិរក្សជីវចម្រុះ* ត្រូវបានចាត់ទុកជាការងារអាទិភាពខ្ពស់ ក្នុងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចអភិវឌ្ឍប្រកបដោយចីរភាព សំដៅផ្តល់អត្ថប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច របស់សហគមន៍ដែលពាក់ព័ន្ធ ។ សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ត្រូវបានដាក់ជូនរដ្ឋសភារួចហើយ ។ ច្បាប់នេះ ធ្វើឱ្យមានការបង្កើតនូវនីតិវិធីគោលការណ៍ណែនាំ និងគោលការណ៍ច្បាប់នានា សម្រាប់ការងាររដ្ឋបាល និងការគ្រប់គ្រងលើតំបន់ការពារធម្មជាតិ សម្រាប់ការការពារសិទ្ធិនិងប្រពៃណីទំនៀមទម្លាប់ របស់ជនជាតិដើមភាគតិច និងសម្រាប់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីស្វែងរកការចូលរួមរបស់ពួកគេក្នុងការគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិ និងក្នុងការប្រើប្រាស់ជីវចម្រុះ ។ *ផែនការសកម្មភាពស្តីពីជីវចម្រុះ* ក៏ត្រូវបានអនុម័ត ហើយគណៈកម្មាធិការជាតិដឹកនាំការងារជីវចម្រុះត្រូវបានបង្កើតឡើង ។ ចំនួនសត្វព្រៃ ត្រូវបានសង្កេតឃើញថា មានការកើនឡើងនៅក្នុងតំបន់ការពារមួយចំនួន ។ ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងតម្រូវការបន្ទាន់នៃការផ្លាស់ប្តូរអាកាសធាតុ ជាពិសេស ភាពរាំងស្ងួតនិងទឹកជំនន់ កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការផ្លាស់ប្តូរអាកាសធាតុ ត្រូវបានរៀបចំឡើង ដោយកំណត់ឡើងនូវសកម្មភាពអាទិភាពទាំងឡាយ ដែលត្រូវការចាំបាច់ដើម្បីសម្របទៅនិងការផ្លាស់ប្តូរអាកាសធាតុ ចំពោះកសិកម្ម ការគ្រប់គ្រងធនធានទឹក ការគ្រប់គ្រងតំបន់ឆ្នេរ និងសុខភាពមនុស្ស ។

**២.៣២** តំបន់ការពារធម្មជាតិចំនួន ២៣កន្លែង ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ។ ការងាររៀបចំផែនទីនិងការកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិចំនួន ១១កន្លែង ត្រូវបានបញ្ចប់ ហើយការបោះបង្គោលសម្គាល់ព្រំប្រទល់ត្រូវបានធ្វើឡើង ហើយផ្លូវប្រវែង ១១០គីឡូម៉ែត្រ នៅក្នុងតំបន់ការពារធម្មជាតិត្រូវបានស្តារឡើងវិញ ។ ការខិតខំប្រឹងប្រែងរួមគ្នា ត្រូវបានធ្វើឡើងដើម្បីការពារនិងថែរក្សាប្រព័ន្ធជីវចម្រុះសំខាន់ៗ ដូចជា តំបន់ការពារធម្មជាតិជួរភ្នំក្រវាញ តំបន់ស្នូលទាំងបីនៃបម្រុងជីវមណ្ឌលបឹងទន្លេសាប និងតំបន់ការពារធម្មជាតិមួយចំនួន

ទៀត ។ ការធ្វើឱ្យមានការចូលរួមពីសហគមន៍ ក្នុងការថែរក្សាប្រព័ន្ធជីវចម្រុះ និងការអភិវឌ្ឍធនធានធម្មជាតិ ដែលទ្រទ្រង់ដល់ការរស់នៅរបស់សហគមន៍តំបន់ការពារធម្មជាតិ កំពុងត្រូវបានជំរុញលើកទឹកចិត្ត នៅក្នុងគម្រោងអភិរក្សមួយចំនួន ជាពិសេស តាមរយៈការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ចំនួន៦៩កន្លែង ។ គណៈ-កម្មាធិការជាតិសម្រាប់គ្រប់គ្រងតំបន់ឆ្នេរត្រូវបានបង្កើតឡើង ដើម្បីជំរុញការចូលរួមរបស់អាជ្ញាធរថ្នាក់ខេត្ត-ក្រុង និងក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរ ។ អង្គការដែលមានមូលដ្ឋាននៅសហគមន៍តំបន់ឆ្នេរចំនួន ៣០ត្រូវបានបង្កើតឡើង ។ ព្រៃកោងកាងចំនួន ៥៤ហិកតា ត្រូវបានដាំដុះឡើងវិញ ហើយប្រភេទរុក្ខជាតិតំបន់ឆ្នេរជាច្រើនត្រូវបានកំណត់ ។

**២.៣៣** ធនធានទឹក គឺជាវិស័យមួយដ៏សំខាន់នៃមូលដ្ឋានធនធានធម្មជាតិនិងបរិស្ថានជាតិ ។ ប្រព័ន្ធផ្លូវទឹកនៃប្រទេសកម្ពុជា (ជាពិសេសប្រព័ន្ធទន្លេសាប) ជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ការនេសាទត្រី ការស្រោចស្រពសម្រាប់បង្កើនផលិតផលកសិកម្ម ការផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ការផ្គត់ផ្គង់ទឹកសម្រាប់ឧស្សាហកម្ម និងការផ្គត់ផ្គង់ទឹកសម្រាប់ផលិតថាមពលវារីអគ្គិសនីនិងនាវាចរ ។ ទោះបីជាប្រទេសកម្ពុជាសម្បូរទៅដោយធនធានទឹកសាប (ទន្លេ ស្ទឹង បឹងបួ និងល្អាងទឹកក្រោមដី) ក៏ដោយ ក៏នៅមានតំបន់មួយចំនួននៃប្រទេសកម្ពុជាតែងតែទទួលរងនូវគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលធ្វើឱ្យប៉ះពាល់ និងបង្កការខូចខាតដល់ផលដំណាំផ្សេងៗ ។ ដូចនេះ ការសាងសង់និងការជួសជុលឡើងវិញនូវ ប្រព័ន្ធធារាសាស្ត្រ ទំនប់ការពារទឹកជំនន់ និងទំនប់ការពារទឹកប្រៃ គឺជាអាទិភាពដ៏ចំបងនៃគោលនយោបាយជាតិលើការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក ។ ទន្ទឹមនឹងនេះ ធនធានទឹកកម្ពុជា ងាយទទួលរងនូវគ្រោះថ្នាក់ ដែលបណ្តាលមកពីសកម្មភាពនានាពីបណ្តាប្រទេសដែលស្ថិតនៅខ្សែទឹកខាងលើនៃទន្លេមេគង្គ ។ គោលនយោបាយជាតិស្តីពី *ការគ្រប់គ្រងធនធានទឹក* ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅខែមករា ឆ្នាំ២០០៤ និងសេចក្តីព្រាងច្បាប់ស្តីពី *ការគ្រប់គ្រងធនធានទឹក* កំពុងត្រូវបានពិនិត្យដោយសភាជាតិ ។ នៅក្នុងរយៈពេល ៥ឆ្នាំ (២០០១-២០០៥) កន្លងមកនេះ សមិទ្ធផលដែលសម្រេចបានរួមមាន បានស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រចំនួន ៣១៥កន្លែង សំរាប់បម្រើដល់ការងារបង្កបង្កើនផលលើផ្ទៃដីសរុបចំនួន ១៥៣.១៤៩ហិកតា សង់ទំនប់ការពារទឹកជំនន់ដែលអាចការពារលើផ្ទៃដីចំនួន ១១៣.៥០០ហិកតា និងសង់ទំនប់ការពារទឹកប្រៃដែលអាចការពារលើផ្ទៃដីចំនួន ១៦.៦៨០ហិកតា ។

**២.៣៤** *ការអភិវឌ្ឍជនបទ* គឺជាបញ្ហាអន្តរវិស័យដ៏ធំមួយ ដែលគ្របដណ្តប់លើវិស័យសុខាភិបាល អប់រំ កសិកម្ម និងវិស័យផ្សេងៗទៀត ។ ការអភិវឌ្ឍជនបទ មានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ ព្រោះ ៨៥ភាគរយនៃប្រជាជនទាំងអស់កំពុងរស់នៅតំបន់ជនបទ ដែលមានអត្រាភាពក្រីក្រខ្ពស់ ។ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចយកវិធីសាស្ត្រដែលមានមុខព្រួញច្រើន ដើម្បីជំរុញការអភិវឌ្ឍជនបទ និងផ្តល់សិទ្ធិអំណាចដល់សហគមន៍មូលដ្ឋាន ក្នុងការរៀបចំផែនការនិងគ្រប់គ្រងការអភិវឌ្ឍមូលដ្ឋានរបស់ពួកគាត់ ។ ការធ្វើវិមជ្ឈការ និង

វិសហមជ្ឈការលើការផ្ដល់សេវាកម្មសាធារណៈ[១] ការគាំទ្រដល់កម្មវិធីទាំងឡាយដែលមានការចូលរួមជាលក្ខណៈវិមជ្ឈការនិងដែលផ្ដោតទៅតាមវិស័យ និងការផ្ដល់ឥណទានដល់គ្រួសារនិងអាជីវកម្មធុនតូចៗ គឺជាឧទាហរណ៍មួយចំនួន ដែលបង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងវិស័យនេះ ។

**២.៣៥** រហូតមកដល់ឆ្នាំ២០០៥ ទន្ទឹមគ្នានឹងការធ្វើបញ្ជីសារពើភ័ណ្ឌផ្លូវជនបទទាំងអស់ ការងារស្ដារឬការសាងសង់នៅក្នុងតំបន់ជនបទទទួលបានលទ្ធផលដូចតទៅ ផ្លូវជនបទប្រវែង ២២.៧០០ គីឡូម៉ែត្រ (ក្នុងនោះប្រវែង ១០.១៣០គីឡូម៉ែត្រជាផ្លូវក្រាលគ្រួសក្រហម) ស្ពានចំនួន ៣.០៤៣ លូបង្ហូរកាត់ផ្លូវចំនួន ១១.៣១៤កន្លែង អណ្ដូងស្អប់ចំនួន ៤៤.៩១៩អណ្ដូង ទំនប់ប្រវែង ៦៩៧គីឡូម៉ែត្រ ប្រឡាយប្រវែង ៥៨៤គីឡូម៉ែត្រ អាងស្តុកទឹកបម្រុងចំនួន ១៩៩៥កន្លែង ស្រះជីកចំនួន ៦.៥០៥កន្លែង ថ្នាក់រៀនចំនួន ១.៨៧៤បន្ទប់ ហើយទីផ្សារនៅជនបទចំនួន ១៧កន្លែង ។

**២.៣៦** *ការធ្វើផែនការមូលដ្ឋានចម្រុះ* គឺជាយន្តការមួយ ដើម្បីធ្វើការកំណត់ឱ្យបានប្រសើរជាងមុននូវអាទិភាពទាំងឡាយ និងដើម្បីរៀបចំកសាងសំណើសម្រាប់កម្មវិធីវិនិយោគ លើការគាំទ្រនិងហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទ ។ ផែនការនេះ ធ្វើចំណាត់ថ្នាក់ឱ្យសហគមន៍ទាំងឡាយ ទៅតាមកម្រិតនៃលទ្ធភាពទទួលបាននូវតម្រូវការនិងសេវាកម្មមូលដ្ឋានអប្បបរមា របស់សហគមន៍ទាំងនោះ ដើម្បីឱ្យការយកចិត្តទុកដាក់ជាអាទិភាពត្រូវបានគិតគូរដល់សហគមន៍ទាំងនោះ សម្រាប់ការអភិវឌ្ឍជនបទ ។

**២.៣៧** ការស្ដារឬសាងសង់ឡើងវិញនូវផ្លូវថ្នល់ជនបទប្រវែង ២២.៧០០គីឡូម៉ែត្រ បានជួយដល់អ្នកផ្ដល់សេវាកម្មជាច្រើន ឱ្យបានទៅដល់តំបន់ជនបទនិងតំបន់ដាច់ស្រយាលមួយចំនួន ដែលបច្ចុប្បន្ននេះទទួលបានការផ្គត់ផ្គង់សេវាកម្មនិងទីផ្សារល្អជាងមុន ។ ការងារខាងលើនេះ ក៏បានជួយសម្រួលឱ្យមានសកម្មភាពសេដ្ឋកិច្ចមមាញឹកជាងមុនផងដែរ ។ កម្មវិធីជាច្រើនដូចជា កម្មវិធីសីលា បានពង្រីកតំបន់គ្របដណ្ដប់របស់ខ្លួន ដោយបច្ចុប្បន្ននេះបានពង្រីកទៅដល់គ្រប់ខេត្ត-ក្រុង និងឃុំ-សង្កាត់ ។ នៅក្នុងអំឡុងឆ្នាំ១៩៩៨-២០០៣ មន្ត្រីរាជការស៊ីវិលជាង ៣.០០០នាក់ និងតំណាងភូមិដែលជាប់ឆ្នោតចំនួន ៧៥.០០០នាក់ ត្រូវបានទទួលការបណ្ដុះបណ្ដាលក្នុងផ្នែកបច្ចេកទេសផ្សេងៗ រួមមានការរៀបចំផែនការដោយមានការចូលរួម ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងកិច្ចសន្យា ការដេញថ្លៃនិងលទ្ធកម្ម ការតាមដាននិងវាយតម្លៃ ។ *មូលនិធិសង្គម* ដែលបានបង្កើតឡើងនៅឆ្នាំ ១៩៩៤ បានផ្ដល់ជំនួយដែលមានការចំណាយប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅតាមតំបន់ជនបទនានា ចំពោះគម្រោងផ្សេងៗ ដូចជា អាគារសិក្សា ធារាសាស្ត្រ មណ្ឌលសុខភាពស្រុកនិងឃុំ អណ្ដូងស្អប់ ស្ពាននិងលូបង្ហូរទឹក និងប្រព័ន្ធបង្ហូរទឹក ។ នៅក្នុងអំឡុងឆ្នាំ១៩៩៨-២០០៣ ក្នុងចំណោមគម្រោង

---

[១] យោងទៅកថាខ័ណ្ឌ ២.១១ និង ២.១២

៣.២៧២ ដែលបានស្នើសុំ មាន១.៩២៨ គម្រោងត្រូវបានទទួលអនុម័ត ក្នុងនោះ ៩០.៨ភាគរយ ជាគម្រោងនៅក្នុងតំបន់ជនបទ ១៥.២ភាគរយនៅតំបន់ដែលធ្លាប់មានជម្លោះ និងក្រៅពីនោះនៅតំបន់ទីប្រជុំជន ។

**២.៣៨** ការពង្រីកឥណទានជនបទដែលមានការប្រាក់ទាប ដើម្បីជំរុញឱ្យមានកំណើននៅតំបន់ជនបទ ជានិច្ចកាលត្រូវបានកំណត់ជាអាទិភាពមួយ ។ ជាមួយនឹងការណែនាំនិងលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្ននេះមានជាង ១៥ស្ថាប័នមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ កំពុងធ្វើការនៅតំបន់ជនបទ រួមជាមួយ ៤០ប្រតិបត្តិករផ្សេងទៀត រួមមាន ធនាគារឯកទេសនិងធនាគារអភិវឌ្ឍន៍ជនបទ ។ តម្រូវការលើសពីការផ្គត់ផ្គង់ ហើយអត្រាការប្រាក់ដែល នៅតែមានកម្រិតខ្ពស់នៅឡើយ គឺជាបញ្ហាដែលត្រូវដោះស្រាយជាបន្ទាន់ ។

## ការស្តារនិងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

**២.៣៩** មូលដ្ឋានបង្អែកសម្រាប់ធ្វើការអភិវឌ្ឍប្រកបដោយចីរភាពគឺ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់និងស្ពាន ផ្លូវដែក កំពង់ផែ ការផលិតថាមពលអគ្គិសនីនិងបណ្តាញចែកចាយ ប្រព័ន្ធធារាសាស្ត្រ និងទូរគមនាគមន៍ជាដើម ។

**២.៤០** ការងារកសាង*ផ្លូវថ្នល់និងកំពង់ផែ* ផ្តោតជាសំខាន់លើ បណ្តាញផ្លូវថ្នល់ ការស្តារនិងពង្រីកកំពង់ផែក្រុងព្រះសីហនុ និងព្រលានយន្តហោះអន្តរជាតិភ្នំពេញនិងសៀមរាប ។ ការយកចិត្តទុកដាក់ជាចម្បង បានផ្តោតទៅលើការស្តារនិងបង្កើនគុណភាពផ្លូវជាតិដែលភ្ជាប់ទៅបណ្តាប្រទេសជិតខាង (ប្រទេសឡាវ ថៃ និងវៀតណាម) បណ្តាញផ្លូវសំខាន់ៗនៅក្នុងប្រទេស និងផ្លូវថ្នល់ដែលភ្ជាប់ទៅតំបន់ជនបទដាច់ស្រយាល រួមទាំងស្ពាននិងការចម្លងសាឡាង ។

**២.៤១** នៅក្នុងអំឡុងពេលពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០០៤ នៅក្នុងចំណោមផ្លូវសរុបប្រវែង ១១.៣១០គីឡូម៉ែត្រ ក្នុងនោះផ្លូវជាតិសរុបប្រវែង ៤.៦៩៥គីឡូម៉ែត្រ (ដែលភ្ជាប់រាជធានីភ្នំពេញទៅនឹងប្រទេសជិតខាង ទីរួមខេត្ត និងកំពង់ផែ) ហើយផ្លូវខេត្តសរុបប្រវែង ៦.៦១៥គីឡូម៉ែត្រ (ដែលភ្ជាប់ទីរួមខេត្តទៅនឹងទីរួមស្រុក) ផ្លូវប្រវែងប្រមាណ ២.១០០គីឡូម៉ែត្រ ត្រូវបានលើកកម្ពស់គុណភាព (ក្រាលកៅស៊ូ) ។ ការសាងសង់ស្ពានគីហ្សូណាកាត់ទន្លេមេគង្គនៅខេត្តកំពង់ចាម (ខែកុម្ភៈ ឆ្នាំ២០០២) និងស្ពានកោះកុង (ឆ្នាំ២០០១) ត្រូវបានបញ្ចប់ជាស្ថាពរ ហើយផ្លូវថ្នល់សំខាន់ៗមួយចំនួនត្រូវបានសាងសង់ឡើងវិញ ក្នុងនោះរាប់បញ្ចូលទាំងការស្តារស្ពាននានាតាមបណ្តោយផ្លូវទាំងនោះផងដែរ ។ ផ្លូវភ្ជាប់ពីទីរួមខេត្តទៅស្រុកនិងតំបន់ជនបទក៏ត្រូវបានជួសជុលផងដែរ ។ ការថែទាំផ្លូវថ្នល់គឺជាអាទិភាពចម្បង ដែលត្រូវធ្វើឡើង ជាមួយនឹងធនធានដ៏មានកម្រិត ។

**២.៤២** កំពង់ផែក្រុងព្រះសីហនុ ដែលស្ថិតនៅចំងាយ ២៣០គីឡូម៉ែត្រ ប៉ែកនិរតីនៃទីក្រុងភ្នំពេញ ហើយដែលលើកដាក់ទំនិញប្រមាណ ៧០ភាគរយនៃទំនិញនាំចូលក្នុងប្រទេស បាននិងកំពុងបង្កើនសមត្ថភាព ហើយជំហានទីមួយនៃដំណើរការនេះជិតនឹងបញ្ចប់នៅឆ្នាំ២០០៥នេះ ។ ការស្តារផ្លូវដែក ឬការកែលម្អបន្ថែមទៀតនូវមធ្យោបាយដឹកជញ្ជូនផ្លូវទឹកតាមដងទន្លេ មានវឌ្ឍនភាពតិចតួច ទោះបីជាការដឹកជញ្ជូនតាមទន្លេរវាងក្រុងភ្នំពេញនិងខេត្តសៀមរាប មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក៏ដោយ ។

**២.៤៣** វិស័យឯកជនកំពុងតែចូលរួមកាន់តែច្រើនជាងមុន ក្រោមរូបភាព *សាងសង់-ដំណើរការ-ផ្ទេរ* ក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ។ ឧទាហរណ៍គួរឱ្យកត់សម្គាល់ មានដូចជា ស្ពានកោះកុង ផ្លូវជាតិលេខ៤ ការកែលម្អព្រលានយន្តហោះអន្តរជាតិភ្នំពេញជាដើម ។

**២.៤៤** ថាមពល : ការធានាឱ្យមានថាមពលអគ្គិសនីគ្រប់គ្រាន់និងមានថ្លៃទាប គឺជាគន្លឹះសម្រាប់អភិវឌ្ឍន៍ប្រទេស ។ ថ្លៃខ្ពស់របស់អគ្គិសនី ជះឥទ្ធិពលទៅលើវិស័យផលិតទាំងអស់ ហើយរារាំងដល់ការវិនិយោគផ្នែកឧស្សាហកម្មនិងការប្រកួតប្រជែង ។ ការទាក់ទាញការវិនិយោគនិងការចូលរួមពីផ្នែកឯកជន ក្នុងការផលិតនិងបែងចែកថាមពលអគ្គិសនី ទៅទីរួមខេត្តនិងទីប្រជុំជនសំខាន់ៗ ទៅតំបន់ជនបទ និងការរៀបចំបណ្តាញបញ្ជូនថាមពលដើម្បីភ្ជាប់កម្ពុជាទៅនឹងបណ្តាប្រទេសជិតខាង ត្រូវបានកំណត់ថា ជាអាទិភាពខ្ពស់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ។ ការផលិតថាមពលអគ្គិសនីនៅភ្នំពេញនិងទីរួមខេត្ត បានកើនឡើងពី ១៦៣.៤ គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ១៩៩៣ ដល់ ៧៥៩.៧ គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០០៤ ។ រោងចក្រអគ្គិសនីថ្មីៗត្រូវបានសាងសង់ចប់ជាស្ថាពរ ។ ការងារដែលត្រូវធ្វើចំពោះមុខ គឺត្រូវបញ្ចប់ការងារស្តារការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅទីរួមខេត្តមួយចំនួន ។ កិច្ចព្រមព្រៀងជាច្រើនជាមួយបណ្តាប្រទេសជិតខាងត្រូវបានចុះហត្ថលេខា ដើម្បីនាំចូលថាមពលអគ្គិសនីសម្រាប់ការប្រើប្រាស់នៅតាមតំបន់ព្រំដែន ។ នៅក្នុងទីរួមស្រុកមួយចំនួន ក្រុមហ៊ុនឯកជនបានផ្គត់ផ្គង់ដល់តម្រូវការថាមពលអគ្គិសនីរបស់មូលដ្ឋាន ។ រាជរដ្ឋាភិបាលកម្ពុជាក៏កំពុងតែជំរុញផងដែរ នូវការអភិវឌ្ឍប្រភពថាមពលដែលថោកជាង ដែលអាចកកើតជាថ្មីបាន និងដែលអាចជំនួសបាន ដូចជា ថាមពលព្រះអាទិត្យ (បានតម្លើងប្រើប្រាស់រួចហើយនៅតំបន់មួយចំនួន) ថាមពលខ្យល់ ឧស្ម័នធម្មជាតិ និងប្រព័ន្ធវារីអគ្គិសនីខ្នាតតូច ។ ការអភិវឌ្ឍដ៏សំខាន់ថ្មីមួយទៀតនៅក្នុងវិស័យថាមពលនេះ គឺការរកឃើញនូវប្រភពធនធានប្រេងកាតនិងឧស្ម័ននៅតាមកន្លែងខ្លះសាកល្បងក្នុងដែនសមុទ្រ ដោយធ្វើឱ្យមានក្តីសង្ឃឹមទៅលើប្រភពដ៏សម្បូរនៃថាមពលនៅក្នុងរយៈពេលពីរ-បីឆ្នាំខាងមុខ ដែលនឹងជួយជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ហើយជាមួយនេះនឹងជួយឱ្យមានការកើនឡើងនៃកម្រិតរបស់ប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស ។ បញ្ហាដែលត្រូវធ្វើចំពោះមុខ គឺត្រូវរៀបចំផែនការឱ្យបានច្បាស់លាស់ ដើម្បីប្រើប្រាស់ធនធានទាំងនេះ ជាពិសេស ឧស្ម័នដែលជាធម្មតាត្រូវបានខ្ជះខ្ជាយនៅក្នុងដំណើរការបូមយកប្រេង ។

**២.៤៥ ព័ត៌មាននិងទូរគមនាគមន៍** : ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ វិស័យទូរគមនាគមន៍មានការរីកចម្រើនយ៉ាងខ្លាំង គួរឱ្យកត់សម្គាល់ ។ នៅដំណាច់ឆ្នាំ១៩៩៨ ដង់ស៊ីតេមធ្យមនៃការប្រើប្រាស់ទូរស័ព្ទ សម្រាប់ទូទាំងប្រទេស បង្ហាញថា ក្នុងចំណោមប្រជាជន១០០នាក់ មានប្រជាជន០,៧៤នាក់ ដែលមានទូរស័ព្ទប្រើ ហើយសម្រាប់ទីក្រុងភ្នំពេញ ដង់ស៊ីតេនេះមាន ២,១៧នាក់ ។ នៅចុងឆមាសទី១នៃឆ្នាំ២០០៥ តួលេខនេះបានកើនឡើងដល់ ៥,៥៧នាក់ សម្រាប់ទូទាំងប្រទេស និង ៤៤,៧០នាក់ សម្រាប់ទីក្រុងភ្នំពេញ ។ អតិថិជនជិត ៨០៦.២០០នាក់ ប្រើប្រាស់សេវាកម្ម ដែលផ្តល់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រុមហ៊ុនទូរគមនាគមន៍ឯកជន ។ អតិថិជនជាង ៨.០០០នាក់ ប្រើប្រាស់សេវាអ៊ិនធឺណេត ។ ប៉ុន្តែ តម្លៃប្រើប្រាស់សេវាទូរគមនាគមន៍នៅតែមានកម្រិតខ្ពស់ ដែលជាបន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់ប្រជាជនទាំងមូល ក៏ដូចជា សម្រាប់ធុរៈកិច្ចផងដែរ ។ ដោយចាប់ផ្តើមពីកម្រិតមួយដែលមិនអាចទុកចិត្តបាន សេវាកម្មប្រៃសណីយ៍ត្រូវបានពង្រីក និងទទួលបាននូវជំនឿទុកចិត្តបន្ថែមទៀតពីសាធារណជន ។ ដើម្បីឱ្យប្រជាជនបាន តាមដានពីវឌ្ឍនភាព និងព័ត៌មានទាំងឡាយដែលកើតឡើងថ្មីៗ ការផ្សាយរបស់ទូរទស្សន៍ជាតិ ត្រូវបានធ្វើឱ្យប្រសើរឡើងជាងមុនហើយ គុណភាពនៃកម្មវិធីផ្សាយ ត្រូវបានកែលម្អជាបន្តបន្ទាប់ ។ ស្ថានីយ៍ទូរទស្សន៍តាមមូលដ្ឋាន ក៏បានដំណើរការ ការផ្សាយនៅក្នុងទីរួមខេត្តមួយចំនួន ។

### ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ

**២.៤៦** ការជំរុញលើកទឹកចិត្តវិស័យឯកជន ដែលជាកម្លាំងជំរុញដ៏ចម្បងនៃកំណើនសេដ្ឋកិច្ច គឺជាមូលដ្ឋានគ្រឹះនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីការផ្តើមដំណើរការ និងត្រូវបានលើកឡើងម្តងទៀតនៅក្នុងយុទ្ធសាស្ត្រចតុកោណ ។ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើរតួជាអង្គភាពកណ្តាល ដើម្បីទាក់ទាញនិងសម្រួលការវិនិយោគឯកជននៅកម្ពុជា ។ វេទិកាចម្រុះកម្រិតខ្ពស់រវាង រាជរដ្ឋាភិបាលនិងផ្នែកឯកជន ត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ១៩៩៩ ដែលបានគាំទ្រដោយក្រុមការងារចម្រុះតាមវិស័យរវាងរដ្ឋាភិបាលនិងផ្នែកធុរៈកិច្ចចំនួនប្រាំពីរ ។ ដំណើរការនេះ ត្រូវបានពង្រឹងនិងពង្រីកជាបន្តទៀត នាខែសីហា ឆ្នាំ២០០៤ តាមរយៈការបង្កើតគណៈកម្មាធិការដឹកនាំកម្រិតខ្ពស់មួយ សម្រាប់ការអភិវឌ្ឍវិស័យឯកជន ។ គណៈកម្មាធិការនេះមានការទទួលខុសត្រូវដោយឡែកមួយចំនួន រួមមាន ការលើកសំណើនិងការអនុវត្តវិធានការទាំងឡាយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ ការសម្រួលផ្នែកពាណិជ្ជកម្ម ហើយដើម្បីជំរុញលើកទឹកចិត្តការអភិវឌ្ឍវិស័យឯកជន ។

**តារាង២.៣ : *ផសស* : ឧស្សាហកម្ម និងសេវាកម្ម**

| សូចនាករសំខាន់ៗ | ១៩៩៣ | ២០០០ | ២០០៥ (ការប៉ាន់ស្មាន) |
|---|---|---|---|
| ***តម្លៃថេរ (គិតជាពាន់លានរៀល)*** | | | |
| ***ឧស្សាហកម្មទាំងមូល*** | **១.១០១** | **៣.០៧៨** | **៦.២៥០** |
| %នៃ *ផសស* | *១២.៤* | *២១.៨* | *២៧.៧* |
| កម្មន្តសាល | ៦៨៣ | ២.២៥៥ | ៤.៥៨១ |
| %នៃ *ផសស* | *៨.០* | *១៦.០* | *២០.៩* |
| *ក្នុងនោះ* វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង | ៦៣ | ១.២៩៧ | ៣.៣៧៧ |
| %នៃ *ផសស* | *០.៧* | *៩.២* | *១៧.៣* |
| សំណង់ | ៣៧៤ | ៧៣២ | ១.៤៨៣ |
| %នៃ *ផសស* | *៤.៤* | *៥.២* | *៦.៨* |
| | | | |
| ***សេវាកម្មទាំងមូល*** | **៣.២៦២** | **៥.២៣១** | **៧.៨៣២** |
| %នៃ *ផសស* | *៣៨.៤* | *៣៧.១* | *៣៥.៨* |
| ពាណិជ្ជកម្ម | ១.២៣៣ | ១.៥១២ | ២.១០៤ |
| %នៃ *ផសស* | *១៤.៥* | *១០.៧* | *៩.៦* |
| សណ្ឋាគារ និង ភោជនីយដ្ឋាន | ២០២ | ៥២១ | ១.១០៧ |
| %នៃ *ផសស* | *២.៤* | *៣.៧* | *៥.១* |
| ការដឹកជញ្ជូន និង ទូរគមនាគមន៍ | ៥៣៧ | ៩៣០ | ១.៥១៤ |
| %នៃ *ផសស* | *៦.៣* | *៦.៦* | *៦.៩* |
| សេវាកម្មផ្សេងៗទៀត | ៣៧៧ | ៨៦១ | ១.៤២៨ |
| %នៃ *ផសស* | *៤.៤* | *៦.១* | *៦.៥* |

***ប្រភព :*** *គណនេយ្យជាតិកម្ពុជា ឆ្នាំ២០០៣-២០០៤ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

**២.៤៧** ការវិនិយោគរបស់ផ្នែកឯកជននៅកម្ពុជា ត្រូវបានធ្វើឡើងនៅក្នុងវិស័យជាច្រើន ប៉ុន្តែវិស័យដែលគួរឱ្យកត់សម្គាល់ច្រើនជាងគេនោះគឺ ឧស្សាហកម្មកាត់ដេរ ទេសចរណ៍ ការងារសំណង់ ធនាគារ អាកាសចរណ៍ ព្រៃឈើ និងកសិដ្ឋានដំណាំ ។ ដូចបានបញ្ជាក់ពីខាងដើម គម្រោងជារូបភាព *សាងសង់-ដំណើរការ-ផ្ទេរ* មួយចំនួន ត្រូវបានដំណើរការដោយផ្នែកឯកជន ។ នៅពេលថ្មីៗនេះ ផ្នែកឯកជនបានចូលរួមយ៉ាងសកម្មផងដែរក្នុងវិស័យអប់រំកម្រិតឧត្តមសិក្សា ។ ប៉ុន្តែ លំហូរចូលនៃការវិនិយោគទៅក្នុងវិស័យអាទិភាព មានសភាពយឺតខ្លាំងជាអាទិ៍ វិស័យអាទិភាពមួយចំនួនដែលរាជរដ្ឋាភិបាលចាត់ទុកថា មានប្រៀបខ្លាំងក្នុងការប្រកួតប្រជែង និងអាចផ្តល់ចំណូលខ្ពស់ ដូចជា កសិកម្ម ការកែច្នៃកសិផល ហេដ្ឋារចនាសម្ព័ន្ធ ។ល។

**២.៤៨** ដោយមានគោលបំណងបម្រើតែទីផ្សារនាំចេញទាំងស្រុង ឧស្សាហកម្មកាត់ដេរ បានផលិតទំនិញប្រមាណ ៨០ភាគរយនៃការនាំចេញសរុបរបស់កម្ពុជា នៅឆ្នាំ២០០៤ ដោយបានកើនឡើងពីត្រឹមតែ ២៦,២លានដុល្លារអាមេរិក នៅឆ្នាំ១៩៩៥ ដល់ ១.៩៨៦លានដុល្លារអាមេរិក នៅឆ្នាំ២០០៤ ។ ផ្ទុយពីការព្យាករណ៍ជាច្រើនដែលគិតថា ល្បឿនកំណើននេះអាចនឹងថយចុះមកយឺតវិញ នៅឆ្នាំ២០០៥ ដោយសារតែកិច្ចព្រមព្រៀងពហុសសៃអំបោះត្រូវបានបញ្ចប់ ជាក់ស្តែង ការនាំចេញសំលៀកបំពាក់នៅតែបន្តកើនឡើងនៅក្នុងកម្រិតមួយខ្ពស់គួរឱ្យភ្ញាក់ផ្អើល ។ នៅពេល ដែលជោគជ័យនេះត្រូវបានទទួលការស្វាគមន៍ ដោយសារតែការរួមចំណែកយ៉ាងច្រើននៃឧស្សាហកម្មនេះនៅក្នុងសេដ្ឋកិច្ចនិងការបង្កើតការងារនោះ ការពឹងផ្អែកទៅលើផលិតផលតែមួយមុខ អាចនឹងបណ្តាលឱ្យមានការគាំងភ្លាមៗនូវវិឌ្ឍនភាព ។ ដូច្នេះ ការរៀបចំឱ្យមានការផលិតផលិតផលច្រើនមុខក្នុងវិស័យឧស្សាហកម្ម គឺជាការងារបន្ទាន់ ចំពោះមុខ ។

**២.៤៩** តួលេខក្នុងតារាង ២.៣ បង្ហាញយ៉ាងច្បាស់លាស់ពីវិស័យឧស្សាហកម្ម។ ផលិតផលឧស្សាហកម្ម កំពុងកើនឡើងយ៉ាងឆាប់រហ័ស ហើយបច្ចុប្បន្ននេះ បានរួមចំណែក ២៨,៦ភាគរយ នៃ*ផសស* នៅឆ្នាំ២០០៥ ដោយបានកើនឡើងពី ១៣ភាគរយ នៅឆ្នាំ១៩៩៣ ដល់ ២១,៨ភាគរយ នៅឆ្នាំ២០០០ ហើយនៅតែបន្តកើនឡើង ។ វិស័យកាត់ដេរ តែឯងបានរួមចំណែករហូតដល់ ១៦ភាគរយ នៃ *ផសស* នៅឆ្នាំ២០០០ ។

**២.៥០** សហគ្រាសតូចនិងមធ្យមដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច និងក្នុងការបង្កើតឱ្យមានការងារនិងប្រាក់ចំណូល ប្រកបដោយចីរភាពសម្រាប់ប្រជាជន ។ សហគ្រាសតូចនិងមធ្យម មានសមាមាត្រ ប្រមាណ ៩៩ភាគរយ នៃសហគ្រាសទាំងអស់ ហើយស្រូបយកជិតពាក់កណ្តាលនៃការងារទាំងអស់ដែលបង្កើតឡើងដោយផ្នែកឯកជន ។ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័ត*ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសតូចនិងមធ្យម* ដ៏ទូលំទូលាយមួយសម្រាប់កម្ពុជា ហើយថ្មីៗនេះ បានរៀបចំនូវ*កម្មវិធីអភិវឌ្ឍន៍សហគ្រាសតូចនិងមធ្យម* ។ លេខាធិការដ្ឋានពិសេសមួយសម្រាប់សហគ្រាសតូចនិងមធ្យម ត្រូវបានបង្កើតឡើង ដើម្បីអនុវត្តគោលនយោបាយ និងកម្មវិធីនានា នៅក្នុងការងារនេះ ។

**២.៥១** វិស័យសេវាកម្មកើនឡើងផងដែរ បើគិតជាតម្លៃដាច់ខាត ប៉ុន្តែសមាមាត្ររបស់វិស័យនេះគិតជាភាគរយនៅក្នុង*ផសស* មាននិន្នាការនៅស្ថេរ ឬអាចមានការថយចុះ។ *វិស័យទេសចរណ៍* និងសកម្មភាពពាក់ព័ន្ធទាំងឡាយ បានជំរុញឱ្យមានការរីកចម្រើននៅក្នុងវិស័យសេវាកម្មទាំងមូល ហើយបានបង្កើតឱ្យមានការងារជាច្រើនប្រភេទ តាមរយៈឥទ្ធិពលនៃតម្រូវការការងារតៗគ្នា ។ ចំនួនភ្ញៀវទេសចរណ៍មកកាន់កម្ពុជា ដែលភាគច្រើនទាក់ទាញដោយតំបន់ប្រាសាទបុរាណនៅខេត្តសៀមរាប បានបង្ហាញពីកំណើនមួយ ដែលមានសន្ទុះទៅមុខឥតឈប់ឈរ និងខ្លាំងក្លា ។ បើប្រៀបធៀបនឹងចំនួន ២៨៦.៥២៤នាក់ នៅក្នុងឆ្នាំ១៩៩៨ បន្ទាប់ពីបានថយចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ១៩៩៧ ដោយសារព្រឹត្តិការណ៍មិនអំណោយផលនៅក្នុងប្រទេស ចំនួនភ្ញៀវទេសចរណ៍បានកើនឡើងដល់

៤៦៦.៣៦៥នាក់ នៅក្នុងឆ្នាំ២០០០ មាន ១,០៥៥លាននាក់ នៅក្នុងឆ្នាំ២០០៤ ហើយអាចនឹងលើសពី ១,៣០ លាននាក់ នៅក្នុងឆ្នាំ២០០៥ ដោយចូលរួមចំណែកក្នុងការរកចំណូលជារូបិយប័ណ្ណបរទេស បាន ៦០០លានដុល្លារអាមេរិក ។

**២.៥២** នៅក្នុងចំណោមពលរដ្ឋទាំងអស់ ដែលស្ថិតនៅក្នុងសកម្មភាពសេដ្ឋកិច្ច (ដោយមិនរាប់បញ្ចូលនូវកម្លាំងពលកម្មតាមផ្ទះ សិស្ស/និស្សិត អ្នកទទួលកម្រៃពីប្រាក់ចំណូល និវត្តជន ជនពិការដែលមិនធ្វើការ) *អត្រាអត់ការងារធ្វើ* បើគិតជាមធ្យម មានកម្រិតទាប គឺតិចជាង ៤ភាគរយ[១] បើគិតជារួមនៅទូទាំងប្រទេស ប៉ុន្តែ ការលើកឡើងនេះ ពុំបានគិតដល់ ភាពមានការងារធ្វើមិនពេញលេញដែលស្ថិតនៅក្នុងកម្រិតមួយខ្ពស់ទេ ។ នៅក្នុងចំណោមអ្នកមានការងារធ្វើ មានប្រហែល ៦២ភាគរយ នៅក្នុងវិស័យកសិកម្ម ព្រៃឈើ និងនេសាទ (បានធ្លាក់ចុះពី ៧៥ភាគរយ នៅក្នុងឆ្នាំ១៩៩៩) ៩,៦ភាគរយ នៅក្នុងវិស័យកម្មន្តសាល (បានកើនឡើងពី ៤,៧ភាគរយ នៅឆ្នាំ១៩៩៩) ហើយមាន ១៣,៩ភាគរយ នៅក្នុងពាណិជ្ជកម្មលក់ដុំនិងរាយ ។

**២.៥៣** ដើម្បីកែលម្អលក្ខខណ្ឌការងារនិងធានាការការពារសិទ្ធិកម្មករ ច្បាប់ការងារត្រូវបានប្រកាសឱ្យប្រើប្រាស់ជាធរមាន។ ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ការងារនេះ បានកែលម្អលក្ខខណ្ឌការងារ។ *អង្គការពលកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ* ដែលកំពុងតាមដានត្រួតពិនិត្យលក្ខខណ្ឌការងារនៅកម្ពុជា បានប្រកាសថា ឧស្សាហកម្មកាត់ដេរនិងស្បែកជើងនៅកម្ពុជា មិនជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មដោយការបង្ខិតបង្ខំ ពលកម្មកុមារ និងការរើសអើងនោះទេ ។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើត*គណៈកម្មការប្រឹក្សាការងារ* និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របទៅតាមច្បាប់ការងារ ។ តាមការត្រួតពិនិត្យទៅលើសហគ្រាសជាង ៥.៥០០ មានសហគ្រាសប្រហែល ៤.០០០ ដែលត្រូវបានរកឃើញថា បានរំលោភទៅលើល័ក្ខខ័ណ្ឌខ្លះនៃច្បាប់ការងារ ។ សេចក្តីជូនដំណឹងជាការព្រមាន ត្រូវបានធ្វើទៅឱ្យសហគ្រាសជាច្រើន ហើយការផាកពិន័យ ត្រូវបានធ្វើឡើងចំពោះសហគ្រាសមួយចំនួនដែរ ។ សមាគមសម្រាប់កម្រិតសហគ្រាស ប្រមាណជាង ៥០០ សហព័ន្ធសហជីពចំនួន ១៦ និងសម្ព័ន្ធសហជីពចំនួន ១ ដែលមានសមាជិកប្រមាណ ២០០.០០០នាក់ត្រូវបានចុះបញ្ជី ។ អ្នកស្វែងរកការងារ ត្រូវបានទទួលជំនួយផងដែរក្នុងការស្វែងរកការងារ រួមមាន ការស្វែងរកការងារនៅក្រៅប្រទេស ។

**២.៥៤** ក្នុងឋានៈជាផ្នែកមួយនៃ*សេវាកម្មសង្គម* អតីតយុទ្ធជននិងមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ បន្តទទួលបាននូវប្រាក់បៀវត្សរ៍ប្រចាំខែ ដែលត្រូវបានកើនឡើងយ៉ាងច្រើនដែរ ។ ជនរងគ្រោះពីគ្រោះមហន្តរាយធម្មជាតិដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត និង ភ្លើងឆេះផ្ទះ បន្តទទួលបានជំនួយ ។ ជំនួយក្នុងការធ្វើនីតិសម្បទា ការបណ្តុះបណ្តាល និងការធ្វើសមាហរណកម្មឡើងវិញ ត្រូវបានផ្តល់ដល់យុវជនដែលប្រព្រឹត្តបទល្មើស និង ជនពិការ

---

[១] អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៣-២០០៤

(៦០ភាគរយនៃជនពិការចំនួន ១៦៩.០០០នាក់ គឺជាជនរងគ្រោះដោយសង្គ្រាម) ។ បន្ទាប់ពីការអនុម័តយកនូវ *គោលនយោបាយសម្រាប់ជនចាស់ជរា* ក្នុងឆ្នាំ២០០៣ សមាគមជនចាស់ជរាចំនួន ១៩៤ ត្រូវបានបង្កើតឡើងក្នុងខេត្ត-ក្រុងចំនួន ១២ ។ ចំពោះការការពារកុមារ ការយកចិត្តទុកដាក់ បានផ្តោតលើការបង្កើតឡើងនូវ *បណ្តាញការពារកុមារដែលផ្អែកលើសហគមន៍* ដែលបានជួយដល់ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ និង ភូមិ ជាច្រើន ។

## ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

**២.៥៥** ផ្នែកនេះ គឺជាមុំកំណើនសំខាន់បំផុតក្នុងយុទ្ធសាស្ត្រចតុកោណ ព្រោះថាគោលដៅអភិវឌ្ឍន៍ទាំងអស់សំដៅឆ្ពោះទៅរកការលើកកម្ពស់ស្ថានភាពរបស់ធនធានមនុស្ស ។

**២.៥៦** *ការអប់រំ* គឺជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ហើយបានរួមចំណែកដោយផ្ទាល់ ក្នុងការកាត់បន្ថយភាពក្រីក្រតាមរូបភាពជាច្រើន ដូចជា តាមរយៈការផ្តល់លទ្ធភាពទទួលនូវចំណេះដឹងច្រើនជាងមុន ក្នុងការទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពនៃកំណើនសេដ្ឋកិច្ច ។ ដូច្នេះ វិស័យអប់រំត្រូវបានទទួលនូវអាទិភាពខ្ពស់នៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ។ វឌ្ឍនភាពដែលបានធ្វើឱ្យកើតមានឡើងរហូតមកទល់នឹងពេលនេះ បង្ហាញពីជោគជ័យដ៏ពិតប្រាកដមួយ សម្រាប់ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល រួមគ្នាជាមួយនឹងកិច្ចសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស តាមរយៈអភិក្រមនៃការគ្រប់គ្រងទូទាំងវិស័យ ។ ក្នុងរយៈ ពេល៥ឆ្នាំកន្លងទៅនេះ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០១-២០០៥ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត ដើម្បីកែទម្រង់វិស័យអប់រំ កែលម្អគុណភាពអប់រំ និងពង្រីកវិសាលភាពវិស័យនេះ ។ ការបែងចែកថវិការបស់ រាជរដ្ឋាភិបាលកម្ពុជា ចំពោះវិស័យនេះ ដែលជាផ្នែកមួយនៃកម្មវិធីសកម្មភាពអាទិភាព[១] បានកើនឡើងពី ១០ភាគរយ នៃថវិកាសរុបក្នុងឆ្នាំ ១៩៩៧ ដល់ ១៩.៥ភាគរយ ក្នុងឆ្នាំ២០០៤ និងឈានដល់ ២០ភាគរយ ក្នុងឆ្នាំ២០០៥ ។ ប្រហែល ៦០ភាគរយនៃទឹកប្រាក់បែងចែកនេះ គឺសម្រាប់ការអប់រំជាមូលដ្ឋាន ដោយផ្តោតការយកចិត្តទុកដាក់លើចំណាយដែលគាំទ្រអ្នកក្រ ។ ទោះបីជាដូចនេះក្តី បញ្ហាមួយចំនួនក្នុងការផ្តល់ថវិកាដែលបានបែងចែកឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលានៅតែបន្តមាន ហើយបញ្ហាទាំងនេះត្រូវតែដោះស្រាយឱ្យបានឆាប់រហ័ស ។

**២.៥៧** អត្រាពិតនៃការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សា ក៏ដូចជា អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ និងពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ បានបង្ហាញឱ្យឃើញពីវឌ្ឍនភាពយ៉ាងច្រើន ។ កំណើននៃការសិក្សារបស់សិស្សស្រីនៅបឋមសិក្សា នៅតែបន្តនាំមុខការសិក្សារបស់សិស្សប្រុស (សិស្សស្រី ២៧ភាគរយ និងសិស្សប្រុស ២២ភាគរយ ចាប់តាំងពីឆ្នាំ១៩៩៩) ដោយបានកាត់បន្ថយគម្លាតយេនឌ័រនៃការសិក្សា ។ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកំពុងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ឬគម្លាត

---

[១] កម្មវិធីសកម្មភាពអាទិភាព រួមមាន វិស័យអប់រំ សុខាភិបាល កសិកម្ម និងការអភិវឌ្ឍជនបទ

នៃការអប់រំ ។ ទោះជាដូចនេះក្តី ទន្ទឹមនឹងចំនួនសិស្សច្រើនចូលរៀននៅសាលាត្រូវបានចាត់ជាកត្តាមួយដ៏សំខាន់ គុណភាពនៃការអប់រំ ក៏ដូចជាលទ្ធផលនៃការសិក្សារបស់សិស្ស អត្រាបោះបង់ចោលការសិក្សានិងត្រួតថ្នាក់ និងផលធៀបសិស្ស-គ្រូ ក៏ជាប្រការចាំបាច់ដែលត្រូវផ្តោតការយកចិត្តទុកដាក់ឱ្យបានច្រើនជាងមុនផងដែរ ។

**២.៥៨** ដើម្បីលើកកម្ពស់កម្រិតស្តង់ដាររបស់ឧត្តមសិក្សា ដែលបច្ចុប្បន្ននេះ ការចូលរួមរបស់វិស័យឯកជនកំពុងតែកើនឡើង រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការវាយតម្លៃគុណភាព ដើម្បីតាមដានត្រួតពិនិត្យលើគុណភាពនៃការបណ្តុះបណ្តាល និងដើម្បីធានាថា និស្សិតដែលបានបញ្ចប់ការសិក្សាមានសមត្ថភាព និងគុណភាពគ្រប់គ្រាន់ ដើម្បីបំពេញការងារសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រទេសជាតិ ។

## តារាង២.៤ : សូចនាករអប់រំ

| សូចនាករ | ១៩៩៣ | ២000 | ២០០៥ (ការប៉ាន់ស្មាន) |
|---|---|---|---|
| ចំនួនសាលាបឋមសិក្សា | ៤.៦៩៣ | ៥.៤៦៨ | ៦.១៨០ |
| ចំងាយផ្លូវដែលឆ្ងាយបំផុតទៅកាន់សាលាបឋមសិក្សា (គ.ម) | | ២ | ១,៥ |
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា (សរុប-សិស្សប្រុស-សិស្សស្រី) | | ៨៧ - ៩០- ៨៤ | ៩១,៩- ៩៣ - ៩០,៧ |
| អត្រាគង់វង្សនៅថ្នាក់ទី១-ទី៦ | | ៥១,០ | ៥៣,១ |
| ចំនួនសាលាមធ្យមសិក្សាបឋមភូមិ | ៣៥៤ | ៣៦៧ | ៨០០ |
| ចំងាយផ្លូវដែលឆ្ងាយបំផុតទៅកាន់មធ្យមសិក្សាបឋមភូមិ (គ.ម) | | ៨ | ៤ |
| អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (សរុប-សិស្សប្រុស-សិស្សស្រី) | | ១៩ - ២១- ១៦ | ២៦,១- ២៧,១-២៤,៨ |
| អត្រាគង់វង្សនៅថ្នាក់ទី១-ទី៩ | | ៣៣ | ៣០,១៨ |
| អត្រានៃអក្ខរជនពីអាយុ១៥-២៤ឆ្នាំ | | ៨២ (១៩៩៨) | ៨៣,៤ |

***ប្រភព :*** *កម្រងស្ថិតិប្រចាំឆ្នាំ ២០០៣ និង ក្រសួងអប់រំ យុវជន និងកីឡា*

**២.៥៩** *សុខាភិបាល* : វិស័យនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ អវត្តមាននៃសុខភាពល្អ គឺជាមូលហេតុនិងផលវិបាកមួយនៃភាពក្រីក្រ ។ ចំពោះហេតុផលសំខាន់ៗនានានិងហេតុផលផ្សេងៗទៀត ដូចជា កង្វះខាតសមត្ថភាព ក្នុងនោះមាន ធនធានមនុស្សដែលមានការបណ្តុះបណ្តាល សន្ទស្សន៍សុខភាពសំខាន់ៗមានកម្រិតទាបច្រើននៅឡើយ បើធៀបនឹងប្រទេសជិតខាងក្នុងសមាគមអាស៊ាន ។ ទោះជាដូចនេះក្តី សន្ទស្សន៍ភាគច្រើនបំផុតបង្ហាញពីការធ្វើឱ្យប្រសើរឡើងជាវិជ្ជមាន នៅក្នុងបណ្តាឆ្នាំថ្មីៗនេះ ហើយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលបានកំណត់សម្រាប់ឆ្នាំ២០១៥ អាចនឹងសម្រេចបាន ឬអាចសម្រេចលើសពីការកំណត់នៅក្នុងករណីមួយចំនួន ។ ជម្ងឺគ្រុនស្វិតដៃជើងត្រូវបានលុបបំបាត់ចោលទាំងស្រុង ហើយសមត្ថភាពផលិតអំបិលអ៊ីយ៉ូដក្នុងប្រទេសសម្រេចបានមានលើសពីតម្រូវការទូទាំងប្រទេស ។ ទោះបីដូចនេះក្តី បញ្ហាប្រឈមដែលនៅតែមាន គឺការផ្តល់នូវលទ្ធភាពទទួលបានសេវាកម្មដែលមានលក្ខណៈងាយស្រួលជាងមុននិងមានតម្លៃតិចជាងមុន ដល់អ្នកក្រ ដើម្បីផ្សារភ្ជាប់នូវតម្លាត

រវាងតំបន់ទីប្រជុំជននិងជនបទ ក៏ដូចជារវាងក្រុមមនុស្សដែលមានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចខុសៗគ្នា ។ ផ្លូវថ្នល់ជនបទដែលមានសណ្ឋានប្រសើរជាងមុន និងប្រាក់បៀវត្សខ្ពស់ជាងមុនសម្រាប់មន្ត្រីរាជការស៊ីវិល អាចជួយសម្រួលដល់ទិដ្ឋភាពមួយចំនួនក្នុងការកាត់បន្ថយនូវគម្លាតទាំងនោះ ។

**២.៦០** ទោះបីជាវឌ្ឍនភាពជាច្រើនសម្រេចបាននៅក្នុងវិស័យសុខាភិបាលក៏ដោយ ការឈានទៅដល់កម្រិតដ៏សមស្របនៃស្ថានភាពសុខាភិបាល ត្រូវដើរនៅលើផ្លូវដ៏វែងឆ្ងាយនៅឡើយ ជាពិសេស ចំពោះការកាត់បន្ថយអត្រាមរណភាពមាតានិងទារក ។ ប៉ុន្តែ វិធានការនានាដែលកំពុងត្រូវបានដាក់ឱ្យអនុវត្ត ជាសញ្ញាមួយដ៏ល្អប្រសើរនាពេលអនាគត ។ ចំនួនសរុបនៃមជ្ឈមណ្ឌលសុខភាពដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីផ្តល់សំណុំសកម្មភាពអប្បបរមាបានកើនឡើងពី ៣៨៦ ក្នុងឆ្នាំ១៩៩៨ ដល់ ៨៣២ ក្នុងឆ្នាំ២០០៤ ហើយចំនួនមន្ទីរពេទ្យបង្អែកសរុបមាន ៦៩ ដែលក្នុងនោះ មន្ទីរពេទ្យបង្អែកចំនួន១៥ បានផ្តល់នូវសំណុំសកម្មភាពបង្គ្រប់នៅឆ្នាំ២០០៤ ។ ជោគជ័យក្នុងវិធានការត្រួតពិនិត្យជម្ងឺ អាចកត់សម្គាល់បានតាមរយៈ (១) ការបង្កើនការព្យាបាល/ការការពារជម្ងឺរបេង (២) ការធ្លាក់ចុះនៃអត្រានៃការកើតឡើងនិងអត្រានៃករណីមរណភាព ដោយសារជម្ងឺគ្រុនចាញ់ គ្រុនឈាម កញ្ច្រិល និងអាសន្នរោគ (៣) ការលុបបំបាត់ទាំងស្រុងនូវជម្ងឺគ្រុនស្វិតដៃជើងនៅក្នុងឆ្នាំ២០០០ ។ ភាគរយនៃស្ត្រីមានផ្ទៃពោះដែលបានទៅពិនិត្យផ្ទៃពោះយ៉ាងហោចណាស់បានពីរដងមុនពេលសម្រាល បានកើនឡើងពី ២៩ភាគរយ នៅក្នុងឆ្នាំ២០០២ ដល់ ៤៧ភាគរយនៅក្នុងឆ្នាំ២០០៤ ។ ប៉ុន្តែទោះបី ជាមានការធ្លាក់ចុះ ដូចដែលបានបង្ហាញក្នុងតារាង ២.៥ ខាងក្រោមក៏ដោយ ក៏អត្រាមួយចំនួននៅតែមានកម្រិតខ្ពស់ជាងគេនៅឡើយនៅក្នុងតំបន់ ។ បញ្ហាដ៏គួរឱ្យព្រួយបារម្ភមួយដែលកំពុងលេចឡើង គឺការកើនឡើងនៃការប្រើប្រាស់គ្រឿងញៀន នៅក្នុងចំណោមយុវជនកម្ពុជានៅក្នុងរយៈពេលពីរ-បីឆ្នាំចុងក្រោយនេះ ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ។

**២.៦១** *ការថយចុះនៃអត្រាមនុស្សពេញវ័យដែលត្រូវបានធ្វើតេស្តឈាមឃើញថាមានមេរោគហ៊ីវវិជ្ជមាន* បានកើតមានឡើង ជាមួយនឹងការយល់ដឹងកម្រិតខ្ពស់ពីមេរោគហ៊ីវ/អេដស៍ ដោយសារការខិតខំប្រឹងប្រែងរួមគ្នាដ៏គួរឱ្យកត់សម្គាល់ តាមរយៈការប្តេជ្ញាចិត្តខ្ពស់របស់រដ្ឋាភិបាល ការផ្តល់មូលនិធិដ៏ច្រើនពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធនៅក្នុងចំណោមដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ដែលពាក់ព័ន្ធក្នុងការងារនេះ ។ នៅក្នុងឆ្នាំ២០០១ ដោយបានទទួលស្គាល់ពីសារៈសំខាន់នៃការឆ្លើយតបជាលក្ខណៈវិមជ្ឈការតាមរយៈយន្តការពហុវិស័យចំពោះការរីករាលដាលនៃមេរោគហ៊ីវ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើត *អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍* ដើម្បីដឹកនាំ សម្របសម្រួលនិងតាមដានត្រួតពិនិត្យការឆ្លើយតបរបស់សង្គមជាតិទាំងមូល តាមរយៈក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង ទាំងអស់ ។ *អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍* តំណាងឱ្យការប្រកាន់ជំហាររបស់កម្ពុជា ចំពោះ

*គោលការណ៍បី-មួយ*[១] និងទទួលខុសត្រូវចំពោះការរៀបចំនិងការត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីរោគហ៊ីវ (២០០១-២០០៥ និង ២០០៦-២០១០) របស់កម្ពុជា ។ បញ្ហាប្រឈមចំពោះមុខ គឺត្រូវរក្សានូវកម្រិតវឌ្ឍនភាព និងកំណត់យុទ្ធសាស្ត្រដើម្បី ទប់ស្កាត់ការរីករាលដាលនៃមេរោគហ៊ីវទៅដល់ក្រុមគ្រួសារ ។

### តារាង២.៥ : សូចនាករសុខាភិបាល

| សូចនាករ | ១៩៩៣ | ២០០០ | ២០០៥ (ការប៉ាន់ស្មាន) |
|---|---|---|---|
| អត្រាមរណភាពទារក ក្នុង១.០០០ កំណើតរស់ | | ៩៥ | ៦៦ |
| អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ក្នុង១.០០០ កំណើតរស់ | | ១២៤ | ៨២ |
| ផលធៀបមរណភាពមាតា ក្នុង១០០.០០០ កំណើតរស់ | | ៤៣៧ | ពុំមានតួលេខ |
| ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) | | ៣២ | ពុំមានតួលេខ |
| កុមារអាយុក្រោម ១ឆ្នាំ បានចាក់ថ្នាំបង្ការជម្ងឺ DPT3 (%) | | ៤៣ | ៨៣ |
| កុមារអាយុក្រោម ១ឆ្នាំ ដែលបានចាក់ថ្នាំបង្ការជម្ងឺកញ្ជ្រិល (%) | | ៤១,៤ | ៨០ |
| ជម្ងឺគ្រុនចាញ់ : អត្រាស្លាប់ (%) | | ០,៤ | ០,៣៦ |
| ជម្ងឺរបេង : អត្រាស្លាប់ (ក្នុងប្រជាជន ១០០.០០០នាក់) | ៩០ (១៩៩៧) | ពុំមានតួលេខ | ពុំមានតួលេខ |
| អត្រាយុវជនដែលផ្ទុកមេរោគអេដស៍ (%នៃយុវជនអាយុ១៥-៤៥) | ៣,០ (១៩៩៧) | ២,៨ | ១,៩ |
| ចំនួនមណ្ឌលសុខភាព | ៥១៤ | ៩៤២ (២០០២) | ៩៦៥ |
| ចំនួនមន្ទីរពេទ្យស្រុកប្រតិបត្តិការ | ៦៥ (១៩៩៧) | ៦៨ (២០០២) | ៦៩ |

***ប្រភព*** *: អង្កេតប្រជាជនពាក់កណ្តាលជំរឿននៅកម្ពុជា ក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ។*
*កំណត់សម្គាល់ : តួលេខទាំងអស់ អាចនឹងកែប្រែទៅតាមទិន្នន័យ ដែលនឹងបានមកពីអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា នាពាក់កណ្តាលឆ្នាំ២០០៦*

**២.៦២** កម្មវិធីសាកល្បងដើម្បីពង្រីកសេវាសុខភាពមូលដ្ឋាន ក្នុងស្រុកប្រតិបត្តិចំនួន ៥ ដោយមានកិច្ចសហការជាមួយផ្នែកឯកជន (អង្គការក្រៅរដ្ឋាភិបាល) តាមរយៈការរៀបចំកិច្ចសន្យា បានអនុវត្តប្រកបដោយជោគជ័យ ដោយបានបង្កើនការផ្តល់សេវាសុខភាពមូលដ្ឋានពីពីរទៅបីដង និងដោយបានកាត់បន្ថយការចំណាយលើសុខភាពរបស់គ្រួសារក្រីក្របានប្រហែលពី ៦០-៧០ភាគរយ ក្នុងរយៈពេល ៣ឆ្នាំ (១៩៩៨-២០០១) ។ កម្មវិធីនេះ ត្រូវបានពង្រីក ដើម្បីគ្របដណ្តប់លើស្រុកប្រតិបត្តិការចំនួន ១១ នៅឆ្នាំ២០០៥ ។ ចំពោះធនធានមនុស្សសម្រាប់វិស័យនេះ ចំនួននិស្សិតដែលបានបញ្ចប់ការបណ្តុះបណ្តាលក្នុងជំនាញថែទាំផ្នែកវេជ្ជសាស្ត្រ បានកើនឡើង ពី ១០៩ ក្នុងឆ្នាំ១៩៩៨ ដល់ ៥៥៩ ក្នុងឆ្នាំ២០០៣ ហើយសិក្ខាកាមប្រហែល ១២.០០០នាក់ បានទទួលការបណ្តុះបណ្តាលនៅនឹងកន្លែង លើការងារសំណុំសកម្មភាពអប្បបរមា ។

**២.៦៣** ចំណាយថវិការបស់រដ្ឋាភិបាលសម្រាប់វិស័យសុខាភិបាល បានកើនឡើង ២៦៤ភាគរយ ចាប់ពីឆ្នាំ១៩៩៨ ដល់ ២០០៤ ។ ជុំវិញបញ្ហាចំណាយថវិកាសម្រាប់វិស័យសុខាភិបាល នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើពោលគឺ មិនត្រឹមតែត្រូវផ្តោតលើការធ្វើវិភាជន៍ជាក់ស្តែងប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានការធានាផងដែរថា ថវិកា

[១] អាជ្ញាធរជាតិ *មួយ* ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ *មួយ* និង ប្រព័ន្ធជាតិ *មួយ* សម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ

ទាំងនោះត្រូវបានផ្ដល់ជូនទាន់ពេលវេលា និងត្រូវបានប្រើប្រាស់សមស្របតាមគោលការណ៍ ។ ប៉ុន្តែ តម្រូវការមានកម្រិតខ្ពស់ខ្លាំង ដោយព្រោះថា ចំណាយជាក់ស្ដែងនៅតែទាប ដោយមិនរាប់បញ្ចូលនូវចំណាយផ្ទាល់របស់វិស័យឯកជន ឬរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។

**២.៦៤** *ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលឆ្នាំ២០០៣-២០០៧* កំពុងត្រូវបានអនុវត្តដោយមានកិច្ចសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដែលកំពុងសហការនៅក្នុងវិស័យនេះ ដោយដំណើរការទៅតាម *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* ។ ការវាយតម្លៃពាក់កណ្ដាលអណត្តិមួយ នឹងត្រូវធ្វើឡើងនៅក្នុងឆ្នាំ២០០៦ ដែលជាពេលដែលផែនការនេះនឹងត្រូវពន្យារដល់ឆ្នាំ២០១០ ដើម្បីឱ្យស្របគ្នាជាមួយនឹងដំណាក់កាលរបស់ *ផយអជ* ។

**២.៦៥** *<u>សមភាពយេនឌ័រ</u>* : បញ្ហាដ៏សំខាន់មួយ គឺត្រូវបង្កើតឱ្យមានតុល្យភាពយេនឌ័រ ដែលប្រកបដោយសមធម៌និងមានស្មេរភាព (រវាងបុរសនិងស្ត្រី រវាងក្មេងប្រុសនិងក្មេងស្រី) ក្នុងការទទួលបាននូវទំនិញនិងសេវាកម្មនានា ការចូលរួមក្នុងនិងការទទួលបានផលប្រយោជន៍ពី ដំណើរការនៃការអភិវឌ្ឍនៅគ្រប់កម្រិតនិងគ្រប់ផ្នែកទាំងអស់ ដូចជាកម្លាំងពលកម្ម ថ្នាក់រៀបចំគោលនយោបាយនិងថ្នាក់ដឹកនាំនយោបាយ ស្ថាប័ននានា ការអប់រំ និងសេវាថែទាំសុខភាព ។ វិសមភាពយេនឌ័រ ក៏ជាមូលហេតុចម្បងនៃភាពក្រីក្រ ជាពិសេស ជាមួយនឹងគ្រួសារដែលមានស្ត្រី (ស្ត្រីមេម៉ាយ) ជាមេគ្រួសារ ។ ដូចនេះ បញ្ហាយេនឌ័រត្រូវបញ្ជ្រាបទៅក្នុងគ្រប់សកម្មភាពទាំងអស់របស់ប្រទេស ហើយគឺជាបញ្ហាមួយក្នុងចំណោមបញ្ហាអន្តរវិស័យដទៃទៀត ។ ការធ្វើឱ្យប្រសើរឡើងជាបណ្ដើរៗត្រូវបានធ្វើឡើងក្នុងរយៈពេលច្រើនឆ្នាំកន្លងមកនេះ ប៉ុន្តែនៅមានបញ្ហាជាច្រើនទៀតដែលត្រូវធ្វើនៅក្នុងការបញ្ជ្រាបនិងបង្កើនកម្រិតនៃការយល់ដឹងអំពីយេនឌ័រ ហើយនឹងត្រូវលេចឡើងនៅក្នុងផ្នែកផ្សេងៗទៀតនៃឯកសារនេះ ។ ក្នុងពេលថ្មីៗនេះ *ច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ* ត្រូវបានអនុម័តរួចហើយ ។ ទន្ទឹមនឹងនេះ សេចក្ដីព្រាងច្បាប់ស្ដីពី*ច្បាប់ប្រឆាំងការជួញដូរ* ត្រូវបានដាក់ជូនទៅដល់រដ្ឋសភា ហើយអាចនឹងត្រូវអនុម័ត នៅក្នុងឆ្នាំ២០០៦ ។

**២.៦៦** *<u>ប្រជាជន</u> :* ប្រជាជនដែលមានការអប់រំ មានសុខភាពល្អ និងមានថាមពលពេញលេញ គឺជាទ្រព្យធន ហើយជាអ្នកបង្កើតនូវទ្រព្យធនរបស់ប្រជាជាតិមួយ ។ ដូចនេះ ប្រជាជន គឺជាបញ្ហាស្នូលនៃការងារទាំងអស់ក្នុងការអភិវឌ្ឍ ហើយជាអ្នករួមចំណែកបង្កើតនិងជាអ្នកប្រើប្រាស់ នូវការអភិវឌ្ឍទាំងនោះ ។ អភិបាលកិច្ចល្អផ្ដល់នូវបរិយាកាសសម្រាប់ប្រជាជនធ្វើឱ្យមានការរីកលូតលាស់ និងធ្វើឱ្យសម្រេចសក្ដានុពលពេញលេញរបស់ខ្លួន ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនផង និងជាប្រយោជន៍របស់សង្គមនិងប្រទេសជាតិផង ។ គោលដៅរបស់គោលនយោបាយជាតិប្រជាជន គឺធ្វើឱ្យមានការផ្លាស់ប្ដូរនៃនិន្នាការប្រជាសាស្ត្រ ដើម្បីធ្វើឱ្យចំនួន សមាសភាព និងរបាយប្រជាជនស៊ីសង្វាក់ជាមួយនឹងភាពចាំបាច់នៃការអភិវឌ្ឍប្រកបដោយចីរភាព សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងសម្រាប់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់រូប ព្រមទាំងដើម្បីធានាឱ្យប្រជាជនកម្ពុជាគ្រប់រូបមានលទ្ធភាព

ប្រើប្រាស់យ៉ាងទូលំទូលាយនូវសេវាសុខភាពបន្តពូជក្នុងឆ្នាំ២០១៥ ។ អាស្រ័យហេតុនេះ នៅក្នុង *គោលនយោបាយជាតិប្រជាជន* របស់កម្ពុជា រាជរដ្ឋាភិបាលបានផ្តល់សារៈសំខាន់យ៉ាងខ្លាំងចំពោះការគាំទ្រដល់សិទ្ធិរបស់គូស្វាមី ដើម្បីធ្វើការសម្រេចចិត្តដោយសេរីនិងដោយទទួលខុសត្រូវ លើចំនួនកូន លើចន្លោះពេលពីកំណើតរបស់កូនមួយទៅកូនមួយទៀត និងលើការកំណត់ពេលវេលាចង់បានកូន ហើយដើម្បីមានលទ្ធភាពទទួលនូវព័ត៌មាន សេវាអប់រំ និងមធ្យោបាយដើម្បីអនុវត្តឆន្ទៈខាងលើនេះ ។ គណៈកម្មាធិការជាតិសម្រាប់ប្រជាជន និងការអភិវឌ្ឍត្រូវបានបង្កើតឡើងដើម្បីអនុវត្តគោលនយោបាយជាតិប្រជាជន ។

## តារាង២.៦ : សូចនាករប្រជាជនសំខាន់ៗ

| សូចនាករសំខាន់ៗ | ១៩៩៣ | ២000 | ២០០៥ (ប៉ាន់ស្មាន) |
|---|---|---|---|
| ចំនួនប្រជាជន (លាននាក់) | ១០,៦៦ | ១២,៩៧ | ១៣,៦៦ |
| សមាមាត្រស្ត្រី/បុរស (ក្នុងចំណោមស្ត្រី១០០) : | ៩១,៧ (១៩៩៦) | ៩៣,០ (១៩៩៨) | ៩៣,៥ (២០០៤) |
| ប្រជាជនពីអាយុ ០-១៤ឆ្នាំ (%) | ៤៣,៩ (១៩៩៦) | ៤២,៨ (១៩៩៨) | ៣៩,០ (២០០៤) |
| ប្រជាជនពីអាយុ ១៥-៥៩ឆ្នាំ (%) | ៥០,៨ (១៩៩៦) | ៥១,៨ (១៩៩៨) | ៥៥,១ (២០០៤) |
| ប្រជាជនពីអាយុ៦០ និងចាស់ជាង (%) | ៥,៣ (១៩៩៦) | ៥,៣ (១៩៩៨) | ៥,៩ (២០០៤) |
| ដង់ស៊ីតេប្រជាជន (ក្នុង១គម $^{២}$) | ៥៩,១ (១៩៩៦) | ៦៤,០ (១៩៩៨) | ៧៤,០ (២០០៤) |
| អាយុសង្ឃឹមរស់មធ្យមពីកំណើត : បុរស/ស្ត្រី | ៥១,៨/៥៥,៨ | ៥៤,៤/៦០,៦ | ៥៧,៩/៦៤,១ |
| អត្រាភាពបង្កើតកូនសរុប | ៥,២ (១៩៩៦) | ៤,០ | ៣,៣ (២០០៤) |
| អត្រាកំណើនប្រចាំឆ្នាំ (%) | ២,៤៩ (១៩៩៨) | ១,៨១ | ១,៨១ (២០០៤) |
| ស្ត្រីរៀបការដែលប្រើប្រាស់វិធីពន្យារកំណើតទំនើប(%) | | ១៨,៥ | ២០,១ |

***ប្រភព*** *: អង្កេតប្រជាសាស្ត្រ ឆ្នាំ១៩៩៦ ជំរឿនប្រជាជន ឆ្នាំ១៩៩៨ វិទ្យាស្ថានជាតិស្ថិតិ*

**២.៦៧** ចំនួនប្រជាជនកម្ពុជាបានទទួលរងការថយចុះយ៉ាងខ្លាំងនៅក្នុងអំឡុងពេលឆ្នាំ១៩៧៥-១៩៧៩ ប៉ុន្តែបានកើនឡើងវិញជាបណ្តើរៗ ចាប់តាំងពីក្រោយដំណាក់កាលនេះមក ដោយសារការថយចុះនៃអត្រាស្លាប់ ការកើនឡើងនៃភាពមានអាយុវែង និងការថយចុះនៃអត្រាស្លាប់របស់ទារក កុមារអាយុក្រោម៥ឆ្នាំ និងមាតា ។ ទោះបីជាសូចនាករមួយចំនួនក្នុងចំណោម សូចនាករទាំងនេះនៅតែមានកម្រិតខ្ពស់នៅឡើយក៏ដោយ បាតុភូតសង្គមទាំងនេះ បានថយចុះគួរឱ្យកត់សម្គាល់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ។ តារាង២.៦ ខាងក្រោម បង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នៃអាយុសង្ឃឹមរស់មធ្យមនៅពេលកើត ដល់៦ឆ្នាំសម្រាប់បុរស និង៩ឆ្នាំសម្រាប់ស្ត្រី ដោយឆ្លុះបញ្ចាំងនូវភាពប្រសើរឡើងនៃសុខុមាលភាពទូទៅ ។ អត្រាកំណើតសរុបមានការថយចុះយ៉ាងច្រើន ។ ទន្ទឹមនឹងនេះ មាននិន្នាការប្រសើរឡើងនៅក្នុងតុល្យភាពភេទ ឬសមាមាត្ររវាងចំនួនបុរសនិងស្ត្រី ដែលបានថយចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ១៩៧៩ ដោយសាររបបប្រល័យពូជសាសន៍ ។ ចំណុចគួរឱ្យកត់សម្គាល់មួយ គឺការកើនឡើងនៃប្រជាជនក្នុងវ័យយុវជន ។ បច្ចុប្បន្ននេះ ៦ភាគរយនៃចំនួនប្រជាជនស្ថិតនៅក្រោមអាយុ ២៥ឆ្នាំ

ហើយក្រុមអាយុ ១០-២០ឆ្នាំមានសមាមាត្រ ៣៦,៥ភាគរយ ។ ដូចនេះ បញ្ហាយុវជន គឺជាកង្វល់និងបញ្ហាប្រឈមមួយដ៏សំខាន់ ជាពិសេស នៅពេលណាដែលមានការកើតឡើងនៃភាពគ្មានការងារធ្វើនិងការធ្វើបម្លាស់ទីលំនៅរបស់យុវជន ហើយនៅពេលណាដែលមានការកើនឡើងនៃសញ្ញានៃឥរិយាបទប្រកបដោយហានិភ័យរបស់យុវជន ក្នុងនោះមាន ការប្រើប្រាស់គ្រឿងញៀនជាដើម ។

## សេចក្តីសន្និដ្ឋាន

**២.៦៨** ទិន្នន័យបរិមាណនិងគុណភាពជាច្រើន ដែលបានបង្ហាញនិងបានយកមកពិភាក្សារហូតមកដល់ត្រឹមនេះ បានបង្ហាញថា តើកម្ពុជាមានការរីកចម្រើនដល់កម្រិតណា ដោយបានចាប់ផ្តើមចេញពីកម្រិតក្រោមសូន្យក្នុងឆ្នាំ ១៩៧៩ ហើយបានបោះជំហានយ៉ាងលឿន ចាប់ពីអាណត្តិទី១នៃរាជរដ្ឋាភិបាល គឺពីឆ្នាំ១៩៩៣ និងជាពិសេសក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ។ រាជរដ្ឋាភិបាលកម្ពុជា ធ្វើការប្តេជ្ញាចិត្ត ដើម្បីពង្រឹងនិងកសាងបន្ថែមពីលើវឌ្ឍនភាពដ៏ធំធេងបែបនេះ ហើយក្នុងករណីមួយចំនួន វឌ្ឍនភាពទាំងនេះមានសភាពគួរឱ្យស្ញើចសរសើរ ។ ដោយមានការប្តេជ្ញាចិត្តដ៏មោះមុត រួមជាមួយនឹងប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដែលធ្វើការដើម្បីប្រទេសជាតិ រាជរដ្ឋាភិបាលកម្ពុជា មានសុទិដ្ឋិនិយមនិងជំនឿជឿជាក់ថា គោលដៅដ៏ធំនេះសម្រាប់ពេលអនាគតដើម្បីនាំកម្ពុជាឆ្ពោះទៅមុខ នឹងអាចសម្រេចបាន ។ *ផយអជ* គឺអំពីអនាគតរបស់កម្ពុជា ដូច្នេះ ផែនការនេះនឹងត្រូវពិភាក្សាបន្ថែមទៀតនៅក្នុងជំពូកបន្តបន្ទាប់ ។

# ជំពូក ៣

## គោលដៅនិងចំណុចដៅអាទិភាព

**៣.០១** ចក្ខុវិស័យយូរអង្វែងរបស់រាជរដ្ឋាភិបាល គឺដើម្បីសម្រេចបានកម្ពុជាមួយ ដែលមានសាមគ្គីភាពសង្គម មានការអប់រំជឿនលឿន និងមានវប្បធម៌ភ្លឺថ្លា ដោយគ្មានភាពក្រីក្រ គ្មានអនក្ខរកម្ម និងគ្មានសុខភាពមិនល្អ សម្រាប់ប្រជាជនកម្ពុជាទាំងអស់រស់នៅជាមួយគ្នាក្នុងភាពសុខុដុម ដោយរួចផុតពីភាពអត់ឃ្លាន វិសមភាព ការបោះបង់ចោល និងភាពងាយរងគ្រោះ ហើយសម្រាប់ពលរដ្ឋទាំងអស់អាចសម្រេចបាននូវសមត្ថភាពពេញលេញក្នុងវិជ្ជាជីវៈដែលពួកគាត់បានជ្រើសរើស ដើម្បីរួមចំណែកក្នុងការធ្វើឱ្យប្រទេសជាតិមានវឌ្ឍនភាពជាបន្តទៅទៀត និងសម្រាប់ការកើនឡើងយ៉ាងខ្ពស់នៃកម្រិតរស់នៅ ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល កំណត់យ៉ាងច្បាស់ពីកម្មវិធីការងារដែលត្រូវធ្វើជាបន្ទាន់ចំពោះមុខ ដូចជា (១) ការជំរុញឱ្យមានកំណើនសេដ្ឋកិច្ច (២) ការបង្កើតការងារសម្រាប់ពលករកម្ពុជាទាំងអស់ (៣) ការអនុវត្តកំណែទម្រង់ដែលចាំបាច់ ដើម្បីធានាឱ្យមានសមធម៌និងយុត្តិធម៌សង្គម និង (៤) ការលើកកម្ពស់ប្រសិទ្ធភាពនៃកម្មវិធីកំណែទម្រង់ទាំងឡាយក្នុងវិស័យទាំងអស់ សំដៅការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងបរិបទនេះ *ផយអជ លើកឡើងអំពីជំហានការងារនិងគោលដៅបន្ទាន់និងរយៈពេលមធ្យម ដែលត្រូវធ្វើនៅពេលអនាគត* ដើម្បីឈានទៅសម្រេចបានយ៉ាងឆាប់រហ័សនូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ។

**៣.០២** នៅពេលដែលអ្នកសង្កេតការអព្យាក្រិត្យ ហើយក៏ដូចជាប្រជាជនកម្ពុជាផងដែរ ទទួលស្គាល់ថា សមិទ្ធផលដែលសម្រេចបានក្នុងរយៈពេលដ៏ខ្លីចុងក្រោយនេះ មានទំហំធំធេង នោះរាជរដ្ឋាភិបាលក៏មើលឃើញយ៉ាងច្បាស់ពីបញ្ហាប្រឈមធំៗទាំងឡាយចំពោះមុខ ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់និងកំណត់អាទិភាពចំពោះគោលដៅនិងសកម្មភាពជាយុទ្ធសាស្ត្រទាំងឡាយ ដែលនឹងអាចធ្វើឱ្យមានវឌ្ឍនភាពដ៏ធំធេងក្នុងគ្រប់វិស័យទាំងអស់ ។ *ជំពូកនេះលើកឡើងពីគោលដៅទាំងឡាយដែល មានលក្ខណៈសម្រិតសម្រាំង មានសារៈសំខាន់ខ្លាំង និងមានអាទិភាពខ្ពស់ មានលក្ខណៈគាំទ្រអ្នកក្រ ព្រមទាំងកំណត់នូវចំណុចដៅសំខាន់ ឬ ចំណុចដៅចម្បង ដែលត្រូវធ្វើឱ្យសម្រេចបានក្នុងរយៈពេល៥ឆ្នាំខាងមុខ ២០០៦-២០១០* ។

**៣.០៣** ការប្រជុំរបស់មេដឹកនាំពិភពលោកនៅអង្គការសហប្រជាជាតិ ក្នុងឆ្នាំ២០០០ បានឯកភាពលើ *សេចក្តីប្រកាសសហស្សវត្សរ៍* មួយ ។ សេចក្តីប្រកាសនោះ គឺជាការប្តេជ្ញាចិត្តជាសាកលមួយ ចំពោះសិទ្ធិមនុស្ស លទ្ធិប្រជាធិតេយ្យ សន្តិភាពនិងសន្តិសុខ និងអភិបាលកិច្ចល្អ ដើម្បីបង្កើតនិងរក្សាស្ថេរភាពបរិស្ថានមួយ ដែលអាចជួយធ្វើឱ្យសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ ។ កម្ពុជាបានគាំទ្រទាំងស្រុង ហើយបានចុះហត្ថលេខា លើ

សេចក្តីប្រកាសនេះ ដោយហេតុថាសេចក្តីប្រកាសនេះ មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងការប្តេជ្ញាចិត្តសម្រាប់រយៈពេលវែងរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជា ស៊ីសង្វាក់គ្នាផងដែរទៅនឹងគោលគំនិតនៃ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើកទី១ និងលើកទី២ ។ សេចក្តីប្រកាស សហស្សវត្សរ៍បានដាក់ចេញនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍អាទិភាពចំនួន ៨ ដោយផ្តោតលើ ការយកចិត្តទុកដាក់និងការប្តេជ្ញាចិត្តរបស់ពិភពលោក ដើម្បីសម្រេចបានចំណុចដៅសំខាន់ៗទាំងឡាយ នៅតាមប្រទេសនីមួយៗ និងជាសកល នៅឆ្នាំ២០១៥ ។

**៣.០៤** ផ្អែកលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក នៅក្នុងឆ្នាំ២០០៣ តាមរយៈដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយមួយក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ កម្ពុជាបានរៀបចំកំណត់គោលដៅប្រាំបួនផ្ទាល់របស់ខ្លួន ដែលហៅថា *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក)* ដោយបន្ថែមគោលដៅមួយទៀត ដែលមានការពាក់ព័ន្ធនិងសារៈសំខាន់ជាបន្ទាន់ចំពោះមុខ ចំពោះប្រទេសជាតិទាំងមូល ។ គោលដៅទាំងនេះរួមមាន :

- លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងការអត់ឃ្លាន ។
- សម្រេចឱ្យបានជាទូទៅការអប់រំមូលដ្ឋានរយៈពេល ៩ ឆ្នាំ ។
- លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី ។
- កាត់បន្ថយអត្រាមរណភាពកុមារ ។
- លើកកម្ពស់សុខភាពមាតា ។
- ប្រយុទ្ធប្រឆាំងនិងមេរោគហ៊ីវ/ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺដទៃទៀត ។
- ធានាចីរភាពបរិស្ថាន ។
- បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ (មិនមែនជាគោលដៅមួយនៃ *គអសក* ប៉ុន្តែជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក) ។
- ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះដោយសារមីន ។

**៣.០៥** គោលដៅទាំង៩នៃ *គអសក* ចែកចេញជាគោលដៅរងជាច្រើន ។ សម្រាប់គោលដៅរងទាំងនោះ ចំណុចដៅច្បាស់លាស់និងអាចវាស់វែងបាន (ឬសូចនាករ) ត្រូវបានកំណត់ឡើង ផងដែរ[១] ។ ការខិតខំប្រឹងប្រែងនិងជោគជ័យក្នុងការធ្វើឱ្យសម្រេចបាននូវចំណុចដៅទាំងនេះសម្រាប់ឆ្នាំ២០១៥ អាចនឹងជួយឱ្យសម្រេចបានគោលដៅទាំង៩ នៃ *គអសក* ។

[១] តារាងពេញលេញមាននៅក្នុងឧបសម្ព័ន្ធ ១.១

**៣.០៦** ក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការពិនិត្យឡើងវិញនិងការវិភាគមួយជាលម្អិត លើចំណុចគោលខ្សែបន្ទាត់គោលសម្រាប់ធ្វើការប្រៀបធៀប និងវឌ្ឍនភាពសម្រាប់ការធ្វើឱ្យសម្រេចបាននូវចំណុចដៅទាំងអស់នៃ *គអសក* ។ ការងារខាងលើនេះបានសន្និដ្ឋានថា ទោះបីជាគោលដៅមួយចំនួននៃ *គអសក* ពិតជាអាចសម្រេចបាន ឬ សម្រេចបានលើសពីការកំណត់ នៅឆ្នាំ២០១៥ក៏ដោយ កិច្ចខិតខំប្រឹងប្រែង ខ្លាំងបន្ថែមទៀត ត្រូវតែធ្វើឡើងជាចាំបាច់ ដើម្បីសម្រេចឱ្យបាននូវគោលដៅមួយចំនួនផ្សេងទៀត[១] ។

**តារាង៣.១ : សមិទ្ធផលសំខាន់ៗ និងការសម្រេចមិនបានតាមចំណុចដៅរបស់ *គអសក* ឆ្នាំ២០០៥**

| ការសម្រេចបាន | ការសម្រេចមិនបានតាមគោលដៅ |
|---|---|
| • ការធ្វើឱ្យប្រសើរឡើងគួរឱ្យកត់សម្គាល់ ក្នុងការបន្ថយភាពក្រីក្រនៅទីប្រជុំជន និងជនបទដែលមានលទ្ធភាពទៅដល់ជាងមុន<br>• ការពង្រីកការអប់រំបឋមសិក្សាដល់កុមារឱ្យបានច្រើនជាងមុន<br>• ការកាត់បន្ថយបានច្រើននូវអត្រាមរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំ<br>• ការធ្វើឱ្យប្រសើរឡើងនូវការចាក់ថ្នាំបង្ការជម្ងឺសំខាន់ៗដល់កុមារ<br>• ការលើកកម្ពស់អត្រាបំបៅកូនដោយទឹកដោះម្តាយ<br>• ការកាត់បន្ថយវិសមភាពយេនឌ័រ ក្នុងស្ទើរតែគ្រប់វិស័យទាំងអស់ ជាពិសេស ការអប់រំបឋមសិក្សា អក្ខរកម្មមនុស្សពេញវ័យ និងការងារដែលមានប្រាក់ឈ្នួលក្នុងផ្នែកកសិកម្ម និងឧស្សាហកម្ម<br>• សមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយជម្ងឺឆ្លង ជាពិសេស ហ៊ីវ/អេដស៍<br>• តំបន់ទីក្រុងទទួលបានទឹកស្អាត ហើយតំបន់ជនបទទទួលបាននូវអនាម័យប្រសើរជាងមុន | • អត្រាភាពក្រីក្រខ្ពស់នៅជនបទ<br>• ភាពមិនជោគជ័យ ក្នុងការបង្កើនការសិក្សាពិតនៅកម្រិតសិក្សាខ្ពស់ជាងបឋមសិក្សា និងក្នុងការរក្សាឱ្យបានអត្រាគង់វង្សខ្ពស់នៃសិស្សដែលបានចូលរៀននៅគ្រប់កម្រិតសិក្សា<br>• ភាពជឿនលឿននៅមានកម្រិត ក្នុងការធ្វើឱ្យសម្រេចគោលដៅនៃសកលកម្មការអប់រំមូលដ្ឋាន៩ឆ្នាំ ជាពិសេសការអប់រំក្រោយបឋមសិក្សា<br>• វិសមភាពយេនឌ័រនៅបឋមសិក្សា មធ្យមសិក្សា និង ឧត្តមសិក្សា<br>• ការនៅតែបន្តកើតមាននូវអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី<br>• ការទទួលបាននូវសេវាសុខាភិបាល ដែលមានគុណភាព ជាពិសេស ក្នុងករណីសុខភាពស្ត្រី និងមាតា<br>• ការរិចរិលនៃបរិស្ថាន ជាពិសេស ការរិចរិលព្រៃឈើនិងធនធានទឹក<br>• ការបន្តមានជនរងគ្រោះដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ |

**៣.០៧** ការធ្វើឱ្យសម្រេចបាន *គអសក* ដែលជាអាទិភាពមួយយ៉ាងពិតប្រាកដនោះ ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើវិធីសាស្ត្ររួម ការប្រឹងប្រែងរួមគ្នា និងលទ្ធផលនៃការងារអភិវឌ្ឍនិងលក្ខខណ្ឌផ្សេងៗទៀត ដូចជា ស្ថេរភាពនយោបាយនិងសង្គម នីតិរដ្ឋ ការថែរក្សាបាននូវសណ្តាប់ធ្នាប់សង្គម កំណែទម្រង់សំខាន់ៗក្នុងរដ្ឋបាលសាធារណៈ និងក្នុងវិស័យផ្សេងៗ កំណើនម៉ាក្រូសេដ្ឋកិច្ចដែលប្រកបដោយស្ថេរភាព ចីរភាព ភាពរឹងមាំ សមធម៌ តុល្យភាព និងដោយមានការបែងចែកបានល្អ (តាមតំបន់និងតាមវិស័យ) ហើយដែលមានការពាក់ព័ន្ធពីវិស័យទាំង

[១] ការពិនិត្យឡើងវិញគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា, ក្រសួងផែនការ, ខែតុលា ឆ្នាំ២០០៥, ខ្លឹមសារសង្ខេបនៅឧបសម្ព័ន្ធ ១.២

អស់ផ្សេងទៀត ដោយវិស័យនីមួយៗមានគោលដៅនិងចំណុចដៅរៀងៗខ្លួន ។ វឌ្ឍនភាពចម្បងៗនឹងមិនអាចកើតមានឡើងបានទេ ប្រសិនបើពុំមានកត្តាមួយចំនួន ដូចឧទាហរណ៍ខាងក្រោម ៖

- កំណើនម៉ាក្រូសេដ្ឋកិច្ចរឹងមាំ និងប្រកបដោយសមធម៌ ។
- ការរក្សាអតិផរណាឱ្យមានស្ថេរភាព ។
- ការបង្កើនឡើងដ៏សមស្របនូវផលិតភាពនិងផលិតកម្មកសិកម្ម ។
- ការការពារនិងលើកកម្ពស់ធនធានធម្មជាតិនិងបរិស្ថាន ។
- ការកែលម្អ ការពង្រីក និងការពង្រឹងជាប្រចាំនូវហេដ្ឋារចនាសម្ព័ន្ធ ។
- ការធ្វើឱ្យមានកំណើនដ៏សមស្របក្នុងវិស័យឧស្សាហកម្ម ដើម្បីបង្កើតការងារ និងចំណូល ។
- ការកំណែទម្រង់សំខាន់ៗនៅក្នុងរដ្ឋបាលសាធារណៈ ដោយរួមបញ្ចូលទាំង កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ និងកំណែទម្រង់ផ្សេងៗទៀតតាមវិស័យ ។
- កំណើនយ៉ាងឆាប់រហ័សនៅក្នុងការវិនិយោគរបស់វិស័យឯកជននៅក្នុងវិស័យផ្សេងៗ ដើម្បីធ្វើឱ្យវឌ្ឍនភាពមានមូលដ្ឋានទូលំទូលាយ និងមានសន្ទុះខ្លាំងក្លា តាមរយៈការកាត់បន្ថយចំណាយអន្តរកម្មក្នុងធុរៈកិច្ចដែលបច្ចុប្បន្នរាំងស្ទះដល់ការវិនិយោគនេះ និងតាមរយៈការរៀបចំនីតិវិធីឱ្យបានសមស្រប
- កំណើនពាណិជ្ជកម្មអន្តរជាតិដែលមិនមានការរាំងស្ទះ ដើម្បីសម្រួលដល់ការទាញយកប្រយោជន៍ពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជាក្នុងការផ្គត់ផ្គង់ទំនិញនិងសេវាកម្ម ទៅកាន់ទីផ្សារក្រៅប្រទេសក្នុងល័ក្ខខ័ណ្ឌប្រកួតប្រជែង និងបង្កើតឱ្យមានទំនាក់ទំនងពីក្រៅប្រទេស ក្នុងការបង្កើននិងការធ្វើពិពិធកម្មការងារ និងប្រាក់ចំណូល ។
- កំណើនយ៉ាងឆាប់រហ័សនៃផ្នែកសេវាកម្ម (រួមបញ្ចូលទាំងវិស័យទេសចរណ៍) ដើម្បីផ្តល់ការងារ និងប្រាក់ចំណូល ។ល។

**៣.០៨** នៅក្នុងឆ្នាំ២០០៣នេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនិងប្រកាសផ្សាយ *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥* ដែលបានកំណត់នូវគោលដៅនិងចំណុចដៅទាំងឡាយ ដែលត្រូវយកទៅអនុវត្តដើម្បីកាត់បន្ថយកម្រិតភាពក្រីក្រនៅក្នុងប្រទេសឱ្យបានឆាប់រហ័ស ។ គោលដៅចម្បងទាំងអស់សម្រាប់ការកាត់បន្ថយភាពក្រីក្រនៅថ្នាក់មូលដ្ឋាន មានភាពស្របគ្នានិងស៊ីសង្វាក់គ្នាជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ទន្ទឹមនឹងនេះ *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* ផ្តល់នូវក្របខ័ណ្ឌមួយនៃការកែទម្រង់និងសកម្មភាពជាអាទិភាពទាំងឡាយ ដែលត្រូវការសម្រាប់ការសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ ។

**៣.០៩** *ការកាត់បន្ថយភាពក្រីក្រតាមរបៀបមួយឆាប់រហ័សបំផុត គឺអាទិភាពចម្បងបង្អស់របស់រាជរដ្ឋាភិបាលកម្ពុជា* ។ ការពិពណ៌នាលម្អិតអំពីស្ថានភាពបច្ចុប្បន្ន មានចែងនៅក្នុងប្រអប់ ២.១ នៃជំពូក ២ ។ ដោយហេតុថា

៩០ភាគរយនៃអ្នកក្រស់នៅតំបន់ជនបទ ការផ្តោតការយកចិត្តទុកដាក់ជាសំខាន់ ចាំបាច់ត្រូវធ្វើឡើងតាមរយៈ *ផយអជ* ដើម្បីជំរុញឱ្យបានលឿននូវការអភិវឌ្ឍជនបទ ។

**៣.១០** ការធ្វើឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ពិសេសសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍមនុស្ស គឺជាអាទិភាពខ្ពស់បំផុត ដូចដែលបានគូសបញ្ជាក់ពីខាងដើម (កថាខ័ណ្ឌ ៣.៧) ប៉ុន្តែ *ផយអជ* ត្រូវពិនិត្យពិចារណាផងដែរទៅលើរាល់ទិដ្ឋភាពសំខាន់ៗនៃតម្រូវការ អាទិភាព គោលដៅនិងចំណុចដៅក្នុងផ្នែកសេដ្ឋកិច្ច-សង្គមកិច្ចរបស់កម្ពុជា ដោយហេតុថា ផែនការនេះ គឺជាការផ្តុំគ្នានៃសកម្មភាពទាំងអស់ដែលនឹងមានផលប៉ះពាល់ជាវិជ្ជមានទៅលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែរ ។ *ដូច្នេះ ជំពូកនេះនឹងលើកឡើងនូវបណ្តាគោលដៅនិងចំណុចដៅជាអាទិភាព* ដែលពាក់ព័ន្ធនឹងសមាសភាគទាំងឡាយរបស់យុទ្ធសាស្ត្រចតុកោណ ដោយរួមបញ្ចូលទាំងសមាសភាគទាំងឡាយ ដែលមានចរិកអន្តរវិស័យ សំដៅជំរុញប្រទេសជាតិឱ្យបានបោះជំហានយ៉ាងលឿនទៅមុខ លើផ្លូវនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ដោយផ្តល់អាទិភាពជាពិសេសលើការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាលើការកាត់បន្ថយឱ្យបានច្រើននូវគម្លាត រវាងពីតំបន់មួយទៅតំបន់មួយ និង រវាងអ្នកមាននិងអ្នកក្រ ។

**៣.១១** *ផយអជ* គឺជាក្របខ័ណ្ឌទូលំទូលាយមួយសម្រាប់ផ្តល់នូវការចង្អុលទិសនិងគោលការណ៍ណែនាំ ដើម្បីនាំប្រទេសជាតិចេញពីស្ថានភាពមួយនាចុងឆ្នាំ២០០៥ ទៅកាន់ស្ថានភាពមួយទៀតដែលត្រូវតែមាននៅឆ្នាំ២០១០ ដោយប្រើប្រាស់ធនធានទាំងឡាយដែលមានស្រាប់តាមរបៀបមួយ ដែលធានាប្រសិទ្ធភាពចំណាយនិងដែលផ្តោតទៅលើលទ្ធផល ។ អាស្រ័យហេតុនេះ ប្រការដែលចាំបាច់នោះ គឺត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំងបំផុតទៅលើបរិបទទាំងមូលនៃប្រទេសនៅលើទិដ្ឋភាពទាំងអស់ ហើយត្រូវធ្វើការកំណត់អាទិភាពសម្រាប់គោលដៅជាយុទ្ធ-សាស្ត្រ និងចំណុចដៅជាតិសំខាន់ៗ ដែលត្រូវសម្រេចឱ្យបាននូវគោលបំណងសម្រាប់ឆ្នាំ២០១០ ។ ដូចនេះ ប្រការដែលត្រូវយកចិត្តទុកដាក់នោះគឺ គោលដៅនិងចំណុចដៅសម្រាប់វិស័យនិងសកម្មភាពអាទិភាព ដោយទុកឱ្យក្រសួង-ស្ថាប័នរដ្ឋាភិបាលដែលទទួលបន្ទុកតាមវិស័យនីមួយៗ យកគោលដៅនិងចំណុចដៅជាយុទ្ធសាស្ត្ររួមទៅបំបែក ពង្រីកបន្ថែម ឱ្យទៅជាគោលដៅលម្អិតនិងចំណុចដៅដែលអាចវាស់វែងបានសម្រាប់ការអនុវត្ត និងការតាមដានត្រួតពិនិត្យ ។

**៣.១២** យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក្តោបយកនូវសមាសភាគទាំងអស់នៃអភិបាលកិច្ច និងកំណើននៅក្នុងក្របខ័ណ្ឌមួយដែលមានលក្ខណៈសមហេតុផល ប្រមូលផ្តុំគ្រប់ជ្រុងជ្រោយ និងស៊ីសង្វាក់គ្នា ។ តារាងម៉ាទ្រីសលទ្ធផលមួយត្រូវបានរៀបចំឡើង ដើម្បីឆ្លុះបញ្ចាំងពីគោលដៅនិងចំណុចដៅអាទិភាពជាយុទ្ធសាស្ត្រដែលត្រូវសម្រេចឱ្យបានក្នុងអំឡុងពេលឆ្នាំ២០០៦-២០១០ ដោយយកក្របខ័ណ្ឌនៃយុទ្ធសាស្ត្រចតុកោណធ្វើជាមូលដ្ឋាន និងដោយមានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័នរដ្ឋាភិបាលទាំងអស់ និងពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស

ហើយតាមរយៈដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ។ ដោយផ្អែកនៅលើការងារនេះ បញ្ហាសំខាន់ៗ និងក្នុងកម្រិតម៉ាក្រូ ត្រូវបានជ្រើសរើសជាចំណុចដៅសំខាន់ៗរបស់ជាតិ ដែលត្រូវសម្រេចឱ្យបានតាមរយៈការអនុវត្ត *ផយអជ* ដូចដែលមានបង្ហាញនៅក្នុងតារាង៣.២ ។

**៣.១៣** ដើម្បីឈានទៅសម្រេចឱ្យបានឆាប់នូវចក្ខុវិស័យរួម រាជរដ្ឋាភិបាលកម្ពុជានឹងផ្តោតការយកចិត្តទុកដាក់លើសមិទ្ធផលកម្រិតជាតិដែលមានអាទិភាពខ្ពស់ គោលដៅជាតិ និងជាយុទ្ធសាស្ត្រ និងចំណុចដៅរួម (សូចនាករ) ដែលត្រូវសម្រេចឱ្យបានតាមរយៈ *ផយអជ* ក្នុងអំឡុងពេលឆ្នាំ២០០៦-២០១០ ។ គោលដៅនិងចំណុចដៅទាំងនេះមានបង្ហាញក្នុងតារាង៣.២ ខាងក្រោម[១] ។ លក្ខណៈពិសេសនៃតារាងនេះគឺ :

- ការកាត់បន្ថយភាពក្រីក្រគឺជាអាទិភាពខ្ពស់បំផុត ដូច្នេះ តារាងបញ្ជីនេះចាប់ផ្តើមពីការកាត់បន្ថយភាពក្រីក្រ និងវិស័យទាំងឡាយដែលជះឥទ្ធិពលខ្លាំងជាងគេ ទៅលើភាពក្រីក្រ ទៅតាមលំដាប់លំដោយដ៏សមហេតុផលមួយ ។
- តារាងនេះ *បង្ហាញ* តែពីគោលដៅចម្បងៗនិងក្នុងកម្រិតជាតិ ដោយរួមបញ្ចូលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទាំងអស់ ប៉ុន្តែមិនមែនគោលដៅរងទេ ។
- តារាងនេះ ផ្តល់នូវចំណុចដៅជាបរិមាណ ដែលអាចវាស់បានច្បាស់លាស់ ហើយចំណុចដៅទាំងនោះត្រូវបានរំលេចឡើងតាមវិស័យ មិនមែនតាមក្រសួង-ស្ថាប័នទេ ។ គោលដៅមួយចំនួន ដូចជា កំណែទម្រង់ គឺស្ថិតក្នុងសណ្ឋានជាគោលដៅដែលមានលក្ខណៈជាគុណភាពច្រើនជាង ។
- គោលដៅនិងចំណុចដៅទាំងអស់ មានលក្ខណៈម៉ាក្រូ ហើយគឺជាគោលគំនិតប្រមូលផ្តុំធំៗ
- ចំណុចដៅ ឬសូចនាករលើកឡើងតែបញ្ហាចំបងៗតែប៉ុណ្ណោះ[២] ។
- គោលដៅរងនិងចំណុចដៅបន្ថែមជាច្រើន ត្រូវបានពិនិត្យឃើញច្បាស់ថាត្រូវ ធ្វើឱ្យសម្រេចបានផងដែរ[៣] ។
- គោលដៅនិងចំណុចដៅលម្អិតទាំងឡាយ ត្រូវកំណត់និងធ្វើឱ្យសម្រេចបានផងដែរនៅកម្រិតវិស័យនិងកម្រិតថ្នាក់ក្រោមជាតិ ។

---

[១] គោលដៅនិងសូចនាករដែលមានលក្ខណៈលម្អិតជាង អាចនឹងត្រូវកំណត់ឡើងនិងអនុវត្តដោយវិស័យ ក្រសួង-ស្ថាប័ននីមួយៗ

[២] ឧទាហរណ៍: ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបង្ហាញតែពីបណ្តាញផ្លូវសំខាន់ៗជាសូចនាករមួយប៉ុណ្ណោះ ។ ផ្នែកផ្សេងៗទៀតដូចជា កំពង់ផែ អាកាសយានដ្ឋាន ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងក្រៅពីនេះ មានលើកឡើងជាលម្អិតនៅក្នុងជំពូក៤។

[៣] ឧទាហរណ៍ : សុខភាពមាតា រួមបញ្ចូលទាំង ការពិនិត្យផ្ទៃពោះ អាហារូបបត្ថម្ភ ។ល។ ហើយមរណភាពមាតា គឺជាការឆ្លុះបញ្ចាំងមួយពីសូចនាករទាំងអស់ផ្សេងទៀត ។ គោលដៅទេសចរណ៍តម្រូវឱ្យមានការបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ កិច្ចខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយ ។ល។ ទិដ្ឋភាពទាំងនេះមានលើកឡើងនៅក្នុងជំពូក៤។

- ចំណុចដៅទាំងអស់ដែលបានលើកឡើងក្នុងតារាងនេះ ហើយចំណុចដៅរង ដែលត្រូវលើកឡើងដោយវិស័យទាំងឡាយ ឬដោយថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវអនុវត្តដោយមានការយកចិត្តទុកដាក់ដូចគ្នា ដើម្បីភាពរុងរឿងរបស់កម្ពុជា ។
- ផែនការលម្អិតតាមវិស័យដែលមួយចំនួនត្រូវបានរៀបចំឡើងរួចមកហើយ ហើយមួយចំនួនផ្សេងទៀតកំពុងឬត្រូវរៀបចំឡើង នឹងពង្រីកគោលដៅរួមទាំងនេះ ព្រមទាំងបំបែកចំណុចដៅនានា ហើយនឹងសម្រេចបាននូវតារាងមួយដែលមានលក្ខណៈទូលំទូលាយនិងវែងជាង ដែលត្រូវយកទៅអនុវត្តនិងតាមដានត្រួតពិនិត្យដោយក្រសួង-ស្ថាប័ននានា ។
- ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងឃុំ-សង្កាត់ទាំងអស់ នឹងត្រូវរៀបចំផែនការលម្អិតដោយឡែក ដើម្បីពង្រីកបន្ថែមទៅលើគោលដៅទាំងឡាយរបស់ *ផយអជ* ទៅតាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ ហើយអនុវត្តផែនការទាំងនោះ ដោយបង្កើនធនធាននិងការទទួលខុសត្រូវ ដែលកំពុងត្រូវបានផ្ទេរទៅឱ្យខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងឃុំ-សង្កាត់ទាំងអស់នោះ តាមរយៈថវិកាជាតិប្រចាំឆ្នាំ ។

**៣.១៤** តារាង ៣.២ បញ្ជាក់ច្បាស់ថា ចំណុចដៅរបស់ *គអសក* មួយចំនួន នឹងអាចសម្រេចបានមុនឆ្នាំ២០១៥ ហើយមួយចំនួនទៀតនឹងអាចសម្រេចបាននៅក្រោយឆ្នាំ២០១៥ ។ មូលដ្ឋានសម្រាប់ឈានទៅសម្រេចការកាត់បន្ថយកម្រិតទូទៅនិងកម្រិតដោយឡែកៗនៃភាពក្រីក្រ ហើយចំណុចដៅទាំងឡាយសម្រាប់ឆ្នាំ២០១០ ហាក់ដូចជាទាមទារពេលវេលាយូរនិងមានការលំបាកដើម្បីឈានទៅដល់ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាមានជំនឿថា គោលដៅទាំងឡាយអាចនឹងសម្រេចបាន ជាពិសេសដោយសារ សមាមាត្រដ៏ធំនៃប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ជាក់ស្តែងកំពុងស្ថិតនៅក្បែរបន្ទាត់នៃភាពក្រីក្រ ហើយអាចនឹងត្រូវរុញឱ្យឡើងផុតលើបន្ទាត់ភាពក្រីក្រ យ៉ាងឆាប់រហ័សតាមរយៈសកម្មភាពនានាដែលបានដៅទុក ។

**៣.១៥** រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តដើម្បីសម្រេចឱ្យបានគោលដៅនិងចំណុចដៅរួម ដែលបានបង្ហាញនៅក្នុងតារាង៣.២ និងគោលដៅនិងចំណុចដៅទាំងឡាយដែលត្រូវយកទៅលម្អិតនិងពង្រីកបន្ថែម តាមវិស័យនិងនៅកម្រិតថ្នាក់ក្រោមជាតិ ។ ចំណុចដៅមួយចំនួនគឺពិតជាមានលក្ខណៈធំធេងពេក ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាមានជំនឿថា ចំណុចដៅទាំងនោះពិតជាអាចសម្រេចបាន ប្រសិនបើជាមានការវិនិយោគនិងការអភិវឌ្ឍធនធានមនុស្សសមស្រប ។ ដើម្បីទទួលបានជោគជ័យ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវយុទ្ធសាស្ត្រជាអាទិភាពទាំងអស់ និងសកម្មភាពទាំងឡាយដែលត្រូវបានផ្តោតការយកចិត្តទុកដាក់លើ តាមរយៈក្របខ័ណ្ឌនៃយុទ្ធសាស្ត្រចតុកោណ ដូចដែលនឹងត្រូវយកមកបង្ហាញនៅក្នុងជំពូក៤ ខាងមុខ ។

## តារាង៣.២ : គោលដៅជាតិ និងសូចនាករសំខាន់ៗរបស់ ផយអជ (ចំណុចដៅ)[1]

### (*) - គោលដៅនិងចំណុចដៅ គអសហ

| | គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | ២០០៥ | ២០១០ | គអសហ-២០១៥ |
|---|---|---|---|---|
| | **លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ (*)** | | | |
| ១* | ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ២០០៤ | ៣៤,៧ | ២៥ | ១៩,៥ |
| | បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៩%នៃផ្ទៃដីទូទាំងប្រទេស) | (២៨,០) | | |
| ២* | ភាគរយនៃប្រជាជននៅតំបន់ជនបទ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ២០០៤ | ៣៩,២ | | |
| | បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៦%នៃផ្ទៃដីទូទាំងប្រទេស) | (៣៣,៧) | | |
| ៣* | ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រស្បៀងអាហារ ២០០៤ | ១៩,៧ | ១៣ | ១០ |
| | បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៦%នៃផ្ទៃដីទូទាំងប្រទេស) | (១៤,២) | | |
| | **លើកកម្ពស់ផលិតភាពនិងផលិតកម្មកសិកម្ម** | | | |
| ៤ | ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ១,៩៧ | ២,៤ | |
| ៥ | ផ្ទៃដីស្រោចស្រព (រួមទាំងការស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រ) (%នៃផ្ទៃដាំស្រូវ) | ២០ | ២៥ | |
| ៦ | កំណែទម្រង់ដីធ្លី : ចំនួនប័ណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់ជូនកសិករ (%នៃផ្ទៃដីសរុប) | ១២ | ២៤ | |
| | **លើកកម្ពស់ក្នុងវិស័យសុខាភិបាល (*)** | | | |
| ៧* | អត្រាមរណភាពទារក ក្នុង១.០០០កំណើតរស់ | ៦៦ | ៦០ | ៥០ |
| ៨* | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ក្នុង១.០០០កំណើតរស់ | ៨២ | ៧៥ | ៦៥ |
| ៩* | មរណភាពមាតា ក្នុង១០០.០០០កំណើតរស់ | ពុំមានតួលេខ | ២៤៣ | ១៤០ |
| ១០* | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) | ពុំមានតួលេខ | ៧០ | *៨០* |
| ១១* | អត្រាប្រេវ៉ាឡង់មេរោគហ៊ីវ/ជម្ងឺអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុពី១៥-៤៩ឆ្នាំ | ១,៩ | ១,៩ | ១,៨ |
| ១២* | ករណីជម្ងឺគ្រុនចាញ់ អត្រាស្លាប់ | ០,៣៦ | ០,២ | ០,១ |
| ១៣* | ករណីអ្នកផ្ទុកជម្ងឺរបេងក្នុង ១០០.០០០នាក់ | ពុំមានតួលេខ | ២១៤ | ១៣៥ |
| ១៤* | ស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប (%) | ២០,១ | ៤៤ | ៦០ |
| ១៥ | មណ្ឌលសុខភាពដែលផ្តល់សេវាសុខភាពបន្តពូជ | ៣៣ | ៤៥ | ៧០ |

[1] សូមមើលការបកស្រាយនៅក្បាខ័ណ្ឌ៣.១៣

| គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | | ២០០៥ | ២០១០ | គអសហ-២០១៥ |
|---|---|---|---|---|
| | ***លើកកម្ពស់វិស័យអប់រំ (*)*** | | | |
| ១៦* | អត្រាពិតនៃការសិក្សា : បឋមសិក្សា (សរុប-ប្រុស-ស្រី) | ៩១,៩-៩៣,០-៩០,៧ | ១០០ | ១០០ |
| ១៧* | អត្រាពិតនៃការសិក្សា : មធ្យមសិក្សាបឋមភូមិ ( សរុប-ប្រុស-ស្រី) | ២៦,១-២៧,១-២៤,៨ | ៧៥ សម្រាប់ទាំងអស់ | ១០០ សម្រាប់ទាំងអស់ |
| ១៨* | អត្រាគង់វង្ស : ថ្នាក់១-៦ | ៥៣,១ | ១០០ | ១០០ |
| ១៩* | អត្រាគង់វង្ស : ថ្នាក់១-៩ | ៣០,១៨ | ៧៦ | ១០០ |
| ២០* | កុមារអាយុ ៦-១៤ឆ្នាំ មិនបានចូលរៀន (%) | ១៨,៧ | ១១ | ០ |
| | ***ការអភិវឌ្ឍជនបទ*** | | | |
| ២១* | ផ្លូវជនបទដែលបានស្តារ លើប្រវែងផ្លូវសរុប ២៨.០០០ គម | ២២.៧០០ | ២៥.០០០ | ២៨.០០០ |
| ២២* | លទ្ធភាពមានទឹកស្អាតបរិភោគ (%នៃប្រជាជនជនបទ) | ៤១,៦ | ៤៥ | ៥០ |
| ២៣* | លទ្ធភាពប្រើប្រាស់សេវាអនាម័យ (%នៃប្រជាជនជនបទ) | ១៦,៤ | ២៥ | ៣០ |
| | ***ចីរភាពបរិស្ថាន (*)*** | | | |
| ២៤* | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (%នៃផ្ទៃដីសរុប) | ៦០ | ៥៨ | ៦០ |
| ២៥* | ការប្រើប្រាស់អុស-ធ្យូង : គ្រួសារ (%) | ៨៣,៩ | ៦១ | ៥២ |
| ២៦* | ការទទួលបានប្រភពទឹកស្អាត (%នៃប្រជាជនទីប្រជុំជន) | ៧៥,៨ | ៨៥ | ៨០ |
| ២៧* | ការទទួលបានការកែលម្អអនាម័យ (%នៃប្រជាជនទីប្រជុំជន) | ៥៥ | ៦៧ | ៧៤ |
| | ***សមធម៌យេនឌ័រ (*)***[១] | | | |
| ២៨* | បញ្ជ្រាបយេនឌ័រនៅគ្រប់មជ្ឈដ្ឋាន (*) | នឹងត្រូវបង្កើតឡើង | | |
| ២៩* | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃ (កសិកម្ម ឧស្សាហកម្ម សេវាកម្ម) % | ៥២,៥-៥៣,៥-២៧,០ | ៥០-៥០-៣៧ | ៥០-៥០-៥០ |
| ៣០* | កម្រិតយល់ដឹងអំពី អំពើហិង្សាប្រឆាំងនឹងស្ត្រី ជាឧក្រិដ្ឋកម្ម % | ៤,៥ | ២៥ | ១០០ |
| | ***កំណែទម្រង់*** | | | |
| ៣១ | បង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច | នឹងត្រូវបង្កើតឡើង | | |
| | ***ធ្វើឱ្យមានស្ថេរភាពកំណើនម៉ាក្រូសេដ្ឋកិច្ចខ្ពស់ (*)*** | | | |
| ៣២ | កំណើន *ផសស* ប្រចាំឆ្នាំ គិតតាមថ្លៃថេរ (%) | ៧,០០ | ៦,០០ | |
| ៣៣ | *ផសស* សម្រាប់មនុស្សម្នាក់ គិតតាមថ្លៃថេរ (ពាន់រៀល) | ១.៤០០ | ២.២៤៣ | |
| ៣៤ | អត្រាអតិផរណា | ៦,២០ | ៣,០០ | |
| | ***កែលម្អការប្រើប្រាស់ថវិកា*** | | | |
| ៣៥ | ចំណូលថវិការដ្ឋសរុប : (%នៃ *ផសស*) | ១១,៨០ | ១៣,៨០ | |
| ៣៦ | ចំណាយថវិការដ្ឋសរុប : (%នៃ *ផសស*) | ១៤,៩០ | ១៦,៥ | |

[១] ចំណុចដៅដែលពាក់ព័ន្ធនឹងយេនឌ័រត្រូវបានបង្ហាញដាច់ដោយឡែកនៅក្នុងវិស័យអប់រំ និងសុខាភិបាល

| គោលដៅសំខាន់១ : ចំណុចដៅ/សូចនាករ | | ២០០៥ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|
| | ***បង្កើនល្បឿនកំណើនក្នុងវិស័យឧស្សាហកម្មនិងការងារ*** | | | |
| ៣៧ | កំណើនប្រចាំឆ្នាំក្នុងផ្នែកកម្មន្តសាល គិតតាមថ្លៃថេរ (%) | ១០,២ | ៧,២ | |
| ២៨* | ពលកម្មកុមារអាយុ ៥-១៧ឆ្នាំ (%) | ២២,៣ | ១០,៦ | ៨ |
| | ***ទេសចរណ៍*** | | | |
| ៣៩ | ចំនួនភ្ញៀវទេសចរណ៍ប្រចាំឆ្នាំ (ពាន់នាក់) | ១.៣០០ | ៣.១២០ | គ្មាន |
| | ***ការបោសសម្អាតមីន ការជួយសង្គ្រោះជនរងគ្រោះ (*)*** | | | |
| ៤០* | ចំនួនអ្នករងគ្រោះ (ស្លាប់ និងរបួស) | ៧៩៧ | ២០០ | ០ |
| ៤១* | *តំបន់ដែលបានបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (%)* | ៥០,៣ | ៧៧ | ១០០ |
| | ***ហេដ្ឋារចនាសម្ព័ន្ធ*** | | | |
| ៤២ | ផ្លូវក្រាលកៅស៊ូ (ផ្លូវជាតិនិងផ្លូវខេត្ត) លើប្រវែងផ្លូវសរុប ១១.៣១០ គម | ២.១០០ | ៤.១០០ | |
| | ***ថាមពល*** | | | |
| ៤៣ | ការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់ (គីឡូវ៉ាត់ម៉ោង) | ៥៤ | ៨៩ | |

# ជំពូក ៤

# យុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗ

៤.០១ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់និងបានប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ ចំពោះអធិបតេយ្យភាពជាតិ សន្តិភាពនិងការបង្រួបបង្រួមជាតិ ស្ថេរភាពនិងសណ្តាប់ធ្នាប់សង្គម ប្រជាធិបតេយ្យនិងការការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលនឹងបង្កើនល្បឿនវឌ្ឍនភាព វិបុលភាព ភាពសុខដុម ហើយនឹងលើកកម្ពស់ជីវភាពរស់នៅនិងមោទនភាពចំពោះខ្លួនឯង សម្រាប់ជនកម្ពុជាក្នុងគ្រប់វិជ្ជាជីវៈ ។

៤.០២ ដោយមានចក្ខុវិស័យច្បាស់លាស់ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តចំពោះការអនុវត្តតាមគោលការណ៍ជាមូលដ្ឋានមួយចំនួនដូចខាងក្រោម ដើម្បីនាំប្រទេសជាតិទៅរកវិបុលភាព :

- ការប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យក្នុងអភិបាលកិច្ច ដែលពលរដ្ឋកម្ពុជាគ្រប់រូបអាចធ្វើការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី ដើម្បីដឹកនាំសង្គមជាតិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- ការការពារសិទ្ធិបុគ្គល និងសិទ្ធិមនុស្ស រួមទាំងសេរីភាពពេញលេញក្នុងការបញ្ចេញមតិ ។
- ការថែរក្សាសន្តិភាព ស្ថេរភាពនយោបាយ នីតិរដ្ឋ សមភាព និងសណ្តាប់ធ្នាប់សង្គម ។
- រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ត្រូវមាន ការឆ្លើយតប ការទទួលខុសត្រូវ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសមត្ថភាពអាចដឹងជាមុនបាន យ៉ាងពេញលេញ ។
- រាជរដ្ឋាភិបាលត្រូវធានាឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច បង្កើតនិងថែរក្សាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងស្ថាប័នសំខាន់ៗ ក៏ដូចជា បង្កើតបរិស្ថានលើកទឹកចិត្តនិងក្របខ័ណ្ឌច្បាប់មួយសម្រាប់កិច្ចដំណើរការ និងការរីកចម្រើនរបស់វិស័យឯកជន ។
- រាជរដ្ឋាភិបាល ត្រូវផ្តល់សេវាសង្គមសំខាន់ៗ សម្រាប់ការបង្កើតនិងការលើកកម្ពស់មូលធនមនុស្ស (វិស័យសុខាភិបាល អប់រំ ការអភិវឌ្ឍវប្បធម៌ជាតិ) ហើយក្នុងន័យនេះ ត្រូវបង្កើតបរិស្ថានមួយ ដែលអាចឱ្យបុគ្គលគ្រប់រូប ធ្វើការស្វែងរកនិងធ្វើឱ្យសម្រេចនូវសក្តានុពលពេញលេញរបស់ពួកគេ និង ធ្វើការរួមចំណែកលើកកម្ពស់សុខុមាលភាពផ្ទាល់ខ្លួនរបស់ពួកគេ និងការរីកចម្រើនរបស់ប្រទេសជាតិ ។
- រាជរដ្ឋាភិបាលត្រូវធានាការគ្រប់គ្រងប្រកបដោយចីរភាព លើបរិស្ថាននិងធនធានធម្មជាតិរបស់ជាតិ (ព្រៃឈើ ជលផល ដី ទឹក និងជីវចម្រុះ) ដែលស្ថានភាពជីវភាពរស់នៅនិងសុខុមាលភាពរបស់មនុស្សត្រូវផ្អែកលើមូលដ្ឋានទាំងនេះ ។

៤.០៣ *ជំពូកនេះ បង្ហាញពីយុទ្ធសាស្ត្រ និងសកម្មភាពចម្បងៗ ដើម្បីអនុវត្តកម្មវិធីនិងការខិតខំប្រឹងប្រែង ដើម្បីសម្រេចគោលដៅរួមដែលបានលើកឡើងនៅក្នុងជំពូក៣* និងការជំនះភាពខ្វះចន្លោះដែលបានគូសបញ្ជាក់នៅផ្នែក

ខាងដើមនៃជំពូក ២ ។ ជំពូកនេះ សង្កត់ធ្ងន់លើយុទ្ធសាស្ត្រគន្លឹះនិងចម្បងៗ ដែលត្រូវបានកំណត់ឡើងតាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងបង្ហាញពីទស្សនៈវិស័យរួមមួយនៃយុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗតែប៉ុណ្ណោះ ។ គោលបំណងសំខាន់នៃ ជំពូកនេះ គឺចង់បង្ហាញតែការណែនាំដ៏ទូលំទូលាយមួយ ហើយមិនមែនជាការពិពណ៌នាលម្អិតនៃការងារ ដែលកំពុងធ្វើ ឬដែលនឹងត្រូវធ្វើដោយក្រសួងនិងស្ថាប័នទាំងឡាយ[១] នោះទេ ។ ការងារលម្អិតនិងច្បាស់លាស់ជាងនេះ អាចនឹងត្រូវកំណត់ឡើងនៅក្នុងផែនការតាមវិស័យ ដែលបានរៀបចំរួចហើយ ឬនឹងត្រូវរៀបចំក្នុងពេលឆាប់ៗ ។ ចំណុចដែលគួរកត់សម្គាល់នោះគឺថា គោលដៅជាច្រើនដែលត្រូវសម្រេចឱ្យបានជាទូទៅ គឺជាគោលដៅផ្នែកបរិមាណ ។ ទិដ្ឋភាពផ្នែកគុណភាពនៃគោលដៅទាំងឡាយ ទោះបីជាមានសារៈសំខាន់ មិនអាចនឹងធ្វើការវាស់វែងបានដោយងាយស្រួលទេ ប៉ុន្តែក្នុងរយៈពេលវែង ទិដ្ឋភាពទាំងនោះអាចនឹងត្រូវទទួលបានការកត់សម្គាល់ និងសម្តែងឱ្យឃើញ តាមរយៈការកែលម្អ តាមមធ្យោបាយផ្សេងៗ ។

៤.០៤ <u>*ភាពក្រីក្រ*</u>[២] : ដោយហេតុថា ៩០ភាគរយនៃអ្នកក្ររស់នៅតំបន់ជនបទ ការយកចិត្តទុកដាក់ពិសេស និងធនធាននិងការវិនិយោគទាំងឡាយដែលបានកំណត់ទុក គឺមានសារៈសំខាន់នៅតំបន់ជនបទ ជាពិសេស តំបន់ដែលមិនបានគ្របដណ្តប់ក្នុងអង្កេតឆ្នាំ១៩៩៣ (និងកន្លែងនានាដែលក្រជាងនៅតាមតំបន់ផ្សេងៗទៀត) ដើម្បីកាត់បន្ថយកម្រិតភាពក្រីក្រឱ្យបានឆាប់រហ័ស និងដើម្បីធ្វើឱ្យសម្រេចបានចំណុចដៅទាំងឡាយនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា សម្រាប់ឆ្នាំ២០១០និង២០១៥ ។ ដោយហេតុថា មួយចំណែកធំជាងមុននៃអ្នកក្រ បច្ចុប្បន្ននេះ កំពុងរស់នៅក្បែរបន្ទាត់ភាពក្រីក្រ[៣] ចំណុចដៅទាំងនេះអាចនឹងសម្រេចបាន ។ ការផ្តោតការយកចិត្តទុកដាក់ជាពិសេសបែបនេះ រួមបញ្ចូលនូវសេវាថែរក្សាសុខភាពនិងសេវាអប់រំ ដែលមានបរិមាណច្រើនជាងមុន និងគុណភាពប្រសើរជាងមុន ការធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូល តាមរយៈសកម្មភាពនានានៅតំបន់ ជនបទ (ការងារស្រែចំការនិងការងារក្រៅពីស្រែចំការ) ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធជនបទ ។ល។ មូលនិធិជាច្រើនបន្ថែមទៀត ត្រូវផ្តល់ទៅដល់វិស័យទាំងនេះ តាមរយៈមូលនិធិឃុំ-សង្កាត់ និងតាមរយៈវិធានការផ្សេងៗទៀត ។ ការសម្រេចបាននូវវឌ្ឍនភាពដើម្បីកាត់បន្ថយភាពក្រីក្រ ដែលជាបញ្ហាអន្តរវិស័យមួយនោះ គឺពឹងផ្អែកទាំងស្រុងលើគោលនយោបាយគាំទ្រអ្នកក្រ និងកិច្ចខិតខំប្រឹងប្រែងនៅក្នុងវិស័យផ្សេងៗទៀត ។ ជាមួយនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងធានាថា:

- យុទ្ធសាស្ត្រតាមវិស័យទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា ផ្តោតការយកចិត្តទុកដាក់លើផលប៉ះពាល់ជាវិជ្ជមានទៅលើភាពក្រីក្រ ដើម្បីសម្រេចបានគោលដៅ ក្នុងការកាត់បន្ថយសន្ទស្សន៍ភាពក្រីក្រឱ្យស្ថិតនៅត្រឹម ២៥ភាគរយ នៅក្នុងឆ្នាំ២០១០ ។

[១] ដូចបានពន្យល់ក្នុងជំពូកខាងដើម គោលដៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាពលម្អិត នឹងត្រូវរៀបចំ ដោយវិស័យ ក្រសួង-ស្ថាប័ន នីមួយៗសម្រាប់ការអនុវត្ត

[២] សូមមើលជំពូក២: ប្រអប់២.១ និងឧបសម្ព័ន្ធ ៣

[៣] ឧបសម្ព័ន្ធ ៣ កឋាខ័ណ្ឌ ៥

- ការវិនិយោគដែលបានកំណត់ទុក និងការយកចិត្តទុកដាក់ ត្រូវបានតម្រង់ទិស ជាពិសេស ឆ្ពោះទៅរកប្រជាជននិងតំបន់ដែលពុំបានទទួលសេវាកម្មគ្រប់គ្រាន់ ជាពិសេស ប្រជាជននិងតំបន់ដែលមានភាពក្រីក្រខ្ពស់ ។
- បន្ថែមពីលើវិធីសាស្ត្រសតាមវិស័យនិងក្នុងកម្រិតជាតិ ហើយរួមទាំងការគាំទ្រពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស កម្មវិធីពិសេសនិងថ្មីៗសម្រាប់គាំទ្រដល់កម្រិតមូលដ្ឋាន ដែលមានផលប្រយោជន៍ដោយផ្ទាល់ចំពោះអ្នកក្រ ត្រូវបានរៀបចំបង្កើតឡើងនិងយកទៅអនុវត្ត[១] ។

**៤.០៥** ដោយបានធ្វើឱ្យមានសន្តិភាព សណ្តាប់ធ្នាប់សង្គម និងកំណើនសេដ្ឋកិច្ចរឹងមាំ កម្ពុជាស្ថិតក្នុងចំណុច *ចាប់ផ្តើមដ៏សំខាន់* សម្រាប់កំណើនលឿននិងប្រកបដោយសមធម៌ជាងមុន ។ រយៈពេល១០ឆ្នាំខាងមុខគឺជា*ទសវត្សរ៍មួយនៃកាលានុវត្តភាព* សម្រាប់ការដឹកនាំប្រទេសឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែលមានទំហំធំធេង និងការលើកស្ទួយអ្នកក្រនិងជនងាយរងគ្រោះ ។ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចាប់យកកាលានុវត្តភាពនេះ ដើម្បីពង្រឹងនិងកសាងបន្ថែមពីលើ សមិទ្ធផលពីអតីតកាល សំដៅធ្វើឱ្យមានផលប៉ះពាល់មួយជាវិជ្ជមាននៅក្នុងរយៈពេល៥ឆ្នាំនៃ*ផយអជ* (២០០៦-២០១០) ។ ពេលវេលានៃការបង្វែរការយកចិត្តទុកដាក់លើការសិក្សានិងអង្កេតធំៗ ទៅរកសកម្មភាពច្បាស់លាស់និងជាក់ស្តែង ដើម្បីបង្កើនល្បឿនវឌ្ឍនភាពក្នុងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា បានមកដល់ហើយ ។ ឥឡូវនេះគឺជាពេលវេលាមួយដ៏សមស្រប ដែលផលប្រយោជន៍សំខាន់ៗទាំងឡាយ ត្រូវបង្កើតឱ្យមានឡើងនៅថ្នាក់មូលដ្ឋាន ដែលនៅទីនោះទង្វើបែបនេះមានសារៈសំខាន់យ៉ាងខ្លាំងបំផុតចំពោះពលរដ្ឋសាមញ្ញ និងសម្រាប់ការកាត់បន្ថយបាននូវភាពក្រីក្រយ៉ាងឆាប់រហ័ស ។ ហេតុដូចនេះ រាជរដ្ឋាភិបាលប្តេជ្ញាអនុវត្តយុទ្ធសាស្ត្រនិងសកម្មភាពទាំងឡាយ ដែលនឹង :

- បញ្ចូលការកាត់បន្ថយភាពក្រីក្រ និងបញ្ហាសមធម៌យេនឌ័រ ទៅក្នុងគ្រប់សកម្មភាពទាំងអស់ ។
- ជំរុញឱ្យកំណែទម្រង់ទាំងឡាយនៅក្នុងវិស័យទាំងអស់ឱ្យបានលឿន ដោយកំណែទម្រង់ទាំងនេះនឹងផ្តល់ផលប្រយោជន៍សម្រាប់រយៈពេលវែង ប៉ុន្តែសម្រាប់រយៈពេលខ្លី កំណែទម្រង់ទាំងនេះអាចនឹងធ្វើឱ្យមានការលំបាកក្នុងការធ្វើការសម្រេចចិត្ត ។
- ជំរុញនិងសម្រួលឱ្យមានកំណើនម៉ាក្រូសេដ្ឋកិច្ច ប្រកបដោយសមធម៌ ដែលបែងចែកបានសមស្របតាមតំបន់និងតាមវិស័យ ដែលមានលក្ខណៈជាប្រព័ន្ធ ដែលរឹងមាំ និងប្រកបដោយចីរភាព ដែលអាចផ្តល់កាលានុវត្តភាពនិងផលប្រយោជន៍បានទាន់ពេលវេលា ចំពោះប្រជាជនគ្រប់រូប ។

[១] កម្មវិធីមួយរបៀបនេះ អាចផ្តល់ពូជនិងជីរទៅដល់កសិករក្រីក្រទាំងឡាយ ដោយផ្អែកលើមូលដ្ឋានមួយដែលមានការជ្រើសរើស ដើម្បីឱ្យមានការចាប់ផ្តើមការកើនឡើងនៃផលិតកម្ម ។ ក្នុងតម្លៃ០,៣០ដុល្លារអាមេរិកក្នុងមួយគីឡូក្រាម ៣៧គីឡូក្រាមនៃពូជស្រូវដែលមានទិន្នផលខ្ពស់សម្រាប់ផ្ទៃដី ០,៥០ហិកតា ដែលមានតម្លៃប្រមាណ១០ដុល្លារអាមេរិក និងជីមានសារជាតិអាសូត-ហ្វូស្វាត-បូតាស្យូម ដែលមានតម្លៃ ១០ដុល្លារអាមេរិកថែមទៀត ដែលសរុបទាំងអស់ប្រមាណ២០ដុល្លារអាមេរិកអាចផ្តល់ដល់គ្រួសារក្រីក្រក្នុងផ្នែកនៃជំនួយ ។ កម្មវិធីនេះអាចជាការវិនិយោគដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ និងអាចមានឥទ្ធិពលច្រើនទៀត ។

- បង្កើនឱ្យបានខ្លាំងនូវ "ការវិនិយោគពិតប្រាកដ " សម្រាប់កំណើន ដូចជា ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (ទីប្រជុំជន ជនបទ និងជាតិ) ក្នុងវិស័យផលិតនានា ដូចជា កសិកម្មនិងឧស្សាហកម្ម និងក្នុងការអភិវឌ្ឍមនុស្ស (វិស័យសុខាភិបាល និងអប់រំ) ។
- តម្រង់ទិសដៅទៅរកប្រជាជនដែលខ្វះខាតបំផុត និងដែលទទួលបានសេវាកម្មតិចតួចបំផុត រួមមានប្រជាជនដែលខ្វះសមត្ថភាពពលកម្មនិងប្រជាជនជាជនជាតិដើមភាគតិច និងវិស័យទាំងឡាយណាដែលជួយកាត់បន្ថយភាពក្រីក្របានឆាប់រហ័ស ។
- រក្សាតុល្យភាពដោយមានការគិតគូរហ្មត់ចត់រវាងវិធីសាស្ត្រពីលើ-ចុះក្រោម (ការកែទម្រង់នៅថ្នាក់ជាតិ) និងវិធីសាស្ត្រពីក្រោម-ឡើងលើ (ថ្នាក់មូលដ្ឋាន) ។
- ផ្តោតការយកចិត្តទុកដាក់លើសកម្មភាពទាំងឡាយ ដែលមានការសាកល្បងត្រឹមត្រូវ ត្រូវការចំណាយទាប និងអាចផ្តល់ផលខ្ពស់ នៅថ្នាក់មូលដ្ឋាន ដែលនៅទីនោះការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស នឹងបង្ហាញពីសក្តានុពល មានផលប៉ះពាល់ខ្លាំងនិងជាវិជ្ជមាន និង/ឬ ផ្តល់ផលប្រយោជន៍ផ្ទាល់ដល់អ្នកក្រ ។
- ធ្វើឱ្យល្អប្រសើរកត្តាសម្រាប់បង្កើនផលិតភាព (មូលធន ពលកម្ម ដី និងធនធានធម្មជាតិនិងកត្តាផ្សេងៗទៀត) ក្នុងគ្រប់សកម្មភាពទាំងអស់ ។
- ជំរុញវិស័យវិទ្យាសាស្ត្រ និងការប្រើប្រាស់បច្ចេកវិទ្យា ។
- ប្រើប្រាស់កម្លាំងពលកម្មមនុស្សឱ្យបានច្រើនតាមដែលអាចធ្វើបាន សម្រាប់គ្រប់ការងារសាងសង់ ដើម្បីបង្កើនចំណូលរបស់គ្រួសារ ជាពិសេស នៅតំបន់ជនបទ ។
- យកចិត្តទុកដាក់លើការកសាងសមត្ថភាពមនុស្សនិងស្ថាប័ននៅគ្រប់វិស័យនិងគ្រប់កម្រិត ដើម្បីបង្កើតនិងធ្វើឱ្យមានចីរភាពនូវ ក្រុមមនុស្សសំខាន់ៗដែលមានជំនាញច្បាស់លាស់ និងមូលធនមនុស្ស ។
- រៀបចំជាបណ្តើរៗនូវយន្តការ ដើម្បីធានាថាមូលនិធិច្រើនបំផុតដែលអាចមាន ត្រូវបានតម្រង់ទិសតាមរយៈថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តសកម្មភាពអភិវឌ្ឍន៍ទាំងឡាយ ។

**៤.០៦** *កត្តាទាំងនេះនឹងជះឥទ្ធិពលនិងតម្រង់ទិសដល់ ព្រមទាំង មានសារៈសំខាន់ចំពោះ យុទ្ធសាស្ត្រទាំងអស់ដែលបានលើកឡើងនៅក្នុងជំពូកនេះ* ។ កត្តាទាំងអស់នេះនឹងជះឥទ្ធិពលនិងមានផលប៉ះពាល់លើការសម្រេចបានគោលដៅនិងចំណុចដៅទាំងឡាយដែលបានបង្ហាញនៅក្នុងជំពូក ៣ (តារាង ៣.២) ។ កត្តាទាំងនេះនឹងត្រូវយកទៅពិចារណាក្នុងការរៀបចំយុទ្ធសាស្ត្រឬផែនការតាមវិស័យ ឬក្នុងពិនិត្យមើលឡើងវិញលើផែនការ ឬយុទ្ធ-សាស្ត្រនិងសកម្មភាពទាំងឡាយតាមវិស័យដែលកំពុងដំណើរការ ។ ក្រុមការងារបច្ចេកទេសចម្រុះ រដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អាចដើរតួនាទីសំខាន់ក្នុងកិច្ចដំណើរការនេះ ។

**៤.០៧** *យុទ្ធសាស្ត្រចតុកោណ "ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព"* ផ្តល់នូវក្របខ័ណ្ឌមួយ ដែលច្បាស់លាស់និងផ្តោតចំបញ្ហា ដើម្បីជំរុញប្រទេសជាតិឱ្យឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចឆាប់រហ័ស ។

គោលដៅនិងចំណុចដៅទាំងឡាយត្រូវបានលើកឡើងនៅក្នុងតារាង៣.២ នៃជំពូក ៣ ដោយផ្អែកលើមូលដ្ឋាននៃអាទិភាពនានាសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ។ ការអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពនានាដែលបានកំណត់ក្នុង *ផយអជ* នឹងត្រូវរៀបចំក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ ។ យុទ្ធសាស្ត្រ និងសកម្មភាពទាំងនោះនឹងត្រូវលើកឡើងបន្ទាប់ពីនេះ តាមលំដាប់លំដោយនៃយុទ្ធសាស្ត្រចតុកោណ ដោយចាប់ផ្តើមពីអភិបាលកិច្ច ។ យុទ្ធសាស្ត្រនិងសកម្មភាពគន្លឹះដែលបានស្នើឡើងនិងបានរំពឹងទុកសម្រាប់រយៈពេល៥ឆ្នាំខាងមុខ (២០០៦-២០១០) ត្រូវបានបង្ហាញនិងយកមកពិចារណា សម្រាប់មុំនីមួយៗរបស់ចតុកោណនីមួយៗ ក៏ដូចជា សម្រាប់បញ្ហាអន្តរវិស័យនិងទូទៅដែលមិនត្រូវបានបញ្ចូលច្បាស់លាស់ក្នុងចតុកោណទាំងអស់ ។

**៤.០៨** យុទ្ធសាស្ត្រចតុកោណមានអភិបាលកិច្ចល្អជាស្នូល ដែលនឹងត្រូវជំរុញនិងអនុវត្តក្នុងបរិស្ថានជុំវិញសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ សម្រាប់គោលបំណងក្នុងការធ្វើឱ្យសម្រេចបាននវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមកិច្ចឆាប់រហ័ស ក្នុងវិស័យអាទិភាពនានា ដែលកំណត់នៅក្នុងចតុកោណសម្រាប់ "កំណើន" ទាំងបួនផ្សេងទៀត[១] ។ ដូច្នេះ នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រទាំងមូលមានទិដ្ឋភាពប្រាំមួយ (៦) ។ ផ្អែកដែលនៅសល់ក្នុងជំពូកនេះ ត្រូវរៀបចំតាមលំដាប់លំដោយនៃយុទ្ធសាស្ត្រចតុកោណ ។

## អភិបាលកិច្ច

**៤.០៩** អភិបាលកិច្ចល្អ គឺជាបុរេលក្ខខណ្ឌដ៏សំខាន់បំផុត សម្រាប់ធ្វើឱ្យសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយចីរភាព ដោយមានសមធម៌ កាលានុវត្តភាពស្មើៗគ្នា និងយុត្តិធម៌សង្គម ។ អភិបាលកិច្ចល្អទាមទារឱ្យមានការចូលរួមទូលំទូលាយ ការចែករំលែកព័ត៌មាន ការបើកទូលាយនិងតម្លាភាព គណនេយ្យភាព សមភាព ការមិនទុកចោលឱ្យបុគ្គលណាម្នាក់នៅក្រៅសង្គម និងការគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ ។ ហេតុដូចនេះ អភិបាលកិច្ចត្រូវគ្របដណ្តប់ការកែទម្រង់លើវិស័យបួន ពោលគឺ (ក) ការប្រឆាំងនឹងអំពើពុករលួយ (ខ) កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ (គ) កំណែទម្រង់រដ្ឋបាលសាធារណៈ រួមទាំងវិមជ្ឈការនិងវិសហមជ្ឈការ និង (ឃ) កំណែទម្រង់កងកំលាំងប្រដាប់អាវុធ ជាពិសេស ការកាត់រំសាយទ័ព ។

**៤.១០** *ផែនការសកម្មភាពអភិបាលកិច្ចទី១ (ផសអ១)* របស់រាជរដ្ឋាភិបាលដែលបានអនុម័តនៅឆ្នាំ២០០១ ដើម្បីជំរុញ កំណែទម្រង់អភិបាលកិច្ចជាលក្ខណៈពហុនិងអន្តរវិស័យ គឺជាក្របខ័ណ្ឌដ៏សំខាន់សម្រាប់សកម្មភាពចំពោះមុខ ។ ផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ដែលទទួលបាន *ផែនការសកម្មភាពអភិបាលកិច្ចទី២ (ផសអ២)* (២០០៥-២០០៨) កំពុងត្រូវបានរៀបចំបញ្ចប់ ។

[១] សូមមើលគំនូសបំព្រួញនៅផ្នែកខាងមុខនៃឯកសារ

**៤.១១** <u>ការប្រឆាំងនឹងអំពើពុករលួយ</u> : អំពើពុករលួយ ធ្វើឱ្យមានការធ្លាក់ចុះខ្សោយ និងធ្វើឱ្យមានផលអាក្រក់ចំពោះកំណើនដែលមានលក្ខណៈរលូនជាប្រព័ន្ធ ។ អំពើពុករលួយ ធ្វើឱ្យកត្តានិងភ្នាក់ងារសេដ្ឋកិច្ចទាំងឡាយស្ថិតក្នុងស្ថានភាពមួយដែលមិនអាចព្យាករណ៍បាននិងមិនចុះសម្រុងជាមួយគ្នា ហើយមិនលើកទឹកចិត្តដល់ការវិនិយោគទាំងក្នុងស្រុកនិងបរទេស ។ អំពើពុករលួយ បង្កឱ្យមានការកើនឡើងនៃចំណាយ ធ្វើឱ្យភាពប្រកួតប្រជែងរបស់កម្ពុជាធ្លាក់ចុះជាងមុន ហើយបណ្តាលឱ្យកម្ពុជាបាត់បង់កាលានុវត្តភាពសំខាន់ៗសម្រាប់កំណើន ។ សកម្មភាពនានានៅក្នុងវិស័យជាច្រើនដែលរួមមាន កំណែទម្រង់និងការផ្លាស់ប្តូរឥរិយាបទ គឺជាកិច្ចការចាំបាច់សម្រាប់ការប្រឆាំងនឹងអំពើពុករលួយ និងជំរុញឱ្យមាន *"វប្បធម៌នៃសេវាកម្ម"* ដែលតាមរយៈនេះ រដ្ឋបាលសាធារណៈដើរតួនាទីយ៉ាងពិតប្រាកដជាឧបករណ៍មួយនៃសេវាកម្មប្រកបដោយប្រសិទ្ធភាពភាពជាក់ស្តែង ប្រតិបត្តិការឆាប់រហ័សភាពមិនលំអៀងសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ។ គោលដៅអាទិភាព រួមមាន :

- *កាត់បន្ថយអំពើពុករលួយឱ្យបានច្រើន នាឆ្នាំ២០១០ ។*
- *ពង្រឹងការអប់រំ ការបោះពុម្ពនិងការផ្សព្វផ្សាយនូវឯកសារច្បាប់ និងឯកសារពាក់ព័ន្ធផ្សេងៗ ។*

**៤.១២** យុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយឱ្យបានច្រើន និងការឈានទៅលុបបំបាត់នូវអំពើពុករលួយ នឹងត្រូវយកទៅអនុវត្តតាមវិធីសាស្ត្រមួយដែលមានមុខព្រួញបី (ការពង្រឹងការអនុវត្តច្បាប់ ការបង្ការ និងការគាំទ្រជាសាធារណៈ ឬការអប់រំសាធារណៈ) ។ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចាត់វិធានការជាក់ស្តែងថា នឹងប្រឆាំងនឹងឫសគល់នៃអំពើពុករលួយ ដោយធានាឱ្យមានសមត្ថភាពអាចដឹងមុនបាន លើកកម្ពស់តម្លាភាព និងគណនេយ្យភាពច្បាស់លាស់នៅក្នុងគ្រប់សកម្មភាព ។ *សកម្មភាពអាទិភាព* នានាដែលបានស្នើឡើង រួមមាន :

- ដាក់ចេញឱ្យប្រើប្រាស់យ៉ាងឆាប់រហ័សនូវច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងការធ្វើឱ្យច្បាប់នេះស្របគ្នានឹងការអនុវត្តល្អប្រសើរ ដែលធ្លាប់បានធ្វើរួចមកហើយនៅកម្រិតអន្តរជាតិ ។
- កសាងសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីគ្រប់គ្រងនិងជំរុញការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកបដោយប្រសិទ្ធភាព ដោយរួមបញ្ចូលទាំងការពង្រឹងការងារអធិការកិច្ច ។
- បង្កើតឡើងនូវស្ថាប័នមួយឯករាជ្យនិងមានប្រសិទ្ធភាព ដើម្បីប្រឆាំងនឹងអំពើពុករលួយ ។
- ធានាឱ្យមានការពង្រឹងការអនុវត្តច្បាប់យ៉ាងតឹងរ៉ឹងបំផុត ដោយមិនទុកឱ្យនរណាម្នាក់រួចខ្លួនផុតពីបទបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះឡើយ ប៉ុន្តែត្រូវដាក់ឱ្យអ្នកនោះនៅក្រោមការវិនិច្ឆ័យយ៉ាងតឹងរ៉ឹងរបស់បទបញ្ញត្តិទាំងនោះ ។
- ប្រកាន់ខ្ជាប់ទៅនឹង ដំណើរការដេញថ្លៃជាសាធារណៈដោយមានការប្រកួតប្រជែង និងតម្លាភាពក្នុងគ្រប់កិច្ចសន្យា ការជួល ឬការលក់ នូវទ្រព្យសម្បត្តិរដ្ឋ ។

- ធ្វើឱ្យដំណើរការសវនកម្ម និងលទ្ធកម្មសាធារណៈ មានប្រសិទ្ធភាពជាងមុន ដើម្បីពង្រឹងតម្លាភាព និង គណនេយ្យភាព ។
- បន្តកិច្ចខិតខំប្រឹងប្រែងប្រែងដែលបានចាប់ផ្តើមរួចហើយ ក្នុងការបង្កើនប្រាក់បៀវត្សរ៍ដែលមានកម្រិតទាបរបស់មន្ត្រីរាជការស៊ីវិល ដើម្បីឱ្យការប្រព្រឹត្តអំពើពុករលួយត្រូវបានកាត់បន្ថយ ។
- ធ្វើឱ្យមានប្រសិទ្ធភាពជាងមុន ក្នុងការផ្តល់សេវាសាធារណៈទាំងឡាយ ដើម្បីបង្ការកុំឱ្យមានកាលានុវត្តភាពសម្រាប់អំពើពុករលួយ ជាពិសេស នៅក្នុងវិស័យនានាដែលពាក់ព័ន្ធនឹងធុរៈកិច្ច និងការវិនិយោគ ។
- បង្កើតការិយាល័យប្រជាជនសម្រាប់ធ្វើជាយន្តការត្រួតពិនិត្យ ដើម្បីបង្ការកុំឱ្យមានអំពើពុករលួយ ។
- បង្កើតនិងជម្រុញការអនុវត្តក្រមសីលធមិសម្រាប់ផ្នែកសាធារណៈ ។
- បន្តចូលរួមយ៉ាងសកម្មនៅក្នុងឆាកអន្តរជាតិ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ដូចដែលបានធ្វើឡើងនៅក្នុងការចូលរួមក្នុងផែនការសកម្មភាពប្រឆាំងនឹងអំពើពុករលួយសម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក ។
- បង្ការនិងបញ្ចៀស "ការខ្ជះខ្ជាយ" នូវទ្រព្យសម្បត្តិឬធនធានសាធារណៈ រួមមាន ការចំណាយសម្រាប់ផលិតកម្មទំនិញនិងសម្រាប់ការផ្តល់សេវាកម្មទាំងឡាយដែលនឹងកើតឡើងខ្ពស់ជាងការចាំបាច់ ហើយធានានៅក្នុងបរិបទនេះថា ឧត្តមភាពប្រកួតប្រជែងជាសកល ត្រូវបានទាញយកឱ្យបានច្រើននូវផលប្រយោជន៍សម្រាប់ការវិនិយោគ ដោយចៀសវាងវិនិយោគទាំងឡាយណា ដែលមានលក្ខណៈប្រកួតប្រជែងតិចជាង ។

៤.១៣ <u>កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ</u>: ជាមួយនឹងភាពជឿនលឿនគួឱ្យកត់សំគាល់ដែលបានអនុវត្តកន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញឱ្យឃើញនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងកិច្ចខិតខំប្រឹងប្រែងពន្លឿនកំណែទម្រង់ច្បាប់ និងតុលាការ ដែលត្រូវបានកត់សំគាល់យ៉ាងច្បាស់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ថាជាធាតុផ្សំយ៉ាងសំខាន់មួយ ។ សេចក្តីសម្រេចមួយចំនួនត្រូវបានធ្វើឡើង ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចតាមរយៈប្រព័ន្ធយុត្តិធម៌មួយ ដែលមានទំនុកចិត្តពីសហគមន៍ជាតិ និងអន្តរជាតិ រួមទាំងវិនិយោគិនផងដែរ ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើតឱ្យមានទំនុកចិត្តនេះ រាជរដ្ឋាភិបាលកម្ពុជា បានអនុមតិចក្ខុវិស័យ និង *យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ* (មិថុនា ២០០៣) ដែលមានទិសដៅយុទ្ធសាស្ត្រចំនួន៧ ។ បន្ទាប់មករាជរដ្ឋាភិបាលបានអនុមតិកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ (២៩ មេសា ឆ្នាំ២០០៥) ។ សកម្មភាពសំខាន់ៗសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ មានដូចខាងក្រោម :

- រៀបចំ និងធ្វើការអនុមតិនូវច្បាប់ និងក្រមជាមូលដ្ឋានដែលទាក់ទងនឹងវិស័យតុលាការ ដូចជា : ច្បាប់ស្តីពីការរៀបចំតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាអាជ្ញា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធី

រដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋបាល និងបទបញ្ញត្តិ ដើម្បីធានាឯករាជ្យភាពនៃសេវាកម្មអយ្យការ ។

- រៀបចំនីតិវិធីនៃការធ្វើច្បាប់ប្រកបដោយតម្លាភាព អនុវត្តកម្មវិធីបង្កើនការយល់ដឹងអំពីសិទ្ធិនិងសេរីភាពនៅសហគមន៍ បង្កើតការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ ។
- ធានាចិរភាពនៃការបោះពុម្ពនិងផ្សព្វផ្សាយរាជកិច្ច និងសេចក្តីសម្រេចរបស់តុលាការ រៀបចំនូវសន្ទានុក្រមច្បាប់ បីភាសា ពង្រឹងជំនួយផ្នែកច្បាប់ ។
- បង្កើតតុលាការ សភាឯកទេសផ្សេងទៀត ទាក់ទងនឹងរឿងក្តីពាណិជ្ជកម្ម ការងារ អនីតិជន និងរដ្ឋបាល ។
- ពង្រីកតុលាការគំរូ ដែលបានបង្កើតរួចហើយនៅខេត្តកណ្តាល ផ្តល់សម្ភារៈបរិក្ខារគ្រប់គ្រាន់ និងទាន់សម័យដល់តុលាការ និងរៀបចំឱ្យមានការិយាល័យផ្តល់ព័ត៌មាននៅតាមសាលាជម្រះក្តី ។
- រៀបចំក្រមសីលធម៌សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធម៌ ។
- បង្កើត និងពង្រឹងយន្តការដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។

៤.១៤ <u>កំណែទម្រង់រដ្ឋបាលសាធារណៈ</u> : កំណែទម្រង់រដ្ឋបាលគឺជាយុទ្ធសាស្ត្រស្នូលសម្រាប់ការងារអភិបាលកិច្ច ។ គោលដៅនៃកំណែទម្រង់នេះ គឺដើម្បីធ្វើឱ្យរដ្ឋបាលក្លាយជាឧបករណ៍មួយរឹងមាំនៃគោលនយោបាយសាធារណៈ ហើយធ្វើឱ្យឧបករណ៍នេះមាន ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ អព្យាក្រឹត្យភាព តម្លាភាព និងការទទួលខុសត្រូវជាងមុន ដើម្បីបម្រើប្រជាជនឱ្យបានល្អប្រសើរជាងមុន ។ ជាមួយមូលដ្ឋានគ្រឹះទាំងឡាយដែលមានរួចហើយ ភារកិច្ចចំពោះមុខគឺ ត្រូវពង្រឹងនិងពង្រីកដំណើរការកំណែទម្រង់ ដើម្បីតម្រង់ទិសដៅទៅរកការកាត់បន្ថយភាពក្រីក្រ នៅពេលដែលមូលដ្ឋានគ្រឹះទាំងនោះមានចីរភាព ។ ដោយផ្អែកលើសមិទ្ធផលដែលមានរហូតមកដល់ពេលនេះ *កម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាល* កំពុងធ្វើការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាល ដើម្បីបម្រើប្រជាជនឱ្យមានភាពប្រសើរជាងមុន នៅទីណានិងនៅពេលណាដែលចាំបាច់ ។ ចំណុចមួយចំនួនខាងក្រោមនេះ បង្ហាញពីវិសាលភាពនៃកំណែទម្រង់ ដែលកំពុងដំណើរការ :

- ទំហំសរុបនៃសេវាកម្មស៊ីវិល នឹងត្រូវបានធ្វើឱ្យមានស្ថេរភាពគួរឱ្យកត់សម្គាល់នៅត្រឹមកម្រិតបច្ចុប្បន្ន ប៉ុន្តែសមាសភាពរបស់វានឹងមានការប្រែប្រួលច្រើន ដើម្បីគាំទ្រដល់វិស័យអាទិភាព និងប្រជាជននៅមូលដ្ឋានដែលរស់នៅក្រៅទីប្រជុំជនធំៗ ។
- ការគ្រប់គ្រងកម្លាំងពលកម្មនិងយន្តការត្រួតពិនិត្យនឹងត្រូវពង្រឹង ដើម្បីផ្គុំធនធានមនុស្សឱ្យចំតម្រូវការអាទិភាព ។
- ប្រាក់បៀវត្សរ៍និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ នឹងត្រូវបង្កើនជាបណ្តើរៗពី ១០ភាគរយ ទៅ ១៥ភាគរយ ក្នុងមួយឆ្នាំ ស្របទៅតាមលទ្ធភាពដែលរាជរដ្ឋាភិបាលមាន ។

- សេវាកម្មសាធារណៈនានា នឹងមានលក្ខណៈការិយាធិបតេយ្យតិចជាងមុន មានប្រសិទ្ធភាពជាងមុន មានលទ្ធភាពទទួលបាននិងតម្លាភាពជាងមុន តាមរយៈការអនុវត្តឧបករណ៍ចម្រុះ ដូចជាច្រកចេញ-ចូលតែមួយ ។
- សមត្ថភាពរបស់ប្រជាជននិងស្ថាប័ននៅក្នុងរដ្ឋបាល នឹងត្រូវអភិវឌ្ឍឡើងជាបន្ទាន់ ដើម្បីគាំទ្រគោលការណ៍ទាំងឡាយរបស់អភិបាលកិច្ចល្អ និងដើម្បីកែលម្អការបំពេញការងារ ។
- ការរៀបចំឱ្យមានស្វ័យប្រវត្តិកម្មជាបណ្តើរៗ នៅក្នុងដំណើរការនៃការគ្រប់គ្រងនិងការផ្តល់សេវាកម្មតាមរយៈបច្ចេកវិទ្យាព័ត៌មាន នឹងត្រូវធ្វើជាបន្តទៀត ដើម្បីលើកកម្ពស់គុណភាពនៃតម្លាភាពរបស់សេវាសាធារណៈ ។

**៤.១៥** សកម្មភាពជាអាទិភាពដែលបានគ្រោងទុក រួមមានៈ

- បន្តរៀបចំបង្កើនបៀវត្សរ៍មន្ត្រីរាជការទៅតាមលទ្ធភាពថវិកាជាតិ ។
- រៀបចំនិងអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ។
- បន្តដាក់ឱ្យអនុវត្តប្រព័ន្ធលាភការថ្មី ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការអនុវត្តការងារ និងផ្តល់ការលើកទឹកចិត្តដល់អ្នកដែលមានគុណសម្បត្តិ ។
- ពង្រឹងការត្រួតពិនិត្យនិងការគ្រប់គ្រងសាធារណៈ តាមរយៈការពង្រឹងអភិក្រមនិងការអនុវត្តការគ្រប់គ្រងធនធានមនុស្ស និងការបន្តធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមព័ត៌មានវិទ្យា ។
- ដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីនានា សម្រាប់ការពង្រាយមន្ត្រីរាជការ ទៅតាមតម្រូវការជាអាទិភាព ។
- អភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន តាមរយៈការប្រកាសឱ្យប្រើក្របខ័ណ្ឌមួយ ដើម្បីគ្រប់គ្រងការអភិវឌ្ឍសមត្ថភាព ការគ្រប់គ្រងការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដោយរួមបញ្ចូលទាំងការអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងតម្លៃនៃការងារបណ្តុះបណ្តាល ។
- អនុវត្តកម្មវិធីកន្សោមអាទិភាព ដែលជាមធ្យោបាយមួយ ផ្តល់ការលើកទឹកចិត្តដល់ការបំពេញការងារដល់មន្ត្រីដែលមានគុណសម្បត្តិ និងការលុបចោលជាបណ្តើរៗនូវរបបប្រាក់ឧបត្ថម្ភបន្ថែម ។

**៤.១៦** <u>វិមជ្ឈការនិងវិសហមជ្ឈការ</u> : កិច្ចអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម ដោយរាប់បញ្ចូលទាំងការកែលម្អ និងការផ្តល់សេវាសាធារណៈនានានៅថ្នាក់ឃុំ តាមលទ្ធភាពដែលអាចធ្វើទៅបាន គឺមានសារៈសំខាន់ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ។ អាទិភាពចម្បងមួយ គឺការកសាងសមត្ថភាពគ្រប់គ្រងនៅមូលដ្ឋាន និងការផ្តល់ធនធានហិរញ្ញវត្ថុក្នុងកម្រិតមួយសមស្រប ។ រាជរដ្ឋាភិបាល បានរៀបចំក្នុងពេលថ្មីៗនេះ នូវ

ប្រព័ន្ធសាកល្បងសម្រាប់ការផ្តល់សេវាកម្ម "ច្រកចេញ-ចូលតែមួយ" នៅក្នុងស្រុកពីរ ដើម្បីធ្វើឱ្យមានសេវារដ្ឋបាលពាក់ព័ន្ធមួយចំនួនដល់ប្រជាជននិងផ្នែកឯកជន ។

**៤.១៧** ការអភិវឌ្ឍនៅកម្រិតមូលដ្ឋាន អាចប្រព្រឹត្តទៅបានប្រសើរបំផុត តាមរយៈការកំណត់និងការធ្វើចំណាត់ថ្នាក់អាទិភាពពីតម្រូវការនៅថ្នាក់មូលដ្ឋាន ។ ក្នុងន័យនេះ ដោយផ្អែកលើគោលដៅរួមរបស់ *ផយអជ* (ជំពូក ៣) ឃុំ-សង្កាត់ ស្រុក-ខ័ណ្ឌ ខេត្ត-ក្រុងនីមួយៗ ត្រូវកំណត់អាទិភាពពីតម្រូវការផ្ទាល់ ដើម្បីធ្វើឱ្យសម្រេចបានគោលដៅតាមមូលដ្ឋានរៀងៗខ្លួន ដោយប្រើប្រាស់កញ្ចប់ថវិកាដែលបានបង្កើតឡើងឱ្យសមស្របទៅនឹងតម្រូវការនោះ តាមរយៈកញ្ចប់ថវិកាអំណោយរួម និងតាមប្រភេទផ្សេងៗ ការបែងចែកពន្ធ និងចំណូលផ្ទាល់ពីពន្ធនៅមូលដ្ឋានដែលបានប្រគល់ជូន ។

**៤.១៨** ដោយយោងតាមជំហានចម្បងដែលត្រូវបានអនុវត្ត តាមរយៈការរៀបចំកសាងក្របខ័ណ្ឌយុទ្ធសាស្ត្ររួមមួយសម្រាប់វិមជ្ឈការនិងវិសហមជ្ឈការ នាដើមឆ្នាំ២០០៥ យុទ្ធសាស្ត្រនិងសកម្មភាពចម្បងៗ ដែលបានលើកឡើងមានជាអាទិ៍ :

- ការរៀបចំសេចក្តីព្រាង និងអនុម័ត ច្បាប់អង្គការ ដើម្បីបញ្ជាក់ច្បាស់អំពីទស្សនៈជាមូលដ្ឋាននៅក្នុងសាប់ស៊ីឌីយ៉ារីទី ដើម្បីផ្តល់ការណែនាំ និងគោលការណ៍ឱ្យបានជាក់លាក់ថែមទៀត ដល់ដំណើរការបែងចែកអំណាច និងមុខងារក្នុងចំណោមរដ្ឋបាលនៅតាមថ្នាក់នានា ។
- ផ្ទេរការទទួលខុសត្រូវបន្ថែមទៀត និងធ្វើឱ្យមានមូលនិធិសម្រាប់ការអភិវឌ្ឍនិងប្រតិបត្តិការពី ក្រសួង-ស្ថាប័ន ទៅដល់ខេត្ត-ក្រុង និងថ្នាក់ក្រោមជាតិនានា ដោយអនុលោមតាមច្បាប់រៀបចំអង្គការ និងលិខិតបទដ្ឋានពាក់ព័ន្ធ និងបទបញ្ញត្តិកែប្រែនានា។
- បន្ថែមការយកចិត្តទុកដាក់លើវឌ្ឍនភាពដែលបានធ្វើរួចមកហើយ តាមរយៈកម្មវិធីដោយឡែកៗពីគ្នារបស់បណ្តាក្រសួង-ស្ថាប័ន ក្នុងនោះមាន ក្រសួងស្ថាប័នដែលកំពុងអនុវត្ត កម្មវិធីសកម្មភាពជាអាទិភាព (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ) ក៏ដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីកំណត់ឱ្យបានច្បាស់ជាងមុនអំពីក្របខ័ណ្ឌការងារ ដែលតាមរយៈនេះ ការធ្វើវិសហមជ្ឈការ និងវិមជ្ឈការសេវាកម្មអាចប្រព្រឹត្តទៅដោយមានភាពរលូនជាងមុន ។
- រៀបចំឱ្យមានលក្ខណៈជាប្រព័ន្ធ និងរៀបចំក្របខ័ណ្ឌស្ថាប័នឱ្យប្រសើរជាងមុននូវការបែងចែកថវិកា ដើម្បីធានាឱ្យមានការផ្ទេរថវិកាយ៉ាងពេញលេញនិងទាន់ពេលវេលា និងបង្កើតឱ្យមានថវិកានៅក្នុងប្រព័ន្ធ "ជំនួយជាកញ្ចប់" គឺ (មូលនិធិឃុំ-សង្កាត់) ដែលបានបង្កើតឡើងរួចហើយពីថវិកាជាតិ ទៅដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ព្រមទាំងអភិវឌ្ឍប្រព័ន្ធជំនួយជាកញ្ចប់ និងការវិភាជន៍តាមវិស័យសម្រាប់ថ្នាក់ខេត្ត

និងថ្នាក់ក្រោមជាតិដ៏ទៃទៀត ដើម្បីធានាឱ្យមានគណនេយ្យភាពនិងតម្លាភាពក្នុងការប្រមូលចំណូល និងការចំណាយ ចំពោះប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ។

- បង្កើននិងកំណត់មុខសញ្ញានៃការផ្តល់មូលនិធិទាំងនេះ ដោយយកអាទិភាពណាមួយជាមូលដ្ឋាន ជាពិសេស តំបន់ដាច់ស្រយាល និងតំបន់ផ្សេងៗទៀត ដែលភាពក្រីក្រមានកម្រិតខ្ពស់ ដើម្បីជួយបំពេញតម្រូវការរបស់មូលដ្ឋានក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការអភិវឌ្ឍផ្សេងៗទៀត តាមរបៀបមួយដ៏មានសារៈប្រយោជន៍ ។
- ពិនិត្យមើលលទ្ធភាពសមស្របសម្រាប់ថ្នាក់ខេត្ត និងថ្នាក់ក្រោមជាតិដ៏ទៃទៀត រួមទាំង ឃុំ-សង្កាត់ ធ្វើការអភិវឌ្ឍដោយផ្អែកលើធនធានផ្ទាល់ខ្លួន ក្នុងនោះរួមមាន ចំណូលផ្ទាល់នៅមូលដ្ឋាន ដែលបានមកពីពន្ធថ្នាក់មូលដ្ឋាន កម្រៃសេវាផ្សេងៗ ការចែករំលែកពន្ធនានាសម្រាប់ថវិកាមូលដ្ឋានជាដើម ។
- ដំណើរការអនុវត្តនូវប្រព័ន្ធគណនេយ្យមូលនិធិឃុំ-សង្កាត់ តាមប្រព័ន្ធព័ត៌មានវិទ្យានៅក្នុងរតនាគារខេត្ត ក្រុង ជាជំហានៗ ។
- កសាងនិងបង្កើនសមត្ថភាពស្ថាប័ន នៅថ្នាក់ក្រោមជាតិគ្រប់កម្រិត ។

**៤.១៩** <u>កំណែទម្រង់កងកម្លាំងប្រដាប់អាវុធនិងការកាត់រំសាយទ័ព</u> : *សៀវភៅសការពារជាតិ* បានចែងច្បាស់នូវគោលនយោបាយនិងកម្មវិធីនានាដែលត្រូវអនុវត្ត ក្នុងនោះមាន ការបែងចែកដីសម្បទានសង្គមកិច្ចដល់យោធិនរំសាយដែលគ្មានដីដោយត្រូវការដី សម្រាប់លំនៅដ្ឋាន និង/ឬសម្រាប់កសិកម្មបង្កើនផល ដើម្បីឱ្យបានសមស្របទៅ តាមអនុក្រឹត្យស្តីពី *សម្បទានដីសង្គមកិច្ច* ។ ដូចគ្នានេះដែរ កិច្ចខិតខំប្រឹងប្រែងទាំងឡាយនឹងត្រូវអនុវត្តជាបន្តទៀតដើម្បី កែទម្រង់ កសាង-បណ្តុះបណ្តាល និងពង្រឹងនគរបាលជាតិ ឱ្យក្លាយជាកងកម្លាំងមានវិជ្ជាជីវៈពិតប្រាកដ ប្រកបដោយបច្ចេកវិទ្យាទំនើប និងមានសមត្ថភាពបំពេញភារកិច្ចទទួលខុសត្រូវរបស់ខ្លួនក្នុងការរក្សា សន្តិសុខ សណ្តាប់ធ្នាប់ និងការឯកភាពគ្នាក្នុងសង្គម ហើយនិងរក្សាការពារអាយុជីវិតនិងទ្រព្យសម្បត្តិជូនប្រជាពលរដ្ឋ ។ នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន កងកម្លាំងនគរបាលជាតិ ជានិច្ចកាលត្រូវធ្វើសកម្មភាពដោយប្រកាន់ជំហរមិនលម្អៀងនិងប្រកបដោយប្រសិទ្ធភាព ដោយគោរពភាពថ្លៃថ្នូរនិងសិទ្ធិរបស់មនុស្ស ។

## បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

**៤.២០** បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំងមូលមានមុំចំនួន៤ គឺ *(១) សន្តិភាព ស្ថេរភាពនយោបាយនិងសណ្តាប់ធ្នាប់សង្គម (២) សមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងក្នុងពិភពលោក (៣) ភាពជាដៃគូក្នុងការអភិវឌ្ឍ និង (៤) បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ* ។ ជាមួយនោះដែរ បញ្ហាពហុវិស័យមួយចំនួនទៀត ក៏ត្រូវបានចាត់ទុកថាជាបរិស្ថានរួមសម្រាប់ការអភិវឌ្ឍផងដែរ ។

**៤.២១** <u>សន្តិភាព ស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម</u> គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។ ជាក់ស្តែង ការផ្សះផ្សារជាតិក្រោយជម្លោះផ្ទៃក្នុង លទ្ធិប្រជាធិបតេយ្យ សណ្តាប់ធ្នាប់សង្គម និងការកាត់បន្ថយឧក្រិដ្ឋកម្មដែលសម្រេចបាននៅក្នុងពេលកន្លងមក តាមរយៈការពិភាក្សានិងការសម្របសម្រួលទៅវិញទៅមក គឺមានតម្លៃខ្ពស់ ហើយត្រូវការការថែរក្សានិងលើកកម្ពស់ជាចាំបាច់ ។ ទាំងអស់នេះ មិនត្រឹមតែមានសារៈសំខាន់សម្រាប់វឌ្ឍនភាពកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏មានសារៈសំខាន់ក្នុងការបង្ហាញមុខមាត់ល្អរបស់ប្រទេសនៅលើពិភពលោកផងដែរ ។ ក្នុងន័យនេះ ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីធានាថា កត្តាទាំងនេះនឹងត្រូវបានបន្តថែរក្សាតាមរូបភាពមួយប្រកបដោយថាមភាពនិងដែលនាំឱ្យមានកំណើន ។

**៤.២២** ទិដ្ឋភាពដ៏សំខាន់មួយនៃការរក្សាស្ថេរភាពនយោបាយនិងការឯកភាពគ្នា គឺការរៀបចំការបោះឆ្នោតជាទូទៅរាល់៥ឆ្នាំម្តង ដើម្បីជ្រើសរើសស្ថាប័នជាតិនានា ដូចជា ព្រឹទ្ធសភា (ដែលនឹងត្រូវរៀបចំនៅឆ្នាំ២០០៦) រដ្ឋសភា (ដែលនឹងត្រូវរៀបចំនៅឆ្នាំ២០០៨) និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលនឹងរៀបចំនៅឆ្នាំ២០០៧) ។ ដោយហេតុថា ថវិកាជាតិតែឯងមិនអាចបំពេញតម្រូវការចំណាយដ៏ច្រើនសម្រាប់ការរៀបចំការបោះឆ្នោតទាំងនេះបាន ជំនួយបន្ថែមពីប្រភពខាងក្រៅនឹងនៅតែជាភាពចាំបាច់ ដូចពេលមុនៗដែរ ។

**៤.២៣** <u>សមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងក្នុងពិភពលោក</u> : ដោយបានដើរតួនាទីយ៉ាងសកម្មក្នុងនាមជាដៃគូមួយនៅក្នុងរាល់កិច្ចការរបស់អាស៊ាន ដោយបានចូលរួមនិងរួមវិភាគទាននៅក្នុងសន្និសីទនិងកម្មវិធីការងារកម្រិតតំបន់ និងដោយបានចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (ឆ្នាំ២០០៤) កម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពដ៏ល្អប្រសើរ ដើម្បីឈានទៅសម្រេចគោលដៅនេះនៅពេលខាងមុខ ។ ទោះជាដូចនេះក្តី កម្ពុជាត្រូវធ្វើការងារច្រើនជាងនេះទៀត ដើម្បីពង្រីកនិងពង្រឹង និងដើម្បីទាញយកអត្ថប្រយោជន៍ ពីដំណើរការនៃសមាហរណកម្មនេះ ។ គោលដៅនៃការងារនេះ គឺដើម្បីធានាថា កិច្ចខិតខំប្រឹងប្រែងដើម្បីការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់និងពិភពលោក ត្រូវផ្តោតការយកចិត្តទុកដាក់លើការផ្តល់ប្រយោជន៍ជូនអ្នកក្រ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជានឹង :

- អនុវត្តតាមយ៉ាងពេញលេញ នូវភាពជាដៃគូក្នុងការអនុវត្តកម្មវិធីនានានៃ ការផ្តួចផ្តើមសម្រាប់សមាហរណកម្មទៅក្នុងអាស៊ាន និងការចូលរួមយ៉ាងពេញលេញ នៅក្នុងកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ ។ ជាពិសេស កិច្ចខិតខំប្រឹងប្រែងទាំងឡាយ គឺដើម្បីអនុវត្តរួមគ្នានូវសកម្មភាពទាំងឡាយរបស់ជាតិនិងតំបន់ ដែលស្របគ្នាទៅនឹង ចក្ខុវិស័យអាស៊ានឆ្នាំ២០២០ កិច្ចព្រមព្រៀងទីក្រុងបាលីលើកទី២ កម្មវិធីសកម្មភាពទីក្រុងវៀងច័ន្ទសម្រាប់ឆ្នាំ២០០៤-២០១០ ដោយរួមបញ្ចូលទាំងផែនការ និងសកម្មភាពទាំងអស់ ។

- អនុវត្តយ៉ាងសកម្មនិងបង្កើននូវចំនួនកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិងដោយមានការអនុគ្រោះ ជាមួយបណ្ដាប្រទេសដទៃទៀត ដើម្បីលទ្ធភាពហូរចូលទៅក្នុងទីផ្សារក្រៅប្រទេសនៃផលិតផលនិងសេវាកម្មរបស់កម្ពុជា ។
- ទាក់ទាញការវិនិយោគ បង្កើនសមត្ថភាពជំនាញ បង្កើតការងារ និងជំរុញឱ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច ដែលនឹងផ្ដល់ផលប្រយោជន៍ដល់អ្នកក្រីក្រ ។
- អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកាតព្វកិច្ច និងការសន្យារបស់កម្ពុជាក្រោមសមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោក ជាពិសេស កម្មវិធីការងារដែលបានអនុម័តដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ព្រមទាំងវាយតម្លៃផលប៉ះពាល់នៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ទៅលើការកាត់បន្ថយភាពក្រីក្រ ដែលផ្ដោតជាពិសេសលើវិស័យកសិកម្ម ដោយរាប់បញ្ចូលទាំងផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ ជាពិសេស ស្ត្រីដែលមានចំនួនច្រើនលើសលប់នៅក្នុងវិស័យមិនផ្លូវការ ។

**៤.២៤** _ភាពជាដៃគូក្នុងការអភិវឌ្ឍ_ : ទិដ្ឋភាពជាមូលដ្ឋានបីដែលពាក់ព័ន្ធនឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជានិងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ គឺ (១) ភាពជាដៃគូជាមួយសង្គមស៊ីវិល (២) ភាពជាដៃគូជាមួយវិស័យឯកជននិងសហគមន៍អ្នកវិនិយោគ និង (៣) ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។ ទិសដៅនៃការងារនេះ គឺដើម្បីពង្រឹងភាពជាដៃគូជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ដើម្បីកែលម្អការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងដោយមានការសម្របសម្រួល ដើម្បីឈានទៅសម្រេចអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយសមធម៌ ។

**៤.២៥** កិច្ចខិតខំប្រឹងប្រែងដែលកំពុងដំណើរការ នឹងត្រូវបន្តនិងពង្រឹង ដើម្បីផ្ដល់ឱកាសឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានរបស់សង្គមស៊ីវិល នៅក្នុងគ្រប់ទិដ្ឋភាពសមស្របនៃដំណើរការការរៀបចំផែនការ និងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងដើម្បីឱ្យសង្គមស៊ីវិលក្លាយជាដៃគូដ៏មានប្រសិទ្ធភាពនៅក្នុងការងារអភិវឌ្ឍ ។ កន្លងមក អង្គការក្រៅរដ្ឋាភិបាលជាច្រើន (ជាតិនិងអន្តរជាតិ) បានចូលរួមរួចមក ហើយនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ក៏ដូចជា ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។ ច្បាប់ស្ដីពីអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវរៀបចំនៅក្នុងពេលឆាប់ៗខាងមុខនេះ ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធទាំងអស់ ។

**៤.២៦** តួនាទីដ៏សំខាន់របស់ _វិស័យឯកជន_ ដែលត្រូវបានចាត់ទុកថាជាក្បាលម៉ាស៊ីននិងជាកម្លាំងជំរុញសម្រាប់ការវិនិយោគនិងកំណើនសេដ្ឋកិច្ច គឺជាកត្តាដែលមិនអាចខ្វះបាន ។ ដោយបានផ្ដល់អាទិភាពខ្ពស់ដល់ការសម្រួលកិច្ចប្រតិបត្តិការរបស់វិស័យឯកជន យន្តការមួយចំនួនត្រូវបានបង្កើតឡើង ហើយកិច្ចខិតខំប្រឹងប្រែងនឹងត្រូវធ្វើ

ជាបន្តទៀត ដើម្បីពង្រឹងនិងពង្រីកទំនាក់ទំនងល្អប្រសើរ ជាមួយវិស័យឯកជន ដោយផ្អែកលើការប្រកាន់ខ្ជាប់ទៅនឹងបញ្ញត្តិច្បាប់នានា និងដោយផ្តោតលើអាទិភាពទាំងឡាយនៃការអភិវឌ្ឍ ។

**៤.២៧** ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស : រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ដោយអំណរគុណថា កម្រិតជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសដ៏សប្បុរសធម៌ ដែលទទួលបានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសចាប់តាំងពីឆ្នាំ ១៩៩៣មក បានជួយយ៉ាងច្រើនដល់ការរីកចម្រើនដ៏គួរឱ្យកត់សម្គាល់របស់កម្ពុជា ។ ជាការពិតណាស់ ក្នុងឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជានឹងបន្តត្រូវការនូវការគាំទ្របែបនេះសម្រាប់រយៈពេលវែងមួយនៅក្នុងពេលខាងមុខ នៅក្នុងពេលដែលកម្ពុជាត្រូវបោះជំហានទៅមុខដើម្បីសម្រេចបានគោលដៅរយៈពេលវែងរបស់ខ្លួន ។ រូបភាពជាច្រើននៃកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មានការរីកចម្រើនក្នុងរយៈកាលកន្លងមក ក្នុងនោះមាន ការប្រជុំប្រចាំឆ្នាំដើម្បីកៀរគរជំនួយ (*កិច្ចប្រជុំពិគ្រោះយោបល់*) ការពិគ្រោះយោបល់នៅកម្រិតវិស័យ ការពិគ្រោះយោបល់នៅក្នុងប្រទេសតាមពេលវេលាកំណត់ ហើយក្នុងពេលថ្មីៗនេះ ការបង្កើតក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស សម្រាប់បញ្ហាពិសេសៗ និងបញ្ហាតាមវិស័យ និងការបង្កើតគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ ដែលជួបប្រជុំគ្នាជារៀងរាល់ត្រីមាស ដើម្បីវាយតម្លៃពីវឌ្ឍនភាពនិងផ្តល់ការតម្រង់ទិសសម្រាប់អនាគត ។ យន្តការទាំងអស់នេះនឹងត្រូវបន្តធ្វើការពង្រឹង ដើម្បីឈានទៅធ្វើឱ្យមានការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព និងទៀងទាត់ និងភាពជាដៃគូ តាមរយៈការបង្កើនភាពជាម្ចាស់និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ។ កិច្ចប្រជុំប្រចាំត្រីមាសជាទៀងទាត់ ឬច្រើនដងតាមភាពចាំបាច់ ក្រុមការងារបច្ចេកទេសនឹងមានតួនាទីសំខាន់ក្នុងការជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំកសាងផែនការថ្មីៗតាមវិស័យ ក្នុងការពិនិត្យកែសម្រួលឡើងវិញនូវផែនការតាមវិស័យដែលកំពុងអនុវត្ត ក្នុងការធ្វើឱ្យរលូននិងការសម្របសម្រួលជំនួយក្រៅប្រទេសសម្រាប់កម្មវិធីនិងគម្រោងទាំងឡាយ ក៏ដូចជា ក្នុងការត្រួតពិនិត្យការអនុវត្តនិងវឌ្ឍនភាពរបស់ផែនការទាំងនោះ ។

**៤.២៨** គួរកត់សម្គាល់ថា ក្នុងពេលកន្លងមក ធនធានដ៏ច្រើនដែលត្រូវបានចំណាយដោយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបានផ្តោតទៅលើជំនួយបច្ចេកទេសនិងការសិក្សាស្រាវជ្រាវនិងការធ្វើអង្កេតនានា ។ ជាការពិត ទោះបីជាការសិក្សាស្រាវជ្រាវនិងការធ្វើអង្កេតទាំងនេះ មានសារៈសំខាន់ក៏ដោយ ក៏ពេលនេះ យើងត្រូវធានាថា ធនធានទាំងឡាយ ត្រូវបានតម្រង់ទិសសារជាថ្មី ដើម្បីធ្វើឱ្យមាន"មូលនិធិបន្ថែម" សម្រាប់សកម្មភាពជារូបវ័ន្ត សម្រាប់ធ្វើឱ្យមានភាពប្រសើរឡើងនៅក្នុងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។

**៤.២៩** នៅកម្រិតពិភពលោក តាមរយៈគំនិតផ្តួចផ្តើមរបស់ *អង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច/គណៈកម្មាធិការជំនួយអភិវឌ្ឍន៍* កិច្ចព្រមព្រៀងអន្តរជាតិ បានប្រកាសឡើង តាមរយៈសេចក្តីថ្លែងការនៃវេទិកាកម្រិតខ្ពស់នៅទីក្រុងរ៉ូម (ឆ្នាំ២០០៣) និងទីក្រុងប៉ារីស (ឆ្នាំ២០០៥) ដែលបានសង្កត់ធ្ងន់ថា ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ ប្រការសំខាន់គឺត្រូវលើកទឹកចិត្ត និងគោរពតាមភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំពេញលេញ

នៃបណ្តាប្រទេសទទួលជំនួយ ក្នុងការរៀបចំនិងការអនុវត្តនូវកិច្ចអភិវឌ្ឍន៍ប្រទេស ។ ទន្ទឹមនឹងនេះ កិច្ចប្រជុំនេះ បានឯកភាពថា ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបន្សុីគោលនយោបាយ អាទិភាព និងកម្មវិធី នៃជំនួយអភិវឌ្ឍន៍របស់ខ្លួន ក៏ដូចជា ធ្វើសុខដុមនីយកម្ម នីតិវិធីការងាររបស់ខ្លួន ជាមួយនឹងគោលនយោបាយ អាទិភាព និងកម្មវិធីអភិវឌ្ឍន៍ ក៏ដូចជា នីតិវិធីការងាររបស់ប្រទេសទទួលជំនួយ ។ ប្រទេសកម្ពុជា ត្រូវបានជ្រើសរើសជាប្រទេសសាកល្បងមួយ សម្រាប់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ។ សេចក្តីប្រកាសនាទីក្រុងម៉ុងទែរ៉េ ឆ្នាំ២០០២ បានបង្ហាញពីការឯកភាពគ្នាផងដែរថា បណ្តាប្រទេសអភិវឌ្ឍន៍ ត្រូវបង្កើនជំនួយអភិវឌ្ឍន៍របស់ខ្លួនបន្ថែមទៀត ។

៤.៣០ *ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍* គឺនឹងត្រូវបញ្ចប់ ដើម្បីធ្វើការបញ្ជាក់ឡើងវិញឱ្យច្បាស់ពី នីតិវិធីនិងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលនឹងគ្រប់គ្រង និងតម្រង់ទិសទាំងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និងទាំងការកំណត់តួនាទីនិងការទទួលខុសត្រូវក្នុងរាជរដ្ឋាភិបាល ។ ប្រការទាំងនេះ នឹងរៀបចំដំណើរការទាំងឡាយឱ្យមានប្រសិទ្ធភាពជាងមុន ដើម្បីកែលម្អ កិច្ចសហប្រតិបត្តិការទៅវិញទៅមក រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។ តាមរយៈយន្តការនៃកិច្ចសហប្រតិបត្តិការ ដែលបានចែងក្នុងឯកសារខាងលើនេះ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបានលើកទឹកចិត្តឱ្យប្តូរចេញការផ្តល់ជំនួយពីគម្រោងទោល ក៏ដូចជា គម្រោងជំនួយបច្ចេកទេស ហើយចាប់ផ្តើមផ្តល់ការគាំទ្រតាមរយៈ *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* ដោយផ្តោតទៅលើការផ្តល់ធនធានមួយភាគធំ តាមរូបភាពការគាំទ្រថវិកាដែលជាទម្រង់មួយល្អប្រសើរ នៅក្នុងលក្ខខណ្ឌមួយដែលមានការព្រមព្រៀងគ្នាថា ត្រូវធ្វើឱ្យមានវឌ្ឍនភាពតាមវិស័យ និង/ឬនៅក្នុងកំណែទម្រង់នានា ។

៤.៣១ <u>បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ</u> : គោលដៅនៃការពង្រឹងបរិស្ថាននេះ គឺត្រូវធានាឱ្យមាន *ការរីកចម្រើនផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងបរិស្ថានហិរញ្ញវត្ថុ* ដើម្បីធ្វើឱ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច ដែលផ្អែកលើមូលដ្ឋានចម្រុះនិងមានលក្ខណៈគាំទ្រអ្នកក្រ ច្រើនជាងមុន ។ កំណើនម៉ាក្រូសេដ្ឋកិច្ច ដែលត្រូវបានធ្វើឱ្យមានការបែងចែកល្អតាមតំបន់និងវិស័យ មានលក្ខណៈរឹងមាំ និងមានចីរភាពរួចមកហើយ ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រុងប្រយ័ត្ន បង្កើតជាចំណុចស្នូលនៃគ្រប់កម្មវិធីសេដ្ឋកិច្ច-សង្គមកិច្ចទាំងអស់ ។ រាជរដ្ឋាភិបាល បានទទួលជោគជ័យក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច នាពេលកន្លងមក និងមានសមត្ថភាពទប់ទល់នឹងវិបត្តិក្រៅប្រទេស ដូចជា វិបត្តិហិរញ្ញវត្ថុនៅអាស៊ីនាឆ្នាំ១៩៩៧ ក៏ដូចជាភាពមិនទៀងទាត់នៃនយោបាយផ្ទៃក្នុង ដែលមានម្តងម្កាល នៅឆ្នាំ១៩៩៧ និងឆ្នាំ២០០៣-២០០៤ ។ តាមរយៈបទពិសោធន៍នេះ រាជរដ្ឋាភិបាលមានទំនុកចិត្តថា ជាមួយនឹងការប្រុងប្រយ័ត្ននិងវិធានការទាន់ពេលវេលា រាជរដ្ឋាភិបាល នឹងមានសមត្ថភាពដើម្បីដឹកនាំស្ថានការណ៍ទាំងមូលក្នុងពេលអនាគតប្រកបដោយជោគជ័យ ។ យុទ្ធសាស្ត្រនិងសកម្មភាពទាំងឡាយនៅក្នុងដំណាក់កាល *ផយអជ* មានដូចខាងក្រោម :

- ធានាឱ្យមានកំណើនថេរនៃ *ផសស* ក្នុងអត្រា ៦ភាគរយ ក្នុងមួយឆ្នាំ ។

- រក្សាស្ថេរភាពវិស័យក្រៅប្រទេស និងស្ថេរភាពអត្រាប្តូរប្រាក់ ។
- កំណត់អត្រាអតិផរណានៅក្រោម ៥ភាគរយ ។
- ប្រមូលចំណូលក្នុងស្រុកឱ្យបានច្រើនបន្ថែមទៀត ។
- ផ្តល់ការវិនិយោគដោយផ្ទាល់ទៅវិស័យទាំងឡាយដែលគាំទ្រដល់តំបន់ជនបទ និងលើកទឹកចិត្តឱ្យមានការវិនិយោគឯកជន ក្នុងវិស័យទាំងនោះ ដែលនឹងជួយពង្រឹកមូលដ្ឋាននៃសកម្មភាពសេដ្ឋកិច្ចនានា ។
- អនុវត្តតាមគោលនយោបាយថវិកាដែលនាំឱ្យមានវឌ្ឍនភាព និងមានលក្ខណៈរិតត្បិត ស្តីពីចំណូលនិងចំណាយ ។
- ធ្វើឱ្យប្រសើរឡើងក្នុងការប្រមូលចំណូល (ពន្ធដារនិងមិនមែនពន្ធដារ) ដោយពង្រីកមូលដ្ឋានយកពន្ធ និងលុបបំបាត់ "វប្បធម៌រួចពន្ធ និងលើកលែងពន្ធ" តាមរយៈការអនុវត្តយ៉ាងហ្មត់ចត់នូវច្បាប់ពន្ធដារ និងវិធានការផ្សេងៗទៀត ។
- ប្រយុទ្ធប្រឆាំងយ៉ាងខ្លាំងក្លាទៅនឹងការរត់គេចពន្ធឆ្លងកាត់ព្រំដែន និងធានាឱ្យមានការប្រមូលបំណុល ។
- តម្រង់ការចំណាយទៅរកវិស័យអាទិភាពនៃការអភិវឌ្ឍ និងវិស័យដែលមិនទាន់បានទទួលការយកចិត្តទុកដាក់ពេញលេញរហូតមកដល់ពេលនេះ ។
- ពង្រឹងនិងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវបទបញ្ញត្តិច្បាប់ទាំងឡាយស្តីពីលទ្ធកម្មសាធារណៈ ។
- ធ្វើសវនកម្មជាប្រចាំ (ផ្ទៃក្នុងនិងពីខាងក្រៅ) ទៅលើចំណូលនិងចំណាយថវិកា ដោយរួមបញ្ចូលទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នទាំងអស់ ។
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងនោះរួមមាន ទ្រព្យសម្បត្តិរូបវ័ន្តនិងអរូបវ័ន្ត ក៏ដូចជាសហគ្រាសរដ្ឋ និងចម្រុះរដ្ឋ តាមរបៀបមួយមានតម្លាភាពនិងប្រសិទ្ធភាព ដើម្បីការពារផលប្រយោជន៍របស់រដ្ឋ និងលើកកម្ពស់ឱ្យមានលំហូរថេរនៃចំណូលថវិកា ។
- អនុវត្តតាមនីតិវិធីដេញថ្លៃសាធារណៈដែលមានលក្ខណៈច្បាស់លាស់និងតម្លាភាព ក្នុងការលក់ចេញ ឬជួលទ្រព្យសម្បត្តិរដ្ឋ ឬសិទ្ធិ ជាក់ស្តែងក្នុងការផ្តល់កិច្ចសន្យារបស់រដ្ឋទាំងអស់ ។
- រក្សាការឃ្លាំមើលដោយប្រុងប្រយ័ត្ន ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការចុះហត្ថលេខាលើកិច្ចសន្យា ជាមួយបណ្តាក្រុមហ៊ុនឯកជន ។

**៤.៣២** កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំចប់សព្វគ្រប់និងកំពុងអនុវត្ត ។ *ក្របខ័ណ្ឌចំណាយនិងសារពើពន្ធរយៈពេលមធ្យមជន្ទាវ៉ាំកិល* ធ្វើការព្យាករណ៍ចំណូលនិងចំណាយ ហើយត្រូវបានយកទៅអនុវត្តតាម ។ ដើម្បីធានាការបង្កើនថវិកាវិភាជន៍និងការផ្តល់ថវិកាទាន់ពេលវេលាទៅវិស័យអាទិភាពដែលគាំទ្រអ្នកក្រ យន្តការជាច្រើននឹងត្រូវបង្កើតឡើង ហើយតាមរយៈយន្តការទាំងនោះ ចំនួនថវិកាប្រចាំឆ្នាំដែលត្រូវធានាឱ្យមាននិងធ្វើឱ្យមានការកើនឡើង នឹងត្រូវផ្តល់ទៅឱ្យវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ សុខាភិបាល និងអប់រំ ។

**៤.៣៣** ដោយមានការដឹកនាំដោយធនាគារជាតិនៃកម្ពុជានិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ វិស័យហិរញ្ញវត្ថុដើរតួនាទីដ៏សំខាន់ក្នុងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងក្នុងការកំណត់ល្បឿននិងទិសដៅរបស់កំណើនសេដ្ឋកិច្ច ។ វិស័យហិរញ្ញវត្ថុ មួយដែលដំណើរការល្អ អាចកាត់បន្ថយនូវភាពមានកម្រិតនៃស្វ័យហិរញ្ញប្បទាន ហើយកៀរគរប្រមូលប្រភពធនធានហិរញ្ញវត្ថុដែលមិនប្រើប្រាស់ សម្រាប់ការវិនិយោគដែលមានប្រយោជន៍សម្រាប់វិស័យផលិត ។ ដើម្បីផ្សារភ្ជាប់ គ្នារវាងការសន្សំ ការវិនិយោគ និងកំណើនសេដ្ឋកិច្ច វិស័យហិរញ្ញវត្ថុចាំបាច់ត្រូវដើរទៅជាមួយគ្នានឹងការអភិវឌ្ឍវិស័យឯកជន និងកំណែទម្រង់អភិបាលកិច្ច ដោយបង្កើតជាសរសរទ្រូងបី ដើម្បីទ្រទ្រង់ចក្កុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការបង្កើតនិងការទ្រទ្រង់កំណើន ដែលជាមធ្យោបាយមួយដ៏សំខាន់សម្រាប់កាត់បន្ថយភាពក្រីក្រ ។ ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០១-២០១០ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០១ គឺជាឧបករណ៍ណែនាំសម្រាប់គោលនយោបាយនិងកម្មវិធីទាំងឡាយក្នុងវិស័យនេះ ហើយប្រមើលមើលពីការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយដ៏ល្អដែលផ្អែកលើទីផ្សារ នៅឆ្នាំ២០១០ ដើម្បីបង្កើនការកៀរគរប្រមូលប្រភពទុនសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០១-២០១០ ដែលកំពុងត្រូវបានអនុវត្តនាបច្ចុប្បន្ននេះ ផ្តោតការយកចិត្តទុកដាក់យ៉ាងទូលំទូលាយទៅលើផ្នែកនិងទិដ្ឋភាពទាំងឡាយនៃវិស័យហិរញ្ញវត្ថុ ជាអាទិ៍មាន :

- ប្រព័ន្ធធនាគារមួយដែលមានលក្ខណៈប្រកួតប្រជែង មានលក្ខណៈប្រមូលផ្តុំ និងមានប្រសិទ្ធភាព ដែលត្រូវគ្រប់គ្រងដោយបទបញ្ញត្តិច្បាប់និងត្រូវត្រួតពិនិត្យ ដើម្បីបង្កើតទុនសម្រាប់ការវិនិយោគរបស់វិស័យឯកជន និងសម្រាប់កំណើន ។
- ប្រព័ន្ធហិរញ្ញវត្ថុជនបទមួយដែលអាចដំណើរការបាន ដែលគាំទ្រអ្នកក្រ និងមានប្រសិទ្ធភាព សម្រាប់ការផ្តល់សេវាហិរញ្ញវត្ថុ ដែលអាចប្រើប្រាស់បានសម្រាប់អ្នកក្រីក្រ ដើម្បីបង្កើនប្រាក់ចំណូលតាមជនបទ និងកាត់បន្ថយភាពក្រីក្រ ។
- វិស័យធានារ៉ាប់រងមួយ ដែលគាំពារអាជីវកម្មនិងឯកត្តជនទាំងឡាយឱ្យផុតពីហេតុការណ៍មិនអនុគ្រោះដែលមិនអាចដឹងមុនបាន និងប្រព័ន្ធប្រាក់សោធនមួយ ដែលផ្តល់ដល់ការចូលនិវត្តន៍ប្រកបដោយការធានា ហើយកត្តាទាំងពីរនេះ នឹងផ្តល់ផងដែរនូវដើមទុនសម្រាប់ការវិនិយោគ ។
- ទីផ្សារទុនមួយដែលមានប្រសិទ្ធភាពនិងតម្លាភាព ដោយមានការប្រមូលផ្តុំយ៉ាងធំមួយនូវអ្នកចេញលក់ភាគហ៊ុន ដែលកៀរគរប្រមូលទុនសម្រាប់ការវិនិយោគរយៈពេលវែង ។
- ទីផ្សាររូបិយវត្ថុមួយដែលអាចធ្វើឱ្យមានអន្តរកម្មរវាងធនាគារ ហើយផ្តល់ឱ្យធនាគារ ក្រុមហ៊ុន និងឯកត្តជន ទាំងឡាយនូវមធ្យោបាយសម្រាប់ការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព ។
- ការបង្កើតស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារ ដូចជា ក្រុមហ៊ុនភតិសន្យា ក្រុមហ៊ុនហិរញ្ញវត្ថុ ក្រុមហ៊ុនវិនិយោគ ក្រុមហ៊ុនដើមទុនចម្រុះ និងស្ថាប័នអភិវឌ្ឍន៍ហិរញ្ញវត្ថុ ។

- បង្កើតឱ្យមានហេដ្ឋារចនាសម្ព័ន្ធគណនេយ្យនិងច្បាប់ ដើម្បីធានាឱ្យមានអភិបាលកិច្ចល្អជាលក្ខណៈសាជីវកម្ម និងមានតម្លាភាព ។

## តារាង៤.១ : ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ[១]

(គិតជាភាគរយនៃ *ផសស* លើកលែងតែមានការបញ្ជាក់)

| សូចនាករសំខាន់ៗ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| **កំណើនពិតនៃ *ផសស* (*ផសស*-%)** | **៧,០** | **៦,០** | **៦,០** | **៥,៨** | **៥,៩** | **៦,០** |
| អតិផរណាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (ចុងឆ្នាំ-គិតជា %) | ៦,២ | ៣,៥ | ៣,០ | ៣,០ | ៣,០ | ៣,០ |
| | | | | | | |
| **ចំណូល** | **១១,៨** | **១២,២** | **១២,៨** | **១៣,២** | **១៣,៥** | **១៣,៨** |
| ចំណូលពន្ធ | ៨,៧ | ៩,៤ | ៩,៤ | ៩,៤ | ៩,៣ | ៩,២ |
| | | | | | | |
| **ចំណាយ** | **១៤,៩** | **១៧,០** | **១៧,២** | **១៧,១** | **១៦,៩** | **១៦,៥** |
| ចំណាយចរន្ត | ៩,៦ | ១០,៥ | ១០,៧ | ១០,៧ | ១០,៧ | ១០,៨ |
| | | | | | | |
| **ការវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ)** | **២១៦** | **២២៧** | **២៤៩** | **២៧៤** | **៣០២** | **៣៣២** |

***ប្រភព:** យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ-របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០០៥ : តារាង ២.២*

**៤.៣៤** ដូចតួលេខដែលបានបង្ហាញក្នុងតារាង៤.១ ស្ថានភាពទូទៅនៃម៉ាក្រូសេដ្ឋកិច្ចសម្រាប់រយៈពេលពីរ-បីឆ្នាំខាងមុខ ហាក់ដូចជាមានស្ថេរភាពនិងគួរជាទីទុកចិត្ត ។ ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ដែលផ្តោតជាសំខាន់ទៅលើការនាំចេញ ដែលបច្ចុប្បន្ននេះជាកម្លាំងនាំមុខយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ច អាចនឹងនៅបន្តរឹងមាំក្នុងរយៈពេលច្រើនឆ្នាំខាងមុខទៀត ប៉ុន្តែអត្រាកំណើនក្នុងផ្នែកនេះអាចនឹងមានការថយចុះ ទោះបីជាប្រព័ន្ធកូតាដែលបានបញ្ចប់នៅដើមឆ្នាំ២០០៥ ពុំមានផលប៉ះពាល់ខ្លាំងទៅលើអត្រាកំណើនសេដ្ឋកិច្ចក៏ដោយ ។ វិស័យទេស-ចរណ៍ក៏បានរួមចំណែកយ៉ាងច្រើន ផងដែរក្នុងសេដ្ឋកិច្ច ហើយត្រូវបានរំពឹងទុកថា នឹងនៅតែរួមចំណែកជាបន្តទៀត ហើយនិន្នាការនៃកំណើនខ្ពស់ក្នុង វិស័យសំណង់ ក៏នឹងបន្តនៅតែមានដែរ ។ ប៉ុន្តែ ប្រការដែលចាំបាច់នោះគឺត្រូវតែពង្រឹងនិងពង្រីកមូលដ្ឋានគ្រឹះ ជាពិសេស ដោយជំរុញឱ្យមានកំណើនក្នុងវិស័យនេះ ដែលនឹងជួយដល់ការកាត់បន្ថយភាពក្រីក្របានយ៉ាងឆាប់រហ័សផងដែរ ។ ការជំរុញការកែទម្រង់ចាំបាច់ខ្លាំងក្នុងផ្នែកអភិបាលកិច្ច អាចជួយដល់ការទាក់ទាញការវិនិយោគច្រើន ថែមទៀត ទាំងអ្នកវិនិយោគក្នុងស្រុកនិងបរទេស ។

**៤.៣៥** កត្តាសំខាន់ៗមួយចំនួន ដែលអាចប៉ះពាល់លើសេដ្ឋកិច្ច មានជាអាទិ៍គឺ : (១) ការបន្តកើនឡើងខ្ពស់នៃថ្លៃប្រេងឥន្ធនៈ (២) ការគំរាមកំហែងពីភេរវកម្មនៅគ្រប់ទីកន្លែងលើពិភពលោកដែលអាចរំខានដល់បរិយាកាសនយោបាយអន្តរជាតិ និងដែលអាចធ្វើឱ្យមានអស្ថេរភាពដល់បរិយាកាសសេដ្ឋកិច្ចដែលអាចដឹងមុនបាន (៣) ការ

[១] តារាងលម្អិតមាននៅក្នុងឧបសម្ព័ន្ធ ២.១ ២.២ និង២.៣

ថយចុះនៃលំហូរចូលនៃ*ជំនួយអភិវឌ្ឍន៍ក្រៅប្រទេស* ដោយសារតែកត្តាពីខាងក្រៅ (៤) ការកកើតឡើងដោយមិនមានការរំពឹងទុកជាមុននៃជម្ងឺឆ្លងមួយចំនួន ដូចជា ជម្ងឺដែលកើតឡើងដោយការរីករាលដាលនៃមេរោគ "ផ្តាសសាយបក្សី" (៥) ការប្រែប្រួលយ៉ាងខ្លាំងនៃអាកាសធាតុ ដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ផលិតផលកសិកម្ម ។

**៤.៣៦** ជាមួយនឹងកំណែទម្រង់ដែលកំពុងដំណើរការរៀបចំ ក៏ដូចជា ដែលកំពុងត្រូវបានអនុវត្ត និងជំហានជាបន្តទៀតនៅក្នុងដំណើរការ *ផយអជ* រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា ការព្យាករណ៍ដែលបានបង្ហាញខាងលើ គួរតែត្រូវបានធ្វើឱ្យក្លាយជាការពិតជាក់ស្តែង ។ មួយផ្នែកនៃចំណូលថវិកាជាតិក្នុងពេលកន្លងមក ភាគច្រើនបានមកពីការគាំទ្រថវិកាឬការគាំទ្រតាមកម្មវិធី ពីស្ថាប័នហិរញ្ញវត្ថុពហុភាគី ដែលត្រូវបានផ្តល់ឱ្យដល់កំណែទម្រង់និងសកម្មភាពពិសេសៗ ។ (ការផ្គត់ផ្គង់នេះត្រូវបានប៉ាន់ស្មានថាមានប្រមាណ ១២០ពាន់លានរៀល ឬ ២៩លានដុល្លារនៅឆ្នាំ២០០៥ ដែលរួមចំណែកប្រមាណ ០,៥ភាគរយ នៃ*ផសស* និង ៥ភាគរយនៃចំណូលថវិកាក្នុងស្រុកសរុប ។ រាជរដ្ឋាភិបាលរំពឹងថា ការផ្គត់ផ្គង់នេះនឹងអាចបន្តមាន នៅក្នុងអំឡុងពេលនៃការរៀបចំនិងការអនុវត្ត *ផយអជ* ។

**៤.៣៧** <u>*បញ្ហាវប្បធម៌និងសាសនា*</u> : បាវចនាខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលគឺ "ជាតិ សាសនា ព្រះមហាក្សត្រ" ។ ជំនឿសាសនា អបិយជំនឿ តម្លៃគ្រួសារ និងវប្បធម៌ដ៏ល្បីល្បាញនិងសំបូរបែប ដែលទ្រទ្រង់ដល់គ្រួសារក្នុងអំឡុងពេលសហស្សវត្សរ៍កន្លងទៅ បានរក្សារបៀបរៀបចំដោយគ្មានការខូចខាត និងបង្កើនការពង្រឹងសង្គមសម្របសម្រួលទៅតាមការផ្លាស់ប្តូរពេលវេលា និងឥទ្ធិពលនានា ។ ទាំងនេះ គឺជាមូលដ្ឋានសម្រាប់ការកសាងការពង្រឹង និងការថែរក្សាសង្គមជាសារវ័ន្ត "*មូលធនសង្គម*" ដែលគ្មានការអភិវឌ្ឍសេដ្ឋកិច្ចណាមួយអាចបង្កើតឬធ្វើឱ្យមានស្ថេរភាពដោយខ្លួនឯងបានទេ ។ ដូច្នេះ មានបញ្ហាសំខាន់ៗអន្តរវិស័យជាច្រើនដែលទាក់ទងនឹងគ្រប់ទស្សនៈវិស័យនៃជីវភាពប្រជាជនកម្ពុជា ។ ទោះបីជាបានទទួលរងគ្រោះច្រើនដោយសាររបបប្រល័យពូជសាសន៍ក្នុងអំឡុងពេលពីឆ្នាំ១៩៧៥-៧៩ ក៏ដោយ ចាប់តាំងពីពេលនោះមកមូលដ្ឋានគ្រឹះនៃសង្គមទាំងនេះ បានរស់រាននិងរឹងមាំឡើងវិញ ។ រាជរដ្ឋាភិបាលកម្ពុជាផ្តល់អាទិភាពខ្ពស់ក្នុងការថែរក្សានិងលើកតម្កើងកេរ្តិ៍ដំណែលវប្បធម៌ដ៏ថ្លៃថ្លាតែមួយរបស់ប្រជាជាតិ ដើម្បីពង្រឹងនិងធ្វើឱ្យមានរបៀបរៀបរយក្នុងសង្គម និងដើម្បីទាក់ទាញ "ទេសចរណ៍វប្បធម៌" ឱ្យចូលមកទស្សនានិងស្ងើចសរសើរចំពោះវប្បធម៌ពីអតីតកាលនិងបច្ចុប្បន្នកាលរបស់កម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់ថវិកាគ្រប់គ្រាន់សម្រាប់គោលបំណងខាងលើ [១] ។

[១] ទេសចរណ៍ផ្អែកលើវប្បធម៌ ត្រូវបានគ្របដណ្តប់ដោយផ្នែកទេសចរណ៍ ដែលជាផ្នែករបស់សេវាកម្ម ។

## ការលើកស្ទួយវិស័យកសិកម្ម

**៤.៣៨** ផ្នែកទាំងបួននៃមុំនេះរបស់យុទ្ធសាស្ត្រចតុកោណគឺ *ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មវិស័យកសិកម្ម (រួមទាំងអាហារូបត្ថម្ភនិងការអភិវឌ្ឍជនបទ) កំណែទម្រង់ដីធ្លីនិងការបោសសំអាតមីន កំណែទម្រង់វិស័យនេសាទនិងជលផល និងកំណែទម្រង់ព្រៃឈើ* ។

**៤.៣៩** <u>ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មវិស័យកសិកម្ម</u> : វិស័យនេះ ផ្តោតភាគច្រើនលើដំណាំគ្រប់មុខ និងការចិញ្ចឹមសត្វ ។ ជាមួយនឹងសក្តានុពលដ៏ធំធេងប៉ុន្តែពុំទាន់បានយកមកប្រើប្រាស់ នៅឡើយសម្រាប់ទាំងការបង្កើន *ផលសរុប* ទាំងសម្រាប់ការលើកកម្ពស់ជីវភាពអ្នកក្រ ជាពិសេស នៅតំបន់ជនបទ វិស័យនេះត្រូវបានទទួលស្គាល់ថាអាចផ្តល់នូវចំណូលខ្ពស់និងឆាប់រហ័សបំផុត ដោយមានការចំណាយទាបល្មម ជាពិសេស ក្នុងផលិតកម្មដំណាំផ្សេងៗ ជាពិសេសស្រូវ និងតាមរយៈពិពិធកម្មដំណាំរួបិយវត្ថុផ្សេងៗទៀត ។ ដោយស្ត្រីជាតំណាងភាគច្រើននៃកម្លាំងពលកម្ម ការធ្វើឱ្យប្រសើរឡើងនៅក្នុងវិស័យនេះអាចផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ស្ត្រី ។ គោលដៅអាទិភាពទាំងឡាយនៅក្នុងវិស័យនេះ គឺការធ្វើឱ្យប្រសើរឡើងនូវ សន្តិសុខស្បៀង ផលិតភាពនិងពិពិធកម្ម និងលទ្ធភាពប្រើប្រាស់ទីផ្សារសម្រាប់ផលិតផលកសិកម្ម ។

### តារាង៤.២ : គោលដៅក្នុងវិស័យកសិកម្មសម្រាប់ឆ្នាំ២០១០

| គោលដៅ | ២០០៥ (ប៉ាន់ស្មាន) | ២០១០ ចំណុចដៅ |
|---|---|---|
| ផលិតផលស្រូវ (លានតោន) | ៤.១៧ | ៥.៥ |
| ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ១.៩៧ | ២.៤ |
| ការនេសាទ (ទឹកសាប សមុទ្រ និង វារីវប្បកម្ម) តោន | ៣៧៤.០០០ | ៤៥០.០០០ |
| ផ្ទៃដីស្រោចស្រព (%នៃផ្ទៃដីដាំស្រូវ) រួមទាំង ការស្រោចស្រពបន្ថែម | ២០ | ២៥ |
| កំណែទម្រង់ដី-ចំនួនប័ណ្ណកម្មសិទ្ធិដែលបានផ្តល់ដល់កសិករ (%នៃផ្ទៃដីសរុប) | ១២ | ២៤ |
| ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (%នៃផ្ទៃដីសរុប) | ៦០ | ៦០ |
| ការពឹងផ្អែកលើឈើដុត (អុស ធ្យូង): គ្រួសារ (%) | ៨៥.៥ | ៦១ |

*សូមមើលតារាង ៣.២*

**៤.៤០** យុទ្ធសាស្ត្រដ៏ទូលំទូលាយមួយសម្រាប់វិស័យកសិកម្មទាំងមូល នៅកំពុងដំណើរការរៀបចំនៅឡើយ ។ តាមរយៈការសហការយ៉ាងជិតស្និទ្ធក្នុងចំណោម បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ *"យុទ្ធសាស្ត្រសម្រាប់កសិកម្មនិងធនធានទឹក"* នឹងរៀបចំឡើងនៅឆ្នាំ២០០៦ ដែលនឹងផ្តោតការយកចិត្តទុកដាក់លើផែនការរបស់អនុ-វិស័យទាំងអស់នៅក្នុងវិស័យនេះ ហើយនៅក្នុងចំណោមការងារផ្សេងៗទៀត និងរួមបញ្ចូលនូវការវិភាគនិងដំណោះស្រាយ និងយុទ្ធសាស្ត្រសម្រាប់ :

- បញ្ហាការគ្រប់គ្រងដីកសិកម្ម : ចំណុចខ្លាំងនិងចំណុចខ្សោយរបស់សេដ្ឋកិច្ចមាត្រដ្ឋាន និងទំហំនិងកត្តាផ្នែកសង្គមដែលទាក់ទងនឹងដីកសិដ្ឋានតូចៗ សហករណ៍កសិករ ការងារកសិដ្ឋានដោយមានកិច្ចសន្យា ការធ្វើសម្បទានដីទ្រង់ទ្រាយធំ (ទាំងអស់នេះគឺនៅក្នុងបរិបទនៃការបង្កើនផលិតកម្មនិងផលិតភាព ពិពិធកម្ម និងការធានាសមភាពនិងយុត្តិធម៌សង្គម) ។
- ផលិតកម្មពូជដែលមានទិន្នផលខ្ពស់ (ឧទាហរណ៍ ស្រូវ) ដែលត្រូវបានបង្កើតឡើងនៅកន្លែងផ្សេងជាពិសេស នៅក្នុងប្រទេសជិតខាងដែលមានលក្ខណៈអាកាសធាតុកសិកម្មប្រហាក់ប្រហែលគ្នាធៀបនឹងការវិនិយោគទ្រង់ទ្រាយធំក្នុងការស្រាវជ្រាវផ្នែកកសិកម្ម ដើម្បីបង្កើតពូជថ្មីនៅកម្ពុជា ។
- ការបង្កើនផលិតកម្មស្រូវសម្រាប់ការនាំចេញ ទៅតាមចំណង់ចំណូលចិត្ត ឬបន្ថែមពីលើផលិតកម្មដំណាំទាំងឡាយដែលមានតម្លៃនិងតួនាទីពិសេស ។
- ការបង្កើនផលិតកម្មដំណាំ ដូចជា ផ្លែឈើ និងបន្លែ ដែលបច្ចុប្បន្ននេះ កម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើការនាំចូល ។
- គោលដៅច្បាស់លាស់ ចំណុចដៅនិងសំណូមពរជាក់លាក់ ដើម្បីសម្រេចបានការបង្កើនផលិតកម្មដំណាំតាមរយៈ ប្រព័ន្ធដាំដុះដែលអាចប្រើប្រាស់បានប្រសើរបំផុតនូវប្រភពធនធានទឹកដែលមានកម្រិត និងកាត់បន្ថយហានិភ័យចំពោះកសិករពីការប្រែប្រួលមិនទៀងទាត់ដោយសារបាតុភូតធម្មជាតិ ដែលកើតមានឡើងពីមួយឆ្នាំ-ទៅមួយឆ្នាំ និងតាមរយៈ ដំណាំល្អៗបំផុតដែលត្រូវដាំដុះគ្រប់រដូវ ដោយផ្តោតការយកចិត្តទុកដាក់លើលក្ខខណ្ឌដីនិងកត្តាផ្សេងៗទៀត លើសក្តានុពលនៃការនាំចេញ និងលើការកែលម្អប្រព័ន្ធធារាសាស្ត្រ ។ល។

៤.៤១ សម្រាប់ពេលនេះ រហូតដល់មានយុទ្ធសាស្ត្រកសិកម្មរួមមួយ រាជរដ្ឋាភិបាលនឹងអនុវត្តសកម្មភាព សម្រាប់លើកកម្ពស់ការងារចំពោះមុខ ដូចតទៅ :

- សន្តិសុខស្បៀង ផលិតភាព និងពិពិធកម្ម ។
- កែលម្អការគ្រប់គ្រងធនធានទឹក សម្រាប់វារីវប្បកម្មលក្ខណៈកសិកម្មនិងលក្ខណៈកសិដ្ឋាន ។
- កែលម្អនិងពង្រីកសេវាផ្សព្វផ្សាយកសិកម្ម ។
- លទ្ធភាពប្រើប្រាស់ទីផ្សារប្រសើរជាងមុនសម្រាប់ផលិតផលកសិកម្ម ជាពិសេសចំពោះផលិតផលពីតំបន់ដាច់ស្រយាល ។
- ជំរុញឱ្យមានបរិយាកាសល្អសម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យកសិកម្ម ។
- ពង្រឹងក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌច្បាប់ ។

**៤.៤២** ដោយផ្អែកលើផលិតភាពទាបនៃដំណាំទាំងអស់ ដែលមួយផ្នែកបណ្តាលមកពីដីគ្មានជីជាតិ បញ្ហាប្រឈមចម្បងបំផុតដែលទាក់ទងទៅនឹងផលិតផលដំណាំ គឺ :

- កំណត់ប្រភេទដំណាំល្អៗបំផុត តាមរយៈការធ្វើអង្កេតគុណភាពដីនិងមធ្យោបាយផ្សេងៗទៀត ដែលអាចដាំដុះនៅក្នុងតំបន់ណាមួយដើម្បីអាចទាញយកចំណូលនិងផលប្រយោជន៍ឱ្យបានច្រើនបំផុត ។
- អនុវត្តយ៉ាងសកម្មនូវការដាំដុះតាមរបៀបប្រពលវប្បកម្មកសិកម្ម ដោយរួមបញ្ចូលទាំងដំណាំតាមរដូវកាល នៅលើផ្ទៃដីដដែល ។
- បង្កើនឱ្យបានច្រើននូវទិន្នផលនៃដំណាំគ្រប់ប្រភេទ ដោយប្រើប្រាស់ធាតុចូលល្អជាងមុន (គ្រាប់ពូជ ជី និងការអនុវត្តត្រឹមត្រូវ) កែលម្អនិងការពង្រីកការគ្រប់គ្រងទឹក និងការការពារផលដំណាំ ហើយជាមួយគ្នានេះដែរ ជំរុញលើកទឹកចិត្តឱ្យប្រើវិធីបង្កើនផលិតកម្មកសិកម្មដោយប្រើប្រាស់មធ្យោបាយផលិតកម្មតិច និងចំណាយទាប ក្នុងនោះរួមមានប្រព័ន្ធនៃការធ្វើប្រពលវប្បកម្មដំណាំស្រូវ ទៅតាមស្ថានភាពសមស្រប ដើម្បីបង្កើនផលប្រយោជន៍ដល់កសិករ និងដើម្បីចៀសវាងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតហួសកម្រិត ។
- ធ្វើពិពិធកម្មដំណាំជាច្រើនប្រភេទដែលអាចដាំដុះបាន ។

**៤.៤៣** យុទ្ធសាស្ត្រអាទិភាពសម្រាប់ ៥ឆ្នាំខាងមុខ (២០០៦-២០១០) រួមមាន :

- រៀបចំនិងអនុវត្តយ៉ាងឆាប់រហ័សនូវយុទ្ធសាស្ត្រដ៏ទូលំទូលាយសម្រាប់ កសិកម្មនិងធនធានទឹក ។
- ផ្តោតលើ "ការដាំដុះជាលក្ខណៈប្រពលវប្បកម្ម" តាមរយៈការបង្កើនចំនួនការដាំដុះក្នុងមួយឆ្នាំៗនៅលើផ្ទៃដីដដែល និងការបង្កើនទិន្នផលក្នុងប្រភេទដំណាំនីមួយៗ ។
- បង្កើនទិន្នផលស្រូវយ៉ាងហោចឱ្យដល់កម្រិតជាមធ្យម ២,៤តោនក្នុងមួយហិកតា ដែលនេះជាអាទិភាពខ្ពស់បំផុតមួយ ។
- លើកទឹកចិត្តការដាំដុះដំណាំឧស្សាហកម្ម ក្នុងនោះរួមមាន ដំណាំហូបផ្លែនិងបន្លែ ដែលជាមធ្យោបាយមួយ ទាំងដើម្បីធ្វើពិពិធកម្ម ទាំងដើម្បីធានាសន្តិសុខនៃចំណូល ស្របពេលជាមួយគ្នានឹងការបន្តផលិត-កម្ម ដំណាំស្បៀងដើម្បីធានាសន្តិសុខស្បៀង ។
- ផ្តួចផ្តើមទស្សនៈ "ភូមិមួយ-ផលិតផលមួយ" ដើម្បីជំរុញលើកទឹកចិត្តឱ្យមានផលិតផលកសិកម្មដែលមានតម្លៃខ្ពស់ ដែលអាចទាក់ទាញឱ្យមានការចូលរួមរបស់ផ្នែកឯកជន តាមរយៈការងារកសិដ្ឋានដោយមានកិច្ចសន្យា និងមធ្យោបាយផ្សេងៗទៀត ។

- ពង្រីកសេវាកម្មគាំទ្រ ដូចជា ការស្រាវជ្រាវក្នុងវិស័យកសិកម្ម សេវាផ្សព្វផ្សាយ ការអភិវឌ្ឍទីផ្សារ ការផ្ដល់មីក្រូឥណទាននៅក្នុងតំបន់ជនបទ (រួមបញ្ចូលទាំងសម្រាប់ប្រព័ន្ធស្រោចស្រពដែលដំណើរការ និងកាន់កាប់ដោយកសិករ) ។ល ។
- កែលម្អផលិតផលកសិកម្ម ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ ។
- ជំរុញនិងធ្វើឱ្យមានស្ថេរភាពកំណើនដែលមានមូលដ្ឋានធំទូលាយ ចំពោះផលិតផលកសិកម្ម តាមរយៈការអភិវឌ្ឍប្រកបដោយចីរភាពនូវផលិតផលដែលមានតម្លៃខ្ពស់ ។
- ធ្វើទំនើបភាវូបនីយកម្មនិងបង្កើនការកែច្នៃកសិផល ដើម្បីបន្ថែមតម្លៃទៅលើផលិតផលជនបទ និងបង្កើនទិន្នផលអង្ករតាមរយៈការបំប្លែងពីស្រូវមកអង្ករ ដើម្បីបង្កើនចំណូលគ្រួសារនៅតំបន់ជនបទ ។
- ពង្រឹង និងពង្រីកផលិតកម្មបសុសត្វ ការចិញ្ចឹមសត្វ និងសេវាកម្មបសុពេទ្យ ។
- ជំរុញលើកទឹកចិត្តឱ្យមានការដាំដុះដំណាំកៅស៊ូទ្រង់ទ្រាយតូច និងជំរុញលើកទឹកចិត្តឱ្យមានការធ្វើឯកជនភាវូបនីយកម្មលើចំការកៅស៊ូរដ្ឋ ។
- អនុម័តនិងអនុវត្តវិធានការថ្មីៗ ដើម្បីផ្ដល់ជំនួយដោយផ្ទាល់ដល់កសិករក្រីក្រ សម្រាប់ការបង្កើនផលិតកម្ម ដំណាំដែលពួកគាត់បានជ្រើសរើសមួយ ។
- បន្តជំរុញលើកទឹកចិត្តឱ្យមានទីផ្សារនាំចេញសម្រាប់ផលិតផលពិសេសៗ ដោយរាប់បញ្ចូលជាពិសេសការនាំចេញផលិតផលដែលគ្មានជាតិគីមី ។

**៤.៤៤** <u>ការចិញ្ចឹមសត្វ</u> : ភាគច្រើននៃការធ្វើស្រែចំការតាមរដូវរបស់ប្រជាជនកម្ពុជា ពឹងផ្អែកលើសត្វពាហនៈជាកម្លាំងអូសទាញសម្រាប់ការភ្ជួររាស់និងសកម្មភាពផ្សេងទៀត ។ សត្វពាហនៈនិងបសុបក្សី ក៏ជាប្រភពផ្ដល់ចំណូលនិងផ្ដល់ប្រូតេអ៊ីនយ៉ាងសំខាន់ផងដែរ សម្រាប់សហគមន៍ជនបទ ។ បញ្ហាប្រឈមក្នុងផ្នែកនេះគឺ ត្រូវកែលម្អគុណភាពនិងសុខុមាលភាពនៃសត្វពាហនៈ ដោយចាប់ផ្ដើមបញ្ចូលនូវពូជល្អជាងនិងធាត់ធំ និងតាមរយៈការពង្រីកការចិញ្ចឹមសត្វនិងសេវាកម្មបសុពេទ្យ ដើម្បីឱ្យអ្នកក្រមានភាពងាយស្រួលក្នុងការប្រើប្រាស់ ។ នៅក្នុងករណីនេះ *ផយអជ* នឹងអនុវត្តនូវយុទ្ធសាស្ត្រសំខាន់ៗ ហើយក៏នឹងត្រូវលើកឡើងជាលម្អិតផងដែរ នៅក្នុងយុទ្ធ-សាស្ត្រវិស័យកសិកម្មដែលបានស្នើឡើង ។

**៤.៤៥** <u>ជលផល</u> : ដោយផ្អែកលើតួនាទីសំខាន់របស់ត្រីនៅក្នុងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជារាប់លាននាក់ក្នុងរូបភាពជាស្បៀងអាហារ អាហារូបត្ថម្ភ ចំណូលនិងការរស់នៅ គោលដៅនៃផ្នែកនេះ គឺដើម្បីធានាឱ្យមានលទ្ធភាពប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានជលផលសម្រាប់អ្នកក្រ ។ អាទិភាពទាំងនោះរួមមានដូចខាងក្រោម :

- លើកកម្ពស់ឱ្យមាននិងពង្រីងការអភិវឌ្ឍដោយផ្អែកលើសហគមន៍ចំពោះវិស័យជលផល តាមរយៈការផ្តល់សិទ្ធិអំណាចទៅឱ្យសហគមន៍មូលដ្ឋាន ដើម្បីឱ្យប្រជាកសិករអាចចូលរួមដោយផ្ទាល់ ដោយសកម្ម និង ដោយសមធម៌ នៅក្នុងការរៀបចំផែនការ ការរៀបចំកម្មវិធី និងការគ្រប់គ្រងវិស័យជលផល ហើយនិង ដើម្បីចៀសវាងការនេសាទហួសកម្រិត ។
- កែលម្អជីវភាពរស់នៅរបស់អ្នកក្រ តាមរយៈការលើកកម្ពស់សមត្ថភាពពួកគាត់ដើម្បីប្រើប្រាស់ត្រីដែលនេសាទបានឱ្យមានប្រសិទ្ធភាពជាងមុន តាមរយៈការកែច្នៃ ការរក្សាទុក ការដឹកជញ្ជូននិងការលក់ដូរ ។
- បង្វែរឡូតិ៍នេសាទមួយចំនួនដែលផុតកិច្ចសន្យាសម្បទាន ទៅជាកន្លែងអភិរក្សពូជមច្ឆាជាតិ ដែលតាមរយៈនេះនឹងបង្កើនផលស្តុកធម្មជាតិផង និងអភិរក្សពូជមច្ឆាជាតិដែលប្រឈមមុខនឹងការផុតពូជ ។
- ការពារជលផលទឹកសាប តាមរយៈការថែរក្សាដែនទឹកទាំងគុណភាពនិងបរិមាណ ដែលជាជម្រកមច្ឆាជាតិ ។
- លើកទឹកចិត្តនិងជំរុញការអភិវឌ្ឍវារីវប្បកម្មរបស់វិស័យឯកជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការត្រីដែលកើនឡើង ហើយទន្ទឹមនេះដើម្បីកាត់បន្ថយសម្ពាធទៅលើធនធានជលផលធម្មជាតិផង ។

**៤.៤៦** <u>សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ</u> : សន្តិសុខស្បៀងនិងអាហារូបត្ថម្ភគឺជាបញ្ហាអន្តរវិស័យមួយយ៉ាងសំខាន់ ហើយការកែលម្អសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងកង្វះមីក្រូសារជាតិ នៅក្នុងចំណោមស្ត្រីនិងកុមារ ។ គោលដៅចម្បងគឺថា "ត្រឹមឆ្នាំ២០១០ ប្រជាជនកម្ពុជាក្រីក្រនិងប្រជាជនដែលស្ថិតក្នុងស្ថានភាពអសន្តិសុខស្បៀង នឹងមានលទ្ធភាពផ្នែកសេដ្ឋកិច្ចល្អប្រសើរច្រើនក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងមានជីវជាតិ ដើម្បីបំពេញសេចក្តីត្រូវការរបបអាហារ និងចំណង់ចំណូលចិត្តរបស់ពួកគេនៅគ្រប់ពេលវេលា សម្រាប់ការរស់នៅដ៏សកម្មនិងមានសុខភាពមាំមួន" ។ ការសម្រេចគោលដៅនេះ ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នានៅក្នុងវិស័យនានា ដូចបានបង្ហាញនៅក្នុង *ផយអជ* ដោយមានការផ្តោតការយកចិត្តទុកដាក់លើសកម្មភាពមួយចំនួន ជាពិសេស លើភាពក្រីក្រនិងអសន្តិសុខស្បៀង ។ សកម្មភាពទាំងនោះរួមមាន :

- ការបង្កើននិងការធានាឱ្យមានស្បៀងគ្រប់គ្រាន់តាមគ្រួសារ ។
- ការកែលម្អលទ្ធភាពទទួលបានស្បៀង (ទាក់ទងនឹងចំណូល និងលទ្ធភាពអាចរកស្បៀងបាន) ។
- ការធានាការប្រើប្រាស់ស្បៀងនិងទម្លាប់ការហូបចុកឱ្យបានល្អប្រសើរ តាមរយៈការអប់រំពីសុខភាព និងអាហារូបត្ថម្ភ (ដោយរួមបញ្ចូលការកែលម្អរបៀបបំបៅកូន និងអាហារូបត្ថម្ភសម្រាប់មាតា) កម្មវិធីផ្តល់បន្ថែមនិងបញ្ចូលមីក្រូសារជាតិក្នុងអាហារ (ជាតិដែក វីតាមីនអា) ការបន្តផលិតអំបិលអ៊ីយ៉ូដ និងការអនុវត្តស្តង់ដារសុវត្ថិភាពស្បៀង ។ល។

៤.៤៧ **កំណែទម្រង់ព្រៃឈើ** : រាល់កិច្ចខិតខំប្រឹងប្រែងនឹងត្រូវធ្វើឡើង ដើម្បីថែរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើឱ្យបាន ៦០ភាគរយនៃផ្ទៃដីសរុប និងបន្តធ្វើការដាំដុះព្រៃឈើឡើងវិញ ទន្ទឹមគ្នានឹងការផ្អាកការផ្តល់ព្រៃសម្បទាន និងការប្រកាន់យកវិធានការឃ្លាំមើលយ៉ាងហ្មត់ចត់ទៅលើអ្នក ដែលកំពុងទទួលបានព្រៃសម្បទាន ដើម្បីធានាថា ពួកអ្នកទាំងនោះ បានដាក់ជូនពិនិត្យនូវផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងព្រៃឈើ រួមជាមួយនឹងការវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថាន ហើយបន្ទាប់ពីការអនុម័ត ពួកអ្នកទាំងនោះនឹងបន្តអនុវត្តតាមស្មារតីនៃឯកសារទាំងពីរនេះ ។ បញ្ហាប្រឈមចំពោះមុខ គឺត្រូវលើកឡើងនូវយុទ្ធសាស្ត្រមួយច្បាស់លាស់ក្នុងការគ្រប់គ្រងព្រៃសម្បទាន ព្រៃគុបប្រចាំឆ្នាំ ព្រៃឈើសហគមន៍ និងតំបន់ការពារ តាមរបៀបមួយដែលមានលក្ខណៈចីរភាព ដោយឈរលើមូលដ្ឋានបីជាសំខាន់ :

- គោលនយោបាយគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដើម្បីធានាឱ្យមានការតាមដានត្រួតពិនិត្យយ៉ាងហ្មត់ចត់និងត្រឹមត្រូវ លើអាជីវកម្មព្រៃឈើ ដោយស្របទៅតាមបទពិសោធន៍ល្អបំផុតដែលបាន អនុវត្តជាលក្ខណៈអន្តរជាតិក្នុងការគ្រប់គ្រងព្រៃឈើ ដើម្បីផ្តល់នូវព្រៃឈើបម្រុងទុកឱ្យបានគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ក្នុងស្រុក សម្រាប់ការការពារប្រឆាំងនឹងភាពរាំងស្ងួតនិងទឹកជំនន់ ព្រមទាំងសម្រាប់ការអភិរក្សព្រៃលិចទឹកដែលជាជម្រកមច្ឆាជាតិ ។
- ប្រព័ន្ធតំបន់ការពារដើម្បីការពារជីវៈចម្រុះ និងប្រភេទរុក្ខជាតិនិងសត្វដែលប្រឈមមមុខនឹងការផុតពូជ ។
- ព្រៃឈើសហគមន៍ដែលជាកម្មវិធីមួយដ៏ល្អ មានតម្លាភាព និងដែលគ្រប់គ្រងដោយផ្ទាល់ពីប្រជាជននៅមូលដ្ឋាន ។

៤.៤៨ ដើម្បីសម្រេចបានគោលដៅរួមនៅក្នុងវិស័យព្រៃឈើ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញានឹងអនុវត្តនូវកម្មវិធីជាតិសម្រាប់ព្រៃឈើ ដោយមានអាទិភាពដូចខាងក្រោម :

- ការពង្រឹងការគ្រប់គ្រងនិងការអភិរក្សព្រៃឈើ ។
- ការជំរុញលើកទឹកចិត្តឱ្យមានការដាំដុះព្រៃឈើឡើងវិញ ដើម្បីជំនួសតម្រូវការចំពោះព្រៃឈើធម្មជាតិ ដោយលើកទឹកចិត្តឱ្យមានការវិនិយោគពីផ្នែកឯកជន និងការចូលរួមពីផ្នែកសាធារណៈ ។
- ការជំរុញលើកទឹកចិត្តឱ្យមានការរួមចំណែករបស់វិស័យព្រៃឈើក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ។
- ការជំរុញលើកទឹកចិត្តឱ្យមានការរួមចំណែករបស់វិស័យព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងកម្មវិធីនានាសម្រាប់ព្រៃឈើសហគមន៍ និងតាមការធ្វើឱ្យមានការចូលរួមរបស់សហគមន៍មូលដ្ឋាន ក្នុងផែនការធ្វើអាជីវកម្មព្រៃឈើ ។
- ការបង្កើតឱ្យមានការយល់ដឹងជាសាធារណៈ ពីការដាំដុះឡើងវិញនិងការប្រើប្រាស់ចំការព្រៃឈើសម្រាប់តម្រូវការឈើធ្វើ អុស ធ្យូង និងពីការមិនត្រូវបំផ្លាញព្រៃឈើ ។

**៤.៤៩** <u>បរិស្ថាននិងការអភិរក្សជីវៈចម្រុះ</u> : គោលដៅក្នុងការការពារ ការអភិរក្ស និងការប្រើប្រាស់ប្រកបដោយចីរភាព នូវធនធានធម្មជាតិទាំងអស់របស់ជាតិ រួមទាំងជីវៈចម្រុះ គឺមិនគ្រាន់តែត្រូវថែរក្សាកេរដំណែលធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែត្រូវលើកកម្ពស់ចីរភាពបរិស្ថាន និងត្រូវរួមចំណែកធ្វើឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការរស់នៅរបស់សហគមន៍ជនបទផងដែរ ។ ក្រៅពីនេះ តំបន់ធម្មជាតិ គួរត្រូវបានជំរុញលើកទឹកចិត្តឱ្យក្លាយទៅជាគោលដៅដែលអាចទាក់ទាញទេសចរណ៍ធម្មជាតិ ដែលនាំមកនូវផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន ។ ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម ការអប់រំនិងការយល់ដឹងអំពីបរិស្ថានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចបានទិសដៅទាំងនេះ ។ ធនធានដែលដុះ និងរស់នៅក្នុងទឹករបស់កម្ពុជា ជាពិសេស បឹងទន្លេសាបនិងទន្លេមេគង្គ ដៃទាំងអស់របស់វា និងតំបន់ឆ្នេរ កំពុងតែទទួលរងនូវសម្ពាធពីការអភិវឌ្ឍដីធ្លី ។ កម្ពុជាកំពុងជួបបញ្ហាធ្ងន់ធ្ងរផងដែរ ដោយសារយើងស្ថិតនៅតាមបណ្តោយខ្សែទឹកខាងក្រោមនិងខាងចុងនៃអាងទន្លេមេគង្គ ដោយមានប្រទេសជាច្រើនស្ថិតនៅខ្សែទឹកខាងលើ ។ ច្បាប់និងគោលនយោបាយជាតិថ្មីៗ នឹងជួយសម្រួលដល់ការលើកកម្ពស់ការគ្រប់គ្រងធនធានទឹកនិងការធ្វើអនាម័យធនធានទឹកទាំងនោះ ។ កិច្ចខិតខំប្រឹងកៀរគរធនធាន នឹងត្រូវធ្វើឡើង ដើម្បីធានានូវជោគជ័យក្នុងការអនុវត្ត *កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ* សំដៅទ្រទ្រង់ការអភិឌ្ឍន៍ប្រកបដោយចីរភាព ក្នុងស្ថានភាពនៃការប្រែប្រួលអាកាសធាតុ ។

**៤.៥០** <u>កំណែទម្រង់ដីធ្លី</u> : ដីធ្លីនិងទឹក គឺជាធនធានធម្មជាតិសំខាន់ពីរ ដែលជាមូលដ្ឋានសម្រាប់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ ។ គោលដៅក្នុងការងារនេះ គឺការធានាសុវត្ថិភាពការកាន់កាប់ដីធ្លី ការអភិវឌ្ឍទីផ្សារដី ការរៀបចំដែនដី និងលទ្ធភាពប្រើប្រាស់ដីធ្លីដែលមានលក្ខណៈគាំទ្រអ្នកក្រ ។ ច្បាប់ភូមិបាល ឆ្នាំ២០០១ នឹងត្រូវបន្តអនុវត្តសំដៅធានាឱ្យមានប្រព័ន្ធមួយប្រកបដោយសមធម៌ ត្រឹមត្រូវជាងមុន និងប្រកបដោយប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងដីធ្លី សម្រាប់ការបែងចែកដីធ្លី សម្រាប់សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី សម្រាប់ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការតាំងលំនៅនិងក្នុងការកាន់កាប់ដីដោយខុសច្បាប់ និងសម្រាប់ការត្រួតពិនិត្យការប្រមូលផ្តុំការបង្កកដីទុកដើម្បីធ្វើអាជីកម្មយកចំណេញ ។ ការងារអាទិភាពចំពោះមុខ គឺត្រូវចេញប័ណ្ណ កម្មសិទ្ធិដីធ្លីដែលមានលក្ខណៈច្បាស់លាស់ ដែលស្របច្បាប់ និងមិនក្លែងបន្លំ ដើម្បីផ្តល់សុវត្ថិភាពក្នុងការកាន់កាប់ដី ដែលគេកំពុងប្រើប្រាស់ជាក់ស្តែង ។ បញ្ហាប្រឈមទាំងឡាយនៅក្នុងការងារនេះ គឺត្រូវត្រួតពិនិត្យនិងទប់ស្កាត់ការប្រមូលយកដីមកកាន់កាប់ដោយបុគ្គលមួយចំនួនតូច រួមទាំងការពិនិត្យឡើងវិញលើដីធំៗ ដែលបានធ្វើសម្បទានរួចហើយ ដែលមានទំហំលើសពីកម្រិតដែលមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ដែលដីទាំងនោះ នៅតែបន្តទុកចោលមិនធ្វើផលិតកម្ម។ សកម្មភាពអាទិភាពមួយចំនួនមានជាអាទិ៍គឺ :

- រៀបចំនិងអនុវត្តគោលនយោបាយទូលំទូលាយស្តីពីដីធ្លី ។

- បន្តពិភាក្សានិងរៀបចំបង្កើតក្របខ័ណ្ឌគតិយុត្តចាំបាច់ សម្រាប់ការអនុវត្តន៍ច្បាប់ភូមិបាលប្រកបដោយប្រសិទ្ធភាព រួមទាំងការចុះបញ្ជីកម្មសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ។
- កែលម្អនិងអនុវត្តនីតិវិធីនៃការងារចុះបញ្ជីដីធ្លី សម្រាប់ការរៀបចំធ្វើប័ណ្ណកម្មសិទ្ធិតាមលក្ខណៈជាប្រព័ន្ធ និងតាមលក្ខណៈដាច់ដោយដុំ និងផ្តល់ប័ណ្ណកម្មសិទ្ធិសម្រាប់ក្បាលដីយ៉ាងតិចបំផុត ៣២ភាគរយនៃក្បាលដីសរុប (ទីប្រជុំជន និងជនបទ) នៅឆ្នាំ២០១០ ។
- អនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ជាពិសេស ការធ្វើអត្តសញ្ញាណកម្មដីរដ្ឋ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ការរៀបចំផែនទីនិងបញ្ជីសារពើភ័ណ្ឌដីធ្លី ។
- ពិនិត្យឡើងវិញការធ្វើសម្បទានដីសេដ្ឋកិច្ចដែលមានរួចមកហើយ និងធ្វើឱ្យការធ្វើសម្បទានទាំងនោះបានសមស្របទៅនឹងគោលការណ៍ណែនាំដែលមានចែងក្នុងអនុក្រឹត្យ ស្តីពីការធ្វើសម្បទានដីសេដ្ឋកិច្ច ។
- រៀបចំនិងអនុវត្តកម្មវិធីសម្រាប់ការធ្វើសម្បទានដីសង្គមកិច្ច ដើម្បីផ្តល់ដីតូចៗដោយមានប័ណ្ណកម្មសិទ្ធិសម្រាប់ការតាំងលំនៅដ្ឋាននិងសម្រាប់ផលិតកម្មកសិកម្ម ហើយផ្តល់ដីយ៉ាងតិចបំផុតសម្រាប់ ១០.០០០ គ្រួសារក្រីក្រដែលគ្មានដី ដោយឈរលើមូលដ្ឋាននៃការសាកល្បងនៃគម្រោងសម្បទានដីសង្គមកិច្ច ។
- បន្តបង្កើតបណ្តាញប្រថពីវិភាគ ទាំងរយៈកំពស់ និងរយៈបណ្តោយ និងការផលិតផែនទីរូបថតតាមផ្កាយរណបសម្រាប់ទូទាំងប្រទេស ។
- បង្កើតស្តង់ដារនៃការអង្កេតនិងការធ្វើផែនទី ។
- លើកកម្ពស់ការធ្វើវិមជ្ឈការនិងវិសហមជ្ឈការនៅក្នុងមុខងារនៃការគ្រប់គ្រង ក្នុងបញ្ហាដីធ្លីនិងសំណង់ ។
- ធ្វើការរៀបចំផែនការរូបសាស្ត្រខ្នាតជាតិ ខ្នាតតំបន់ ខ្នាតស្រុក-ខ័ណ្ឌ និងខ្នាតតូចៗដោយការកសាងប្លង់កំណត់តំបន់អភិវឌ្ឍន៍ ឬប្លង់យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ ការធ្វើសមាហរណកម្មផែនការរៀបចំក្រុងភូមិភាគ និងថ្នាក់ជាតិ ដែលរួមទាំងការផ្តល់សេវារៀបចំនិងសម្របសម្រួលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ១០០ស្រុក ជាពិសេស ស្រុកតាមបណ្តោយព្រំដែន ។
- កែលម្អតម្លាភាពនិងគណនេយ្យភាព ក្នុងការផ្តល់សេវាកម្មនៅក្នុងវិស័យសំណង់និងនគរូបនីយកម្ម រួមទាំងប្រព័ន្ធវាយតម្លៃដី ។
- ពង្រឹងគណៈកម្មការសុរិយោដីនិងយន្តការផ្សេងទៀត សម្រាប់ដោះស្រាយជម្លោះដីធ្លី ដើម្បីធានាឱ្យមានដំណោះស្រាយជម្លោះប្រកបដោយយុត្តិធម៌ និងទាន់ពេលវេលា ។

**៤.៥១** <u>ការបោសសម្អាតមីន</u> : ប្រតិបត្តិការបោសសំអាតមីនមិនគ្រាន់តែជាបញ្ហាទាក់ទងទៅនឹងមនុស្សធម៌និងសន្តិសុខប៉ុណ្ណោះទេ ប៉ុន្តែវាមានការទាក់ទងខ្លាំងផងដែរទៅនឹងបញ្ហាសេដ្ឋកិច្ចនិងសង្គមកិច្ច ជាពិសេស បញ្ហាបែងចែកដីធ្លី និងសន្តិសុខសម្រាប់គ្រួសារកសិករក្រីក្រនៅតំបន់ជនបទដាច់ស្រយាល ។ ប្រតិបត្តិការបោសសម្អាតមីនបានត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍជនបទ ។ គោលដៅនៃការងារនេះ គឺត្រូវបន្តការបោសសម្អាតមីននិងយុទ្ធ-

ភ័ណ្ឌមិនទាន់ផ្ទុះ និងបន្តយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ដើម្បីកាត់បន្ថយចំនួនអ្នករងគ្រោះដោយសារមីនឱ្យបានតិចជាង ២០០នាក់ នៅឆ្នាំ២០១០ ពីចំនួន ៧៩៧នាក់ នៅឆ្នាំ២០០៥ ហើយដើម្បីបង្កើនផ្ទៃដីដែលបានដោះមីនពីចំនួន ៣២.៩៧៤ នៅឆ្នាំ២០០៥ ឱ្យដល់ ៤៥.០០០ហិកតា នៅឆ្នាំ២០១០ ។

**៤.៥២** ការអភិវឌ្ឍជនបទ : ការអភិវឌ្ឍជនបទ គឺជាបញ្ហាអន្តរវិស័យមួយយ៉ាងសំខាន់ ដែលរាប់បញ្ចូលតាំងពីបញ្ហាប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ការធ្វើវិមជ្ឈការ និងរហូតដល់ការបង្កើននិងការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ សេវាអប់រំនិងសេវាសុខាភិបាល ដល់ប្រជាជននៅជនបទ ។ ដូចនេះ ការអភិវឌ្ឍជនបទគឺជាសមាសភាគមួយយ៉ាងសំខាន់ សម្រាប់ប្រជាពលរដ្ឋនៅជនបទផ្ទាល់ ហើយក៏ជាធាតុផ្សំមួយយ៉ាងសំខាន់ផងដែរ សម្រាប់លើកកម្ពស់វិស័យកសិកម្មនិងការកាត់បន្ថយភាពក្រីក្រ ។ ការអភិវឌ្ឍជនបទនេះ ក៏ជាសកម្មភាពមួយជាអាទិភាពផងដែរ សម្រាប់ធានាឱ្យមានការធ្វើពិពិធកម្មនិងការចំណាយថវិកា ។

**៤.៥៣** ការផ្តល់និងការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធជនបទ ជាពិសេស គមនាគមន៍ជនបទ ការផ្គត់ផ្គង់ទឹកនិងអនាម័យ ការកែលម្អលទ្ធភាពទទួលបានឥណទាននិងហិរញ្ញវត្ថុនៅជនបទ ការជំរុញលើកទឹកចិត្តឱ្យមានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និងការលើកទឹកចិត្តឱ្យមានការអភិវឌ្ឍសហគមន៍ជនបទ តាមរយៈការធ្វើវិមជ្ឈការនិងវិសហមជ្ឈការ គឺជាការងារមួយចំនួនក្នុងចំណោមការងារសំខាន់ៗទាំងឡាយដែលធ្វើឡើងដើម្បីអភិវឌ្ឍជនបទ ។ ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់នឹងត្រូវបន្តធ្វើ ដើម្បីអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ការស្តារនិងសាងសង់ផ្លូវថ្នល់រួមបញ្ចូលទាំងស្ពាននិងលូតូចៗ អណ្តូងទឹក ប្រព័ន្ធអនាម័យ សាលារៀន ទ្វារទឹក និងប្រព័ន្ធធារាសាស្ត្រតូចៗ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងផ្សេងៗដែលបានគ្រោងសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម អាចផ្តល់កាលានុវត្តភាពរកការងារ និងរកចំណូលនៅតំបន់ជនបទ ហើយតាមរយៈនេះ ក៏អាចបញ្ឈប់ការផ្លាស់ប្តូរទីលំនៅក្នុងស្រុក ពីតំបន់ជនបទទៅតំបន់ទីប្រជុំជនផងដែរ ។

### តារាង៤.៣ : ចំណុចដៅឆ្នាំ២០១០ សម្រាប់ការអភិវឌ្ឍជនបទ

| គោលដៅ | ២០០៥ (ប៉ាន់ស្មាន) | ២០១០ (ចំណុចដៅ) |
|---|---|---|
| ការស្តារផ្លូវជនបទ (ក្នុងចំណោមចម្ងាយផ្លូវសរុបប្រវែង ២៨.០០០ គម) (គម) | ២២.៧០០ | ២៥.០០០ |
| លទ្ធភាពទទួលបានទឹកស្អាតសម្រាប់បរិភោគ (%នៃប្រជាជននៅជនបទ) | ៤១,៦ | ៤៥ |
| លទ្ធភាពទទួលបានអនាម័យ (%នៃប្រជាជននៅជនបទ) | ១៦,៤ | ២៥ |

**៤.៥៤** យន្តការ *ផែនការមូលដ្ឋានចម្រុះ* ថ្មី នឹងត្រូវបានប្រើប្រាស់ដើម្បីផ្តោតការយកចិត្តទុកដាក់ ជាអាទិភាពលើតំបន់ជនបទដែលមិនបានទទួលសេវាកម្មគ្រប់គ្រាន់ ។ សកម្មភាពជាអាទិភាពទាំងឡាយសម្រាប់ពេលអនាគតរួមមាន (បន្ថែមលើសកម្មភាពទាំងឡាយដែលបានគ្របដណ្តប់ដោយ ការធ្វើវិមជ្ឈការនិងវិសហមជ្ឈការ[១]) :

[១] សូមមើលកថាខ័ណ្ឌ ៤.១៦ ដល់ ៤.១៨

- បន្តនិងការជំរុញផ្តល់និងលើកកម្ពស់គុណភាពហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាកម្មរបស់ប្រជាជននៅជនបទ និងធ្វើឱ្យមានការងាយស្រួលដឹកជញ្ជូនផលិតផលនៅជនបទទៅកាន់ទីផ្សារ ។
- ធ្វើឱ្យប្រសើរឡើងនិងការបង្កើនលទ្ធភាពប្រកបដោយចីរភាព ក្នុងការទទួលបាននិងប្រើប្រាស់ទឹកស្អាតសម្រាប់បរិភោគនិងអនាម័យ ជាពិសេស នៅសហគមន៍ជនបទដែលរស់នៅតំបន់ខ្វះខាតទឹក ។
- ជំរុញការគ្រប់គ្រងទឹក (ការស្តុកទឹកទុក ប្រឡាយ និងធារាសាស្ត្រ) ដើម្បីសម្រេចបានប្រសើរជាងនូវទិន្នផលនៃដំណាំនិងត្រីដែលខ្ពស់និងមានស្ថេរភាព ។
- រៀបចំបង្កើតមជ្ឈមណ្ឌលសហគមន៍ជនបទ ដោយផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធសមស្រប ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចមូលដ្ឋាន និងផ្តល់លក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការរស់នៅរបស់ប្រជាជនមូលដ្ឋាន ។
- យោងតាមមាត្រា ២៧ មាត្រា ៣០ និងមាត្រា៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវពិនិត្យ និងពង្រឹងឡើងវិញនូវគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍ ដោយមានការចូលរួមពីសហគមន៍នៅមូលដ្ឋាន ។
- ពង្រីកមីក្រូហិរញ្ញវត្ថុ និងការកាត់បន្ថយអត្រាការប្រាក់ខ្ពស់ ដោយអនុវត្តវិធានការសមស្រប រួមទាំងការលើកទឹកចិត្តឱ្យមានការបង្កើតសហករណ៍កសិករ ។
- ផ្តល់ការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ និងការការពារជនជាតិភាគតិច ។
- ការពារតំបន់ជនបទឱ្យរួចផុតពីគ្រោះធម្មជាតិ ដូចជាទឹកជំនន់ គ្រោះរាំងស្ងួតជាដើម ។ល។ តាមរយៈការអប់រំនិងការបង្កលក្ខណៈឱ្យសហគមន៍អាចមានការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយ និងការកាត់បន្ថយហានិភ័យ ។
- ផ្តល់បណ្តាញសុវត្ថិភាពដល់កសិករក្រីក្រ ដែលរងគ្រោះដោយធម្មជាតិ រួមទាំង ការស្វែងរកនូវវិធានការថ្មីៗ ដូចជា ការធានារ៉ាប់រងសុខភាព ឬការធានារ៉ាប់រងដំណាំ ។ល។
- លើកទឹកចិត្តឱ្យមានការចូលរួមច្រើនឡើងរបស់ផ្នែកឯកជននៅក្នុងសហគ្រាស ដែលមានមូលដ្ឋាននៅតាមភូមិនិងនៅតាមកសិដ្ឋាន និងក្នុងអនុវិស័យសំខាន់ៗ រួមមាន វារីវប្បកម្ម ផលិតកម្មដំណាំនិងបសុសត្វ និងសហគ្រាសកសិកម្មដែលមានទ្រង់ទ្រាយតូច និងដែលតម្រង់ទិសទៅរកទីផ្សារ និងពាណិជ្ជកម្ម ដូចជា ការកែច្នៃ ការងារក្រោយពេលប្រមូលផល និងយន្តូបនីយកម្ម ។

## ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

**៤.៥៥** ការងារនេះ គឺជាចតុកោណមួយសម្រាប់កំណើននៃយុទ្ធសាស្ត្រចតុកោណនេះ ដែលគ្របដណ្តប់ *(ក) ការសាងសង់បន្ថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ខ) ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ (គ) ការអភិវឌ្ឍវិស័យថាមពល និងបណ្តាញអគ្គិសនី (ឃ) ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍* ។

**៤.៥៦** ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន : បណ្តាញនិងប្រព័ន្ធដឹកជញ្ជូនដែលតភ្ជាប់គ្រប់ទីកន្លែងនៃប្រទេស គឺជាសរសៃឈាម ដែលជួយឱ្យកម្ពុជាមានសេដ្ឋកិច្ចចម្រុះមួយ ហើយមានសារៈសំខាន់បំផុតសម្រាប់កំណើនសេដ្ឋកិច្ច ដែលបែងចែកទៅគ្រប់វិស័យ ។ ដោយជួយសម្រួលដល់ពាណិជ្ជកម្ម ការផ្លាស់ប្តូរទំនិញនិងសេវាកម្ម ដោយជួយជំរុញសមាហរណកម្មទីផ្សារក្នុងស្រុក ក៏ដូចជា ដោយជួយឱ្យមានសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រួមមាន ផ្លូវថ្នល់ កំពង់ផែ ផ្លូវទឹកក្នុងប្រទេស ផ្លូវដែក និងអាកាសយានដ្ឋាន ។ គោលដៅនៃការងារនេះ គឺត្រូវបង្កើតបណ្តាញគមនាគមន៍មួយដែលមានភាពងាយស្រួល មានភាពទូលំទូលាយ មានសុវត្ថិភាព មានប្រសិទ្ធភាពសេដ្ឋកិច្ច ដែលជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម ជំរុញលើកទឹកចិត្តវិស័យទេសចរណ៍ ការអភិវឌ្ឍជនបទ និងបម្រើដល់កិច្ចការការពារជាតិ ។

**៤.៥៧** ខិតខំស្តារ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងផ្នែកទាក់ទងដល់ការអភិវឌ្ឍផ្សេងៗ ដែលនឹងផ្តោតការយកចិត្តទុកដាក់បង្កើនសមាហរណកម្មអភិវឌ្ឍន៍ក្នុងតំបន់ដូចខាងក្រោម :

- ទាក់ទាញទេសចរណ៍ (ដោយរាប់បញ្ចូលតំបន់ត្រីកោណ សៀមរាប ព្រះវិហារនិងកំពង់ធំ និងតំបន់សេដ្ឋកិច្ចទេសចរណ៍) ។
- តំបន់ឧស្សាហកម្ម ដោយរាប់បញ្ចូលអាគារពាណិជ្ជកម្ម និងតំបន់តាមបណ្តោយឆ្នេរ ។
- តំបន់កសិឧស្សាហកម្ម ។

**៤.៥៨** ការងារយ៉ាងច្រើនត្រូវបានអនុវត្តក្នុងការស្តារផ្លូវគ្រប់ប្រភេទ និងក្នុងការផ្តល់សារៈសំខាន់ទៅឱ្យបណ្តាញផ្លូវថ្នល់ ដែលជាផ្នែកនៃបណ្តាញផ្លូវថ្នល់អាស៊ាន ។ អាទិភាពសម្រាប់ដំណាក់កាលនៃ *ផយអជ* គឺ :

- បញ្ចប់ការរៀបចំនិងអនុម័តច្បាប់ប្រើប្រាស់ផ្លូវថ្នល់ ដើម្បីជំនះកង្វះខាតក្នុងដំណើរការរៀបចំ ផែនការ និងថវិកា ដែលមានលក្ខណៈឯកភាពនិងជាប្រព័ន្ធ និងដើម្បីកំណត់ឱ្យបានច្បាស់លាស់ នូវតួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងការងារជួសជុលនិងថែទាំផ្លូវថ្នល់ ។
- កំណត់អាទិភាព ស្តារ និងជួសជុលឡើងវិញ នូវផ្លូវសំខាន់ៗទៅតាមលទ្ធភាពដែលអាចធ្វើបាន ។
- ផ្តល់អាទិភាពដល់ឃុំឬភូមិដែលពុំទាន់មានផ្លូវទៅដល់ ពង្រីកបណ្តាញផ្លូវជនបទដើម្បីធានាថាឃុំទាំងអស់មានលទ្ធភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ទីរួមស្រុក និងទៅកាន់បណ្តាញផ្លូវជាតិនិងផ្លូវខេត្ត ។
- ដោះស្រាយបញ្ហាជូនប្រជាជនដែលត្រូវរុះរើទីលំនៅដោយមូលហេតុនៃការសាងសង់ផ្លូវថ្នល់ ដោយសន្តិវិធី និងតាមផ្លូវច្បាប់ ។

- ធានាឱ្យមានការថែទាំគ្រប់ប្រភេទផ្លូវទាំងអស់ទៅតាមអាទិភាពឱ្យបានសមស្របជាងមុន ដោយត្រូវគិតថា នៅពេលណាដែលផ្លូវត្រូវបានកែលម្អរួចហើយ ការកើនឡើងនៃចរាចរ នឹងធ្វើឱ្យមានការខូចខាតផ្លូវ ហើយតម្រូវឱ្យមានការថែទាំផ្លូវប្រសើរនិងញឹកញាប់ជាងមុន ។
- ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវវិធានការដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ជាពិសេស សម្រាប់ការសាងសង់និងថែទាំផ្លូវជនបទ ដើម្បីបង្កើនចំណូលជនបទ ។
- ធ្វើឱ្យមានការចូលរួមពីផ្នែកឯកជន ក្នុងការសាងសង់និងថែទាំផ្លូវ ស្ពាន ដោយប្រើប្រាស់រូបភាព សាងសង់-ដំណើរការ-ផ្ទេរ និងរូបភាពផ្សេងៗទៀត ដែលការចំណាយអាចប្រមូលបានវិញតាមរយៈការទារពន្ធពីអ្នកដែលធ្វើចរាចរឆ្លងកាត់ ។

**៤.៥៩** ក្រៅពីផ្លូវជនបទដែលបានលើកឡើងរួចមកហើយ និងបន្ថែមពីលើការងារជួសជុលនិងស្តារឡើងវិញផ្លូវឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ចំណុចដៅជាបរិមាណដែលត្រូវសម្រេចឱ្យបាននៅក្នុងដំណាក់កាល *ផយអជ* (២០០៦-២០១០) គឺត្រូវលើកកម្ពស់ផ្លូវជាតិនិងផ្លូវខេត្តប្រវែង ២.០០០គីឡូម៉ែត្រថែមទៀត ដែលនឹងធ្វើឱ្យប្រវែងសរុបនៃផ្លូវដែលនឹងត្រូវលើកកម្ពស់មានដល់ ៤.១០០គីឡូម៉ែត្រ ។

**៤.៦០** <u>កំពង់ផែ</u> : ការនាំចូលនិងការនាំចេញទំនិញដែលមានបរិមាណច្រើន ស្ទើរតែទាំងអស់ គឺត្រូវលើកដាក់នៅកំពង់ផែពីរ កំពង់ផែក្រុងព្រះសីហនុនិងកំពង់ផែក្រុងភ្នំពេញ ហើយកំពង់ផែក្រុងភ្នំពេញ អាចទទួលបានតែកប៉ាល់តូចៗល្មមប៉ុណ្ណោះ ។ ដើម្បីលើកដាក់បរិមាណទំនិញដែលមានការកើនឡើង កំពង់ផែក្រុងព្រះសីហនុកំពុងត្រូវបានលើកកម្ពស់សមត្ថភាពលើកដាក់ ហើយឃ្លាំងស្តុកកុងទែណើដំណាក់កាលទី២ នឹងត្រូវសាងសង់ឡើង ។

**៤.៦១** <u>ផ្លូវដែក</u> : បណ្តាញផ្លូវដែកពីរខ្សែដែលមួយខ្សែតភ្ជាប់ពីភ្នំពេញទៅក្រុងព្រះសីហនុ និងមួយខ្សែទៀតតភ្ជាប់ពីភ្នំពេញទៅព្រំប្រទល់ប្រទេសថៃ ចាំបាច់ត្រូវធ្វើការជួសជុល និងកែលម្អឡើងវិញជាបន្ទាន់ ហើយកំណល់ផ្លូវដែកទាំងអស់ក៏ត្រូវធ្វើការជួសជុលផងដែរ ។ អាទិភាពមួយទៀត គឺត្រូវស្តារឡើងវិញបណ្តាញផ្លូវដែកភាគខាងត្បូង ដើម្បីដឹកជញ្ជូនទំនិញដែលមានបរិមាណច្រើនជាងពីកំពង់ផែ ក្នុងអត្រាតម្លៃដឹកជញ្ជូនដែលមានលក្ខណៈប្រកួតប្រជែង ។

**៤.៦២** <u>ផ្លូវទឹកក្នុងប្រទេស</u> : អាទិភាពបន្ទាន់ចំពោះមុខ គឺត្រូវស្តារឡើងវិញម៉ាស៊ីនបូមដី ដើម្បីបូមដីស្តារបាតទន្លេនៅតាមបណ្តោយផ្លូវទឹកសំខាន់ៗទាំងអស់ ជាពិសេសទន្លេមេគង្គនិងទន្លេសាប ដើម្បីសម្រួលដល់ការដឹកជញ្ជូនតាមផ្លូវទឹកតាមទន្លេ ។

**៤.៦៣** <u>សេវាកម្មអាកាសចរណ៍ស៊ីវិល</u> ដើរតួយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ដែលជាវិស័យស្នូលដែលមានឥទ្ធិពលយ៉ាងធំធេងដល់សេដ្ឋកិច្ចជាតិ ។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋាន

អន្តរជាតិកងកេង (ក្រុងព្រះសីហនុ) នឹងត្រូវធ្វើការកែលម្អថែមទៀតទៅតាមកិច្ចព្រមព្រៀង *សាងសង់-ដំណើរការ-ផ្ទេរ* ដែលមានស្រាប់ ។ អាកាសយានដ្ឋានអន្តរជាតិសៀមរាប ក៏ត្រូវធ្វើការពង្រីកនិងកែលម្អផងដែរទៅតាមស្តង់ដារអន្តរជាតិ ។ អាកាសយានដ្ឋានក្នុងស្រុកមួយ ចំនួនចាំបាច់ត្រូវធ្វើការកែលម្អឱ្យមានកម្រិតខ្ពស់ជាងមុន ដើម្បីបង្កលក្ខណៈឱ្យមានចរាចរញឹកញាប់ជាងមុនទៅកាន់តំបន់ដាច់ស្រយាល ដែលមានសក្តានុពលទេសចរណ៍ខ្ពស់ ។ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំស្វែងរករូបភាព ផ្សេងៗទៀតក្នុងការផ្តល់ហិរញ្ញប្បទាន ជាពិសេសតាមរយៈរូបភាព *សាងសង់-ដំណើរការ-ផ្ទេរ* ដែលពាក់ព័ន្ធជាមួយផ្នែកឯកជន ។

**៤.៦៤ <u>ការគ្រប់គ្រងធនធានទឹក និងការស្រោចស្រព</u> :** ធនធានទឹកបានចូលរួមគាំទ្រដល់តម្រូវការក្នុងវិស័យជាច្រើននៃសេដ្ឋកិច្ចជាតិ ។ នាពេលបច្ចុប្បន្ន សម្ពាធដ៏ធ្ងន់ធ្ងរមកលើធនធានទឹក ដែលធ្វើឱ្យហានិភ័យនៃការបំពុលមានកម្រិតខ្ពស់ បង្កឡើងដោយសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច តែងតែកើតមានឡើងនារដូវប្រាំង ឬការអូសបន្លាយរយៈពេលនៃគ្រោះរាំងស្ងួត ។ម្យ៉ាងទៀត បរិមាណទឹកដ៏លើសលប់នៅរដូវវស្សា បង្កឱ្យមានទឹកជំនន់ ដែលធ្វើឱ្យបាត់បង់អាយុជីវិតមនុស្ស-សត្វ និងបង្កការលំបាកដល់ការរស់នៅរបស់ប្រជាជន ព្រមទាំងធ្វើឱ្យ *ផសស* របស់ជាតិមានការធ្លាក់ចុះ ។ គោលបំណងនៃការកាត់បន្ថយនូវគ្រោះថ្នាក់ដែលបង្កឡើងដោយបាតុភូតធម្មជាតិខាងលើ គឺត្រូវអនុម័តវិធីសាស្ត្ររួមក្នុងការអភិវឌ្ឍនិងការគ្រប់គ្រងធនធានទឹក ។ ការអភិវឌ្ឍនិងការគ្រប់គ្រងធនធានទឹក ត្រូវផ្តោតការយកចិត្តទុកដាក់លើ (ក) ការធានាឱ្យបានទាំងបរិមាណទឹកគ្រប់គ្រាន់ និងគុណភាពទឹកសមស្របសម្រាប់បំពេញតម្រូវការឱ្យបានពេញមួយឆ្នាំដល់គ្រប់វិស័យ ព្រមទាំងថែរក្សាឱ្យបាននូវប្រព័ន្ធអេកូឡូស៊ីនៃទឹក (ខ) ការគ្រប់គ្រងឱ្យបាននូវលំហូរទឹកជំនន់ និងបង្កើនសមត្ថភាពសហគមន៍ដើម្បីទប់ទល់នឹងទឹកជំនន់ (គ) ការគ្រប់គ្រងទឹកសម្រាប់កសិកម្ម តាមរយៈការបង្កើនសមត្ថភាពអាងស្តុកទឹក ការសាងសង់ប្រព័ន្ធធារាសាស្ត្រនិងប្រឡាយដោះទឹកសមស្រប (ឃ) ការរក្សាធនធានទឹកកុំឱ្យមានភាពក្រខ្វក់ដើម្បីទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ី ជាពិសេស សំរាប់មច្ឆា ។ សកម្មភាពជាអាទិភាពលើការអភិវឌ្ឍនិងគ្រប់គ្រងធនធានទឹកសម្រាប់រយៈពេល ៥ឆ្នាំ ខាងមុខរួមមាន :

- ស្តារនិងជួសជុលឡើងវិញនូវ ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹកដែលមានស្រាប់នៅក្នុងតំបន់ដែលភាពក្រីក្រមានកំរិតខ្ពស់ និងនៅតាមតំបន់ព្រំដែន ។
- ពង្រឹងនិងពង្រីកសមត្ថភាពអាងស្តុកទឹក ព្រមទាំងជំរុញការប្រើប្រាស់បច្ចេកវិទ្យារក្សាទឹកទុក ។
- បង្កើនការប្រើប្រាស់ធនធានទឹកក្រោមដីនៅតំបន់ដែលខ្សត់ទឹកលើដី ឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាព ។
- រៀបចំនិងអនុវត្តន៍នូវវិធានការគ្រប់គ្រងនិងកាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត ។
- ពង្រឹងនិងបង្កើនសហគមន៍កសិករប្រើប្រាស់ទឹក ដោយលើកទឹកចិត្តឱ្យស្ត្រីចូលរួមជាសមាជិក ។
- ជំរុញការវិនិយោគវិស័យឯកជនលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក និងវិស័យផ្សេងៗទៀត ដែលពាក់ព័ន្ធការគ្រប់គ្រងទឹកសម្រាប់កសិកម្ម ។

- កែលម្អនិងតម្លើងប្រព័ន្ធតាមដានអង្កេតនិងត្រួតពិនិត្យឧតុនិយម-ជលសាស្ត្រនៅទូទាំងប្រទេស ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពការព្យាករណ៍ឧតុនិយម-ជលសាស្ត្រ ក្នុងគោលបំណងបម្រើដល់ការកសាងសេដ្ឋកិច្ច-សង្គមជាតិ ព្រមទាំងផ្តល់ព័ត៌មានស្តីពីអាកាសធាតុ-ជលសាស្ត្រ ឱ្យបានទាន់ពេលវេលាជូនដល់សាធារណៈជន ។
- ជំរុញការគ្រប់គ្រងអាងទន្លេ និងការបែងចែងទឹកឱ្យបានសមស្របនិងមានប្រសិទ្ធភាព។

**៤.៦៥** <u>វិស័យថាមពល និងអគ្គិសនី</u> : ការបន្តអភិវឌ្ឍវិស័យថាមពលជាផ្នែកសំខាន់មួយក្នុងចំណោមគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការកើនឡើងនៃតម្រូវការអគ្គិសនី ។ ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺត្រូវធានាឱ្យមានសន្តិសុខថាមពលនៅទូទាំងប្រទេស ។ ប្រព័ន្ធផលិតកម្ម ប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយ ថាមពលក្នុងស្រុក នឹងត្រូវដាក់ឱ្យដំណើរការដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នៅតាមទីប្រជុំជននិងជនបទ និងតម្រូវការនៅក្នុងសេដ្ឋកិច្ចមួយដែលកំពុងរីកចម្រើន ។ យុទ្ធសាស្ត្រវិស័យថាមពលរបស់កម្ពុជារយៈពេល ១៥ឆ្នាំ ២០០៦-២០២០ កំពុងដំណើរការរៀបចំ ។ យុទ្ធសាស្ត្រនេះ ស្នើឡើងដើម្បីឱ្យមានភាពជាម្ចាស់ការក្នុងវិស័យថាមពល តាមរយៈ ពាណិជ្ជកម្មថាមពលអគ្គិសនី និងការផ្លាស់ប្តូរថាមពលអគ្គិសនីជាមួយប្រទេសជិតខាង និងសមាហរណកម្មទៅក្នុងតំបន់ ។ ការផលិតថាមពលអគ្គិសនីនិងការធ្វើឱ្យអគ្គិសនីមានថ្លៃទាប នឹងអាចកាត់បន្ថយបានភ្លាមៗនូវការចំណាយផលិតកម្មនៅក្នុងវិស័យកម្មន្តសាល និងការចំណាយប្រតិបត្តិការនៅក្នុងវិស័យផ្សេងៗទៀត ហើយតាមរយៈនេះនឹងមានការទាក់ទាញការវិនិយោគនិងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលកម្ពុជាឱ្យតម្លៃខ្ពស់ដល់ការចូលរួមរបស់ផ្នែកឯកជន ក្នុងការនាំមុខនៅក្នុងដំណើរការវិនិយោគនៅក្នុងវិស័យនេះ ។

**៤.៦៦** យុទ្ធសាស្ត្ររយៈពេលមធ្យម រួមមាន :

- បន្តធ្វើការជួសជុលនិងសាងសង់រោងចក្រថាមពលក្នុងស្រុក ។
- ខិតខំបញ្ចៀសការប្រើប្រាស់ប្រភពថាមពល ដែលមានថ្លៃខ្ពស់ហើយយកចិត្តទុកដាក់ជំរុញអភិវឌ្ឍប្រភពថាមពលដែលមានថ្លៃទាប ។
- ទិញថាមពលអគ្គិសនីនៅក្នុងថ្លៃសមស្របពីប្រទេសជិតខាង តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ដែលនឹងត្រូវពិនិត្យនិងកែសម្រួលទៅតាមពេលវេលាកំណត់ជាក់លាក់ ។
- បន្តតម្លើង និងពង្រីកប្រព័ន្ធបញ្ជូន និងបែងចែកថាមពលអគ្គិសនីកម្រិតជាតិ ។
- បន្តពង្រីកការធ្វើអគ្គិសនីភាវូបនីយកម្មនៅតំបន់ជនបទ ។

**៤.៦៧** <u>ប្រេងនិងឧស្ម័ន</u> : លទ្ធភាពខ្ពស់ក្នុងការរុករកធនធានប្រេងនិងឧស្ម័នក្នុងសមុទ្រនៅក្នុងប្រទេស នឹងផ្តល់នូវការលើកស្ទួយដល់សេដ្ឋកិច្ចជាតិ ។ បញ្ហាប្រឈមចំពោះមុខ គឺត្រូវរៀបចំផែនការពីពេលបច្ចុប្បន្ននេះទៅ

ដើម្បីប្រើប្រាស់ប្រភពថាមពលនេះ និងប្រើប្រាស់ចំណូលដែលទទួលបានពីប្រភពធនធាននេះ តាមរូបភាពមួយល្អបំផុត សំដៅទាញយកផលប្រយោជន៍សម្រាប់ប្រទេសជាតិនិងប្រជាពលរដ្ឋ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ។ រាជរដ្ឋាភិបាលកម្ពុជានឹងចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវក្នុងពេលឆាប់ៗនេះ ដើម្បីជ្រើសរើសយកបទពិសោធន៍ល្អៗ និងចៀសវាងគ្រោះថ្នាក់ ទាំងឡាយដែលធ្លាប់បានកើតឡើងនៅតាមបណ្តាប្រទេសផលិតប្រេង ។ ឧស្ម័នដែលបានពីអណ្តូងប្រេងក្នុងសមុទ្រ (បើមិនដូច្នោះទេឧស្ម័នទាំងនោះនឹងឆេះចោលនៅកន្លែងខួងយកប្រេង) ត្រូវបានយកមកប្រើប្រាស់ក្នុងរូបភាពផ្សេងៗដែលមានប្រយោជន៍សម្រាប់ផលិតកម្ម នៅលើដីគោក ដូចជាយកមកប្រើប្រាស់សម្រាប់ផលិតកម្មជី សម្រាប់ការផលិតថាមពល សម្រាប់ធ្វើជាប្រភពថាមពលតាមរោងចក្រឧស្សាហកម្មជាច្រើនប្រភេទ ។ រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការសិក្សាស្រាវជ្រាវ និងខិតខំប្រឹងប្រែងដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីឱ្យធនធានប្រេងនិងឧស្ម័នដ៏មានតម្លៃ (រាប់បញ្ចូលទាំងឧស្ម័នដែលបានពីអណ្តូងប្រេង) ត្រូវបានយកទៅប្រើប្រាស់ ដោយមានសារប្រយោជន៍ទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

**៤.៦៨** <u>បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍</u> : ចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍ គឺត្រូវអភិវឌ្ឍប្រព័ន្ធទូរគមនាគមន៍និងប្រៃសណីយ៍មួយដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចនិងមានគុណភាពកម្រិតពិភពលោក ដែលត្រូវគ្របដណ្តប់ទូទាំងប្រទេស ។ ការសម្រេចបានចក្ខុវិស័យនេះ ទាមទារឱ្យមានការវិនិយោគខ្ពស់ ដើម្បីកសាងមូលដ្ឋាននៃហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទូរគមនាគមន៍ទាំងឡាយ ជាពិសេស ខ្សែកាបអុបទិចដែលអាចប្រើប្រាស់ល្បឿនខ្ពស់ ដើម្បីរៀបចំប្រព័ន្ធទូរគមនាគមន៍ទាំងឡាយនៅជនបទ ។ បញ្ហាប្រឈមបន្ទាន់ចំពោះមុខ គឺការបញ្ចុះតម្លៃសេវាទូរគមនាគមន៍ ដែលជាជំនួយដល់អាជីវកម្មនិងប្រជាជនជាទូទៅ ។ វិស័យទូរគមនាគមន៍និងព័ត៌មានវិទ្យា ត្រូវដាក់ឱ្យដំណើរការសម្រាប់ធ្វើឱ្យប្រសើរឡើងនៃស្ថានភាពរស់នៅរបស់អ្នកក្រ ។ អាទិភាពទាំងឡាយសម្រាប់ដំណាក់កាល *ផយអជ* (២០០៦-២០១០) គឺ :

- បន្ទាបតម្លៃខ្ពស់របស់សេវាកម្មទូរគមនាគមន៍ ឱ្យបានឆាប់រហ័ស ។
- ពង្រីកបណ្តាញទូរគមនាគមន៍ទាំងឡាយនៅក្នុងតំបន់ទីប្រជុំជន និងពង្រីកបណ្តាញទាំងនោះទៅដល់ទីប្រជុំតូចៗ និងតំបន់ជនបទ ។
- ពង្រីកសេវាប្រៃសណីយ៍ពីតំបន់ទីក្រុង-ទីប្រជុំជន ដល់តំបន់ជនបទប្រកបដោយគុណភាព មានតម្លៃថោកសមរម្យ និងពង្រឹងសមត្ថភាពស្ថាប័នគ្រប់គ្រង ។
- ពង្រីកនិងធ្វើឱ្យប្រសើរឡើងនូវវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃបណ្តាញផ្សព្វផ្សាយរបស់រដ្ឋ : វិទ្យុ ទូរទស្សន៍ និងទីភ្នាក់ងារសារព័ត៌មាន ។
- បន្តអនុវត្តគោលនយោបាយបើកទូលាយក្នុងការជំរុញការចូលរួមរបស់ផ្នែកឯកជន ។

**៤.៦៩** ការផ្តោតការយកចិត្តទុកដាក់នឹងនៅតែបន្ត ទៅលើការជំរុញការប្រើប្រាស់យ៉ាងទូលំទូលាយនូវបច្ចេកវិទ្យាព័ត៌មាន នៅក្នុងគ្រប់រាល់រូបភាពនៃការគ្រប់គ្រងក្នុងរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរក្សាប្រកបដោយប្រសិទ្ធភាព នូវឯកសារនានា ទិន្នន័យមូលដ្ឋាន និងគេហទំព័រ ដែលនឹងផ្តល់ភាពងាយស្រួលប្រើប្រាស់ដល់សាធារណជនទាំងឡាយ លើគ្រប់រូបភាពនៃសេចក្តីត្រូវការ ។ ក្រសួង-ស្ថាប័ននីមួយៗ នឹងបង្កើតគេហទំព័រផ្ទាល់ខ្លួន ហើយកែលម្អវាឱ្យទាន់ពេលវេលាក្នុងរាល់ ៦ខែម្តង ឬញឹកញាប់ជាងនេះទៅតាមតម្រូវការចាំបាច់ ។ គេហទំព័រទាំងនេះ នឹងមានផ្ទុកនូវទិន្នន័យនិងព័ត៌មានទាំងអស់ ដែលមានការទាក់ទងទៅនឹងក្រសួង-ស្ថាប័ន ។

## ការអភិវឌ្ឍវិស័យឯកជននិងការបង្កើតការងារ

**៤.៧០** មុំទាំងបួននៃចតុកោណនេះគឺ : *(ក) ការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ (ខ) ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម (គ) ការបង្កើតការងារ និងធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករនិងនិយោជិត* និង *(ឃ) ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម* ។

**៤.៧១** <u>ការពង្រឹងវិស័យឯកជន</u> : វិស័យឯកជន ត្រូវបានចាត់ទុកជាកម្លាំងជំរុញចម្បងនៃកំណើនសេដ្ឋកិច្ច ទន្ទឹមគ្នានឹងពេលដែលរដ្ឋាភិបាលដើរតួយ៉ាងសំខាន់ជាអ្នករៀបចំយុទ្ធសាស្ត្រ មគ្គុទ្ទេសក៍ និងអ្នកគ្រប់គ្រងដំណើរការអភិវឌ្ឍ ហើយជាអ្នកសម្រួលក្នុងការបង្កើតឱ្យមាននូវបរិយាកាសល្អប្រសើរសម្រាប់ការវិនិយោគឯកជននិងសហគ្រាស ។ ដើម្បីដោះស្រាយបញ្ហាសំខាន់ទាំងឡាយដែលបង្អាក់ដល់ការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា " *ផែនការ ១២ ចំណុច* " ដែលលើកឡើងពីការប្តេជ្ញាចិត្តទាំងឡាយរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងបរិយាកាសវិនិយោគ និងសម្រួលដល់ពាណិជ្ជកម្ម[១] ត្រូវបានអនុម័ត ។

**៤.៧២** រាជរដ្ឋាភិបាលនឹងបន្តជំរុញ រក្សា និងលើកកម្ពស់បរិយាកាសអំណោយផលនេះ តាមរយៈ :

- ការបង្កើនសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ និងការធ្វើឱ្យមានកម្លាំងពលករជំនាញ (តាមរយៈការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនិងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗទៀត) ។
- បង្កើត និងអនុវត្តតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងបង្កើតការងារជូនប្រជាជន ។
- ការពង្រឹងជាបន្តទៀតនូវក្របខណ្ឌច្បាប់សម្រាប់សហគ្រាស រួមមានច្បាប់ លិខិតបទដ្ឋាន និងសមត្ថភាពស្ថាប័នដែលសម្រួលដល់ការធ្វើអាជីវកម្ម ជំនួញ និងការវិនិយោគឯកជន ក្នុងបរិយាកាសមួយដែលមានការប្រកួតប្រជែងដោយស្មើភាពគ្នា តម្លាភាព គណនេយ្យភាព និងភាពអាចព្យាករណ៍បាន ។

---

[១] កម្ពុជា : *ការចាប់យកកាលានុវត្តភាពពិភពលោក : ការវាយតំលៃបរិយាកាសវិនិយោគនិងយុទ្ធសាស្ត្រកំណែទម្រង់* ធនាគារពិភពលោក មិថុនា ២០០៤

- ការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាពនិងយ៉ាងឆាប់រហ័ស នូវកត្តាចម្បងៗទាំងឡាយ ដែលបង្អាក់ដល់កំណើនផ្នែកឯកជន ដែលបានកំណត់ក្នុងការអង្កេតបរិយាកាសវិនិយោគ[១] ដូចជា អភិបាលកិច្ចខ្សោយ បន្ទុកផ្នែកទិដ្ឋភាពច្បាប់ ភាពខ្សោយនៅក្នុងបរិយាកាសតុលាការនិងច្បាប់ ។
- ការលុបបំបាត់នូវភាពមិនប្រាកដប្រជានិងភាពមិនអាចព្យាករណ៍បានដែលមាននាពេលបច្ចុប្បន្ន ដែលបង្កឡើងដោយកត្តាដូចបានពោលខាងលើ ដែលធ្វើឱ្យអ្នកវិនិយោគពិតប្រាកដនិងសម្រាប់រយៈពេលវែងចៀសចេញពីកម្ពុជា ដោយធ្វើឱ្យគេអាចយល់បានថា អ្នកវិនិយោគទាំងឡាយណាដែលនៅកម្ពុជា គឺជាអ្នកចង់ទាញយកផលចំណេញភ្លាមៗ និងឆ្លៀតឱកាសរកចំណេញ ឬក៏ធ្វើអាជីវកម្មនៅក្នុងផ្នែកមិនផ្លូវការដើម្បីគេចពន្ធ ហើយជាមួយនេះ ដើម្បីរកផលចំណេញឱ្យបានច្រើនបំផុត ។
- ការដាក់ឱ្យដំណើរការ "ច្រកចេញចូលតែមួយ" ជាយន្តការសម្របសម្រួលមួយដ៏ឆាប់រហ័សរបស់រដ្ឋាភិបាល សម្រាប់ពាណិជ្ជកម្ម និងអ្នកវិនិយោគទាំងអស់ ។
- ការបន្តការពិភាក្សាដោយចំហជាមួយផ្នែកឯកជន តាមរយៈវេទិកាផ្នែកឯកជន និងគណៈកម្មាធិការសម្រាប់អភិវឌ្ឍន៍ផ្នែកឯកជន ដើម្បីដោះស្រាយការព្រួយបារម្ភទាំងឡាយរបស់ផ្នែកឯកជន ។

**៤.៧៣** ដើម្បីលើកកម្ពស់កំណើនដែលនាំមុខដោយការនាំចេញ និងកំណើនដើម្បីគាំទ្រអ្នកក្រ តាមរយៈការធ្វើពិពិធកម្ម រាជរដ្ឋាភិបាលនឹងបន្តលើកទឹកចិត្ត សម្រួល និងផ្តល់ការគាំទ្រដល់ការវិនិយោគ ផ្នែកឯកជនក្នុងវិស័យមួយចំនួន និងក្នុងវិស័យអាទិភាព ដូចខាងក្រោម ៖

- កសិកម្ម និងកសិ-ឧស្សាហកម្ម រួមទាំង ធារាសាស្ត្រ ដោយសារវិស័យទាំងនេះមានសក្តានុពលខ្ពស់សម្រាប់កំណើនខ្លាំង និងមានផលប៉ះពាល់ខ្លាំងលើសេដ្ឋកិច្ច តាមរយៈការបង្កើនចំណូលក្នុងតំបន់ជនបទ និងបង្កើនតម្រូវការ ។
- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងទូរគមនាគមន៍ ។
- ការផលិតនិងការចែកចាយថាមពលអគ្គិសនី ។
- ឧស្សាហកម្មដែលត្រូវការកម្លាំងពលកម្មច្រើន និងកម្មន្តសាលកែច្នៃសម្រាប់ការនាំចេញ ។
- ទេសចរណ៍ និងវិស័យពាក់ព័ន្ធ ។
- ការអភិវឌ្ឍធនធានមនុស្ស ។

**៤.៧៤** <u>ពាណិជ្ជកម្ម</u> ៖ ដោយផ្សារភ្ជាប់ផលិតកម្មទៅនឹងការប្រើប្រាស់ ឬអ្នកផលិតទៅនឹងអ្នកប្រើប្រាស់ ពាណិជ្ជកម្ម គឺជាមធ្យោបាយដ៏សំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ។ ការជំរុញលើកទឹកចិត្តពាណិជ្ជកម្មសម្រាប់ផលិតផលកម្ពុជា គឺជាអាទិភាពខ្ពស់ក្នុងចំណោមអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាល ។

---

[១] យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឯកជនសម្រាប់កម្ពុជា: *ការវាយតម្លៃបរិយាកាសវិនិយោគ*: ធនាគារពិភពលោក ឆ្នាំ២០០៣

ប្រសិនបើមានការលក់ដូរនៅទីផ្សារ ការវិនិយោគអាចនឹងហូរចូល ដើម្បីលើកទឹកចិត្តនិងលើកកម្ពស់ផលិតកម្ម នៃទំនិញ និងសេវាកម្ម ដោយប្រើប្រាស់ភាពខ្លាំងពិតប្រាកដរបស់កម្ពុជា ដូចដែលធ្លាប់បានកើតមានឡើងក្នុង ឧស្សាហកម្មកាត់ដេរ ហើយអាចនឹងសម្រេចបានក្នុងវិស័យកសិកម្ម ការកែច្នៃកសិកម្ម សិប្បកម្ម និងផ្នែក ផ្សេងទៀត ។

**៤.៧៥** តាំងពីឆ្នាំ២០០១ ក្របខណ្ឌគោលនយោបាយពាណិជ្ជកម្មមួយសម្រាប់ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្ម ក្នុងនិងក្រៅប្រទេស ត្រូវបានដាក់ឱ្យដំណើរការ ដែលជាមធ្យោបាយមួយដើម្បីជំរុញកំណើននិងចូលរួមក្នុងការ កាត់បន្ថយភាពក្រីក្រ ។ គំនិតផ្តួចផ្តើមនានានិងវិធានការកែទម្រង់ ទាំងឡាយដែលត្រូវបានយកមកប្រើប្រាស់ ដើម្បីអនុវត្តក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្មឱ្យបានពេញលេញ ក្នុងការនាំចេញយ៉ាងសកម្មនិងការធ្វើ សមាហរណកម្មប្រទេសទៅក្នុងតំបន់ និងការចូលរួមទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ២០០៤ ។ រាជរដ្ឋាភិបាលក៏បានចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិង/ឬពាណិជ្ជកម្ម អនុគ្រោះជាមួយប្រទេសជាច្រើន ប្រកបដោយជោគជ័យ ។ ទោះជាដូចនេះក្តី នៅមានការរាំងស្ទះជាច្រើនទៀត ដែលមានលក្ខណៈប្រហាក់ ប្រហែលទៅនឹងការរាំងស្ទះនៅក្នុងការវិនិយោគឯកជនក្នុងវិស័យឧស្សាហកម្ម ដែលជាឧបសគ្គនៃកំណើនក្នុង វិស័យពាណិជ្ជកម្ម ។ *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* មួយសម្រាប់ផ្នែកពាណិជ្ជកម្មកំពុងត្រូវបានរៀបចំ ។ បញ្ហា ប្រឈមបន្ទាន់ចំពោះមុខទាំងឡាយ គឺត្រូវធានាថាកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះ ទាំងឡាយដែលបានចុះ ហត្ថលេខារួចហើយ ត្រូវបានទទួលឧត្តមភាពតាមរយៈពាណិជ្ជកម្មឯកជន ក្នុងការនាំផលិតផលកម្ពុជាទៅកាន់ ទីផ្សារបរទេស ដើម្បីការនាំចេញទាំងឡាយអាចមានលក្ខណៈចម្រុះនិងទូលំទូលាយ ដោយជួយឱ្យការនាំចេញ លែងមានការពឹងផ្អែកទៅលើឧស្សាហកម្មកាត់ដេរតែមួយមុខ ។

**៤.៧៦** កំណែទម្រង់នានាដែលរាជរដ្ឋាភិបាលកម្ពុជានឹងបន្តក្នុងអភិបាលកិច្ច វិស័យតុលាការនិងច្បាប់ និងរដ្ឋបាល សាធារណៈ ក៏ដូចជា ក្នុងការស្តារហេដ្ឋាចរនាសម្ព័ន្ធមូលដ្ឋាន នឹងពិតជារួមចំណែកក្នុងការធ្វើឱ្យមានបរិយាកាសល្អ ប្រសើរជាងមុខ សម្រាប់ពាណិជ្ជកម្មនិងការវិនិយោគដោយផ្នែកឯកជន ។ បន្ថែមពីលើការដោះស្រាយឧបសគ្គ ទាំងឡាយក្នុងផ្នែកឧស្សាហកម្ម កម្មន្តសាលនិងឧស្សាហកម្មកែច្នៃ ក៏ដូចជា ក្នុងផ្នែកពាណិជ្ជកម្ម រាជរដ្ឋាភិបាល កម្ពុជានឹង :

- ជំរុញលើកទឹកចិត្តយ៉ាងសកម្មឱ្យមានលទ្ធភាពចូលទៅក្នុងទីផ្សារក្រៅប្រទេសនានា របស់ផលិតផល ពិសេសនិងមានគុណភាពខ្ពស់របស់កម្ពុជា ដែលរាប់បញ្ចូលទាំងផលិតផលកសិកម្ម (ជាពិសេស ផលិត-ផលដែលបានកែច្នៃរួចហើយ) ផលិតផលកែច្នៃពីត្រី និងសេវាកម្មកម្លាំងពលកម្ម ។
- ជំរុញផលិតផលកម្ពុជានៅទីផ្សារបរទេស ។

- ជំរុញលើកទឹកចិត្តឱ្យមានការបង្កើតសមាគមសម្រាប់សមាជិកភាពនៃធុរៈកិច្ច និងពង្រឹងសមត្ថភាពផ្សព្វផ្សាយរបស់សមាគមទាំងនោះ ។
- កាត់បន្ថយឧបសគ្គដែលបណ្តាលមកពីគោលនយោបាយ ចំពោះអន្តរកម្មធុរៈកិច្ចប្រកបដោយប្រសិទ្ធភាព ។
- រៀបចំឱ្យមានប្រសិទ្ធភាពនូវអធិការកិច្ចគយ ដើម្បីធ្វើឱ្យការងារនេះ មានភាពងាយស្រួលជាងមុនសម្រាប់អតិថិជន និងមិនមានការពន្យារនិងការចំណាយដែលផ្សារភ្ជាប់នឹងស្ថានភាពនេះ រួមទាំងការរៀបចំ និងការអនុវត្តច្បាប់គយនិងរដ្ឋករ ដែលបានកែសម្រួលរួចហើយ ។
- កាត់បន្ថយឧបសគ្គនៃការនាំចូល ដូចជាតម្លៃខ្ពស់នៃការចុះបញ្ជីនិងតម្លៃនៃការចេញអាជ្ញាប័ណ្ណ ។
- ជួយសម្រួលដល់ការបង្កើត តំបន់កែច្នៃសម្រាប់ការនាំចេញ ដើម្បីជំរុញឧស្សាហកម្មកែច្នៃនិងកម្មន្តសាលសម្រាប់បម្រើឱ្យការនាំចេញ ។

**៤.៧៧ ទេសចរណ៍** : ការកើនឡើងយ៉ាងឆាប់រហ័ស បានជំរុញឱ្យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ ក្លាយជាវិស័យទីពីរបន្ទាប់ពីឧស្សាហកម្មកាត់ដេរ និងមានតួនាទីក្នុងការជំរុញកំណើនសេដ្ឋកិច្ចនិងការផ្តល់ឱកាសការងារជូនប្រជាពលរដ្ឋកម្ពុជាមួយចំនួនធំ ទាក់ទងនឹងផ្នែកមួយចំនួនដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ការដឹកជញ្ជូន និងសេវាកម្មផ្សេងៗទៀត ។ គោលនយោបាយសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ត្រូវបានផ្អែកលើគោលការណ៍ជាមូលដ្ឋានបី (ក) ការអភិវឌ្ឍត្រូវមានលក្ខណៈចីរភាព ពឹងផ្អែកលើកេរដំណែលវប្បធម៌ស្ថាបត្យកម្ម ប្រវត្តិសាស្ត្រ និងធម្មជាតិដ៏ល្អត្រកាលនៃទឹកដីកម្ពុជា ។ សំខាន់ជាងនេះទៀត គឺការអភិវឌ្ឍដែលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ (ខ) ការផ្សព្វផ្សាយយ៉ាងសកម្មនិងមានលក្ខណៈច្នៃប្រឌិតអំពីវិស័យទេសចរណ៍ ដើម្បីធ្វើឱ្យកម្ពុជាក្លាយទៅជាគោលដៅទេសចរណ៍ "វប្បធម៌និងធម្មជាតិ" មួយក៏គួរជាទីទាក់ទាញដែលមានលក្ខណៈប្រកួតប្រជែងនៅក្នុងតំបន់ និងអន្តរជាតិ (គ) ក្រៅពីការកើនឡើងនៃចំនួនភ្ញៀវទេសចរដែលបានមកដល់ ត្រូវបង្កើនចំនួនថ្ងៃដែលអ្នកទេសចរស្នាក់នៅក្នុងប្រទេស និងការចំណាយរបស់ភ្ញៀវទេសចរ ព្រមទាំងធ្វើឱ្យមានគោលដៅទេសចរណ៍ច្រើនប្រភេទ និងច្រើនកន្លែង ។ លើសពីនេះទៀត ការខិតខំប្រឹងប្រែងនឹងត្រូវធ្វើឡើង ដើម្បីធានាថាផលប្រយោជន៍សមស្របនៃវិស័យទេសចរណ៍ នឹងជួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅ ជុំវិញតំបន់ទេសចរណ៍ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ ។ ការផ្តួចផ្តើមគំនិតសំខាន់ៗដែលនឹងត្រូវបន្តធ្វើឱ្យមានប្រសិទ្ធភាពថែមទៀត ជាអាទិ៍ :

- គោលនយោបាយបើកចំហជើងមេឃ ។
- ធ្វើឱ្យមានភាពងាយស្រួលក្នុងការទទួលទិដ្ឋាការ និងការទស្សនា ។
- កិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន និងកិច្ចព្រមព្រៀងផ្សេងៗទៀត ដូចជាការពង្រឹងទេសចរណ៍ក្នុងតំបន់ជាដើម ។

- ពង្រឹងសមត្ថភាព និងយន្តការប្រឆាំងបទល្មើស ពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទរាល់រូបភាពនៃអាជីវកម្មលើកុមារ ។

**៤.៧៨** រាជរដ្ឋាភិបាលបានបន្តការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ផ្លូវគោក អាកាសយានដ្ឋាន កំពង់ផែ ប្រព័ន្ធទឹកស្អាត អគ្គិសនី) ក៏ដូចជាការផ្តល់នូវបរិយាកាសសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម និងបង្កលក្ខណៈងាយស្រួលឱ្យមានការកើនឡើងនៃភ្ញៀវទេសចរ ការស្នាក់នៅ និងការទស្សនា ។ ដោយមានការកើនឡើងជាបន្តបន្ទាប់ក្នុងល្បឿនលឿន ចំនួនភ្ញៀវទេសចរមកដល់ប្រចាំឆ្នាំ ត្រូវបានរំពឹងថា នឹងកើនដល់ប្រមាណ ៣លាននាក់ នៅឆ្នាំ២០១០ ចំណូលទេសចរណ៍នឹងកើនឡើងដល់ប្រមាណ ១.៥០០លានដុល្លារ និងផ្តល់ការងារដល់ប្រជាពលរដ្ឋប្រមាណ ៤០០.០០០នាក់ ។ សម្រាប់គោលបំណងនេះ រាជរដ្ឋាភិបាលត្រូវអនុវត្ត វិធានការគាំទ្រជាច្រើនដូចខាងក្រោម :

- ការបង្កើតឡើងនូវក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយវិស័យទេសចរណ៍ ដើម្បីបង្កលក្ខណៈអោយផ្នែកសាធារណៈ និងឯកជនចូលរួមសហការគ្នាក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ។
- ការបង្កើតការិយាល័យ ឬបញ្ជរពត៌មានទេសចរណ៍នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ។
- លើកទឹកចិត្តឱ្យមានការផ្តល់សេវាព័ត៌មាន ដូចជា សណ្ឋាគារឬផ្ទះសំណាក់ មគ្គុទ្ទេសក៏ទេសចរ អាកាសចរណ៍និងសេវាដែលមានការពាក់ព័ន្ធ ភោជនីយដ្ឋាន គមនាគមន៍ ។ល។
- កែលម្អនិងអភិវឌ្ឍបន្ថែមទៀតនូវផលិតផលទេសចរណ៍ ដោយផ្តោតទៅលើតំបន់អាទិភាពទាំងបួន (តំបន់សៀមរាប-អង្គរ ភ្នំពេញ និងតំបន់ជុំវិញតំបន់ឆ្នេរ និងតំបន់ភូមិភាគឥសាន្ត) និងពង្រីកទៅកាន់តំបន់ផ្សេងៗ ទៀតនៅទូទាំងប្រទេស ។

**៤.៧៩** <u>សហគ្រាសតូចនិងមធ្យម</u> : សហគ្រាសតូចនិងមធ្យមជាធម្មតាស្ថិតនៅជាប់ប្រជាជនសាមញ្ញ និងផ្តល់ផលប្រយោជន៍ដល់សហគមន៍ជនបទក្នុងការកែច្នៃ និងតម្លៃបន្ថែមទៅលើផលិតផល ក៏ដូចជាការបង្កើតការងារ ។ សហគ្រាសតូចនិងមធ្យមផ្តល់ផងដែរនូវការតភ្ជាប់យ៉ាងសំខាន់ទៅនឹងវិស័យពាណិជ្ជកម្ម ក៏ដូចជា ទៅនឹងសហគ្រាសធំៗ ។ ដើម្បីជំរុញល្បឿននិងសម្រួលដល់សហគ្រាសតូចនិងមធ្យម រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការដូចខាងក្រោម :

- ដាក់ឱ្យមាននូវវិធានការទាំងឡាយ ដើម្បីឱ្យសហគ្រាសធុនតូចនិងមធ្យម និងមីក្រូសហគ្រាសដំណើរការក្នុងបរិស្ថានធុរៈកិច្ចមួយមានផលចំណេញ និងបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានរយៈពេលមធ្យម និងវែង ។
- បង្កើតប្រព័ន្ធពិសេសៗដើម្បីគាំទ្រស្ត្រីក្នុងធុរៈកិច្ច និងបង្កលក្ខណៈងាយស្រួលដល់ស្ត្រី ឱ្យអាចប្រើប្រាស់សេវាកម្មនិងកម្មវិធីនានានៃការអភិវឌ្ឍសហគ្រាសតូចនិងមធ្យម ។

- កាត់បន្ថយនីតិវិធីការចុះបញ្ជីក្រុមហ៊ុន និងជួយក្នុងដំណើរការនៃការចាប់ផ្តើមរបស់សហគ្រាសតូចនិងមធ្យម ។
- បង្កើតស្ថាប័នស្តង់ដារជាតិនិងស្ថាប័នផលិតភាព ដើម្បីជួយធានាគុណភាពនៃផលិតផលក្នុងស្រុកនិងបង្កើនផលិតភាព ។
- ជំរុញគាំទ្រសេវាប្រឹក្សាដល់សហគ្រាសតូចនិងមធ្យម ដើម្បីជួយអភិវឌ្ឍបច្ចេកវិទ្យាទំនើបនៅក្នុងផលិតកម្ម ការកែលម្អគុណភាពផលិតផល ការគ្រប់គ្រងនិងការស្វែងរកទីផ្សារ ។
- ជំរុញការបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងក្នុងស្រុកនិងក្រៅស្រុក ។
- ពង្រឹងក្របខ័ណ្ឌច្បាប់ ដោយបង្កើតច្បាប់នានាដែលពាក់ព័ន្ធនឹងរោងចក្រ តំបន់ឧស្សាហកម្ម ប៉ាតង់និងការបង្កើតមុខទំនិញថ្មីៗ ខ្នាតនិងរង្វាស់រង្វាល់ និងសុវត្ថិភាពឧស្សាហកម្ម ។
- លើកកម្ពស់កិច្ចសហប្រតិបត្តការ ជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការជំរុញសហគ្រាសតូចនិងមធ្យម ។

៤.៨០ <u>ឥណទានជនបទ</u> គឺជាកត្តាមួយសំខាន់សម្រាប់ការពង្រីកសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលំទូលាយសម្រាប់ការអភិវឌ្ឍជនបទ និងសម្រាប់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការគាំទ្រផលិតកម្មកសិកម្ម និងការបង្កើតនិងការពង្រីកធុរៈកិច្ច (ជាពិសេសសហគ្រាសតូចនិងមធ្យម) តាមរយៈការបង្កើនផលិតភាព ការបង្កើតចំណូលព្រមទាំងសម្រាប់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ។ មូលនិធិជាច្រើន ថែមទៀត គឺជាតម្រូវការចាំបាច់សម្រាប់ជួយបំពេញមួយផ្នែកលើតម្រូវការដ៏ធំក្នុងឥណទានជនបទ ។ បញ្ហាប្រឈមដ៏ចម្បងបំផុតគឺត្រូវស្វែងរកដំណោះស្រាយនិងមធ្យោបាយនានា ដែលតាមរយៈនេះ ឥណទានជនបទ អាចមានសម្រាប់ការប្រើប្រាស់ក្នុងអត្រាការប្រាក់មួយទាបច្រើនជាងអត្រាដែលមានបច្ចុប្បន្ន (៤៨ភាគរយក្នុងមួយឆ្នាំ) ។ ដើម្បីធានាឱ្យមានលទ្ធភាពច្រើនជាងមុននិងមានលក្ខណៈងាយស្រួលដល់អ្នកក្រ ក្នុងការទទួលបានឥណទាន ជាពិសេសសម្រាប់គោលបំណងធ្វើផលិតកម្ម រាជរដ្ឋាភិបាលនឹងចាត់វិធានការដើម្បីពង្រីកនិងបន្ថយចំណាយខ្ពស់សម្រាប់ឥណទានជនបទ តាមរយៈ :

- ការពិនិត្យពិចារណានិងការជំរុញលើកទឹកចិត្តឱ្យមានការបង្កើតស្ថាបន័ ដូចជា សហករណ៍អ្នកប្រើប្រាស់ដែលមាននៅក្នុងតំបន់មួយចំនួននៃទ្វីបអាស៊ី ។
- ការបង្វែរអង្គការក្រៅរដ្ឋាភិបាលដែលកំពុងដំណើរការការងារនេះ ឱ្យក្លាយជាប្រតិបត្តិករហិរញ្ញវត្ថុ ដែលមានការចុះបញ្ជីឈ្មោះត្រឹមត្រូវ (ដំណើរការនេះ បានចាប់ផ្តើមរួចមកហើយ ហើយអង្គការក្រៅរដ្ឋាភិបាលជាច្រើនត្រូវបានផ្តល់អាជ្ញាប័ណ្ណរួចហើយ) ។
- ការធ្វើឱ្យប្រសើរឡើងការត្រួតពិនិត្យស្ថាប័នទាំងនេះ ដើម្បីធានាថា ស្ថាប័នទាំងនេះពិតជាដំណើរការសមស្របទៅតាមគោលការណ៍ ។

- ការកាត់បន្ថយអត្រាការប្រាក់ដែលមានជាទូទៅ តាមរយៈបទពិសោធន៍ដ៏ល្អប្រសើរដែលធ្លាប់មានមក ហើយ ។

**៤.៨១** ការបង្កើតការងារនិងលក្ខខណ្ឌការងារល្អប្រសើរជាងមុន : ទិសដៅសំខាន់ៗក្នុងការងារនេះ គឺការបង្កើតកាលានុវត្តភាពការងារដែលមានសារៈប្រយោជន៍ ទាំងក្នុងផ្នែករៀបរយនិងទាំងក្នុងផ្នែកមិនរៀបរយ ការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ពលករមានគុណភាព និងការលុបបំបាត់រូបភាពអាក្រក់បំផុតនៃពលកម្មកុមារ ។ ឧស្សាហកម្មកាត់ដេរដែលកើនឡើងយ៉ាងឆាប់រហ័ស បានធ្វើឱ្យមានការប្រែប្រួលនៃស្ថានភាពការងារនៅទីប្រជុំជន តាមរយៈការបង្កើតនិងការធ្វើឱ្យមានស្ថេរភាពការងារដែលប្រើកម្លាំងពលកម្មច្រើន ជាពិសេស សម្រាប់ស្ត្រីក្មេងៗ ។ ក៏ដូចនៅក្នុងវិស័យផ្សេងៗទៀតដែរ គោលនយោបាយមួយដែលមានលក្ខណៈជាប្រព័ន្ធកំពុងត្រូវបានយកមកអនុវត្ត ដើម្បីបង្កើតការងារឱ្យបានច្រើនជាងមុន ជាពិសេស សម្រាប់ប្រជាជនក្មេងៗដែលកំពុងចូលខ្លួនក្នុងទីផ្សារពលកម្ម និងសម្រាប់ពលរដ្ឋកម្ពុជាទាំងអស់តាមរយៈវិធានការទាំងឡាយ ដូចខាងក្រោម :

- បង្កើនផលិតភាពកសិកម្ម ដើម្បីបង្កើតកាលានុវត្តភាពការងារនៅជនបទឱ្យបានច្រើនជាងមុន ដែលនឹងមានឥទ្ធិពលខ្លាំងទៅលើវិស័យជាច្រើន រួមបញ្ចូលទាំង តាមរយៈការបង្កើនតម្រូវការទំនិញ និងសេវាកម្មផ្សេងៗ ។
- លើកទឹកចិត្តការវិនិយោគផ្ទាល់ពីបរទេសនិងការវិនិយោគក្នុងស្រុកនៅក្នុងវិស័យអាទិភាព ជាពិសេស វិស័យកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មនិងគម្រោងដែលប្រើប្រាស់ពលកម្មច្រើន ព្រមទាំងវិស័យទេសចរណ៍ ។
- បង្កើតបណ្តាញអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជំនាញផ្សេងៗ ដើម្បីបម្រើដោយស្មើភាពគ្នាទាំងបុរសនិងទាំងស្ត្រី ជាពិសេស ជនក្រីក្រ ជនពិការ និងក្រុមជនដែលងាយរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ សម្រាប់រយៈពេលខ្លីនិងវែង ។
- រៀបចំបង្កើតមូលដ្ឋានទិន្នន័យកម្លាំងពលកម្មមួយ និងប្រព័ន្ធស្ថិតិមួយ ដោយមានទិន្នន័យដែលបំបែកលម្អិតជាច្រើនប្រភេទ ដូចជា តាមយេនឌ័រ ពិការភាព និងកត្តាផ្សេងៗទៀតដែលទាក់ទងនឹងសង្គមកិច្ច ។
- ជួយពលករកម្ពុជាក្នុងការស្វែងរកការងារនៅបណ្តាប្រទេសផ្សេងៗទៀត ។

**៤.៨២** ការធានាឱ្យមានលក្ខខណ្ឌនៃកន្លែងធ្វើការដែលមានសុវត្ថិភាព ត្រឹមត្រូវ និងមានអនាម័យល្អ និងលក្ខខណ្ឌកិច្ចសន្យាដែលត្រឹមត្រូវនិងយុត្តិធម៌សម្រាប់កម្លាំងពលកម្ម គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការងារ ហើយក៏ជាផ្នែកមួយដ៏សំខាន់នៃការងារផងដែរ ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងដោះស្រាយជាប្រចាំ នូវបញ្ហាទាំងអស់នេះ រួមមាន ការកម្រិតអប្បបរមានៃប្រាក់ឈ្នួលប្រចាំខែនិងថ្ងៃឈប់សម្រាក ការកាត់បន្ថយវិសមភាពក្នុងប្រាក់ឈ្នួលរវាងបុរសនិងស្ត្រី ដំណោះស្រាយជម្លោះនិងការមិនឯកភាពគ្នាតាមសន្តិវិធី ដោយមិនបង្កឡើងនូវ

ការអាក់ខានដល់សង្វាក់ផលិតកម្ម និងការបាត់បង់ប្រាក់ឈ្នួលរបស់និយោជិក ។ អាទិភាពទាំងឡាយក្នុងការងារនេះគឺ :

- ពង្រឹងយ៉ាងខ្លាំងក្លានូវការអនុវត្តច្បាប់ស្តីពីការងារនិងអនុសញ្ញាអន្តរជាតិ ដែលទាក់ទងទៅនឹងតួនាទីសហជីពកម្មករ ដើម្បីការពារសិទ្ធិនិងកាតព្វកិច្ចរបស់កម្មករ និយោជិត និងនិយោជក ។
- ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់កម្មករនិងនិយោជិត រួមបញ្ចូលទាំង កម្មករបម្លាស់ប្តូរទីលំនៅ ទាំងក្នុងនិងក្រៅប្រទេស និងកម្មករមានផ្ទៃពោះ ។
- បន្តនិងពង្រឹងការខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយសមាមាត្រនៃកុមារធ្វើការងារ (ពលកម្មកុមារ) ។
- ពង្រឹងការអនុវត្តច្បាប់ស្តីពីសន្តិសុខសង្គម ។
- បង្កើត " *បេឡាជាតិសន្តិសុខសង្គមមួយ* " ។
- ពិនិត្យជម្រើសដែលអាចធ្វើបាន សម្រាប់ការបង្កើតបេឡាសោធន ជាពិសេស សម្រាប់ជនពិការ និងអ្នកនៅក្នុងបន្ទុក និងការធានារ៉ាប់រងសម្រាប់គ្រោះថ្នាក់ការងារ ដូចមានចែងក្នុងច្បាប់ការងារ ។

**៤.៨៣** <u>បណ្តាញសុវត្ថិភាពសង្គម</u> : រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តផ្តល់នូវ<u>អន្តរាគមន៍សម្រាប់វិស័យសង្គមកិច្ច</u> ដែលក្នុងនោះរួមមាន (ក) ការកាត់បន្ថយភាពងាយរងគ្រោះរបស់អ្នកក្រ (ខ) វិធានការដើម្បីសម្រាលផលប៉ះពាល់នៃគ្រោះធម្មជាតិ (គ) ការជួយជនរងគ្រោះដោយសារបាតុភូតទាំងនោះ (ឃ) ការពង្រីកកម្មវិធីនីតិសម្បទានិងកម្មវិធីសមាហរណកម្មឡើងវិញសម្រាប់ជនពិការ សម្រាប់ជនដែលរងគ្រោះដោយគ្រឿងញៀន សម្រាប់ជនរងគ្រោះដោយសារការជួញដូរនិងកុមារដែលប្រព្រឹត្តខុសច្បាប់ ក៏ដូចជា ការពង្រីកកម្មវិធីសុខុមាលភាពសម្រាប់ជនចាស់ជរា កុមារកំព្រា មេម៉ាយនិងពោះម៉ាយក្រីក្រ គ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ ស្ត្រីរងគ្រោះជនគ្មានទីលំនៅដ្ឋាន និងអតីតយុទ្ធជននិងគ្រួសាររបស់ពួកគេ (ង) ការទប់ស្កាត់បទល្មើសនិងការការពារសុវត្ថិភាពសហគមន៍នៅថ្នាក់ឃុំ-សង្កាត់ ស្រុក-ខ័ណ្ឌ ខេត្ត-ក្រុង និងថ្នាក់ជាតិ ដោយសហការក្នុងភាពជាដៃគូអភិវឌ្ឍន៍ និងអ្នកមានចំណែកពាក់ព័ន្ធផ្សេងៗទៀត ។ យុទ្ធសាស្ត្រនិងសកម្មភាពជាអាទិភាព ទាំងឡាយដែលត្រូវអនុវត្តរួមមាន ការអនុម័តយកនិងការពង្រឹងការអនុវត្តច្បាប់សំខាន់ៗ និងការបង្កើតមជ្ឈមណ្ឌលនីតិសម្បទាសម្រាប់កុមារកំព្រា ជនអនាថាតាមផ្លូវ ជនពិការ ជនចាស់ជរា ព្រមទាំងស្ត្រីនិងកុមាររងគ្រោះដោយការជួញដូរ ។ ដោយសារបច្ចុប្បន្ននេះ បញ្ហាគ្រឿងញៀនបានក្លាយជាកង្វល់ដ៏ធំមួយ សម្រាប់សន្តិសុខ និងសុខុមាលភាពនៃសង្គមជាតិទាំងមូល វិធានការដើម្បីទប់ស្កាត់ ការផលិត ការហូរចូល ការលក់ដូរ និងការប្រើប្រាស់គ្រឿងញៀន នឹងត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់ដោយអាជ្ញាធរពាក់ព័ន្ធ ។

## ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

**៤.៨៤** ផ្នែកនេះបង្ហាញពីចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលភាគច្រើនគ្របដណ្តប់លើផ្នែកសង្គមកិច្ច ក្នុងនោះរួមមាន *អប់រំ សុខាភិបាល សមភាពយេនឌ័រ និងបញ្ហាប្រជាជន* ។

**៤.៨៥** ការអប់រំ : ការអប់រំត្រូវបានទទួលយកជាសកល ថាជាមូលដ្ឋានសិទ្ធិមនុស្សមួយដ៏សំខាន់ ។ ការអប់រំក៏ជាកត្តាចម្បងមួយផងដែរ ដែលផ្តល់វិភាគទានដល់ការកាត់បន្ថយភាពក្រីក្រ ។ ទិសដៅរយៈពេលវែង គឺដើម្បីធានាថា កុមារនិងយុវជនកម្ពុជាទាំងអស់មានឱកាសស្មើៗគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ដោយពុំគិតពីឋានៈក្នុងសង្គម តំបន់ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ ឬភាពពិការឡើយ ។ ការអប់រំនឹងបង្កើតឱ្យមានមោទនភាពចំពោះជាតិនិងចំពោះខ្លួនឯងក្នុងឋានៈជាពលរដ្ឋម្នាក់ មានកម្រិតសីលធម៌និងសុទិដ្ឋិនិយមខ្ពស់ ក៏ដូចជា មានការទទួលខុសត្រូវចំពោះប្រទេសជាតិនិងប្រជាជន ។ តួនាទីនៃការអប់រំ គឺដើម្បីលើកកម្ពស់គុណភាពសិស្ស-និស្សិត ដើម្បីក្លាយខ្លួនជាអ្នកមានផលប្រយោជន៍ និងការរស់នៅប្រកបដោយភាពសុខដុមរមនានៅក្នុងសង្គមមួយដែលស្ថិតនៅក្នុងបរិបទនៃសកលភាវូបនីយកម្ម ។

**៤.៨៦** វិស័យអប់រំគឺជាវិស័យមួយដែលត្រូវបានទទួលស្គាល់ថាសម្រេចបានជោគជ័យនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់កម្ពុជា ទាំងនៅក្នុងការងារកំណែទម្រង់ ទាំងនៅក្នុងការសម្រេចបាននូវសមិទ្ធផលទាំងឡាយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមជាច្រើននៅតែកើតមានឡើងនៅឡើយ ហើយនៅក្នុងចំណោមបញ្ហាប្រឈមទាំងនោះ មានជាអាទិ៍ ភាពចាំបាច់និងបន្ទាន់ក្នុងការលើកកម្ពស់គុណភាពនៃការអប់រំ ។ កិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីដែលមានចំណែកពាក់ពន្ធ័នានា មានការរីកចម្រើនច្រើនក្នុងរយៈពេលថ្មីៗកន្លងទៅនេះ ។ តាមរយៈបទពិសោធន៍ដែលទទួលបានក្នុងការអនុវត្ត *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-២០០៥ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០* មួយទៀត ត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកមានចំណែកពាក់ពន្ធ័ទាំងអស់ ហើយផែនការនេះបានបញ្ចូលនូវគោលដៅទាំងឡាយនៃ *ផែនការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-២០១៥* ។ ផែនការនេះ គឺជាក្របខ័ណ្ឌគោលនយោបាយនិងការអនុវត្តដ៏សំខាន់មួយ សម្រាប់ការកែលម្អស្ថានភាពរស់នៅរបស់អ្នកក្រ ដោយប្រើប្រាស់ការអប់រំជាកត្តាសំខាន់ក្នុងការលើកកម្ពស់ការអភិវឌ្ឍសង្គមនិងកំណើនសេដ្ឋកិច្ច ។ ការផ្តោតការយកចិត្តទុកដាក់ ត្រូវធ្វើឡើងនៅក្នុងការកែលម្អគុណភាពអប់រំនៅគ្រប់កម្រិតទាំងនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា បឋមភូមិ មធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា ។ ផ្នែកនេះ គូសបញ្ជាក់ពីចំណុចសំខាន់ៗនៃ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០* ដែលផ្តល់ព័ត៌មានលម្អិតជាងនេះ ។

**៤.៨៧** បង្អែករឹងមាំរបស់ប្រទេសជាតិមួយ គឺជា "*សំណុំដ៏សំខាន់*" នៃធនធានមនុស្សដែលមានការអប់រំ មានជំនាញ មានទេពកោសល្យ និងមានសមត្ថភាព នៅក្នុងវិស័យនានានៃផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច ។ នាពេលបច្ចុប្បន្ននេះ ការផ្តល់សេវាអប់រំនៅកម្រិតឧត្តមសិក្សា ជាពិសេស ការផ្តល់ដោយផ្នែកឯកជន ហាក់ដូចជាមិនទាន់មានតុល្យភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លីនៃទីផ្សារ ដូចជា តម្រូវការបន្ទាន់នូវបុគ្គលិកគ្រប់គ្រងថ្នាក់ទាបនិងថ្នាក់មធ្យម ។ ការបន្សុីគ្នាមិនត្រឹមត្រូវរវាងទិដ្ឋាភាពការងាររយៈពេលវែងនិងការសិក្សា កំពុងតែនៅកើតមានឡើង ។ ដើម្បីឱ្យមានការរីកចម្រើននិងរក្សាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ប្រទេសជាតិត្រូវការមុខជំនាញជាច្រើន ដូចជា អ្នកវិទ្យាសាស្ត្រ វិស្វករ អ្នកស្រាវជ្រាវ និងអ្នកឯកទេស នៅតាមផ្នែកនានានៃសេដ្ឋកិច្ច-សង្គមកិច្ច ។ បញ្ហាប្រឈមនៅក្នុងវិស័យអប់រំ គឺត្រូវផ្តល់សេវាកម្មនានាសម្រាប់ការអប់រំចាំបាច់ប្រកបដោយគុណភាពខ្ពស់នៅក្នុងគ្រប់វិស័យ តាមរយៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេទេស និងការអប់រំកម្រិតឧត្តមសិក្សា ហើយត្រូវមានសមត្ថភាពទាក់ទាញនិស្សិតឱ្យមកចូលរួមក្នុងវគ្គសិក្សាទាំងនេះ ។ ចំពោះបញ្ហានេះ តួនាទីរបស់ *គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា* គឺមានសារៈសំខាន់ក្នុងការវាយតម្លៃនិងទទួលស្គាល់គុណភាពតែចំពោះមហាវិទ្យាល័យទាំងឡាយណា ដែលមានលក្ខណៈវិនិច្ឆ័យផ្នែកគុណភាពជាអប្បបរមា និងមានសារៈសំខាន់សម្រាប់ការរៀបចំបង្កើតឡើងនូវ *យុទ្ធសាស្ត្រអប់រំឧត្តមសិក្សា* ដ៏ទូលំទូលាយមួយ ។

**៤.៨៨** នៅក្នុងចំណោមអាទិភាពទាំងឡាយនៃ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០* និងគោលនយោបាយសំខាន់ៗ ការងារដែលត្រូវធ្វើ ជាអាទិ៍មាន :

- ការធានាឱ្យមានលទ្ធភាពចូលរៀនប្រកបដោយភាពងាយស្រួលនិងសមធម៌ ជាពិសេស សម្រាប់អ្នកក្រ ក្មេងស្រី ជនជាតិភាគតិច និងកុមារក្រីក្រ ក៏ដូចជា ប្រជាជនរស់នៅក្នុងតំបន់ដែលអត្រាភាពក្រីក្រខ្ពស់ ។
- សកលកម្មនៃការអប់រំមូលដ្ឋាន ៩ឆ្នាំ និងលើកកម្ពស់កាលានុវត្តភាពជីវិតរស់នៅ ។
- ការបង្កើនគុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ ដោយរាប់បញ្ចូលទាំង តាមរយៈការធ្វើទំនើបកម្ម និងកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព ។
- ការផ្សារភ្ជាប់ការអប់រំនិងការបណ្តុះបណ្តាល ទៅនឹងទីផ្សារពលកម្មរយៈពេលវែងនិងមធ្យម និងទៅនឹងសង្គម រួមបញ្ចូលទាំង ការអប់រំឱ្យមានជំនាញសម្រាប់ការរស់នៅនិងសុខភាពល្អ និងការអប់រំអំពីការការពារមេរោគហ៊ីវ/ជម្ងឺអេដស៍ ។
- ការអភិវឌ្ឍបន្ថែមទៀតក្នុងវិស័យយុវជននិងកីឡា ដោយបង្កើនការយកចិត្តទុកដាក់ចំពោះយុវជនក្នុងគ្រប់មុខជំនាញ ។
- ការអភិវឌ្ឍនិងការកសាងសមត្ថភាពស្ថាប័ន សម្រាប់ការងារវិមជ្ឈការ ។

**៤.៨៩** ក្នុងពេលថ្មីៗនេះ វឌ្ឍនភាពសំខាន់ៗមួយចំនួនត្រូវបានធ្វើឱ្យសម្រេចឡើង ក្នុងការបង្កើនកម្រិតចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ (បញ្ចប់ការសិក្សាជាមូលដ្ឋាន ៩ឆ្នាំ) ប៉ុន្តែទោះជាដូចនេះក្តី គម្លាតធំចំពោះអ្នកក្រខ្លាំងនិងនៅតំបន់ដាច់ស្រយាល នៅតែមាននៅឡើយ ។ នៅពេលដែលកម្រិតនៃការចុះឈ្មោះចូលរៀននិងផលធៀបយេនឌ័រនៅកម្រិតបឋមសិក្សា អាចសម្រេចបាន ១០០ភាគរយ នៃគោលដៅនៅមុនឆ្នាំ២០១៥ កម្រិតនៃការចុះឈ្មោះចូលរៀន និងផលធៀបយេនឌ័រនៅកម្រិតមធ្យមសិក្សា នឹងមិនអាចសម្រេចបាន ១០០ភាគរយតាមចំណុចដៅ បើមិនមានការខិតខំប្រឹងប្រែងរួមគ្នានោះទេ ។ គោលដៅសំខាន់ៗចំពោះមុខរបស់វិស័យអប់រំរួមមាន :

- កាត់បន្ថយចំងាយផ្លូវ ដែលកុមារធ្វើដំណើរពីផ្ទះមកកាន់សាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ តាមរយៈ ការសាងសង់និងបើកសាលារៀននៅជិតភូមិដែលកុមាររស់នៅ ជាពិសេស នៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ។
- បង្កលក្ខណៈងាយស្រួល ដើម្បីឱ្យកុមារីបានចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិនិងកម្រិតសិក្សាខ្ពស់ជាង ។
- កាត់បន្ថយការចំណាយរបស់ឪពុកម្តាយសិស្សក្នុងការចុះឈ្មោះចូលរៀន និងធានាឱ្យមានការចូលរៀន និងការសិក្សារបស់កុមារក្រីក្រ ហើយតាមរយៈនេះ នឹងធានាឱ្យមានការកាត់បន្ថយកម្លាំងពលកម្មកុមារផងដែរ ។
- បង្កើនគុណភាពអប់រំឱ្យដល់និងក្រោយកម្រិតអប់រំមូលដ្ឋាន រាប់បញ្ចូលទាំងការកែសម្រួលកម្មវិធីសិក្សា និងការដាក់បញ្ចូលស្តង់ដារអប្បបរមានៃលទ្ធផលនៃការសិក្សារបស់សិស្ស និងប្រព័ន្ធវាយតម្លៃការសិក្សារបស់សិស្ស សម្រាប់ថ្នាក់ទី៣ ថ្នាក់ទី៦ និងថ្នាក់ទី៩ ។ ការអភិវឌ្ឍគ្រូបង្រៀន និងការកំណត់ប៉ុស្តិ៍បំពេញការងារគ្រូ ការធានាគុណភាព និងប្រព័ន្ធវាយតម្លៃនិងទទួលស្គាល់គុណភាព ។

**៤.៩០** ទន្ទឹមនឹងពេលដែលយុទ្ធសាស្ត្ររយៈពេលវែងមួយត្រូវបានរៀបចំឡើង ហើយការវិនិយោគត្រូវបន្តធ្វើសម្រាប់វឌ្ឍនភាពនៅកម្រិតមធ្យមសិក្សា ឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងដំណាក់កាល *ផយអជ* គោលដៅនិងចំណុចដៅសំខាន់ៗ ជាអាទិ៍មាន :

## តារាង៤.៤ : វិស័យអប់រំ : គោលដៅនិងចំណុចដៅសំខាន់ៗ

| ចំណុចដៅ និងសូចនាករ | | ២០០៥ | ២០១០ | ២០១៥ |
|---|---|---|---|---|
| ១ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា (ថ្នាក់ទី១ដល់ថ្នាក់ទី៦) សរុប-សិស្សប្រុស-សិស្សស្រី (%) | ៩១.៩-៩៣.០-៩០.៧ | ១០០ (ទាំងអស់) | |
| ២ | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧ដល់ថ្នាក់ទី៩) សរុប សិស្សប្រុស សិស្សស្រី (%) | ២៦.១-២៧.១-២៤.៨ | ៧៥ (ទាំងអស់) | ១០០ (ទាំងអស់) |
| ៣ | អត្រាគង់វង្ស : ថ្នាក់ទី១ដល់ថ្នាក់ទី៦ | ៥៣.១ | ១០០ | |
| ៤ | អត្រាគង់វង្ស : ថ្នាក់ទី១ដល់ថ្នាក់ទី៩ | ៣០.១៨ | ៥០ | ១០០ |
| ៥ | អក្ខរកម្មអ្នកដែលមានអាយុពី ១៥-២៤ឆ្នាំ (%) | ៨៣.៤ | ៩៥ | ១០០ |

**៤.៩១** យុទ្ធសាស្ត្រចំបងៗនិងសកម្មភាពសំខាន់ៗរបស់វិស័យអប់រំ ដើម្បីសម្រេចគោលដៅទាំងនេះ និងគោលដៅផ្សេងៗទៀត រួមមាន :

- បង្កើនចំនួនកុមារថ្នាក់មត្តេយ្យសិក្សា ដែលចូលរៀនក្នុងកម្មវិធីអប់រំសម្រាប់កុមារតូចៗ ដែលបានរៀបចំឡើងនៅក្នុងសាលា សហគមន៍ និងតាមផ្ទះ ។
- បង្កើនចំនួនសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ជាពិសេស នៅតំបន់ដាច់ស្រយាល និងតំបន់ដែលទទួលសេវាកម្មមិនគ្រប់គ្រាន់ ។
- បង្កើនចំនួនគ្រូបង្រៀន ទាំងគ្រូប្រុសនិងគ្រូស្រីនៅគ្រប់កម្រិតសិក្សាទាំងនោះ ដើម្បីលើកកម្ពស់ផលធៀបសិស្ស-គ្រូ និងសមាមាត្របុគ្គលិកសិក្សាស្រី ជាពិសេស ការផ្តល់ប្រាក់លើកទឹកចិត្ត សម្រាប់ការបំពេញការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ។
- លើកកម្ពស់គុណភាពគ្រូបង្រៀន តាមរយៈការអភិវឌ្ឍមុខរបរវិជ្ជាជីវៈ ដែលផ្សារភ្ជាប់ទៅនឹងការផ្តល់ប្រាក់លើកទឹកចិត្ត សម្រាប់ការបំពេញការងារ ។
- យកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើនប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន (បាននឹងកំពុងដំណើរការ) និងបើកប្រាក់បៀវត្សរ៍ឱ្យទាន់ពេលវេលា ។
- ធានាគុណភាពអប់រំ តាមរយៈការកែលម្អការផ្តល់នូវសៀវភៅសិក្សា សម្ភារៈសិក្សា បរិក្ខារអប់រំ បណ្ណាល័យ និងបន្ទប់ពិសោធន៍ ។
- រៀបចំឱ្យមានស្តង់ដារគុណភាពសម្រាប់គ្រប់កម្រិត និងប្រព័ន្ធវាយតម្លៃថ្នាក់ជាតិមួយសម្រាប់ការអប់រំមូលដ្ឋាន ។

- បង្កើនចំនួនអន្តេវាសិកដ្ឋានដែលមានសុវត្ថិភាពសម្រាប់សិស្សស្រីដែលមកពីតំបន់ឆ្ងាយៗ ដើម្បីមករៀននៅសាលាមធ្យមសិក្សាបឋមភូមិដែលជិតបំផុត នៅលើមូលដ្ឋាននៃគម្រោងសាកល្បងជាគំរូដែលបាន និងកំពុងដំណើរការរួចហើយ ។
- កាត់បន្ថយបន្ទុកចំណាយរបស់សិស្សក្រីក្រ ជាពិសេសសិស្សស្រី តាមរយៈការផ្តល់អាហារូបករណ៍ (នៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា) និងការលុបបំបាត់ការបង់ប្រាក់ក្រៅផ្លូវការគ្រប់ប្រភេទទៅឱ្យគ្រូ ។
- ពង្រីកនិងកំណត់មុខសញ្ញាឱ្យបានល្អជាងមុនសម្រាប់កម្មវិធីផ្តល់អាហារសម្រន់នៅបឋមសិក្សា និងកម្មវិធីលើកទឹកចិត្តសម្រាប់សិស្សថ្នាក់ទី៧ ដល់ទី៩ ។
- បន្តធានាឱ្យមានការវិភាជន៍ឱ្យបានគ្រប់គ្រាន់និងការផ្តល់ឱ្យបានទាន់ពេលវេលានូវថវិកាចរន្ត សម្រាប់វិស័យអប់រំ ជាពិសេស សម្រាប់ការអប់រំមូលដ្ឋាន ។
- បង្កើននិងកែលម្អកម្មវិធីអក្ខរកម្មសម្រាប់ប្រជាជនពេញវ័យ ជាពិសេស សម្រាប់ស្ត្រី ។

**៤.៩២** <u>សុខាភិបាល</u> **:** ការលើកកម្ពស់ស្ថានភាពសុខភាពរបស់ប្រជាជនគឺជាអាទិភាពមួយខ្ពស់បំផុត ។ ការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ ក៏ដូចជា សុខភាពបន្តពូជ សុខភាពមាតានិងកុមារ ការលុបបំបាត់មូលហេតុបណ្តាលនៃជម្ងឺ ការចាត់វិធានការបង្ការ និងការផ្តល់ការព្យាបាលដែលចាំបាច់ គឺមានសារៈសំខាន់ ក្នុងការលើកកម្ពស់ស្ថានភាពសុខភាពនៃប្រជាជនជាទូទៅ ជាពិសេស ជនងាយរងគ្រោះដែលគ្មានមធ្យោបាយ ដើម្បីទទួលបានសេវាទាំងនោះ ។ កត្តាអន្តរវិស័យនិងកត្តាផ្សេងទៀតជាច្រើនដែលប៉ះពាល់ដល់ស្ថានភាពសុខភាពរបស់ប្រជាជន មានជាអាទិ៍ (ក) ភាពក្រីក្រជាមូលហេតុនិងបច្ច័យអាក្រក់នៃសុខភាពមិនល្អ (ខ) ការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកក្រ ដែលរារាំងមិនឱ្យពួកគាត់មានលទ្ធភាពទទួលសេវាសុខាភិបាលសាធារណៈ (គ) ការកែលម្អគុណភាពទឹកនិងសេវាអនាម័យ (ឃ) ការអប់រំប្រសើរជាងមុននិងកម្រិតអក្ខរកម្មខ្ពស់ជាងមុន ក៏ដូចជាលទ្ធភាពទទួលបានព័ត៌មាន និងការយល់ដឹងច្រើនជាងមុន (ង) សមធម៌យេនឌ័រ (ច) បណ្តាញសុវត្ថិភាពសង្គមសម្រាប់អ្នកក្រនិងអ្នកងាយរងគ្រោះ (ឆ) ការផ្តល់អាហារូបត្ថម្ភល្អជាងមុន តាមរយៈ ការធ្វើអន្តរាគមន៍សមស្រប ។ល។

**៤.៩៣** *ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលឆ្នាំ២០០៣-២០០៧* ដែលនឹងត្រូវបន្តរហូតដល់ឆ្នាំ២០១០ បន្ទាប់ពីការត្រួតពិនិត្យឡើងវិញនៅឆ្នាំ២០០៦ (នៅពេលដែលមានទិន្នន័យការកែសម្រួលរួចតាមរយៈអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា) ផ្តល់នូវក្របខ័ណ្ឌសកម្មភាពដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចបាននូវអាទិភាពនានា ដែលក្នុងនោះរួមមាន (ក) ការផ្តល់សេវាសុខាភិបាល (ខ) ការផ្លាស់ប្តូរឥរិយាបទ (គ) ការកែលម្អគុណភាព (ឃ) ការអភិវឌ្ឍធនធានមនុស្ស (ង) ហិរញ្ញប្បទានសុខាភិបាល (ច) ការអភិវឌ្ឍស្ថាប័ន ។ *ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល* គឺជាក្របខ័ណ្ឌនៃការណែនាំតម្រង់ទិស សម្រាប់គ្រប់សកម្មភាពទាំងអស់ក្នុងវិស័យ

សុខាភិបាល ការរៀបរាប់ខាងក្រោមនេះ (រួមបញ្ចូលទាំងសូចនាករនៅក្នុងតារាង ៤.៥) គឺគ្រាន់តែលើកមក បង្ហាញបញ្ហាសំខាន់ៗមួយចំនួនតែប៉ុណ្ណោះ ពុំបានធ្វើការបញ្ជាក់លម្អិតនោះទេ ។

**៤.៩៤** សុខាភិបាល គឺជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាពទាំងបួនរបស់ *កម្មវិធីសកម្មភាពអាទិភាព* ដែលធានាបាននូវការធ្វើវិភាជន៍និងការផ្តល់ថវិកាទាន់ពេលវេលា ទាំងចំណាយចរន្តនិងមូលធន ។ តែទោះជាដូចនេះក្តី នៅក្នុងការប្រើប្រាស់ថវិកាជាក់ស្តែង ថ្នាក់ជាតិហាក់ដូចជាប្រើប្រាស់ចំណែកមួយធំជាងនៅថ្នាក់ខេត្តនិងថ្នាក់ក្រោមបន្តបន្ទាប់ ។ ដោយសារអ្នកផ្តល់សេវាច្រើន ទាំងផ្នែករដ្ឋនិងទាំងផ្នែកឯកជន ហើយការចំណាយដែលកើតមានដោយបុគ្គលម្នាក់ៗ ដែលពួកគេភាគច្រើនជាអ្នកក្រីក្របំផុត ធ្វើឱ្យមានការពិបាកណាស់ដើម្បីកែតម្រូវការប៉ាន់ប្រមាណចំណាយឱ្យបានត្រឹមត្រូវលើការថែទាំសុខភាពនៅកម្ពុជា ប៉ុន្តែផ្អែកលើមូលដ្ឋានមួយចំនួន ការចំណាយនៅតែមានកម្រិតទាបនៅឡើយ ប្រហែល ៣៣ដុល្លារអាមេរិកក្នុងប្រជាជនម្នាក់ ។ " *មូលនិធិសមធម៌* " ត្រូវបានចាប់ផ្តើមអនុវត្ត ដើម្បីបំពេញបន្ថែមពីលើប្រព័ន្ធមិនទូទាត់ថ្លៃព្យាបាលជម្ងឺដែលមានស្រាប់ និងដើម្បីកែលម្អលទ្ធភាពប្រើប្រាស់នូវប្រព័ន្ធថែទាំសុខភាព ។ គម្រោងសាកល្បងចំនួន ១៧ កំពុងដំណើរការក្នុងចំណោមខេត្ត-ក្រុងចំនួន ១៣ ហើយ *មូលនិធិសមធម៌* នឹងត្រូវបង្កើនកម្រិត នៅក្នុងពេលដ៏ខ្លីខាងមុខ ។ ទោះបីជាដូចនេះក្តី វិធីសាស្ត្រជាច្រើនទៀតប្រកបដោយចីរភាពជាង សម្រាប់ជួយអ្នកក្រនៅក្នុងរយៈពេលវែង ត្រូវតែបានយកមកគិតគូរពិចារណា ។ ដើម្បីឈានទៅសម្រេចបាននូវការកែលម្អគុណភាព ការការពារនិងការថែរក្សាសុខភាព គម្រោង *សំណុំសកម្មភាពអប្បបរមា* និង *គម្រោងសំណុំសកម្មភាពបង្គ្រប់* ត្រូវបាននិងកំពុងដាក់ឱ្យដំណើរការ ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន បាននឹងកំពុងអនុវត្តកិច្ចសន្យាគម្រោងសាកល្បងនៅក្នុងស្រុកប្រតិបត្តិចំនួន ១១ ដើម្បីធានាផ្តល់ឱ្យបានសមរម្យនូវការថែទាំសុខភាព ជាពិសេស នៅតំបន់អ្នកក្រីក្រនិងអ្នករស់នៅតំបន់ដាច់ស្រយាល ដើម្បីឱ្យបានដល់ដៃជនងាយរងគ្រោះនៅតំបន់នោះ ។ គម្រោងទាំងអស់នេះ នឹងត្រូវពង្រីកទៅកាន់តំបន់ផ្សេងៗទៀត ។

## តារាង៤.៥ : វិស័យសុខាភិបាល : គោលដៅ និងចំណុចដៅអាទិភាព

| | ចំណុចដៅ និងសូចនាករ | ២០០៥ | ២០១០ | ២០១៥ |
|---|---|---|---|---|
| ១ | អត្រាមរណភាពទារក ក្នុង ១.០០០កំណើតរស់ | ៦៦ | ៦០ | ៥០ |
| ២ | អត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ ក្នុង ១.០០០កំណើតរស់ | ៨២ | ៧៥ | ៦៥ |
| ៣ | អត្រាមរណភាពមាតា ក្នុង ១០០.០០០កំណើតរស់ | ពុំមានតួលេខ | ២៤៣ | ១៤០ |
| ៤ | ប្រេវ៉ាឡង់ហ៊ីវ/អេដស៍ %នៃមនុស្សពេញវ័យ អាយុ ១៥-៤៩ឆ្នាំ | ១,៩ | ១,៩ | ១,៨ |
| ៥ | កាត់បន្ថយអត្រាស្លាប់ជម្ងឺគ្រុនចាញ់ % | ០,៣៦ | ០,២៥ | ០,១ |
| ៦ | កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជម្ងឺរបេងសួតវិជ្ជមាន BK ក្នុង ១០០.០០០នាក់ | ពុំមានតួលេខ | ២១៤ | ១៣៥ |

*ទិន្នន័យនឹងមានការផ្លាស់ប្តូរទៅតាមលទ្ធផលអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជាឆ្នាំ២០០៥*

**៤.៩៥** សកម្មភាពនិងយុទ្ធសាស្ត្រជាអាទិភាព ដើម្បីអនុវត្តនៅក្នុងវិស័យសុខាភិបាល រួមមាន :

- បង្កើនល្បឿនកំណែទម្រង់នៅគ្រប់ផ្នែកទាំងអស់ ។
- ព្យាយាមនិងសម្រេចការសម្របសម្រួលប្រសិទ្ធភាពចំណាយ ឱ្យបានប្រសើរនៅក្នុងកម្មវិធីត្រួតពិនិត្យជម្ងឺ តាមរយៈខ្សែបណ្តោយនិងយន្តការបែងចែកសេវាសុខាភិបាល ។
- លើសពីនេះទៀត ពង្រីកនិងពង្រឹងមូលនិធិសមធម៌សុខាភិបាល ដើម្បីជួយអ្នកក្រីក្រឱ្យអាចប្រើប្រាស់សេវាសុខភាពសាធារណៈបាន ស្រាវជ្រាវដើម្បីស្វែងរកមធ្យោបាយនានាប្រកបដោយចីរភាពក្នុងការជួយអ្នកក្រីក្រ ដើម្បីមានភាពងាយស្រួលក្នុងការទទួលបាននូវប្រព័ន្ធថៃទាំសុខភាព ដោយមិនបាច់បង់ថ្លៃព្យាបាល ឬតាមរយៈនៃជំនួយរូបិយវត្ថុដែលមានគោលដៅច្បាស់លាស់ ។
- ជាទូទៅ ធ្វើសនិទានកម្មប្រព័ន្ធស្តារចំណាយឡើងវិញ ដើម្បីធានាឱ្យមានការអនុវត្តល្អប្រសើរបំផុត ។
- ស្វែងរកវិធីនិងមធ្យោបាយនានា ដើម្បីកែលម្អឱ្យបានប្រសើរឡើងនូវហិរញ្ញប្បទានសម្រាប់មន្ទីរពេទ្យ ។
- បង្កើនការជ្រើសរើសនិងការបណ្តុះបណ្តាលឆ្មប និងធានាការបែងចែកពួកគេឱ្យទៅបម្រើការងារនៅតំបន់ដែលមានតម្រូវការ ។
- បង្កើនសមាមាត្រនៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ និងលើកកម្ពស់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្រាលកូនដោយការវះកាត់ ។
- កែលម្អសុខភាពកុមារ តាមរយៈការគ្របដណ្តប់ជាទូទៅ នៃអន្តរាគមន៍របស់កម្មវិធី *ប័ណ្ណពិន្ទុសម្រាប់ការតមវង្សនៃកុមារ* រួមបញ្ចូលទាំង អន្តរាគមន៍ផ្នែកអាហារូបត្ថម្ភ និងកម្មវិធី *ការគ្រប់គ្រងចម្រុះនៃជម្ងឺវ័យកុមារ* ។
- កែលម្អសេវានិងព័ត៌មានពីសុខភាពបន្តពូជ រួមទាំង ការពន្យារកំណើត និងដោះស្រាយបញ្ហានិងសេវាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ របស់យុវជន ។
- ពិនិត្យស្វែងរកលទ្ធភាពក្នុងការពង្រីកកម្មវិធីអ្នកស្ម័គ្រចិត្តតាមភូមិដែលមានបច្ចុប្បន្ន សម្រាប់ការថៃទាំសុខភាពទាក់ទងនឹងជម្ងឺគ្រុនចាញ់ ដើម្បីផ្តល់ការការពារនិងថែរក្សាសុខភាព តាមរយៈ បុគ្គលិកសុខាភិបាលតាមភូមិដែលមានតម្លៃពលកម្មទាប ដែលត្រូវបានជ្រើសរើសដោយសហគមន៍ និងចែករំលែកចំណេះដឹងអប្បបរមាស្តីពីការថៃទាំសុខភាព ។
- សាងសង់ឬស្តារឡើងវិញ និងកែសម្រួលមណ្ឌលសុខភាពបន្ថែមទៀត (ថ្នាក់ស្រុកនិងឃុំ) និងមន្ទីរពេទ្យបង្អែកថ្នាក់ស្រុក ជាពិសេស នៅតំបន់ក្រីក្របំផុត ។
- លើកកម្ពស់ការអប់រំ និងសេវាសង្គ្រោះបន្ទាន់ ។
- ពង្រឹងការអនុវត្តបទបញ្ញត្តិនិងច្បាប់សុខាភិបាល ដែលទាក់ទងនឹងវេជ្ជសាស្ត្រនិងឱសថ ព្រមទាំងសុវត្ថិ-ភាពចំណីអាហារផងដែរ ។

- ធានាផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់វិស័យសុខាភិបាល ។
- បង្កលក្ខណៈងាយស្រួលនិងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ក្នុងការផ្តល់សេវាសុខភាព ទាំងនៅទីប្រជុំជន និងទាំងនៅទីជនបទ ។

**៤.៩៦** <u>មេរោគហ៊ីវ/ជម្ងឺអេដស៍</u> **:** ការការពារ ការព្យាបាល ការថែទាំ និងការខិតខំកាត់បន្ថយផលប៉ះពាល់ពីមេរោគហ៊ីវ/ជម្ងឺអេដស៍ គឺជាកត្តាសំខាន់រួមចំណែកដល់គោលដៅរួមនៃ *ផយអជ* ក្នុងការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច ។ កិច្ចប្រឹងប្រែងរួមគ្នា បានធ្វើឱ្យមានការថយចុះប្រេវ៉ាឡង់បន្ទាប់ពីមានការសង្កេតមើលចាប់តាំងពីឆ្នាំ១៩៩៧ ការពង្រីកសេវាកម្មយ៉ាងឆាប់រហ័សសម្រាប់ប្រជាជនដែលមានផ្ទុកមេរោគហ៊ីវ តាមរយៈបន្តការថែទាំ បង្កើនកម្រិតយល់ដឹងអំពីមេរោគហ៊ីវដល់ប្រជាជនទាំងអស់ និងការផ្លាស់ប្តូរបរិយាកាសគោលនយោបាយ ដូចជា ការអនុម័តិច្បាប់ស្តីពីការការពារនិងការត្រួតពិនិត្យមេរោគហ៊ីវ/ជម្ងឺអេដស៍ ។ ប៉ុន្តែ ធម្មតាការប្រែប្រួលនៃជម្ងឺរាតត្បាត ប្រមូលផ្តុំលើក្រុមដែលមានហានិភ័យខ្ពស់ ដែលរាលដាលក្នុងចំណោមប្រជាជន ទូទៅចាំបាច់ត្រូវពង្រឹងបន្ថែមទៀតនូវការទទួលខុសត្រូវនៅថ្នាក់ជាតិចំពោះមេរោគហ៊ីវ/ជម្ងឺអេដស៍ ។ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហាពហុវិស័យ ដែលបានណែនាំតាមរយៈ *ផយអជ សម្រាប់ការឆ្លើយតបយ៉ាងទូលំទូលាយលើមេរោគហ៊ីវ/ជម្ងឺអេដស៍ ឆ្នាំ២០០៦-២០១០* ជាមួយនឹងការឆ្លើយតបយ៉ាងខ្លាំងក្លាតាមលក្ខណៈវិមជ្ឈការ ។ អាទិភាពសំខាន់ៗ រួមមាន :

- ជំរុញកម្មវិធីលើកទឹកចិត្តឱ្យបានទូលំទូលាយ ចំពោះបុរស ស្ត្រីក្នុងការប្រើប្រាស់ស្រោមអនាម័យ និងជំរុញសកម្មភាពប្រើប្រាស់ស្រោមអនាម័យសម្រាប់ប្រជាជនទូទៅ ដែលធ្វើសកម្មភាពផ្លូវភេទ រួមមាន ស្ត្រីមនុស្សពេញវ័យ និងយុវវ័យ ។
- ទប់ស្កាត់ការឆ្លងនៃមេរោគហ៊ីវ/ជំងឺអេដស៍ ទៅលើគ្រួសារ តាមរយៈកម្មវិធីព័ត៌មាន ការអប់រំ ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់ជាលក្ខណៈបុគ្គល ។
- បង្កើននិងកែលម្អសេវាគាំទ្រ និងសេវាថែទាំសុខភាព ដែលមានផលប៉ះពាល់ដោយមេរោគហ៊ីវ/ជម្ងឺអេដស៍ ។

**៤.៩៧** <u>សមភាពយេនឌ័រ</u> : រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកស្ត្រីមានតួនាទីសំខាន់នៅក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជា ។ ផែនការយុទ្ធសាស្ត្រសម្រាប់ស្ត្រី *"នារីរតនៈ"* ឬ *"ស្ត្រីគឺជាត្បូងមានតម្លៃ"* នឹងបន្តនូវភាពខ្លាំងក្លាក្នុងគោលបំណងផ្តល់ជូនស្ត្រីកម្ពុជានូវតម្លៃនិងក្តីសង្ឃឹមក្នុងជីវិត តាមរយៈ ការបញ្ជ្រាបយេនឌ័រនៅគ្រប់សកម្មភាពទាំងអស់ ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់លើការលើកទឹកចិត្ត និងការលើកកម្ពស់ស្ថានភាពសង្គមរបស់ស្ត្រីដោយផ្តោតការយកចិត្តទុកដាក់លើការអនុវត្តយុទ្ធសាស្ត្រយេនឌ័រ ការកសាងសមត្ថភាពស្ត្រីលើគ្រប់វិស័យ ការផ្លាស់

ឬទតិរិយាបថសង្គមដែលមានការរើសអើងប្រឆាំងនឹងស្ត្រី និងការធានានូវសិទ្ធិរបស់ស្ត្រីឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមយ៉ាងសកម្ម និងដោយស្មើភាពក្នុងការកសាងប្រទេសជាតិ ។

**៤.៩៨** បញ្ហាសំខាន់បំផុតដើម្បីកាត់បន្ថយភាពក្រីក្រ គឺការលុបបំបាត់យ៉ាងឆាប់នូវរាល់ឧបសគ្គចំពោះមុខ និងដែលជាប់ពាក់ព័ន្ធនឹងវិសមភាពយេនឌ័រ ដូចជា វិសមភាពក្នុងការទទួលបានការអប់រំ ថ្លៃឈ្នួលការងារ ភាពជាម្ចាស់កម្មសិទ្ធិក្នុងការកាន់កាប់ដីធ្លី ការថែរក្សាសុខភាពបន្តពូជរបស់ពួកគេ ភាពងាយទទួលរងគ្រោះដោយសារមេរោគហ៊ីវ ជម្ងឺអេដស៍ និងការជួញដូរស្ត្រី និងការធ្វើការងារដែលមិនទទួលបានផលប្រយោជន៍ជាទូទៅ ទាំងក្នុងគ្រួសារនិងសង្គម នៅពេលជាមួយគ្នានេះដែរ ការទទួលបន្ទុកដ៏ធ្ងន់ធ្ងរក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។ ខណៈពេលដែលស្ត្រីជាច្រើនជាកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្ម ដោយសារបច្ចុប្បន្នវិស័យកាត់ដេរីកចម្រើនយ៉ាងឆាប់រហ័ស ទោះបីជាស្ត្រីដ៏ច្រើនលើសលប់ជាកម្លាំងពលកម្មដែលមានកម្រិតទាប ក៏តំណាងរបស់ស្ត្រីនៅក្នុងកម្រិតអ្នកតាក់តែងគោលនយោបាយនិងការធ្វើសេចក្ដីសម្រេចចិត្ត រួមមានរដ្ឋសភាជាតិ និងស្ថាប័នប្រជាធិបតេយ្យផ្សេងៗ មន្ត្រីរាជការ និងផ្នែកផ្សេងៗទៀតនៅមានកម្រិតទាបនៅឡើយ ហើយត្រូវទាមទារធ្វើការកែលម្អដោយយកចិត្តទុកដាក់ ។

**៤.៩៩** ដោយសារយេនឌ័រជាបញ្ហាអន្តរវិស័យ និងជាការទទួលខុសត្រូវរបស់គ្រប់ស្ថាប័នទាំងអស់ បញ្ហានិងយុទ្ធសាស្ត្រដើម្បីដោះស្រាយវិសមភាពយេនឌ័រត្រូវបានបង្ហាញ រួចមកហើយនៅក្នុងវិស័យផ្សេងៗដូចជា កសិកម្ម ការងារ អប់រំ សុខាភិបាល និងផ្នែកផ្សេងៗទៀតនៅផ្នែកខាងដើមនៃជំពូកនេះ ។ ចំនួនដ៏ច្រើននិងទិដ្ឋភាពផ្សេងៗនៃការបញ្ជ្រាបយេនឌ័រនៅក្នុងប្រទេស ត្រូវមានការចូលរួមយ៉ាងខ្លាំងក្លា ។ នៅថ្នាក់ជាតិ ក៏ដូចជាថ្នាក់ក្រោមជាតិ និងការចូលរួមនៅថ្នាក់មូលដ្ឋាន គឺផ្ដោតទៅលើ :

- ការប្ដេជ្ញាចិត្តកសាងសមត្ថភាពនៅគ្រប់កម្រិតទាំងអស់ រួមមាន ទាំងអ្នកធ្វើគោលនយោបាយ និងកម្មវិធីនានា ដែលទាក់ទងនឹងយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ ។
- ជំរុញការផ្ដល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។
- លើកកម្ពស់ការការពារខាងផ្លូវច្បាប់ចំពោះស្ត្រី ។

**៤.១០០** *ផយអជ* នឹងផ្ដោតលើផ្នែកសំខាន់ៗមួយចំនួន តាមរយៈការផ្សព្វផ្សាយចំណេះដឹង និងសកម្មភាពសំខាន់នានា រួមមាន :

- បញ្ជ្រាបយេនឌ័រទៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជាទាំងមូល រួមមាន នៅក្នុងថ្នាក់រដ្ឋាភិបាលទាំងអស់ និងនៅក្នុងដំណើរការផ្ដល់ថវិកា ។

- ណែនាំ ដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី (តាមរយៈការលុបបំបាត់អំពើពុករលួយ និងការពង្រឹងច្បាប់ឱ្យបានម៉ឺងម៉ាត់) និងទំនៀមទំលាប់វប្បធម៌ ដែលទ្រទ្រង់ វិសមភាពយេនឌ័រនៅក្នុងគ្រួសារ និងសង្គម ។
- បង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានផលិតភាពទ្រព្យសកម្ម ដូចជា មូលធនហិរញ្ញវត្ថុ ការកាត់បន្ថយការរើសអើងដែលទាក់ទងនឹងយេនឌ័រនៅលើទីផ្សារពលកម្ម និងផ្តល់បរិយាកាសដ៏ល្អប្រសើរដើម្បីឱ្យស្ត្រីអាចចូលរួមបានច្រើនជាងមុននៅក្នុងការងារដែលមានគុណភាពខ្ពស់ ។
- ដោះស្រាយបញ្ហាផ្សេងៗ ដូចជាការបង្កើន ការចូលរួមរបស់ស្ត្រីនៅក្នុងរចនាសម្ព័ន្ធនៃសេចក្តីសម្រេចនានា ទាំងក្នុងនិងក្រៅផ្លូវការ ជំរុញឱ្យស្ត្រីទទួលបាននូវកម្រិតឋានៈនិងតួនាទីខ្ពស់នៅក្នុងរដ្ឋបាលសាធារណៈ តាមរយៈគោលនយោបាយនិងច្បាប់ ។ បង្កើនល្បឿននិងជំរុញឱ្យមានការអនុវត្តច្បាប់រដ្ឋប្បវេណីឱ្យបានម៉ឺងម៉ាត់ក្នុងការដោះស្រាយអំពើហិង្សាក្នុងគ្រួសារ ជំរុញឱ្យមានការអនុម័តច្បាប់ជួញដូរមនុស្ស និងការអនុវត្តផែនការសកម្មភាពជាតិ ដើម្បីការពារជនរងគ្រោះដោយអំពើហិង្សា ។

**៤.១០១** <u>គោលនយោបាយប្រជាជន</u> : គោលនយោបាយនេះក៏ជាបញ្ហាអន្តរវិស័យមួយយ៉ាងទូលំទូលាយ ដែលមានការពាក់ព័ន្ធនឹងវិស័យផ្សេងៗទៀតជាច្រើន ដូចជា សុខាភិបាល អប់រំ បរិស្ថាន ម៉ាក្រូសេដ្ឋកិច្ច សមភាពយេនឌ័រ បញ្ហាគ្រឿងញៀន និងវិស័យផ្សេងៗទៀត ។ បច្ចុប្បន្នអត្រាកំណើនប្រជាជនប្រចាំឆ្នាំគឺ ១,៨ភាគរយ ជាបន្ទុកដ៏ធ្ងន់ធ្ងរមួយទៅលើ សេវាសាធារណៈនិងធនធាន និងជាកត្តាមួយរួមចំណែកឱ្យកើតមានភាពក្រីក្រ ។ ដំណោះស្រាយជាអាទិភាពរួមមាន :

- គាំទ្រដល់គូស្វាមីភរិយានិងបុគ្គលម្នាក់ៗឱ្យធ្វើការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវលើចំនួនកូន និងការពន្យារកំណើត ហើយឱ្យទទួលបាននូវ ព័ត៌មាន ការអប់រំ សេវាកម្មនានា និងមធ្យោបាយដើម្បីអនុវត្តការសម្រេចចិត្តខាងលើ ។
- កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃការផ្លាស់ប្តូរទីលំនៅ ទៅលើទីប្រជុំជននិងជនបទ ។
- បញ្ចូលអថេរប្រជាជន រួមទាំង បញ្ហាមនុស្សចាស់និងការផ្លាស់ទីលំនៅ ទៅក្នុងគោលនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច នៅគ្រប់កម្រិតទាំងអស់នៃផែនការ និងកម្មវិធីនានា ។

**៤.១០២** <u>ចំណាយ ធនធាន និងការរៀបចំកម្មវិធី</u> : ការសម្រេចបាននូវគោលដៅនិងចំណុចដៅទាំងអស់ នៅក្នុងកំឡុងពេលអនុវត្ត *ផយអជ* ២០០៦-២០១០ នឹងពាក់ព័ន្ធទៅនឹងចំនួនដ៏ច្រើននៃធនធានហិរញ្ញវត្ថុនិងធនធានបច្ចេកទេស ទាំងផ្នែកសាធារណៈនិងទាំងផ្នែកឯកជន ។ ការលើកឡើងនៅក្នុងជំពូកបន្ទាប់ (ជំពូក ៥) រួមជាមួយចំនួនធនធានដែលអាចរកបាន និងការរៀបចំកម្មវិធីក្បៀរគរជំនួយ តាមរយៈកម្មវិធីវិនិយោគសាធារណៈ និងថវិកាប្រចាំឆ្នាំ ។

# ជំពូក ៥

# ចំណាយ ធនធាន និងការរៀបចំកម្មវិធី

**៥.០១** ការអនុវត្តប្រកបដោយជោគជ័យ និងទាន់ពេលវេលានៃយុទ្ធសាស្ត្រ និងសមិទ្ធផលនៃចំណុចដៅ[១] *ផយអជ* អំពាវនាវរកការវិនិយោគបន្ថែមដែលត្រឹមត្រូវនិងចំទិសដៅ និងការប្រើប្រាស់ដោយផ្តោតចំបញ្ហានិងប្រកបដោយប្រសិទ្ធភាព ។ ការវិនិយោគទាំងនេះ នឹងត្រូវប្រព្រឹត្តទៅ ទាំងក្នុងវិស័យឯកជនដើម្បីធ្វើឱ្យមានចីរភាពនិងបង្កើនសកម្មភាពសេដ្ឋកិច្ច ទាំងក្នុងវិស័យសាធារណៈដើម្បីផ្តល់កម្លាំងជំរុញកំណើននិងការកាត់បន្ថយភាពក្រីក្រ ។ ជំពូកនេះ ផ្តោតជាសំខាន់លើវិស័យសាធារណៈ ដែលទាក់ទងនឹង :

- កម្រិតនៃការវិនិយោគសាធារណៈ ដែលត្រូវការចាំបាច់ក្នុងរយៈពេលនៃការអនុវត្ត *ផយអជ* (២០០៦-២០១០) ដោយគិតពិចារណាផងដែរនូវរាល់ឧបសគ្គនានា ដែលបណ្តាលមកពីសមត្ថភាពស្រូបយកនៃប្រព័ន្ធរដ្ឋបាលសាធារណៈ ។
- ប្រភពផ្សេងៗនៃមូលនិធិសម្រាប់ការវិនិយោគ ។
- របៀបរបប និតិវិធី និងវិធីសាស្ត្ររៀបចំកម្មវិធី និងប្រតិបត្តិការនៃការវិនិយោគ ។

**៥.០២** ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានការឯកភាពពីមូលនិធិរូបិយវត្ថុអន្តរជាតិ បានគ្រោងទុកជាមុននូវកំណើន *ផសស* ថេរមួយស្មើ ៦,០ភាគរយ ក្នុងរយៈពេលប្រាំឆ្នាំនៃ *ផយអជ* (២០០៦-២០១០) ដោយបានថ្លឹងថ្លែងអំពីកត្តាខាងក្រៅនិងខាងក្នុងដែលអាចប៉ាន់ស្មានបាន (ឧបសម្ព័ន្ធ២.១) ។ ដើម្បី សម្រេចបានកម្រិតកំណើននេះ វិស័យនីមួយៗត្រូវឱ្យមានអត្រាកំណើនប្រចាំឆ្នាំដែលអាចព្យាករណ៍បាន ដែលអាចធ្វើបានពិតប្រាកដ ដូចដែលមានក្នុងឧបសម្ព័ន្ធ២.១ ។ ដើម្បីសម្រេចបានកម្រិតនានាដូចដែលបានព្យាករណ៍នៃកំណើនតាមវិស័យ កម្រិតអប្បបរមាពិតប្រាកដនៃ "ការវិនិយោគពិតប្រាកដ" គឺជាការចាំបាច់នៅក្នុងវិស័យផ្សេងៗ (ឧបសម្ព័ន្ធ ២.២) ។

---

[១] ជំពូក៣ និង ៤

## តារាង៥.១ : កម្រិតវិនិយោគដែលចាំបាច់

### ២០០៦-២០១០ (លានដុល្លារអាមេរិក)

| សរុបចំណាយវិនិយោគដែលចាំបាច់ និងអាចធ្វើបាន | ៦.៤០១,១០ |
|---|---|
| ក្នុងនោះ  វិនិយោគសាធារណៈ : | ២.៣៨៤,៦០ |
| -ហិរញ្ញប្បទានក្នុងស្រុក | ៧៨៣,៣០ |
| -ហិរញ្ញប្បទានក្រៅប្រទេស | ១.៦០១,៣០ |
| វិនិយោគឯកជន : | ៤.០១៦,៥០ |
| -ហិរញ្ញប្បទានក្នុងស្រុក | ២.៧៥៨,៥០ |
| -ហិរញ្ញប្បទានក្រៅប្រទេស | ១.២៥៨,00 |
| ហិរញ្ញប្បទានក្នុងស្រុកសរុប | ៣.៥៤១,៨០ |
| ហិរញ្ញប្បទានក្រៅស្រុកសរុប | ២.៨៥៩,៣០ |

***ប្រភព:*** *ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងឧបសម្ព័ន្ធ ២.២*

**៥.០៣** ការវិនិយោគក្នុងវិស័យឯកជនរួមមានពីរផ្នែក ការវិនិយោគក្នុងប្រទេស និងការវិនិយោគផ្ទាល់ពីក្រៅប្រទេស ។ ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច បានប៉ាន់ប្រមាណថា ការវិនិយោគផ្ទាល់ពីក្រៅប្រទេស ដែលបច្ចុប្បន្នភាគច្រើនស្ថិតនៅក្នុងផ្នែកឧស្សាហកម្មសំលៀកបំពាក់ និងវិស័យទេសចរណ៍ អាចនឹងលើសពី ១.២៥៨លានដុល្លារអាមេរិក ក្នុងរយៈពេលផែនការនេះ ។ រាជរដ្ឋាភិបាលកម្ពុជាមានជំនឿថា ការវិនិយោគផ្ទាល់ពីក្រៅប្រទេសអាចកើនទៅដល់កម្រិតមួយខ្ពស់ជាងច្រើន ក្នុងអំឡុងពេលនៃ*ផយអជ*[១] ហើយអាចនឹងធ្វើឱ្យមានសកម្មភាពខ្លាំងក្លា និងចម្រុះប្រភេទ ដើម្បីគ្របដណ្តប់យ៉ាងទូលំទូលាយ និងស៊ីជម្រៅទៅលើផ្នែកអន្តរវិស័យជាច្រើន និងបែងចែកតាមតំបន់ភូមិសាស្ត្រនានា ហើយនិងប្រកបដោយចីរភាពក្នុងរយៈពេលវែង ។ រាជរដ្ឋាភិបាលនឹងធានាថា ប្រការនេះអាចសម្រេចបានតាមរយៈ កំណែទម្រង់ផ្នែករដ្ឋបាលច្បាប់ និងហិរញ្ញវត្ថុ ដូចដែលបានបញ្ជាក់រួចមកហើយនៅក្នុងជំពូក៤ ដើម្បីបង្កើតបាននូវបរិយាកាសមួយប្រកបដោយភាពងាយស្រួលនិងមានការប្រកួតប្រជែង ហេតុដូចនេះ កម្ពុជានឹងក្លាយទៅជាប្រទេសដែលមានការលូតលាស់ និងប្រកបដោយសុវត្ថិភាព អាចព្យាករណ៍បាន និងមានផលចំណេញសម្រាប់រយៈពេលវែងចំពោះការវិនិយោគផ្ទាល់ពីក្រៅប្រទេសទាំងឡាយ ។

**៥.០៤** វិស័យហិរញ្ញវត្ថុ (ធនាគារនិងការធានារ៉ាប់រង) មិនទាន់ក្លាយជាដៃគូសំខាន់មួយក្នុងការវិនិយោគក្នុងប្រទេសនៅឡើយ ទោះបីជាធនាគារផ្តល់ឥណទានផ្សេងៗជាច្រើន រួមមានឥណទានជនបទក៏ដោយ ។ អត្រាការប្រាក់កម្ចីខ្ពស់ បានធ្វើឱ្យការខ្ចីប្រាក់ពុំមានការកើនឡើង ។ កម្រិតការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុសម្រាប់ការវិនិយោគរយៈពេលវែងនៅតែមានកំរិតទាបខ្លាំង ។ ប្រាក់ដុល្លារអាមេរិកមួយចំនួនធំ ដែលបានផ្ញើនៅធនាគារពាណិជ្ជ

[១] ការប៉ាន់ស្មានដែលបានធ្វើការកែសម្រួលនៅខែធ្នូ ឆ្នាំ២០០៥ បានដាក់បញ្ចូលតួលេខនេះក្នុងកម្រិត ១.៣៨៤លានដុល្លារ (សូមមើលតារាង៤.១ និងឧបសម្ព័ន្ធ២.១ ។

ក្នុងប្រទេសកម្ពុជា មិនទាន់បានយកទៅប្រើប្រាស់ឱ្យបានពេញលេញសម្រាប់ការវិនិយោគក្នុងប្រទេសនៅឡើយ ហើយប្រាក់មួយចំនួនបែរជាត្រូវយកទៅវិនិយោគនៅទីកន្លែងផ្សេងទៅវិញ[១] ។ ដូច្នេះ ការជំរុញឱ្យធនាគារផ្តល់មូលនិធិបម្រើការងារសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា គឺជាអាទិភាពដ៏សំខាន់មួយ នឹងអាចធ្វើទៅបានតាមរយៈការបង្កើនតម្រូវការសម្រាប់ការវិនិយោគនានាក្នុងប្រទេស ។

**៥.០៥** *ជំពូកនេះស្តីពី ការវិនិយោគសាធារណៈឬការវិនិយោគវិស័យសាធារណៈ*[២] ។ ថវិកាចំនួន ២.៣៨៤,៦០ លានដុល្លារអាមេរិកក្នុងតារាង៥.១ សម្រាប់ការវិនិយោគសាធារណៈ ផ្តោតជាសំខាន់លើ "*ការវិនិយោគមូលធន*" ឬ "*ការវិនិយោគពិត*" ។ ការវិនិយោគនេះ បង្ហាញពី "*លទ្ធភាពអាចធ្វើទៅបាន*" ប៉ុន្តែមិនបានយកមកពិចារណាពេញលេញនូវរាល់ "*តម្រូវការ*" ចាំបាច់ក្នុងការចំណាយសម្រាប់វិស័យសង្គមកិច្ច និងវិស័យផ្សេងៗទៀត ដើម្បីសម្រេចបាន *គអសក* និងគោលដៅរួមនានាដែលបានលើកឡើងក្នុងជំពូក៣[៣] ព្រមទាំងការចំណាយចរន្តបន្ថែមដែលមានកើតឡើងដោយសារការវិនិយោគថ្មីៗ និងការកើនឡើងនៃការចំណាយផ្សេងៗ ។ "*តម្រូវការ*" នាពេលអនាគតក្នុងវិស័យសាធារណៈ ដែលហួសនិងខ្ពស់ជាងចំនួនដែលត្រូវចំណាយ ដូចជាចំណាយចរន្តថែងក្នុងថវិកាប្រចាំឆ្នាំ (ដែលភាគច្រើនឆ្ពោះទៅរកការចំណាយសង្គមនិងចំណាយជាអាទិភាពផ្សេងទៀត ហើយដាច់ដោយឡែកពីចំណាយលើផ្នែកការពារជាតិនិងសន្តិសុខ) រួមមានដូចខាងក្រោម :

- ការវិនិយោគមូលធនថ្មី និងចំណាយបន្ថែមលើការវិនិយោគដែលកំពុងដំណើរការ ។
- ការចំណាយចរន្តបន្ថែម ដែលកើនហួសនិងខ្ពស់ជាងការកើនឡើងជាធម្មតានៃមុខចំណាយដែលមានស្រាប់ (ដូចជា បៀវត្សរ៍មន្ត្រីរាជការស៊ីវិល) រួមបញ្ចូលទាំងចំណាយថែទាំបន្ថែមលើការវិនិយោគថ្មីៗ ។
- ការចំណាយបន្ថែមទៅលើមុខចំណាយមិនមែនមូលធន ដូចជា ការឧបត្ថម្ភបន្ថែមនិងអាហារូបករណ៍ថ្មី ឬបន្ថែម ។
- ការចំណាយទៅលើជំនួយបច្ចេកទេសក្រៅប្រទេស ទោះបីស្ថិតនៅក្នុងកម្រិតត្រូវកាត់បន្ថយយ៉ាងឆាប់រហ័សក៏ដោយ ។

**៥.០៦** ដើម្បីសម្រុះសម្រួលដល់ការចំណាយដែលចាំបាច់ទាំងអស់សម្រាប់ធ្វើឱ្យសម្រេចគោលដៅនិងចំណុចដៅទាំងឡាយ (ជាពិសេស *គអសក*) បរិមាណចំណាយហិរញ្ញវត្ថុសរុបក្នុងអំឡុងពេល *ផយអជ* (២០០៦-២០១០) ចាំបាច់ត្រូវមាន (គិតជាលានដុល្លារអាមេរិក) :

---

[១] ដូចនៅពាក់កណ្តាលឆ្នាំ២០០៥ ប្រាក់បញ្ញើជាដុល្លារអាមេរិកនៅធនាគារពាណិជ្ជមាន ៨៥៧លាន ដែលត្រូវបានបញ្ចេញឱ្យខ្ចីតែ ៥២៣លានដុល្លារប៉ុណ្ណោះ រីឯចំនួនផ្សេងទៀត ត្រូវបាននាំចេញទៅក្រៅប្រទេស ។

[២] ការវិនិយោគទាំងនេះត្រូវបានកំណត់លើវិស័យ និងសកម្មភាពទាំងឡាយដែលផ្នែកឯកជនពុំមានបំណង ឬមានចំណាប់អារម្មណ៍សម្រាប់ផលចំណេញ ប៉ុន្តែជាការវិនិយោគដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេស ។

[៣] ជំពូក ៣ : តារាង ៣.២

| | |
|---|---|
| ▪ ការវិនិយោគវិស័យសាធារណៈតាមចំណោលម៉ាក្រូសេដ្ឋកិច្ច[១] | ២.៣៨៤,៦០ |
| ▪ បន្ថែម : វិស័យសង្គមកិច្ចបន្ថែម និងចំណាយអភិបាលកិច្ច | ៣០០,០០ |
| ជំនួយបច្ចេកទេស ការបណ្តុះបណ្តាល និងអង្កេត | ៥០០,០០ |
| ចំណាយចរន្តបន្ថែម | ៣០០,០០ |
| ទុនបម្រុងសម្រាប់វិស័យផលិត | ១៥,៤០ |
| **ចំណាយសរុប**[២] | **៣.៥០០,០០** |

**៥.០៧** សូចនាករដែលគួរឱ្យជឿបានផ្សេងទៀតនៃចំណាយ "*ចាំបាច់*" គឺ សេចក្តីលម្អិតនៃកម្មវិធី និងសកម្មភាពនានាទៅតាមការប៉ាន់ស្មានចំណាយដែលមានចែងក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល *(កវស)* ដែលមិនគ្រាន់តែឆ្លុះបញ្ចាំងនូវសំណើរបស់បណ្តាក្រសួង និងស្ថាប័ននានាទេ ប៉ុន្តែក៏ឆ្លុះបញ្ចាំងពីសមត្ថភាពដែលស្រូបបានរបស់គេដែរ ។ តាមរយៈការធ្វើចំណោលលើចំនួនសរុប ១.៩៣៧,៥៩ លានដុល្លារអាមេរិកដែលប៉ាន់ប្រមាណក្នុងកម្មវិធីវិនិយោគសាធារណៈ ឆ្នាំ២០០៥-២០០៧[៣] តាមរយៈនិងការគិតគូរពិចារណាអំពីតម្រូវការសម្រាប់គំនិតផ្តួចផ្តើមសំខាន់ៗ ក្នុងការជំរុញល្បឿនរីកចម្រើនដើម្បីឈានទៅទៅសម្រេចបានគោលដៅ និងចំណុចដៅនៅឆ្នាំ២០១០ ចំណាយហិរញ្ញវត្ថុសរុប នៃ *ផយអជ* អាចត្រូវការថវិកាចំនួន ១៥.២២៥ពាន់លានរៀល ស្មើនឹង ៣.៥០០លានដុល្លារអាមេរិក[៤] ដោយមានកម្រិតដូចគ្នាដោយចៃដន្យ ជាមួយនឹងចំនួនដែលបានមកពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនៃកឋាខ័ណ្ឌ ៥.០៦ ខាងលើ ។ បរិមាណនេះអាចមានប្រហែល ៧០០លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ដែលកាន់តែកើនឡើងជាលំដាប់ពីឆ្នាំ២០០៦ ។

**៥.០៨** នៅពេលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[៥] កម្មវិធី និងគម្រោងលម្អិតដែលបានស្នើឡើងមិនទាន់ត្រូវបានរៀបចំពេញលេញ សម្រាប់បញ្ហាតាមវិស័យនីមួយៗ និងបញ្ហាអន្តរវិស័យ ។ ដូចបានលម្អិតក្នុងជំពូកមុនៗរួចមកហើយ[៦] កម្មវិធីនិងគម្រោងទាំងនោះ នឹងត្រូវរៀបចំឡើងនៅដើមឆ្នាំ២០០៦ ចាប់ផ្តើមគិតគូរដោយពេញលេញនូវអាទិភាពពិតប្រាកដ ដូចមាននៅក្នុងកឋាខ័ណ្ឌ ៤.០៥ នៃជំពូក៤ ។ ដូច្នេះ នៅដំណាក់កាលនេះ មិនអាច ឬចាំបាច់ធ្វើការកំណត់នូវការចំណាយផ្សេងៗសម្រាប់សកម្មភាពនានាក្នុងកម្រិតជាក់លាក់ពិតប្រាកដមួយនោះឡើយ ។

---

[១] ឧបសម្ព័ន្ធ ២.២ ។

[២] បរិមាណសរុប ៣.៥០០លានដុល្លារ គឺជាចំណាយសរុបសម្រាប់វិស័យសាធារណៈ ដែលបានបញ្ជាក់នៅ កឋាខ័ណ្ឌ ៥.០៥ ដែលបរិមាណវិនិយោគសរុប ៣.៥៤០,៨លានដុល្លារ ដែលបានមកពី "ប្រភពហិរញ្ញវត្ថុក្នុងស្រុក" ក្នុងតារាង ៥.១ គឺជាទុនសុទ្ធ ដែលចំណាយទាំងសម្រាប់វិស័យសាធារណៈ ៧៨៣,៣ លានដុល្លារ និងវិស័យឯកជន ២.៧៥៨,៥០លានដុល្លារ នេះជាតួលេខពីរប្រហាក់ប្រហែលគ្នា ។

[៣] សូមអានទំព័រ ១១៤ (ឯកសារភាសាអង់គ្លេស) នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ និងតម្រូវការជំនួយអភិវឌ្ឍន៍ ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលបានបង្ហាញក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៤ ។

[៤] ឧបសម្ព័ន្ធ ២.២ ។

[៥] ខែវិច្ឆិកា ឆ្នាំ២០០៥ : កវស សម្រាប់ឆ្នាំ២០០៦-២០០៨ នឹងត្រូវរួចរាល់នៅខែធ្នូ ឆ្នាំ២០០៥

[៦] ជំពូកទី ១: កឋាខ័ណ្ឌ ១.១១ ជំពូក ៣: កឋាខ័ណ្ឌ ៣.១៣ ជំពូក ៤: កឋាខ័ណ្ឌ ៤.០៥

ក្នុងករណីខ្លះ ការចំណាយបែបនេះ ត្រូវបានគណនាក្នុងលក្ខណៈលម្អិតបន្ថែមទៀត នៅពេលណាដែលកម្មវិធីនិងសកម្មភាពទាំងនោះ ត្រូវបានគ្រោងរៀបចំ ហើយអាចមានលទ្ធភាពធនធាន ហើយនឹងត្រូវយកទៅបង្ហាញជាបន្តបន្ទាប់នៅក្នុងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ។

**៥.០៩** *ការធ្វើវិភាជន៍ការចំណាយទូទៅ* : គប្បីផ្តល់លទ្ធភាពធនធានឱ្យបានគ្រប់គ្រាន់ ចំពោះវិស័យទាំងឡាយដើម្បីអាចសម្រេចបានគោលដៅនិងចំណុចដៅជាអាទិភាព ក្នុងស្ថានភាពតីរក្សាតុល្យភាព ដែលផ្តោតឱ្យចំទិសដៅ និងឆ្ពោះទៅរកអ្វីមួយច្បាស់លាស់ ដូចបានពិភាក្សារួចមកហើយក្នុងជំពូក៣ និងជំពូក៤ ។ ដូចបានលើកឡើងនៅផ្នែកខាងដើមរួចមកហើយ គោលដៅចម្បង គឺកាត់បន្ថយភាពក្រីក្រ ដែលការងារនេះទាមទារបង្កើនការវិនិយោគនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ដែលមានប្រជាជនក្រីក្រជាង៩០ភាគរយរស់នៅ ដោយផ្តោតជាសំខាន់ទៅលើកំណើនកសិកម្ម ។ វិស័យផលិតកម្មទាំងអស់ដែលនាំឱ្យមានកំណើន ចាំបាច់ត្រូវធានាឱ្យមានធនធានតាមតម្រូវការ ។ ដូចគ្នានេះដែរ វិស័យសង្គមកិច្ចជាអាទិភាព ដែលជួយជំរុញប្រមូលផ្តុំ និងធានាចីរភាពនៃធនធានមនុស្ស (ដែលរួមចំណែកផងដែរចំពោះកំណើនសម្រាប់រយៈពេលវែង) ត្រូវទទួលបាននូវការផ្គត់ផ្គង់ធនធានដែលត្រូវការចាំបាច់ ។ ដោយផ្អែក តាមសេចក្តីត្រូវការជាមុនទាំងនេះ និងដោយសារតែពុំមានការណែនាំណាដែលគួរឱ្យជឿទុកចិត្តបានក្នុងការវិនិយោគកន្លងមក[1] ការធ្វើវិភាជន៍ដ៏ល្អប្រសើរបំផុតនូវធនធានទាំងអស់ នឹងត្រូវធ្វើឡើង ដោយផ្តោតលើកំណើនជាអាទិភាព និងផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីបង្កើនល្បឿនអភិវឌ្ឍន៍ និងសម្រេចបាននូវការកាត់បន្ថយ ភាពក្រីក្រព្រមទាំងចំណុចដៅនានានៅក្នុងគោលដៅសហស្សវត្សរ៍កម្ពុជា ។ ដោយហេតុនេះហើយ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចថា ចំណាយសរុបចំនួន ១៥.២២៥ពាន់លានរៀល ស្មើនឹង ៣.៥០០លានដុល្លារអាមេរិក ដែលគ្រោងសម្រាប់វិស័យសាធារណៈតែមួយសម្រាប់រយៈពេល (២០០៦-២០១០) នឹងត្រូវបែងចែក ដូចមាន បង្ហាញក្នុងតារាង ៥.២ ។ ទិដ្ឋភាពសំខាន់ៗមួយចំនួន នៅក្នុងតារាងមានដូចតទៅ :

- ការធ្វើវិភាជន៍ការចំណាយលើវិស័យសាធារណៈ ត្រូវស្របជាមួយការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច ។

[1] ទំព័រ៤៣នៃឯកសាររបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ២០០២និងឆ្នាំ២០០៣ (តុលា២០០៤) របស់ កអក/គជនា បង្ហាញពីតួលេខចំណាយរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសសម្រាប់ឆ្នាំ១៩៩២-២០០៣ ។ តួលេខទាំងនោះ មិនមានភាពជាក់លាក់សម្រាប់ធ្វើការប្រៀបធៀបឡើយដោយសារ (ក) ចំណាត់ថ្នាក់មិនស៊ីគ្នាទៅនឹងតារាង៥.២ (ដែលតារាងនេះមានទម្រង់ដូចគ្នានឹងតារាងនៅក្នុងទំព័រ១១៤ នៃឯកសារកអក/គជនា ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលបានបង្ហាញនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាខែធ្នូ ឆ្នាំ២០០៤) (ខ) ចំណាយអភិវឌ្ឍន៍កន្លងមក ដែលភាគច្រើនបំផុតបានមកពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ពុំបានតម្រង់ទិសច្បាស់លាស់ស្របទៅតាមទិសដៅរបស់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី១និងទី២ទេ ប៉ុន្តែបានផ្អែកទៅលើអាទិភាពនិងការជ្រើសរើសរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសផ្ទាល់ ទោះជាដូចនេះក្តី ការចំណាយបែបនេះ ពិតជាបានរួមចំណែកធ្វើឱ្យមានកំណើន ដោយហេតុថា ការចំណាយណាមួយ អាចត្រូវបានធ្វើឡើង នៅក្នុងពេលដែលប្រទេសមួយចាប់ផ្តើមចេញពីចំណុចសូន្យ ដូចដែលកម្ពុជាបានឆ្លងកាត់រួចមកហើយ ។ ហេតុនេះ *ផយអជ* ធ្វើការវិភាជន៍ធនធានដែលមានលក្ខណៈប្រសើរជាងមុន ស្របទៅតាមតម្រូវការនៃអាទិភាពនានា ។

- ការធ្វើវិភាជន៍ទាំងនេះ ត្រូវតែជាក់ស្តែង ដែលទាក់ទងទៅនឹងលទ្ធភាពធនធានដែលមាន ឧទាហរណ៍ ៣.៥០០លានដុល្លាអាមេរិក (ប្រសិនបើធនធានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់មានភាពរលូនត្រឹមត្រូវទៅនឹង *ផយអជ*) ។
- ការធ្វើវិភាជន៍ចំពោះវិស័យសាធារណៈ ត្រូវផ្តោតទៅលើ និងក្នុងរង្វង់វិស័យនិងសកម្មភាពទាំងឡាយ ដែលមិនមានវិសាលភាពក្នុងការទាក់ទាញវិនិយោគ ឬការចូលរួមពីវិស័យឯកជន ។
- ដោយសារការកាត់បន្ថយភាពក្រីក្រជាអាទិភាពខ្ពស់បំផុត ហើយកម្រិតភាពក្រីក្រខ្ពស់នៅតំបន់ជនបទ វិស័យសាធារណៈ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើតំបន់ជនបទ ដែលជាង៦០ភាគរយនៃធនធាន នឹងត្រូវផ្តល់ផលប្រយោជន៍ចំពោះតំបន់ជនបទ ។
- សកម្មភាពជាអាទិភាពនានា ផ្សារភ្ជាប់ជាមួយវិស័យសេដ្ឋកិច្ច-សង្គមកិច្ច នឹងមានផលឥទ្ធិពលភ្លាមៗ ចំពោះការកាត់បន្ថយភាពក្រីក្រ ការសម្រេចបាននូវ *គអសក* និងចំណុចដៅនៃកំណើនសេដ្ឋកិច្ច ។
- បរិមាណទឹកប្រាក់៣.៥០០លានដុល្លារ គឺមានរាប់បញ្ចូលនូវការចំណាយក្នុងវិស័យសាធារណៈ (កឋាខ័ណ្ឌ ៥.០៥) ដែលបានមកពីគ្រប់ប្រភពទាំងអស់ ដូចបានរៀបរាប់នៅក្នុងកឋាខ័ណ្ឌ៥.១១ (ដែលភាគច្រើនពុំស្ថិតក្នុងថវិកាជាតិបច្ចុប្បន្ន) ។ បរិមាណនេះ មិនរាប់បញ្ចូលការវិនិយោគ ឬការចូលរួមរបស់ផ្នែកឯកជនទេ ទោះជាផ្នែកមួយ ឬផ្នែកទាំងអស់ដែលបានវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬក៏សកម្មភាពវិស័យសាធារណៈផ្សេងៗ តាមរយៈ *សាងសង់-ដំណើការ-ផ្ទេរ* ឬតាមការរៀបចំស្រដៀងៗគ្នានេះ ក៏ពុំមានរាប់បញ្ចូលដែរ ។
- ការធ្វើវិភាជន៍ទៅគ្រប់វិស័យទាំងអស់ ត្រូវបានផ្អែកទៅលើការប៉ាន់ស្មានពីតម្រូវការ ហើយទ្រទ្រង់ដល់កំណើនដែលបានរំពឹងទុកជាមុន ដើម្បីឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ និងសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។
- ការពន្យល់លម្អិតមានផ្តល់ជូនជាកំណត់សម្គាល់នៅផ្នែកខាងក្រោមនៃតារាង ។

**៥.១០** រាជរដ្ឋាភិបាលកត់សម្គាល់ថា មានកម្មវិធី និងគម្រោងនានាកំពុងដំណើរការ ជាពិសេស កម្មវិធីនិងគម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដែលស្រូបយកផ្នែកខ្លះនៃធនធានដែលអាចរកបាន ។ រាជរដ្ឋាភិបាលនឹងពិនិត្យឡើងវិញ (តាមរយៈយន្តការក្រុមការងារបច្ចេកទេស ជាឧទាហរណ៍) ដើម្បីឱ្យដឹងថាកម្មវិធី និងគម្រោង ទាំងអស់នេះស្ថិតនៅក្នុងព្រំដែននៃអាទិភាពនានាដែលបានគ្រោងឡើងក្នុងឯកសារនេះ ។ លើសពីនេះទៀត តាមរយៈការពិនិត្យឡើងវិញរបៀបនេះ រាជរដ្ឋាភិបាលនឹងខិតខំប្រឹងប្រែង ក្នុងការធានាថា ធនធានដែលប្រើប្រាស់ ចំពោះការចំណាយគ្មានអាទិភាព នឹងត្រូវបានតម្រង់ទិសសារជាថ្មី ដើម្បីឱ្យវិស័យអាទិភាពអាចទទួលបានចំណែក តាមតម្រូវការនៅក្នុងការវិភាជន៍ចុងក្រោយ ដូចមានក្នុងតារាង៥.២ ។ ចំពោះវិស័យនីមួយៗ

ផែនការលម្អិត នឹងត្រូវបង្កើតឡើង ដើម្បីប្រើប្រាស់ថវិកាវិភាជន៍ ដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធនានា[១] ។

## FnFanEd l Gacrk)ansRmabvsysaFarN[3]

**៥.១១** រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា ការចំណាយដែលបានប៉ាន់ស្មានសរុប ចំនួន៣.៥០០លានដុល្លារសម្រាប់វិស័យសាធារណៈក្នុងកំឡុងពេល *ផយអជ* ២០០៦-២០១០ អាចទទួលបានពីប្រភពមូលនិធិ ដូចខាងក្រោម :

- អតិរេក (សម្រាប់មូលធនវិនិយោគ) នៅក្នុងថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល (ចំណូលសរុបគិតទាំងចំណូលចរន្តនិងចំណូលជាទុន ដកចេញនូវជំនួយដោយមានការជួយផ្គត់ផ្គង់តិចតួចពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ចំណាយចរន្ត ដោយរួមបញ្ចូលទាំងសេវាកម្ម បំណុល និងសំណង) ។
- ជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលនានា)[២] ។
- ប្រាក់កម្ចីសម្បទានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (សំខាន់ពីស្ថាប័នហិរញ្ញវត្ថុពហុភាគី) ។
- ប្រភពធនធានមិនមែនប្រពៃណី រួមទាំងដៃគូអភិវឌ្ឍន៍ក្រៅប្រទេសដែលមិនមែនជាប្រពៃណី (មានទាំងជំនួយឥតសំណង និងកម្ចីពាក់កណ្តាលសម្បទាន[៣]) ។
- ការបន្ធូរបន្ថយបំណុលទំនងជាអាចប្រព្រឹត្តទៅបាន ពីព្រោះតែស្ថានភាពកម្ពុជាជាប្រទេសមានចំណូលតិច ដូច្នេះនឹងមានការបញ្ចេញមូលនិធិពីសេវាកម្មបំណុល ដើម្បីសម្រេចបានចំណុចដៅដ៏សំខាន់នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

**៥.១២** ផ្អែកលើលំហូរចូលនៃមូលនិធិពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសកន្លងមក និងអតិរេកថវិកាប្រចាំឆ្នាំដែលបានព្យាករណ៍ លទ្ធភាពធនធានប៉ាន់ស្មានសម្រាប់ការអនុវត្ត *ផយអជ* រយៈពេលប្រាំឆ្នាំ២០០៦-២០១០ មានដូចខាងក្រោម :

- ថវិកាប្រមាណ ៣.៣៧០លានរៀល ស្មើនឹង ៧៧៥លានដុល្លារ[១] ឬប្រហែល ១៥៥លានដុល្លារក្នុងមួយឆ្នាំ បានមកពីអតិរេកថវិការបស់រាជរដ្ឋាភិបាល (គោលដៅជាគន្លឹះរបស់រាជរដ្ឋាភិបាល គឺត្រូវកៀរគរប្រភពធនធានក្នុងស្រុកឱ្យបានច្រើនថែមទៀត) ។

---

[១] ដូចដែលបានលើកឡើងពីខាងដើម អភិក្រមគ្រប់គ្រងទូទាំងវិស័យជាលម្អិត និងផែនការផ្សេងៗទៀត នឹងត្រូវរៀបចំឡើង ដើម្បីបំបែកជាលម្អិត ពង្រីករៀបចំជាកម្មវិធី នូវអនុគោលដៅនិងអនុចំណុចដៅជាតិ នៅក្នុងត្រីមាសដំបូងនៃឆ្នាំ២០០៦ (សូមមើលជំពូក៤) ។

[២] ទោះបីជាជំនួយឥតសំណងនេះគឺជាប្រភពដ៏សំខាន់នៃការគាំទ្រដ៏គួរជាទីចង់បានក៏ដោយ ក៏ការចង្អុលបង្ហាញថ្មីៗ ជាពិសេស ពីស្ថាប័នហិរញ្ញវត្ថុពហុភាគីនានាបង្ហាញថា ជំនួយបែបនេះមិនត្រូវបានលើកទឹកចិត្តទេ ។ ម្យ៉ាង ស្ថាប័នហិរញ្ញវត្ថុពហុភាគី បានសម្រេចផ្តល់ការគាំទ្រភាគច្រើនបំផុតជា "ជំនួយឥតសំណង" ដែលជំនួសឱ្យកម្ចីសម្បទាន ប៉ុន្តែម្យ៉ាងទៀត ស្ថាប័នហិរញ្ញវត្ថុពហុភាគីក៏បានសម្រេច (ក) កាត់បន្ថយបរិមាណសរុបនៃជំនួយ (ខ) ដាក់ឱ្យមានលក្ខខណ្ឌថ្មី ដែលជាហេតុនាំឱ្យរាំងស្ទះដល់ការផ្តល់មូលនិធិ ។

[៣] រួមបញ្ចូលទាំងជំនួយឥតសំណងនិងកម្ចីពាក់កណ្តាលសម្បទាន ពីធនាគារពិភពលោកនិងធានាគារអភិវឌ្ឍន៍អាស៊ី ។

- ទឹកប្រាក់ចំនួន ២.៥០០លានដុល្លារ ប្រហែលជា ៥០០លានដុល្លារក្នុងមួយឆ្នាំ បានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសជាប្រពៃណី មានទាំងប្រាក់កម្ចី ទាំងជំនួយឥតសំណង ដែលរួមបញ្ចូលចំណាយផ្ទាល់ទាំងអស់ដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសនានា នៅក្នុងគណនេយ្យរបស់កម្ពុជា ។

**៥.១៣** ដូច្នេះ ទឹកប្រាក់សរុបចំនួន ៣.២៧៥លានដុល្លារ ត្រូវបានប៉ាន់ស្មានថា អាចមានសម្រាប់គ្រប់សកម្មភាពនៃវិស័យសាធារណៈរបស់ *ផយអជ* ក្នុងរយៈពេល៥ឆ្នាំ (២០០៦-២០១០) ហើយបើធៀបទៅនឹងតម្រូវការប្រមាណចំនួន ៣.៥០០លានដុល្លារ គឺនៅខ្វះប្រហែលតែ ២២៥លានដុល្លារ ប៉ុណ្ណោះ ។ កង្វះនេះអាចកើនឡើងច្រើនថែមទៀត ប្រសិនបើថវិកាវិភាជន៍ និងការប្រើប្រាស់ថវិកា ជាពិសេសពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមិនបានបន្សុីពេញលេញជាមួយនិងសកម្មភាពជាអាទិភាពនានារបស់ *ផយអជ* ហើយម្យ៉ាងទៀត ប្រសិនបើថវិកាមួយចំនួនបានប្រើប្រាស់ទៅលើមុខចំណាយមិនអាទិភាព ដែលជ្រើសរើសដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស[២] ។

**៥.១៤** ប្រសិនបើការចំណាយដែលបានព្យាករណ៍ទុកចំនួន ៣.៥០០លានដុល្លារ នៅក្នុងវិស័យសាធារណៈ ក្នុងកំឡុងពេលនៃ *ផយអជ* កើតមានដូចដែលបានព្យាករណ៍ទុក រាជរដ្ឋាភិបាលមានសង្ឃឹមយ៉ាងខ្លាំងថា គោលដៅនិងចំណុចដៅនៃ *ផយអជ* (ការកាត់បន្ថយភាពក្រីក្រ *គអសក* កំណើនសេដ្ឋកិច្ចឆាប់រហ័យ) អាចសម្រេចបាន ។ *មានវិធីពីរ (សេណារីយោ)* តាមរយៈករណីនេះអាចត្រូវបានបង្ហាញ ។ *សេណារីយោទី១* គឺថា ចំនួនមូលនិធិសរុប ៣.៥០០លានដុល្លារអាមេរិក គឺអាចរកបានដោយផ្អែកតាមអាទិភាពនៃតារាង៥.២ និងជំនួយបច្ចេកទេសដាច់ៗគ្នាត្រូវបានកម្រិតមិនឱ្យច្រើនជាង ៥០០លានដុល្លារអាមេរិក ។ នេះជាអប្បបរមាដែលត្រូវការ និងដែលអាចមាន ។

**៥.១៥** *សេណារីយោទី២* គឺជាបញ្ហាដែលធនធានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់មិនអាចរកបានពេញលេញសម្រាប់គោលបំណងដែលជាអាទិភាពនៅក្នុង *ផយអជ* ។ បញ្ហានេះ អាចបកស្រាយបានម្យ៉ាងទៀតថា :

- ការប្រើប្រាស់ជំនួយបច្ចេកទេសដាច់ៗគ្នាធ្លាប់មានច្រើនជាង ៥០០លានដុល្លារអាមេរិក ជាឧទាហរណ៍ ដោយផ្អែកតាមរបាយការណ៍សហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ២០០២ និងឆ្នាំ២០០៣ (ទំព័រទី២០ នៃរបាយការណ៍គោល) ចំនួន ៤៤.១ភាគរយ នៃមូលនិធិដៃគូអភិវឌ្ឍន៍ក្រៅប្រទេស សម្រាប់ក្នុងកំឡុងពេលឆ្នាំ ១៩៩៩-២០០៣ ត្រូវបានចំណាយលើសហប្រតិបត្តិការបច្ចេកទេសដាច់ៗគ្នា ។ បើយកសមាមាត្រខាងលើនេះ ធៀបជាមួយនឹងជំនួយ ២.៥ពាន់លានដុល្លារ ដែលរំពឹងថានឹងអាចទទួលបានពីដៃគូអភិវឌ្ឍន៍

[១] តាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (ឧបសម្ព័ន្ធ២.១) ខែតុលា ឆ្នាំ២០០៥ គឺជាការព្យាករណ៍ដែលយកចេញពីទឹកប្រាក់ចំនួន ៣.៥០០លានដុល្លារអាមេរិក ។ ឱនភាពធនធានអាចមានប្រមាណ ៤៥លានដុល្លារអាមេរិកក្នុងមួយឆ្នាំ (ឬ ២២៥លានដុល្លារអាមេរិកសម្រាប់រយៈពេល៥ឆ្នាំ ២០០៦-២០១០) ។ ម្យ៉ាងវិញទៀត អតិរេកថវិកា (ចំណូលសរុបដកចំណាយចរន្ត) អាចមានប្រមាណ ៧៧៥លានដុល្លារ ដែលជាទូទៅស្មើនឹង ៧៨៣.៣លានដុល្លារអាមេរិក ដែលជា "ហិរញ្ញប្បទានដោយធនធានក្នុងស្រុក" ដូចនៅក្នុងតារាង ៥.១ ។

[២] កន្លងមក មួយផ្នែកធំនៃធនធានដែលបានកំណត់ដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសសម្រាប់កម្ពុជា ត្រូវបានចំណាយដោយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ទាំងនោះទៅលើកម្មវិធីនានាដែលជាជម្រើសរបស់ពួកគេ ដោយមិនធ្វើឡើងតាមរយៈថវិកាជាតិ ។

ក្រៅប្រទេសសម្រាប់ដំណាក់កាលរបស់ *ផយអជ* នោះជំនួយបច្ចេកទេសជាច់ៗគ្នាអាចនឹងមានដល់ ១,១ពាន់លានដុល្លារ គឺលើស ៦០០លានដុល្លារ ពីការគិតគូនៅក្នុង *ផយអជ* ដែលមានប្រមាណ ៥០០លានដុល្លារ ។

- កម្មវិធីនិងគម្រោងមួយចំនួនដែលអនុវត្តដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មិនត្រូវបានដាក់បញ្ចូលនៅក្នុងអាទិភាពនៃ *ផយអជ* ទេ ។

**៥.១៦** ដើម្បីអនុវត្ត *ផយអជ* ប្រកបដោយជោគជ័យនិងមានប្រសិទ្ធភាព ត្រូវការថវិកាចំនួន ៣.៥០០លានដុល្លារ ដើម្បីចំណាយតាមរបៀបដែលបានគ្រោងនៅក្នុងតារាង៥.២ ការចំណាយលើសខ្លះទៀតជាង ៥០០លានដុល្លារ ទៅលើជំនួយបច្ចេកទេសក្រៅប្រទេស និងចំនួនបានចំណាយទៅលើគម្រោងជំនួយបច្ចេកទេសក្រៅប្រទេសដែលមិនស្ថិតក្នុងការកំណត់នៃ *ផយអជ* នឹងកាត់បន្ថយធនធានជំនួយបច្ចេកទេសក្រៅប្រទេសដែលលើសទាំងនោះដែលអាចរកបានសម្រាប់ *ផយអជ* ។ ការកាត់បន្ថយរបៀបនេះ នឹងបង្កើនគម្លាតហិរញ្ញវត្ថុ ហើយករណីនេះ នឹង (ក) ឬមួយត្រូវបំពេញដោយធនធានបន្ថែម[១] ឬមួយ (ខ) ការសម្រេចបាននៃចំណុចដៅ *ផយអជ* នឹងត្រូវជួបការលំបាកដោយសារគម្លាតហិរញ្ញវត្ថុនេះ ។

**៥.១៧** ការឯកភាពគ្នាជាសាកលលើភាពជាដៃគូក្នុងកម្រិតខ្ពស់ ត្រូវបានផ្តួចផ្តើមឡើងដើម្បីជួយបណ្តាប្រទេសក្រីក្រឱ្យសម្រេចបាន *គអសក* និងផ្តល់មូធនិធិដែលចាំបាច់សម្រាប់គោលបំណង ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំប្រឹងប្រែង ដើម្បីធានាកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយបណ្តាដៃគូអភិវឌ្ឍន៍ក្រៅប្រទេសដែលធនធានក្រៅប្រទេសត្រូវតម្រឹមឱ្យបានពេញលេញទៅនឹងគោលដៅនិងចំណុចដៅរបស់ *ផយអជ* តាមរយៈការតម្រង់ទិសឡើងវិញនូវមូលនិធិពីបណ្តាវិស័យដែលមានអាទិភាពតិចតួច ដែលទទួលបានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសនាពេលបច្ចុប្បន្ន រួមមាន ការកាត់បន្ថយឱ្យបានច្រើនក្នុងជំនួយបច្ចេកទេសដាច់ៗគ្នា ហេតុដូចនេះ "*ការផ្ទេរដុលពិត*" នៃមូលនិធិអាចកើតឡើងសម្រាប់ការវិនិយោគដែលគ្រោងទុកក្នុង *ផយអជ* ។ របៀបដែលប្រសើរបំផុត ដើម្បីទទួលបានចំណែកសំខាន់នៃជំនួយអភិវឌ្ឍន៍ តាមរយៈ "ការគាំទ្រគម្រោងថវិកា" ដែលទាក់ទងទៅនឹងការអនុវត្តបែបគុណភាព និងបរិមាណដែលអាចវាស់បានក្នុងវិស័យនីមួយៗដែលបានជ្រើសរើស ។ ដូច្នេះ ការគាំទ្រគម្រោងថវិកាអាចជួយបានតាមមធ្យោបាយបី គឺ (ក) លើកកម្ពស់ភាពជាម្ចាស់និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលនៃអាទិភាពគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍នានា (ខ) ការងារគណនេយ្យដែលមានការតាមដាននិងតម្លាភាពត្រឹមត្រូវជាងមុន នៃជំនួយក្រៅប្រទេស (គ) ការតាមដានមើល និងគណនេយ្យភាពក្នុងប្រទេស តាមរយៈស្ថាប័នប្រជាធិបតេយ្យនានា សម្រាប់ការទទួលនិងប្រើប្រាស់មូលនិធិក្រៅប្រទេស ។ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំ

[១] ប្រសិនបើគេសន្មតថា ជំនួយបច្ចេកទេសដាច់ៗគ្នាបន្ថែមមានចំនួន ៦០០លានដុល្លារ ហើយគម្រោងមិនមែនអាទិភាពដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសក្នុងទឹកប្រាក់ប្រមាណ ២០០លានដុល្លារ នោះ គម្លាតនឹងកើនឡើងដល់ ៨០០លានដុល្លារ ។ ធនធានបន្ថែមដែលត្រូវការចាំបាច់ដើម្បីបំពេញគម្លាតដែលធ្វើឱ្យកើនឡើងនូវការចំណាយសរុបក្នុងវិស័យសាធារណៈក្នុងអំឡុងពេលនៃ *ផយអជ* នឹងកើនដល់ ៤.៣០០លានដុល្លារ ។

ស្វែងរកកិច្ចសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសនានា ដើម្បីឈានឆ្ពោះទៅរក "*ការគាំទ្រគម្រោងថវិកា*" ដែលជាយន្តការដ៏ប្រសើរបំផុតសម្រាប់ការផ្តល់ការគាំទ្រពីខាងក្រៅ ប៉ុន្តែត្រូវទទួលស្គាល់ថា ដំណើរការនេះអាចត្រូវប្រើពេលវេលាយូរឆ្នាំ ដើម្បីរៀបចំនិងធ្វើឱ្យមានវឌ្ឍនភាព ។ ដើម្បីចាប់ផ្តើមការងារនេះ រាជរាជរដ្ឋាភិបាលត្រូវធ្វើសុខដុមនីយកម្មកម្មវិធីជំនួយ តាមរយៈវិធីសាស្ត្រនានា ដូចជា អភិក្រមគ្រប់គ្រងទូទាំងតាមវិស័យ ដើម្បី សម្រេចបានភាពរលូននិងភាពពង្កឹត្នា ហើយចៀសវាងបាននូវការត្រួតគ្នានិងការធ្វើសារឡើងវិញ ។ ការងារនេះគួរដំណើរការតាមរយៈបណ្តាក្រុមការងារបច្ចេកទេស ។

**៥.១៨** គម្លាតប្រមាណ ២២៥លានដុល្លារ ស្មើនឹង ៦,៤៣ភាគរយនៃការចំណាយសរុបដែលបានប៉ាន់ស្មាន ចំនួន ៣.៥០០លានដុល្លារ បានគ្រោងដោយ *ផយអជ* ។ គម្លាតនេះអាចកើនឡើងច្រើន ប្រហែល ១.០២៥លានដុល្លារ ប្រសិនបើសេណារីយោដែលមានក្នុងកឋាខ័ណ្ឌ៥.១៥ (មើលកំណត់សម្គាល់នៅទំព័រ១១២) ទទួលជោគជ័យ ។ រាជ-រដ្ឋាភិបាលជឿជាក់ថា បញ្ហានេះអាចសម្រេចបាន តាមរយៈ :

- ចំណូលបន្ថែមរបស់រាជរដ្ឋាភិបាល ដែលអាចកើនឡើងពីការខិតខំប្រឹងប្រែងកៀរគរចំណូលក្នុងស្រុក និងលទ្ធភាពការធ្វើអាជីវកម្មប្រេង និងឧស្ម័នបម្រុងរបស់ប្រទេសបានជោគជ័យ ។
- ចំពោះស្ថានភាពប្រទេសដែលមានការអភិវឌ្ឍតិចតួច ហើយស្ថានភាពរបស់កម្ពុជា ដែលជាប្រទេសសាកល្បងសម្រាប់ភាពរលូននិងសុខដុមនីយកម្ម មូលនិធិបន្ថែមពិសេសពីបណ្តាដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ជាផ្នែកនៃការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដោយការបង្កើនបណ្តាចំណុចដៅជំនួយអភិវឌ្ឍន៍ឱ្យខិតទៅជិត ០,៧ភាគរយនៃ ផសស (សេចក្តីប្រកាសនៅទីក្រុងម៉ុងតេរេ ឆ្នាំ២០០២) ជាពិសេស ដោយគិតចំពោះស្ថានភាពរបស់កម្ពុជា ទាំងជាប្រទេសអភិវឌ្ឍន៍តិចតួច ទាំងជាប្រទេសសាកល្បងសម្រាប់សុខដុមនីយកម្ម និងការតម្រឹមតម្រង់ ។
- ធនធានដែលបានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមិនមែនជាប្រពៃណី ។
- មូលនិធិដែលបានបន្ធូរបន្ថយ តាមរយៈការបន្ធូរបន្ថយបំណុលដែលអាចធ្វើបាន ។

**៥.១៩** កម្ពុជាទទួលជំនួយក្រៅប្រទេស ទាំងប្រាក់កម្ចី និងជំនួយឥតសំណង ប៉ុន្តែជាប្រទេសមានការអភិវឌ្ឍតិចតួច មិនអាចទ្រទ្រង់នឹងបន្ទុកប្រាក់កម្ចី ទោះជាដូចនេះក្តី កម្ពុជាអាចទទួលបានសម្បទាន ព្រោះថា ប្រជាជនជំនាន់ក្រោយមិនអាចទទួលបន្ទុកសងបំណុលនេះបាន ។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាមានបំណង :

- ទទួលជំនួយពីក្រៅប្រទេសភាគច្រើនក្នុងទម្រង់ជំនួយឥតសំណងឱ្យបានច្រើនតាមដែលអាចធ្វើបាន ដែលត្រូវប្រើប្រាស់សម្រាប់វិស័យសង្គមកិច្ចទាំងអស់ និងផ្តល់មូលនិធិដោយផ្ទាល់ដល់ថ្នាក់មូលដ្ឋាន[១] ដោយធ្វើការកាត់បន្ថយកម្រិតនៃជំនួយបច្ចេកទេស ការធ្វើអង្កេត និងការងារប្រហាក់ប្រហែលផ្សេងៗទៀត ។

[១] សូមមើល កឋាខ័ណ្ឌ ៤.០៤

- ទុនបម្រុងការប្រើប្រាស់កម្ចីក្នុងទម្រង់សម្បទានឬពាក់កណ្តាលសម្បទាន ឱ្យបានច្រើនតាមអាចធ្វើបាន ក្រោយមកក្នុងលក្ខណៈប្រុងប្រយ័ត្នតែលើចំណាយមូលធនសំខាន់ៗ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ឬអាទិភាពខ្ពស់ អាចវាស់វែងបាន មានចំណូលច្បាស់លាស់ ឬកម្មវិធីនានាដែលបង្កើតទិន្នផលឬចំណូល ។

## កម្មវិធី : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ និងថវិកាប្រចាំឆ្នាំ

**៥.២០** វិភាជន៍ហិរញ្ញវត្ថុដែលបានធ្វើឡើងសម្រាប់វិស័យផ្សេងៗនៅក្នុង *ផយអជ* (តារាង ៥.២) មានទិសដៅ ឬការតម្រង់ទិសទូលំទូលាយឆ្ពោះទៅមុខ ។ ដើម្បីឱ្យក្លាយទៅជាប្រតិបត្តិការវិភាជន៍ហិរញ្ញវត្ថុដែលត្រូវបញ្ចប់នៅពេលមានគម្រោងសំណើច្បាស់លាស់សម្រាប់ទុនជាក់ស្តែង និងចំណាយចរន្តលើមូលដ្ឋានប្រចាំឆ្នាំ ។ ដើម្បីសម្រេចគោលបំណងនេះ យន្តការកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលដែលមានស្រាប់ នឹងត្រូវបានប្រើប្រាស់សម្រាប់កំណត់ផែនការ ដំណាក់កាល និងចំណាយប៉ាន់ស្មានលើសកម្មភាពជាក់លាក់ក្នុងឆ្នាំនីមួយៗ សម្រាប់រយៈពេល៣ឆ្នាំបន្ទាប់ ។ ធ្វើដូច្នេះ វិស័យនីមួយៗ ឬថ្នាក់ក្រោមជាតិ នឹងចងចាំកាន់តែច្បាស់នូវគោលដៅរួមនានាដែលត្រូវសម្រេច និងចំណុចដៅច្បាស់លាស់ដែលនៅកំណត់ក្នុង *ផយអជ* ។ ក្នុងការរៀបចំផែនការវិនិយោគសម្រាប់ឆ្នាំនីមួយៗ ដោយផ្អែកលើទុន ឬមធ្យោបាយរបស់វិស័យនីមួយៗ និងថ្នាក់ក្រោមជាតិ ស្ថាប័នកណ្តាលនានា[១] នឹងធានាថា *ក្រវស* ត្រូវអនុវត្តតាមទិសដៅ តាមការគូសបញ្ជាក់ និងតាមការចង្អុលបង្ហាញក្នុងន័យចំណាយវិនិយោគដែលមាននៅក្នុង *ផយអជ* ដែលត្រូវពិនិត្យនិងកែសម្រួលឡើងវិញពីពេលមួយទៅពេលមួយ ។ សំណើ ឬគម្រោងនានាដែលមិនអនុលោមទៅតាម ឬមិនសមស្របទៅនឹង *ផយអជ* នឹងមិនអាចត្រូវបានចាត់ជាអាទិភាពក្នុង *ក្រវស* ទេ។

**៥.២១** ដូចបានពិចារណាខាងដើម ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសបានជំរុញយ៉ាងខ្លាំងក្លានិងបន្ទាន់ដើម្បីធានាថា បញ្ឈប់ការគាំទ្ររបស់ខ្លួនលើកម្មវិធី ឬគម្រោងដែលគ្មានអាទិភាពក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ បញ្ហានេះ នឹងត្រូវបានធានាដោយការលើកទឹកចិត្តដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អនុវត្តផ្សារភ្ជាប់ទៅនឹងសេចក្តីណែនាំ និងបែបបទ ដែលបានចែងក្នុងក្របខ័ណ្ឌការគ្រប់គ្រងសហប្រតិបត្តិការអភិវឌ្ឍន៍ថ្មី ដែលនឹងបញ្ចប់ក្នុងពេលឆាប់ៗខាងមុខ។ ទោះជាយ៉ាងនេះ កម្មវិធី និងគម្រោងនានាដែលត្រូវបានទទួលស្គាល់ថាបានចាប់ផ្តើមរួចហើយ ត្រូវបន្តដំណើរការតាមដំណើរ ។ ប៉ុន្តែទោះក្នុងករណីទាំងនោះ រាល់ការប្រឹងប្រែងត្រូវតែប្តូរទិសកម្មវិធី ឬគម្រោងឆ្ពោះទៅអាទិភាពនៃ *ផយអជ*[១] ។

---

[១] ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

[១] ការងារនេះត្រូវអនុវត្តតាមរយៈក្រុមការងារបច្ចេកទេសនានា ។

**៥.២២** រាជរដ្ឋាភិបាលកម្ពុជានឹងធានាថា ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងវិភាជន៍ចំណាយថវិកាប្រចាំឆ្នាំ ត្រូវបានបង្កើតឡើងក្នុងពេលជាមួយគ្នានឹងវិភាជន៍គោលដៅ និងចំណុចដៅព្រមទាំងក្របខ័ណ្ឌ *កវស* (ដែលគោលបំណង គឺធ្វើឱ្យស្របជាមួយនឹងវិភាជន៍ និងចំណុចដៅរបស់ *ផយអជ* ) ។ ដូច្នេះពីជំហានមូលដ្ឋានមួយទៅជំហានមូលដ្ឋានមួយ គោលដៅ ចំណុចដៅ និងវិភាជន៍ទូទៅរបស់ *ផយអជ* ដូចខណៈដែលពិនិត្យកែលម្អពីពេលមួយទៅពេលមួយ បានណែនាំ ដឹកនាំ និងមានឥទ្ធិពលដល់ *កវស* និងថវិកាប្រចាំឆ្នាំ ។

**៥.២៣** ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងរៀបចំ និងបញ្ចប់ជាស្ថាពរនៅចុងឆ្នាំ២០០៥ ។ ដោយកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ស្តីពីការកៀរគរជំនួយនៅពេលខាងមុខ នឹងប្រព្រឹត្តទៅតែមួយលើកនៅ ខែមីនា ឆ្នាំ២០០៦ ការបង្ហាញកម្មវិធីវិនិយោគសាធារណៈឆ្នាំ២០០៦-២០០៨ នាពេលប្រជុំនោះនឹងត្រូវធ្វើឱ្យមានភាពស៊ីសង្វាក់ជាមួយនឹងអាទិភាពដែលបានកំណត់នៅក្នុង *ផយអជ* នេះ។ ទោះយ៉ាងនេះក្តី ថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំ២០០៦ ត្រូវបានរៀបចំរួចរាល់ជាស្ថាពរនៅខែធ្នូ ឆ្នាំ២០០៥ ដោយគ្មានបន្សល់ពេលវេលាសម្រាប់សម្រេចបានទំនាក់ទំនងច្បាស់លាស់ជាមួយ *ផយអជ* និង *កវស* ។ ប៉ុន្តែ ជាគម្រោងចំណាយថវិកាដែលត្រូវបានទទួលស្គាល់ជាទូទៅទំនងមានក្នុងទិសដៅលើកឡើងក្នុង *ផយអជ* ប្រសិនជាមានការខុសគ្នា នោះក៏ស្ថិតក្នុងកម្រិតបន្តិចបន្តួច ។ ដំណើរការនៃប្រតិបត្តិការក្នុងពេលតែមួយរវាង *ផយអជ កវស* និងគម្រោងថវិកាប្រចាំឆ្នាំមានភាពរលូនពេញទំហឹងនឹងត្រូវបានធានាច្បាស់លាស់ពីពាក់កណ្តាលឆ្នាំ២០០៦ តទៅ[១] ។ ស្ថាប័នកណ្តាលសំខាន់បួនរបស់រាជរដ្ឋាភិបាល[២] ដែលមានទំនាក់ទំនងគ្នាទៀងទាត់នឹងធានាថា កិច្ចព្រមព្រៀងនេះសម្រេចបានទាន់ពេលវេលា ។ ធ្វើយ៉ាងដូច្នេះ ស្ថាប័នទាំងបួន អាចពិនិត្យទៅលើទិដ្ឋភាពទាំងមូលសម្រាប់វិស័យនីមួយៗ និងការប្រើប្រាស់ចំណាយថវិកា ដូចដែលវិភាជន៍មិននៅឈរតែឯកឯង ប៉ុន្តែដូចជាការបំពេញបន្ថែមមធ្យោបាយទៅក្នុងកម្មវិធីគាំទ្រពីខាងក្រៅប្រទេស[៣] ។

**៥.២៤** *ផយអជ* អមដោយ *កវស* សម្រាប់ឆ្នាំ២០០៦-២០០៨ នឹងត្រូវតែជាឯកសារផែនការរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរជំនួយ នាកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងខែមីនា ឆ្នាំ២០០៦ ។ នៅបណ្តាឆ្នាំក្រោយៗមកទៀត

---

[១] បែបបទដែលបានគ្រោងក្នុងជំពូក ៦ ។

[២] ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

[៣] ប្រសិនបើការចំណាយលើជំនួយទាំងអស់មិនបានធ្វើឡើងតាមរយៈការគាំទ្រថវិកា (តាមរយៈថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា) នោះការចំណាយទាំងឡាយនៅក្នុងថវិកាដែលគ្រាន់តែជាផ្នែកមួយនៃការចំណាយសាធារណៈសរុបសម្រាប់វិស័យនីមួយៗ នឹងមិនបានឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដអំពីនៃការបែងចែកនៅក្នុងវិស័យនីមួយៗ ក្នុងការចំណាយសាធារណៈសរុបទេ ។ ដូច្នេះ រូបភាពរួមគួរតែត្រូវបានពិនិត្យមើល ដើម្បីឱ្យបានដឹងពីរបៀបនៃចំណែករបស់វិស័យនីមួយៗក្នុងការចំណាយសាធារណៈ ហើយមិនត្រូវពិនិត្យមើលតែចំណែកនៅក្នុងថវិកា ដែលគ្រាន់តែជាប្រភពតែមួយគត់នៃការផ្តល់ថវិកាសម្រាប់វិស័យសាធារណៈប៉ុណ្ណោះទេ ។

របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត *ផយអជ* ប្រចាំឆ្នាំ[១] និងការកែលម្អ *ករស* នឹងជាឯកសារគោលរបស់រាជរដ្ឋាភិបាលសម្រាប់បណ្តាកិច្ចប្រជុំក្បៀរគរជំនួយ ។

**៩.២៥** តាមរយៈសេចក្តីប្រកាសអន្តរជាតិកម្រិតខ្ពស់នៅទីក្រុងរ៉ូម និងទីក្រុងប៉ារីស[២] នោះ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់បានប្តេជ្ញាក្នុងការបន្សុីគ្រប់កម្មវិធីជំនួយទាំងអស់ ទៅនឹងអាទិភាព និងបណ្តាផែនការអភិវឌ្ឍន៍ទាំងអស់ក្រោមការដឹកនាំ និងភាពជាម្ចាស់របស់បណ្តាប្រទេសអ្នកទទួលជំនួយ ។ ដើម្បីចាប់ផ្តើមដំណើរការបន្សុីសម្រាប់រយៈពេលនេះ រាជរដ្ឋាភិបាលនឹងសំណូមពរដល់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស[៣] ដោយធ្វើការចាប់ផ្តើមពីកិច្ចប្រជុំក្បៀរគរជំនួយនៅខែមីនា ឆ្នាំ២០០៦ ដោយមិនត្រឹមតែបង្ហាញពីចំនួនសរុបដែលជាជំនួយនឹងផ្តល់ជូនកម្ពុជាក៏ប៉ុន្តែត្រូវធ្វើការបញ្ជាក់ច្បាស់ផងដែរ ស្តីពី (ក) បរិមាណទឹកប្រាក់ដែលនឹងផ្តល់ជូនតាមវិស័យនីមួយៗ ក្នុងលក្ខណៈស្រដៀងគ្នាជាមួយនឹងវិភាជន៍ *ផយអជ* (ខ) លទ្ធភាពបន្តនូវប្រភេទកម្មវិធីឬគម្រោងនានា ដែលផ្តល់ការគាំទ្រស្របជាមួយនិងការវិភាជន៍ហិរញ្ញវត្ថុសម្រាប់វិស័យនីមួយៗ (គ) បរិមាណទឹកប្រាក់ដែលត្រូវចំណាយសម្រាប់បណ្តាកម្មវិធីឬគម្រោងនានាកំពុងដំណើរការ (ឃ) មានថវិកាសម្រាប់គម្រោងថ្មីៗ (ង) ដោយពុំគិតបញ្ចូលនូវជំនួយបច្ចេកទេសទៅនឹងបរិមាណសរុប ។

**៩.២៦** ដូចបានបញ្ជាក់ជូនរួចមកហើយ *ផយអជ* គឺជាឯកសាររស់ និងអាចកែសម្រួលបាន និងជាឧបករណ៍ណែនាំមានការប្រែប្រួល មានសមត្ថភាពសម្រួល និងកាត់តម្រឹមទៅតាមទិន្នន័យដែលបានរួមបញ្ចូលគ្នា និងតាមកាលៈទេសៈ ។ ដូច្នេះ លទ្ធផលនិងផលប្រយោជន៍ចុងក្រោយស្តីពីគោលដៅនិងចំណុចដៅសំខាន់ៗ នឹងត្រូវតាមដានត្រួតពិនិត្យនិងវាយតម្លៃយ៉ាងទៀងទាត់ ដើម្បីពិភាក្សាក្នុងការកែតម្រូវប្រចាំឆ្នាំក្នុង *ផយអជ* ។ វិធីសាស្ត្រ និងនីតិវិធីនានា សម្រាប់ការកែតម្រូវប្រចាំឆ្នាំទាំងនោះ នឹងត្រូវពន្យល់បកស្រាយក្នុងជំពូក៦ ។

---

[១] សូមមើលជំពូក ៦ សម្រាប់ការលម្អិតបន្ថែម

[២] សូមមើលជំពូក ៤ កឋាខ័ណ្ឌ ៤.២៩

[៣] ជាពិសេស ដោយសារតែកម្ពុជាគឺជាប្រទេសសាកល្បងមួយសម្រាប់កិច្ចខិតខំប្រឹងប្រែងនេះ ។

## តារាង៩.២ : វិភាជន៍របស់ *វិយអជ* តាមវិស័យ ២០០៦-២០១០

(គិតជាលានដុល្លារអាមេរិក)

| វិស័យ | បរិមាណ | បរិមាណ | ភាគរយ | ជនបទ | ភាគរយ | ទីប្រជុំជន | ភាគរយ | កំណត់ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | ១ |
| **វិស័យសង្គមកិច្ច** | | | | | | | | |
| អប់រំ: អប់រំមូលដ្ឋាន ៦០% | ៥៥០ | | ១៥,៧១ | ៣៣០ | ៦០ | ២២០ | ៤០ | ២ |
| សុខាភិបាល | ៦០០ | | ១៧,១៤ | ៤២០ | ៧០ | ១៨០ | ៣០ | |
| **សរុប** | | **១.១៥០** | **៣២,៨៦** | | | | | |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី:ផ្សេងពីធញ្ញជាតិ | ១៥០ | | ៤,២៩ | ១៤៣ | ៩៥ | ៨ | ៥ | ៣ |
| ធញ្ញជាតិតាមរដូវ: ស្រូវ និងផ្សេងៗ | ២០០ | | ៥,៧១ | ២០០ | ១០០ | ០ | | |
| អភិវឌ្ឍន៍ជនបទ | ៣៥០ | | ១០,០០ | ៣៥០ | ១០០ | ០ | | ៤ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៨០ | | ២,២៩ | ១២ | ១៥ | ៦៨ | ៨៥ | ៥ |
| **សរុប** | | **៧៨០** | **២២,២៩** | | | | | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាស | ៥៥០ | | ១៥,៧១ | ២៧៥ | ៥០ | ២៧៥ | ៥០ | ៦ |
| ទឹក និងអនាម័យ (មិនគិតជនបទ) | ១៥០ | | ៤,២៩ | ១៥ | ១០ | ១៣៥ | ៩០ | ៧ |
| ថាមពល និងអគ្គិសនី | ១២០ | | ៣,៤៣ | ៦០ | ៥០ | ៦០ | ៥០ | ៨ |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៦០ | | ១,៧១ | ៣០ | ៥០ | ៣០ | ៥០ | ៩ |
| **សរុប** | | **៨៨០** | **២៥,១៤** | | | | | |
| **សេវាកម្ម និងកម្មវិធីអន្តរវិស័យ** | | | | | | | | |
| ការបញ្ជ្រាបយេនឌ័រ | ៣០ | | ០,៨៦ | ៩ | ៣០ | ២១ | ៧០ | ១០ |
| ទេសចរណ៍ | ៣០ | | ០,៨៦ | ៨ | ២៥ | ២៣ | ៧៥ | |
| បរិស្ថាន និងអភិរក្ស | ១០០ | | ២,៨៦ | ៩០ | ៩០ | ១០ | ១០ | ១១ |
| សហគមន៍ និងសេវាកម្មសង្គម | ៨០ | | ២,២៩ | ៦០ | ៧៥ | ២០ | ២៥ | |
| វប្បធម៌ និងសិល្បៈ | ៣០ | | ០,៨៦ | ១៥ | ៥០ | ១៥ | ៥០ | |
| អភិបាលកិច្ច និងរដ្ឋបាល | ២២០ | | ៦,២៩ | ៤៤ | ២០ | ១៧៦ | ៨០ | ១២ |
| **សរុប** | | **៤៩០** | **១៤,០០** | | | | | |
| **មិនទាន់បែងចែក** | | **២០០** | **៥,៧១** | ១០០ | ៥០ | ១០០ | ៥០ | ១៣ |
| **សរុបរួម** | | **៣.៥០០** | **១០០** | **២.១៦០** | **៦២%** | **១.៣៤០** | **៣៨%** | **១៤** |

***កំណត់ពន្យល់ :***

១. ក. បរិមាណតាមវិស័យនីមួយៗរួមមាន : ធនធានដែលបានមកពីគ្រប់ប្រភពទាំងអស់ : រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ចំណាយផ្ទាល់ឬតាមរយៈរាជរដ្ឋាភិបាលកម្ពុជា) ។

ខ. ចំណាយមូលធន ចំណាយចរន្តបន្ថែម ជំនួយបច្ចេកទេស ចំណាយក្នុងការតាមដានត្រួតពិនិត្យ ប្រមូលទិន្នន័យ ការថែរក្សាគេហទំព័រ ។

គ. តួលេខជនបទ-ទីប្រជុំជន ត្រូវបានចង្អុលបង្ហាញ និងគប្បីរួមបញ្ចូលគ្នា ។

ឃ. បរិមាណទាំងនេះ ក៏រួមទាំងការផ្តល់ប្រាក់ជំនួយទាំងអស់ទៅថ្នាក់ខេត្ត ស្រុក និងឃុំ សម្រាប់អនុវត្តដោយផ្ទាល់ ។

២. ក. រួមទាំង យុវជន និងកីឡា ។

ខ. ៦០ភាគរយ នៃចំនួនសរុប នឹងត្រូវបែងចែកសម្រាប់ការអប់រំមូលដ្ឋាន ។

៣. រួមទាំង ការនេសាទ ការបោសសម្អាតមីន និងសកម្មភាពផ្សេងៗក្រៅពីដំណាំតាមរដូវ មិនរាប់បញ្ចូលរុក្ខាប្រមាញ់ដែលបានបង្ហាញនៅក្នុងផ្នែកបរិស្ថាន និងអភិរក្ស ។

៤. ការអភិវឌ្ឍជនបទ : រួមទាំង កម្មវិធីសីលា ផ្លូវជនបទ ទីផ្សារ គម្រោងប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកនិងអនាម័យ វិមជ្ឈការនិងវិសហមជ្ឈការ អភិបាលកិច្ចមូលដ្ឋាន ។

៥. រួមបញ្ចូលនូវ : ការបង្កើតការងារ និងបញ្ហាកម្លាំងពលកម្ម ។

៦. មិនរាប់បញ្ចូល ផ្លូវជនបទ ។ ផ្លូវជាតិនិងផ្លូវខេត្ត មានផលប្រយោជន៍ដល់តំបន់ជនបទ ដូច្នេះផ្លូវទាំងពីរប្រភេទនេះមានសមាមាត្រ ៥០ភាគរយ ។ ត្រូវមានការចូលរួមពីផ្នែកឯកជន។ រួមបញ្ចូលទាំង ចំណាយបន្ថែមលើការថែទាំ ។

៧. មិនរាប់បញ្ចូលសកម្មភាពនៅតំបន់ជនបទ ដែលបានកំណត់នៅក្នុងការអភិវឌ្ឍជនបទ ។

៨. ការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។

៩. ការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។

១០ សម្រាប់បង្កើតការយល់ដឹង និងការបញ្ជ្រាប ។ វិស័យដទៃទៀតនឹងបញ្ចូលសកម្មភាពនានាក្នុងការងាររបស់គេ ។

១១ រួមទាំងរុក្ខាប្រមាញ់ ។

១២ រួមទាំង :

ក. កំណែទម្រង់ទាំងអស់ ដូចជា កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច កំណែទម្រង់សារពើពន្ធ និងកំណែទម្រង់ផ្សេងៗទៀត ។

ខ. ការសិក្សានិងការអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ ដូចជា ជំរឿនប្រជាជនឆ្នាំ២០០៨ ការវាយតម្លៃភាពក្រីក្រ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ការតាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ* ។ល។

គ. ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ល។

ឃ. ការបោះឆ្នោតនានា ។

ង. សកម្មភាពរដ្ឋបាលសាធារណៈផ្សេងៗទៀត ។

១៣. ទុនបម្រុងសម្រាប់ការបំបែរទិសដៅប្រើប្រាស់ប្រភពធនធាន បើសិនជាចាំបាច់ ។

១៤. ភាពខុសគ្នាបន្តិចបន្តួចក្នុងតួលេខសរុបនានា (ជនបទ ទីប្រជុំជន) និងតួលេខសរុបរួម អាស្រ័យទៅនឹងការតម្រឹមលេខទសភាគ។

# ជំពូក ៦

# ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

**៦.០១** ដើម្បីធានាថា ការអនុវត្ត *ផយអជ* មានដំណើរការស្របទៅនឹងជំហានដែលចង់បាន ឱ្យសម្រេចគោលដៅនិងចំណុចដៅនានារបស់ *ផយអជ* ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃវឌ្ឍនភាពជាប្រចាំ ទាមទារធ្វើការកែតម្រូវពាក់កណ្តាលអណត្តិជាចាំបាច់ ដោយប្រើប្រាស់លទ្ធផលដែលរកឃើញ និងទិន្នន័យផ្សេងៗទៀត ដែលអាចកើតមាន ។ ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយដែលមានប្រសិទ្ធភាពដែលអាចមានលទ្ធភាព វាយតម្លៃពីវឌ្ឍនភាព និងការផ្តល់ទុនទាន់ពេលវេលា ការឆ្លើយតបប្រចាំឆ្នាំចំពោះអ្នករៀបចំគោលនយោបាយ គឺជាសមាសភាគទាំងមូលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

**៦.០២** ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* នឹងមានក្នុងផ្នែកនៃការអនុវត្តសូចនាករ លទ្ធផលដែលទទួលបានពីក្របខ័ណ្ឌ និងអាទិភាពនៃ *ផយអជ* ស្របជាមួយនឹងយន្តការដែលមាន ប្រសិទ្ធិភាពសម្រាប់តាមដានវឌ្ឍនភាព ។ គោលបំណង ត្រូវធានាការតាមដានត្រួតពិនិត្យ និងការវាយតម្លៃវឌ្ឍនភាពជាប្រចាំ និងទៀងទាត់ពេលកំណត់ ដោយផ្អែកទៅនឹងធាតុចូល លទ្ធផល និងសមិទ្ធផលនៃយុទ្ធសាស្ត្រ និងសកម្មភាពផ្សេងៗនៅក្នុង *ផយអជ* ។

**៦.០៣** ដើម្បីចាប់ផ្តើមអនុវត្តការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនេះ *ផយអជ* ទាំងមូល នឹងត្រូវធ្វើការកែសម្រួលឡើងវិញនៅខែមិថុនា ឆ្នាំ២០០៦[១] ដើម្បីពិចារណាពីធាតុចូលនិងទិន្នន័យបន្ថែមថ្មីនានា ពីគ្រប់វិស័យ និងក្រោមថ្នាក់ជាតិទាំងអស់ ។ បន្ទាប់មក ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយមានចំណែកអ្នកពាក់ព័ន្ធទាំងអស់នៅដើមឆ្នាំ២០០៦ ផែនការលម្អិតតាមវិស័យ និងក្រោមថ្នាក់ជាតិ នឹងត្រូវរៀបចំឡើងឱ្យស្របគ្នាជាមួយនឹងគោលដៅ ចំណុចដៅ និងតម្លៃដែលបានបំបែកចេញ ក៏ដូចជាមធ្យោបាយលម្អិតបន្ថែមទៅលើរបៀបរិភាជន៍ធនធាន នឹងត្រូវប្រើប្រាស់តាមវិធីដែលអាចធ្វើឱ្យបានប្រសើរបំផុត[២] ។ របាយការណ៍ស្តីពីលទ្ធផលដែលទទួលបានពីការងារខាងលើ នឹងត្រូវធ្វើការគិតគូរនៅក្នុង "ការពិនិត្យដំបូង" នៃការអនុវត្ត *ផយអជ* ។ របាយការណ៍

---

[១] ក្រុមការងារបច្ចេកទេសទាំងអស់នឹងចូលរួមនៅគ្រប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្ត *ផយអជ* ។

[២] ដូចបានបង្ហាញក្នុងជំពូក១ ដោយផ្អែកលើគោលដៅនិងចំណុចដៅអាទិភាពជាតិ ក៏ដូចជាការបែងចែកសូចនាករតាមវិស័យដែលបានផ្តល់ក្នុង *ផយអជ* ក្រសួង/ស្ថាប័ននីមួយៗនឹងរៀបចំផែនការលម្អិតតាមផ្នែករបស់ខ្លួននៅខែមិថុនា ឆ្នាំ២០០៦ ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ ។ ដូចគ្នា នេះ ក្រោមថ្នាក់ជាតិ (ខេត្ត ស្រុក និងឃុំ) នឹងធ្វើការពិគ្រោះយោបល់ពីខែមករា-មេសា ឆ្នាំ២០០៦ ដើម្បីរៀបចំផែនការលម្អិតរបស់ខ្លួននៅកន្លែងដែលសមរម្យ ។

នេះនឹងជះឥទ្ធិពលដោយផ្ទាល់ ហើយនឹងត្រូវគិតគូរក្នុងការរៀបចំ *ករស* ឆ្នាំ២០០៧-២០០៩ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ២០០៧-២០១១ និងថវិកាប្រចាំឆ្នាំ២០០៧ ។

**៦.០៤** វឌ្ឍនភាពនៃការអនុវត្ត *ផយអជ* នឹងត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ ហើយរបាយការណ៍នឹងត្រូវរៀបចំដោយផ្អែកតាមការរកឃើញ និងសកម្មភាព កែសម្រួលដែលបានលើកឡើង ។ ការវាយតម្លៃដូចនោះនឹងធ្វើរៀងរាល់ដើមឆ្នាំនីមួយៗ ហេតុដូចនេះ ការតម្រង់ទិសឡើងវិញ និង/ឬការកែតម្រូវដែលអាចធ្វើបាន អាចត្រូវធ្វើតាមរយៈការពិនិត្យប្រចាំឆ្នាំ ។ ដូច្នេះ ការងារការវាយតម្លៃ លើកដំបូងនឹងត្រូវអនុវត្តក្នុងកំឡុងពីខែមករា ដល់ខែមីនា ឆ្នាំ២០០៧ ហើយរបាយការណ៍វឌ្ឍនភាពនឹងត្រូវរៀបចំនៅខែមិថុនា ឆ្នាំ២០០៧ ។ ពេលវេលាដែលបានកំណត់ដូចគ្នានេះដែរ នឹងត្រូវធ្វើការសង្កេតសម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពនៅក្នុងឆ្នាំនីមួយៗ ដែលទទួលបានជោគជ័យ ។ របាយការណ៍វឌ្ឍនភាពនឹងត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយ ហើយនឹង (១) បង្កើតមូលដ្ឋានសម្រាប់ការកែតម្រូវ និងការតម្រង់ទិសឡើងវិញ នៃសកម្មភាពសម្រាប់ឆ្នាំបន្ទាប់ (២) ប្រើប្រាស់ស្របជាមួយនឹង *ករស* ជារបាយការណ៍របស់រាជរដ្ឋាភិបាល ដើម្បីការងារការកៀរគរជំនួយប្រចាំឆ្នាំ (ឧទាហរណ៍ ការប្រជុំក្រុមពិគ្រោះយោបល់ជាដើម) ។ ឯកសារ *ផយអជ* ស្របជាមួយនឹង *ករស* ឆ្នាំ២០០៦-២០០៨ (ស្របគ្នាទាំងស្រុងជាមួយនឹង *ផយអជ*) នឹងជាឯកសារចម្បងរបស់រាជរដ្ឋាភិបាលសម្រាប់ការណែនាំការពិភាក្សានៅឯកិច្ចប្រជុំការកៀរគរជំនួយនាខែមីនា ឆ្នាំ២០០៦ ។

**៦.០៥** ក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃរួមនៃ *ផយអជ* នឹងត្រូវរៀបចំ ដើម្បីអនុវត្តការងារសំខាន់ៗពីរ ។ ទី១ *ផយអជ* នឹងធ្វើការតាមដានត្រួតពិនិត្យប្រចាំឆ្នាំ វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ កម្មវិធី និងការសម្រេចបានគោលដៅ ចំណុចដៅ តាមរយៈការកំណត់ពីរ (១) ធាតុចូល និងលទ្ធផល និង (២) លទ្ធផលនៃការអភិវឌ្ឍ ។ ទី២ *ផយអជ* នឹងគាំទ្រការវាយតម្លៃគោលនយោបាយ កម្មវិធី តាមរយៈការប្រើប្រាស់សូចនាករជាមូលដ្ឋាន ទាំងការពិនិត្យឡើងវិញជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ កម្មវិធីនៃ *ផយអជ* និងការវាយតម្លៃពីទំនាក់ទំនងរវាងការអនុវត្តសកម្មភាព និងការផ្លាស់ប្តូរក្នុងលទ្ធផលដែលគ្រោងទុក ។

**៦.០៦** ទិន្នន័យពីសូចនាករធាតុចូលនិងលទ្ធផល ភាគច្រើននឹងត្រូវប្រមូលតាមរយៈប្រព័ន្ធរដ្ឋបាល ។ សម្រាប់គោលបំណងនេះ អាទិភាពដ៏សំខាន់មួយរបស់ *ផយអជ* នឹងត្រូវដាក់ឱ្យដំណើរការនូវប្រព័ន្ធព័ត៌មានរដ្ឋបាលដែលសមហេតុផល និងដែលអាចជឿទុកចិត្តបាន ។ ផ្ទុយមកវិញ ការវាយតម្លៃគោលនយោបាយឬកម្មវិធី នឹងពាក់ព័ន្ធភាគច្រើនបំផុតជាមួយនឹងសូចនាករលទ្ធផលដែលមានការប្រែប្រួលយឺត ។ សម្រាប់កាតវាយតម្លៃនេះ ប្រភពព័ត៌មានចម្បងគឺ ការធ្វើអង្កេតនានាទៅតាមកាលវេលាកំណត់ ។

**៦.០៧** ក្នុងទស្សនៈសំខាន់បំផុត នៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ ពីការអនុវត្ត *ផយអជ* រចនាសម្ព័ន្ធមួយដែលមានពីរកម្រិត នឹងត្រូវអនុម័តជាក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការរបស់វា ។ នៅថ្នាក់ជាតិ

ចំនួន"សូចនាករសំខាន់ៗ" ដែលបានកំណត់ និងអាចគ្រប់គ្រងបាន នឹងត្រូវប្រើប្រាស់ដើម្បីត្រួតពិនិត្យទំហំសំខាន់ៗនៃវឌ្ឍនភាពប្រចាំឆ្នាំនៃ *ផយអជ* ដែលផ្អែកលើមូលដ្ឋាននេះ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនេះ នឹងត្រូវធ្វើការរៀបចំឡើង ។ កម្រិតទី២នៃរចនាសម្ព័ន្ធ នឹងត្រូវប្រើប្រាស់នៅតាមក្រសួង-ស្ថាប័ន ។ ក្រសួង-ស្ថាប័នពាក់ព័ន្ធនីមួយៗ នឹងរៀបចំបញ្ជីសូចនាកររបស់ខ្លួន ដោយផ្អែកលើ *ផយអជ* សូចនាករនៃ *គអសក* ស្ថិតក្រោមសមត្ថកិច្ច និងសូចនាករផ្សេងៗទៀត ដែលទាក់ទងនឹងគោលបំណងសម្រាប់ការតាមដានត្រួតពិនិត្យតាមវិស័យ ។ គោលបំណងនៃការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ នឹងត្រូវធ្វើឱ្យបានស៊ីជម្រៅ និងលម្អិតបន្ថែម នៅថ្នាក់ក្រសួង-ស្ថាប័ន ដើម្បីគាំទ្រការវិភាគ និងការតាមដានត្រួតពិនិត្យលម្អិតពីគោលនយោបាយ កម្មវិធី និងធ្វើការតម្រង់ទិសឡើងវិញ ។

**៦.០៨** គម្រោងនៃក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* នឹងត្រូវបញ្ចប់នៅខែមិថុនា ឆ្នាំ២០០៦ ដែលជាពេលវេលាសម្រាប់ក្រសួងផែនការ ដាក់ឱ្យដំណើរការក្របខ័ណ្ឌនិងស្ថាប័នដែលចាំបាច់ ដើម្បីធានាលទ្ធផលនៃរបាយការណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* ប្រចាំឆ្នាំ ដោយប្រើប្រាស់សូចនាករសំខាន់ៗ និងព័ត៌មានពាក់ព័ន្ធ ។ សូចនាករដែលមានក្នុងតារាង៣.២ (ជំពូក៣) នឹងត្រូវប្រើប្រាស់ជាសូចនាការសំខាន់ៗនេះ ។ ដូចគ្នានេះដែរ ក្រសួង-ស្ថាប័នពាក់ព័ន្ធនីមួយៗ នឹងបង្កើតក្របខ័ណ្ឌប្រតិបត្តិចាំបាច់នៅខែមិថុនា ឆ្នាំ ២០០៦ ដើម្បីធានាការតាមដានត្រួតពិនិត្យជាប្រចាំនៃសូចនាករដែលបានកំណត់ ។ ក្នុងការជ្រើសរើសសូចនាករក្រសួង-ស្ថាប័ននីមួយៗ នឹងអនុវត្តតាមការណែនាំរួមខ្លះៗ ដើម្បីធានាការដាក់ បញ្ចូលសូចនាករដែល :

- សម្របសម្រួលការធ្វើសេចក្ដីសម្រេចចិត្តដែលបានកំណត់ និងជួយដល់ការកំណត់ឡើងវិញនៃអាទិភាព និង គោលនយោបាយ ។
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព តាមរយៈការកែលម្អការចែករំលែកព័ត៌មាន ។
- ជំរុញឱ្យមានការយោគយល់គ្នាកាន់តែប្រសើរឡើងនៃទំនាក់ទំនងរវាងការអនុវត្ត *ផយអជ* និងផលប៉ះពាល់នៃលទ្ធភាព ។
- មានទស្សនៈច្បាស់លាស់ ដើម្បីបញ្ចូលទៅក្នុងការបង្កើតប្រព័ន្ធទិន្នន័យ ។

ក្រសួងផែនការនឹងបង្កើតទម្រង់របាយការណ៍រួមមួយ និងអនុម័តតារាងពេលវេលា ដើម្បីកំណត់មាតិកា ភាពជាប់លាប់និងពេលវេលាកំណត់នៃការរាយការណ៍របស់ក្រសួង/ស្ថាប័ន តាមរយៈការពិភាក្សាគ្នា ។ ទម្រង់របាយការណ៍នេះ នឹងត្រូវបញ្ចប់នៅខែមិថុនា ឆ្នាំ២០០៦ ។

**៦.០៩** វិទ្យាស្ថានជាតិស្ថិតិ (*វជស*) នៃក្រសួងផែនការ គឺជាស្ថាប័នដែលបានចាត់តាំង និងមានសិទ្ធិអំណាចខាងបច្ចេកទេស ដើម្បីប្រមូល ដំណើរការ និងបង្ហាញទិន្នន័យផ្សេងៗ ដែលទាក់ទងនឹងប្រទេសកម្ពុជា ។ ច្បាប់ស្ថិតិបានអនុម័ត នៅខែមីនា ឆ្នាំ២០០៥ អនុញ្ញាតឱ្យ *វជស* ទទួលខុសត្រូវគ្រប់សកម្មភាពទាំងអស់ ដែល

ទាក់ទងនឹងស្ថិតិ និងការបង្កើតព័ត៌មានផ្សេងៗនៅក្នុងប្រទេស ។ ដូច្នេះ *វជស* នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យមានទិន្នន័យជាប្រចាំអំពីសូចនាករ *ផយអជ* សម្រាប់គោលបំណងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ។ *វជស* ទើបបានបញ្ចប់នាពេលថ្មីៗ អំពីផែនការមេស្តីពីស្ថិតិ[១] សម្រាប់កម្ពុជា ដែលបង្កើតឡើងជាផែនការអាទិភាព សម្រាប់រយៈពេលវែង សម្រាប់ប្រព័ន្ធស្ថិតិជាតិរបស់ប្រទេស ដែលរួមមាន *វជស* អង្គភាពស្ថិតិនៅតាមបណ្តាក្រសួងពាក់ព័ន្ធ និងធនាគារជាតិនៃកម្ពុជា ។ ផែនការមេស្តីពីស្ថិតិផ្តល់ទស្សនៈ យុទ្ធសាស្ត្ររយៈពេលវែង និងផែនការហិរញ្ញប្បទានសម្រាប់សកម្មភាពស្ថិតិ សម្រាប់រយៈពេលពីឆ្នាំ២០០៦-២០១៥ ហើយផែនការមេនេះ ក៏បានគ្រោងផងដែរនូវកម្មវិធីការងារ និងស្ថិតិហេដ្ឋារចនាសម្ព័ន្ធជាអាទិភាព ដែលរួមមានលទ្ធផលស្ថិតិសំខាន់ៗ ដែលត្រូវអនុវត្តក្នុងអំឡុងពេលនោះ ។ ក្នុងក្របខ័ណ្ឌនេះ ផែនការការងាររយៈពេលមធ្យម (២០០៦-២០១០) នឹងត្រូវបញ្ចូលសម្រាប់ការបង្កើតទិន្នន័យស្ថិតិ អំពីសូចនាកររបស់ *ផយអជ* តាមកម្រិតស្មើៗគ្នាតាមតម្រូវការ ។ ដូចគ្នានេះដែរ *វជស* នឹងប្រើប្រាស់កាំអ៊ិនហ្វូ (ប្រព័ន្ធព័ត៌មានរបស់វា) ដើម្បីគាំទ្រការតាមដានត្រួតពិនិត្យ និងការផ្សព្វផ្សាយ ។ ចំពោះសកម្មភាពទាំងអស់ខាងលើសមត្ថភាពរបស់ *វជស* និងស្ថាប័នពាក់ព័ន្ធរបស់ប្រព័ន្ធស្ថិតិជាតិ នឹងត្រូវកែសម្រួលជាបន្តបន្ទាប់ ទាំងផ្នែកជំនាញមនុស្ស និងលទ្ធភាពបច្ចេកទេស ។

**៦.១០** សម្រាប់ការត្រួតពិនិត្យជាប្រចាំនៃដំណើរការ *ផយអជ* លើមូលដ្ឋានប្រចាំឆ្នាំ ផែនការការងាររយៈពេលមធ្យមរបស់ផែនការមេស្តីពីស្ថិតិ អាចបង្កើតយន្តការ ដើម្បីអង្កេតតាមដានប្រចាំឆ្នាំ ឬកំណត់ចន្លោះពេលស្មើៗគ្នា ឬក៏ជំរឿនឬអង្កេតចន្លោះពេលស្មើៗគ្នាវែងជាងនេះ ដូចជា ជំរឿនប្រជាជន ជំរឿនកសិកម្ម ជំរឿនសហគ្រាស អង្កេត សេដ្ឋកិច្ច-សង្គមកិច្ច អង្កេតប្រជាសាស្ត្រនិងសុខភាព និងអង្កេតផ្សេងៗទៀត ។ ទិន្នន័យតាមតំបន់តូចៗ និងទិន្នន័យរបាយការណ៍រដ្ឋបាលជាប្រចាំ ក៏មានសារៈសំខាន់ណាស់ដែរ សម្រាប់គោលបំណងការរៀបចំផែនការដែលបានដៅ និងកម្មវិធីសកម្មភាពនានា ហើយនិងជាការបំពេញបន្ថែមដ៏មានសារៈសំខាន់ចំពោះព័ត៌មានដែលបានពីសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដូចជាអង្កេតគំរូជាតិ ជាដើម ។ ហេតុដូចនេះ ទិន្នន័យមូលដ្ឋានឃុំដែលមាន ត្រូវដើរតួនាទីយ៉ាងសំខាន់ ក្នុងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* ។ ចំពោះបញ្ហាទាំងនេះ នឹង ត្រូវទាមទារការកែលម្អបន្ថែមក្នុងទិន្នន័យមូលដ្ឋាន និងទំនាក់ទំនងទិន្នន័យ រវាង *វជស* ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាមួយក្រោមថ្នាក់ជាតិ ។ ក្រសួងផែនការ នឹងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងរៀបចំក្របខ័ណ្ឌអនុវត្តជាក់ស្តែងមួយ និងវិធីសាស្ត្រក្រោមផែនការការងាររយៈពេលមធ្យម ដើម្បីតាមដានវឌ្ឍនភាព អំពីសូចនាករសំខាន់ៗរបស់ *ផយអជ* នៅខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះ នឹងបង្កើតផ្នែកនៃរបាយការណ៍វឌ្ឍនភាពដំបូងអំពី *ផយអជ* ដែលនឹងត្រូវធ្វើឱ្យរួចរាល់នៅខែមិថុនា ឆ្នាំ២០០៦ ។

---

[១] ផែនការមេស្ថិតិសម្រាប់កម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការន ខែកញ្ញា ឆ្នាំ២០០៥

**៦.១១** សម្រាប់ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនៅថ្នាក់ក្រសួង-ស្ថាប័ន ប្រភពព័ត៌មានសំខាន់ៗ គឺជាប្រព័ន្ធទំនាក់ទំនងរដ្ឋបាលនិងរបាយការណ៍របស់ស្ថាប័នទាំងនោះ ។ នាពេលបច្ចុប្បន្ននេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ រក្សាទិន្នន័យមូលដ្ឋាន និងព័ត៌មានស្ថិតិរបស់ខ្លួនផ្ទាល់ ប៉ុន្តែសមត្ថភាពរបស់ពួកគេ គឺមិនទាន់ស្មើគ្នានៅឡើយ ។ ទស្សនៈសំខាន់ៗនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនៅថ្នាក់ក្រសួង-ស្ថាប័នក្រោមក្របខ័ណ្ឌ *ផយអជ* គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវការកែតម្រូវឱ្យមានលក្ខណៈជាប្រព័ន្ធនូវសមត្ថភាពការប្រមូល និងដំណើរការទិន្នន័យ ជាពិសេស ទំហំសូចនាកររបស់ *ផយអជ* ដែលបានអនុម័ត និងដែលបានលើកឡើងដោយក្រសួង-ស្ថាប័ននានា ។ ការគាំទ្រចាំបាច់នឹងត្រូវផ្តល់ ដើម្បីបង្កើតនិងថែរក្សាគេហទំព័រផ្ទាល់របស់ក្រសួង-ស្ថាប័ននីមួយៗ ដើម្បីធ្វើការកែសម្រួលរៀងរាល់៦ខែម្តង ដែលពួកគេនឹងផ្តល់និន្នន័យពាក់ព័ន្ធអំពីសូចនាករសម្រាប់ប្រើប្រាស់ តាមរយៈប្រព័ន្ធគ្រប់គ្រងផ្ទាល់របស់ពួកគេ ក៏ដូចជាសម្រាប់ផ្ទៃក្នុងរាជរដ្ឋាភិបាល និងការប្រើប្រាស់ជាសាធារណៈ ។

**៦.១២** ជាក់ស្តែង ការអនុម័តក្របខ័ណ្ឌទូលំទូលាយមួយសម្រាប់ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ *ផយអជ* មិនបានរារាំងតម្រូវការដើម្បីអនុវត្តវិធីសាស្ត្រតាមវិស័យ និងវិធីសាស្ត្រចូលរួម ក្នុងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ *ផយអជ* ។ ទាំងអស់នេះ នឹងត្រូវប្រើប្រាស់ជាប្រភពសក្តានុពលដ៏សំខាន់នៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ដែលផ្តោតលើបញ្ហាដែលបានកំណត់ច្បាស់ និងទាន់ពេលវេលា ។ បញ្ហាទាំងនេះនឹងត្រូវបញ្ចូលផងដែរ នូវដំណើរការអនុវត្តន៍ *ផយអជ* ។ ដូចគ្នានេះដែរ ឧបករណ៍ថ្មីៗនិងទាន់សម័យ (ឧទាហរណ៍ ការដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ ទាក់ទងនឹងទស្សនៈនៃការផ្លាស់ប្តូរ និងការពេញចិត្តជាមួយនឹងបរិមាណនិងគុណភាពនៃសេវាសាធារណៈផ្សេងៗ) នឹងត្រូវប្រើប្រាស់ ដើម្បីលើកកម្ពស់សមាសភាពចូលរួម និងសម្លេងប្រជាជននៅមូលដ្ឋាន ដើម្បីបញ្ចូលទៅក្នុងការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ *ផយអជ* ។

# ជំពូក ៧

# សេចក្ដីសន្និដ្ឋាន

**៧.០១** ការយកចិត្តទុកដាក់យ៉ាងពេញលេញក្នុងការធ្វើឱ្យមានវឌ្ឍនភាពរហូតមកដល់ឆ្នាំ២០០៥ និងការទទួលបានជោគជ័យនៃស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ឯកសារនេះត្រូវបានច្របាច់និងរួមបញ្ចូលគ្នារវាង *គអសក* និង *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* និង :

- បង្ហាញយ៉ាងច្បាស់ពី ការកំណត់គ្រប់ជ្រុងជ្រោយនៃគោលដៅម៉ាក្រូទាំងឡាយ ដែលនឹងត្រូវសម្រេចឱ្យបាននៅក្នុងរយៈពេល ៥ឆ្នាំខាងមុខ (២០០៦-២០១០) តាមរយៈការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។
- ធ្វើឱ្យងាយយល់យុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗ ដែលនឹងត្រូវសម្រេចឱ្យបានដោយវិស័យនីមួយៗ និងដោយយកចិត្តទុកដាក់លើបញ្ហាអន្តរវិស័យ ។
- ចង្អុលបង្ហាញការចំណាយហិរញ្ញវត្ថុរួមចាំបាច់សម្រាប់រយៈពេលនោះ និងបានជ្រើសរើសការបែងចែកចំណាយនេះតាមវិស័យ ។
- កំណត់និងបង្ហាញច្បាស់ ពីគ្រប់ធនធានដែលមាន ។
- បង្ហាញពីគម្រោងដែលបានបញ្ចប់និងកំពុងដំណើរការរបស់ *ផយអជ* ទាក់ទងជាមួយ *កវស* និងដំណើរការថវិកាប្រចាំឆ្នាំ ។
- លម្អិតសេចក្ដីត្រូវការសម្រាប់ការតាមដានត្រួតពិនិត្យឱ្យបានជិតដល់ពីវឌ្ឍនភាពនៃការអនុវត្ត *ផយអជ* ក៏ដូចជា វិធីសាស្ត្រដែលនឹងត្រូវរៀបចំឡើងសម្រាប់គោលដៅខាងលើ ។
- បង្ហាញម្ដងហើយម្ដងទៀតថា ឯកសារផែនការនេះជាឯកសារមួយរស់ ប្រែប្រួលតាមកាលៈទេសៈ និងមានលក្ខណៈឌីណាមិច ហើយនឹងត្រូវបានកែសម្រួលដោយរួមច្របាច់បញ្ចូលទិន្នន័យជាច្រើនទៀត និងផ្អែកលើការរកឃើញនៅពេលរៀបចំការពិនិត្យមើលឡើងវិញប្រចាំឆ្នាំ និងរបាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្ត ។

**៧.០២** ឯកសារនេះកំណត់ខ្លួនឯងដើម្បីធ្វើការកំណត់ជារួមលើ កម្រិតជាតិ បណ្ដាគោលដៅជាយុទ្ធសាស្ត្រនិងអាទិភាព បណ្ដាចំណុចដៅឬសូចនាករ និងការវិភាជន៍ធនធាន ។ គោលដៅនិងចំណុចដៅទាំងនេះនឹងត្រូវបំបែកនិងលម្អិតបន្ថែមទៀតនៅតាមវិស័យនិងថ្នាក់ក្រោមជាតិ សម្រាប់ការធ្វើកិច្ចពិគ្រោះយោបល់យ៉ាងទូលំទូលាយ ដែលនឹងធ្វើឡើងនៅក្នុងអំឡុងពេលពីរ-បីខែ ដើមឆ្នាំ២០០៦ ។ កិច្ចពិគ្រោះយោបល់នេះនឹងត្រូវបានសម្រប

សម្រួលដោយក្រសួងផែនការ ធ្វើការសហការជាមួយនឹងស្ថាប័នសំខាន់ៗមួយចំនួន[១] ទៀតដែលទទួលខុសត្រូវក្នុងការកែសម្រួលនិងធ្វើបច្ចុប្បន្នភាព *ផយអជ* ។

**៧.០៣** កត្តាមួយចំនួនដែលមិនអាចថ្លឹងថ្លែងបាន និងមិនអាចប៉ាន់ស្មានទុកមុន ឬមានហានិភ័យ ដែលអាចមានផលប៉ះពាល់លើការអនុវត្ត និងវឌ្ឍនភាពរបស់ *ផយអជ* នោះគឺ :

- ធនធានដែលបានរំពឹងទុកនឹងមិនត្រូវបានទទួល ជាពិសេសពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។
- ថ្លៃឡើងខ្ពស់នៃប្រេងឥន្ធនៈនិងឧស្ម័នលើពិភពលោក នៅតែបន្តឡើងរហូតដល់កម្រិតមិនអាចស្មានដល់ (ជាងពីរដងនៃថ្លៃនៅឆ្នាំ២០០៤) ដែលនឹងជំរុញឱ្យមានអតិផរណាដល់កម្រិតខ្ពស់ ។
- ស្ថានភាពខាងនយោបាយ សន្តិសុខ និងសង្គមក្នុងតំបន់ និងពិភពលោក ដោយសារសកម្មភាពនៃភេរវកម្ម ។
- ឧបសគ្គពាណិជ្ជកម្ម អន្តរជាតិមិនត្រូវបានធ្លាក់ចុះតាមជំហានដែលបានរំពឹងទុក ។
- ការរីករាលដាលនៃជម្ងឺនានាដូចជា ជម្ងឺផ្តាសាយបក្សី និងជម្ងឺថ្មីៗផ្សេងទៀត ។
- គ្រោះធម្មជាតិ កើតចេញមកខុសពីកម្រិតធម្មតា ដូចជា ការសារចុះសារឡើងនៃគ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់ ដែលមានឥទ្ធិពលលើផលិតផលដំណាំ និងបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងទ្រព្យសម្បត្តិ ។

**៧.០៤** មាគ៌ាដែលត្រូវធ្វើដំណើរទៅមុខ មានការប្រឈមនិងការលំបាក ។ ទោះជាដូចនេះក្តី រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា អាចអនុវត្ត *ផយអជ* ក្នុងគ្រប់ប្រធានបទទាំងអស់ ដើម្បីយកចិត្តទុកដាក់ធ្វើការផ្លាស់ប្តូរទៅរកភាពប្រាកដនិយមពីមួយឆ្នាំទៅមួយឆ្នាំ ហើយគ្រប់ធនធានដែលត្រូវការទាំងអស់នឹងមានគ្រប់គ្រាន់ ។ រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា នឹងទទួលបានកិច្ចសហការយ៉ាងពេញលេញពីគ្រប់អ្នករួមចំណែកទាំងអស់ (ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស សង្គមស៊ីវិល និងគ្រប់ក្រសួង/ស្ថាប័នរដ្ឋាភិបាល) ក្នុងការធ្វើឱ្យមានភាពប្រាកដនិយមបណ្តាគោលដៅរបស់ *ផយអជ* ដើម្បីធ្វើឱ្យប្រសើរឡើងការរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេស កាត់បន្ថយឱ្យបានឆាប់រហ័សនូវកម្រិតនៃភាពក្រីក្រ ។

[១] ក្រសួងផែនការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ឧបសម្ព័ន្ធ ១.១

## សូចនាករនិងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

**សំគាល់ :** ១. ឆ្នាំជាមូលដ្ឋាន និងគោលដៅសម្រាប់ឆ្នាំ ២០០៥, ឆ្នាំ២០១០ និងឆ្នាំ២០១៥ ដែលយកពីរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ២០០៣ ។

២. ការសម្រេចបាននៅឆ្នាំ២០០៥ ដែលយកពីការកែលម្អគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា នាខែកញ្ញា ឆ្នាំ២០០៥។

៣. ស្ថានភាព ពីការកែលម្អគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា នាខែកញ្ញា ឆ្នាំ២០០៥ :

- ក : ដំណើរការងារបច្ចុប្បន្នត្រូវតាមចំណុចដៅ និងនៅឆ្នាំ២០១៥ បានសម្រេចលើសការរំពឹងទុក ។
- ខ : ដំណើរការងារបច្ចុប្បន្នត្រូវតាមចំណុចដៅ និងអាចសម្រេចបានតាមចំណុចដៅនៅឆ្នាំ២០១៥ ។
- គ : ដំណើរការងារបច្ចុប្បន្នមិនត្រូវតាមចំណុចដៅ ប៉ុន្តែស្ថានភាពមានភាពប្រសើរជាងឆ្នាំជាមូលដ្ឋាន និន្នាការនេះ ចំណុចដៅនៅឆ្នាំ ២០១៥ ហាក់ដូចជាពុំអាចសម្រេចបាន ។
- ឃ : ដំណើរការងារបច្ចុប្បន្នមិនត្រូវតាមចំណុចដៅ ហើយស្ថានភាពពុំមានភាពប្រសើរជាងឆ្នាំជាមូលដ្ឋាន និន្នាការនេះ ចំណុចដៅនៅឆ្នាំ២០១៥ ហាក់ដូចជាពុំអាចសម្រេចបាន ។
- ង : ដំណើរការងារបច្ចុប្បន្នមិនត្រូវតាមចំណុចដៅ ហើយស្ថានភាពកាន់តែអាក្រក់ជាងឆ្នាំជាមូលដ្ឋាន និន្នាការនេះ ចំណុចដៅនៅឆ្នាំ២០១៥ ហាក់ដូចជាពុំអាចសម្រេចបាន ។

| ល.រ | ពតិមានលំអិត | មូលដ្ឋាន | ឆ្នាំ | ២០០៥ | | ២០១០ | ២០១៥ | ស្ថានភាព |
|---|---|---|---|---|---|---|---|---|
| | | | | ចំណុចដៅ | បាន់ ស្មាន | | | |
| | **គអសក១: លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន** | | | | | | | |
| | **១. កាត់បន្ថយឱ្យបានពាក់កណ្តាលរវាងឆ្នាំ១៩៩៣ និង២០១៥ នូវសមាមាត្រប្រជាជនដែលមានចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ** | | | | | | | |
| ១.១ | កាត់បន្ថយសមាមាត្រប្រជាជនដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (%) | (៣៩) | ១៩៩៣ | ៣១ | ៣៤,៧[1] (២៨.0) | ២៥ | ១៩,៥ | គ |
| ១.២ | បង្កើនសមាសភាគប្រជាជនដែលក្រជាងគេបំផុតក្នុងការចំណាយថ្នាក់ជាតិ (%) | ៧,៤ | ១៩៩៣ | ៩ | | ១០ | ១១ | ង |
| | ប្រៀបធៀបការប៉ាន់ស្មាននៅឆ្នាំ ២០០៤ | (៨,៥) | | | (៧) | | | |
| ១.៣ | កាត់បន្ថយសមាមាត្រកុមារធ្វើការងារដែលមានអាយុពី ៥ ដល់ ១៧ឆ្នាំ (%) | ១៦,៥ | ១៩៩៩ | ១៣ | ២២,៣ | ១០,៦ | ៨ | ង |
| | **២. កាត់បន្ថយឱ្យបានពាក់កណ្តាលរវាងឆ្នាំ ១៩៩៣ និង ២០១៥ នូវសមាមាត្រប្រជាជនដែលទទួលរងនូវការអត់ឃ្លាន** | | | | | | | |
| ១.៤ | កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទម្ងន់ (ទម្ងន់ធៀបនឹងអាយុ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ (%) | ៤៥,២ | ២000 | ៣៦ | ពុំមានតួលេខ | ២៩ | ២២ | |
| ១.៥ | កាត់បន្ថយសមាមាត្រប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ម្ហូបអាហារ (%) | (២០) | ១៩៩៣ | ១៦ | ១៩,៧ (១៤,២)[2] | ១៣ | ១០ | គ |

[1] ទិន្នន័យសម្រាប់ ១.១ និង ១.៥ បង្ហាញពីសភាពការនៅក្នុងតំបន់ (៥៦ភាគរយ នៃបណ្តាភូមិនៅជនបទ និង ៥៦ភាគរយនៃចំនួនគ្រួសារធ្វើអង្កេតនៅឆ្នាំ១៩៩៣ ដែលតំបន់ផ្សេងទៀតនាពេលនោះមានបញ្ហាសន្តិសុខ ។

[2] ដូចគ្នានិងចំណុចខាងលើដែរ ។

| ល.រ | ពតិមានលំអិត | មូលដ្ឋាន | ឆ្នាំ | ២០០៥ | | ២០១០ | ២០១៥ | ស្ថានភាព |
|---|---|---|---|---|---|---|---|---|
| | | | | ចំណុចដៅ | ប៉ាន់ ស្មាន | | | |
| ១.៦ | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារក្រិន (កម្ពស់ធៀបនឹងអាយុ <2SD) ដែលមានអាយុក្រោម ៥ឆ្នាំ (%) | ៤៤.៦ | ២០០០ | ៣៥ | ពុំមានតួលេខ | ២៨ | ២២ | |
| ១.៧ | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារស្គម (ទម្ងន់ធៀបនឹងកម្ពស់ <2SD) ដែលមានអាយុក្រោម ៥ឆ្នាំ (%) | ១៥ | ២០០០ | ១៣ | ពុំមានតួលេខ | ១០ | ៩ | |
| ១.៨ | សមាមាត្រគ្រួសារប្រើប្រាស់អំបិលអ៊ីយ៉ូត (%) | ១៤ | ២០០០ | ៨០ | ៣១.៥ | ៩០ | ៩០ | គ |
| | | | | | | | | |
| | **គអសក២: សម្រេចឱ្យបានជាទូទៅនូវការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ** | | | | | | | |
| | **៣. ធានាឱ្យកុមារទាំងអស់បានបញ្ចប់ការសិក្សាក៏រិតបឋមនៅមុនដំណាច់ឆ្នាំ ២០១០ និងការសិក្សាក៏រិតមូលដ្ឋានរយៈពេល ៩ឆ្នាំ នៅមុនដំណាច់ឆ្នាំ២០១៥** | | | | | | | |
| ២.១ | អត្រាពិតចូលរៀនថ្មី | ៨១ | ២០០១ | ៩៥ | ៨១,០ | ១០០ | ១០០ | ឃ |
| ២.២ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | ៨៧ | ២០០១ | ៩៥ | ៩១,៩ | ១០០ | ១០០ | គ |
| ២.៣ | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ១៩ | ២០០១ | ៥០ | ២៦,១ | ៧៥ | ១០០ | គ |
| ២.៤ | កាត់បន្ថយសមាមាត្រកុមារអាយុ ពី ៦ ដល់ ១៤ឆ្នាំ ដែលមិនបានចូលរៀន (%) | ៣៥ | ១៩៩៩ | ២២ | ១៨,៧ | ១១ | ០ | ក |
| ២.៥ | អត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ទី៥ | ៥៨ | ២០០១ | ៧៧ | ៥៩,២ | ១០០ | ១០០ | ឃ |
| ២.៦ | អត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ទី៦ (ថ្នាក់ចុងក្រោយនៃការសិក្សាបឋមសិក្សា) | ៥១ | ២០០១ | ៧៣ | ៥៣,១ | ១០០ | ១០០ | ឃ |
| ២.៧ | អត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ទី៩ (ថ្នាក់ចុងក្រោយនៃការសិក្សាកម្រិតមូលដ្ឋាន) | ៣៣ | ២០០១ | ៥២ | ៣០,១៨ | ៧៦ | ១០០ | ង |
| ២.៨ | អត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី ១៥ ដល់ ២៤ឆ្នាំ | ៨២ | ១៩៩៩ | ៩០ | ៨៣,៤ | ៩៥ | ១០០ | ឃ |
| | **៤. លុបបំបាត់វិសមភាពយេនឌ័រក្នុងការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ឆ្នាំ** | | | | | | | |
| ២.៩ | ផលធៀបសិស្សស្រី/ប្រុសនៅបឋមសិក្សា (%) | ៨៧ | ២០០១ | ៩៨ | ៨៩.៥ | ១០០ | ១០០ | គ |
| ២.១០ | ផលធៀបសិស្សស្រី/ប្រុសនៅមធ្យមសិក្សាបឋមភូមិ (%) | ៦៣ | ២០០១ | ៩៦ | ៧៧ | ១០០ | ១០០ | គ |
| | | | | | | | | |
| | **គអសក៣: លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធអំណាចដល់ស្ត្រី** | | | | | | | |
| | **៥. កាត់បន្ថយគម្លាតយេនឌ័រនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា** | | | | | | | |
| ៣.១ | បង្កើនផលធៀបរវាងសិស្សស្រី និងសិស្សប្រុសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (%) | ៤៨ | ២០០១ | ៥៥ | ៥៩,៩ | ៨០ | ១០០ | ខ |
| ៣.២ | បង្កើនផលធៀបរវាងនិស្សិតស្រី និងនិស្សិតប្រុសនៅកម្រិតឧត្តមសិក្សា (%) | ៣៨ | ២០០១ | ៥០ | ៤៥,៦ | ៧០ | ៨៥ | គ |
| ៣.៣ | បង្កើនផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរសអាយុពី ១៥ ដល់ ២៤ឆ្នាំ (%) | ៨៧ | ១៩៩៨ | ៩៥ | ៩០,០ | ១០០ | ១០០ | គ |

| ល.រ | ពតិមានលំអិត | មូលដ្ឋាន | ឆ្នាំ | ២០០៥ | | ២០១០ | ២០១៥ | ស្ថានភាព |
|---|---|---|---|---|---|---|---|---|
| | | | | ចំណុចដៅ | ប៉ាន់ ស្មាន | | | |
| ៣.៤ | បង្កើនផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរសអាយុពី ២៥ ដល់ ៤៤ឆ្នាំ (%) | ៧៨ | ១៩៩៨ | ៨៥ | ៨០.០ | ១០០ | ១០០ | គ |
| | **៦. លុបបំបាត់គម្លាតយេនឌ័រ សម្រាប់ការងារមានប្រៀវត្សរ៍នៅគ្រប់វិស័យសេដ្ឋកិច្ច** | | | | | | | |
| ៣.៥ | បង្កើនសមាមាត្រស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យកសិកម្ម (%) | ៣៥ | ១៩៩៨ | ៥០ | ៥២.៥ | ៥០ | ៥០ | ក |
| ៣.៦ | បង្កើនសមាមាត្រស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យឧស្សាហកម្ម (%) | ៤៤ | ១៩៩៨ | ៥០ | ៥៣.៥ | ៥០ | ៥០ | ក |
| ៣.៧ | បង្កើនសមាមាត្រស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យសេវាកម្ម (%) | ២១ | ១៩៩៨ | ៣០ | ២៧ | ៣៧ | ៥០ | គ |
| | **៧. លុបបំបាត់គម្លាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ** | | | | | | | |
| ៣.៨ | បង្កើនសមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ (%) | ១២ | ២០០៣ | ១៧ | ១៧.១ | ២៤ | ៣០ | ខ |
| ៣.៩ | បង្កើនសមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងព្រឹទ្ធសភា (%) | ១៣ | ២០០៣ | ១៧ | ១៤ | ១៤ | ៣០ | គ |
| ៣.១០ | បង្កើនសមាមាត្រស្ត្រីជារដ្ឋមន្ត្រី (%) | ៨ | ២០០៣ | ៩ | ៧.១ | ១២ | ១៥ | ង |
| ៣.១១ | បង្កើនសមាមាត្រស្ត្រីជារដ្ឋលេខាធិការ (%) | ៦ | ២០០៣ | ៨ | ៧.១ | ១៥ | ១៨ | គ |
| ៣.១២ | បង្កើនសមាមាត្រស្ត្រីជាអនុរដ្ឋលេខាធិការ (%) | ៥ | ២០០៣ | ៨ | ១១.៩ | ១៧ | ២០ | ក |
| ៣.១៣ | បង្កើនសមាមាត្រស្ត្រីជាអភិបាលខេត្ត (%) | ០ | ២០០៣ | ៣ | ០ | ៦ | ១០ | ង |
| ៣.១៤ | បង្កើនសមាមាត្រស្ត្រីជាអភិបាលរងខេត្ត (%) | ១ | ២០០៣ | ៤ | ១.៧ | ៨ | ១៥ | ឃ |
| ៣.១៥ | បង្កើនសមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ (%) | ៨ | ២០០៣ | ៨ | ៨.៧ | ១៥ | ២៥ | ក |
| | **៨. កាត់បន្ថយរាល់គ្រប់ទម្រង់នៃអំពើហិង្សាចំពោះស្ត្រី និងកុមារ** | | | | | | | |
| ៣.១៦ | បង្កើនអត្រានៃប្រជាជនដែលដឹងថាអំពើហិង្សាចំពោះស្ត្រីគឺជាអាកប្បកិរិយាខុសឆ្គង និងជាអំពើឧក្រិដ្ឋ (%) | ពុំមានតួលេខ | | ២៥ | ៤.៥ | ៥០ | ១០០ | ង |
| ៣.១៧ | បង្កើនអត្រានៃករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានពិគ្រោះយោល់ដោយបុគ្គលិកដែលមានជំនាញ (%) | ពុំមានតួលេខ | | ២០ | | ៥០ | ១០០ | |
| ៣.១៨ | ច្បាប់ប្រឆាំងអំពើហិង្សាចំពោះស្ត្រី និងកុមារត្រូវបានតាក់តែងឡើង និងអនុវត្តដោយអនុលោមទៅតាមនិយាមអន្តរជាតិ (ឆ្នាំ) | | | ២០០៥ | | | | |
| ៣.១៩ | ប្រមូលទិន្នន័យស្ថិតិប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យអំពើហិង្សាចំពោះស្ត្រី (ឆ្នាំ) | | | ២០០៥ | | | | |
| ៣.២០ | តាក់តែងឡើង និងអនុវត្តផែនការទប់ស្កាត់អំពើហិង្សា (ឆ្នាំ) | | | ២០០៥ | | | | |
| | | | | | | | | |
| | **គអសក៤: កាត់បន្ថយអត្រាមរណភាពកុមារ** | | | | | | | |
| | **៩. បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ** | | | | | | | |

| ល.រ | ពតិមានលំអិត | មូលដ្ឋាន | ឆ្នាំ | ២០០៥ | | ២០១០ | ២០១៥ | ស្ថានភាព |
|---|---|---|---|---|---|---|---|---|
| | | | | ចំណុចដៅ | ប៉ាន់ ស្មាន | | | |
| ៤.១ | កាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ ក្នុង ១.០០០កំណើតរស់ | ១២៤ | ១៩៩៨ | ១០៥ | ៨២ | ៨៥ | ៦៥ | ក |
| ៤.២ | កាត់បន្ថយអត្រាមរណភាពទារក ក្នុង ១.០០០កំណើតរស់ | ៩៥ | ១៩៩៨ | ៧៥ | ៦៦ | ៦០ | ៥០ | ក |
| ៤.៣ | បង្កើនសមាមាត្រកុមារអាយុក្រោម ១ឆ្នាំ បានទទួលការចាក់ថ្នាំការពារជំងឺកញ្ជិល (%) | ៤១.៤ | ២០០០ | ៨០ | ៨០ | ៨៥ | ៩០ | ខ |
| ៤.៤ | បង្កើនសមាមាត្រកុមារអាយុក្រោម ៦-៥៩ ខែ បានទទួលថ្នាំវីតាមីន អា (%) | ២៨ | ២០០០ | ៧០ | ពុំមានតួលេខ | ៨០ | ៩០ | |
| ៤.៥ | បង្កើនសមាមាត្រកុមារអាយុក្រោម ១ឆ្នាំ បានទទួលចាក់ថ្នាំការពារជំងឺខាន់ស្លាក់ ក្អកមាន់ និងតេតាណូស (%) | ៤៣ | ២០០០ | ៨០ | ៨៣ | ៨៥ | ៩០ | ក |
| ៤.៦ | បង្កើនសមាមាត្រទារកត្រូវបានបំបៅដោះដល់អាយុ ៦ខែ (%) | ១១.៤ | ២០០០ | ២០ | ពុំមានតួលេខ | ៣៤ | ៤០ | |
| ៤.៧ | បង្កើនសមាមាត្រនៃម្តាយដែលចាប់ផ្តើមបំបៅដោះទារកទើបនឹងកើតក្នុងរយៈពេលមួយម៉ោងនៃកំណើត (%) | ១១ | ២០០០ | ២៨ | ២៥.៣ | ៤៥ | ៦២ | ក |
| | | | | | | | | |
| | **គអសក៥: លើកកម្ពស់សុខភាពមាតា** | | | | | | | |
| | **១០. បន្ថយផលធៀបមរណភាពមាតា** | | | | | | | |
| ៥.១ | កាត់បន្ថយផលធៀបមរណភាពមាតា ក្នុង ១០០.០០០ កំណើតកូន | ៤៣៧ | ១៩៩៧ | ៣៤៣ | ពុំមានតួលេខ | ២៤៣ | ១៤០ | |
| ៥.២ | កាត់បន្ថយអត្រាលទ្ធភាពផ្តល់កំណើតសរុប | ៤ | ១៩៩៨ | ៣.៨ | ៣.៣ | ៣.៤ | ៣.០ | ក |
| ៥.៣ | បង្កើនសមាមាត្រនៃការសម្រាលកូន ដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ (%) | ៣២ | ២០០០ | ៦០ | ពុំមានតួលេខ | ៧០ | ៨០ | |
| ៥.៤ | បង្កើនសមាមាត្រនៃស្ត្រីរៀបការដែលប្រើប្រាស់វិធីពន្យារកំណើតទំនើប (%) | ១៨.៥ | ២០០០ | ៣០ | | ៤៤ | ៦០ | គ |
| | តែក្នុងផ្នែកសាធារណៈ (%) | (១១.៥) | | | (២០.១) | | | |
| ៥.៥ | បង្កើនសមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលទទួលការពិគ្រោះមុនពេលសម្រាលកូនបានពីរដង ឬច្រើនជាងជាមួយបុគ្គលិកសុខាភិបាលដែលមានជំនាញ (%) | ៣០.៥ | ២០០០ | ៦០ | | ៧៥ | ៩០ | គ |
| | តែក្នុងផ្នែកសាធារណៈ (%) | (២៥.៤) | | | (៤៧) | | | |
| ៥.៦ | កាត់បន្ថយសមាមាត្រស្ត្រីមានផ្ទៃពោះ ដែលមានជំងឺស្លេកស្លាំងខ្វះជាតិដែក (%) | ៦៦ | ២០០០ | ៥០ | ពុំមានតួលេខ | ៣៩ | ៣៣ | |
| ៥.៧ | កាត់បន្ថយសមាមាត្រស្ត្រីអាយុ ១៥ ដល់ ៤៩ឆ្នាំ ដែលមានផលធៀបទម្ងន់នឹងកម្ពស់ក្រោម ១៨.៥ គក/ម៉ែតការ៉េ (%) | ២១ | ២០០០ | ១៧ | ពុំមានតួលេខ | ១២ | ៨ | |
| ៥.៨ | កាត់បន្ថយសមាមាត្រស្ត្រីអាយុ ១៥ ដល់ ៤៩ឆ្នាំ ដែលមានជំងឺស្លេកស្លាំងខ្វះជាតិដែក (%) | ៥៨ | ២០០០ | ៤៥ | ពុំមានតួលេខ | ៣២ | ១៩ | |

| ល.រ | ពតិមានលំអិត | មូលដ្ឋាន | ឆ្នាំ | ២០០៥ | | ២០១០ | ២០១៥ | ស្ថានភាព |
|---|---|---|---|---|---|---|---|---|
| | | | | ចំណុចដៅ | បាន់ ស្មាន | | | |
| ៥.៩ | បង្កើនសមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលសម្រាលកូនដោយការវះកាត់ (%) | ០,៨ | ២០០០ | ២ | ០,៨ | ៣ | ៤ | ឃ |
| | | | | | | | | |
| | **គអសក៦: ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺដទៃទៀត** | | | | | | | |
| | **១១. បន្ថយការរីករាលដាលនៃមេរោគអេដស៍/ ជំងឺអេដស៍** | | | | | | | |
| ៦.១ | កាត់បន្ថយអត្រាប្រេវ៉ាឡង់ មេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥ ដល់ ៤៩ឆ្នាំ (%) | ៣,០ | ១៩៩៧ | ២,៣ | ១,៩ | ២ | ១,៨ | ក |
| ៦.២ | កាត់បន្ថយអត្រាប្រេវ៉ាឡង់ មេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះអាយុពី ១៥ ដល់ ២៤ឆ្នាំ បានពិនិត្យផ្ទៃពោះមុនសម្រាល (%) | ២,៥ | ១៩៩៨ | ២,៤ | ២,១ | ២,០ | ១,៥ | ក |
| ៦.៣ | បង្កើនសមាមាត្រប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ ក្នុងពេលរួមភេទចុងក្រោយ (%) | ៩១ | ២០០២ | ៩៨ | ៩៦,៧ | ៩៨ | ៩៨ | គ |
| ៦.៤ | បង្កើនសមាមាត្រនៃយុវជនអាយុពី ១៥ ដល់ ២៤ឆ្នាំ ដែលបានរាយការណ៍ពីការប្រើប្រាស់ស្រោមអនាម័យក្នុងពេលរួមភេទជាមួយដៃគូមិនទៀងទាត់ (%) | ៨២ | ២០០២ | ៨៥ | ពុំមានតួលេខ | ៩០ | ៩៥ | |
| ៦.៥ | បង្កើនសមាមាត្រនៃការប្រើប្រាស់ស្រោមអនាម័យដែលបានរាយការណ៍ដោយស្ត្រីរៀបការ ដែលដឹងខ្លួនថាស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ (%) | ១ | ២០០០ | ២ | ពុំមានតួលេខ | ៥ | ១០ | |
| ៦.៦ | បង្កើនសមាមាត្រនៃស្ត្រីពិនិត្យផ្ទៃពោះមុនសម្រាលដែលមានផ្ទុកមេរោគអេដស៍ ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្តាយទៅកូន (%) | ២,៧ | ២០០២ | ១០ | ៣,៨ | ៣៥ | ៥០ | គ |
| ៦.៧ | បង្កើនសមាមាត្រនៃអ្នកជម្ងឺអេដស៍ ដែលបានទទួលថ្នាំប្រឆាំងការឆ្លងមេរោគអេដស៍ (%) | ៣ | ២០០២ | ២៥ | ៤៥ | ៦០ | ៧៥ | ក |
| | **១២. បន្ថយការរីករាលដាលនៃជំងឺគ្រុនចាញ់ ជម្ងឺគ្រុនឈាម និងជម្ងឺរបេង** | | | | | | | |
| ៦.៨ | កាត់បន្ថយអត្រាការស្លាប់ដោយសារជម្ងឺគ្រុនចាញ់ ដែលបានរាយការណ៍ដោយមណ្ឌលសុខភាពសាធារណៈ (%) | ០,៤ | ២០០០ | ០,៣ | ០,៣៦ | ០,២៥ | ០,១ | គ |
| ៦.៩ | បង្កើនសមាមាត្រនៃប្រជាជននៅតំបន់មានជម្ងឺគ្រុនចាញ់ខ្ពស់ដែលប្រើមុងជ្រលក់ថ្នាំកាលពីយប់កន្លងមក (%) | ២៤ | ២០០០ | ៨០ | ៤៩ | ៩៥ | ៩៨ | គ |
| ៦.១០ | កាត់បន្ថយចំនួនអ្នកជម្ងឺគ្រុនចាញ់ ដែលទទួលបានការព្យាបាលនៅមណ្ឌលសុខភាពសាធារណៈ ក្នុងប្រជាជន ១.០០០នាក់ | ១១,៤ | ២០០០ | ៩ | ៧,៣ | ៧ | ៤ | ក |
| ៦.១១ | បង្កើនសមាមាត្រនៃសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់ពីរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់ ៩៥% តាមរូបមន្តជាតិ (%) | ៦០ | ២០០២ | ៧០ | ពុំមានតួលេខ | ៨០ | ៩៥ | |

| ល.រ | ពតិមានលំអិត | មូលដ្ឋាន | ឆ្នាំ | ២០០៥ | | ២០១០ | ២០១៥ | ស្ថានភាព |
|---|---|---|---|---|---|---|---|---|
| | | | | ចំណុចដៅ | ប៉ាន់ ស្មាន | | | |
| ៦.១២ | កាត់បន្ថយចំនួនអ្នកជម្ងឺគ្រុនឈាម ដែលទទួលបានការព្យាបាលនៅក្នុងមណ្ឌលសុខភាពសាធារណៈ ក្នុងប្រជាជន ១.០០០នាក់ | ១ | ២០០១ | ០,៨ | ០,៨៤ | ០,៦ | ០,៤ | **គ** |
| ៦.១៣ | កាត់បន្ថយអត្រាស្លាប់ដោយជម្ងឺគ្រុនឈាម ដែលបានរាយការណ៍ដោយបណ្តុលសុខភាពសាធារណៈ (%) | ១,៥ | ២០០៣ | ១ | ០,៧៤ | ០,៥ | ០,៣ | **ក** |
| ៦.១៤ | កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជម្ងឺរបេងសួតវិជ្ជមាន ក្នុងចំណោមប្រជាជន ១០០.០០០នាក់ | ៤២៨ | ១៩៩៧ | ៣២១ | ពុំមានតួលេខ | ២១៤ | ១៣៥ | |
| ៦.១៥ | កាត់បន្ថយអត្រាស្លាប់ដោយជម្ងឺរបេង ក្នុងចំណោមប្រជាជន ១០០.០០០នាក់ | ៩០ | ១៩៩៧ | ៦៨ | ពុំមានតួលេខ | ៤៥ | ៣២ | |
| ៦.១៦ | បង្កើនសមាមាត្រនៃអ្នកដែលបានប៉ាន់ស្មានថាមានករណីរបេងសួតវិជ្ជមានថ្មី បានរកឃើញក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (%) | ៥៧ | ២០០២ | ៧០ | ៦១ | >៧០ | >៧០ | **គ** |
| ៦.១៧ | រក្សាសមាមាត្រនៃអ្នកជម្ងឺរបេងសួតវិជ្ជមាន ដែលបានកត់ត្រាហើយបានព្យាបាលប្រកបដោយជោគជ័យក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (%) | ៨៩ | ២០០២ | >៨៥ | | ៨៥ | ៨៥ | |
| | | | | | | | | |
| | **គអសក៧: ធានាចីរភាពបរិស្ថាន** | | | | | | | |
| | **១៣. បញ្ចូលគោលការណ៍អភិវឌ្ឍន៍ចីរភាព ទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន** | | | | | | | |
| ៧.១ | រក្សានូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (% នៃផ្ទៃដីសរុប) | ៦០ | ២០០២[១] | ៦០ | ៥៨ | ៦០ | ៦០ | |
| ៧.២ | រក្សានូវផ្ទៃដីតំបន់ការពារធម្មជាតិចំនួន ២៣កន្លែង (លានហត) | ៣,៣ | ១៩៩៣ | ៣,៣ | ពុំមានតួលេខ | ៣,៣ | ៣,៣ | |
| ៧.៣ | រក្សានូវតំបន់អភិរក្សព្រៃឈើថ្មីទាំង ៦ (លានហត) | ១,៣៥ | ១៩៩៦ | ១,៣៥ | ពុំមានតួលេខ | ១,៣៥ | ១,៣៥ | |
| ៧.៤ | បង្កើនចំនួនអ្នកអភិរក្សតំបន់ការពារធម្មជាតិ | ៦០០ | ២០០១ | ៧៧២ | ពុំមានតួលេខ | ៩៨៧ | ១,២០០ | |
| ៧.៥ | រក្សាចំនួនអ្នកអភិរក្សតំបន់ព្រៃឈើ | ៥០០ | ២០០១ | ៥០០ | ពុំមានតួលេខ | ៥០០ | ៥០០ | |
| ៧.៦ | បង្កើនសមាមាត្រឡូតិ៍នេសាទដែលប្រគល់ជូនសហគមន៍មូលដ្ឋាន (%) | ៥៦ | ១៩៩៨ | ៥៨ | ៥៦,៤៦ | ៦០ | ៦០ | **គ** |
| ៧.៧ | បង្កើនចំនួនសហគមន៍ឡូតិ៍នេសាទមូលដ្ឋាន | ២៦៤ | ២០០០ | ៣៦៤ | ៣៧៥ | ៤៦៤ | ៥៨៩ | **ក** |
| ៧.៨ | បង្កើនផ្ទៃទីជម្រកសុវត្ថិភាពមច្ឆា (ពាន់ហត) | ២៦៤ | ២០០០ | ៥៨១ | ពុំមានតួលេខ | ៥៨១ | ៥៨១ | |
| ៧.៩ | កាត់បន្ថយការប្រើអុសដុតរបស់គ្រួសារ (%) | ៩២ | ១៩៩៣ | ៧០ | ៨៣,៩ | ៦១ | ៥២ | **គ** |
| | **១៤. កាត់បន្ថយអោយបានពាក់កណ្តាល សមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់ទឹកស្អាតជាប្រចាំនៅដំណាច់ឆ្នាំ ២០១៥** | | | | | | | |
| ៧.១០ | បង្កើនសមាមាត្រប្រជាជន ជនបទដែលមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាត (%) | ២៤ | ១៩៩៨ | ៣០ | ៤១,៦ | ៤០ | ៥០ | **ក** |

[១] ផ្ទៃដីព្រៃ គឺជាតម្លៃមធ្យមក្នុងរយៈកំឡុងពេល ឆ្នាំ១៩៩២-២០០២

| ល.រ | ពតិមានលំអិត | មូលដ្ឋាន | ឆ្នាំ | ២០០៥ | | ២០១០ | ២០១៥ | ស្ថានភាព |
|---|---|---|---|---|---|---|---|---|
| | | | | ចំណុចដៅ | បាន់ ស្មាន | | | |
| ៧.១១ | បង្កើនសមាមាត្រប្រជាជន ទីប្រជុំជនដែលមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាត (%) | ៦០ | ១៩៩៨ | ៦៨ | ៧៥.៨ | ៧៤ | ៨០ | ក |
| | **១៥. កាត់បន្ថយអោយបានពាក់កណ្តាល សមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់អនាម័យប្រសើរជាងមុនជាប្រចាំនៅដំណាច់ឆ្នាំ ២០១៥** | | | | | | | |
| ៧.១២ | បង្កើនសមាមាត្រប្រជាជនជនបទ ដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង (%) | ៨.៦ | ១៩៩៦ | ១២ | ១៦.៤ | ២០ | ៣០ | ក |
| ៧.១៣ | បង្កើនសមាមាត្រប្រជាជនទីក្រុង/ទីប្រជុំជន ដែលមានលទ្ធ-ភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង (%) | ៤៩ | ១៩៩៨ | ៥៥ | ៥៥ | ៦៧ | ៧៤ | គ |
| | **១៦. បង្កើនអត្រាប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ នៅមុនដំណាច់ឆ្នាំ ២០១៥** | | | | | | | |
| ៧.១៤ | បង្កើនអត្រាប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ នៅមុនដំណាច់ឆ្នាំ២០១៥ (%) | ១៥ | ២០០០ | ១៦ | ១៦ | ៣២ | ៦៥ | |
| | **គអសក៨: បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍** | | | ពុំមានចំណុចដៅច្បាស់លាស់ | | | | |
| | ពីចំណុចដៅរួមទី ១៧ ដល់ ២៣ សម្រាប់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមានភាពទូលំទូលាយ សម្រាប់ក្នុងប្រទេសពុំមានចំណុចដៅច្បាស់លាស់ | | | | | | | |
| | | | | | | | | |
| | **គអសក៩: ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ** | | | | | | | |
| | **២៤. ឆ្ពោះទៅរកអត្រាគ្រោះថ្នាក់សូន្យដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ** | | | | | | | |
| ៩.១ | កាត់បន្ថយចំនួនជនរងគ្រោះដោយសារមីនអោយដល់សូន្យនៅត្រឹមឆ្នាំ ២០១២ | ១.៦៩១ | ១៩៩៣ | ៥០០ | ៧៩៧ | ២០០ | ០ | គ |
| ៩.២ | បោសសំអាតតំបន់ដែលសង្ស័យថាមានមីនអោយអស់ (%) | ១០ | ១៩៩៥ | ៥១ | ៥០.៣ | ៧៧ | ១០០ | ខ |
| | **២៥. លុបបំបាត់ផលប៉ះពាល់ជាវិជ្ជមានដល់មនុស្សជាតិ និងសេដ្ឋកិច្ច សង្គមកិច្ចដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះនៅឆ្នាំ២០១៥** | | | | | | | |
| ៩.៣ | បង្កើតក្របខ័ណ្ឌការងារជំនួយទូលំទូលាយមួយដល់ជនរងគ្រោះមុនឆ្នាំ២០០៥ | | | | | ២០០៧ | | |
| ៩.៤ | បង្កើតកញ្ចប់ជំនួយ និងធ្វើសមាហរណកម្មទៅក្នុងសង្គមដល់ជនរងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ | ពុំមានតួលេខ | | កំណត់នៅពេលក្រោយ | | | | |

# ឧបសម្ព័ន្ធ ១.២

## ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

## ដកស្រង់ចេញពីការសម្រួលឆ្នាំ២០០៥[១]

**១.** គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាមាន ៩គោលដៅ ២៥ចំណុចដៅរួម និង ១០៦ចំណុចដៅ ដែលបានផ្តោតលើ (ក) ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ (ខ) សកលកម្មការអប់រំមូលដ្ឋានចំនួន ៩ឆ្នាំ (គ) សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (ឃ) មរណភាពកុមារ (ង) មរណភាពមាតា (ច) មេរោគហ៊ីវ/ជម្ងឺអេដស៍ ជម្ងឺគ្រុនចាញ់ និងជម្ងឺដទៃទៀត (ឆ) ចីរភាពបរិស្ថាន (ជ) បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ និង (ឈ) ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះដោយសារមីន ។ នៅក្នុងសូចនាករជាក់លាក់នៃ *គអសក* នីមួយៗដែលបានលើកឡើង ចំណុចដៅរយៈពេលខ្លី មធ្យម និងវែង ដែលនឹងត្រូវធ្វើឱ្យសម្រេចក្នុងអំឡុងពេល ឆ្នាំ២០០៥-២០១០ និងឆ្នាំ២០១៥ ត្រូវបានកំណត់ឡើង ។

**២.** ទន្ទឹមនឹងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាងមួយទសវត្សរ៍កន្លងទៅ ក្នុងការអនុវត្តគោលនយោបាយគាំទ្រអ្នកក្រ និងកំណែទម្រង់យ៉ាងទូលំទូលាយ ដែលមានគោលបំណងពង្រឹងប្រជាធិបតេយ្យ ការគោរពច្បាប់ និងអភិបាលកិច្ចល្អ ការប្រឈមមុខដ៏ចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍនាពេលបច្ចុប្បន្នគឺ សម្រេចឱ្យបានចំណុចដៅទាំងឡាយដែលបានកំណត់នៅក្នុង *គអសក* ។

### លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ

**៣.** ការប៉ាន់ស្មានពីវឌ្ឍនភាពនៃគោលដៅនេះដោយប្រើប្រាស់ទិន្នន័យមូលដ្ឋានឆ្នាំ១៩៩៣-១៩៩៤ នៅមានចន្លោះខ្វះខាត ព្រោះថា ទិន្នន័យមូលដ្ឋាននេះប្រមូលមកតាមរយៈការធ្វើអង្កេតដែលមិនបានគ្របដណ្តប់ទូទាំងប្រទេសទេ ដោយមូលហេតុសន្តិសុខនៅពេលនោះ ។ ទោះជាដូចនេះក្តី តាមរយៈការប៉ាន់ស្មានដែលមាន បានបង្ហាញថា អត្រាភាពក្រីក្របានថយចុះគួរឱ្យកត់សម្គាល់នៅក្នុងតំបន់ទីប្រជុំជននិងតំបន់ជនបទមួយចំនួនដែលបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ ប៉ុន្តែ បច្ចុប្បន្ននេះ អត្រាភាពក្រីក្រនៅតំបន់ជនបទភាគច្រើនដែលអង្កេតឆ្នាំ១៩៩៣-១៩៩៤ មិនបានគ្របដណ្តប់ និងនៅតំបន់ដែលពិបាកទៅដល់ មានកម្រិតខ្ពស់ជាងច្រើន ។

**៤.** តាមរយៈការប៉ាន់ស្មានដោយប្រើប្រាស់ទិន្នន័យដែលប្រមូលបានដោយប្រើប្រាស់វិធីសាស្ត្រីខល អត្រាប្រជាជនកម្ពុជាដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រមាន ៣៤.៧ភាគរយនៅឆ្នាំ២០០៤ ។ ដោយគ្មានការប៉ាន់ស្មានដែលអាចប្រៀបធៀបគ្នាបាន សម្រាប់ប្រជាជនសរុបក្នុងឆ្នាំ១៩៩៣-១៩៩៤ ទេ ការវាយតម្លៃការប្រែប្រួលនៃភាពក្រីក្រសម្រាប់ទូទាំងប្រទេស មានការលំបាក ។ ទោះជាដូចនេះក្តី ការប្រែប្រួលនៃអត្រាភាពក្រីក្រសម្រាប់

[១] ការសម្រេច *គអសក* លៃសម្រួលឆ្នាំ២០០៥ ក្រសួងផែនការ រាជរដ្ឋាភិបាលកម្ពុជា

ប្រជាជនដែលរស់នៅក្នុងតំបន់ដែលមានស្ថានភាពភូមិសាស្ត្រដូចគ្នានឹងតំបន់ ដែលគ្របដណ្តប់ដោយការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៣-១៩៩៤ ត្រូវបានធ្វើការប៉ាន់ស្មាន ។ ការអង្កេតនេះបានគ្របដណ្តប់តែ ៥៩ភាគរយ នៃតំបន់ភូមិសាស្ត្រទូទាំងប្រទេសកម្ពុជា ហើយបានសាកសួរគ្រួសារតែប្រមាណ ៦៨ភាគរយនៃចំនួនគ្រួសារសរុបប៉ុណ្ណោះ ដោយមិនបានបញ្ចូលនូវអ្នកក្រីក្រជាច្រើន និងតំបន់មួយចំនួនដែលមិនបានគ្របដណ្តប់ដោយអង្កេត ដោយហេតុផលអសន្តិសុខនៅតំបន់នោះ នាពេលនោះ ។ ការប៉ាន់ស្មានដោយផ្អែកលើសំណាកគំរូដែលមានលក្ខណៈអាចប្រៀបធៀបបាន ក្នុងតំបន់ដែលគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ បានបង្ហាញពីការធ្លាក់ចុះយ៉ាងខ្លាំងនៃអត្រាភាពក្រីក្រពី ៣៩ភាគរយនៅឆ្នាំ១៩៩៣-១៩៩៤ មកត្រឹម ២៨ភាគរយនៅឆ្នាំ២០០៤ ។

**៥.** ប្រហាក់ប្រហែលគ្នានេះដែរ អត្រាប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ សម្រាប់ទូទាំងប្រទេសគឺ ១៩,៧ភាគរយនៅឆ្នាំ២០០៤ ប៉ុន្តែពុំមានតួលេខបង្ហាញសម្រាប់ទូទាំងប្រទេសនៅមុនឆ្នាំនេះឡើយ ។ ទោះជាដូចនេះក្តី តាមរយៈការប៉ាន់ស្មានដោយប្រើប្រាស់សំណាកគំរូដូចខាងដើម បង្ហាញថា សមាមាត្រប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ ក៏ធ្លាក់ចុះច្រើនដែរពី ២០ភាគរយនៅឆ្នាំ១៩៩៣-១៩៩៤ មក ១៤,៦ភាគរយនៅឆ្នាំ២០០៤ ក្នុងតំបន់ដែលគ្របដណ្តប់ដោយអង្កេត១៩៩៣-១៩៩៤ ។

**៦.** អត្រាភាពក្រីក្រនៅតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ ដែលបានគណនាពីទិន្នន័យដែលមានគឺ ៤៥,៦ភាគរយក្នុងឆ្នាំ២០០៤ គឺមានកម្រិតខ្ពស់ជាងអត្រាភាពក្រីក្រនៅក្នុងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេត១៩៩៣-១៩៩៤ ដែលមានកម្រិតតែ ២៨ភាគរយប៉ុណ្ណោះ ។ ប្រហាក់ប្រហែលគ្នានេះដែរ សន្ទស្សន៍ភាពក្រីក្រម្ហូបអាហារត្រូវបានប៉ាន់ស្មានថាមានកម្រិត ២៨,៧ភាគរយ នៅតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ គឺខ្ពស់ជាងពីរដងកម្រិតនៅក្នុងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេតខាងលើ ដែលមានតែ ១៤,២ភាគរយប៉ុណ្ណោះ ។

**៧.** នៅពេលដែលភាពជោគជ័យរបស់កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រនៅតំបន់ទីប្រជុំជន និងតំបន់ដែលអាចទៅដល់ជាច្រើនទៀត ត្រូវបានទទួលការកោតសរសើរ បញ្ហាប្រឈមមុខដ៏ធំនៅក្នុងទសវត្សរ៍ខាងមុខ គឺត្រូវកាត់បន្ថយភាពក្រីក្រដែលមានកម្រិតខ្ពស់ នៅតំបន់ជនបទដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ ។ ដើម្បីសម្រេចបានការកាត់បន្ថយភាពក្រីក្រនៅតំបន់ដែលមិនបានគ្របដណ្តប់នេះ និងដើម្បីសម្រេចបានពាក់កណ្តាលចំណុចដៅនៃអត្រាភាពក្រីក្រសម្រាប់ទូទាំងប្រទេសដែលបានកំណត់ក្នុង *គអសក* ពីកម្រិតដែលមានក្នុងឆ្នាំ១៩៩៣-១៩៩៤ កម្ពុជាត្រូវតែបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងរួមចំណែកគាំទ្រអ្នកក្រីក្របានច្រើនបន្ថែមទៀត ក្នុងអំឡុងពេល ១០ឆ្នាំខាងមុខ ។ លក្ខខណ្ឌដំបូងបង្អស់និងសំខាន់មួយសម្រាប់ធ្វើឱ្យសម្រេចបានការកាត់បន្ថយភាពក្រីក្រនៅតំបន់ដែលមិនបានគ្របដណ្តប់នេះគឺ ត្រូវឯកភាពទៅនឹងគោលបំណង យុទ្ធសាស្ត្រនិងសកម្មភាពទាំងឡាយដែលបានផ្តោតនិងកំណត់រួចហើយ ដើម្បីជំរុញការកាត់បន្ថយ

ភាពក្រីក្រនៅតំបន់ជនបទ ជាពិសេស នៅតំបន់ដែលរងគ្រោះដោយមានភាពក្រីក្រកម្រិតខ្ពស់ និងដែលមិនបាន គ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ ។

**៨.** ទោះបីជាមានភស្តុតាងបង្ហាញពីវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏ហាក់ដូចជាមានការកើន ឡើងនូវការរងទុកលំបាកក្នុងចំណោមប្រជាជនមួយផ្នែក ជាពិសេសស្ត្រីនិងកុមារ ។ ដូចជាបញ្ហា នៅតំបន់ជនបទ ដែរគឺ បញ្ហាវិសមភាពមានការកើនឡើង ហើយធ្វើឱ្យមានផលប៉ះពាល់ដល់កុមារធ្វើការងារ ដែលជាមូលដ្ឋាន សម្រាប់អភិវឌ្ឍន៍ធនធានមនុស្សរបស់កម្ពុជានៅជំនាន់បន្ទាប់ទៀត ។

## សកលកម្មនៃការអប់រំមូលដ្ឋានចំនួន ៩ឆ្នាំ

៩. កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ នៅក្នុងការបង្កើនភាពទទួលបានសេវាអប់រំមូលដ្ឋាន ប៉ុន្តែ ប្រទេសជាតិមានការងារជាច្រើនទៀតដែលត្រូវបំពេញ ដើម្បីសម្រេចឱ្យបានចំណុចដៅទាំងឡាយដែលបាន កំណត់នៅក្នុង *គអសក* ។ តាមការប៉ាន់ស្មានបង្ហាញថា សូចនាករមួយក្នុងចំណោមសូចនាករទាំងដប់ក្នុងផ្នែកនេះ មានស្ថានភាពកាន់តែអាក្រក់ នៅពេលដែលសូចនាករបួនផ្សេងទៀតត្រូវបានបង្ហាញថាមានវឌ្ឍនភាពតែបន្តិច បន្តួចប៉ុណ្ណោះ ។ ឯក្នុងចំណោមសូចនាករដែលនៅសល់ប្រាំទៀត បួនមិនបានបង្ហាញពីភាពជឿនលឿនគ្រប់គ្រាន់ ដើម្បីឱ្យសម្រេចចំណុចដៅនៅឆ្នាំ២០០៥ទេ ស្របពេលដែលសូចនាករមួយដែលនៅសល់ (សមាមាត្រកុមារពី ៦-១៤ឆ្នាំមិនបានចូលរៀន) ត្រូវបានបង្ហាញថាបានអនុវត្តលើសចំណុចដៅឆ្នាំ២០០៥ ។

១០. អត្រាពិតនៃការចូលរៀនថ្មី (ប្រៀបធៀបនឹងសក្តានុពលជាក់ស្តែងនៃការចូលរៀនថ្មីនៅថ្នាក់ទី១) ស្ថិតនៅ កម្រិតដដែលគឺ ៨១ភាគរយ នៅឆ្នាំ២០០១ និង២០០៥ ដែលចំណុចដៅសម្រាប់ឆ្នាំ២០០៥គឺ ៩៥ភាគរយ ។ អត្រាគង់វង្ស (សមាមាត្រសិស្សដែលបានរៀនដល់ថ្នាក់ចុងក្រោយនៃភូមិសិក្សាណាមួយ) ពីថ្នាក់ទី១ដល់ថ្នាក់ទី៩ បានធ្លាក់ចុះពី ៣៣ភាគរយនៅឆ្នាំ២០០១ ដល់ ៣០,១៨ភាគរយ នៅឆ្នាំ២០០៥ ដែលចំណុចដៅសម្រាប់ ឆ្នាំ២០០៥គឺ ៥២ភាគរយ ។ អត្រាគង់វង្សផ្សេងទៀត (ពីថ្នាក់ទី១ ដល់ ថ្នាក់ទី៥ និង ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦) ត្រូវបានបង្ហាញថា មានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ។ លទ្ធផលទាំងនេះ និងលទ្ធផលផ្សេងៗទៀត នៅតែមាន គម្លាតឆ្ងាយពីចំណុចដៅទាំងឡាយ ដែលបានកំណត់ដើម្បីធ្វើឱ្យសម្រេចបានគោលដៅនៃសកលកម្មការអប់រំមូល ដ្ឋានចំនួន ៩ឆ្នាំ ។ ការប៉ាន់ស្មានទាំងនេះ បញ្ជាក់ពីការមិនប្រែប្រួលនៃប្រសិទ្ធភាពកម្រិតទាបរបស់ប្រព័ន្ធអប់រំ នៅកម្ពុជា ។

**១១.** នៅឆ្នាំ២០០៥ កុមារអាយុពី ៦-១៤ឆ្នាំ ប្រមាណ ១៨,៧ភាគរយ មិនបានចូលរៀន ដែលជាកម្រិតមួយ ល្អជាងចំណុចដៅដែលបានកំណត់ ២២ភាគរយសម្រាប់ឆ្នាំ២០០៥ និង ៣៥ភាគរយសម្រាប់ឆ្នាំ១៩៩៩ ។ ទោះជាដូចនេះក្តី តួលេខនេះចាំបាច់ត្រូវតែធ្វើការបរិយាយដោយប្រយ័ត្នប្រយែង នៅក្នុងយោបល់ដែលថា

សមាមាត្រកុមារធ្វើការងារអាយុពី ៥-១៧ឆ្នាំ មានការកើនឡើង ។ របាយការណ៍ជាច្រើន បង្ហាញថា មានកុមារជាច្រើនដែលមានអាយុលើសពី ១១ឆ្នាំ នៅរៀនក្នុងសាលាបឋមសិក្សា ដែលបង្កឱ្យឪពុកម្តាយមានភាពស្ទាក់ស្ទើរក្នុងចិត្តក្នុងការបញ្ជូនកូនទៅសាលារៀន ។ មូលហេតុផ្សេងៗទៀត ដែលបង្កឱ្យមានភាពស្ទាក់ស្ទើរក្នុងចិត្តនេះរួមមាន គុណភាពនៃការអប់រំមានកម្រិតទាប ខ្វះខាតគ្រូដែលបានឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យ ខ្វះខាតសៀវភៅនិងសម្ភារៈសិក្សា និងភាពក្រីក្ររបស់គ្រួសារផ្ទាល់ ។ ការប៉ាន់ស្មានពីប្រាក់បៀវត្សរ៍សមរម្យសម្រាប់ផ្តល់ដល់គ្រូបង្រៀន និងការបញ្ជូនគ្រូបង្រៀនដែលមានគុណភាពទៅតំបន់ជនបទ គួរតែត្រូវបានពិចារណា ។

**១២.** អត្រាអក្ខរភាពនៃក្រុមជនអាយុពី ១៥-២៤ឆ្នាំ ភាគច្រើននៅតែមិនមានការប្រែប្រួលទេ នៅក្នុងអំឡុងពេលថ្មីៗកន្លងទៅនេះ ។ នៅឆ្នាំ២០០៥ អត្រាអក្ខរភាពនេះមាន ៨៣ភាគរយ ធៀបនឹង៨២ភាគរយនៅឆ្នាំ១៩៩៩ ។ ចំណុចដៅនៃ *គអសក* បានកំណត់ថានឹងបង្កើនឱ្យដល់ ៩០ភាគរយនៅឆ្នាំ២០០៥ ។ បញ្ហាដ៏ចម្បងមួយផ្សេងទៀតគឺ ការលុបបំបាត់គម្លាតយេនឌ័រនៅក្នុងការអប់រំមូលដ្ឋាន ។ ការអនុវត្តនៅឆ្នាំ២០០៥ នេះបានបង្ហាញការមិនសម្រេចបានតាមចំណុចដៅដែលបានកំណត់ ជាពិសេស នៅកម្រិតមធ្យមសិក្សាបឋមភូមិ ។

### លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

**១៣.** កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពច្រើនក្នុងការជំរុញឱ្យមានសមភាពយេនឌ័រ ហើយសូចនាករជាច្រើនត្រូវបានសម្រេចជិតស្មើនិងចំណុចដៅដែលបានកំណត់ ។ ទោះជាដូចនេះក្តី មានបញ្ហាធំៗជាច្រើន ជាពិសេស នៅក្នុងផ្នែកអំពើហិង្សាក្នុងគ្រួសារ ទើបតែត្រូវបានចាប់ផ្តើមយកចិត្តទុកដាក់ដោះស្រាយនៅក្នុងពេលថ្មីៗកន្លងទៅនេះ ។ លើសពីនេះទៀត ទោះបីជាមានការធ្វើឱ្យប្រសើរឡើងជាក់ស្តែងមួយចំនួនក៏ដោយ ក៏នៅមានបញ្ហាជាច្រើនទៀតដែរ ។

**១៤.** ជាច្រើនឆ្នាំមកហើយ វិសមភាពយេនឌ័រនៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា មានការថយចុះ ហើយនៅឆ្នាំ២០០៥ អត្រាធៀបសិស្សប្រុសធៀបនឹងសិស្សស្រី ទាំងនៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា មានកម្រិតជិតស្មើនឹងចំណុចដៅដែលបានកំណត់ក្នុង *គអសក* ។

**១៥.** អត្រាធៀបអក្ខរជនបុរសធៀបនឹងស្ត្រីក្នុងក្រុមអាយុ ១៥-២៤ឆ្នាំ មានកម្រិតទាបជាងចំណុចដៅ ដែលបានកំណត់សម្រាប់ឆ្នាំ២០០៥ ។ តាមការប៉ាន់ប្រមាណ អត្រានេះមានកម្រិត ៩០ភាគរយនៅឆ្នាំ២០០៥ ដែលសម្រាប់ឆ្នាំនេះ ចំណុចដៅត្រូវបានកំណត់ ៩៥ភាគរយ និងចំណុចដៅសម្រាប់ឆ្នាំ១៩៩៨ ត្រូវបានកំណត់ ៨៧ភាគរយ ។ ប្រហាក់ប្រហែលគ្នានេះដែរ អត្រាធៀបអក្ខរជនប្រុសធៀបនឹងស្ត្រីក្នុងក្រុមអាយុ ២៥-៤៤ឆ្នាំ បានកើនឡើងបន្តិចបន្តួចដល់ ៨០ភាគរយនៅឆ្នាំ២០០៥ ដែលចំណុចដៅត្រូវបានកំណត់ ៨៥ភាគរយ ។

**១៦.** លក្ខណៈដែលគួរឱ្យកត់សម្គាល់បំផុតនៃអំណាចរបស់ស្ត្រីនោះគឺ ការកើនឡើងនៃការរួមចំណែករបស់ស្ត្រីក្នុងការងារទទួលកម្រៃនៅក្នុងវិស័យធំៗទាំងបី ព្រមទាំងការសម្រេចបានចំណុចដៅទាំងឡាយ ទាំងនៅក្នុងវិស័យកសិកម្មនិងឧស្សាហកម្ម ។ មានតែនៅក្នុងផ្នែកសេវាកម្មទេ ដែលកម្រិតនៃវឌ្ឍនភាពសម្រេចមិនបានតាមចំណុចដៅ ។ ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃក្នុងផ្នែកសេវាកម្មមាន ២៧ភាគរយនៅឆ្នាំ២០០៥ ធៀបនឹងចំណុចដៅដែលត្រូវបានកំណត់ ៣០ភាគរយ ។ ទោះជាដូចនេះក្តី ត្រូវចងចាំថា ស្ត្រីភាគច្រើនបំផុតធ្វើការនៅក្នុងផ្នែកមិនរៀបរយ និងក្នុងការងារក្នុងគ្រួសារមិនទទួលកម្រៃ ។

**១៧.** ការផ្លាស់ប្តូរនៃស្ថានភាពរបស់ស្ត្រីក្នុងបរិយាកាសនយោបាយមានសភាពយឺតៗ ។ ស្ត្រីនៅតែមានតំណាងតិចតួចក្នុងផ្នែក នយោបាយ រដ្ឋបាល និងក្នុងផ្នែកផ្សេងទៀត ។ ការលើកលែងមួយដែលគួរឱ្យកត់សម្គាល់គឺឋានៈជាន់ខ្ពស់ក្នុងការងារមួយចំនួននៃសេវាកម្មសាធារណៈ ដូចជាអនុរដ្ឋលេខាធិការ ស្ត្រីបានចូលរួមច្រើនលើសពីចំណុចដៅសម្រាប់ឆ្នាំ២០០៥ ទោះបីជាមានកម្រិតទាបជាង ១២ភាគរយក៏ដោយ ។

**១៨.** មានភស្តុតាងបង្ហាញថា អំពើហិង្សាប្រឆាំងនឹងស្ត្រីមានកម្រិតខ្ពស់ ហើយជាទូទៅ វិសមភាពយេនឌ័រនៅតែជាបញ្ហាធ្ងន់ធ្ងរនៅកម្ពុជា ។ ការអនុម័តច្បាប់ថ្មីស្តីពីអំពើហិង្សាក្នុងគ្រួសារនាពេលថ្មីៗនេះ គឺជាការបង្ហាញឱ្យឃើញច្បាស់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការកែលម្អស្ថានភាពនេះ ប៉ុន្តែការប្រឈមក្នុងផ្នែកនេះមានលក្ខណៈធំធេង ។

## កាត់បន្ថយមរណភាពកុមារ

**១៩.** ការប៉ាន់ស្មានពីមរណភាពកុមារ បានបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ នៅក្នុងគ្រប់វិស័យទាំងអស់ ។ ទោះជាដូចនេះក្តី ការប៉ាន់ស្មានពីមរណភាពកុមារនៅពេលបច្ចុប្បន្ននេះ គួរតែត្រូវបានគិតគូរឱ្យបានល្អិតល្អន់ ដោយហេតុថា នៅក្នុងការប្រមូលទិន្នន័យពីមរណភាពកុមារនេះ បច្ចេកវិទ្យានិងវិធីសាស្ត្រអង្កេតជាច្រើនត្រូវបានប្រើប្រាស់ខុសៗគ្នា ។ អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ត្រូវបានប៉ាន់ប្រមាណថា មាន ៨២ ក្នុងចំណោម ១.០០០កំណើតរស់ នៅឆ្នាំ២០០៥ ធៀបនឹង ១២៤ នៅឆ្នាំ១៩៩៨ ។ ចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ២០០៥ គឺ ១០៥ ក្នុងចំណោម ១.០០០កំណើតរស់ ។ ប្រហាក់ប្រហែលគ្នានេះដែរ អត្រាមរណភាពទារកត្រូវបានប៉ាន់ស្មានថាមាន ៦៦ ក្នុងចំណោម ១.០០០កំណើតរស់ នៅឆ្នាំ២០០៥ បើធៀបនឹងចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ២០០៥ គឺ ៧៥ ហើយ ចំណុចដៅសម្រាប់ឆ្នាំ១៩៩៨ គឺ ៩៥ ក្នុងចំណោម ១.០០០កំណើតរស់ ។ និន្នាការដែលបានចង្អុលបង្ហាញនេះ មានភាពស៊ីសង្វាក់គ្នានឹងការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃអត្រាបង្កើតកូនសរុប និងរបាយការណ៍ស្តីពីកំណើននៃការផ្តល់វ៉ាក់សាំងការពារ (ទាំងជម្ងឺកញ្ជ្រឹល និងជម្ងឺ DPT3) ។ ជាឧទាហរណ៍ សមាមាត្រកុមារក្រោមអាយុ ១ឆ្នាំដែលបានទទួលវ៉ាក់សាំងការពារជម្ងឺ DPT3 បានកើនឡើងពី ៤៣ភាគរយ នៅឆ្នាំ២០០០ ដល់ ៨៣ភាគរយនៅឆ្នាំ២០០៥ ដែលសម្រេចបានលើសពីចំណុចដៅដែលត្រូវបាន

កំណត់តែ ៨០ភាគរយប៉ុណ្ណោះ ។ ចំពោះចំណុចដៅនៃការផ្ដល់វ៉ាក់សាំងការពារជម្ងឺកញ្ជ្រឹល ក៏បានធ្វើឱ្យសម្រេចដែរ ដោយមាន ការកើនឡើងពី ៤១ភាគរយនៅឆ្នាំ២០០០ ដល់ ៨០ភាគរយនៅឆ្នាំ២០០៥ ។

**២០.** សមាមាត្រមាតាដែលបានបំបៅដោះកូនក្រោយពេលកើត ១ម៉ោង បានកើនឡើងដល់ជាង ២៩ភាគរយនៅឆ្នាំ២០០៥ គឺលើសពីចំណុចដៅដែលបានកំណត់ ។ ទោះជាដូចនេះក្ដី មូលហេតុចម្បងនៃមរណភាពកុមារនៅកម្ពុជាគឺ ជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ និងជម្ងឺអាសន្នរោគ ដែលទាមទារឱ្យមានមធ្យោបាយមានប្រសិទ្ធភាពដើម្បីដោះស្រាយ ។

**២១.** ទោះជាដូចនេះក្ដី ការធ្លាក់ចុះយ៉ាងឆាប់រហ័សពីដំបូងនៃអត្រាមរណភាពកុមារដែលបណ្ដាលមកពីការថយចុះនៃភាពបង្កើតកូននិងកត្តាផ្សេងៗទៀត ហាក់ដូចជាមិនមានស្ថេរភាពទេ លុះត្រាតែកត្តាផ្សេងៗដែលបានលើកឡើងនិងជាមូលហេតុធ្វើឱ្យមានអត្រាមរណភាពកុមារខ្ពស់នៅកម្ពុជា ដូចជា ភាពក្រីក្រ កង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀង ការទទួលបានទឹកស្អាតនិងការកែលម្អអនាម័យមិនគ្រប់គ្រាន់ ផ្ទះទ្រុឌទ្រោម ចំណេះដឹងស្ដីពីអនាម័យខ្លួនប្រាណនៅមានកំណត់ ការអនុវត្តអសុវត្ថិភាពសេវាសុខភាព និងភាពមិនគ្រប់គ្រាន់នៃប្រព័ន្ធថែទាំសុខភាពនិងកម្មវិធីត្រួតពិនិត្យជម្ងឺ ត្រូវបានដោះស្រាយ ។ សារថ្លែងដ៏សំខាន់មួយបង្ហាញឱ្យឃើញថា មរណភាពកុមារនៅកម្ពុជា នៅតែស្ថិតក្នុងចំណោមកម្រិតដែលខ្ពស់ជាងគេនៅក្នុងតំបន់ ដែលនេះគឺជា សក្ដានុពលនៃកម្មវិធីទាំងឡាយសម្រាប់ត្រួតពិនិត្យជម្ងឺ ធ្វើឱ្យខិតទៅជិតគោលដៅដែលបានកំណត់ ដែលវឌ្ឍនភាពនៅពេលខាងមុខនឹងបង្កើនភាពពឹងផ្អែកលើភាពជោគជ័យក្នុងការបង្កើតសេវាសុខភាពសកម្ម ដែលវឌ្ឍនភាពនាពេលបច្ចុប្បន្ននេះមិនទាន់មានភាពគួរឱ្យពេញចិត្តនៅឡើយ ។

### កែលម្អសុខភាពមាតា

**២២.** ព័ត៌មានថ្មីៗស្ដីពីស្ថានភាពសុខភាពមាតាមានតិចតួចណាស់ ។ ទិន្នន័យស្ដីពីសុខភាពមាតានេះ មានតែសូចនាករបួនប៉ុណ្ណោះ ក្នុងចំណោមសូចនាករដប់ ។ ជាពិសេស ពុំមានទិន្នន័យស្ដីពីសូចនាករដ៏សំខាន់បំផុតមួយគឺ អត្រាមរណភាពមាតាទេ ។ ប៉ុន្តែ ចំពោះទិន្នន័យទាំងឡាយណាដែលអាចរកបាន ព័ត៌មានស្ដីពីស្ថានភាពសុខភាពមាតា មានលក្ខណៈមិនឯកភាពគ្នា ។

**២៣.** អត្រាបង្កើតកូនសរុបបានថយចុះពី ៤,០ ក្នុងឆ្នាំ១៩៩៨ មកត្រឹម ៣,៣ នៅឆ្នាំ២០០៥ គឺសម្រេចបានលើសចំណុចដៅ ដែលត្រូវបានកំណត់តែត្រឹម ៣,៨ ប៉ុណ្ណោះ ។ សមាមាត្រស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើបតាមរយៈផ្នែកសាធារណៈបានកើនឡើងដល់ ២០,១ភាគរយ នៅឆ្នាំ២០០៥ ។ ទោះជាដូចនេះក្ដី នៅមានស្ត្រីរៀបការហើយជាច្រើនទៀត ដែលបានទទួលសេវាពន្យារកំណើតនេះតាមរយៈប្រព័ន្ធ ទីផ្សារក្នុងសង្គម និងពីផ្នែកឯកជន ហើយបើគិតពីចំនួនសរុបនៃអ្នកដែលប្រើប្រាស់សេវាពន្យារកំណើតទំនើបនេះ មានជិត

ស្មើនឹង ៣០ភាគរយ ដែលជាចំណុចដៅដែលត្រូវបានកំណត់សម្រាប់ឆ្នាំ២០០៥ ។ ប្រហាក់ប្រហែលគ្នានេះ ភាគរយនៃស្ត្រីមានផ្ទៃពោះបានទទួលការពិគ្រោះយោបល់ពិនិត្យ ផ្ទៃពោះមុនពេលសម្រាលពីរដងយ៉ាងតិច ពីបុគ្គលិកសុខាភិបាលនៅផ្នែកសាធារណៈ បានកើនឡើងពី ២៩,៨ភាគរយ ដល់ ៤៧ភាគរយ ក្នុងរយៈពេលដូចគ្នា ។ អត្រាសរុប ដោយគិតបញ្ចូលទាំងការផ្តល់សេវាកម្មពិគ្រោះយោបល់នេះដោយផ្នែកឯកជន អាចនឹងជិតស្មើចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ២០០៥ គឺ ៦០ភាគរយ ។ ការវិភាគដោយប្រើប្រាស់ ទិន្នន័យពីការធ្វើអង្កេតពាក់កណ្តាលជំរឿនកម្ពុជា២០០៤ បង្ហាញថា ជាងមួយភាគប្រាំនៃមូលហេតុទាក់ទងនឹង ជម្ងឺបណ្តាលឱ្យស្លាប់ស្ត្រីក្នុងក្រុមអាយុពី ១៥-៤៤ឆ្នាំ គឺដោយសារតែបញ្ហាស្មុគស្មាញទាក់ទងនឹងការមានផ្ទៃពោះ រួមទាំងនៅក្នុងពេលសម្រាលកូនផង ។ តួលេខយ៉ាងខ្ពស់ដូច្នេះ ទាមទារឱ្យមានការវាយតម្លៃដោយប្រុងប្រយ័ត្ន ពីស្ថានភាពនិងពិនិត្យមើលឡើងវិញលើអន្តរាគមន៍នានា ។

## ប្រយុទ្ធប្រឆាំងនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺដទៃទៀត

**២៤.** កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការធ្វើឱ្យសម្រេចចំណុចដៅនានាក្នុងគោលដៅ ដែលត្រូវបានកំណត់សម្រាប់ឆ្នាំ២០០៥ ដោយប្រើមធ្យោបាយមានប្រសិទ្ធភាពនានាក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ ជម្ងឺគ្រុនចាញ់ ជម្ងឺគ្រុនសន្លំ និងជម្ងឺធ្ងន់ធ្ងរផ្សេងទៀត ដូចជាជម្ងឺរបេងជាដើម ។ ស្របពេលដែលក្នុងគោលដៅនេះមានទិន្នន័យតែ ១២ ក្នុងចំណោម ១៩សូចនាករ នៅឆ្នាំ២០០៥ ភាគច្រើននៃសូចនាករនេះសុទ្ធតែសម្រេចបានលើសពីចំណុចដៅដែលបានកំណត់ ។

**២៥.** ក្នុងករណីនៃមេរោគហ៊ីវ/ជម្ងឺអេដស៍ អត្រារីករាលដាលក្នុងចំណោមមនុស្សពេញវ័យ អាយុ ១៥-៤៨ឆ្នាំ មានការថយចុះខ្លាំង ពី ៣,០ភាគរយនៅឆ្នាំ១៩៩៧ មកត្រឹម ១,៩ភាគរយនៅឆ្នាំ២០០៥ ដែលសម្រេចបានលើសពីចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំនោះ គឺ២,៣ភាគរយ[១] ។ អត្រារីករាលដាលនៃមេរោគហ៊ីវក្នុងចំណោមស្ត្រីមានផ្ទៃពោះ អាយុពី ១៥-២៤ឆ្នាំ ហើយបានទៅមជ្ឈមណ្ឌលទទួលការពិគ្រោះយោបល់ពិនិត្យផ្ទៃពោះមុនពេលសម្រាល ក៏មានការថយចុះពី ២,៥ភាគរយនៅឆ្នាំ១៩៩៨ ដល់២,១ភាគរយនៅឆ្នាំ២០០៥ ដែលសម្រេចលើសចំណុចដៅដែលត្រូវបានកំណត់តែត្រឹម ២,៤ភាគរយប៉ុណ្ណោះ ។ អត្រាប្រើប្រាស់ស្រោមអនាម័យរបស់ស្ត្រីរកស៊ីផ្លូវភេទ មានកម្រិតជិតស្មើ ៩៨ភាគរយ នៅឆ្នាំ២០០៥ គឺកើនឡើងពីកម្រិត ៩១ភាគរយនៅឆ្នាំ២០០១ ។ អត្រាប្រជាជនទទួលបានវិធីព្យាបាលរោគដោយប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ មាន៤៥ភាគរយ ដែលល្អជាងចំណុចដៅសម្រាប់ឆ្នាំ២០០៥ នេះ ដែលបានកំណត់តែ ២៥ភាគរយ ហើយការអនុវត្តនៅឆ្នាំ២០០២ សម្រេចបានតែ ៣ភាគរយប៉ុណ្ណោះ ។ ប្រជាជនជាង ៩.០០០នាក់ បានទទួលការព្យាបាលនេះ គិតត្រឹមត្រីមាសទី៣ នៃឆ្នាំ២០០៥ ។

---

[១] ការប៉ាន់ស្មានមួយចំនួនសម្រាប់បណ្តាឆ្នាំមូលដ្ឋាន ត្រូវបានកែសម្រួលឡើងវិញ ដោយសារតែវិធីសាស្ត្រមានការកែសម្រួល

**២៦.** អត្រាស្លាប់ដោយជម្ងឺគ្រុនចាញ់ដែលបានផ្តល់ព័ត៌មានដោយផ្នែកសុខភាពសាធារណៈ បានថយចុះពី ០,៤ ភាគរយ នៅឆ្នាំ២០០០ មកត្រឹម ០,៣៦ភាគរយនៅឆ្នាំ២០០៥ ទោះបីជាចំណុចដៅត្រូវបានកំណត់ឱ្យបញ្ចុះដល់ ០,៣ភាគរយក៏ដោយ ។ ក្នុងករណី ជម្ងឺគ្រុនសន្និ អត្រាស្លាប់បណ្តាលមកពីជម្ងឺនេះ មានការថយចុះគួរឱ្យកត់សម្គាល់ ពី ១,៥ភាគរយនៅឆ្នាំ២០០០ មកត្រឹម ០,៧៤ភាគរយនៅឆ្នាំ២០០៥ ល្អប្រសើរជាងចំណុចដៅដែលបានកំណត់ គឺ ១ភាគរយ ។

**២៧.** ទោះបីជាលទ្ធផលជាច្រើនមានលក្ខណៈគួរជាទីពេញចិត្តក៏ដោយ ក៏សេចក្តីអំណរពេញលេញមិនអាចកើតមានឡើងចំពោះជម្ងឺដ៏កាចសាហាវ ដូចជា មេរោគហ៊ីវ/ជម្ងឺអេដស៍ និងជម្ងឺរបេងទេ ។ ជម្ងឺទាំងនេះគឺជាមូលហេតុយ៉ាងចម្បងនៃការស្លាប់ ប្រជាជននៅគ្រប់ក្រុមអាយុទាំងអស់ ។ លើសពីនេះទៀត ការព្រួយបារម្ភពីករណីថ្មីៗទាក់ទងនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ដូចជា ការចម្លងពីឪពុកម្តាយទៅកូន និងពីប្តីទៅប្រពន្ធជាដើម ចាំបាច់ត្រូវតែធ្វើការដោះស្រាយ ។ ការរីករាលដាលដោយស្ងៀមស្ងាត់នៃមេរោគហ៊ីវ/ជម្ងឺអេដស៍ទៅតំបន់ជនបទ ក៏ជាបញ្ហាចម្បងមួយដែរ ។ យុទ្ធសាស្ត្រអន្តរាគមន៍នៃសាមញ្ញ ដើម្បីប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ដោយការផ្តោតការយកចិត្តទុកដាក់លើតំបន់ទីប្រជុំជននិងបណ្តាក្រុមជនដែលរងគ្រោះខ្លាំង ចាំបាច់ត្រូវតែបំពេញបន្ថែមដោយវិធីសាស្ត្រដែលអាចដោះស្រាយ នូវភាពងាយរងគ្រោះក្នុងជួរប្រជាជន និងទីកន្លែងដែលបានកំណត់ ។

### ការធានានិរភាពបរិស្ថាន

**២៨** ព័ត៌មានដែលអាចទទួលបាននៅក្នុងផ្នែកនេះ នៅមានគម្លាតយ៉ាងច្រើន ទិន្នន័យជាច្រើនដែលអាចយកមកធ្វើការវិភាគ គឺមានលក្ខណៈវិជ្ជមាន ។ ព័ត៌មានបច្ចុប្បន្នស្តីពីបញ្ហាសំខាន់នៃនិរភាពបរិស្ថាននៅកម្ពុជា (បញ្ហានៃវិសាលភាពព្រៃឈើនិងការគ្រប់គ្រង) គឺមិនអាចរកបាន ។ ប៉ុន្តែជាទូទៅទទួលស្គាល់ថា ដំណើរនៃការបំផ្លាញព្រៃឈើមិនត្រូវបានកាត់បន្ថយតាមផែនការនៅឡើយ ។ ដំណើរការថយចុះព្រៃឈើ គឺជាផ្នែកមួយបានឆ្លុះបញ្ចាំងពីការកើតឡើងខ្ពស់នៃការប្រើប្រាស់អុសជាថាមពល ។ នៅឆ្នាំ១៩៩៣ ៩២ភាគរយនៃគ្រួសារបានប្រើប្រាស់អុសជាថាមពល ។ ចំនួននេះបានធ្លាក់ចុះបន្តិចបន្តួច មកត្រឹមប្រហែល ៨៤ភាគរយនៅឆ្នាំ២០០៥ ចំណែកឯចំណុចដៅគឺត្រូវបានកំណត់ឱ្យនៅត្រឹម ៧០ភាគរយ ។ ចំណុចដៅទាំងអស់នោះនឹងនៅតែក្នុងការស្រមើស្រមៃ បើសិនជាការខិតខំប្រឹងប្រែងមិនបានយកទៅអនុវត្តនៅក្នុងផ្នែកទាំងពីរនៃព្រៃឈើ និងថាមពលនោះទេ ។

**២៩** ក្នុងឆ្នាំ២០០៥ លទ្ធភាពទទួលបានប្រភពទឹកស្អាតក្នុងចំណោមប្រជាជននៅជនបទបានកើនឡើងដល់ ៤២ ភាគរយ និងទីប្រជុំជន បានកើនឡើងដល់ប្រហែល ៧៦ភាគរយ ។ លទ្ធភាពទទួលបានទឹកស្អាត លើសចំណុចដៅដែលកំណត់ត្រឹម ៣០ភាគរយ នៅជនបទ និង៦៨ភាគរយ នៅទីប្រជុំជន ។ ដូចគ្នានេះដែរ លទ្ធភាពទទួលបានអនាម័យល្អប្រសើរឡើងក្នុងចំណោមប្រជាជននៅជនបទ បានកើនឡើងដល់ ១៦ភាគរយ ធៀបនឹងចំណុចដៅ ១២ភាគរយ នៅឆ្នាំ២០០៥ ។ ក្នុងករណីប្រជាជននៅទីប្រជុំជន លទ្ធភាពទទួលបានអនាម័យប្រសើរឡើង មាន

៥៧ភាគរយ រីឯចំណុចដៅគឺ ៥៩ភាគរយនៅឆ្នាំ២០០៥ ។ បើប្រៀបធៀបជាមួយជោគជ័យដទៃទៀត ការធ្វើឱ្យបានសម្រេចចំណុចដៅដែលមានលក្ខណៈអន់ថយជាងនេះ មួយផ្នែកអាចពន្យល់បានតាមរយៈការហូរចូលយ៉ាងច្រើននៃអ្នកក្រជនបទ មកកាន់តំបន់ទីប្រជុំជន ។ នាពេលអនាគត ការខិតខំប្រឹងប្រែងផ្តោតទៅលើការលើកកម្ពស់ផលិតភាពកសិកម្ម ដើម្បីកាត់បន្ថយអត្រាការផ្លាស់ប្តូរទីលំនៅពីជនបទមកទីប្រជុំជន និងដើម្បីកែលម្អជីវភាពរស់នៅរបស់អ្នកក្រីក្រនៅទីប្រជុំជន ។

## ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ

៣០ កម្ពុជាជាប្រទេសរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក្នុងចំណោមបណ្តាប្រទេសដែលមានផលប៉ះពាល់ទាំងឡាយ ។ កម្ពុជាបានអនុម័តចំណុចដៅសម្រាប់អនុវត្តន៍ការបោសសំអាតមីនឱ្យអស់នៅតំបន់ដែលមានគ្រាប់មីននៅត្រឹមឆ្នាំ២០១២ ។ ទោះបីមានវឌ្ឍនភាពសំខាន់ៗជាច្រើន ត្រូវបានធ្វើឡើងក៏ដោយ ក៏ចំណុចដៅនេះទំនងជាមិនអាចសម្រេចបានឡើយ ។ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការ ត្រូវបានរៀបចំឡើងវិញនឹងបញ្ចប់សកម្មភាពនៅឆ្នាំ២០១៥ ។

៣១ ប៉ុន្តែគម្លាតដ៏ធំ គឺទាក់ទងទៅនឹងក្នុងការកាត់បន្ថយចំនួនជនរងគ្រោះថ្នាក់ក្នុងមួយឆ្នាំៗ ។ ចំនួនអ្នកស្លាប់មានប្រមាណ ៨០០នាក់ នៅឆ្នាំ២០០៥ បើធៀបជាមួយនឹងចំណុចដៅដែលបានកំណត់គឺ ១.៦៩១នាក់ នៅឆ្នាំ១៩៩៣ ៥០០នាក់ នៅឆ្នាំ២០០៥ និង ២០០នាក់ នៅឆ្នាំ២០១០ ។ អត្រាស្លាប់ខ្ពស់នេះបានកើតឡើង ថ្វីបើការបោសសំអាតបានច្រើនជាង ៥០ភាគរយលើតំបន់ដែលមានគ្រាប់មីន ប្រៀបធៀបនឹងឆ្នាំ១៩៩៥ ដែលមានតែ ១០ភាគរយប៉ុណ្ណោះក៏ដោយ ។ មួយផ្នែកនៃមូលហេតុដែលបណ្តាឱ្យស្លាប់នេះ គឺបណ្តាមកពីទីកន្លែងដែលបានបោសសម្អាតមីន និងលំនៅដ្ឋានរបស់ប្រជាជនមួយចំនួន ស្ថិតនៅជិតនឹងតំបន់ដែលគ្របដណ្តប់ដោយគ្រាប់មីនដែលធ្វើឱ្យអត្រាស្លាប់នៅតែខ្ពស់ដដែល ។ មូលហេតុសំខាន់ៗដទៃទៀត គឺដោយសារការបំបែកយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដើម្បីយកលោហៈធាតុលក់ ។ បញ្ហាចុងក្រោយនេះ ចាំបាច់ក៏ត្រូវយកចិត្តទុកដាក់ជាបន្ទាន់ផងដែរ ។

## ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា : បញ្ហាប្រឈមនាពេលអនាគត

៣២ ទោះបីជាកម្ពុជា កំពុងស្ថិតនៅផ្លូវ ដលត្រូវសម្រេចចំណុចដៅនៃ *គអសក* ជាច្រើនក៏ដោយ ក៏កម្ពុជាមិនមែនស្ថិតនៅក្នុងដំណាក់កាលក្នុងវិស័យសំខាន់ៗជាច្រើនដែលទាក់ទងនឹងសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ ការអប់រំ និងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចប្រកបដោយចីរភាព ។ សមិទ្ធផលសំខាន់ៗ និងគម្លាតជាច្រើនក្នុងការសម្រេចបាន *គអសក* ត្រូវបានសង្ខេបនៅក្នុងតារាង ១ ។

## តារាង ១: សមិទ្ធផលសំខាន់ៗ និង ការសម្រេចមិនបានតាមចំណុចដៅរបស់ *គអសក* ឆ្នាំ២០០៥

| ការសម្រេចបាន | ការសម្រេចមិនបានតាមគោលដៅ |
|---|---|
| • ការធ្វើឱ្យប្រសើរឡើងអត្រាភាពក្រីក្រនៅទីប្រជុំជន និងតំបន់ជនបទដែលមានលទ្ធភាពទៅដល់ ។<br>• ការពង្រីកការអប់រំបឋមសិក្សាដល់កុមារឱ្យបានច្រើនជាងមុន<br>• ការកាត់បន្ថយបានច្រើននូវអត្រាមរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំ<br>• ការធ្វើឱ្យប្រសើរឡើងនូវការចាក់ថ្នាំបង្ការជម្ងឺសំខាន់ៗដល់កុមារ<br>• ការលើកកម្ពស់អត្រាបំបៅកូនដោយទឹកដោះម្ដាយ<br>• ការកាត់បន្ថយវិសមភាពយេនឌ័រ ក្នុងស្ទើរតែគ្រប់វិស័យទាំងអស់ ជាពិសេស ក្នុងការអប់រំបឋមសិក្សា អក្ខរកម្មមនុស្សពេញវ័យនិងការងារដែលមានប្រាក់ឈ្នួលក្នុងផ្នែកកសិកម្ម និងឧស្សាហកម្ម<br>• សមិទ្ធផលគួរឱ្យកាត់សម្គាល់ក្នុងការកាត់បន្ថយជម្ងឺឆ្លង ជាពិសេស ហ៊ីវ/អេដស៍<br>• តំបន់ទីក្រុងទទួលបានទឹកស្អាត ហើយតំបន់ជនបទទទួលបាននូវអនាម័យប្រសើរជាងមុន | • អត្រាភាពក្រីក្រខ្ពស់នៅជនបទ<br>• ភាពមិនជោគជ័យក្នុងការបង្កើនការសិក្សាពិតនៅកម្រិតខ្ពស់ជាងបឋមសិក្សា និងក្នុងការរក្សាឱ្យបានអត្រាគង់វង្សខ្ពស់នៅគ្រប់កម្រិតសិក្សា<br>• ភាពជឿនលឿននៅមានកម្រិត ក្នុងការធ្វើឱ្យសម្រេចគោលដៅនៃសកលកម្មការអប់រំមូលដ្ឋាន៩ឆ្នាំ ជាពិសេសការអប់រំក្រោយបឋមសិក្សា<br>• វិសមភាពយេនឌ័រនៅ មធ្យមសិក្សា និងឧត្តមសិក្សា<br>• ការនៅតែបន្តកើតមាននូវអំពើហិង្សាកម្រិតខ្ពស់ក្នុងគ្រួសារទៅលើស្ត្រី<br>• ការទទួលបាននូវសេវាសុខាភិបាល ដែលមានគុណភាព ជាពិសេស ក្នុងករណីសុខភាពស្ត្រី និងមាតា<br>• ការរិចរិលនៃបរិស្ថាន ជាពិសេស ការរិចរិលព្រៃឈើ និងធនធានទឹក<br>• ការបន្តមានជនរងគ្រោះដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ |

**៣៣** លទ្ធផលសម្រេចបានរបស់កម្ពុជានាពេលបច្ចុប្បន្ន ទាក់ទងទៅនឹង *គអសក* គឺមិនច្បាស់លាស់និងនៅមានកម្រិត ។ កម្ពុជានឹងមិនអាចសម្រេចបាន *គអសក* នៅឆ្នាំ២០១៥ ឡើយ ប្រសិនបើកិច្ចខិតខំ ប្រឹងប្រែងរបស់ជាតិទាំងមូលមិនត្រូវបានពង្រឹង និងបំពេញបន្ថែមដោយការគាំទ្រពីសហគមន៍អន្តរជាតិទេនោះ ។ បើសិនជាគ្មានការគាំទ្របែបនេះទេ កម្ពុជានឹងធ្លាក់ចុះទាបជាងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ថែមទៀត នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក តាមរយៈនេះ គម្លាតផ្នែកសេដ្ឋកិច្ចនិងសង្គមក្នុងតំបន់កាន់តែមានទំហំខ្លាំងឡើង ។

**៣៤** វឌ្ឍនភាពរបស់កម្ពុជាឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ត្រូវជួបឧបសគ្គជាច្រើន ដែលបញ្ហាសំខាន់ពីរគឺ ការខ្វះខាតមូលនិធិវិនិយោគ និងការទទួលបានសេវាទីផ្សារអន្តរជាតិមានកម្រិតទាបបំផុត ជាពិសេស ទៅកាន់ទីផ្សារនៅក្នុងបណ្ដាប្រទេសអភិវឌ្ឍន៍ ទោះបីជាកម្ពុជាបានចូលជាសមាជិកពាណិជ្ជកម្មពិភពលោកក៏ដោយ ។ ការខ្វះខាតធនធានបែបនេះ ចាំបាច់ត្រូវដោះស្រាយឡើងវិញតាមរយៈលំហូរចូលជំនួយដ៏ច្រើន កាត់បន្ថយសេវាបំណុល និងបង្កើនលំហូរចូលនៃគណនេយ្យចរន្ត ដូចជា មានចែងក្នុងគោលដៅទី៨ នៃ*គអសក* ។ ជោគជ័យរបស់កម្ពុជានៅក្នុងទីផ្សារពាណិជ្ជកម្មសម្រាប់ការអភិវឌ្ឍ និងការឈានទៅសម្រេចបាន *គអសក* ទាមទារនូវការធ្វើពាណិជ្ជកម្មឱ្យកាន់តែច្រើនឡើងចូលទៅក្នុងទីផ្សារអន្តរជាតិ តាមរយៈការផ្ដល់នូវភាពអនុ-

គ្រោះទីផ្សារ លទ្ធភាពទទួលបានការនាំចេញផលិតផលជាច្រើន ដូចជា ការផ្តល់ឱ្យនូវកូតាមិនកំណត់ និងការលើកលែងពន្ធសម្រាប់គ្រប់ផលិតផលទំនិញដែលត្រូវបង់ពន្ធគយ នៅទីផ្សារក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ។ កម្ពុជាអាចសម្រេចបាន *គអសក* ប្រសិនបើគំនិតផ្តួចផ្តើមសំខាន់ៗត្រូវបានអនុវត្តដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និងសហគមន៍អន្តរជាតិ ដើម្បីបំពេញបន្ថែមលើយុទ្ធសាស្ត្រជាតិរួម ដែលមាននិន្នាការគាំទ្រ *គអសក* ។

# ឧបសម្ព័ន្ធ ២.១

## កម្ពុជា : សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

### ការប៉ាន់ស្មានពីឆ្នាំ ២០០៦-២០១០

| ពតិមានលំអិត | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| | ប៉ាន់ស្មាន | ព្យាករណ៍ | | | | |
| | | | | | | |
| ***ផសស*** **(ថ្លៃថេរ) ពាន់លានរៀល** | **១៩,២៩៤** | **២០,៤៥២** | **២១,៦៧៩** | **២២,៩៣៦** | **២៤,២៩០** | **២៥,៧៤៧** |
| *ផសស* ជាក់ស្តែង (% កំណើន) | ៧,០ | ៦,០ | ៦,០ | ៥,៨ | ៥,៩ | ៦,០ |
| អតិផរណាប្រាក់រៀល (%) | ៦,២ | ៣,៥ | ៣,០ | ៣,០ | ៣,០ | ៣,០ |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ) | ២១៦ | ២២៧ | ២៤៩ | ២៧៤ | ៣០២ | ៣៣២,០ |
| សន្សំបរទេសសរុប (ចំនួនខែនៃការនាំចូល) | ២,៥ | ២,៥ | ២,៥ | ២,៦ | ២,៨ | ៣,០ |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារ) | ៤.១២៨ | ៤.២១៩ | ៤.២២៨ | ៤.២៧៨ | ៤.៣២៨ | ៤.៣៧៨ |
| ការនាំចេញ (លានដុល្លារ) | ២.៧០៧ | ២.៩៣១ | ៣.១៧២ | ៣.៣៩៥ | ៣.៦៤៣ | ៣.៩១៨ |
| ការនាំចូល (លានដុល្លារ) | ៣.៧៣៨ | ៤.១៦៩ | ៤.៥០៣ | ៤.៨២៧ | ៥.១៧២ | ៥.៥២៧ |
| តុល្យភាពគណនេយ្យចរន្ត (% នៃ *ផសស*) (រួមទាំងការផ្ទេរផ្លូវការ) | -៤,១ | -៥,៤ | -៤,៩ | -៤,០ | -៣,៣ | -២,៦ |
| **វិស័យសារពើពន្ធ (% *ផសស*)** | | | | | | |
| **ចំណូលថវិកា** | **១១,៨** | **១២,២** | **១២,៨** | **១៣,២** | **១៣,៥** | **១៣,៨** |
| ចំណូលពន្ធ-គយ | ៨,៧ | ៩,៤ | ៩,៤ | ៩,៤ | ៩,៣ | ៩,២ |
| ចំណូលមិនមែនពន្ធ-គយ | ២,៥ | ២,៦ | ២,៦ | ២,៦ | ២,៧ | ២,៧ |
| **ចំណាយថវិកា** | **១៤,៩** | **១៧,០** | **១៧,២** | **១៧,១** | **១៦,៩** | **១៦,៥** |
| ចំណាយមូលធន | ៥,៣ | ៦,៦ | ៦,៦ | ៦,៣ | ៦,២ | ៥,៩ |
| ចំណាយចរន្ត | ៩,៦ | ១០,៥ | ១០,៧ | ១០,៧ | ១០,៧ | ១០,៨ |
| **តុល្យភាពចរន្ត** | **១,៦** | **១,៥** | **២,០** | **២,៣** | **២,៦** | **២,៩** |

| ***ផសស*** **តាមវិស័យ គិតតាមតម្លៃថេរឆ្នាំ ២០០០ (% ប្រែប្រួលប្រចាំឆ្នាំ)** | | | | | | |
|---|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **៤,៥** | **៣,៤** | **៣,៧** | **៣,៧** | **៣,៨** | **៣,៨** |
| ស្រូវ | ៨,០ | ៣,៥ | ៤,០ | ៤,០ | ៤,០ | ៤,០ |
| បសុសត្វ និងបសុបក្សី | ៤,០ | ៤,០ | ៤,៥ | ៤,៥ | ៥,០ | ៥,០ |
| ការនេសាទ | ០,០ | ៣,០ | ៣,០ | ៣,០ | ៣,០ | ៣,០ |
| រុក្ខាប្រមាញ់ និងឈើមូល | ០,០ | ២,០ | ២,០ | ២,០ | ២,០ | ២,០ |
| **ឧស្សាហកម្ម** | **១០,៧** | **៩,១** | **៨,១** | **៧,១** | **៧,២** | **៧,៣** |
| រ៉ែ | ៩,០ | ៩,០ | ៨,០ | ៨,០ | ៨,០ | ៨,០ |

| ពតិមានលំអិត | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| | ប៉ាន់ស្មាន | ព្យាករណ៍ | | | | |
| កម្មន្តសាល | ១០,២ | ៨,៦ | ៨,២ | ៦,៨ | ៦,៩ | ៧,១ |
| ចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ | ២,០ | ៤,០ | ៤,១ | ៤,៥ | ៤,៥ | ៤,៥ |
| វាយនភ័ណ្ឌ សំលៀកបំពាក់ និងស្បែកជើង | ១៣,០ | ១០,០ | ៩,០ | ៧,០ | ៧,០ | ៧,០ |
| ក្តារបន្ទះ ក្រដាស និងបោះពុម្ព | ២,០ | ២,០ | ៣,០ | ៣,០ | ៤,០ | ៤,០ |
| ផលិតផលជ័រកៅស៊ូ | (៥,០) | ០,០ | ២,០ | ២,០ | ៣,០ | ៤,០ |
| ផលិតផលផ្សេងៗទៀត | ៣,០ | ៥,០ | ៨,០ | ៩,០ | ១០,០ | ១២,០ |
| អគ្គិសនី ឧស្ម័ន និងទឹកស្អាត | ៤,៥ | ៦,០ | ៧,០ | ៧,០ | ៧,០ | ៧,០ |
| សំណង់ | ១៣,០ | ១១,០ | ៨,០ | ៨,០ | ៨,០ | ៨,០ |
| **សេវាកម្ម** | **៦,៣** | **៦,០** | **៦,៦** | **៦,៨** | **៧,១** | **៧,១** |
| ពាណិជ្ជកម្ម | ៥,០ | ៥,០ | ៥,០ | ៥,០ | ៦,០ | ៦,០ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ១៥,០ | ១០,០ | ១០,០ | ១០,០ | ១០,០ | ១០,០ |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | ៥,០ | ៦,០ | ៧,០ | ៧,០ | ៧,០ | ៧,០ |
| ហិរញ្ញវត្ថុ | ៦,០ | ៦,០ | ៦,០ | ៦,០ | ៦,០ | ៦,០ |
| រដ្ឋបាលសាធារណៈ | ៣,០ | ៣,០ | ៣,០ | ៣,០ | ៣,០ | ៣,០ |
| ភ្នាក់ងារផ្តល់សេវាកម្ម និងអាជីវកម្ម | ៤,០ | ៥,០ | ៦,០ | ៦,០ | ៦,០ | ៦,០ |
| សេវាកម្មផ្សេងទៀត | ៦,០ | ៦,០ | ៧,០ | ៨,០ | ៨,០ | ៨,០ |
| | | | | | | |

**ប្រភព:** មូលនិធិរូបិយវត្ថុអន្តរជាតិ

# ឧបសម្ព័ន្ធ ២.២
## ប៉ាន់ស្មានពីការវិនិយោគ ឆ្នាំ២០០៦_២០១០

(លានដុល្លារ)

| ពតិមានលំអិត/ វិស័យ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **១៦៨.៨** | **១៧៧.២** | **១៨៦.១** | **១៩៩.៤** | **២០៣.៥** | **៩៣១.០** |
| ដំណាំ | ១៣៨.១ | ១៤៤.៩ | ១៥២.១ | ១៥៩.៧ | ១៦៥.៩ | ៧៦០.៧ |
| បសុសត្វ និងបសុបក្សី | ១០.៦ | ១១.២ | ១១.៩ | ១២.៧ | ១៣.៦ | ៦០.០ |
| ការនេសាទ | ១១.៤ | ១២.០ | ១២.៦ | ១៣.២ | ១៣.៨ | ៦៣.០ |
| រុក្ខាប្រមាញ់ និងអាជីវឈើមូល | ៨.៨ | ៩.១ | ៩.៤ | ៩.៨ | ១០.២ | ៤៧.៣ |
| **ឧស្សាហកម្ម** | **៤៥៨.៧** | **៥១០.២** | **៥៧២.៩** | **៦៤៦.៩** | **៧៣៦.៣** | **២.៩២៥.០** |
| រ៉ែ | ០.៦ | ០.៧ | ០.៨ | ០.៩ | ១.០ | ៤.០ |
| កម្មន្តសាល | ១៦០.០ | ១៧៧.១ | ១៩៨.៤ | ២២៥.៨ | ២៦២.៧ | ១.០២៤.០ |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ១៤.៧ | ១៥.៤ | ១៦.២ | ១៧.២ | ១៨.៣ | ៨១.៨ |
| វាយនភ័ណ្ឌ សំលៀកបំពាក់ និងស្បែកជើង | ១១៧.១ | ១៣១.៥ | ១៤៩.៣ | ១៧២.២ | ២០៣.៤ | ៧៧៣.៥ |
| ក្តារបន្ទះ ក្រដាស និងបោះពុម្ព | ៥.៥ | ៥.៨ | ៦.៣ | ៦.៩ | ៧.៦ | ៣២.១ |
| ផលិតផលកៅស៊ូ | ៩.០ | ៩.៩ | ១១.១ | ១២.៨ | ១៥.២ | ៥៨.០ |
| ផលិតផលផ្សេងៗទៀត | ១៣.៦ | ១៤.៤ | ១៥.៥ | ១៦.៧ | ១៨.៣ | ៧៨.៥ |
| អគ្គិសនី ឧស្ម័ន និងទឹកស្អាត | ៨៦.២ | ៩៦.៥ | ១០៨.៥ | ១២២.១ | ១៣៧.៣ | ៥៥០.៦ |
| សំណង់ | ២១១.៩ | ២៣៦.០ | ២៦៥.៣ | ២៩៨.២ | ៣៣៥.៣ | ១.៣៤៦.៧ |
| **សេវាកម្ម** | **៤២៣.៣** | **៤៥៩.៩** | **៥០១.៩** | **៥៥០.៧** | **៦០៩.១** | **២.៥៤៤.៩** |
| ពាណិជ្ជកម្ម | ៧០.០ | ៧៦.៣ | ៨១.៩ | ៨៧.៦ | ៩៣.៨ | ៤០៩.៦ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៧៥.៤ | ៨៤.២ | ៩៥.៦ | ១១០.៥ | ១៣០.៧ | ៤៩៦.៤ |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | ៧៨.៨ | ៨៥.៧ | ៩៣.១ | ១០១.៣ | ១១០.១ | ៤៦៩.០ |
| ហិរញ្ញវត្ថុ | ៦.៧ | ៧.៣ | ៧.៩ | ៨.៥ | ៩.៣ | ៣៩.៧ |
| រដ្ឋបាលសាធារណៈ | ១១៣.២ | ១២០.១ | ១២៨.២ | ១៣៦.៩ | ១៤៦.២ | ៦៤៤.៦ |
| ភ្នាក់ងារផ្តល់សេវាកម្ម និងអាជីវកម្ម | ៥៥.៨ | ៦០.១ | ៦៦.០ | ៧៣.៤ | ៨៣.១ | ៣៣៨.៤ |
| សេវាកម្មផ្សេងទៀត | ២៣.៥ | ២៦.៤ | ២៩.២ | ៣២.៤ | ៣៦.០ | ១៤៧.៥ |
| | | | | | | |
| **សរុប** | **១.០៥០.៨** | **១.១៤៧.៣** | **១.២៦០.៩** | **១.៣៩៣.០** | **១.៥៤៨.៩** | **៦.៤០០.៩** |
| | | | | | | |
| **ការវិនិយោគទុនសរុប** | **១.០៥០.៨០** | **១.១៤៧.៤០** | **១.២៦០.៩០** | **១.៣៩៣.០០** | **១.៥៤៩.០០** | **៦.៤០១.១០** |
| **វិនិយោគសាធារណៈ** | **៤០៩.០០** | **៤៣២.១០** | **៤៧៣.០០** | **៥១៩.៣០** | **៥៥៥.២០** | **២.៣៨៤.៦០** |

| ពតិមានលំអិត/វិស័យ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | សរុប |
|---|---|---|---|---|---|---|
| ហិរញ្ញប្បទានក្នុងស្រុក | ៨៦,៦០ | ១១២,៦០ | ១៤៦,៤០ | ១៩០,៣០ | ២៤៧,៤០ | ៧៨៣,៣០ |
| ហិរញ្ញប្បទានពីបរទេស | ៣២២,៣០ | ៣១៩,៥០ | ៣២៦,៧០ | ៣២៥,០០ | ៣០៧,៨០ | ១.៦០១,៣០ |
| **វិនិយោគឯកជន** | **៦៤១,៨០** | **៧១៥,៣០** | **៧៨៧,៩០** | **៨៧៧,៧០** | **៩៩៣,៨០** | **៤.០១៦,៥០** |
| ហិរញ្ញប្បទានក្នុងស្រុក | ៤៥៦,៨០ | ៥១១,៣០ | ៥៥២,៩០ | ៥៩៥,៧០ | ៦៤១,៨០ | ២.៧៥៨,៥០ |
| ហិរញ្ញប្បទានពីបរទេស | ១៨៥,០០ | ២០៤,០០ | ២៣៥,០០ | ២៨២,០០ | ៣៥២,០០ | ១.២៥៨,០០ |
| **សរុបហិរញ្ញប្បទានក្នុងស្រុក** | **៥៤៣,៤០** | **៦២៣,៩០** | **៦៩៩,៣០** | **៧៨៦,០០** | **៨៨៩,២០** | **៣.៥៤១,៨០** |
| **សរុបហិរញ្ញប្បទានពីបរទេស** | **៥០៧,៣០** | **៥២៣,៥០** | **៥៦១,៧០** | **៦០៧,០០** | **៦៥៩,៨០** | **២.៨៥៩,៣០** |

**ប្រភព:** ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ខែកញ្ញា ឆ្នាំ២០០៥)

| | |
|---|---|
| វិនិយោគសាធារណៈ (មូលធន)<br>ប៉ាន់ស្មានដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ២.៣៨៤,៦០ |
| តម្រូវការចិកាបន្ថែមសម្រាប់វិស័យសង្គមកិច្ច | ៣០០,០០ |
| ជំនួយបច្ចេកទេស អង្កេត និងបណ្តុះបណ្តាល | ៥០០,០០ |
| ចំណាយចរន្តបន្ថែម | ៣០០,០០ |
| ទុនបម្រុង (មិនធ្វើវិភាជន៍) | ១៥,៤០ |
| **សរុបចំណាយ *ផយអជ*** | **៣.៥០០,០០** |

| | |
|---|---|
| *កវស* ប៉ាន់ស្មាន ២០០៥-២០០៧ : មូលធន | ២.៣៧២,៦២ |
| : ជំនួយបច្ចេកទេសដាច់ៗគ្នា | ៨៥៦,៦៨ |
| បូកបន្ថែមចំណាយចរន្ត | ២៧០,៧០ |
| **សរុបចំណាយ *ផយអជ*** | **៣.៥០០,០០** |

# ឧបសម្ព័ន្ធ ២.៣

## ចំណាយថវិកា

## ការបែងចែកតាមវិស័យ និងអាទិភាពក្រសួង

(គិតជាភាគរយនៃការចំណាយរបស់រដ្ឋាភិបាល)

| ពតិមានលំអិត/ វិស័យ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| | | ប៉ាន់ស្មាន | | | | |
| **រដ្ឋបាលទូទៅ** | **១៤,០៣** | **១៣,៨៤** | **១៣,៩០** | **១៤,០០** | **១៤,០០** | **១៤,០០** |
| យុត្តិធម៌ | ០,៦៦ | ០,៦៧ | ០,៦៧ | ០,៦៧ | ០,៦៨ | ០,៦៨ |
| រដ្ឋបាលទូទៅផ្សេងទៀត | ១៣,៣៧ | ១៣,១៨ | ១៣,២៣ | ១៣,៣៣ | ១៣,៣២ | ១៣,៣២ |
| **ការពារជាតិ និងសន្តិសុខសង្គម** | **២២,៨០** | **២០,៨៧** | **២១,៣០** | **២១,៣០** | **២១,១០** | **២០,៨០** |
| **សេវាកម្មសង្គមកិច្ច** | **៣៨,៤៣** | **៣៧,៣៦** | **៣៨,៤០** | **៣៨,៤៥** | **៣៨,៥០** | **៣៩,២០** |
| សុខាភិបាល | ១២,០៤ | ១២,៧៤ | ១២,៧៥ | ១២,៧៥ | ១២,៧៥ | ១២,៩១ |
| អប់រំ | ១៨,៤៩ | ១៨,៤៩ | ១៨,៥០ | ១៨,៥០ | ១៨,៥០ | ១៨,៨១ |
| កិច្ចការនារី | ០,៥៦ | ០,៥៦ | ០,៥៦ | ០,៥៦ | ០,៥៦ | ០,៥៦ |
| សេវាកម្មសង្គមកិច្ចផ្សេងទៀត | ៧,៣៤ | ៥,៥៧ | ៦,៦០ | ៦,៦៥ | ៦,៧០ | ៦,៩៣ |
| **សេវាកម្មសេដ្ឋកិច្ច** | **១០,០៨** | **១១,១០** | **១១,១១** | **១១,១១** | **១១,២០** | **១១,៣៩** |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២,៥៣ | ២,៦៧ | ២,៦៧ | ២,៦៧ | ២,៧០ | ២,៧៥ |
| អភិវឌ្ឍន៍ជនបទ | ១,២៤ | ១,៣១ | ១,៣១ | ១,៣១ | ១,៣២ | ១,៣៣ |
| សេវាកម្មសេដ្ឋកិច្ចផ្សេងទៀត | ៦,៣១ | ៧,១៣ | ៧,១៣ | ៧,១៣ | ៧,១៨ | ៧,៣១ |
| **សន្សំ និងបំណុល** | **១៤,៦៦** | **១៦,៨៤** | **១៥,២៩** | **១៥,១៤** | **១៥,២០** | **១៤,៦១** |
| **ចំណាយចរន្តរបស់រដ្ឋាភិបាល (ពាន់លានរៀល)** | **១.៩៨៣,៦០** | **២.៣៧៨,៥២** | **២.៧៦៩,០៤** | **៣.០៨៨,៧៣** | **៣.៣៧៣,៣៧** | **៣.៦១៤,២០** |

**ប្រភព:** ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ខែវិច្ឆិកា ឆ្នាំ២០០៥)

# ឧបសម្ព័ន្ធ ៣

## វឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ និងបញ្ហាប្រឈមក្នុង ៥ឆ្នាំ[១]

**១.** ការរាលដាលនៃភាពក្រីក្ររបស់កម្ពុជា ក្នុងបរិបទនៃសង្គ្រាមស៊ីវិលជាង ២ទសវត្សរ៍ និងទុក្ខវេទនា គឺជាបញ្ហាប្រឈមគន្លឹះមួយរបស់រាជរដ្ឋាភិបាល ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទី១ ឆ្នាំ១៩៩៦-២០០០ បានចាប់ផ្តើមជាមួយនឹងការសន្មតថា "ការលុបបំបាត់ភាពក្រីក្រ គឺជាទិសដៅតែមួយគត់និងយូរអង្វែងរបស់រាជរដ្ឋាភិបាល ហើយការកាត់បន្ថយភាពក្រីក្រនេះគឺជាការនាំមុខស្នូលនៃផែនការឆ្នាំ១៩៩៦-២០០០" ។ ទិសដៅនេះត្រូវបានលើកឡើងជាថ្មីទៀត ក្នុងឯកសារគោលនយោបាយបន្តមកទៀត ដូចជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើទី២ ឆ្នាំ២០០១-២០០៥ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣-២០០៥ ។

**២.** ប៉ាន់ស្មានក្រីក្រសម្រាប់កម្ពុជាបានផ្អែកលើការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា[២] ។ ការអង្កេតចុងក្រោយនេះត្រូវបានធ្វើឡើងនៅឆ្នាំ២០០៤ ដែលបានប្រមូលទិន្នន័យស្តីពីការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ដោយប្រើប្រាស់វិធីសាស្ត្រវិខល និងវិធីសាស្ត្រដាតរី ។ តារាង១ ធ្វើការប្រៀបធៀបកម្រិតភាពក្រីក្រនៅកម្ពុជា ដែលបានមកពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៣-១៩៩៤ ដែលគ្របដណ្តប់បានតែ ៥៩ភាគរយនៃតំបន់ទូទាំងប្រទេសនិង ៦៨ភាគរយនៃគ្រួសារទាំងអស់ ដោយសារតែបញ្ហាសន្តិសុខនៅពេលនោះ ជាមួយនឹងកម្រិតភាពក្រីក្រដែលបានមកពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ២០០៤ ដែលបានគ្របដណ្តប់ទូទាំងប្រទេស[៣] ។

### តារាង១ : ផលធៀបការរាប់ចំនួនជនក្រីក្រនៅកម្ពុជា

(គិតជាភាគរយ)

| | បន្ទាត់ភាពក្រី | | បន្ទាត់ភាពក្រីក្រម្ហូបអាហារ | |
|---|---|---|---|---|
| | ១៩៩៣-៩៤ | ២០០៤ | ១៩៩៣-៩៤ | ២០០៤ |
| ក) ទូទាំងកម្ពុជា | | | | |
| ភ្នំពេញ | - | ៤,៦ | - | ២,៦ |
| តំបន់ទីប្រជុំជនផ្សេងទៀត | - | ២៤,៦ | - | ១៤,២ |

[១] កំណត់សម្គាល់នេះរៀបចំដោយក្រសួងផែនការ ខែតុលា ឆ្នាំ២០០៥

[២] គួរបញ្ជាក់នៅទីនេះថា ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចដែលបានដំណើរការរៀបចំនៅពេលវេលាខុសៗគ្នា តួលេខភាពក្រីក្រដែលទទួលបានមិនអាចធ្វើការប្រៀបធៀបបានទេ ដោយសារមានលក្ខណៈខុសគ្នាខាងបច្ចេកទេសអង្កេត ការគ្របដណ្តប់ ការប្រមូលទទិន្នន័យ និងវិធីសាស្ត្រផ្សេងៗទៀត ។ ក្នុងការប្រៀបធៀបភាពក្រីក្រនៅគ្រប់ពេលទាំងអស់ត្រូវចងចាំការណែនាំនេះក្នុងគំនិតជានិច្ច ។

[៣] តួលេខសម្រាប់ឆ្នាំ២០០៤ ត្រូវបានផ្អែកលើតួលេខចំណាយលើការប្រើប្រាស់ដែលទទួលបានពីការប្រមូលដោយវិធីសាស្ត្រវិខល សម្រាប់សំណាកគំរូ១២ខែនៃឆ្នាំ២០០៤ ។ ចំណុចដៅថ្មីនិងការប៉ាន់ស្មានភាពក្រីក្រសម្រាប់ឆ្នាំ២០០៤ ដោយប្រើប្រាស់តួលេខដែលបានប្រមូលដោយប្រើប្រាស់វិធីសាស្ត្រដាយរីនៅមិនទាន់មាននៅឡើយ ។ តួលេខភាពក្រីក្រសម្រាប់ឆ្នាំ១៩៩៣-១៩៩៤ បានផ្អែកលើតួលេខដែលបានប្រមូលដោយប្រើប្រាស់វិធីសាស្ត្រវិខល ។

| | បន្ទាត់ភាពក្រី | | បន្ទាត់ភាពក្រីក្រម្ហូបអាហារ | |
|---|---|---|---|---|
| | ១៩៩៣-៩៤ | ២០០៤ | ១៩៩៣-៩៤ | ២០០៤ |
| តំបន់ជនបទ | - | ៣៩,២ | - | ២២,២ |
| កម្ពុជា | - | ៣៤,៧ | - | ១៩,៧ |
| ខ) តំបន់ភូមិសាស្ត្រដែលបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៣-៩៤ | | | | |
| ភ្នំពេញ | ១១,៤ | ៤,៦ | ៦,២ | ២,៦ |
| តំបន់ប្រជុំជនផ្សេងទៀត | ៣៦,៦ | ២០,៥ | ១៩,៦ | ១២,៥ |
| តំបន់ជនបទ | ៤៣,១ | ៣៣,៧ | ២២,០ | ១៦,៧ |
| កម្ពុជា | ៣៩,០ | ២៨,០ | ២០,០ | ១៤,២ |
| គ) តំបន់ភូមិសាស្ត្រដែលបានបាន គ្របដណ្តប់ដោយអង្កេតសេដ្ឋ-កិច្ច-សង្គមកិច្ច ១៩៩៣/១៩៤ | ... | ៤៥,៦ | ... | ២៨,៧ |

*ចំណាំ : "..." មានន័យថា ពុំទាន់មានទិន្នន័យបញ្ជាក់ ។ ខ្សែបន្ទាត់ភាពក្រីក្រផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ (ដែលផ្តល់ ២.១០០កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ) និងការចំណាយមិនមែនម្ហូបអាហារក្នុងកម្រិតអប្បបរមា ។*

**៣.** លទ្ធផលបង្ហាញថាសន្ទស្សន៍នៃភាពក្រីក្រសម្រាប់ទូទាំងកម្ពុជាគឺ ៣៤,៧ភាគរយក្នុងឆ្នាំ២០០៤ ។ ពុំមានការប៉ាន់ស្មានអាចប្រៀបធៀបជាមួយភាពក្រីក្រសម្រាប់ទូទាំងនៅឆ្នាំ១៩៩៣-៩៤ ទេ ដោយសារតំបន់ភូមិ-សាស្ត្រដែលគ្របដណ្តប់ដោយការអង្កេតឆ្នាំ១៩៩៣-១៩៩៤ មានចំនួនតិចពេក ។ ទោះជាដូចនេះក្តី ការប៉ាន់ស្មាននៅឆ្នាំ២០០៤ ពីសំណាកគំរូ ដែលបានគ្របដណ្តប់លើតំបន់ភូមិសាស្ត្រដូចគ្នាក្នុងការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៣-១៩៩៤ បានបង្ហាញថា អត្រាភាពក្រីក្រនៅកម្ពុជាមានការថយចុះយ៉ាងខ្លាំង ពី ៣៩ភាគរយក្នុងឆ្នាំ ១៩៩៣-១៩៩៤ មក ២៨ភាគរយក្នុងឆ្នាំ២០០៤ ។ និន្នាការនេះបង្ហាញពីការធ្លាក់ចុះនៃភាពក្រីក្រ ប្រហែល ១១ភាគរយ ដែលក្នុងរយៈពេលនោះ គឺប្រហែលថយចុះជាមធ្យម ១ភាគរយ ក្នុងមួយឆ្នាំ ។

**៤.** ដូចគ្នាដែរ ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារ សម្រាប់ទូទាំងប្រទេសគឺ ១៩,៧ភាគរយក្នុងឆ្នាំ២០០៤ ដែលក្នុងនោះ នៅតំបន់ភូមិសាស្ត្រដែលជាសំណាកគំរូអាចប្រៀបធៀបបាន សន្ទស្សន៍ភាពក្រីក្រម្ហូបអាហារបានធ្លាក់ចុះពី ២០ភាគរយ ទៅ ១៤,២ភាគរយក្នុងរយៈពេលដូចគ្នា គឺពីឆ្នាំ១៩៩៣-១៩៩៤ ទៅឆ្នាំ២០០៤ ។ ភាពក្រីក្រដែលបានវាស់វែងតាមរយៈសន្ទស្សន៍ទាំងពីនេះ បានថយចុះនៅក្នុងតំបន់ទាំង៣នៃប្រទេស សម្រាប់តំបន់ភូមិសាស្ត្រដែលជាសំណាកគំរូអាចប្រៀបធៀបបាន ទោះបីជានៅតំបន់ជនបទនៅតែមានអត្រាភាពក្រីក្រខ្ពស់ខ្លាំងក៏ដោយ ។

**៥.** ក្នុងរយៈពេលដូចគ្នា ការប្រែប្រួលភាពក្រីក្រដែលមានការពាក់ព័ន្ធ ដូចជាសន្ទស្សន៍គម្លាតនៃភាពក្រីក្រ (P1) និងស្វ័យគុណនៃសន្ទស្សន៍គម្លាតភាពក្រីក្រ (P2) ឆ្លុះបញ្ចាំងជាទូទៅពីការប្រែប្រួលដែល បានពិនិត្យឃើញក្នុង

ផលធៀបរាប់ចំនួនមនុស្ស ដូចដែលបានរៀបរាប់ខាងលើ ។ តាមរៈសន្ទស្សន៍ភាពក្រីក្រដែលបានធ្លាក់ចុះស្របគ្នាក្នុងតំបន់ទាំង៣ សម្រាប់តំបន់ភូមិសាស្ត្រដែលជាសំណាកគំរូអាចប្រៀបធៀបបាន ទាំងនេះ បានបង្ហាញថា មួយផ្នែកធំនៃប្រជាជនក្រីក្រ កំពុងស្ថិតនៅជិតបន្ទាត់ភាពក្រីក្រជាងក្នុងពេលឆ្នាំ១៩៩៣/១៩៩៤ [១] ។

**៦.** ក្នុងឆ្នាំ២០០៤ អត្រាភាពក្រីក្រដែលខ្ពស់ជាងគេនៅទូទាំងប្រទេសកម្ពុជា ដែលបានប្រៀបធៀបទៅនឹងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ គឺជាតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៤៤ភាគរយនៃតំបន់សរុបទូទាំងប្រទេស) ។ តាមការគណនាដ៏សាមញ្ញមួយបង្ហាញថា ផលធៀបរាប់ចំនួនមនុស្សក្នុងតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ នេះ មាន ៤៥,៦ភាគរយក្នុងឆ្នាំ២០០៤ (ប្រៀបធៀបទៅនឹង ២៨ភាគរយក្នុងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤) ដែលជាមួយគ្នានោះ សន្ទស្សន៍ភាពក្រីក្រម្ហូបអាហារគឺ ២៨,៧ភាគរយ (ប្រៀបធៀបទៅនឹង ១៤,២ភាគរយ ក្នុង តំបន់ដែលបានគ្របដណ្តប់ដោយអង្កេតឆ្នាំ ១៩៩៣-១៩៩៤) [២] ។

**៧.** ជាង ៩០ភាគរយនៃប្រជាជនក្រីក្ររស់នៅក្នុងតំបន់ជនបទ នេះបង្ហាញឱ្យឃើញថា ភាពក្រីក្រនៅកម្ពុជាភាគច្រើនមានឫសគល់នៅក្នុងវិស័យកសិកម្ម ដែលមានផលិតភាពនិងកំណើនទាប ប៉ុន្តែបានផ្តល់ជីវិតរស់នៅដល់ប្រជាជនភាគច្រើននៅក្នុងប្រទេស ។ ជាមួយគ្នានឹងភាពខុសគ្នាយ៉ាងខ្លាំងនៃអត្រាភាពក្រីក្រ ភាពខុសគ្នារវាងចំណែកនៃប្រជាជនក្រីក្រនៅជនបទ និងចំណែកនៃប្រជាជនក្រីក្រនៅទីប្រជុំជន ក៏កើនឡើងកាន់តែខ្លាំងដែរ ដែលក្នុងរយៈពេលនោះ ចំណែកនៃប្រជាជនក្រីក្រនៅជនបទមានការកើនឡើង បើប្រៀបធៀបទៅនឹងប្រជាជនក្រីក្រទាំងអស់នៅក្នុងប្រទេស (ពី ៨៧ភាគរយក្នុងឆ្នាំ១៩៩៣/៩៤ ទៅ ៩១ភាគរយក្នុងឆ្នាំ២០០៤) ហើយ ចំណែកនៃប្រជាជនក្រីក្រនៅទីក្រុងភ្នំពេញបានធ្លាក់ចុះ បើប្រៀបធៀបទៅនឹងប្រជាជនក្រីក្រទាំងអស់នៅក្នុងប្រទេស (ពី ៣ភាគរយ ទៅ ១ភាគរយ) និងនៅក្នុងតំបន់ទីប្រជុំជនផ្សេងទៀត អត្រានេះបានថយចុះ ពី ១០ភាគរយ ទៅ ៨ភាគរយ ។

**៨.** ស្ថានភាពនៃជនក្រីក្រកម្ពុជា គឺពុំមានភាពខុសគ្នាខ្លាំងពីប្រជាជនក្រីក្រក្នុងប្រទេសក្រីក្រផ្សេងទៀតទេ ។ ភាពក្រីក្រទូទៅ ក៏ដូចជាភាពក្រីក្រម្ហូបអាហារនៅក្រុងភ្នំពេញ មានកម្រិតខ្ពស់ជាងខ្លាំងនៅក្នុងតំបន់ជនបទ និងតំបន់ទីប្រជុំជនផ្សេងទៀត ។ ក្រៅពីការរស់នៅនៅតំបន់ជនបទ ប្រជាជនក្រីក្រតែងតែមានកម្រិតអប់រំទាប លទ្ធភាព

---

[១] លំដាប់ទី១ នៃភាពលើសលុបនៃការបូកបន្ថែមបន្តការបែងចែកចំណាយពិតសម្រាប់មនុស្សម្នាក់ ក្នុងឆ្នាំ២០០៤ លើការបែងចែកឆ្នាំ១៩៩៣-១៩៩៤ នៅកម្ពុជា បង្ហាញថា និន្នាកានៃភាពក្រីក្រក្នុងរយៈពេលនោះ អាចដូចគ្នាលើជួរនៃបន្ទាត់ភាពក្រីក្រដែលអាចមានជាក់ស្តែងទាំងអស់ ។

[២] ជាមួយចំណែកនៃប្រជាជនដែលបានប៉ាន់ស្មានប្រហែល ៣៨ ភាគរយក្នុងតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ ដោយសន្មតថា x គឺជាសន្ទស្សន៍ភាពក្រីក្រក្នុងតំបន់ដែលមិនបានគ្របដណ្តប់ក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ សម្រាប់សន្ទស្សន៍ភាពក្រីក្រគណនាតាម $០,៦២ \times ២៧,៩៧ + ០,៣៨ \times x = ៣៤,៦៨$ ដែលអាចទទួលបាន $x = ៤៥,៦៣\%$ ដូចគ្នានេះដែរសម្រាប់សន្ទស្សន៍ភាពក្រីក្រម្ហូបអាហារ គណនាតាម $០,៦២ \times ១៤,១៨ + ០,៣៨ \times x = ១៩,៦៨$ ដែលអាចទទួលបាន $x = ២៨,៦៥\%$ ។

មានកំរិតក្នុងការទទួលបានដីនិងទ្រព្យសកម្មផ្សេងទៀត និងប្រមូលផ្តុំច្រើននៅក្នុងការងារដែលទទួលបានកំរៃទាប ការងារដែលប្រើប្រាស់កម្លាំងពលកម្ម និងការងារដែលសង្គមមិនសូវចាប់អារម្មណ៍ ។ ទាំងនៅក្នុងតំបន់ទីក្រុង និងតំបន់ជនបទ អ្នកក្រីក្រទទួលបានសេវាកម្ម និងភាពទំនើកម្មតិចតួច ។ ប្រជាជនក្រីក្រទាំងនោះរស់នៅក្នុងផ្ទះដែលមានគុណភាពទាប ជាមួយការមិនទទួលបានមានកម្រិតនូវសេវាមូលដ្ឋាន ដូចជាទឹកស្អាត និងការធ្វើឱ្យប្រសើរឡើងអនាម័យ ។ ប្រជាជនក្រីក្រតែងតែរស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើន មានកូនច្រើន និងមានមេគ្រួសារដែលមានការអប់រំតិចតួច ។ ប្រជាជនទាំងនោះក៏មានលទ្ធភាពតិចតួចក្នុងការទទួលបានតិចតួចនូវសេវាសាធារណៈ ។

**៩.** ជាការពិតនៅកម្ពុជា ភាពក្រីក្រនៅតំបន់ជនបទបានធ្លាក់ចុះក្នុងអត្រាមួយយឺត១ ជាងភាពក្រីក្រនៅភ្នំពេញ ឬតំបន់ទីប្រជុំជនផ្សេងទៀត ។ ការធ្លាក់ចុះខ្លាំងនៃភាពក្រីក្រក្នុងតំបន់នេះ (ជាទូទៅនៅក្នុងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤) គឺដោយសារឥទ្ធិពលនៃកំណើនដ៏ខ្លាំងនៅតំបន់ទីប្រជុំជន និងការប្រមូលផ្តុំវិនិយោគសាធារណៈក្នុងតំបន់ទាំងនោះ ។ នេះឆ្លុះបញ្ចាំងឱ្យឃើញពី "លទ្ធផលនៃសន្តិភាព " ដែលកម្ពុជាបានទទួល តាមរយៈការបញ្ចប់នូវជម្លោះនិងភាពឯកកោរជាងពីរទសវត្សរ៍កន្លងមក ដែលធ្វើឱ្យមានការកើនឡើងនូវការវិនិយោគនិងកំណើនសេដ្ឋកិច្ច ហើយជាលទ្ធផលធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្រ[៣] ។ ទោះជាដូចនេះក្តី ជាទូទៅកំណើននេះមិនមានតុល្យភាពទេ ដោយបានប្រមូលផ្តុំច្រើននៅទីក្រុងភ្នំពេញនិងទីប្រជុំជននានា មានមូលដ្ឋានតិចតួច និងនាំមុខដោយសកម្មភាពដូចជា ឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ ។

**១០.** ផ្ទុយទៅវិញ កំណើននៃសកម្មភាពនៅជនបទ ដែលជាចម្បងផ្អែកលើកសិកម្ម បានបង្ហាញពីគម្លាតច្រើននិងដែលអាចប្រែប្រួលនៅពីក្រោយសេដ្ឋកិច្ច ។ លើសពីនេះទៀត កំណើនក្នុងវិស័យកសិកម្មនៅពេលអំឡុងពេលនោះ ត្រូវបានកំណត់ភាគច្រើននៅក្នុងតំបន់ជនបទមួយចំនួនដែលមានអំណោយផលច្រើន ។ ភាពខុសគ្នាយ៉ាងខ្លាំងនៃកម្រិតភាពក្រីក្រ រវាងតំបន់ដែលបានគ្របដណ្តប់ និងមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ គឺជាលទ្ធផលនៃកត្តាទាំងនោះ ។

**១១.** ប្រសិនបើកំណើននៅតែបន្តនៅទីប្រជុំជន ភាពក្រីក្រនៅជនបទនឹងនៅតែមានកម្រិតខ្ពស់ ជាពិសេសនៅពេលដែលទំហំនៃភាពក្រីក្រកាន់តែធំឡើងនៅតំបន់ជនបទ ។ នៅក្នុងស្ថានភាពបែបនេះ ការកាត់បន្ថយភាពក្រីក្រ ដែលទទួលបានពី *ផយអជ* នឹងមានកម្រិតតិចតួចបំផុត ។ បញ្ហានេះ នឹងធ្វើឱ្យរាំងស្ទះដល់ការសម្រេចបានចំណុចដៅទាំងឡាយរបស់ *ផយអជ* នាឆ្នាំ២០១០ និង *គអសក* នាឆ្នាំ២០១៥ ។ ដូច្នេះ បញ្ហាប្រឈមចម្បងរបស់

---

[៣] ក្នុងរយៈពេលនោះដែរ កម្ពុជាបានទទួលផលចំណេញពីលក្ខខណ្ឌអំណោយផលសំខាន់ៗ ដូចជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពីចុងឆ្នាំ១៩៩០ ទៅ២០០៥ និងបន្តនៅក្នុងបញ្ជីសុវត្ថិភាពរបស់សហរដ្ឋអាមេរិករហូតដល់ឆ្នាំ២០០៨។

*ផយអជ* គឺអនុម័តនូវយុទ្ធសាស្ត្រនិងសកម្មភាពដែលបានកំណត់រួចហើយ ដើម្បីជំរុញការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ជាពិសេស នៅតំបន់ដែលមានភាពក្រីក្រខ្ពស់ និងតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤ ។ លើសពីនេះ បញ្ហាប្រឈមនៃ *ផយអជ* នឹងត្រូវពង្រីកថែមទៀតនូវសមិទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ ដែលបានមកពីវឌ្ឍនភាពនៃសមាសភាគសំខាន់ពីរនៃយុទ្ធសាស្ត្រចតុកោណ (សន្តិភាពនិងសន្តិសុខ សមាហរណកម្មទៅក្នុងតំបន់និងពិភពលោក) និងការផ្តួចផ្តើមឱ្យមានវឌ្ឍនភាព យ៉ាងឆាប់រហ័សដោយស្មើភាព នៅក្នុងមុំផ្សេងទៀតនៃយុទ្ធសាស្ត្រចតុកោណ រួមទាំងការបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមនិងធនធានមនុស្ស ។

**១២.** ចំនួនភូមិទាំងឡាយដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤ តាមខេត្ត ត្រូវបានបង្ហាញក្នុងតារាង២ ។ ចំនួនភូមិទាំងអស់មាន ៥.០៩៣ភូមិនៅជនបទ និង ៩០ភូមិនៅទីប្រជុំជន ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ នេះ ដោយហេតុថាជាតំបន់ពិបាកធ្វើដំណើរទៅដល់ និងបញ្ហាសន្តិសុខ ។ អង្កេតនេះមិនបានគ្របដណ្តប់ទាំងស្រុងនូវខេត្ត៦ គឺខេត្តកោះកុង ក្រចេះ មណ្ឌលគីរី ព្រះវិហារ រតនគីរី និងស្ទឹងត្រែង ។

**១៣.** តារាងទី២នេះបង្ហាញថា ភូមិដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤ ភាគច្រើនស្ថិតនៅតំបន់ជនបទ ដែលភាពក្រីក្រមានកម្រិតខ្ពស់នៅក្នុងឆ្នាំ២០០៤ ។ នៅក្នុងបណ្តាឆ្នាំបន្ទាប់នេះ ទំនាក់ទំនងរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ (ដែលបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣/៩៤) អាចមានភាពល្អប្រសើរជាងមុន និងបន្តរីកចម្រើន ហើយកម្រិតនៃភាពក្រីក្រក្នុងតំបន់ទាំងអស់នោះនឹងថយចុះ ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចទូទៅរបស់កម្ពុជាមានជាមធ្យមប្រហែល ៦ភាគរយក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ ។ ម៉្យាងវិញទៀត បន្ថែមលើវិធានការជំរុញល្បឿនកំណើននៅតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤ នឹងទាមទារឱ្យការយកចិត្តទុកដាក់ជាពិសេស និងធាតុចូលនិងការវិនិយោគដែលបានកំណត់ ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យថយចុះពីកម្រិតខ្ពស់ដែលមានស្រាប់ ។ ជាការពិតដែលថា បណ្តាឃុំនិងភូមិនៅតំបន់ផ្សេងទៀត នៅដាច់ស្រយាលនិងប្រមូលផ្តុំខ្ពស់នៃអ្នកក្រីក្រ ។ លើសពីនេះទៀត បណ្តាយុទ្ធសាស្ត្រនៃ *ផយអជ* គប្បីទទួលស្គាល់ថា ជាតម្រូវការជាក់លាក់នៃជនជាតិភាគតិច និងជនអន្តោប្រវេសន៍ដែលមានទំនាក់ទំនងស្មុគស្មាញទៅនឹងបញ្ហាសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌ ច្បាប់ នយោបាយ និងបញ្ហាដទៃទៀត ។

## តារាង២ : តំបន់ក្រៅអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤

| ខេត្ត-ក្រុង | ចំនួនតំបន់ក្រៅអង្កេត | |
|---|---|---|
| | ទីប្រជុំជន | ជនបទ |
| បន្ទាយមានជ័យ | ៧ | ៣៩៥ |
| បាត់តំបង | ... | ២៩១ |

| ខេត្ត-ក្រុង | ចំនួនតំបន់ក្រៅអង្កេត | |
|---|---|---|
| | ទីប្រជុំជន | ជនបទ |
| កំពង់ចាម | ... | ៣៣៤ |
| កំពង់ឆ្នាំង | ... | ២៦៨ |
| ក្រុងព្រះសីហនុ | ... | ៥៩ |
| កំពង់ស្ពឺ | ... | ៩៦៨ |
| កំពង់ធំ | ... | ៦៦៣ |
| កំពត | ... | ៣១៥ |
| កណ្ដាល | ... | ១០៩ |
| កោះកុង | ១០ | ១០៩ |
| ក្រចេះ* | ... | ២៤៣ |
| មណ្ឌលគិរី* | ១៣ | ៧៤ |
| ភ្នំពេញ | ... | ... |
| ព្រះវិហារ* | ២៧ | ១៧០ |
| ព្រៃវែង | ... | ... |
| ពោធិសាត់ | ... | ៥១ |
| រតនៈគិរី* | ១៦ | ២២៧ |
| សៀមរាប | ... | ៦៨៩ |
| ស្ទឹងត្រែង* | ១៧ | ១១២ |
| ស្វាយរៀង | ... | ... |
| តាកែវ | ... | ៦៦ |
| **សរុប** | **៩០** | **៥.០៩៣** |

*កំណត់ចំណាំ* : ខេត្តដែលមានសញ្ញា (*) ជាខេត្តដែលនៅក្រៅអង្កេតទាំងស្រុង ។ ក្នុងសំណាកគំរូនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ១៩៩៣/៩៤ ក្រុងកែប គឺស្ថិតនៅក្នុងខេត្តកំពត ឧត្តរមានជ័យស្ថិតនៅក្នុងខេត្តសៀមរាប និង ក្រុងប៉ៃលិនស្ថិតនៅក្នុងខេត្តបាត់ដំបង ។

**១៤.** សកម្មភាពពិសេសទាំងអស់នេះ នឹងរួមបញ្ចូល ការពឹងផ្អែកលើស្ថានភាពដែលមានស្រាប់ និងតម្រូវការជាក់លាក់នៅមូលដ្ឋាន ការថែទាំសុខភាពឱ្យបានកាន់តែច្រើននិងល្អប្រសើរឡើង ការពង្រីកប្រព័ន្ធអប់រំ ការបង្កើតសកម្មភាពកសិកម្មនិងមិនមែនកសិកម្មនៅជនបទ ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ការបង្កើនជីវភាពរស់នៅប្រកបដោយនិរន្តរភាព និងសកម្មភាពប្រហាក់ប្រហែលដទៃទៀត ។ ជាមួយគ្នានេះ ការផ្ដល់មូលនិធិច្រើនបន្ថែមទៀតទៅឱ្យតំបន់ដែលមិនបានគ្របដណ្ដប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ ទាំងនោះក្នុងអំឡុងពេល *ផយអជ* តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ ក៏ជាការចាំបាច់ណាស់ដែរ ។

**១៥.** បញ្ហាចម្បងផ្សេងទៀតសម្រាប់ *ផយអជ* ទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ គឺការកើនឡើងនៃនិន្នាការវិសមភាព ដោយសារតែផលប៉ះពាល់នៃកំណើនសេដ្ឋកិច្ចលើភាពក្រីក្រ ក៏អាស្រ័យផងដែរលើបញ្ហាដែលកើតមានឡើងចំពោះវិសមភាព[១] ។ ការកើនឡើងនៃវិសមភាពនៅកម្ពុជា ជាពិសេស នៅតំបន់ជនបទ បង្ហាញថា ទម្រង់នៃកំណើននៅតំបន់ជនបទកន្លងមកនៅកម្ពុជា មាននិន្នាការជាមូលដ្ឋានឆ្ពោះទៅរកការកើតឡើងវិសមភាពកាន់តែខ្ពស់ ។ ដើម្បីទប់ទល់នឹងនិន្នាការបែបនេះ ជាមួយនឹងការជំរុញផលិតភាពនិងផលទទួលបានឱ្យកាន់តែខ្ពស់ គោលនយោបាយនិងយុទ្ធសាស្ត្រកំណើននៃ *ផយអជ* ត្រូវតែដោះស្រាយប្រភពដែលនាំឱ្យមានការកើនឡើងនៃវិសមភាព ដូចជា ការពង្រាយមិនស្មើនៃកាលានុវត្តភាពសេដ្ឋកិច្ចនិងសង្គម ការចែកទុនហិរញ្ញវត្ថុនិងមូលធនមនុស្សមិនត្រឹមត្រូវ និងការកើនឡើងគម្លាតក្នុងផ្នែកដទៃនៃជីវិត ។ ថាមពលសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចដែលបានមកទាំងពីសកម្មភាពកសិកម្មនិងពុំមែនកសិកម្ម ភាពចម្រុះមួយដែលចាំបាច់ក្នុងការគាំទ្រការកាត់បន្ថយភាពក្រីក្រក្នុងអំឡុងពេល *ផយអជ* និងពេលអនាគត ។

**១៦.** នៅក្នុងអំឡុងពេលនៃ *ផយអជ* កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនចំណូលកសិកម្ម ចាំបាច់ត្រូវធ្វើឡើងនៅក្នុងវិស័យសំខាន់ៗជាច្រើន ដូចជា បង្កើនផលិតភាពដំណាំធញ្ញជាតិ (ជាពិសេសស្រូវ) តាមរយៈការប្រើប្រាស់ប្រភេទពូជនិងធាតុចូលដទៃទៀតឱ្យកាន់តែប្រសើរឡើង ការគ្រប់គ្រងដីនិងសត្វចង្រៃ និងការត្រួតពិនិត្យទឹកឱ្យបានល្អប្រសើរ ជាពិសេស តាមរយៈសំណង់ធារាសាស្ត្រខ្នាតតូច ។ ការបង្កើនផលិតកម្មបសុសត្វ និងនេសាទក៏សំខាន់ដែរ ហើយបញ្ហានេះតម្រូវឱ្យមានការកែលម្អសេវាកម្មបច្ចេកទេស សម្រាប់សុខភាពសត្វ សម្រាប់ការស្រាវជ្រាវអំពីជលផលនេសាទ អភិរក្ស និងការគ្រប់គ្រង ។ ការគាំទ្រ សម្រាប់ការពង្រីកលទ្ធភាពទទួលបានសេវាពីស្ថាប័នហិរញ្ញវត្ថុជនបទជាផ្លូវការ នឹងមានសារៈសំខាន់សម្រាប់កសិករ និងសហគ្រិននៅតំបន់ជនបទនានាដើម្បីជួយឱ្យពួកគេពង្រីកកម្រិតប្រតិបត្តិការ និងទទួលបានប្រាក់ចំណេញច្រើននិងមានសកម្មភាពស្ថេរភាព ។ ដូចគ្នានេះដែរ ការកាត់បន្ថយបញ្ហាប្រឈមពីដីធ្លីនឹងទាមទារនូវការបង្កើនកិច្ចខិតខំប្រឹងប្រែងលើការផ្តល់កម្មសិទ្ធិដីធ្លី ដែលជាផ្នែកមួយនៃការបង្កើតនូវតម្លាភាព និងសុវត្ថិភាពទីផ្សារដីធ្លី ។

**១៧.** នៅកម្ពុជា សេដ្ឋកិច្ចជនបទមិនមែនកសិកម្មរួមមាន ពាណិជ្ជកម្ម ការដឹកជញ្ជូន ការកែច្នៃ កម្មន្តសាលខ្នាតតូច ការលក់រាយនិងសេវាកម្ម និងកត្តាប្រហាក់ប្រហែលផ្សេងទៀត គឺជាសក្តានុពលដ៏សំខាន់សម្រាប់កំណើនខ្លាំង និងការកាត់បន្ថយភាពក្រីក្រឆាប់រហ័ស ។ *ផយអជ* នឹងត្រូវកំណត់ដើមទុនសម្រាប់សក្តានុពលទាំង

---

[១] ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចបង្ហាញថា មេគុណហ្ស៊ីនីដែលត្រូវបានប៉ាន់ប្រមាណចំណាយប្រើប្រាស់ក្នុងម្នាក់សម្រាប់កម្ពុជានៅឆ្នាំ២០០៤ គឺ ០,៤០ ដោយមានកម្រិតខ្ពស់នៅតំបន់ទីប្រជុំជនដទៃទៀតគឺ ០,៤៤ នៅភ្នំពេញគឺ ០,៣៧ និងនៅតំបន់ជនបទគឺ ០,៣៤ បង្កើតនូវវិសមភាពនៅកម្ពុជាក្នុងចំណោមបណ្តាប្រទេសដែលមានមេគុណនេះខ្ពស់បំផុតនៅភូមិភាគអាស៊ីបូព៌ា-ប៉ាស៊ីហ្វិក។ សម្រាប់សំណាកគំរូប្រៀបធៀបតាមភូមិសាស្ត្រ មេគុណហ្ស៊ីនីបានកើនឡើងពី ០,៣៥ ក្នុងឆ្នាំ១៩៩៣-១៩៩៤ ទៅ ០,៤០ ក្នុងឆ្នាំ២០០៤ សម្រាប់កម្ពុជា (មានការធ្លាក់ចុះពី ០,៣៩ ទៅ ០,៣៧ នៅភ្នំពេញ និងនៅស្ទើរតែថេរក្នុងកម្រិត ០,៤៤ នៅតំបន់ទីប្រជុំជនដទៃទៀត ប៉ុន្តែកើនឡើងខ្លាំងពី ០,៣៥ ទៅ ០,៤០ នៅតំបន់ជនបទ)។ ទិន្នន័យវិសមភាពចំណូលមិនមាន គ្រប់គ្រាន់ទេ ប៉ុន្តែវិសមភាពចំណូលក៏មាន និន្នាការស្រដៀងគ្នាដែរ។

អស់នេះ ។ គោលនយោបាយនានាបានតម្រង់ទៅរកការបង្កើនទ្រព្យរូបវន្តរបស់អ្នកក្រីក្រ ដូចជា ដី ឥណទាន និង ហេដ្ឋារចនាសម្ព័ន្ធជនបទ នឹងក្លាយទៅជាផ្នែកទាំងមូលមួយនៃការជំរុញកំណើនដ៏ឆាប់រហ័សនៃ វិស័យជនបទ និងសេដ្ឋកិច្ចទាំងមូល ។

**១៨.** ដើម្បីធានានូវភាពជោគជ័យ និងនាំមកនូវលទ្ធផលយ៉ាងឆាប់រហ័យនិងប្រកបដោយប្រសិទ្ធភាព សកម្មភាព ជាក់លាក់នានានៃ *ផយអជ* នឹងត្រូវបានរៀបចំឡើង ដោយឈរលើអ្វីដែលត្រូវបានសម្រេចកន្លងមក និងតាមរយៈ ការផ្លាស់ប្តូរការផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្ត និងគោលនយោបាយទាំងអស់នេះនឹងធ្វើឱ្យផលចំណេញ មានការកើនឡើងដល់អ្នកក្រីក្រនៅជនបទ ។ សកម្មភាពទាំងនេះក៏នឹងធានានូវសកម្មភាពមួយឆាប់រហ័សជាង និងប្រកបដោយចីរភាពថែមទៀត ឆ្ពោះទៅរកសមភាព និងយុត្តិធម៌មិឱ្យកាន់តែប្រសើរឡើង ។

**១៩.** សមាសភាគដ៏សំខាន់របស់ *ផយអជ* នឹងធានាថា ជាមួយនឹងការអនុវត្តសេដ្ឋកិច្ចដែលមានកម្រិតខ្ពស់ជាង កំណើនត្រូវតែបានដល់អ្នកក្រីក្រ ហើយនិងបានពង្រីកកាលានុវត្តភាពរបស់ពួកគេ ។ ម៉្យាងវិញទៀត គោល នយោបាយនានានឹងត្រូវធានាថា អ្នកក្រីក្រមានធនធាន ពោលគឺមានការអប់រំ មានសុខភាពល្អ មានលទ្ធភាព ទទួលបានដើមទុននិងទីផ្សារ សម្លេងនិងសិទ្ធិអំណាច និងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការប្រើ-ប្រាស់ទុនលើការពង្រីកកាលានុវត្តភាពនៃកំណើន ។ ដូច្នេះ ការប្រែក្លាយយុទ្ធសាស្ត្រនៃ *ផយអជ* ទៅជាសកម្មភាព ជាក់ស្តែងនិងមានប្រសិទ្ធភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រ នឹងទាមទារឱ្យមានសេចក្តីសម្រេចចិត្ត និងប្រឌិត ញាណ មិនគ្រាន់តែពីរាជរដ្ឋាភិបាលកម្ពុជានិងអ្នកមានចំណែកពាក់ព័ន្ធក្នុងស្រុកដទៃទៀតប៉ុណ្ណោះទេ តែក៏មានពី ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសផងដែរ ។

# ឧបសម្ព័ន្ធ ៤
# បញ្ជីឯកសារយោង


សមិទ្ធផលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ការកែតម្រូវសម្រាប់ឆ្នាំ២០០៥ (សេចក្តីព្រាង) ក្រសួងផែនការ ខែកញ្ញា ឆ្នាំ២០០៥ ។

ស្ថិតិកសិកម្ម ឆ្នាំ២០០៤-២០០៥ ក្រសួងកសិកម្ម ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៥ ។

កម្ពុជា : ស្ថិតិព្រៃឈើ ឆ្នាំ២០០៤ (រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខែឧសភា ឆ្នាំ២០០៥) ។

របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ២០០៣ (ខែវិច្ឆិកា ឆ្នាំ២០០៣) ក្រសួងផែនការ ។

ការអង្កេតស្តីពីការវាយតម្លៃភាពក្រីក្រនៅកម្ពុជា ២០០៥ ។

កម្ពុជា : ការទទួលយកកាលានុវត្តភាពសកល : ការវាយតម្លៃបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រ កំណែទម្រង់ រៀបចំដោយក្រុមការងារធនាគារពិភពលោក ខែសីហា ឆ្នាំ២០០៤ ។

ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៣/០៤ ។

ក្របខ័ណ្ឌគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ខែតុលា ឆ្នាំ២០០៥ ។

ផែនការវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០០៤ រាជរដ្ឋាភិបាលកម្ពុជា ខែសីហា ឆ្នាំ២០០១ ។

ផែនការសកម្មភាពអភិបាលកិច្ច ឆ្នាំ២០០១ ។

ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណនិងតម្រូវការជំនួយអភិវឌ្ឍន៍ : គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (រៀបចំសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៤) ។

សេរីភាពទូលំទូលាយ : ឆ្ពោះទៅការអភិវឌ្ឍ សន្តិសុខ និងសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា : របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់មហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ ។

គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៤ ព្រឹត្តិប័ត្រលេខ ៩ វិទ្យាស្ថានជាតិស្ថិតិ ខែមិថុនា ឆ្នាំ២០០៥ ។

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ : ឆ្នាំ២០០៣-២០០៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច រាជរដ្ឋាភិបាលកម្ពុជា ខែធ្នូ ឆ្នាំ២០០២ ។

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ : របាយការណ៍វឌ្ឍនភាព (ការកែតម្រូវ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ : ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។

ចំណោលប្រជាជនកម្ពុជា ឆ្នាំ១៩៩៨-២០២០ : ការកែតម្រូវឡើងវិញលើកទីមួយ : វិជ្ជាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវពីប្រជាជន សកលវិទ្យាល័យភូមិន្ទភ្នំពេញ ខែមិថុនា ឆ្នាំ២០០៤ ។

ការវាយតម្លៃវិស័យឯកជនសម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ខែធ្នូ ឆ្នាំ២០០៣ ។

យុទ្ធសាស្ត្រចតុកោណ : សុន្ទរកថាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ ភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ (ផ្សព្វផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី) ។

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី២ (២០០១-២០០៥) ក្រសួងផែនការ ។

ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម រាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥ ។

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ : របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០៥ ។

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ : ការវិនិយោគរបស់កម្ពុជាក្នុងពេលអនាគត របាយការណ៍ប្រចាំ ឆ្នាំ២០០៤ ។

ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ឆ្នាំ២០០៦-២០១០ អ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាថ្ងៃទី៧ ខែមីនា ឆ្នាំ២០០៥ ។

រាជរដ្ឋាភិបាលកម្ពុជា : ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ១៧មិថុនា ២០០៥ ។

# ឧបសម្ព័ន្ធ ៥
## ពាក្យអក្សរកាត់

| | |
|---|---|
| កវស | : កម្មវិធីវិនិយោគសាធារណៈ |
| កព | : កម្លាំងពលកម្ម |
| គអសក | : គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| គម | : គីឡូម៉ែត្រ |
| គម$^{២}$ | : គីឡូម៉ែត្រការ៉េ |
| គវម | : គីឡូវ៉ាត់ម៉ោង |
| ផយអជ | : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផសស | : ផលិតផលក្នុងស្រុកសរុប |
| ផសអ១ | : ផែនការសកម្មភាពអភិបាលកិច្ច ១ |
| ផសអ២ | : ផែនការសកម្មភាពអភិបាលកិច្ច ២ |
| ពក | : ពលកម្ម |
| ហត | : ហិកតា |
| វជស | : វិទ្យាស្ថានជាតិស្ថិតិ |

# ឧបសម្ព័ន្ធ ៦

## ប្រកាស